ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ឆ្នាំង

# សៀវភៅជំនួយគ្រូ
# មត្តេយ្យសិក្សាសហគមន៍

## សម្រាប់ខែទី៣ និងទី៤



**ឧបត្ថម្ភដោយ**

អង្គការគាំពារកុមារខ្មែរ

特定非営利活動法人
幼い難民を考える会
CARING FOR YOUNG REFUGEES

**ខែឧសភា ឆ្នាំ២០២៤**

# សមាសភាពគណៈកម្មការ

## ១. គណៈកម្មការគ្រប់គ្រង និងដឹកនាំ

| | |
|---|---|
| ១. លោក ស៊ឹម ប្រិម | ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្តកំពង់ឆ្នាំង |
| ២. លោកស្រី ចាន់ ស្រី | នាយិកាអង្គការគាំពារកុមារខ្មែរ |
| ៣. លោកស្រី ស៊ុំ សុភ័ក្រ | អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ឆ្នាំង |
| ៤. លោកស្រី អ៊ុម សុផានី | ទីប្រឹក្សាបច្ចេកទេសផ្នែកអប់រំកុមារតូច អង្គការ CYK |

## ២. គណៈកម្មការនិពន្ធខ្លឹមសារ និងរៀបរៀង

| | |
|---|---|
| ១. លោកស្រី នៅ និមល | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង |
| ២. លោក ឯម ស៊ីនួន | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តពោធិ៍សាត់ |
| ៣. លោក អេត អូ | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តតាកែវ |
| ៤. លោក ហាម វណ្ណារិទ្ធ | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកណ្តាល |
| ៥. លោក ហែម ចន្ធី | អនុប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពត |
| ៦. លោកស្រី លន់ សត្យា | អនុប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង |
| ៧. លោកស្រី ប៊ួយ សំអឿន | មន្ត្រីការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង |
| ៨. លោកស្រី ប៉ាង ទីម៉េត | មន្ត្រីការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង |
| ៩. លោកស្រី តេង ផានី | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង |
| ១០. លោកស្រី ញ៉ែម សៀងថៃ | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង |
| ១១. លោក ជឿន វណ្ណៈ | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង |
| ១២. លោកស្រី មុំ ចរិយា | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង |
| ១៣. លោកស្រី ផូ សុម៉ាលី | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង |
| ១៤. លោកស្រី ខាត់ ផល្លាប | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង |
| ១៥. លោក ទេស សារិ | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុកជលគិរី ខេត្តកំពង់ឆ្នាំង |

## ៣. គណៈកម្មការកុំព្យូទ័រ និងរចនាបថ

| | |
|---|---|
| ១. លោក ហាម វណ្ណារិទ្ធ | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកណ្តាល |
| ២. លោក ហែម ចន្ធី | អនុប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពត |
| ៣. លោក ជឿន វណ្ណៈ | មន្ត្រីជំនាញអប់រំកុមារតូច នៃរដ្ឋបាលស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង |

## ៤. គណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់

| | |
|---|---|
| ១.លោកស្រី ស៊ុំ សុភ័ក្ត្រ | អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ឆ្នាំង |
| ២. លោកស្រី អ៊ុម សុផានី | ទីប្រឹក្សាបច្ចេកទេសផ្នែកអប់រំកុមារតូច អង្គការ CYK |
| ៣. លោកស្រី នៅ និមល | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង |
| ៤. លោក ឯម ស៊ីនួន | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តពោធិ៍សាត់ |
| ៥. លោក អេត អូ | ប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តតាកែវ |
| ៦. លោក ហែម ចន្ធី | អនុប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពត |
| ៧. លោកស្រី លន់ សត្យា | អនុប្រធានការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ឆ្នាំង |

# ការណែនាំអនុវត្តជារួម

សៀវភៅនេះមានគោលបំណង ឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់គ្រូមត្តេយ្យសិក្សាសហគមន៍ ដែលត្រូវមានឯកសារគ្រប់គ្រាន់និងសម្បូរបែបក្នុងការដឹកនាំសកម្មភាពបង្រៀន និងរៀនឱ្យមានលក្ខណៈជាថ្នាក់កុមារមេត្រី ស្របតាមគោលវិធីសាស្ត្រចម្រុះ។ ម្យ៉ាងទៀតសៀវភៅនេះបានជួយដល់គ្រូឱ្យមានភាពងាយស្រួលពីដំណើរការនៃការបង្រៀន ការរៀបចំកិច្ចតែងការបង្រៀនជាពិសេសការកំណត់វត្ថុបំណងទៅតាមមេរៀននីមួយៗ ការប្រើប្រាស់សម្ភារឧបទេសសម្រាប់គ្រូ និងកុមារ ការរៀបចំកុមារធ្វើសកម្មភាព និងយល់កាន់តែច្បាស់ពីខ្លឹមសារមេរៀន ទៅតាមមុខវិជ្ជា និងរបៀបលេងល្បែងទៅតាមមុខវិជ្ជាទាំង៥ ដែលគ្រូត្រូវផ្ទេរចំណេះដឹងឱ្យកុមារ ហើយកុមារមានលទ្ធភាពទទួលបានពេញលេញនូវសុខុមាលភាពរាងកាយ និងផ្លូវចិត្ត ស្មារតីសាមគ្គី មានភាពម្ចាស់ការ ការទទួលខុសត្រូវ សមត្ថភាពពិចារណា ការដោះស្រាយបញ្ហា មានស្មារតីស្រឡាញ់បរិស្ថាន និងការចូលរួមរបស់កុមារ ។

ចំពោះចំនួនថ្ងៃដែលបានរៀបចំនៅក្នុងសៀវភៅនេះគឺយកតាមចំនួនថ្ងៃក្នុងប្រតិទិនសិក្សាឆ្នាំ២០២៣-២០២៤ ដែលមានចំនួន ២០១ថ្ងៃត្រូវរៀន។ ប៉ុន្តែបើគ្រូត្រូវរៀបចំកម្មវិធីសិក្សាទៅតាមឆ្នាំនីមួយៗអាចជ្រើសរើសមេរៀនក្នុងសៀវភៅនេះយកទៅរៀបចំទៅតាមលំដាប់លំដោយក្នុងខែ នៃឆ្នាំ និងអាចបន្ថែមមេរៀន ឬប្តូរមេរៀនទៅតាមគំនិតច្នៃប្រឌិតរបស់គ្រូម្នាក់ៗ ធ្វើយ៉ាងណាឱ្យបានសម្រេចលទ្ធផលដូចគ្នា។

សៀវភៅនេះមិនមែនជាកិច្ចតែងតែងការបង្រៀនទេ ព្រោះសរសេរតែពីដំណើរការបង្រៀននៅជំហានទី៣ (មេរៀនថ្មី) ប៉ុណ្ណោះ ដូចនេះគ្រូនៅតែរក្សាការសរសេរកិច្ចតែងការបង្រៀន និងផែនការបង្រៀនប្រចាំថ្ងៃដដែល។

ចំពោះការប្រើប្រាស់សម្ភារឧបទេសសម្រាប់គ្រូ និងសម្រាប់កុមារ ការរៀបចំកុមារធ្វើសក្មភាព និងវិធីសាស្ត្រនៃការបង្រៀន ដែលបានកំណត់ទៅតាមមេរៀននីមួយៗក្នុងសៀវភៅនេះ ពេលយកទៅអនុវត្តគ្រូអាចបត់បែនបានតាមស្ថានភាពជាក់ស្តែងទៅតាមសាលានីមួយៗ និងតាមមេរៀននៃមុខវិជ្ជានីមួយៗ។

ចំពោះការធ្វើចលនាទៅតាមខ្លឹមសារនៃបទចម្រៀងក្នុងមុខវិជ្ជាចិត្តចលភាព និងការធ្វើកាយវិការ ទៅតាមខ្លឹមសារនៃបទចម្រៀងក្នុងមុខវិជ្ជាសិក្សាសង្គម គ្រូអាចបត់បែនទៅតាមគំនិតច្នៃប្រឌិតរបស់គ្រូម្នាក់ៗ គ្រាន់តែធ្វើយ៉ាងណាឱ្យស្របទៅតាមខ្លឹមសារនៃបទចម្រៀងនីមួយៗ។

បើករណីមេរៀននៅក្នុងមុខវិជ្ជាណាមួយ ពេលពង្រឹងចំណេះដឹង (ជំហាន៤) គ្រូនាំកុមារធ្វើសកម្មភាព ហើយត្រូវមានសម្ភារសម្រាប់ប្រើប្រាស់នោះគ្រូត្រូវបន្ថែមឈ្មោះនិងចំនួនសម្ភារទៅក្នុងចំណុចនៃការរៀបចំសម្ភារ។

សៀវភៅជំនួយគ្រូដែលក្រុមការងារបានរៀបចំនេះមិនទាន់បានល្អប្រសើរនៅឡើយ មានមេរៀនក្នុងមុខវិជ្ជាខ្លះ សរសេរមិនទាន់បានទៅតាមលំដាប់លំដោយពីដំណើរការបង្រៀននោះទេ ដោយសារពេលវេលាមិនសមស្របទៅតាមចំនួនមេរៀនក្នុងកម្មវិធីសិក្សា ដូច្នេះបើមានមេរៀនក្នុងមុខវិជ្ជាណាមួយដែលមើលទៅហើយពិបាកយល់នោះ គ្រូអាចកែតម្រូវបានឱ្យប្រសើរជាងនេះ ពិសេសឱ្យតែកុមារបានទទួលចំណេះដឹងស្របទៅតាមវត្ថុបំណងនៃមេរៀននីមួយៗ។

សៀវភៅជំនួយគ្រូមត្តេយ្យសិក្សាសហគមន៍ ដែលក្រុមការងារបានរៀបចំនេះមិនមែនជាបទពិសោធន៍ល្អសម្រាប់គ្រូយកធ្វើជាគំរូតាមនោះទេ គ្រាន់តែជាសៀវភៅយោងសម្រាប់គ្រូយកទៅបានជាគំនិតដោយគួបផ្សំទៅនឹងគំនិតច្នៃប្រឌិតរបស់គ្រូម្នាក់ៗ ដើម្បីឱ្យការងារបង្រៀន និងរៀនបានកាន់តែល្អប្រសើរបន្ថែមទៀត ជាពិសេសកុមារទាំងអស់រៀនមានគុណភាពដូចគ្នាៗ ដើម្បីជាមូលដ្ឋានគ្រឹះរឹងមាំ ត្រៀមខ្លួនចូលរៀននៅសាលាបឋមសិក្សាមិនទត្រួតថ្នាក់ និងមិនបោះបង់ការសិក្សាឡើយ។

# ឯកសារយោង

១. សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ទាំង៥មុខវិជ្ជា របស់នាយកដ្ឋានអប់រំកុមារតូច ឆ្នាំ២០២២
២. សៀវភៅការផលិតសម្ភារៈល្បែង សម្រាប់កុមារតូច របស់នាយកដ្ឋានអប់រំកុមារតូច ឆ្នាំ២០២៤
៣. សៀវភៅណែនាំ សម្រាប់គ្រូបង្រៀន មត្តេយ្យសិក្សា ស្ដីពីសម្ភារៈជំនួយបន្ថែម របស់ក្រសួងអប់រំ ឆ្នាំ២០១៨
៤. ឯកសារ សម្រាប់មត្តេយ្យសិក្សាសហគមន៍ របស់នាយកដ្ឋានអប់រំកុមារតូច ឆ្នាំ២០០៦
៥. កម្មវិធីសិក្សាលម្អិត សម្រាប់មត្តេយ្យសិក្សាសហគមន៍ របស់នាយកដ្ឋានអប់រំកុមារតូច ឆ្នាំ២០២១
៦. សៀវភៅរឿងនិទាន របស់អង្គការគាំពារកុមារខ្មែរ (CYK)
៧. ចម្រៀងកុមារមត្តេយ្យ ភាគ១ និងភាគ២ របស់អង្គការគាំពារកុមារខ្មែរ (CYK) បោះពុម្ពឆ្នាំ ២០១២
៨. សៀវភៅកំណាព្យ និងពាក្យបណ្ដៅសម្រាប់មត្តេយ្យសិក្សា បោះពុម្ពឆ្នាំ ២០០៧




រឿង
ឆ្នាំ ២០១០


រឿង
ឆ្នាំ ២០១០


រឿង
ទីណូនិង ស្បែកជើង
ឆ្នាំ ២០១០


រឿង
សម្លាញ់បីនាក់
ឆ្នាំ ២០១០


រឿង
ឆ្នាំ ២០១០


រឿង
ប្រាជ្ញាទីណូ
ឆ្នាំ ២០១០


កំណាព្យ
ឆ្នាំ ២០០៧


រឿង
ឆ្នាំ ២០១០


សួនកំណាព្យកុមារ


ឆ្នាំ ២០០៧



# កម្មវិធីសិក្សាខែទី៣

## កម្មវិធីសិក្សាប្រចាំខែទី៣ (២០ថ្ងៃ)

| ម៉ោង | ថ្ងៃទី១ សុក្រ | ថ្ងៃទី២ សៅរ៍ | ថ្ងៃទី៣ ចន្ទ | ថ្ងៃទី៤ អង្គារ | ថ្ងៃទី៥ ពុធ |
|---|---|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | | | |
| ៧៖១០-៧៖៤០ | ល្បែងចលនា៖<br>"លោតមឹកយន្តហោះ" | ហាត់ប្រាណតាមបទចម្រៀង៖<br>"កូនកំប្រុក" | ហាត់ប្រាណតាមរឿងនិទាន៖<br>"មេមាន់នាំកូនទៅរកចំណី" | ចលនាមូលដ្ឋាន៖ "លោត"<br>-លោតចូលកងឬរង្វង់<br>-លោតបត់បែនតាមខ្សែកាច់<br>-លោតរំលងឧបសគ្គ | ចលនាចរន្ត៖ "ដើរ រត់ លោត"<br>-ដើរខ្វែងជើងទៅមុខ<br>-រត់គ្រវីដៃទៅមុខ<br>-លោតជើងម្ខាងទៅមុខ<br>-រត់តិចៗទៅមុខ |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀង "ជម្រាបសួរ"<br>- ទម្លាប់ល្អ៖ លាងដៃ មុននិងក្រោយពេលញ៉ាំអាហារ | | | | |
| ៨៖១០-៨៖៤០ | ភាសាខ្មែរ<br>ល្បែង៖សង្កេតរូបគូសរង្វង់រូបដែលខុសគេ | បុរេគណិត<br>សម្គាល់៖ចំនួននិងលេខពី១ដល់៨ | ភាសាខ្មែរ<br>ល្បែង៖ចង់ទិព្វទាយសំឡេងសត្វ | វិទ្យាសាស្ត្រ<br>សង្កេត៖សម្ភារប្រើប្រាស់ក្នុងគ្រួសារ | បុរេគណិត<br>ល្បែង៖ផ្គុំចំនួនចំណុចទៅនឹងលេខពី១ដល់៨ |
| ៨៖៤០-៨៖៥០ | **ចេញលេង** | | | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>ល្បែង៖ធ្វើសកម្មភាពតាមមេដឹកនាំ | សិក្សាសង្គម<br>រឿងនិទាន៖កុមារីតូចនិងខ្លាឃ្មុំទាំងបី (និទាន) | សិក្សាសង្គម<br>ចម្រៀង៖មេអំបៅទៅសាលារៀន (ពេលទី២) | សិក្សាសង្គម<br>គំនូរ៖គូររូបចានបាយ | សិក្សាសង្គម<br>សកម្មភាពកសាង៖ ដេរតាមទម្រង់រូបផ្ទះ |
| ៩៖២០-៩៖៥០ | វិទ្យាសាស្ត្រ<br>ទស្សនាសង្កេត៖ដើមឈើហូបផ្លែ | ភាសាខ្មែរ<br>សម្គាល់តួអក្សរ៖ "ធ" | វិទ្យាសាស្ត្រ<br>សង្កេត៖គ្រួសារ | បុរេគណិត<br>ល្បែង៖គូសភ្ជាប់ពណ៌ដូចគ្នា | ភាសាខ្មែរ<br>សម្គាល់តួអក្សរ៖ "ដ" |
| ៩៖៥០-១០៖០០ | **ចេញលេង** | | | | |
| ១០៖១០-១០៖៣០ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | ចិត្តចលភាព<br>ល្បែង៖ ក្រងកៅស៊ូកងជាខ្សែ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ |

| ម៉ោង | ថ្ងៃទី៦ សុក្រ | ថ្ងៃទី៧ សៅរ៍ | ថ្ងៃទី៨ ចន្ទ | ថ្ងៃទី៩ អង្គារ | ថ្ងៃទី១០ ពុធ |
|---|---|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | | | |
| ៧៖១០-៧៖៤០ | ល្បែងចលនា៖<br>"លោតមឹកយន្តហោះ"<br>(រំលឹក) | ហាត់ប្រាណតាមបទចម្រៀង៖<br>"កូនកំប្រុក" (រំលឹក) | ហាត់ប្រាណតាមរឿងនិទាន៖<br>"មេមាន់នាំកូនទៅរកចំណី"<br>(រំលឹក) | ចលនាមូលដ្ឋាន៖ "លោត"<br>-លោតចូលកងឬរង្វង់<br>-លោតបត់បែនតាមខ្សែកាច់<br>-លោតរំលងឧបសគ្គ(រំលឹក) | ចលនាចរន្ត៖"ដើរ រត់ លោត"<br>-ដើរខ្វែងជើងទៅមុខ<br>-រត់គ្រវីដៃទៅមុខ<br>-លោតជើងម្ខាងទៅមុខ<br>-រត់តិចៗទៅមុខ(រំលឹក) |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀង "ជម្រាបសួរ"<br>- ទម្លាប់ល្អ៖ ត្រូវសម្អាតខ្លួនប្រាណ សម្លៀកបំពាក់និងសម្ភារៈប្រើប្រាស់ | | | | |
| ៨៖១០-៨៖៤០ | ភាសាខ្មែរ<br>ល្បែង៖ធ្វើតាមការណែនាំ<br>(សកម្មភាពមាន៣ជំណាក់) | បុរេគណិត<br>ល្បែង៖ពស់ព្រួយចិត្ត | ភាសាខ្មែរ<br>កំណាព្យ៖ពិធីបុណ្យអុំទូក | វិទ្យាសាស្ត្រ<br>សន្ទនា៖ មុខរបរសមាជិក<br>គ្រួសារកុមារម្នាក់ៗ (រំលឹក) | បុរេគណិត<br>ល្បែង៖ទៅផ្សារទិញសម្ភារផ្ទះ<br>បាយចំនួន ១ដល់៨ |
| ៨៖៤០-៨៖៥០ | **ចេញលេង** | | | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>ល្បែង៖ធ្វើសកម្មភាពតាមមេ<br>ដឹកនាំ (រំលឹក) | សិក្សាសង្គម<br>រឿងនិទាន៖គ្រួសារខ្ញុំ (និទាន) | សិក្សាសង្គម<br>ចម្រៀង៖ បណ្ដាំដែលអ្នកគ្រូ<br>ផ្ដាំទៅ (ពេលទី១) | សិក្សាសង្គម<br>គំនូរ៖គំនូសផ្ដាមស្លឹកឈើ | សិក្សាសង្គម<br>សកម្មភាពកសាង៖ បត់រូបផ្ទះ |
| ៩៖២០-៩៖៥០ | វិទ្យាសាស្ត្រ<br>ល្បែង៖ភ្លើងឆេះលើភ្នំសម្ភារផ្ទះ<br>បាយ | ភាសាខ្មែរ<br>សន្ទនា៖អ្វីៗដែលខ្ញុំចូលចិត្ត | វិទ្យាសាស្ត្រ<br>សន្ទនា៖មុខរបរសមាជិកគ្រួសារ<br>កុមារម្នាក់ៗ | បុរេគណិត<br>ល្បែង៖ពស់ព្រួយចិត្ត<br>(រំលឹក) | ភាសាខ្មែរ<br>ល្បែង៖ទះដៃតាមចំនួនព្យាង្គ<br>ដែលរៀនរួច |
| ៩៖៥០-១០៖០០ | **ចេញលេង** | | | | |
| ១០៖១០-១០៖៣០ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | ចិត្តចលភាព<br>ល្បែង៖ក្រងកៅស៊ូកងជាខ្សែ<br>(រំលឹក) | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ |

| ម៉ោង | ថ្ងៃទី១១ សុក្រ | ថ្ងៃទី១២ សៅរ៍ | ថ្ងៃទី១៣ ចន្ទ | ថ្ងៃទី១៤ អង្គារ | ថ្ងៃទី១៥ ពុធ |
|---|---|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | | | |
| ៧៖១០-៧៖៤០ | ល្បែងចលនា៖<br>"លោតមឹកផ្ទះ" | ហាត់ប្រាណតាមបទចម្រៀង៖<br>"បូតសណ្ដែក" | ហាត់ប្រាណតាមរឿងនិទាន៖<br>"ទន្សាយនាំកូនទៅរកចំណី" | ចលនាមូលដ្ឋាន៖ "លោត"<br>-លោតជើង២ទៅមុខ<br>-លោតជើង២ទៅឆ្វេងទៅស្ដាំ<br>-លោតកាន់វត្ថុទៅដាក់ក្នុងកន្ត្រក | ចលនាចរន្ត៖ "ដើរ រត់ លោត"<br>-ដើរជំហានវែងៗទៅមុខ<br>-រត់ទៅវាយវត្ថុចងព្យួរ<br>-លោតជើង២ទៅមុខ<br>-ដើរលឿនទៅមុខ |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមាននិងអវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀង "ជម្រាបសួរ"<br>- ទម្លាប់ល្អ៖ មករៀនឱ្យទៀងទាត់ពេលវេលារៀងរាល់ថ្ងៃ | | | | |
| ៨៖១០-៨៖៤០ | ភាសាខ្មែរ<br>កំណាព្យ៖ថៃសម្លៀកបំពាក់ | បុរេគណិត<br>ល្បែង៖ដូមីណូ | ភាសាខ្មែរ<br>ល្បែង៖ភ្លើងឆេះលើភ្នំតួអក្សរ "ឆ ជ ឈ" | វិទ្យាសាស្ត្រ<br>ល្បែង៖ថង់ទិព្វទាយវត្ថុជាតុដើមនៃសម្ភារផ្ទះបាយ | បុរេគណិត<br>ល្បែង៖ផ្គូផ្គងចំនួនរូបភាពទៅនឹងចំនួនចំណុចទៅនឹងលេខពី១ដល់៨ |
| ៨៖៤០-៨៖៥០ | **ចេញលេង** | | | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>ល្បែង៖អ្នកវាយកណ្ដឹង | សិក្សាសង្គម<br>រឿងនិទាន៖ស្វាកាន់ខ្មៅដៃ (និទាន) | សិក្សាសង្គម<br>ចម្រៀង៖ បណ្ដាំដែលអ្នកគ្រូផ្ដាំទៅ (ពេលទី២) | សិក្សាសង្គម<br>គំនូរ៖ផាត់ពណ៌រូបពែងទឹក | សិក្សាសង្គម<br>សកម្មភាពកសាង៖ រៀបវត្ថុតូចៗបិទលើរូបផ្ទាំង |
| ៩៖២០-៩៖៥០ | វិទ្យាសាស្ត្រ<br>សង្កេត៖ការវិវត្តរបស់មនុស្ស | ភាសាខ្មែរ<br>សម្គាល់តួអក្សរ៖ "ឈ" | វិទ្យាសាស្ត្រ<br>សង្កេត៖សម្ភារផ្ទះបាយ | បុរេគណិត<br>សម្គាល់៖ ឆ្វេង ស្ដាំ មុខ ក្រោយ | ភាសាខ្មែរ<br>កំណាព្យ៖ សាលា និងផ្ទះ |
| ៩៖៥០-១០៖០០ | **ចេញលេង** | | | | |
| ១០៖១០-១០៖៣០ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | ចិត្តចលភាព<br>ល្បែង៖ ផ្ទាត់កៅស៊ូគងគ្នា | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ |

| ម៉ោង | ថ្ងៃទី១៦ សុក្រ | ថ្ងៃទី១៧ សៅរ៍ | ថ្ងៃទី១៨ ចន្ទ | ថ្ងៃទី១៩ អង្គារ | ថ្ងៃទី២០ ពុធ |
|---|---|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | | | |
| ៧៖១០-៧៖៤០ | ល្បែងចលនា៖<br>"លោតគាបវត្ថុនឹងភ្លៅ<br>ប្រណាំងគ្នា" | ហាត់ប្រាណតាមបទចម្រៀង៖<br>"បូតសណ្ដែក" (រលឹក) | ហាត់ប្រាណតាមរឿងនិទាន៖<br>"ទន្សាយនាំកូនទៅរកចំណី"<br>(រលឹក) | ចលនាមូលដ្ឋាន៖ "លោត"<br>-លោតជើង១ទៅមុខ<br>-លោតជើង១បត់បែនតាមផ្លូវកាច់<br>-លោតកាន់វត្ថុទៅដាក់ក្នុង<br>កន្ត្រក | ចលនាចរន្ត៖ "ដើរ រត់ លោត"<br>-ដើរជំហានវែងៗទៅមុខ<br>-រត់ទៅវាយវត្ថុចងព្យួរ<br>-លោតជើង២ទៅមុខ<br>-ដើរលឿនទៅមុខ (រំលឹក) |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមាននិងអវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀង "ជម្រាបសួរ"<br>- ទម្លាប់ល្អ៖ សម្អាតធ្មេញ មុននិងក្រោយពេលគេង និងក្រោយពេលញ៉ាំបាយ | | | | |
| ៨៖១០-៨៖៤០ | ភាសាខ្មែរ<br>ល្បែង៖គូសភ្ជាប់តួអក្សរដែល<br>ដូចគ្នា | បុរេគណិត<br>ល្បែង៖បំពេញលេខតាមចម្លោះ<br>ពី១ដល់៨ | ភាសាខ្មែរ<br>ល្បែង៖រៀបតួអក្សរពី ក ដល់<br>ឈ តាមរូបផ្សេងៗ | វិទ្យាសាស្ត្រ<br>ពិសោធន៍៖ វត្ថុលិចនិងមិន<br>លិចក្នុងទឹក | បុរេគណិត<br>គំនូរ៖គូសតាមស្នាមចុចលេខ<br>៥ និង៦ |
| ៨៖៤០-៨៖៥០ | **ចេញលេង** | | | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>ល្បែង៖អ្នកវាយកណ្ដឹង (រំលឹក) | សិក្សាសង្គម<br>រឿងនិទាន៖បូណាជាកូនល្អ<br>(អំណាន) | សិក្សាសង្គម<br>ចម្រៀង៖ស្អាតជានិច្ច (ទះដៃ<br>តាមចង្វាក់ ៣,៣,៧) | សិក្សាសង្គម<br>គំនូរ៖គូរសេរី | សិក្សាសង្គម<br>សកម្មភាពកសាង៖ ដោត<br>បំពង់បឺតឆ្លាស់ពណ៌ |
| ៩៖២០-៩៖៥០ | វិទ្យាសាស្ត្រ<br>សង្កេត៖សម្ភារដំណេក | ភាសាខ្មែរ<br>កំណាព្យ៖ត្រូវហូបទឹកឆ្អិន | វិទ្យាសាស្ត្រ<br>ល្បែង៖ធ្វើចំណាត់ថ្នាក់សម្ភារ<br>ផ្ទះបាយនិងសម្ភារដំណេក | បុរេគណិត<br>ល្បែង៖បន្ថែមនិងបន្ថយ<br>ចំនួនពី១ដល់៥ (រំលឹក) | ភាសាខ្មែរ<br>គំនូរ៖គូតាមស្នាមចុចតួអក្សរ<br>ឃ ង ច |
| ៩៖៥០-១០៖០០ | **ចេញលេង** | | | | |
| ១០៖១០-១០៖៣០ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | ចិត្តចលភាព<br>ល្បែង៖ ផ្ទាត់កៅស៊ូគងគ្នា<br>(រំលឹក) | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ |

# ដំណើរការបង្រៀនតាមកម្មវិធី

# សកម្មភាពបង្រៀនប្រចាំខែ ទី៣
# ថ្ងៃទី១
ម៉ោងទី១ (រយៈពេល ៣០នាទី)
## មុខវិជ្ជា៖ ចិត្តចលភាព
## ល្បែងចលនា៖ លោតមឹកយន្តហោះ

**១. វត្ថុបំណង៖**
- កុមារប្រាប់ពីរបៀបលោតមឹកយន្តហោះ បានត្រឹមត្រូវ
- កុមារលោតមឹកយន្តហោះ បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន ប្រុងប្រយ័ត្នក្នុងការទប់លំនឹងខ្លួន និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** មេមឹកសម្រាប់កុមារម្នាក់ៗ

**៣. ការរៀបចំកុមារ៖** រៀបចំកុមារជា២ក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងដំហានទី៣)
- គ្រូឱ្យកុមារតម្រង់ជួរជា៣ជួរដែលមានសមាជិកស្មើៗគ្នា (២ក្រុម)
- បន្ទាប់មកគ្រូឱ្យកុមារធ្វើចលនាលោតជើងមួយទៅមុខទៅក្រោយចុះឡើង
- គ្រូឱ្យនាំកុមារសង្កេតមើលគំនូសមឹកយន្តហោះដែលគ្រូបានគូសរួច ហើយសួរកុមារថា តើកូនសង្កេតមើលគំនូសនេះទៅមើលថា មានរូបរាងដូចអ្វី? ចូរកូនទស្សន៍ទាយទៅមើលថាតើគ្រូនិងនាំកូនលេងអ្វីជាមួយគំនូសនេះ?តើកូនធ្លាប់លេងវាពីមុនមកដែរឬទេ?
- គ្រូទទួលចម្លើយកុមារដោយលើកទឹកចិត្ត
- បន្ទាប់មកគ្រូប្រាប់កុមារថាគំនូសនេះ ជាគំនូសមឹកយន្តហោះ ហើយគ្រូនឹងនាំកូនលេងនឹងគំនូសនេះ។
- គ្រូចាប់ផ្តើមណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេងដល់កុមារ ថា ដើម្បីលេងលើគំនូសនេះបាន កូនៗត្រូវមានមេមឹកម្នាក់មួយៗ(លើកមេមឹកបង្ហាញ) បន្ទាប់មកកូនៗនៅក្នុងក្រុមទាំង២ត្រូវ ប៉ាវ រកអ្នកឈ្នះដើម្បីមានសិទ្ធិលេងមុនគេ។ ការលេងគឺកូនត្រូវបោះមេមឹកចូលទៅក្នុងក្រឡាចក្រត្រង្គទី១ ដោយលោតជើងមួយរំលងត្រង់កន្លែងដែលមានមេមឹក គឺលោតចូលក្នុងក្រលាចក្រត្រង្គទី២ រហូតដល់ក្រឡាចក្រត្រង្គទី៨ និងលោតត្រឡប់មកវិញ ដើម្បីយកមេមឹករួចបោះបន្ត ក្នុងករណីកូនទី១ ធ្វើបានដល់លេខ៨ មានសិទ្ធិបូលយកផ្ទះមួយដោយគូសសញ្ញាសម្គាល់។ ករណីបោះរំលង ឬបោះមេជាប់ខ្សែ ឬចេញក្រៅខ្សែ ត្រូវផ្អាក រួចផ្ទូរសិទ្ធិដល់កូនដែលប៉ាវចាញ់លេងម្តង។ក្នុងករណីបើមានអ្នកបានផ្ទះហើយ ពេលអ្នកលោតបន្ត លោតទៅជាន់ផ្ទះគេ (ចាញ់ត្រូវប្តូរវេនវិញ)
- បន្ទាប់មកគ្រូឱ្យកុមារ១ឬ២នាក់ និយាយឡើងវិញ បើកុមារនិយាយមិនបានគ្រូនិយាយប្រាប់ម្តងទៀត
- គ្រូឱ្យកុមារស្ម័គ្រចិត្តម្នាក់ឡើងមកលេងសាកល្បងតាមរបៀបដែលបានណែនាំ
- បន្ទាប់មកគ្រូចាប់ផ្តើមឱ្យតំណាងក្រុមទាំង២ ប៉ាវដើម្បីរកអ្នកឈ្នះដើម្បីលេងមុខគេ
- គ្រូនាំកុមារលេង និងសម្របសម្រួលដំណើរការលេង ដោយផ្ទៀងផ្ទាត់ទៅនឹងលក្ខខណ្ឌដែលបានប្រាប់
- ប្រសិនបើមានពេលវេលា គ្រូអាចឱ្យសមាជិកក្នុងក្រុមនីមួយៗផ្លាស់ប្តូរគ្នាលេងបន្តឱ្យបានច្រើនគ្នា
- គ្រូលើកសរសើរចំពោះអ្នកដែលឈ្នះ ចំពោះអ្នកចាញ់គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ

- បន្ទាប់ពីលេងរួចហើយ គ្រូនាំកុមារធ្វើចលនាបេះផ្កាយកមកហិត ដោយដកដង្ហើមចូល ចេញវែងៗ៣ ទៅ ៤ដង (កូនៗស្រូបយកខ្យល់ដង្ហើមចូល ហើយស្រូបខ្យល់ដង្ហើមចេញមកក្រៅវែងៗដូចជាហិតយកក្លិនផ្កាដែលក្រអូប) រួចគ្រូសួរកុមារថា **តើផ្កាដែលកូនបានហិតនេះមានក្លិនក្រអូបឬទេ?**
- គ្រូទទួលចម្លើយកុមារ ដោយលើកសសើរ។
- គ្រូសួរម្តងមួយសំណួរឱ្យកុមារឆ្លើយ៖
  - តើមុននេះ កូនៗបានលេងល្បែងអ្វី?
  - តើកូនបានធ្វើចលនាអ្វីខ្លះ?
  - តើមុខវិជ្ជាដែលកូនរៀនថ្ងៃនេះជាមុខវិជ្ជាអ្វី?មេរៀនអ្វីដែរ?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់បញ្ជាក់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជា៖ចិត្តចលភាព មេរៀនល្បែងចលនា " លោតមឹកយន្តហោះ "
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ទាំងអស់គ្នា

❖ **បញ្ជាក់៖** គ្រូត្រូវគូសគំនូសមឹកយន្តហោះឱ្យបានរួចជាស្រេចមុនចាប់ផ្តើមដំណើរការបង្រៀន



ម៉ោងទី ២ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ សិក្សាសង្គម

# សកម្មភាពប្រចាំថ្ងៃ

## ១. វត្ថុបំណងៈ

- កុមារប្រាប់បានពីរបៀបគួរសមជាមួយគ្រូពេលចូលថ្នាក់រៀន ឈ្មោះថ្ងៃ ខែ ឆ្នាំដែលកំពុងរៀន វត្តមាន និងអវត្តមានកុមារប្រចាំថ្ងៃ ពេលវេលាដែលត្រូវលាងដៃ និងសកម្មភាពដែលត្រូវរៀនក្នុងមួយព្រឹកបានត្រឹមត្រូវ
- កុមារកំណត់បានពីឈ្មោះថ្ងៃ ខែ ឆ្នាំដែលកំពុងរៀនចំនួនវត្តមាន និងអវត្តមានកុមារប្រចាំថ្ងៃ ពេលវេលាដែលត្រូវលាងដៃ និងសកម្មភាពដែលត្រូវរៀនក្នុងមួយព្រឹកបានត្រឹមត្រូវ
- កុមារសប្បាយរីករាយ យកចិត្តទុកដាក់ក្នុងសង្កេតឈ្មោះ និងសហការជួយគ្នា។

## ២. សម្ភារបង្រៀនៈ

-បញ្ជីហៅឈ្មោះកុមារ.តារាងឈ្មោះថ្ងៃក្នុងសប្តាហ៍

-តារាងប្រតិទិនប្រចាំខែ.បញ្ជីឈ្មោះកុមារម្នាក់ៗ

-តារាងឈ្មោះខែទាំង១២ ( មករា...ធ្នូ )

-តារាងឈ្មោះឆ្នាំខ្មែរទាំង១២ ( ជូត...កុរ )

-តារាងខ្មៅដៃ ( បើមាន )

**៣.ការរៀបចំកុមារៈ** រៀបចកុមារអង្គុយជាអក្សរអ៊ុយ "U"

**៤.ដំណើរការបង្រៀនៈ**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារក្រោកឈរទាំងអស់គ្នាលើកដៃសំពះជម្រាបសួរគ្រូពេលគ្រូដើរចូលក្នុងថ្នាក់
- គ្រូឱ្យកុមារឈរទល់មុខគ្នា២ៗនាក់នៅតាមជួរ រួចច្រៀងបទ « ជម្រាបសួរ » ដើម្បីស្វាគមន៍មិត្តភក្តិ រួចឱ្យកុមារអង្គុយចុះវិញ
- គ្រូសួរកុមារថ្ងៃនេះថ្ងៃអ្វី ? ទីប៉ុន្មាន? ខែអ្វី? ឆ្នាំប៉ុន្មាន ? ឱ្យកុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ
- គ្រូឱ្យកុមារ១នាក់មកអូសតារាងឈ្មោះថ្ងៃ ប្រចាំសប្តាហ៍ឱ្យចំថ្ងៃកំពុងរៀននិងប្រាប់ឈ្មោះថ្ងៃនោះ
- គ្រូឱ្យកុមារមួយនាក់មកចង្អុលឈ្មោះថ្ងៃម្សិលមិញ និងថ្ងៃស្អែក ក្នុងតារាងឈ្មោះថ្ងៃប្រចាំសប្តាហ៍ រួចប្រាប់ឈ្មោះថ្ងៃនោះ
- គ្រូឱ្យកុមារ១នាក់ឡើងមកគូសរង្វង់លេខថ្ងៃកំពុងរៀន នៅក្នុងតារាងប្រតិទិន និងប្រាប់ឈ្មោះលេខនោះ និងគូសខ្វែងថ្ងៃម្សិលមិញ រួចប្រាប់ឈ្មោះថ្ងៃនោះ
- គ្រូសួរកុមារ ថ្ងៃនេះជាថ្ងៃអ្វី ? ទីប៉ុន្មាន ?ខែអ្វី ? ឆ្នាំប៉ុន្មាន? បើកុមារឆ្លើយមិនត្រូវគ្រូប្រាប់ រួចនាំកុមារថាតាម ( ក្រុម  ទាំងអស់គ្នា )
- គ្រូសរសេរឈ្មោះ ថ្ងៃ ខែ ឆ្នាំ លើក្តារខៀន រួចនាំកុមារអាន ដោយគ្រូជាអ្នកចង្អុលឱ្យចំតួអក្សរ( ជាក្រុម និងទាំងអស់គ្នា )
- គ្រូហៅនិងចែកបណ្ណឈ្មោះឱ្យកុមារម្នាក់ៗរួចប្រាប់កុមារ ( កូនយកបណ្ណឈ្មោះកូនម្នាក់ៗទៅពិនិត្យមើលដើម្បីចំណាំអក្សរ )
- គ្រូឱ្យកុមារម្នាក់ៗយកបណ្ណឈ្មោះរបស់ខ្លួនទៅដាក់ក្នុងតារាងឈ្មោះឱ្យកុមារតាមក្រុមនិងប្រាប់កុមារ

(កូនសង្កេតមើលពណ៌បណ្ណឈ្មោះដែលកាន់នៅដៃទៅផ្ទៀងពណ៌បណ្ណឈ្មោះនៅក្នុងតារាងឈ្មោះកុមារតាមក្រុម បន្ទាប់មកកូនផ្ទៀងឈ្មោះក្នុងបណ្ណដែលកាន់នៅដៃ ទៅនឹងឈ្មោះដែលមាននៅក្នុងតារាង

ឈ្មោះកុមារតាមក្រុម បើរាងដូចគ្នាកូនត្រូវស៊កចូលទៅក្នុងតារាងនោះដោយដាក់ស្របគ្នា

- ពេលកុមារយកឈ្មោះទៅដាក់ក្នុងតារាងឈ្មោះកុមារតាមក្រុមគ្រប់គ្នាហើយ គ្រូនាំកុមារផ្ទៀងផ្ទាត់ឈ្មោះកុមារម្ដងមួយក្រុមៗ បើមានកុមារណាដាក់ខុស ត្រូវនាំគ្នាជួយកែតម្រូវ
- គ្រូនាំកុមារផ្ទៀផ្ទាត់វត្តមាន និង អវត្តមានតាមក្រុមនីមួយៗដោយបញ្ជាក់ពីចំនួនវត្តមាន និង អវត្តមាន។ បើមានកុមារអវត្តមានត្រូវផ្ទៀងផ្ទាត់បណ្ណឈ្មោះកុមារដែលនៅសល់ទៅនឹងបណ្ណឈ្មោះនៅក្នុងតារាងឈ្មោះកុមារតាមក្រុម
- គ្រូបង្ហាញពីឈ្មោះកុមារអវត្តមាន ដោយប្រាប់ឈ្មោះ និងប្រាប់ពីមូលហេតុ។ បើករណីកុមារឈប់គ្មានច្បាប់ទេ គ្រូត្រូវអប់រំណែនាំដោយបញ្ជាក់ប្រាប់កុមារ ( បើសិនជាកូនឈប់ត្រូវសុំអនុញ្ញាតច្បាប់ពីគ្រូ មិនត្រូវឈប់ឥតដំណឹងទេ )គ្រូនាំកុមាររាប់ចំនួនកុមារវត្តមាន និង អវត្តមាន តាមក្រុម និងមួយថ្នាក់
- គ្រូចុះអវត្តមានកុមារនៅខាងលើជ្រុងក្ដារខៀន និងចុះក្នុងសៀវភៅបញ្ជីហៅឈ្មោះ
- គ្រូឱ្យកុមារម្នាក់ឡើងមកយកកូនកាសអាកាសធាតុ និងកូនកាសសម្គាល់ថ្ងៃឈប់ និងថ្ងៃរៀនដាក់ក្នុងតារាងខ្មៅដៃ ។ នាំកុមារផ្ទៀងផ្ទាត់ គ្រូឱ្យកុមារម្នាក់ឡើងមកយកកូនកាសអាកាសធាតុ និងកូនកាសសម្គាល់ថ្ងៃឈប់ និងថ្ងៃរៀនដាក់ក្នុងតារាងខ្មៅដៃ រួច នាំកុមារផ្ទៀងផ្ទាត់ ទៅនឹងអាកាសធាតុជាក់ស្ដែង និងរូបសម្គាល់ថ្ងៃរៀន និងថ្ងៃឈប់ បើកុមារដាក់ខុសត្រូវជួយកែតម្រូវ ( បើសិនគ្រូមានតារាងខ្មៅដៃទើបអនុវត្ត )
- គ្រូនាំកុមាររាប់ឈ្មោះខែទាំង១២ ( មករា...ធ្នូ)និងឈ្មោះឆ្នាំខ្មែរទាំង១២ ( ជូត...កុរ ) ដោយគ្រូជាអ្នកចង្អុល។

✱ ទម្លាប់ល្អ៖ លាងដៃមុននឹងក្រោយពេលញុំាអាហារ៖

- គ្រូប្រើតុក្កតាដើម្បីសំដែង៖ សួស្ដី! មិត្តភក្ដិទាំងអស់គ្នា ថ្ងៃនេះខ្ញុំចង់នាំមិត្តភក្ដិទាំងអស់គ្នាទៅញុំាបាយនៅផ្ទះខ្ញុំ។ តើមិត្តភក្ដិនាំគ្នាទៅចូលរួមជាមួយខ្ញុំដែរឬទេ ? ពេលមុនញុំាបាយតើមិត្តភក្ដិទាំងអស់គ្នាធ្វើអ្វីខ្លះ? ចុះពេលញុំាបាយរួចហើយមិត្តភក្ដិទាំងអស់គ្នាត្រូវធ្វើអ្វីខ្លះទៀត?
- ពេលគ្រូសំដែងតុក្កតាចប់ គ្រូណែនាំកុមារថា៖ មុនពេលញុំាបាយកូនៗត្រូវនាំគ្នាលាងដៃឱ្យស្អាតជាមួយនឹងសាប៊ូ ក្រោយពេលញុំាបាយរួចកូនក៏ត្រូវលាងដៃឱ្យស្អាតជាមួយនឹងសាប៊ូដែរ។
- គ្រូសួរកុមារ៖ តើមុនពេលញុំាបាយកូនៗត្រូវធ្វើដូចម្ដេច? ហើយពេលញុំាបាយរួចកូនត្រូវធ្វើដូចម្ដេច?

✱ គ្រូប្រាប់ពីសកម្មភាពដែលត្រូវរៀនក្នុងមួយព្រឹក រួចឱ្យកុមារថាតាម( ជាក្រុម រួចទាំងអស់គ្នា )។

ម៉ោងទី៣ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ ភាសាខ្មែរ

## ល្បែង៖ សង្កេតរួចគូសរង្វង់រូបដែលខុសគេ

**១. វត្ថុបំណង៖**

-កុមារប្រាប់ឈ្មោះរូបភាពដែលខុសគេ បានត្រឹមត្រូវ

-កុមារគូសរង្វង់លើរូបភាពដែលខុសគេ បានត្រឹមត្រូវ

-កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** ផ្ទាំងរូបភាពអ៊ុតរួច ហ្វឺតសរសេរក្តារខៀន

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជាអក្សរអ៊ុយ "ប" និងចែកកុមារជាក្រុមតូចៗឱ្យអង្គុយជារង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូរៀបចំសម្ភារដាក់លើតុរួចជាស្រេច បន្ទាប់មកសួរកុមារថា តើសម្ភារទាំងនេះមានអ្វីខ្លះ?
- គ្រូបង្ហាញផ្ទាំងរូបភាពនោះ រួចឱ្យកុមារប្រាប់ឈ្មោះ
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូមានរូបភាព១ផ្ទាំងនេះ សម្រាប់ឱ្យកូនអនុវត្តតាមក្រុម ហើយក្នុងមួយក្រុមៗកូនត្រូវបានផ្ទាំងរូបភាពនេះ១ផ្ទាំង និងប៊ិកហ្វឺតមួយដើម
  - ពេលក្រុមកូនបានផ្ទាំងរូបភាពនេះហើយ កូនត្រូវចែកគ្នាមើល ដើម្បីរករូបភាពខុសគេ ហើយកុំដណ្តើមគ្នា
  - នៅពេលកូនសង្កេតរួចហើយ កូនត្រូវឱ្យមិត្តភក្តិណាម្នាក់ក្នុងក្រុម យកប៊ិកហ្វឺតទៅគូសរង្វង់ជុំវិញរូបភាពណាដែលខុសគេ
  - ពេលក្រុមកូនណាធ្វើរួចហើយ ត្រូវយកទៅបិទលើក្តារខៀននៅកន្លែងដែលគ្រូកំណត់ឱ្យ ហើយយកប៊ិកហ្វឺតទៅទុកនៅតុគ្រូវិញ រួចកូននាំគ្នាទៅអង្គុយនៅក្រុមធំវិញ
  - បើក្រុមណាគូសមិនត្រឹមត្រូវទេនោះ គឺជាអ្នកចាញ់ និងឱ្យមិត្តភក្តិជួយកែតម្រូវ
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមដំណាក់កាលនីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- រៀបចំកុមារជា៣ក្រុម អង្គុយទៅតាមទីកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងមកយកសម្ភារដែលគ្រូបានរៀបចំរួច ទៅអនុវត្តតាមក្រុម
- គ្រូដើរសម្របសម្រួលទៅតាមក្រុមនីមួយៗ
- បន្ទាប់ពីកុមារអនុវត្តតាមក្រុមរួច គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលម្តងមួយក្រុមៗ ដោយឱ្យតំណាងក្រុមឡើងមកប្រាប់ពីអ្វីដែលពួកគេបានធ្វើ
- គ្រូលើកសរសើរក្រុមណាដែលធ្វើបានត្រឹមត្រូវ និងលើកទឹកចិត្តក្រុមដែលមិនទាន់ធ្វើបានត្រឹមត្រូវ
- **គ្រូសួរកុមារ៖**
  - កូនៗទាំងអស់គ្នាសប្បាយទេ?**តើមុននេះកូនៗបានលេងល្បែងអ្វី**?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - **តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ **ថ្ងៃនេះយើងរៀនមុខវិជ្ជា ភាសាខ្មែរ អំពីល្បែង មេរៀន** " សង្កេតរួចគូសរង្វង់រូបដែលខុសគេ"

**-គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនណា

ឆ្លើយដូច ចម្លើយ របស់គ្រូឬទេ ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បាន ត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)

- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## ល្បែង៖ ធ្វើសកម្មភាពតាមមេដឹកនាំ

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីឈ្មោះមិត្តភក្តិដែលជាមេដឹកនាំ បានត្រឹមត្រូវ
- កុមារបង្ហាញឈ្មោះមិត្តភក្តិដែលជាមេដឹកនាំ បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន និងមានភាពសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** អង្គុយជារាងអក្សរអ៊ុយ "ប" ជារង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំណួរ តើកូនៗធ្លាប់ធ្វើជាមេដឹកនាំដែរឬទេ? ដូចច្នេះកូនៗទាយមើលថាថ្ងៃនេះគ្រូបង្រៀនកូនពីមុខវិជ្ជាអ្វី? អំពីអ្វី? ឱ្យកុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ ។ ពេលកុមារប្រាប់រួច គ្រូត្រូវសរុបនូវអ្វីដែលពួកគេបានប្រាប់
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះគ្រូបង្រៀនមុខវិជ្ជា សិក្សាសង្គម អំពីល្បែង ធ្វើសកម្មភាពតាមមេដឹកនាំ
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងការនិយាយប្រាប់របស់គ្រូ ដោយសួរកុមារថា តើអម្បាញ់មិញមានកូនណាទាយត្រូវឬទេ? បើមានមិត្តភក្តិយើងទាយត្រូវដូចនេះកូនៗនាំគ្នាទះដៃសរសើរមិត្តភក្តិយើងទាំងអស់គ្នា។ ឯកូនដែលទាយមិនទាន់ត្រូវ កូនក៏ឆ្លាតដែរ ព្រោះកូនបានឆ្លើយនឹងសំណួរ តែថ្ងៃក្រោយកូនត្រូវគិតបន្ថែម ហើយចាំឆ្លើយសំណួរគ្រូទៀតណា !
- គ្រូនាំកុមារអានពីមុខវិជ្ជា និងចំណងជើងមេរៀន (ជាក្រុម និងទាំងអស់គ្នា)
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនលេងទាំងអស់គ្នាជាមួយគ្រូ ហើយកូននាំគ្នាអង្គុយជារង្វង់
  - គ្រូឱ្យកូនណាម្នាក់ស្ម័គ្រចិត្តចេញទៅក្រៅថ្នាក់ មិនឱ្យមើលឃើញកូនៗក្នុងថ្នាក់ទេ
  - កូនៗដែលនៅអង្គុយជារង្វង់ក្នុងថ្នាក់ត្រូវជ្រើសរើសកូនណាម្នាក់ឱ្យដឹកនាំមិត្តភក្តិធ្វើសកម្មភាពនានាតាមចិត្តរបស់កូន (ឧទាហរណ៍ សិតសក់ធ្វើកាយវិការដូចសត្វស្វា ដូចអ្នកកូតទ្រ នាំច្រៀងជាដើម )
  - កូនៗទាំងអស់ ត្រូវមើលមកកូនដែលជាអ្នកដឹកនាំធ្វើសកម្មភាព បើអ្នកដឹកនាំធ្វើសកម្មភាពអ្វី កូនៗទាំងអស់ធ្វើតាមទាំងអស់គ្នា។ ពេលកូននៅក្រៅថ្នាក់ចូលមកក្នុងថ្នាក់ពួកកូននៅតែធ្វើដដែល មិនត្រូវឈប់ធ្វើទេ
  - គ្រូឱ្យកូនដែលចេញទៅក្រៅថ្នាក់ចូលមកក្នុងថ្នាក់វិញ រួចឈរសម្លឹងមើលសកម្មភាពដែលមិត្តភក្តិកំពុងធ្វើ រួចទាយរកអ្នកដែលដឹកនាំគេធ្វើ បើកូនទាយមិនត្រូវទេ កូននៅតែអ្នកចេញក្រៅថ្នាក់ដដែលអាចបន្តទាយរកអ្នកដែលដឹកនាំគេធ្វើបានពីរ ឬបីដងទៀត បើនៅតែទាយមិនត្រូវទេ គឺប្តូរអ្នកផ្សេង

វិញម្តង ប៉ុន្តែបើកូនចេញក្រៅថ្នាក់ទាយត្រូវនោះ អ្នកដែលដឹកនាំគេធ្វើត្រូវចេញទៅក្រៅថ្នាក់វិញម្តង អ្នកចេញទៅក្រៅថ្នាក់មកអង្គុយក្នុងថ្នាក់វិញម្តង ។ រួចជ្រើសរើសអ្នកដឹកនាំធ្វើថ្មីទៀត និងធ្វើដូចអ្នកមុនដែរ ។

- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្តងទៀត)
- គ្រូរៀបចំកុមារលេងទាំងអស់គ្នា ដោយឱ្យកុមារទៅអង្គុយជារង្វង់នៅកន្លែងដែលគ្រូបានរៀបចំ
- គ្រូនាំកុមារលេងតាមអ្វីដែលគ្រូបានណែនាំ
- គ្រូ និងកុមារផ្ទៀងផ្ទាត់លទ្ធផល (បើកុមារធ្វើបានគ្រូលើកសរសើរ តែបើកុមារធ្វើមិនបានគ្រូត្រូវលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត )
- គ្រូនាំកុមារលេង និងផ្ទៀងផ្ទាត់របៀបនេះ រហូតចប់ម៉ោង

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ វិទ្យាសាស្ត្រ

## ទស្សនាសង្កេតៈ ដើមឈើហូបផ្លែ

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីឈ្មោះដើមឈើហូបផ្លែ និងផលប្រយោជន៍ បានត្រឹមត្រូវ។
- កុមារបង្ហាញពី សារសំខាន់នៃ ដើមឈើ ហូបផ្លែ បានត្រឹមត្រូវ។
- កុមារយកចិត្តទុកដាក់មានបម្រុងប្រយ័ត្នទម្លាប់ញុំាផ្លែឈើហូបផ្លែ សហការ សប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ** គ្រូអាចបត់បែនបានទៅតាមមូលដ្ឋាន

**៣. ការរៀបចំកុមារៈ** អង្គុយជារាងអក្សរអ៊ុយ "ប"ជាជួរជាក្រុមតូចៗ

**៤. ដំណើរការបង្រៀនៈ**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំណួរៈ
  - ថ្ងៃនេះមេឃស្រឡះល្អ តើកូនទាំងអស់គ្នាចង់ដើរលេងឬទេ?តើកូនចង់ទៅលេងនៅឯណា?
  - តើកូនធ្លាប់ឃើញម្តាយកូនទិញផ្លែឈើអ្វីខ្លះ រាល់ៗថ្ងៃឱ្យកូនញុំា?
  - តើផ្លែឈើ ទាំងនោះគេដាំនៅឯណា?
  - តើកូនចង់ទៅមើលដើមឈើហូបផ្លែជាមួយគ្រូឬទេ?បើកូនចង់ទៅមើលដើមឈើហូបផ្លែកូនត្រូវនាំគ្នាស្តាប់គ្រូ

-គ្រូណែនាំកុមារមុនពេលចេញដំណើរៈពេលដើរនៅតាមផ្លូវកូនៗទាំងអស់គ្នាដើរខាងស្តាំដៃ ដើរជិតៗគ្រូ កុំដើរលឿនទៅចោលគ្រូ កុំប្រទ្បែងគ្នា លេងនៅតាមផ្លូវ។ ហើយកូនមើលនៅតាមផ្លូវបើមានអ្វីៗកូនជួយប្រាប់គ្រូនិងប្រាប់មិត្តភក្តិយើងទៅវិញ ទៅមក។ បើកូនឃើញហើយមិនស្គាល់ទេនោះកូនត្រូវសួរគ្រូៈពេលដើរទៅដល់ដើមឈើហូបផ្លែកូនៗត្រូវនាំគ្នាជម្រាបសួរម្ចាស់ចំការហើយមិនត្រូវរញ៉េរញ៉ៃពេញចំការគាត់ទេ កូនត្រូវនាំគ្នាដើរមើលឱ្យមានសណ្តាប់ធ្នាប់ទើបជាកូនល្អ ។

- គ្រូឱ្យកុមារមកជុំគ្នារួចហើយក៏ធ្វើដំណើរចេញទៅលេងចំការដើមឈើហូបផ្លែ
- ពេលដើរតាមផ្លូវគ្រូត្រូវស្តាប់កុមារជជែកគ្នា ហើយបើគេនិយាយខុសគ្រូកែលម្អភ្លាមប៉ុន្តែបើកុមារស្ងាត់ស្ងៀមមិននិយាយអ្វីសោះគ្រូត្រូវបំផុសសំណួរ(តើនៅតាមដងផ្លូវកូនឃើញអ្វីខ្លះ?)

-ពេលជិតទៅដល់ចំការដើមឈើហូបផ្លែ គ្រូឱ្យកុមារឈប់ទាំងអស់គ្នាបន្តិចរួចប្រាប់កុមារឱ្យមើលទៅខាងមុខ តើឃើញអ្វីខ្លះ? ឱ្យកុមារប៉ាន់ស្មានទាយ តាមគំនិតរបស់កុមារម្នាក់ៗ ដោយមិនគិតពីចម្លើយត្រូវឬខុសឡើយ។
- គ្រូឱ្យកុមារធ្វើដំណើរបន្តទៀតដើម្បីឱ្យឆាប់ទៅដល់ចំការដើមឈើហូបផ្លែ
- ពេលទៅដល់ចំការដើមឈើហូបផ្លែគ្រូនាំកុមារទាំងអស់ជម្រាបសួរម្ចាស់ចំការរួចឱ្យកុមារប្រាប់ម្ចាស់ចំការ (ពួកខ្ញុំមកពីសាលាមត្តេយ្យសិក្សា...)និងសួរម្ចាស់ចំការ(តើមីងឈ្មោះអ្វីដែរ?ពួកខ្ញុំអាចសុំមើលចំការផ្លែឈើមីងបានដែរឬទេ?)ឱ្យកុមារអរគុណម្ចាស់ចំការ។
- គ្រូនាំកុមារដើរចូលទៅក្នុងចំការនិងប្រាប់កុមារឱ្យនាំគ្នាដើរមើលជុំវិញចំការផ្លែឈើមីងតើកូនឃើញមានដើមអ្វីខ្លះ?
- គ្រូប្រាប់កុមារពេលកូនដើរមើលដើមឈើហូបផ្លែមីង កូនមិនត្រូវបេះបោចឬដើរជាន់ដំណាំមីងទេ
- ពេលកុមារមើលជុំវិញចំការរួចហើយ ក៏ឱ្យកុមារមកជុំគ្នាហើយជួបជាមួយម្ចាស់ចំការដើម្បីឱ្យកុមារសួរគាត់ពីរបៀបដាំ និងការថែទាំដើមឈើហូបផ្លែទាំងអស់នោះ។
- ពេលកុមារមិនសូវចេះសួរគ្រូត្រូវបំផុសគំនិតឱ្យកុមារសួរទៅម្ចាស់ចំការ (ឧទាហរណ៍ៈតើដើមឈើហូបផ្លែទាំងអស់នេះឈ្មោះអ្វី?តើដាំរបៀបដូចម្តេច?ដាំប៉ុន្មានឆ្នាំទើបបានទទួលផល? តើមីងថែទាំដើមឈើហូបផ្លែ ដូចម្តេចទើបដំណាំល្អនិងមិនងាប់ ?តើមីងយកផ្លែឈើទៅលក់នៅឯណា?លក់ក្នុងមួយខែបានប៉ុន្មានរៀល?ហេតុអ្វីបានចាំបាច់ធ្វើរបងព័ទ្ធជុំវិញ?...)
- ពេលកុមារសួរម្ចាស់ចំការរួចហើយគ្រូឱ្យកុមារចូលរួមធ្វើការងារផ្ទាល់ជាមួយម្ចាស់ចំការដូចជាដកស្មៅជ្រោយដីដាក់ដី ស្រោចទឹកជាដើម។ បន្ទាប់មកក៏នាំកុមារលាងដៃឱ្យស្អាត។
- គ្រូនាំកុមារជម្រាបលាម្ចាស់ចំការដើម្បីធ្វើដំណើរមកសាលារៀនវិញ។
- ពេលមកដល់សាលាវិញគ្រូឱ្យកុមារអង្គុយសម្រាកឱ្យបាត់ហត់បន្តិចសិន
- គ្រូបំផុសសំណួរៈតើអម្បាញ់មិញកូននាំគ្នាទៅដើរលេងនៅឯណា?កូនឃើញអ្វីខ្លះ?ដូច្នេះកូនជួយប្រាប់គ្រូថាតើអម្បាញ់មិញកូនរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី?
- គ្រូប្រាប់កុមារៈថ្ងៃនេះយើងរៀនមុខវិជ្ជា វិទ្យាសាស្ត្រ អំពីទស្សនាសង្កេត "ដើមឈើហូបផ្លែ" តើមុននេះមានកូនណាទាយត្រូវឬទេ?បើអញ្ចឹងកូននាំគ្នាទះដៃទាំងអស់គ្នាដើម្បីសរសើរមិត្តភក្តិយើងដែលបានទាយត្រូវ។
- ចំពោះកូនដែលទាយមិនត្រូវកុំអន់ចិត្តអី ព្រោះកូនក្លាហាន ហ៊ានឆ្លើយសំណួរគ្រូបាន ។
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន(ជាក្រុមនិងទាំងអស់គ្នា)។

### ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

**✱ ល្បែងសេរី**

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីរបៀបលេងល្បែងទៅតាមចំណង់ចិត្តរបស់ពួកគេបានត្រឹមត្រូវ
- កុមារជ្រើសរើសល្បែងលេងទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេបានត្រឹមត្រូវ
- កុមារ សប្បាយរីករាយ សហការគ្នាក្នុងការលេងមានចិត្តអំណត់។

**២. ការរៀបចំសម្ភារៈ** សម្ភារមាននៅតាមជ្រុងថ្នាក់រៀននិងក្រៅថ្នាក់

**៣. ការរៀបចំកុមារៈ**

- កុមារអង្គុយជាអក្សរអ៊ុយ "U" និងក្រុមតូច
- កុមារអង្គុយទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេម្នាក់ៗក្នុងថ្នាក់និងក្រៅថ្នាក់

**៤.ដំណើរការបង្រៀនៈ**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរកុមារៈ កូនទាំងអស់គ្នាចង់លេងល្បែងឬទេ? បើកូនចង់លេង តើកូននាំគ្នាលេងល្បែងអ្វីខ្លះ? ដូច្នេះគ្រូនិង ឱ្យកូនទាំងអស់គ្នាលេងទៅតាមចំណង់ចំណូលចិត្តរបស់កូន។
- គ្រូប្រាប់កុមារៈ ថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជា សិក្សាសង្គម អំពីល្បែងសេរី
- គ្រូឱ្យកុមារអានមុខវិជ្ជា និងចំណងជើង មេរៀនជាក្រុមនិងទាំងអងស់គ្នា
- គ្រូបង្ហាញសម្ភារល្បែងដែលមាននៅតាមជ្រុងឱ្យកុមារដឹងពីទីកន្លែងដែលកុមារត្រូវនាំគ្នាយកមកលេង
- គ្រូណែនាំកុមារមុនពេលលេងៈ
  - គ្រូឱ្យកុមារទាំងអស់គ្នាយកសម្ភារដែលមាននៅក្នុងថ្នាក់រៀនលេងទៅតាមចំណង់ចំណូលចិត្តរបស់កូនម្នាក់ៗ ឬកូនអាចទៅលេងល្បែងនៅក្រៅថ្នាក់ក៏បាន
  - ពេលកូនយកសម្ភារទាំងនោះមកលេង កូនត្រូវចេះថែរក្សាសម្ភារទាំងនោះ ហើយពេលឈប់លេង កូនត្រូវមើលសម្ភារនោះឱ្យបានគ្រប់ចំនួនមិនឱ្យបាត់បង់ ទើបយកទៅទុកឱ្យមានសណ្តាប់ធ្នាប់នៅកន្លែងដើមវិញ
  - ពេលលេងកូនអាចលេងម្នាក់ឯងក៏បាន កូនអាចលេងជាមួយមិត្តភក្តិក៏បាន អាស្រ័យទៅតាមចិត្តរបស់កូន។បើកូនលេងជាមួយមិត្តភក្តិ កូនត្រូវចេះចែកគ្នាលេងកុំដណ្តើមគ្នា កុំស្រែកឡូឡា ទើបជាកូនល្អ
  - ចំពោះទីកន្លែងដែលពួកកូនត្រូវលេងនោះអាចលេងនៅក្នុងថ្នាក់ក៏បាន លេងនៅក្រៅថ្នាក់ក៏បាន ស្រេចតែ ចិត្តពួកកូន។ បើកូនណាចង់លេងស្គរ ឬគោះកំប៉ុង កូនត្រូវលេងឱ្យឆ្ងាយពីមិត្តភក្តិ កុំឱ្យរំខានមិត្តភក្តិ
  - បើមានកូនណាមិនសូវចេះលេង ឬមិនចូលលេងនឹងគេនោះ កូនៗត្រូវជួយប្រាប់មិត្តភក្តិនិងនាំមិត្តភក្តិលេងផង
  - ពេលកូនឈប់លេង កូនត្រូវនាំគ្នាយកសម្ភារទៅទុកកន្លែងដើមវិញ រួចនាំគ្នាមកអង្គុយនៅក្រុមធំវិញ
  - គ្រូឱ្យកុមារស្ម័គ្រចិត្តមួយនាក់ និយាយពីអ្វីដែលគ្រូបានប្រាប់។ គ្រូត្រូវបំពេញបន្ថែមនូវអ្វីដែលកុមារនិយាយមិនបានពេញលេញ
- គ្រូឱ្យកុមារលើកកៅអីទុកទៅខាង ម្តងមួយក្រុមៗរួចនាំគ្នាទៅយកសម្ភារមកលេង
- គ្រូឱ្យកុមារលេងតាមចំណង់ចំណូលចិត្តរបស់ពួកគេ
- គ្រូដើរសម្របសម្រួល កុមារលេងដើម្បីកែតម្រូវកុមារលេងខុស និងជួយកុមារណាដែលមិនទាន់ចេះលេង
- ពេលកុមារលេងចប់គ្រូឱ្យកុមារយកសម្ភារទៅទុកដាក់ឱ្យមានសណ្តាប់ធ្នាប់នៅតាមកន្លែងដើមវិញ រួចឱ្យពួកគេ យកកៅអីមករៀបអង្គុយជារាងអក្សរអ៊ុយវិញ
- ពេលកុមារអង្គុយជុំគ្នាហើយ គ្រូឱ្យកុមារនិយាយប្រាប់ពីអ្វីដែលគេបានលេង និងគេស្គាល់អ្វីខ្លះ? ឱ្យកុមារនិយាយ ទៅតាមការយល់ដឹងរបស់គេ។ ចំពោះចំនួនកុមារដែលត្រូវនិយាយអាស្រ័យទៅតាមពេលវេលា។

*** រំលឹកមេរៀនប្រចាំថ្ងៃៈ** គ្រូសួរកុមារពីមេរៀនដែលបានរៀនក្នុងមួយព្រឹក ក្នុងករណីកុមារមិនអាចប្រាប់បានគ្រប់ គ្រូត្រូវប្រាប់បន្ថែម រួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា។

* អនាម័យរៀបចំខ្លួនទៅផ្ទះ៖ គ្រូឱ្យកុមារលាងដៃ លុបមុខ សិតសក់ឱ្យស្អាតរួចរៀបចំកៅអីទុក និងតម្រង់ជួរទៅតាមក្រុម គ្រូណែនាំសណ្តាប់ធ្នាប់ពេលដើរតាមផ្លូវ ការគួសមជាមួយមនុស្សពេលទៅដល់ផ្ទះ ការទុកដាក់សម្ភារ សកម្មភាពមុន និងក្រោយពេលញ៉ាំបាយ ...។

## ថ្ងៃទី២

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

## ហាត់ប្រាណតាមបទចម្រៀង៖ កូនកំប្រុក

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបលោតតាមចង្វាក់ទៅមុខបានត្រឹមត្រូវ
- កុមារធ្វើចលនាលោតទៅមុខដោយផុចកែងដៃលោតទៅមុខតាមចង្វាក់បានត្រឹមត្រូវ
- បណ្តុះស្មារតីកុមារឱ្យមានភាពរហ័សរហួន ក្លាហាន ស្វាហាប់ និងមានបម្រុងប្រយ័ត្នក្នុងពេលធ្វើចលនាដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** ឈរជាជួរ(៣ក្រុម)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរ ៣ជួរតាមក្រុម(ក្រុមទី១ ទី២ ទី៣) ហើយគ្រូឈរពីខាងមុខកុមារ
- គ្រូអោយកុមារលោតសន្ទឹងដៃឱ្យអស់ រួចរលាស់ដៃចុះឡើងៗ ឱ្យបាន ៥ដង ទៅ ៦ដង
- គ្រូច្រៀងឱ្យកុមារស្តាប់ និងធ្វើចលនាឱ្យកុមារមើលតាមបទចម្រៀងរហូត១ចប់
- គ្រូនាំកុមារច្រៀងនិងធ្វើចលនាតាមបទចម្រៀងទាំងអស់គ្នាអាស្រ័យតាមពេលវេលា(២ឬ៣ចប់)
- គ្រូសួរថា តើកូនៗទាំងអស់គ្នាមានដែលស្គាល់ដើមឈើអ្វីខ្ពស់ៗ ហើយគេគៀបយកទឹកមកធ្វើជាស្ករ? (ដើមត្នោត)ហើយកូនមានដឹងឬទេថា តើសត្វអ្វីដែលចូលចិត្តស៊ីផ្លែត្នោត? (កណ្តុរ សំពោច កំប្រុក...)
- ថ្ងៃនេះកូនរៀនមុខវិជ្ជា ចិត្តចលភាព អំពីហាត់ប្រាណតាមបទចម្រៀង ចំណងជើង «កូនកំប្រុក» គ្រូឱ្យកុមារថាតាម១នាក់ ២នាក់តាមក្រុមទាំងអស់គ្នា
- បន្ទាប់មកគ្រូនាំកុមារលើកដៃធ្វើចលនាកាន់ប៉េងប៉ោងផ្លុំ ១ ២ ៣ ផ្លុំ(ដកដង្ហើមចេញដកដង្ហើមចូលវែងៗ ហើយស្រែកធ្វើសំឡេងដូចប៉េងប៉ោងបែក ភុងៗ)

*របៀបធ្វើចលនា*

- ផ្លោតៗ ផ្លោះទៅលើចុងត្នោត ក្រោកៗ ក្រោក កកេរផ្លែក្រេក ក្រោក=កុមារដាក់ដៃទាំងពីរទៅមុខដោយផុចកែងដៃរួចលោតជាចង្វាក់ទៅមុខ
- បក់កន្ទុយតែកតោក ហើយធ្វើក្បាលងីងើៗ (២ដង)=កុមារយកដៃទាំងពីរដាក់ទៅក្រោយខ្នងច្រតចង្កេះធ្វើជាកន្ទុយរួចលោតជាចង្វាក់ទៅមុខ។

អត្ថបទចម្រៀង "កូនកំប្រុក"

-ផ្លោតៗផ្លោះទៅលើចុងត្នោត ក្រោក ក្រោក ក្រោក កកេរផ្លែក្រេកក្រោក

បក់កន្ទុយតែកតោក ហើយធ្វើក្បាលងីងើៗ(២ដង)។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការ បង្រៀនអនុវត្ត ដូច ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ លាងដៃមុននឹងក្រោយពេលញុំាអាហារ៖(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី ២ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

**ម៉ោងទី៣ (រយៈពេល ៣០នាទី)**

## មុខវិជ្ជា៖ បុរេគណិត

### សម្គាល់៖ ចំនួន និងលេខពី ១ ដល់ ៨

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីចំនួននិងលេខពី ១ ដល់៨ តាមលំដាប់លំដោយ បានត្រឹមត្រូវ
- កុមាររាប់ចំនួននិងលេខពី ១ ដល់៨ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារឈ្លាសវៃ រហ័សរហួន ក្នុងការគិតបានហ្មត់ចត់ សប្បាយរីករាយ។

**២. សម្ភារបង្រៀន៖**

- បណ្ណចំនួនរូបភាពពី១ ដល់៨ ចំនួន ៨ បន្ទះ
- បណ្ណចំនួនចំណុចពី១ ដល់៨ ចំនួន៨ បន្ទះ
- បណ្ណលេខ១ ដល់លេខ៨ ចំនួន ៥ បន្ទះ
- ស្កុតក្រដាស់ ១ដុំ កន្ត្រៃ

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរអ៊ុយ "U" និងក្រុមតូច

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- ថ្ងៃនេះគ្រូយក មុខវិជ្ជា បុរេគណិត មេរៀន សម្គាល់ "ចំនួន និងលេខពី១ ដល់ ៨" មកបង្រៀនកូន
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើង ២ទៅ ៣ដង តាមក្រុមនិងទាំងអស់គ្នា
- គ្រូបង្ហាញបណ្ណចំនួនរូបភាពពី១ ដល់៨ ឱ្យកុមារប្រាប់ចំនួនរូបភាពនៅក្នុងបណ្ណនីមួយៗ រួចយកទៅបិទ នៅលើក្តារខៀន រួចនាំកុមាររាប់
- គ្រូបង្ហាញបណ្ណចំនួនចំណុចពី១ ដល់៨ ឱ្យកុមារប្រាប់ពីចំនួនចំណុចនៅក្នុងបណ្ណនីមួយៗ រួចយកទៅ បិទ នៅលើក្តារខៀនពីក្រោមចំនួនរូបភាព រួចនាំកុមាររាប់
- គ្រូបង្ហាញបណ្ណលេខពី១ ដល់៨ ឱ្យកុមារប្រាប់ពីលេខនោះ រួចយកទៅបិទនៅលើក្តារខៀនពីក្រោមចំនួន ចំណុចពី១ដល់៨ រួចនាំកុមាររាប់
- គ្រូនាំកុមាររាប់ចំនួនរូបភាព ចំនួនចំណុចនិងលេខពី១ ដល់៨ សាឡើងវិញម្តងមួយៗ គ្រូណែនាំកុមារជា មុនសិន រួចឱ្យក្រុមនីមួយៗទៅជ្រុងសិក្សា ដើម្បីរើសវត្ថុដែលមាននៅក្នុងជ្រុង នោះ (តាមវត្ថុជាក់ស្តែង ដែលមានដូចជាបំពង់បឺត ចង្កឹះ ដុំឈើ...)
- គ្រូឱ្យកុមារក្រុមទី១ រើសវត្ថុចំនួន៦
- គ្រូឱ្យកុមារក្រុមទី២ រើសវត្ថុចំនួន៧
- គ្រូឱ្យកុមារក្រុមទី៣ រើសវត្ថុចំនួន៨
- គ្រូឱ្យកុមាររាប់ចំនួនវត្ថុតាមក្រុមនីមួយៗ កុមារ និងគ្រូ ផ្ទៀងផ្ទាត់របៀបនេះគ្រប់ក្រុម។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ សិក្សាសង្គម

## រឿងនិទាន៖ កុមារីតូចនិងខ្លាឃ្មុំទាំងបី (និទាន)

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីសកម្មភាពតួអង្គតាមដំណើររឿង បានត្រឹមត្រូវ
- កុមារនិទានរឿងនិងវិភាគតួអង្គនៅក្នុងសាច់រឿងបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ និងយកគំរូតាមតួអង្គល្អ សហការជួយគ្នា និទានរឿងឱ្យមិត្តភក្តិស្តាប់ ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាបណ្តុំ ជាជួរ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំនួរ៖ តើកូនធ្លាប់ជួយឪពុកម្តាយធ្វើការងារផ្ទះដែរឬទេ? ការងារអ្វីខ្លះ? តើថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអំពីអ្វី? គ្រូសរុបចម្លើយរបស់កុមារ
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជា ភាសាខ្មែរ ចំណងជើងរឿងនិទាន "កុមារីតូចនិងកូនខ្លាឃ្មុំទាំងបី"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដោយសួរកុមារថា៖មុននេះមានកូនណាឆ្លើយដូចចម្លើយគ្រូដែរឬទេ?ដូចច្នេះ កូនទះដៃសរសើរមិត្តភក្តិយើងដែលដែលបានទាយត្រូវទាំងអស់គ្នា
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
- ប្រាប់ឈ្មោះអ្នកនិពន្ធ៖ រឿងនិទាននេះនិពន្ធដោយអ៊ុំៗជាគ្រូនៅក្រសួងអប់រំ ឱ្យកុមារថាតាម
- គ្រូនិទានរឿងផ្ទាល់មាត់ឱ្យកុមារស្តាប់ ដោយលើកដាក់សម្លេងតាមតួអង្គនៃសាច់រឿង
- គ្រូនាំកុមារអានពាក្យពិបាក ជាក្រុម និងទាំងអស់គ្នា៖
    - វង្វេង មានន័យថា ភ្លេច ច្រលំ មិនច្បាស់លាស់
    - ប្រាជ្ញាភ្លឺថ្លា មានន័យថា ឆ្លាតចេះចាំ
    - សូរសម្រែក មានន័យថា សម្លេងដែលស្រែកឮខ្លាំងៗ
- អត្ថន័យរឿងគឺអប់រំកូនឱ្យចេះស្តាប់ពាក្យទូន្មានរបស់ចាស់ទុំមុនធ្វើអ្វីមួយ និងមិនត្រូវយករបស់គេដោយមិនមានការអនុញ្ញាតពីម្ចាស់គេទេ
- តើនៅក្នុងរឿងនេះមានតួអង្គប៉ុន្មាននាក់
- ឱ្យកុមារនិទានឡើងវិញ
- គ្រូសួរកុមារ៖ក្រោយពីស្តាប់រឿងនេះចប់ តើក្នុងរឿងមានតួអង្គប៉ុន្មាន? តួអង្គណាខ្លះ? តើកុមារីតូចបានជួបនរណានៅក្នុងព្រៃ ?តើកុមារីតូចរកផ្លូវមកវិញដោយរបៀបណា? (កុមារឆ្លើយតបសំណួរគ្រូទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូសង្ខេបរឿងឱ្យកុមារស្តាប់ឡើងវិញម្តងទៀត
- បន្ទាប់មកគ្រូឱ្យកុមារនិយាយសង្ខេបរឿងឡើងវិញឱ្យមិត្តភក្តិស្តាប់ (កុមារនិយាយពីអ្វីដែលគេបានចងចាំ

## កុមារីតូច និងខ្លាឃ្មុំទាំងបី

កាលពីព្រេងនាយមានកុមារីតូចម្នាក់រស់នៅជាមួយម្តាយនាងនៅក្បែរព្រៃមួយ។ ម្តាយបានហាមកូនស្រីរបស់ ខ្លួនថា ៖ កុំឱ្យទៅដើរលេងនៅក្នុងព្រៃនោះ ព្រោះវាមានគ្រោះថ្នាក់ច្រើនណាស់។ ប៉ុន្តែថ្ងៃមួយនៅពេលកំពុងបេះផ្កាលេង កុមារីតូចស្រាប់តែដើរចូលទៅក្នុងព្រៃនោះយ៉ាងជ្រៅដោយមិនដឹងខ្លួនឡើយ។ នៅពេលដែលកុមារីតូចចង់ត្រឡប់មក ផ្ទះវិញ នាងដឹងថានាងពិតជាវង្វេងផ្លូវហើយ កុមារីតូចប្រុងនឹងស្រែកយំទៅហើយ ស្រាប់តែនាងក្រឡេកមើលទៅខាង មុនក៏ឃើញមានផ្ទះមួយស្ថិតនៅកណ្តាលព្រៃនោះ។

ឱ ! ជាការពិតណាស់ នោះមិនមែនជាផ្ទះនាងទេ។ ក៏ប៉ុន្តែកុមារីតូចគិតថា នាងនឹងជួបប្រទះមនុស្សណាម្នាក់ នៅទីនោះដែលអាចជួយជូននាងឱ្យត្រឡប់ទៅផ្ទះវិញបាន។ គិតដូច្នោះហើយ កុមារីតូចក៏ដើរសំដៅទៅផ្ទះជិតនោះរួចក៏ ស្រែកហៅដោយគ្មាននរណាឆ្លើយសោះ នាងក៏ដើរចូលទៅ។ អីក៏ចម្លែកម្ល៉េះផ្ទះនេះ! វត្ថុគ្រប់ប្រភេទទាំងអស់សុទ្ធតែ មានបីៗ ហើយមួយប្រភេទៗ សុទ្ធតែមានទំហំខុសៗគ្នាទាំងបីដែរ។ នៅទីនោះមានតុបី៖ តុធំមួយ តុមធ្យមមួយ និងតុ តូចមួយ កៅអីមានបី ៖ កៅអីធំមួយ កៅអីមធ្យមមួយ និងកៅអីតូចមួយ បានសម្លបី ៖បានសម្លធំមួយ បានសម្លមធ្យម មួយ និងបានសម្លតូចមួយ កុមារីតូចដើរចូលទៅជិត។ នាងឃ្លានខ្លាំងណាស់។ កុមាររីតូចអង្គុយនៅលើកៅអីធំ តែ កៅអីនោះខ្ពស់ពេក។ នាងអង្គុយលើកៅអីមធ្យមម្តងប៉ុន្តែកៅអីនោះពិបាកអង្គុយណាស់។ ពេលនោះកុមារីតូចក៏ទៅ អង្គុយលើកៅអីតូចម្តង។ កៅអីតូចនេះអង្គុយស្រួលណាស់! ក៏ប៉ុន្តែមិនបានប៉ុន្មានវិនាទីផងវាក៏បាក់ទៅ។ ម្តងនេះ កុមារីតូចភ្លក្សសម្លនៅក្នុងចានធំប៉ុន្តែសម្លក្តៅពេក នាងភ្លក្សសម្លនៅក្នុងចានមធ្យមតែសម្លនៅក្នុងចាននោះប្រៃពេក។ ពេលនោះនាងក៏ភ្លក្សសម្លនៅក្នុងចានតូចទៅ។ ម្តងនេះសម្លឆ្ងាញ់ណាស់ឆ្ងាញ់រហូតធ្វើឱ្យនាងញ៉ាំអស់ពីក្នុងចាន។ កុមារីតូចទទួលអារម្មណ៍ថាដូចជាអស់កម្លាំងណាស់។ នាងក៏ឡើងលើផ្ទះចូលទៅកាន់បន្ទប់។ នៅទីនោះកុមារីតូចក៏មានបីដែរ គឺ គ្រែធំមួយ គ្រែមធ្យមមួយ គ្រែតូចមួយ។ កុមារីតូចសាកល្បងគេងលើគ្រែធំ ប៉ុន្តែគ្រែ នោះរឹងពេកពិបាកគេងណាស់ នាងសាកល្បងគេងលើគ្រែមធ្យមម្តង តែគ្រែមធ្យមនោះទន់ពេក បន្ទាប់មកនាងក៏សាក ល្បងគេងលើគ្រែតូចម្តង គ្រែតូចនេះស្រួលគេងណាស់ ស្រួលរហូតធ្វើឱ្យតូចគេងលង់លក់ទៅ។ពេលជាមួយគ្នានោះដែរ ម្ចាស់ផ្ទះក៏ត្រឡប់មកពីរដើរលេងវិញ គឺជាខ្លាឃ្មុំបី! ពិតប្រាកដណាស់វាគឺជាខ្លាឃ្មុំទាំងបី ខ្លាឃ្មុំធំគឺជាឪពុក ខ្លាឃ្មុំដែលមានមធ្យមជាម្តាយ និងខ្លាឃ្មុំតូចដែលត្រូវជាកូន។ នៅពេលដែលពួកគេចូលមកដល់ក្នុងផ្ទះបាយ។ ខ្លាឃ្មុំធំជាឪពុកកំស្រែកឡើងដោយសំឡេងឮខ្លាំងៗរបស់វាថា៖មានអ្នកណាម្នាក់មកអង្គុយលើកៅអីខ្ញុំហើយ។ ចំណែកខ្លាឃ្មុំមធ្យមជាម្តាយ ក៏ស្រែកឡើងដោយសំឡេងល្មមឡើងដែរថា៖ចំណែកកៅអីខ្ញុំក៏មានអ្នកណាមកអង្គុយដែរ! ព្រមគ្នានោះដែរខ្លាឃ្មុំតូច ដែលជាកូនស្រែករដោយសំឡេងតូចឆ្មាររបស់វាព្រមទាំងយំផងថា៖មានអ្នកណាម្នាក់ធ្វើឱ្យកៅអីខ្ញុំបាក់ហើយ! បន្ទាប់ មកខ្លាឃ្មុំទាំងបី ដើរទៅជិតតុរបស់ពួកគេ រំពេចនោះខ្លាឃ្មុំធំជាឪពុកស្រែកឡើងដោយសំឡេងខ្លាំងៗរបស់វាឡើងទៀត ថា៖ មានអ្នកណាម្នាក់លូកសម្លរបស់ខ្ញុំហើយ! ឯខ្លាឃ្មុំជាម្តាយស្រែកដោយសំឡេងល្មមៗរបស់វាដែរថា៖ សម្លរបស់ខ្ញុំក៏ មានគេលូកដែរ! ពេលជាមួយគ្នានេះខ្លាឃ្មុំតូចជាកូនក៏ស្រែកឡើងដោយសំឡេងតូចឆ្មាររបស់វាព្រមទាំងយំផងថា៖មាន អ្នកណាបានញ៉ាំសម្លរបស់ខ្ញុំអស់រលីងហើយ! ខ្លាឃ្មុំទាំងបីឡើងទៅកាន់បន្ទប់របស់គេទៀត ខ្លាឃ្មុំធំជាឪពុកក៏ស្រែក ឡើងដោយសំឡេងឮខ្លាំងរបស់ពួកគេថា៖មានអ្នកណាម្នាក់មកដេកលេងលើគ្រែរបស់ខ្ញុំ! រីឯខ្លាឃ្មុំជាម្តាយស្រែកដោយ សំឡេងល្មមៗថា៖គ្រែរបស់ខ្ញុំក៏មានគេមកដេកលេងដែរ។ទន្ទឹមគ្នានេះខ្លាឃ្មុំតូចជាកូនបែរជាសើចទៅវិញព្រមទាំង ស្រែកដោយសំឡេងតូចឆ្មារថា៖អ្នកណានេះកំពុងតែដេកលើគ្រែខ្ញុំ! ទន្ទឹមគ្នានឹងឮសូរសម្រែកទាំងនេះកុមារី តូចក៏

ភ្ញាក់ ដឹងខ្លួនឡើង។

ពេលដែលនាងបើកភ្នែកភ្លាម នាងមានការភ័យខ្លាចយ៉ាងខ្លាំង ហើយក៏រត់ចេញទៅយ៉ាងលឿនដោយភ្លេចយក ទាំងផ្កា និងស្បែកជើងរបស់នាងទៅជាមួយផង។ ប៉ុន្តែសំណាងល្អ ខ្លាឃ្មុំទាំងបីសុទ្ធតែជាសត្វស្លូត ចេះគួរសមទាំង អស់។ ពេលដែលកុមារីតូចរត់ទៅ ខ្លាឃ្មុំធំជាឪពុកស្រែកដោយសំឡេងឮខ្លាំងថា៖
គេមិនត្រូវចូលក្នុងផ្ទះអ្នកដទៃដោយ ម្ចាស់គេមិននៅ ឬដោយគ្មានសុំការអនុញ្ញាតពីម្ចាស់ផ្ទះយ៉ាងដូចនេះទេ!

ចំណែកឯខ្លាឃ្មុំជាម្តាយស្រែកដោយសំឡេងល្មមៗថា៖ នាងត្រូវតែស្តាប់បង្គាប់ និងគោរពម្តាយរបស់នាងជា និច្ច! នៅពេលជាមួយគ្នានោះដែរ ខ្លាឃ្មុំតូចជាកូនដែលស្លូតគួរឱ្យស្រឡាញ់ខ្លាំងនោះស្រែកដោយសំឡេងតូចច្មារយ៉ាង គ្រលួចថា៖ បត់ស្តាំ! ហើយបត់ឆ្វេង! ឯងនឹងរកផ្ទះឯងឃើញបានយ៉ាងឆាប់រហ័ស! ដោយសារការចង្អុលបង្ហាញផ្លូវពី កូនខ្លាឃ្មុំ កុមារីតូចរកឃើញផ្លូវត្រឡប់ទៅផ្ទះនាងវិញ។ តាំងពីកើតហេតុការណ៍ផ្សងព្រេងមក កុមារីតូចតែងតែស្តាប់ បង្គាប់ម្តាយនាងជានិច្ច នាងឈប់ទៅដើរលេងក្នុងព្រៃម្នាក់ឯងទៀត ហើយនាងក៏លែងលួចចូលទៅក្នុងផ្ទះអ្នកដទៃ ដោយគ្មានការអញ្ជើញផងដែរ។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

## សម្គាល់តួអក្សរ៖ "ធ"

### ១. វត្ថុបំណង៖

- កុមារប្រាប់ពីរូបរាង និងឈ្មោះអក្សរ "ធ" បានត្រឹមត្រូវ
- កុមារកំណត់ពីរូបរាងឈ្មោះអក្សរ"ធ" និងរកពាក្យថ្មីផ្តើមចេញពីអក្សរ"ធ" បានត្រឹមត្រូវ
- កុមារក្លាហាន និងយកចិត្តទុកដាក់ ព្យាយាមក្នុងការរកពាក្យថ្មីផ្តើមពីអក្សរ"ធ"។

### ២. សម្ភារបង្រៀន៖

- ផ្ទាំងរូបភាព ធៃថាវ ធៃឃ្មុំ ធ័ត្រ
- បណ្ណពាក្យ ធៃថាវ ធៃឃ្មុំ ធ័ត្រ និងល្បះ ចៅធេ ឆាធៃថាវ
- ប៊ិក ហ្វឺត ស្កុត កន្ត្រៃ(កាត់រៀបចំឱ្យហើយ)

### ៣. ការរៀបចំកុមារ៖ អង្គុយជារាងអក្សរអ៊ុយ "ប"

### ៤. ដំណើរការបង្រៀន៖(អនុវត្តនៅក្នុងជំហានទី៣)

**+ រកពាក្យ និងឃ្លា**

- គ្រូបង្ហាញផ្ទាំងរូបភាព "ធៃថាវ" ដោយបិទបាំងបញ្ចេញខាងលើបន្តិច ខាងក្រោមបន្តិច ខាងឆ្វេងបន្តិច ខាងស្តាំបន្តិច រួចឱ្យកុមារទាយ
- បើករូបបង្ហាញ ដើម្បីផ្ទៀងផ្ទាត់ចម្លើយ (បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត ហើយយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចបង្ហាញបណ្ណពាក្យ "ធៃថាវ" បិទពីក្រោមរូប រួចនាំកុមារអានទាំងរូប និង ពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញរូបភាព"**ធៃឃ្មុំ**" ដោយរលាស់មួយភ្លែតឱ្យកុមារឃើញ ហើយឱ្យកុមារទាយ បន្ទាប់មកគ្រូបង្ហាញរូបដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះ

បិទលើក្ដារខៀន រួចបង្ហាញបណ្ណពាក្យ "**ឆៃយ៉ាំ**" ហើយបិទពីក្រោមរូប និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង

- គ្រូឱ្យកុមារមួយនាក់ចេញទៅក្រៅថ្នាក់ ហើយមើលផ្ទាំងរូបភាព "**ឆ័ត្រ**" រួចហើយឱ្យចូលថ្នាក់វិញ ហើយខ្សឹបពាក្យ "**ឆ័ត្រ**" បន្តគ្នាឱ្យបាន ៥នាក់។ ខ្សឹបដល់អ្នកទី៥ ត្រូវឱ្យអ្នកទី៥ និយាយប្រាប់មិត្តភក្ដិឮពាក្យអ្វី? រួចសួរអ្នកទី១វិញ ត្រឹមត្រូវឬទេ? បន្ទាប់មក គ្រូបង្ហាញរូបភាព "**ឆ័ត្រ**" ដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវ សរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្ដារខៀន ហើយបង្ហាញបណ្ណពាក្យ"**ឆ័ត្រ**" និងបិទពីក្រោមរូបភាព និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញឃ្លា "**ចៅឆេ ឆាឆៃថាវ**" អានឱ្យកុមារស្ដាប់រួចយកបិទពីក្រោមពាក្យ
- នាំកុមារអានរូប ពាក្យ និងឃ្លា (២ដង) គ្រូនាំកុមារអានផង និងចង្អុលផង។

**+ ស្ដាប់សូរពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារស្ដាប់ (២ឬ៣ចប់) ដើម្បីឱ្យកុមារទាយសូរ និងញែកសូរនៃពាក្យ និងឃ្លា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- សួរកុមារ តើពាក្យ និងឃ្លាដែលគ្រូបានអានអម្បាញ់មិញឮសូរដូចម្ដេច? (ពេលកុមារឆ្លើយ គ្រូមិនបាច់វាយតម្លៃត្រូវឬខុសទេ)។

**+ ពិនិត្យរូបរាងអក្សរនៅក្នុងពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារសង្កេត (២ឬ៣ចប់) ដើម្បីឱ្យកុមារពិនិត្យរករូបរាងតួអក្សរដែលមានរាងដូចគ្នាច្រើន (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- គ្រូឱ្យកុមារដែលស្ម័គ្រចិត្តឡើងមកគូសវង់ជុំវិញតួអក្សរដែលមានរាងដូចគ្នាច្រើន (ពេលកុមារឡើងមកគូសជុំវង់វិញអក្សរមានរាងដូចគ្នាច្រើន បើកុមារចង់គូសប៉ុណ្ណាឱ្យគេគូសតាមចិត្តរបស់គេ គ្រូមិនត្រូវបញ្ឈប់ឬបង្ខំគេឡើយ)
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលទាំងអស់គ្នា បើមានកុមារគូសវង់ខុសត្រូវឱ្យកុមារដទៃជួយកែតម្រូវ។ នាំកុមាររាប់ចំនួនអក្សរដែលកុមារគូសវង់ដើម្បីផ្ទៀងផ្ទាត់ពីចំនួនច្រើន។

**+ ប្រាប់ឈ្មោះតួអក្សរ៖**

- គ្រូសួរកុមារ តើតួអក្សរដែលកូនគូសវង់ជុំវិញនៅក្នុងពាក្យ និងឃ្លានោះឈ្មោះអក្សរអ្វី? បើកុមារឆ្លើយមិនត្រូវទេនោះ គ្រូត្រូវប្រាប់រួចនាំកុមារអាន (ក្រុមរួចទាំងអស់គ្នា)
- គ្រូបង្ហាញអក្សរចល័ត "ឆ" រួចសួរកុមារ អក្សរដែលគ្រូបង្ហាញនេះរាងដូចអក្សរដែលកូនបានគូសវង់នោះឬទេ? បើដូច ឈ្មោះអក្សរអ្វីដែរ?
- គ្រូសរសេរអក្សរ"ឆ" យ៉ាងធំនៅជ្រុងក្ដារខៀន ដើម្បីឱ្យកុមារសង្កេតពីទិសនៃសំណេរ
- គ្រូសួរកុមារ អក្សរដែលគ្រូសរសេរនេះតើដូចអក្សរដែលគ្រូបង្ហាញនេះដូចអក្សរដែលកូនគូសវង់ឬទេ? ឈ្មោះអ្វី?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនអក្សរ"ឆ" នាំកុមារអានអក្សរ"ឆ" (ក្រុមរួចទាំងអស់គ្នា) ឱ្យបាន២ឬ៣ដង
- គ្រូសរសេរចំណងជើងមេរៀនលើក្ដារខៀន រួចនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន (ក្រុមរួចទាំងអស់គ្នា)

**+ ប្រៀបធៀបអក្សរស្រដៀង៖**
- គ្រូសរសេរអក្សរ "ឆ ជ ច " នៅលើក្តារខៀន
- គ្រូអានអក្សរ "ឆ ជ ច" ឱ្យកុមារស្តាប់ និងសង្កេត
- គ្រូសួរកុមារ តើអក្សរទាំងអស់នេះមានលក្ខណៈដូចគ្នានៅត្រង់ណាខ្លះ? ហើយខុសគ្នាត្រង់ណាខ្លះ?
- កុមារនិយាយប្រាប់ផងឡើងមកចង្អុលផង។

**+ រកពាក្យថ្មីផ្តើមពីអក្សរ"ង" ៖**
- គ្រូអានពាក្យ និងឃ្លាសារឡើងវិញឱ្យបានច្រើនដងដើម្បីឱ្យកុមារស្តាប់សូរ
- ឱ្យកុមាររកពាក្យថ្មីដែលផ្តើមពីអក្សរ"ឆ"
- គ្រូសរសេរពាក្យដែលកុមាររកបាននៅលើក្តារខៀនទាំងអស់ទាំងពាក្យត្រឹមត្រូវ និងពាក្យមិនត្រឹមត្រូវ
- នាំកុមារផ្ទៀងផ្ទាត់ដោយគ្រូអានម្តងមួយពាក្យៗ រួចសួរកុមារតើពាក្យនេះមានអក្សរ"ឆ" ឬទេ? បើត្រឹមត្រូវគ្រូគូសរង់ជុំវិញពាក្យនោះ។ បើពាក្យខុសគ្រូមិនត្រូវធ្វើអ្វីទាំងអស់។ គ្រូធ្វើរបៀបនេះទាល់តែអស់ពាក្យដែលកុមាររកបាន។
-

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

## ល្បែង៖ ក្រងកៅស៊ូកងជាខ្សែ

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពី របៀបធ្វើចលនាម្រាមដៃ ក្រងកៅស៊ូកងជាខ្សែ បានត្រឹមត្រូវ
- កុមារធ្វើចលនាម្រាមដៃ ដោយក្រងកៅស៊ូកងជាខ្សែ បានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ ព្យាយាមអំណត់ មានបម្រុងប្រយ័ត្ន និងមានភាពជឿជាក់

**២. សម្ភារបង្រៀន៖** កៅស៊ូកង ២ទៅ៣ កញ្ចប់

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារង្វង់តាមក្រុមតូចៗ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)
- គ្រូប្រាប់ពីមុខវិជ្ជា និងចំណងជើងមេរៀន រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា
- គ្រូដាក់កញ្ចប់សម្ភារៈនៅលើតុពីមុខកុមារ រួចឱ្យកុមារស្ម័គ្រចិត្តចំនួន៣នាក់ មកស្ទាបហើយទាយ សម្ភារៈនៅក្នុងកញ្ចប់ រួចឱ្យទៅអង្គុយកន្លែងវិញ
- គ្រូឱ្យកុមារ១នាក់ ឡើងមកលូកយកសម្ភារៈនៅក្នុងថង់ នោះចេញមួយចំនួន រួចសួរកុមារថា៖ តើមិត្តភក្តិយើង៣នាក់ អម្បាញ់មិញមានអ្នកណាទាយត្រូវឬទេ? គ្រូសរុបចម្លើយកុមារ
- គ្រូឱ្យកុមារទាំងអស់ទះដៃសរសើរមិត្តភ័ក្តដែលបានទាយត្រូវនិងលើកទឹកចិត្តអ្នកដែលទាយមិនទាន់ត្រូវ
- គ្រូសួរកុមារ៖ តើកូនដឹងទេ ថាគ្រូយកសម្ភារៈនេះមកឱ្យកូនធ្វើអ្វី ? កុមារឆ្លើយតបតាមគំនិតរបស់គេម្នាក់ៗ
- គ្រូណែនាំរបៀបលេង ដល់កុមារ៖
  - គ្រូឱ្យកូនៗលេងជាក្រុមតូចៗ ហើយក្នុងមួយក្រុមត្រូវបានសម្ភារៈនេះមួយកញ្ចប់ និងក្រុមនិមួយៗត្រូវអង្គុយថារង្វង់

- ពេលក្រុមកូននិមួយៗបានសម្ភារៈ ហើយកូនត្រូវចាក់កៅស៊ូពីស្បោងដាក់នៅកណ្តាលរង្វង់ កូនៗកុំលេង កុំដណ្តើមគ្នា
- ដំបូងក្រុមនិមួយៗ ត្រូវប៉ាវរកអ្នកចាប់ផ្តើមមុនគេ
- កូនដែលត្រូវចាប់ផ្តើមមុនគេ ត្រូវអង្គុយសណ្តូកជើង យកកៅស៊ូកកងមួយមកពាក់នឹងមេជើង ឆ្វេងឬស្តាំ។
- បន្ទាប់មកកូនយកកៅស៊ូក១ថ្មី មកស៊កបញ្ចូលក្នុងកៅស៊ូដែលទាក់នឹងមេជើង ហើយបត់កៅស៊ូនោះជាពីរឱ្យផ្គោបគ្នារួចយកកៅស៊ូកងមួយទៀត មកស៊កបញ្ចូលបន្តទៅក្នុងកៅស៊ូមុន ហើយបត់ជាពីរឱ្យគ្នាដូចមុន។
- កូនត្រូវធ្វើបែបនេះបន្តគ្នារហូតសល់កៅស៊ូតែ១
- កៅស៊ូដែលសល់១នោះ ត្រូវស៊កបញ្ចូលបន្តគ្នា តែបត់ជា២មិនដូចមុនទេ គឺយកកៅស៊ូម្ខាងស៊កបញ្ចូលគ្នា ទាញចេញយកតែម្ខាងដើម្បីផ្ចិតមុខបានជាខ្សែមួយរួចជាស្រេច។
- ពេលចាប់ផ្តើមលេង កូនត្រូវចេះរង់ចាំវេនលេងម្តងម្នាក់បន្តគ្នា កុំដណ្តើមគ្នា ។

- គ្រូឱ្យកុមារណាម្នាក់ស្ម័គ្រចិត្តនិយាយ ឡើងវិញពីអ្វីដែលគ្រូបានប្រាប់ បើនិយាយមិនទាន់ច្បាស់លាស់ទេ គ្រូត្រូវប្រាប់សារឡើងវិញ
- គ្រូរៀបចំកុមារជាក្រុម រួចឱ្យទៅអង្គុយជារង្វង់ ទៅតាមកន្លែងដែលគ្រូបានរៀបចំទុក
- គ្រូឱ្យតំណាងក្រុមនិមួយៗ យកសម្ភារៈទៅចែកគ្នាអនុវត្ត
- គ្រូចាប់ផ្តើមឱ្យសញ្ញា ដើម្បីឱ្យក្រុមនិមួយៗប៉ាវ រកអ្នកឈ្នះ
- គ្រូទុកពេលឱ្យកុមារអនុវត្តការលេង
- គ្រូដើរសម្របសម្រួលគ្រប់ក្រុម និងជួយកែតម្រូវក្រុមណាដែលលេងខុស
- នៅពេលក្រុមនិមួយៗ លេងដល់អ្នកចុងក្រោយ គ្រូ និងកុមារនាំគ្នាផ្ទៀងផ្ទាត់លទ្ធផលដើម្បីរកអ្នកឈ្នះ និងអ្នកចាញ់
- គ្រូនាំកុមារលេង និងផ្ទៀងផ្ទាត់របៀបនេះ រហូតដល់បញ្ចប់ម៉ោង គ្រាន់តែលេងចប់មួយដងផ្ទៀងផ្ទាត់មួយដង ហើយចែកក្រុមសារថ្មី និងត្រូវប៉ាវរកអ្នកចាប់ផ្តើមសារជាថ្មី ពេលលេងបន្ត។

# ថ្ងៃទី៣

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលនាព

## ហាត់ប្រាណតាមរឿងនិទាន៖ មេមាន់នាំកូនទៅរកចំណី

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបដើរទៅមុខថយក្រោយ រត់លឿន លោតឡើងចុះ តាមខ្លឹសារនៃរឿងនិទានបានត្រឹមត្រូវ
- កុមារដើរទៅមុខថយក្រោយ  រត់លឿន លោតឡើងចុះ តាមខ្លឹសារនៃរឿងនិទានបានត្រឹមត្រូវ
- កុមារមានបម្រុងប្រយ័ត្ន ស្វាហាប់ រហ័សរហួន អំណត់ព្យាយាមនិងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** ឈរជាជួរ (ចំនួនជួរអាចបត់បែនតាមស្ថានភាពកុមារតិចឬច្រើនដែលមាននៅក្នុងថ្នាក់)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរទៅតាមទីកន្លែងដែលបានកំណត់
- តើនៅផ្ទះរបស់កូនមានចិញ្ចឹមសត្វស្លាបអ្វីខ្លះ?តើសត្វអ្វីពេលដែលវាពងស្រែកលឺតុកកាតតៗ?ដូច្នេះ កូនទាំងអស់ គ្នាយកប្រអប់ដៃទាំងពីរក្តាប់ដាក់នៅត្រង់ទ្រូង រួចធ្វើត្រាប់តាមសត្វទទះស្លាបហើរជាមួយ គ្រូ ដោយហើរទៅ មុខ រួច ត្រឡប់មកកន្លែងដើមវិញ
- គ្រូប្រាប់មុខវិជ្ជានិងចំណងជើង៖ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព អំពីហាត់ប្រាណតាមរឿងនិទាន "មេមាន់នាំ កូនទៅរកចំណី" រួចឱ្យកុមារថាតាមជាក្រុម ឬជាបុគ្គល២ទៅ៣ដង
- គ្រូនាំកុមារពិភាក្សាអំពីការធ្វើចលនា ដើរ រត់ លោតឡើង ចុះ តាមខ្លឹមសាររឿងនិទានដោយប្រាប់កុមារ ពេលគ្រូនិទានដល់ពាក្យកូនមាន់ដើរផងលោតផង ដើរថយក្រោយជំហ៊ានវែងៗ កូនត្រូវដើរនិងលោតរួច ដើរថយក្រោយជំហ៊ានវែងៗ ពេលគ្រូនិទានដល់ពាក្យមេមាន់នាំកូនរត់លោតទំលើរបង និងហក់ឡើងចុះ កូនត្រូវធ្វើចលនារត់ លោតឡើង ចុះ...។
- គ្រូចាប់ផ្តើមនិទានរឿងបណ្តើរនាំកុមារធ្វើសកម្មភាពបណ្តើរតាមខ្លឹមសាររឿង បើកុមារធ្វើចលនាណាមួយ មិនទាន់ត្រឹមត្រូវគ្រូជួយកែតម្រូវ (ក្នុងករណីសល់ម៉ោងគ្រូអាចធ្វើឡើងវិញម្តងទៀត)
- គ្រូឱ្យកុមារទាំងអស់មកឈរជាជួររួចសួរថាកូនៗហាត់ទេ?តើកូនស្រេកទឹកឬទេ? បើទឹកក្តៅកូនញ៉ាំបាន ឬទេ? បើចង់ញ៉ាំត្រូវធ្វើដូចម្តេច? ដូចច្នេះកូនៗទាំងអស់គ្នាយកដៃស្តាំធ្វើជាកែវទឹក ដៃឆ្វេងច្រត់ចង្កេះ រួចនាំគ្នាឱនធ្វើជាដួសទឹកយកមកដាក់ជិតមាត់ហើយនាំគ្នាផ្លុំតិចៗ រួចនាំគ្នាញ៉ាំទាំងអស់គ្នា(ធ្វើរបៀប នេះម្តងទៀត)។

អត្ថបទរឿងនិទាន "មាន់នាំកូនទៅរកចំណី

មានមេមាន់មួយបាននាំកូនដើរចេញពីទ្រុង ពួកវាបានដើរផង លោតផង ហើយទទះស្លាបភ្លឹបៗ ហើយស្រែកថា" ក្រុកៗ ៗ" ។ មេមាន់ដើរមួយៗ ដើម្បីទៅរកចំណីនៅជិតរបងផ្ទះស្រាប់តែវាឃើញពស់មួយវារ ឡើងលើរបង ពួកគេភ័យណាស់ក៏ដើរថយក្រោយមួយៗ ដោយជំហានវែងៗ។ មេមាន់ក៏នាំកូនរត់លោតទំលើ របងមួយ រួចហក់ចុះទៅលើដីវាលម្ខាងទៀត។ ដើរបណ្តើរលោតបណ្តើរ ដោយទទះស្លាបភ្លឹបៗ ហើយក៏នាំកូន កកាយដីរកចំណី ម្តងកាយទៅខាងឆ្វេង ម្តងកាយទៅខាងស្តាំ លោតចុះ លោតឡើង ព្រោះគេសប្បាយដោយ បានស៊ីចំណីយ៉ាងឆ្ងាញ់ ស្រាប់តែពេលនោះមេមាន់ក្រឡេកទៅឃើញសត្វស្ទាមួយយ៉ាងធំបំរុងនឹងចាប់កូនវា ស៊ីជាចំណី ។ ពេលនោះមេមាន់ក៏កៀងកូន ស្រែកថា កូនៗ រត់លឿនចូលទ្រុងវិញ ។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" ( ដំណើរការ បង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី២ )
* ទម្លាប់ល្អៈ លាងដៃមុននឹងក្រោយពេលញ៉ាំអាហារៈ( ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១ ម៉ោងទី២ )
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៣ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

## ល្បែង ៖ ចង់ទិញទាយសម្លេងសត្វ

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីឈ្មោះសត្វ តាមរយៈការស្តាប់សម្លេង បានត្រឹមត្រូវ
- កុមារទាយសម្លេងសត្វ និងគ្រាប់តាមនិមិត្តសញ្ញា បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** កូនកាសរូបភាពសត្វ ចង់

**៣. ការរៀបចំកុមារៈ** ឱ្យកុមារអង្គុយជារាងអក្សរ អ៊ុយ "U" និងចែកកុមារជាក្រុមតូចៗឱ្យអង្គុយជារង្វង់

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូលើកចង់ និងកូនកាសរូបភាពសត្វ បង្ហាញកុមារ រួចឱ្យកុមារប្រាប់ឈ្មោះ
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - កូនៗត្រូវឈរជារង្វង់ ហើយគ្រូកំណត់យកកូនណាម្នាក់ជាអ្នកចាប់ផ្តើមកាន់ចង់មុនគេ
  - ពេលឮគ្រូឱ្យសញ្ញាទះដៃ កូនដែលកាន់ចង់ត្រូវហុចទៅអ្នកស្តាំដៃបន្តៗគ្នា ដោយច្រៀងបណ្តើរ ទះដៃបណ្តើរ
  - ពេលគ្រូឱ្យសញ្ញាបញ្ឈប់ ចង់នៅដៃកូនណា កូននោះត្រូវលូកដៃយកបណ្ណរូបភាពនោះមួយសន្លឹកមកមើល ហើយធ្វើសម្លេងគ្រាប់តាមសត្វនោះ ហើយកូនដទៃទៀតជាអ្នកទាយឈ្មោះសត្វដែលមិត្តភក្តិបានធ្វើសម្លេង
  - បន្ទាប់មកកូនលើកបណ្ណរូបភាពនោះបង្ហាញមិត្តភក្តិ ដើម្បីផ្ទៀងផ្ទាត់ចម្លើយរួចកូនត្រូវយកបណ្ណនោះឱ្យគ្រូទុក ។ ពេលផ្ទៀងផ្ទាត់លទ្ធផលហើយ កូនត្រូវហុចចង់នោះទៅមិត្តភក្តិបន្តទៀតតាមសញ្ញាបញ្ជារបស់គ្រូ ។ កូនលេងរបៀបនេះរហូតដល់គ្រូបញ្ឈប់ ។
  - ពេលកូនណាទាយខុស ឬធ្វើសម្លេងខុស គឺជាអ្នកចាញ់ ហើយឱ្យមិត្តភក្តិដទៃទៀតជួយប្រាប់ និងកែតម្រូវ
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមដំណាក់កាលនីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូនាំកុមារអនុវត្តការលេង ដោយគ្រូកែតម្រូវចំពោះកុមារណាដែលលេងមិនទាន់ត្រឹមត្រូវ
- **គ្រូសួរកុមារៈ**

- កូនៗទាំងអស់គ្នាសប្បាយទេ?**តើមុននេះកូនៗបានលេងល្បែងអ្វី**? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- **តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)

- គ្រូប្រាប់កុមារ **ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែង មេរៀន** " ថង់ទិញ ទាយសម្លេងសត្វ "
- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)
- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា** ។
-

## ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## ចម្រៀង៖ មេអំបៅទៅសាលារៀន (ពេលទី២)

**១. វត្ថុបំណង៖**

- កុមារប្រាប់បាន ពី របៀបច្រៀង និងធ្វើកាយវិការតាមបទច្រៀង បានត្រឹមត្រូវ
-កុមារច្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀងបានត្រឹមត្រូវ
-កុមារស្រឡាញ់ចូលចិត្តច្រៀង និងសហការគ្នាដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាអក្សរ "ប" កុមារឈរជាជួរនិងជារង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារប្រាប់ចំណងជើងចម្រៀង
- គ្រូឱ្យកុមារច្រៀង និង ធ្វើកាយវិការកម្រិតពេលទី១សាឡើងវិញ
- កុមារច្រៀង និងធ្វើកាយវិការកម្រិតពេលទី១សាឡើងវិញ
- គ្រូច្រៀងបំបាត់ពាក្យខ្លះៗឱ្យកុមារច្រៀងបំពេញពាក្យដែលបាត់៖អើយ...មេអំបៅ ហិច...សំដៅ ទៅរក...ផ្កា
- កុមារច្រៀង៖ អើយមើលមេអំបៅ ហិចហើរសំដៅ ទៅរកក្រេបផ្កា
- គ្រូធ្វើកាយវិការ ដូចខ្លឹមសារបទចម្រៀងក្នុងកម្រិតពេលទី១ រីឯកុមារច្រៀងទាំងអស់គ្នា
- គ្រូច្រៀង កុមារទាំងអស់គ្នាធ្វើកាយវិការ តាមបទចម្រៀង។
- គ្រូណែនាំប្រាប់ពីការប្រើសញ្ញាបាតដៃបញ្ជា៖
- បើកាលណាគ្រូផ្ងារបាតដៃឡើងទៅក្រុមណា ក្រុមនោះត្រូវច្រៀង និងធ្វើកាយវិការ
- បើកាលណាគ្រូផ្កាប់បាតដៃចុះទៅក្រុមណា ក្រុមនោះត្រូវឈប់ច្រៀង និងឈប់ធ្វើកាយវិការ
- បើកាលណាគ្រូផ្ងារបាតដៃទាំង២ឡើង ក្រុមនីមួយៗត្រូវច្រៀង និងធ្វើកាយវិការទាំងអស់គ្នា
- ហើយបើកាលណាគ្រូផ្កាប់បាតដៃទាំង២ចុះ ក្រុមនីមួយៗត្រូវឈប់ច្រៀង និងឈប់ធ្វើកាយវិការទាំងអស់គ្នា
- គ្រូនាំកុមារច្រៀង និង ធ្វើកាយវិការទាំងអស់គ្នាសាឡើងវិញជាក្រុម ឬ ទាំងអស់គ្នាឱ្យបាន ២ ឬ ៣ចប់
- គ្រូសួរ៖កូៗទាំងអស់គ្នាសប្បាយទេ? តើអម្បាញ់មិញកូនៗរៀនមុខវិជ្ជាអ្វី? មានចំណងជើងដូចម្ដេច? និងបានធ្វើអ្វីខ្លះ ?
- កុមារឆ្លើយ៖ រៀនមុខវិជ្ជាសិក្សាសង្គម ចម្រៀង មេអំបៅទៅសាលារៀនពេលទី២ ឆ្លើយតាមការយល់

ដឹងរបស់កុមារ
- គ្រូប្រាប់កុមារៈ ថ្ងៃនេះយើងរៀនមុខវិជ្ជាសិក្សាសង្គម ចំណងជើង ចម្រៀង មេអំបៅទៅសាលារៀនពេលទី២គ្រូនាំកុមារអានមុខវិជ្ជា ចំណងជើងមេរៀនជាក្រុម ឬ ទាំងអស់គ្នា ។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

### សង្កេត៖ គ្រួសារ

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីសមាជិក និងសកម្មភាពក្នុងគ្រួសារបានត្រឹមត្រូវ
- កុមាររៀបរាប់ពីឈ្មោះសមាជិក និងសកម្មភាពក្នុងគ្រួសារបានត្រឹមត្រូវ
- បណ្តុះកុមារឱ្យមានភាពក្លាហាន និងចេះស្រឡាញ់គ្រួសារ គោរពសមាជិកគ្រួសារ និងចេះជួយការងារក្នុងគ្រួសារ

**២. សម្ភារៈបង្រៀន៖** ផ្ទាំងរូបភាពសកម្មភាពក្នុងគ្រួសារ ចំនួន ៤ផ្ទាំង

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារាងពាក់កណ្តាលរង្វង់ អក្សរ "U" និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)
- គ្រូសួរកុមារៈ កូនដឹងទេ តើថ្ងៃនេះគ្រូបានអ្វីផ្ញើកូនៗទាំងអស់គ្នា?
- គ្រូឱ្យកុមារបិទភ្នែកទាំងអស់គ្នា ពេលកុមារបិទភ្នែក គ្រូយកស្រោមសំបុត្រដែលច្រកផ្ទាំងរូបភាពសកម្មភាពក្នុងគ្រួសារមកដាក់លើតុពីមុខកុមារ
- គ្រូឱ្យកុមារបើកភ្នែកវិញ រួចសួរកុមារ តើមានអ្វីនៅពីមុខកូន? តើស្រោមសំបុត្រនេះមានអ្វីខ្លះ?
- គ្រូឱ្យកុមារម្នាក់ឡើងមកយកទាំងរូបភាពចេញពីស្រោមសំបុត្ររួចផ្ទៀងផ្ទាត់ទៅនឹងលទ្ធផលដែលកុមារបានទាយ បើមានកុមារណាទាយត្រូវគ្រូសរសើរកុមារដោយពាក្យសម្តី (កូនដែលបានឆ្លើយត្រូវកូនឆ្លាតមែន ហើយពូកែទៀត ប៉ុន្តែកូនឆ្លើយមិនត្រូវក៏ឆ្លាតដែរ ដែលក្លាហានហ៊ានឆ្លើយសំណួរគ្រូ)។គ្រូបញ្ជាក់ប្រាប់កុមារៈ រូបភាពនេះហៅថាគ្រួសារ រួចនាំកុមារអាន
- គ្រូសួរកុមារៈ កូនដឹងទេថាគ្រូយកផ្ទាំងរូបភាពនេះមកឱ្យកូនៗទាំងអស់គ្នាធ្វើអ្វី?
- គ្រូណែនាំកុមារពីរបៀបអនុវត្តតាមក្រុមនីមួយៗ៖
  - គ្រូឱ្យកូនៗអនុវត្តតាមក្រុមតូចៗ ហើយក្នុងក្រុមនីមួយៗត្រូវបានផ្ទាំងរូបភាពនេះមួយផ្ទាំង
  - ពេលក្រុមនីមួយៗបានផ្ទាំងរូបភាពនេះហើយ កូនត្រូវដាក់កណ្តាលរង់ ហើយនាំគ្នាសង្កេតមើលរូបទាំងអស់នោះ ហើយពិភាក្សាគ្នាលើរូបនីមួយៗថា បានឃើញអ្វីខ្លះក្នុងរូបភាព? តើក្នុងរូបភាពមាននរណាខ្លះ? តើពួកគេកំពុងធ្វើអ្វី? ពេលកូននាំគ្នាសង្កេតកូនកុំដណ្តើមគ្នា កុំដកផ្ទាំងរូបភាពនេះចុះឡើង បើកូនអង្គុយបញ្ច្រាសរូបត្រូវបង្វិលផ្ទាំងរូបភាពឱ្យត្រូវមិត្តភក្តិអាចមើលឃើញច្បាស់។ ហើយបើកូនណាស្គាល់ជួយប្រាប់ទៅមិត្តភក្តិដែលគេមិនស្គាល់ផង។ ហើយកូនត្រូវរកមិត្តណាម្នាក់សម្រាប់ឡើងនិយាយប្រាប់ពីអ្វីដែលកូនបានស្គាល់
  - ពេលកូនៗពិភាក្សាគ្នាចប់គ្រប់ក្រុមហើយ ត្រូវនាំគ្នាទៅអង្គុយនៅក្រុមដុំវិញដោយយកសម្ភារៈទៅរៀងៗខ្លួន។
- គ្រូឱ្យកុមារ១នាក់ ឡើងនិយាយពីអ្វីដែលត្រូវបានប្រាប់ បើនិយាយមិនបានទេឱ្យមិត្តភក្តិជួយបំពេញ

បន្ថែម ប៉ុន្តែបើនៅតែនិយាយមិនបានពេញលេញទេនោះគ្រូត្រូវនិយាយប្រាប់កុមារសារឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមហើយអង្គុយជារង្វង់តាមទីកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូអោយតំណាងក្រុមនីមួយៗមកយកសម្ភារៈទៅ ហើយនាំគ្នាអនុវត្តតាមការណែនាំ
- គ្រូដើរសម្របសម្រួលកុមារគ្រប់ក្រុមទាំងអស់ ដើម្បីជួយក្រុមណាដែលមិនទាន់យល់ច្បាស់
- ពេលក្រុមនីមួយៗត្រូវបានបញ្ចប់ការងារ គ្រូឱ្យពួកគេទៅអង្គុយនៅក្រុមធំវិញដោយយកផ្ទាំងរូបភាពទៅរៀងៗខ្លួន ទុកបង្ហាញពេលឡើងរាយការណ៍
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងមកនិយាយប្រាប់មិត្តភក្តិនិងគ្រូពីលទ្ធផលដែលពួកគេបានពិភាក្សាគ្នា (ម្តងមួយក្រុមៗ) ដោយលើកផ្ទាំងរូបភាពចង្អុលបង្ហាញឈ្មោះរូបម្តងមួយៗ
- គ្រូត្រូវកែតម្រូវពាក្យដែលពួកគេនិយាយមិនទាន់បានត្រឹមត្រូវតាមអក្ខរាវិរុទ្ធ រួចនាំកុមារអាននូវពាក្យទាំងនោះទាំងអស់គ្នា។
- គ្រូសរុបពីលទ្ធផលរបស់កុមារគ្រប់ក្រុម បន្ទាប់ពីបានស្តាប់ពួកគេនិយាយចប់។ (ឧទាហរណ៍៖ គ្រូស្តាប់កុមារប្រាប់បានតែឈ្មោះ និងសកម្មភាពខ្លះៗក្នុងរូបតែប៉ុណ្ណោះ។ ឯសកម្មភាពដែលបានណែនាំផ្សេងៗទៀតប្រាប់មិនបាន។ ដូច្នេះគ្រូត្រូវគិតគួរផ្តល់ចំណេះដឹងថ្មីបន្ថែមឱ្យពួកគេអ្វីខ្លះទៀត?)
- គ្រូត្រូវផ្តល់ចំណេះដឹងថ្មីៗបន្ថែមតាមរយៈ៖
  - គ្រូបង្ហាញផ្ទាំងរូបភាពឱ្យកុមារសង្កេតជារួម ឱ្យកុមារបានមើលឃើញទាំងអស់គ្នា។ បន្ទាប់មកគ្រូចង្អុលនឹងប្រាប់ឈ្មោះសមាជិកគ្រួសារក្នុងរូបម្តងមួយៗ និងសកម្មភាពផ្សេងៗ ដែលកុមារមិនស្គាល់ និងមិនបានប្រាប់ រួចឱ្យកុមារថាតាម ជាក្រុមនិងទាំងអស់គ្នា
  - គ្រូបំផុសសំណួរ៖ តើកូនអាចជួយធ្វើកិច្ចការអ្វីខ្លះក្នុងគ្រួសារ?តើកូនស្រលាញ់គ្រួសាររបស់កូនដែរឬទេ?ហេតុអ្វីបានជាកូនស្រឡាញ់គ្រួសាររបស់កូន? បើកុមារមិនអាចឆ្លើយបានគ្រូត្រូវប្រាប់ (បោសសំរាម បត់ភួយមុង...។ )។នាំកុមារថាតាមជាក្រុមនិងទាំងអស់គ្នា។
- គ្រូយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចនាំកុមារអានឈ្មោះនៅរូបភាពនីមួយៗដោយគ្រូជាអ្នកចង្អុលផងប្រាប់ឈ្មោះផង និងប្រាប់ពីសកម្មភាពក្នុងគ្រួសារទាំងអស់នោះ។
- គ្រូសួរកុមារ៖ អម្បាញ់មិញកូនស្គាល់អ្វីខ្លះ? ដូច្នេះថ្ងៃនេះយើងរៀនពីមុខវិជ្ជាវិទ្យាសាស្ត្រអំពីសង្កេត គ្រួសារ។
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន (ជាក្រុមនឹងទាំងអស់គ្នា)។

**ម៉ោងទី៦ (រយៈពេល ៣០នាទី)**

## មុខវិជ្ជា៖ សិក្សាសង្គម

*** ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ៖**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី៤

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

### ចលនាមូលដ្ឋាន៖ លោត "លោតចូលកងឬរង្វង់ លោតបត់បែនតាមខ្សែកាច់ លោតរំលងឧបសគ្គ"

**១. វត្ថុបំណង៖**

-កុមាររៀបរាប់ពីរបៀបលោតចូលកងឬរង្វង់ លោតបត់បែនតាមខ្សែកាច់ លោតរំលងឧបសគ្គ បាន ច្បាស់លាស់
-កុមារបង្ហាញពីរបៀប លោតចូលកងឬរង្វង់ លោតបត់បែនតាមខ្សែកាច់ លោតរំលងឧបសគ្គ បានត្រឹមត្រូវ
-កុមារមានភាពស្វាហាប់ រហ័សរហួន បម្រុងប្រយ័ត្ន សហការគ្នា និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** -កង និង ខ្សែ

**៣. ការរៀបចំកុមារ៖** ចែកកុមារជាបីក្រុម ដោយឱ្យកុមារឈរជាជួរ (បើកុមារច្រើនអាចចែកជា៦ក្រុម ២ក្រុម ធ្វើ១សកម្មភាព)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនាំកុមារធ្វើសកម្មភាពដើរ ដោយឱ្យកុមារធ្វើចលនាដើរដូចពួកងទ័ព ជ្រុំជើងមួយកន្លែង
- គ្រូបង្ហាញសម្ភារម្តងមួយៗឱ្យកុមារប្រាប់ឈ្មោះ
- គ្រូណែនាំកុមារពីរបៀបធ្វើចលនាមូលដ្ឋាននីមួយៗ លោតចូលកងឬរង្វង់ លោតបត់បែនតាមខ្សែកាច់ លោតរំលងឧបសគ្គ
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ(បើកុមារនិយាយមិនបានគ្រូប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាបីក្រុម និង អនុវត្តតាមសកម្មភាពនីមួយៗ៖
  - ក្រុមទី១៖ លោតចូលកងឬរង្វង់ឆ្ពោះទៅតាមទីកំណត់
  - ក្រុមទី២៖លោតបត់បែនតាមខ្សែកាច់ឆ្ពោះទៅតាមទីកំណត់
  - ក្រុមទី៣៖ លោតរំលងឧបសគ្គឆ្ពោះ ទៅតាមទីកំណត់
- បន្ទាប់ពីកុមារបានលោតតាមរបៀបខាងលើរួច គ្រូឱ្យក្រុមនីមួយៗប្តូរសកម្មភាពលោតតាមសញ្ញារបស់គ្រូ
- គ្រូដើរសម្របសម្រួលតាមក្រុមទាំង៣ ដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានលោតគ្រប់សកម្មភាព
- គ្រូសួរកុមារ៖
  - តើមុននេះ កូនៗបានធ្វើចលនាអ្វីខ្លះ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - គ្រូសួរទៅកុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី?

  (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារថា ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព មានចំណងជើងមេរៀន៖ ចលនាមូលដ្ឋាន "លោត" **លោតចូលកងឬរង្វង់ លោតបត់បែនតាមខ្សែកាច់ លោតរំលងឧបសគ្គ**
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយរបស់គ្រូឬទេ? បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្ត)
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
- គ្រូនាំកុមារផ្លុំទឹកក្តៅដោយដកដង្ហើមចូល ចេញវែងៗ (កូនៗយកដៃ ធ្វើកាយវិការដូចកាន់កែវទឹកក្តៅ រួចយកមក ដាក់ជិតមាត់ ហើយផ្លុំ ដោយដកដង្ហើមចូល ចេញឱ្យវែងៗ រហូតដល់ទឹកត្រជាក់ រួចកូនញុំា គ្រូសួរកុមារថាតើកូនៗ ឆ្អែតហើយឬនៅ? កុមារឆ្លើយថាឆ្អែតហើយ) គ្រូអាចឱ្យកុមារធ្វើ ពីរ ឬបីដងក៏បាន តាមជាក់ស្តែង ។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការ បង្រៀនអនុវត្ត ដូច ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ លាងដៃមុននឹងក្រោយពេលញ៉ាំអាហារ៖(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៤ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

### សង្កេត៖ សម្ភារប្រើប្រាស់ក្នុងគ្រួសារ

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីឈ្មោះសម្ភារប្រើប្រាស់ក្នុងគ្រួសារ និងការប្រើប្រាស់បានត្រឹមត្រូវ
- កុមារបង្ហាញសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ និងការប្រើប្រាស់សម្ភារបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ សប្បាយរីករាយ និងចេះស្រឡាញ់ថែរក្សាសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ ។

**២. សម្ភារបង្រៀន៖** ផ្ទាំងរូបភាពសម្ភារប្រើប្រាស់ក្នុងគ្រួសារ (កង់ ម៉ូតូ គ្រែ អំពូលភ្លើង កង្ហារ តុ កៅអី ក្រាស់សិតសក់...)ចំនួន ៤ផ្ទាំង

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារាងពាក់កណ្តាលរង្វង់ (អក្សរ U) និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរបំផុសកុមារ៖ កូនដឹងទេ តើក្នុងគ្រួសាររបស់កូនមានសម្ភារៈប្រើប្រាស់អ្វីខ្លះ?
- គ្រូយកផ្ទាំងរូបភាពសម្ភារប្រើប្រាស់ក្នុងគ្រួសារដោយពញ្ញាក់អារម្មណ៍ឱ្យកុមារសង្កេត ហើយសួរកុមារថា តើកូនឃើញអ្វីខ្លះក្នុងរូបភាពនេះ?តើរូបភាពនេះប្រាប់កូនពីអ្វី? បើមានកុមារណាឆ្លើយត្រូវគ្រូសរសើរ កុមារដោយពាក្យសម្តី (កូនដែលបានឆ្លើយត្រូវកូនឆ្លាតមែន ហើយពូកែទៀត ប៉ុន្តែកូនឆ្លើយមិនត្រូវក៏ឆ្លាតដែរ ដែលក្លាហានហ៊ានឆ្លើយសំណួរគ្រូ)។គ្រូបញ្ជាក់ប្រាប់កុមារ៖ រូបភាពនេះ គឺជាសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ រួចនាំកុមារអាន
- គ្រូសួរកុមារ៖ កូនដឹងទេថា គ្រូនឹងឱ្យកូនៗធ្វើអ្វីជាមួយផ្ទាំងរូបភាពនេះ?
- គ្រូណែនាំកុមារពីររបៀបអនុវត្តតាមក្រុមនីមួយៗ៖
    - គ្រូឱ្យកូនៗអនុវត្តតាមក្រុមតូចៗ ហើយក្នុងក្រុមនីមួយៗត្រូវបានផ្ទាំងរូបភាពនេះមួយផ្ទាំង
    - ពេលក្រុមនីមួយៗបានផ្ទាំងរូបភាពនេះហើយ កូនត្រូវដាក់កណ្តាលវង់ ហើយនាំគ្នាសង្កេតមើលរូបទាំងអស់នោះ ហើយពិភាក្សាគ្នាលើរូបនីមួយៗថា តើឃើញអ្វីខ្លះក្នុងរូបភាព? តើសម្ភារនីមួយៗគេប្រើសម្រាប់ធ្វើអ្វី? ពេលកូននាំគ្នាសង្កេតកូនកុំដណ្តើមគ្នា កុំដកផ្ទាំងរូបភាពនេះចុះឡើង បើកូនអង្គុយបញ្ច្រាសរូបត្រូវបង្វិលផ្ទាំងរូបភាពឱ្យត្រូវមិត្តភក្តិអាចមើលឃើញច្បាស់។ ហើយបើកូនណាស្គាល់ជួយប្រាប់ទៅមិត្តភក្តិដែលគេមិនស្គាល់ផង។ ហើយកូនត្រូវរកមិត្តណាម្នាក់សម្រាប់ឡើងនិយាយប្រាប់ពីអ្វីដែលកូនបានស្គាល់ និងដឹង
    - ពេលកូនៗពិភាក្សាគ្នាចប់គ្រប់ក្រុមហើយ ត្រូវនាំគ្នាទៅអង្គុយនៅក្រុមដុំវិញដោយយកសម្ភារៈទៅរៀងៗខ្លួន។

-គ្រូឱ្យកុមារ១នាក់ ឡើងនិយាយពីអ្វីដែលត្រូវបានប្រាប់ បើនិយាយមិនបានទេឱ្យមិត្តភក្តិជួយបំពេញបន្ថែម ប៉ុន្តែបើនៅតែនិយាយមិនបានពេញលេញទេនោះគ្រូត្រូវនិយាយប្រាប់កុមារសារឡើងវិញម្តងទៀត

- រៀបចំកុមារជាក្រុមហើយអង្គុយជារង្វង់តាមទីកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូអោយតំណាងក្រុមនីមួយៗមកយកសម្ភារទៅ ហើយនាំគ្នាអនុវត្តតាមការណែនាំ
- គ្រូដើរសម្របសម្រួលកុមារគ្រប់ក្រុមទាំងអស់ ដើម្បីជួយក្រុមណាដែលមិនទាន់យល់ច្បាស់
- ពេលក្រុមនីមួយៗត្រូវបានបញ្ចប់ការងារ គ្រូឱ្យពួកគេទៅអង្គុយនៅក្រុមធំវិញដោយយកផ្ទាំងរូបភាពទៅរៀងៗខ្លួន ទុកបង្ហាញពេលឡើងរាយការណ៍
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងមកនិយាយប្រាប់មិត្តភក្តិនិងគ្រូពីលទ្ធផលដែលពួកគេបានពិភាក្សាគ្នា (ម្តងមួយក្រុមៗ) ដោយលើកផ្ទាំងរូបភាពចង្អុលបង្ហាញឈ្មោះរូបម្តងមួយៗ
- គ្រូត្រូវកែតម្រូវពាក្យដែលពួកគេនិយាយមិនទាន់បានត្រឹមត្រូវតាមអក្ខរាវិរុទ្ធ រួចនាំកុមារអាននូវពាក្យទាំងនោះទាំងអស់គ្នា។
- គ្រូសរុបពីលទ្ធផលរបស់កុមារគ្រប់ក្រុម បន្ទាប់ពីបានស្តាប់ពួកគេនិយាយចប់។ (ឧទាហរណ៍៖ គ្រូស្តាប់បានកុមារប្រាប់បានពីឈ្មោះសម្ភារៈ និងការបង្ហាញពីការប្រើប្រាស់ បានខ្លះតែប៉ុណ្ណោះ។ នៅមានឈ្មោះសម្ភារនិងការប្រើប្រាស់ផ្សេងទៀតដែលកុមារប្រាប់មិនបាន។ ដូច្នេះគ្រូត្រូវគិតគួរផ្តល់ចំណេះដឹងថ្មីបន្ថែមឱ្យពួកគេអ្វីខ្លះទៀត?)
- គ្រូត្រូវផ្តល់ចំណេះដឹងថ្មីៗបន្ថែមតាមរយៈ៖
  - គ្រូបង្ហាញផ្ទាំងរូបភាពឱ្យកុមារសង្កេតជារួម ឱ្យកុមារបានមើលឃើញទាំងអស់គ្នា។ បន្ទាប់មកគ្រូចង្អុលនឹងប្រាប់ពីឈ្មោះសម្ភារនីមួយៗ និងការប្រើប្រាស់សម្ភារ ឱ្យកុមារបានដឹង
  - គ្រូបំផុសសំណួរ៖ តើកូនត្រូវធ្វើដូចម្តេចដើម្បីថែរក្សាសម្ភារៈប្រើប្រាស់ក្នុងគ្រួសារឱ្យបានគង់វង្ស? បើកុមារមិនអាចឆ្លើយបានគ្រូត្រូវប្រាប់ ហើយនាំកុមារថាតាមជាក្រុមនិងទាំងអស់គ្នា។
- គ្រូយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចនាំកុមារអានឈ្មោះនៅរូបភាពនីមួយៗដោយគ្រូជាអ្នកចង្អុលផងប្រាប់ឈ្មោះផង ប្រាប់ពីការប្រើប្រាស់សម្ភារ និងប្រាប់ពីការថែរក្សាសម្ភារទាំងអស់នោះ ផងដែរ។
- គ្រូសួរកុមារ៖ អម្បាញ់មិញកូនស្គាល់អ្វីខ្លះ? ដូច្នេះថ្ងៃនេះយើងរៀនពីមុខវិជ្ជាវិទ្យាសាស្ត្រអំពីសង្កេតសម្ភារប្រើប្រាស់ក្នុងគ្រួសារ
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន (ជាក្រុមនឹងទាំងអស់គ្នា)។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ សិក្សាសង្គម

## គំនូរៈ គូររូបចានបាយ

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីរបៀបគូររូបចានបាយ បានត្រឹមត្រូវ
- កុមារកាន់ខ្មៅដៃគូររូបចានបាយដោយទប់លំនឹង បានត្រឹមត្រូវ
- កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់ សហការចូលរួមយ៉ាងសកម្មនិងសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ**

\+ **សម្ភារសម្រាប់គ្រូៈ**

- ផ្ទាំងក្រដាសដែលមានគូររូបចានបាយចំនួន១សន្លឹក
- ផ្ទាំងក្រដាសសដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀន(ក្រដាសផ្ទាំងធំ)
- ខ្មៅដៃចំនួន១ដើម,ស្កុតចំនួន១ដុំ។

\+ **សម្ភារសម្រាប់កុមារៈ** ផ្ទាំងក្រដាសសដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀននៅក្បាលសន្លឹកកិច្ចការគ្រប់ចំនួនកុមារ និងខ្មៅដៃគ្រប់ចំនួនកុមារ

**៣. ការរៀបចំកុមារៈ** អង្គុយរាងអក្សរ "ប" បែកកុមារជាក្រុម(អនុវត្តជាបុគ្គល)

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរៈ តើពេលញ៉ាំកូនៗដាក់បាយនឹងអ្វី?(ចម្លើយតាមគំនិតកុមារម្នាក់ៗ)
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារថាតាម(ជាក្រុមនិងទាំងអស់គ្នា)
- គ្រូបង្ហាញផ្ទាំងក្រដាសដែលមានគូររូបចានបាយរួចស្រេច ឱ្យកុមារសង្កេតនិងប្រាប់ឈ្មោះ រួចបិទនៅលើក្ដាខៀនឱ្យកុមារមើលជាគំរូ
- គ្រូបង្ហាញផ្ទាំងក្រដាសស១សន្លឹកទៀត ដែលគ្រូមិនទាន់គូររូបចានបាយឱ្យកុមារសង្កេត
- គ្រូប្រាប់កុមារៈ ផ្ទាំងក្រដាសសនេះគ្រូទុកសម្រាប់គូរ ឱ្យកូនមើលពីរបៀបគូរ។ ដូច្នេះកូននាំគ្នាចាំមើលទាំងអស់គ្នាតើគ្រូចាប់ផ្ដើមគូរពីណាទៅណា?
- គ្រូយកផ្ទាំងក្រដាស់នោះទៅបិទនៅលើក្ដាខៀន ជិតផ្ទាំងក្រដាសជាគំរូដើម្បីណែនាំពីរបៀបគូរ
- គ្រូណែនាំពីរបៀបគូរនៅលើផ្ទាំងក្រដាសសដែលបានបិទលើក្ដាខៀន ដោយគូរបណ្ដើរ និយាយប្រាប់កុមារបណ្ដើរយឺតៗ ដើម្បីឱ្យកុមារសង្កេតពីទិសនៃការគូរ។
- **គ្រូប្រាប់កុមារៈ**
  - កូនយកខ្មៅដៃគូររូបចានបាយដោយចាប់ គូរបន្ទាត់កោងពីឆ្វេងទៅស្ដាំ គូរបន្ទាត់កោងបត់ពីស្ដាំទៅឆ្វេង ហើយគូរបន្ទាត់កោងបត់មកឆ្វេងវិញ (តាមរូបគំនូរគំរូរបស់គ្រូដាក់ស្ដែង)
  - បន្ទាប់មកកូនយកខ្មៅដៃកូនគូររូបចានបាយឱ្យពេញលេញ
- គ្រូបង្ហាញផ្ទាំងក្រដាសជាសន្លឹកកិច្ចការកុមារម្នាក់ៗរួចប្រាប់កុមារ=កូនម្នាក់ៗត្រូវបានផ្ទាំងសន្លឹកកិច្ចការនេះមួយសន្លឹកនិងខ្មៅដៃមួយដើម សម្រាប់កូនគូរទៅតាមអ្វីដែលគ្រូបានបង្ហាញ
- គ្រូរៀបចំកុមារឱ្យអង្គុយទៅតាមតុដែលគ្រូបានរៀបចំឬបង្វិលកៅអី អង្គុយគូរ (តាមស្ថានភាពជាក់ស្ដែង)
- ឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅចែកគ្នាអនុវត្ត
- កុមារម្នាក់ៗនាំគ្នាអនុវត្ត គ្រូដើរសម្របសម្រួលគ្រប់ក្រុម ដើម្បីជួយកុមារណាដែលមិនទាន់ចេះកាន់ខ្មៅដៃ

គូរ និងមិនទាន់យល់ពីរបៀបគូរ និងដាក់ឈ្មោះកុមារម្នាក់ៗពីខាងក្រោមសន្លឹកកិច្ចការ
- គ្រូប្រាប់កុមារៈ ពេលកូនគូររួចហើយកូនយកខ្មៅដៃទៅទុកឱ្យគ្រូវិញ ហើយសន្លឹកកិច្ចការរបស់កូនទុកនៅរៀងៗខ្លួន។
- ពេលកុមារគូរហើយគ្រប់គ្នា គ្រូឱ្យកុមារទៅអង្គុយកន្លែងដើមជារាងអក្សរ(អ៊ុយ)វិញ
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារទៅឈរម្តងមួយក្រុមនៅខាងមុខ ហើយកាន់សន្លឹកកិច្ចការដាក់នៅត្រង់ដើមទ្រូងបង្ហាញមិត្តភក្តិ ដើម្បីឱ្យពួកគេជាអ្នកផ្ទៀងផ្ទាត់។
- គ្រូសួរកុមារដែលជាអ្នកផ្ទៀងផ្ទាត់: តើមិត្តភក្តិយើងគូរបានត្រឹមត្រូវទេ? ស្អាតទេ? បើមានកុមារណាបង្អាប់គំនូររបស់មិត្តភក្តិណាម្នាក់ គ្រូត្រូវចេះកែតម្រូវទៅជាពាក្យសម្ដីលើកទឹកចិត្តកុមារនោះវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការរបស់មិត្តភក្តិគេឱ្យគ្រូសម្រាប់ទុកដាក់តាំងស្នាដៃកុមារ។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ បុរេគណិត

## ល្បែង៖ គូសភ្ជាប់ពណ៌ដូចគ្នា

**១. វត្ថុបំណង៖**
- កុមារប្រាប់ពីរបៀបគូសភ្ជាប់ពណ៌ដែលដូចគ្នាខៀវក្រហមលឿងបៃតង តាមការណែនាំ បានត្រឹមត្រូវ
- កុមារគូសភ្ជាប់ពណ៌ដែលដូចគ្នាខៀវក្រហមលឿងបៃតង បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** ផ្ទាំងពណ៌អ៊ុតរួច ៥ផ្ទាំង ហ្វឺតសរសេរក្តារខៀន តាមដាក់ស្តែង

**៣. ការរៀបចំកុមារៈ** ឱ្យកុមារអង្គុយជារាងពាក់កណ្តាលរង្វង់ អក្សរ "U" និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)
- គ្រូបង្ហាញផ្ទាំងពណ៌ ដែលគ្រូបានរៀបចំទុកនៅតាមទីកន្លែងរួចជាស្រេច (ផ្ទាំងមានពណ៌ខៀវ ក្រហម លឿង បៃតង ដាក់ឆ្លាស់លាយគ្នាជាមួយពណ៌ផ្សេងៗទៀតនៅលើក្រដាសតែ១ និងហ្វឺត ) ហើយសួរកុមារថា តើសម្ភារទាំងអស់នេះមានអ្វីខ្លះ?
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
    - គ្រូឱ្យកូនៗលេងជាក្រុម ដោយក្នុងមួយក្រុមមានផ្ទាំងពណ៌មួយសន្លឹក និងហ្វឺត១ដើម
    - ពេលក្រុមកូនបានផ្ទាំងពណ៌នេះហើយ កូននាំគ្នាសង្កេតពណ៌ដែលដូចគ្នា កូនត្រូវយកប៊ិកហ្វឺតមកគូសវង់លើពណ៌ដែលដូចគ្នា។ ពេលកូនសង្កេត ត្រូវចែកគ្នាសង្កេតកុំដណ្តើមគ្នាណា ។
    - ពេលក្រុមកូនណាធ្វើរួចហើយ កូនត្រូវយកមកបិទលើក្តារខៀនតាមកន្លែងដែលគ្រូបានរៀបចំឱ្យ ហើយយកប៊ិកហ្វឺតទៅទុកនៅតុគ្រូវិញ
    - ក្រុមណាដែលហើយមុនគេ ត្រូវទះដៃចំនួន៣ដង
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបដែលក្រុមត្រូវធ្វើតាមការណែនាំ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- ឱ្យកុមារទៅអង្គុយនៅតាមក្រុម តាមកន្លែងដែលគ្រូបានរៀបចំ ដោយគ្រូរៀបចំកុមារជា៣ក្រុម

- ឱ្យតំណាងក្រុមឡើងមកយកសម្ភារទៅអនុវត្ត
- តាមក្រុមនីមួយៗអនុវត្ត ហើយគ្រូជាអ្នកដើរសម្របសម្រួល
- ពេលកុមារធ្វើចប់គ្រប់ក្រុមហើយ ឱ្យពួកគេទៅអង្គុយជារួមវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗ ដែលបានបិទលើក្ដារខៀន ដោយឱ្យតំណាងក្រុមនីមួយៗឡើងបង្ហាញពីអ្វីដែលក្រុមបានធ្វើ ( ធ្វើម្ដងមួយក្រុម)
- គ្រូលើកសរសើរចំពោះក្រុមដែលធ្វើរួចមុនគេ ចំពោះក្រុមធ្វើហើយក្រោយគេ គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ )
- **គ្រូសួរកុមារៈ**
  - កូនៗទាំងអស់គ្នាសប្បាយទេ ? **តើមុននេះ កូនៗបានលេងល្បែងអ្វី**? (កុមារឆ្លើយទៅតាមគំនិតរបស់គេ
  - **តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ **ថ្ងៃនេះយើងរៀនមុខវិជ្ជាបុរេគណិត មេរៀនល្បែង** "គូសភ្ជាប់ពណ៌ដែលដូចគ្នា"
- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត) **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា** ។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

*** ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ:**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី៥

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

**ចលនាចរន្ត៖ ដើរ រត់ លោត "ដើរខ្វែងជើងទៅមុខ រត់គ្រវីដៃទៅមុខ លោតជើងម្ខាងទៅមុខ រត់តិចៗទៅមុខ"**

**១. វត្ថុបំណង៖**

- កុមាររៀបរាប់ពីរបៀបធ្វើចលនានីមួយៗ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារធ្វើចលនានីមួយៗ តាមលំដាប់លំដោយបាន ត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន បម្រុងប្រយ័ត្ន រង់ចាំវេន និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** ចែកកុមារជាបីក្រុម ដោយឱ្យកុមារឈរជាជួរ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនាំកុមារធ្វើសកម្មភាពដើរ ដោយឱ្យកុមារធ្វើចលនាដើរដូចអ្នកបង្ហាញម៉ូដ
- គ្រូណែនាំកុមារពីរបៀបធ្វើចលនាចរន្តនីមួយៗ (ដើរខ្វែងជើងទៅមុខ រត់គ្រវីដៃទៅមុខ លោតជើងម្ខាងទៅមុខ រត់តិចៗទៅមុខ)
  - ដើរខ្វែងជើង៖ ដំបូងជើងស្តាំដើរបោះទៅឆ្វេងដៃ បន្ទាប់មកជើងឆ្វេងដើរបោះទៅស្តាំដៃ ដើរខ្វែងជើងទៅមុខដល់កន្លែងដែលគ្រូបានកំណត់
  - រត់គ្រវីដៃ៖ រត់ទៅមុខដោយយកដៃទាំងពីរបោះទៅមុខដូចអ្នកហែលទឹក
  - លោតជើងម្ខាងទៅមុខ ៖ ជើងឆ្វេងលើកបត់ក្រោយជើងស្តាំលោតទៅមុខ
  - រត់តិចៗទៅមុខ៖ រត់ជើងពីរតិចៗទៅមុខដល់កន្លែងដែលគ្រូបានកំណត់
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូដើរសម្របសម្រួលតាមក្រុមទាំង៣ ដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានដើរគ្រប់សកម្មភាព
- គ្រូសួរកុមារ៖
  - **តើមុននេះ កូនៗបានធ្វើចលនាអ្វីខ្លះ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - **គ្រូសួរទៅកុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារថា **ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព មានចំណងជើងមេរៀន៖ ចលនាចរន្ត ដើរ រត់ លោត" ដើរខ្វែងជើងទៅមុខ រត់គ្រវីដៃទៅមុខ លោតជើងម្ខាងទៅមុខ រត់តិចៗទៅមុខ "**
- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយរបស់គ្រូឬទេ? បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្ត)
- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា**
- គ្រូនាំកុមារផ្លុំទឹកក្តៅដោយដកដង្ហើមចូល ចេញវែងៗ (កូនៗយកដៃ ធ្វើកាយវិការដូចកាន់កែវទឹកក្តៅ រួចយកមកដាក់ជិតមាត់ ហើយផ្លុំ ដោយដកដង្ហើមចូល ចេញឱ្យវែងៗ រហូតដល់ទឹកត្រជាក់ រួចកូនញ៉ាំ គ្រូសួរកុមារថាតើកូនៗឆ្អែតហើយឬនៅ? កុមារឆ្លើយថាឆ្អែតហើយ) គ្រូអាចឱ្យកុមារធ្វើ ពីរ ឬបីដងក៏បានតាមជាក់ស្តែង ។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" ( ដំណើរការ បង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី២ )
* ទម្លាប់ល្អ៖ លាងដៃមុននឹងក្រោយពេលញ៉ាំអាហារ៖( ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១ ម៉ោងទី២ )
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៥ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

### ល្បែង៖ ផ្គុំចំនួនចំណុចទៅនឹងលេខពី១ដល់៨

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបផ្គុំចំនួនចំណុចទៅនឹងលេខពី១ដល់៨ បានត្រឹមត្រូវ
- កុមារផ្គុំចំនួនចំណុចទៅនឹងលេខពី១ដល់៨ បានត្រឹមត្រូវ
- កុមារក្លាហាន ចូលរួមសហការ ឈ្លាសវៃ រហ័សរហួន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បណ្ណចំណុចលេខពី១ដល់៨ និងបណ្ណចំនួនលេខពី១ដល់៨ ចំនួន៣ឈុត

**៣. ការរៀបចំកុមារ៖** - ឱ្យកុមារអង្គុយជារាងពាក់កណ្តាលរង្វង់ និង ជាក្រុមតូចជារង្វង់

**៤. ដំណើរការបង្រៀន៖**( អនុវត្តនៅក្នុងជំហានទី៣ )

- **គ្រូបំផុសសំណួរ៖** កូនដឹងទេថ្ងៃនេះកូនៗអាចទាយបានទេ តើបន្តិចទៀតនេះកូនទាំងអស់គ្នារៀនពីមុខវិជ្ជាអ្វី? អំពីអ្វីដែរ? ឱ្យកុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ
- គ្រូប្រាប់កុមារថ្ងៃនេះរៀនមុខវិជ្ជាៈបុរេគណិត អំពី**ផ្គុំចំនួនចំណុចទៅនឹងលេខពី១ដល់៨**
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងការនិយាយប្រាប់របស់គ្រូ រួចសួរកុមារថាតើមុននេះមានកូនណាទាយត្រូវឬទេ? បើមានកូនណាទាយត្រូវ ឱ្យកូនដទៃទៀតទះដៃសរសើរ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ( ជាក្រុម និងទាំងអស់គ្នា )
- គ្រូឱ្យកុមារក្រោកឈរទាំងអស់គ្នា ហើយលាតម្រាមដៃឆ្វេងរួចយកចង្អុលដៃស្តាំរាប់ម្រាមដៃឆ្វេងពី១ដល់៨
- គ្រូបង្ហាញសម្ភារដែលត្រូវយកឱ្យកុមារលេង
    - បង្ហាញបណ្ណចំនួនចំណុចពី១ដល់៨ រួចនាំកុមាររាប់បណ្ណចំនួនចំណុចនោះម្តង១ៗ រួចដាក់លើតុពីមុខកុមារ ធ្វើយ៉ាងណាឱ្យកុមារមើលឃើញ
    - បង្ហាញបណ្ណលេខពី១ដល់៨ រួចនាំកុមាររាប់បណ្ណលេខនោះម្តង១ៗ រួចដាក់លើតុពីមុខកុមារ ធ្វើយ៉ាងណាឱ្យកុមារមើលឃើញ ។
- គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង
    - គ្រូឱ្យកូនៗលេងទៅតាមក្រុម ហើយក្នុងក្រុមនីមួយៗត្រូវបានសម្ភារទាំងនេះមួយកញ្ចប់ ហើយសម្ភារទាំងនេះគ្រូដាក់ច្របូកច្របល់គ្នា

- នៅពេលក្រុមកូននីមួយៗបានកញ្ចប់សម្ភារនេះហើយ កូនត្រូវចាក់សម្ភារពីកញ្ចប់នៅកណ្ដាល វង់ រួចនាំគ្នាសង្កេតដើម្បីរកបណ្ណចំនួនចំណុច និងបណ្ណលេខ ដែលមានចំនួនស្មើគ្នាពី១ដល់៨ រួចយកមកផ្គុំបញ្ចូលគ្នាម្ដងមួយៗ កូនៗត្រូវចេះចែកគ្នារៀប មិនត្រូវដណ្ដើមគ្នា ត្រូវចេះរង់ចាំវេន
- ពេលក្រុមកូននីមួយៗនាំគ្នាផ្គុំបណ្ណបញ្ចូលគ្នារួចហើយនោះ កូនៗត្រូវនាំគ្នាពិនិត្យមើលឡើងវិញ ក្រែងមានរៀបខុស ។

- គ្រូឱ្យកូន១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមអ្វីដែលគ្រូប្រាប់ (បើកុមារនិយាយមិនបាន គ្រូត្រូវប្រាប់ម្ដងទៀត)
- គ្រូចែកកុមារទាំងអស់ជាក្រុម រួចទៅអង្គុយជារង្វង់នៅកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូឱ្យតំណាងក្រុមនីមួយៗយកសម្ភារទៅអនុវត្ត
- គ្រូដើរសម្របសម្រួលគ្រប់ក្រុម ហើយជួយណែនាំបន្ថែមចំពោះក្រុមណាដែលមិនទាន់យល់ច្បាស់
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗ ដោយឱ្យកុមារតាមក្រុមផ្ទៀងផ្ទាត់លទ្ធផលគ្នាទៅវិញទៅមក។ នៅពេលផ្ទៀងផ្ទាត់ក្រុមណាមួយ ត្រូវឱ្យម្ចាស់ក្រុមជាអ្នកនិយាយបង្ហាញពីអ្វីដែលក្រុមបានធ្វើ បើរៀបមិនទាន់បានត្រឹមត្រូវ ឱ្យកុមារក្រុមដទៃទៀតជួយកែលម្អ និងនាំកុមាររាប់ចំនួនទាំងនោះ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតគ្រប់ក្រុមទាំងអស់ ។ ពេលផ្ទៀងផ្ទាត់រួចគ្រប់ក្រុមហើយ គ្រូត្រូវឱ្យតំណាងក្រុមប្រមូលសម្ភារទៅទុកជូនគ្រូវិញ ហើយនាំគ្នាទៅអង្គុយក្រុមធំវិញ ។
-

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពកសាង៖ ដេរតាមទម្រង់រូបផ្ទះ

**១. វត្ថុបំណង៖**
- កុមារប្រាប់ពីរបៀបដេរតាមទម្រង់រូបផ្ទះ បានត្រឹមត្រូវ
- កុមារមានសមត្ថភាពក្នុងការដេរតាមទម្រង់រូបផ្ទះ បានត្រឹមត្រូវ។
- បណ្ដុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន មានចិត្តស្រឡាញ់ និងចូលចិត្តកំណាព្យ។

**២.សម្ភារបង្រៀន៖**
- គ្រូ៖ផ្ទាំងរូបភាពផ្ទះដែលបានដេររួចចំនួនមួយផ្ទាំង ,ផ្ទាំងរូបភាពផ្ទះដែលមិនទាន់ដេរចំនួនមួយផ្ទាំង , អំបោះមួយដុំ ១
- កុមារ៖ផ្ទាំងរូបភាពផ្ទះគ្រប់ចំនួនកុមារដែលមានដាក់ថ្ងៃខែឆ្នាំអនុវត្ត មុខវិជ្ជាចំណងជើង មេរៀននៅលើសន្លឹកិច្ចការ ,អំបោះមួយដុំ ១ គ្រប់ចំនួនក្រុមកុមារ(១ក្រុម១ដុំ)

**៣.ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរ "U" រង្វង់ជា៣ក្រុម

**៤.ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)
- គ្រូបង្ហាញរូបផ្ទះដែលបានដេររួចឱ្យកុមារប្រាប់ឈ្មោះនិងយករូបនោះបិទលើកក្ដារខៀនជាគំរូសម្រាប់កុមារសង្កេត
- គ្រូណែនាំពីរបៀបដេរតាមទម្រង់រូបផ្ទះយឺតៗដើម្បីឱ្យកុមារងាយចាប់បាន
  - គ្រូឱ្យកូនលេងជាក្រុមតូចៗហើយក្រុមនីមួយៗ ត្រូវបានផ្ទាំងរូបភាពផ្ទះមួយសន្លឹក«អំបោះមួយដុំ
  - ដំបូងកូននាំគ្នាយកផ្ទាំងរូបភាពផ្ទះមួយផ្ទាំងដាក់នៅចំកណ្ដាល និងអំបោះមួយដុំក៏ដាក់ចំកណ្ដាល

រង្វង់ក្បែរគ្នាដែរ

- បន្ទាប់មកកូនណាម្នាក់ក្នុងក្រុមយកអំបោះមួយដុំនិងផ្ទាំងរូបផ្ទះហើយយកទៅដេរតាមទម្រង់រូបផ្ទះ ប៉ុន្តែមិនឱ្យដេរខុសផ្ទៃរូបផ្ទះទេ គ្រូប្រាប់កុមារបណ្តើរធ្វើបង្ហាញបណ្តើរ ប៉ុន្តែការដេរតាមទម្រង់រូបផ្ទះ មិនចាំបាច់ដេរពេញសាច់របស់វាទេគ្រាន់តែដេរតាមទម្រង់រូបផ្ទះទៅបានហើយ
- ពេលកូននាំគ្នាដេរលើទម្រង់រូបផ្ទះតាមក្រុមនីមួយៗត្រូវចេះរង់ចាំវេនធ្វើម្នាក់ម្តងៗកុំដណ្តើមគ្នា ប្រយ័ត្នដេរខុស

- គ្រូរៀបចំកុមារជាក្រុមតូចៗរួចឱ្យទៅអង្គុយជារង្វង់នៅទីកន្លែងដែលបានរៀបចំ។
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារៈដែលគ្រូត្រៀមទុកអនុវត្ត
- គ្រូឱ្យកុមារក្នុងក្រុមនីមួយៗចាប់ផ្តើមអនុវត្តទាំងអស់គ្នាទៅតាមការណែនាំ
- គ្រូដើរសម្របសម្រួលកុមារគ្រប់ក្រុមហើយជួយកែតម្រូវក្រុមណាដែលធ្វើមិនទាន់បាន
- គ្រូប្រាប់កុមារៈបើក្រុមកូនណាធ្វើរួចហើយកូនយកទៅបិទលើការខៀនតាមកន្លែងដែលគ្រូកំណត់ឱ្យទៅតាមក្រុមនីមួយៗហើយពួកកូនត្រូវយកសម្ភារៈទៅទុកជូនគ្រូវិញនិងនាំគ្នាទៅអង្គុយនៅតាមក្រុមដំរិញ
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលដោយឱ្យតំណាងក្រុមទៅឈរនៅជិតរូបដែលបានបិទនៅលើការខៀនបន្ទាប មកឱ្យកុមារក្រុមធំសង្កេតមើលរូបនោះ ដើម្បីវាយតម្លៃ( តើដេរតាមទម្រង់រូបផ្ទះបានត្រឹមត្រូវទេ ? )
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតគ្រប់ក្រុមទាំងអស់នៅពេលផ្ទៀងផ្ទាត់មានក្រុមណាធ្វើមិនបានល្អគ្រូ មិនត្រូវស្តីបន្ទោសឡើយ ត្រូវចេះលើកទឹកចិត្តកុមារឱ្យខិតខំប្រឹងប្រែងបន្តទៀត
- គ្រូឱ្យតំណាងក្រុមនីមួយៗដករូបចេញពីក្តារខៀនជូនគ្រូរួចគ្រូដាក់ឈ្មោះក្រុមសម្រាប់ទុកដាក់តាំងស្នាដៃកុមារ
- គ្រូសួរកុមារៈថ្ងៃនេះយើងនាំគ្នារៀនមុខវិជ្ជាអ្វី ?អំពីអ្វី ?
- គ្រូប្រាប់កុមារៈថ្ងៃនេះយើងនាំគ្នារៀនមកវិជ្ជាសិក្សាសង្គម អំពីសកម្មភាពកសាង«**ដេរតាមទម្រង់រូបផ្ទះ**»
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងអ្វីដែលគ្រូបានប្រាប់ បើមានកុមារទាយត្រូវលើកសរសើរដោយប្រើពាក្យសម្តី
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀនជាក្រុមរួចទាំងអស់គ្នា។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈភាសាខ្មែរ

## សម្គាល់តួអក្សរៈ "ដ"

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីរូបរាង និងឈ្មោះអក្សរ "ដ" បានត្រឹមត្រូវ
- កុមារកំណត់បានពីរូបរាងឈ្មោះអក្សរ"ដ" និងរកពាក្យថ្មីផ្តើមចេញពីអក្សរ"ដ" បានត្រឹមត្រូវ
- កុមារក្លាហាន និងយកចិត្តទុកដាក់ ព្យាយាមក្នុងការរកពាក្យថ្មីផ្តើមពីអក្សរ"ដ"។

**២. សម្ភារបង្រៀនៈ**

- ផ្ទាំងរូបភាព ដួង ដើង ដក់
- បណ្ណពាក្យ ដួង ដើង ដក់ និងល្បះ ពូដុំដឹកដើងសសរ
- ប៊ិក ហ្វឺត ស្កុត ( កាត់រៀបចំឱ្យហើយ )

**៣. ការរៀបចំកុមារៈ** អង្គុយជាអក្សរ អ៊ុយ "ប"

**៤. ដំណើរការបង្រៀនៈ**( អនុវត្តនៅក្នុងដំហានទី៣ )

+ **រកពាក្យ និងឃ្លា**
- គ្រូបង្ហាញផ្ទាំងរូបភាព "ដួង" ដោយបិទបាំងបញ្ចេញខាងលើបន្តិច ខាងក្រោមបន្តិច ខាងឆ្វេងបន្តិច ខាងស្តាំបន្តិច រួចឱ្យកុមារទាយ
- បើករូបបង្ហាញ ដើម្បីផ្ទៀងផ្ទាត់ចម្លើយ (បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត ហើយយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចបង្ហាញបណ្ណពាក្យ "ដួង" បិទពីក្រោមរូប រួចនាំកុមារអានទាំងរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញរូបភាព"**ជើង**" ដោយលាស់មួយភ្លែតឱ្យកុមារឃើញ ហើយឱ្យកុមារទាយ បន្ទាប់មកគ្រូបង្ហាញរូបដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចបង្ហាញបណ្ណពាក្យ "**ជើង**" ហើយបិទពីក្រោមរូប និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូឱ្យកុមារមួយនាក់ចេញទៅក្រៅថ្នាក់ ហើយមើលផ្ទាំងរូបភាព "**ជក់**" រួចហើយឱ្យចូលថ្នាក់វិញ ហើយខ្សឹបពាក្យ "**ជក់**" បន្តគ្នាឱ្យបាន ០៥នាក់។ ខ្សឹបដល់អ្នកទី០៥ ត្រូវឱ្យអ្នកទី០៥ និយាយប្រាប់មិត្តភក្តិឮពាក្យអ្វី? រួចសួរអ្នកទី១វិញ ត្រឹមត្រូវឬទេ? បន្ទាប់មក គ្រូបង្ហាញរូបភាព "**ជក់**" ដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវ សរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន ហើយបង្ហាញបណ្ណពាក្យ"ជក់" និងបិទពីក្រោមរូបភាព និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញឃ្លា "**ពូជុំជីកជើងសសរ**" អានឱ្យកុមារស្តាប់រួចយកបិទពីក្រោមពាក្យ
- នាំកុមារអានរូប ពាក្យ និងឃ្លា (២ដង) គ្រូនាំកុមារអានផង និងចង្អុលផង។

+ **ស្តាប់សូរពាក្យ និងឃ្លា៖**
- គ្រូអានពាក្យ និងឃ្លាឱ្យកុមារស្តាប់ (២ឬ៣ចប់) ដើម្បីឱ្យកុមារទាយសូរ និងញែកសូរនៃពាក្យ និងឃ្លា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- សួរកុមារ តើពាក្យ និងឃ្លាដែលគ្រូបានអានអម្បាញ់មិញឮសូរដូចម្តេច? (ពេលកុមារឆ្លើយ គ្រូមិនបាច់វាយតម្លៃត្រូវឬខុសទេ)។

+ **ពិនិត្យរូបរាងអក្សរនៅក្នុងពាក្យ និងឃ្លា៖**
- គ្រូអានពាក្យ និងឃ្លាឱ្យកុមារសង្កេត (២ឬ៣ចប់) ដើម្បីឱ្យកុមារពិនិត្យរករូបរាងតួអក្សរដែលមានរាងដូចគ្នាច្រើន (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- គ្រូឱ្យកុមារដែលស្ម័គ្រចិត្តឡើងមកគូសរង្វង់ជុំវិញតួអក្សរដែលមានរាងដូចគ្នាច្រើន (ពេលកុមារឡើងមកគូសជុំវង់វិញអក្សរមានរាងដូចគ្នាច្រើន បើកុមារចង់គូសប៉ុណ្ណាឱ្យគេគូសតាមចិត្តរបស់គេ គ្រូមិនត្រូវបញ្ឈប់ឬបង្ខំគេឡើយ)
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលទាំងអស់គ្នា បើមានកុមារគូសរង់ខុសត្រូវឱ្យកុមារដទៃជួយកែតម្រូវ។ នាំកុមាររាប់ចំនួនអក្សរដែលកុមារគូសរង់ដើម្បីផ្ទៀងផ្ទាត់ពីចំនួនច្រើន។

+ ប្រាប់ឈ្មោះតួអក្សរ៖
- សួរកុមារ តើតួអក្សរដែលកូនគូសរង់ជុំវិញនៅក្នុងពាក្យ និងឃ្លានោះឈ្មោះអក្សរអ្វី? បើកុមារឆ្លើយមិនត្រូវទេនោះ គ្រូត្រូវប្រាប់រួចនាំកុមារអាន (ក្រុមរួចទាំងអស់គ្នា)
- គ្រូបង្ហាញអក្សរចល័ត "ជ" រួចសួរកុមារ អក្សរដែលគ្រូបង្ហាញនេះរាងដូចអក្សរដែលកូនបានគូសរង់នោះ

ឬទេ ? បើដូច ឈ្មោះអក្សរអ្វីដែរ ?
- គ្រូសរសេរអក្សរ"ជ" យ៉ាងធំនៅជ្រុងក្ដារខៀន ដើម្បីឱ្យកុមារសង្កេតពីទិសនៃសំណេរ
- គ្រូសួរកុមារ អក្សរដែលគ្រូសរសេរនេះតើដូចអក្សរដែលគ្រូបង្ហាញនេះដូចអក្សរដែលកូនគូសវង់ឬទេ ? ឈ្មោះអ្វី ?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនអក្សរ"ជ" នាំកុមារអានអក្សរ"ជ" (ក្រុមរួចទាំងអស់គ្នា) ឱ្យបាន២ឬ៣ដង
- គ្រូសរសេរចំណងជើងមេរៀនលើក្ដារខៀន រួចនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន (ក្រុមរួចទាំងអស់គ្នា)

+ ប្រៀបធៀបអក្សរស្រដៀង៖
- គ្រូសរសេរអក្សរ "ជ ថ ផ " នៅលើក្ដារខៀន
- គ្រូអានអក្សរ "ជ ថ ផ" ឱ្យកុមារស្ដាប់ និងសង្កេត
- សួរកុមារ តើអក្សរទាំងអស់នេះមានលក្ខណៈដូចគ្នានៅត្រង់ណាខ្លះ ? ហើយខុសគ្នាត្រង់ណាខ្លះ ?
- កុមារនិយាយប្រាប់ផងឡើងមកចង្អុលផង។

+ រកពាក្យថ្មីផ្ដើមពីអក្សរ"ជ" ៖
- គ្រូអានពាក្យ និងឃ្លាសារឡើងវិញឱ្យបានច្រើនដងដើម្បីឱ្យកុមារស្ដាប់សូរ
- ឱ្យកុមាររកពាក្យថ្មីដែលផ្ដើមពីអក្សរ"ជ"
- គ្រូសរសេរពាក្យដែលកុមាររកបាននៅលើក្ដារខៀនទាំងអស់ទាំងពាក្យត្រឹមត្រូវ និងពាក្យមិនត្រឹមត្រូវ
- នាំកុមារផ្ទៀងផ្ទាត់ដោយគ្រូអានម្ដងមួយពាក្យៗ រួចសួរកុមារតើពាក្យនេះមានអក្សរ"ជ" ឬទេ ? បើត្រឹមត្រូវគ្រូគូសវង់ជុំវិញពាក្យនោះ។ បើពាក្យខុសគ្រូមិនត្រូវធ្វើអ្វីទាំងអស់។ គ្រូធ្វើរបៀបនេះទាល់តែអស់ពាក្យដែលកុមាររកបាន។

### ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

*** ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ:**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី៦

ម៉ោងទី១ (រយៈពេលៈ ៣០នាទី)

## មុខវិជ្ជាៈចិត្តចលភាព

វំលឹក **ល្បែងចលនាៈ លោតមីកយន្តហោះ**

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី១)

**ម៉ោងទី ២ (រយៈពេល ៣០នាទី)**

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការ បង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អៈ - ត្រូវសម្អាតខ្លួនប្រាណសំលៀកបំពាក់និងសម្ភារៈប្រើប្រាស់ៈ
  - **គ្រូបំផុសសំណួរៈ** តើក្នុងមួយថ្ងៃកូនងូតទឹកប៉ុន្មានដង? ហេតុអ្វីបានជាកូនត្រូវងូតទឹក? បើខោអាវដែលកូនពាក់ប្រឡាក់ហើយនោះ តើកូនត្រូវពាក់ទៀតឬទេ? បើមិនពាក់តើកូនយកទៅទុកនៅឯណា? នៅផ្ទះ តើកូនមានសម្ភារអ្វីសម្រាប់លេង? សម្រាប់ប្រើប្រាស់? បើសម្ភារទាំងនោះប្រឡាក់ធូលីដី តើកូនត្រូវធ្វើដូចម្តេច?
  - គ្រូណែនាំកុមារបន្ថែមៈ ពេលខ្លួនកូនប្រឡាក់ធូលីឬដី កូនត្រូវងូតទឹកដុសសាប៊ូឱ្យស្អាត ហើយមួយថ្ងៃកូនត្រូវងូតទឹកបីដង គឺពេលព្រឹក ពេលថ្ងៃត្រង់ និងពេលល្ងាច។ ចំពោះសម្លៀកបំពាក់កូនត្រូវបោកឱ្យស្អាតហើយពេលប្រឡាក់កូនមិនត្រូវពាក់ទាំងប្រឡាក់ទេ នាំឱ្យមានមេរោគ ។ ចំពោះសម្ភារដែលកូនលេងឬប្រើប្រាស់ក៏ត្រូវសម្អាតឱ្យបានស្អាតជាប្រចាំរៀងរាល់ថ្ងៃដែរ មិនត្រូវប្រើប្រាស់ឬលេងទាំងប្រឡាក់នោះទេ។
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៦ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

**ល្បែងៈ ធ្វើតាមការណែនាំ (សកម្មភាពមាន៣ជំណាក់)**

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីសកម្មភាពតាមជំណាក់កាល ដោយអនុវត្ត តាមការណែនាំ បានត្រឹមត្រូវ
- កុមារ បង្ហាញពីសកម្មភាពតាមការណែនាំ៣ជំណាក់កាល បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** កែវទឹក តុ

**៣. ការរៀបចំកុមារៈ** ឱ្យកុមារអង្គុយជារាងពាក់កណ្តាលរង្វង់ អក្សរ "ប" និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញកែវទឹក និងតុ រួចសួរកុមារៈ តើសម្ភារទាំងនេះគ្រូយកមកធ្វើអ្វី? កូនជួយប្រាប់គ្រូបានទេ កូនរៀនមុខវិជ្ជាអ្វី? អំពីអ្វី?

- គ្រូប្រាប់ពីមុខវិជ្ជា និងចំណងជើងមេរៀនឱ្យកុមារស្តាប់ ។ រួចធ្វើការផ្ទៀងផ្ទាត់ទៅនឹងចម្លើយប៉ាន់ស្មានរបស់កុមារ ។ បើមានកុមារឆ្លើយត្រូវ គ្រូឱ្យកុមារទាំងអស់ទះដៃសរសើរមិត្តភក្តិទាំងនោះ
- នាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន (អានជាបុគ្គល និងទាំងអស់គ្នា)
- គ្រូបង្ហាញកែវទឹក និងតុ ឱ្យកុមារសង្កេតម្តងទៀត ដោយបង្ហាញពីទីកន្លែង គឺមានកែវទឹកលើតុ ក្រោយខ្នងកុមារចម្ងាយ៣ម៉ែត្រ
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនលេងម្តងម្នាក់ៗ តាមការដឹកនាំរបស់គ្រូ
  - **ពេលគ្រូហៅកូនណាម្នាក់ កូនត្រូវមកឈរជិតគ្រូ ហើយស្តាប់អ្វីដែលគ្រូបាននិយាយប្រាប់ រួចកូនធ្វើសកម្មភាពតាមអ្វីដែលគ្រូបានប្រាប់ ដូចជាគ្រូប្រាប់កូនទៅយកកែវទឹកមកជូនគ្រូ រួចទៅអង្គុយលើកៅអីរបស់កូនវិញ បន្ទាប់មកកូនទះដៃពីរដង**
  - ពេលមិត្តភក្តិយើងកំពុងធ្វើតាមការណែនាំរបស់គ្រូ កូនៗទាំងអស់គ្នាអង្គុយនៅកន្លែងតាមដានសកម្មភាពរបស់មិត្តភក្តិយើង ដើម្បីឱ្យដឹងថា មិត្តភក្តិយើងធ្វើត្រូវ ឬខុស
  - បើកូនណាធ្វើមិនទាន់បានត្រឹមត្រូវតាមការណែនាំរបស់គ្រូ គឺជាអ្នកចាញ់ ហើយឱ្យមិត្តភក្តិជួយកែតម្រូវ ហើយត្រូវនៅមួយកន្លែង ។ ពេលលេងចប់ អ្នកចាញ់ទាំងអស់ត្រូវធ្វើអ្វីតាមមិត្តភក្តិឱ្យធ្វើ ។
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមដំណាក់កាលនីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូនាំកុមារលេងដោយហៅកុមារម្តងម្នាក់ៗឱ្យអនុវត្តតាមការណែនាំរបស់គ្រូ ដោយហៅកុមារមកឈរជិត រួចនិយាយថា កូនទៅយកកែវទឹកនៅលើតុមកជូនគ្រូ រួចទៅអង្គុយលើកៅអីរបស់កូនវិញ បន្ទាប់មកកូនទះដៃ២ដង
- គ្រូនាំកុមារផ្ទៀងផ្ទាត់សកម្មភាពដែលកុមារម្នាក់ៗបានធ្វើ
- គ្រូលើកសរសើរចំពោះកុមារដែលអនុវត្តបានត្រឹមត្រូវ ចំពោះកុមារអនុវត្តពុំទាន់បានល្អ គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទោះបង្អាប់កុមារឡើយ
- គ្រូនាំកុមារលេងរបៀបនេះរហូតដល់ម៉ោង ។
-

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

### រំលឹក ល្បែងៈ ធ្វើសកម្មភាពតាមមេដឹកនាំ

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៤)

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ វិទ្យាសាស្ត្រ

### ល្បែងៈ ភ្លើងឆេះលើភ្នំ សម្ភារផ្ទះបាយ

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីឈ្មោះសម្ភារផ្ទះបាយ បានត្រឹមត្រូវ
- កុមារលេងល្បែងភ្លើងឆេះលើភ្នំ សម្ភារផ្ទះបាយ បានត្រឹមត្រូវ

- កុមារមានភាពឈ្លាសវៃ សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បន្ទះបណ្ណសម្ភារផ្ទះបាយ (ក្នុងមួយមុខចំនួន២សន្លឹក)

**៣. ការរៀបចំកុមារ៖** ឱ្យកុមារឈរជុំគ្នាជាបណ្តុំជាមួយគ្រូ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញបន្ទះបណ្ណសម្ភារផ្ទះបាយ ដែលគ្រូបានរៀបចំទុក រួចឱ្យកុមារប្រាប់ឈ្មោះសម្ភារផ្ទះបាយទាំងនោះ
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនលេងទាំងអស់គ្នា ហើយកូនត្រូវឈរផ្តុំគ្នាជិតគ្រូ
  - គ្រូមានបន្ទះបណ្ណសម្ភារផ្ទះបាយចំនួន២សន្លឹក ។ បន្ទះបណ្ណសម្ភារផ្ទះបាយនីមួយៗមាន២សន្លឹក គឺមួយសន្លឹកសម្រាប់គ្រូកាន់លើកបង្ហាញកូន និងមួយសន្លឹកទៀតសម្រាប់បិទនៅតាមដើមឈើសម្រាប់ឱ្យពួកកូនរត់ចូល
  - កូនៗត្រូវសង្កេតបន្ទះបណ្ណសម្ភារផ្ទះបាយដែលគ្រូបានបិទនៅតាមដើមឈើដើម្បីចំណាំទីកន្លែង ហើយចាំស្តាប់ពាក្យគ្រូនិយាយ
  - ពេលឮគ្រូនិយាយថា៖ « ភ្លើងឆេះលើភ្នំហើយ » កូនទាំងអស់គ្នាត្រូវរត់តិចៗដោយសេរី
  - ពេលឮគ្រូនិយាយថា៖ «ភ្លើងឆេះលើភ្នំកាន់តែខ្លាំងហើយ» កូនទាំងអស់គ្នាត្រូវរត់លឿនដោយសេរី
  - ពេលឮគ្រូនិយាយថា៖ «ភ្លើងរលត់ហើយ» កូនទាំងអស់គ្នាត្រូវមើលមកគ្រូលើកបន្ទះសម្ភារផ្ទះបាយ កូនត្រូវនាំគ្នារត់ទៅរកបន្ទះបណ្ណសម្ភារផ្ទះបាយដែលគ្រូបានបិទនៅលើដើមឈើ ឱ្យដូចបន្ទះបណ្ណ ដែលគ្រូបានលើក
  - បើកូនណារត់ទៅរកបន្ទះបណ្ណសម្ភារផ្ទះបាយមិនត្រឹមត្រូវតាមបន្ទះបណ្ណ ដែលគ្រូលើកបង្ហាញ គឺជាអ្នកចាញ់ ហើយមិត្តភក្តិជួយកែតម្រូវ
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមដំណាក់កាលនីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូនាំកុមារលេងទាំងអស់គ្នា ពេលលេងម្តង គ្រូត្រូវនាំកុមារផ្ទៀងផ្ទាត់ម្តង ដោយឱ្យកុមារសង្កេតបន្ទះបណ្ណសម្ភារផ្ទះបាយដែលគ្រូលើក ទៅនឹងបន្ទះបណ្ណសម្ភារផ្ទះបាយដែលកុមាររត់ទៅរក និងឱ្យពួកគេប្រាប់ឈ្មោះសម្ភារផ្ទះបាយនោះ រួចនាំកុមារថាតាម ទាំងអស់គ្នា
- គ្រូនាំកុមារលេងរបៀបនេះឱ្យបានគ្រប់សម្ភារផ្ទះបាយ
- គ្រូលើកសរសើរចំពោះកុមារដែលធ្វើបានល្អ ចំពោះកុមារដែលធ្វើមិនទាន់បានល្អគ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ )
- **គ្រូសួរកុមារ៖**
  - កូនៗទាំងអស់គ្នាសប្បាយទេ? តើមុននេះកូនៗបានលេងល្បែងអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ អំពីល្បែង " ភ្លើងឆេះលើភ្នំ សម្ភារផ្ទះបាយ "
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ សិក្សាសង្គម

*** ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

## ថ្ងៃទី៧

ម៉ោងទី១ (រយ:ពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

រំលឹក **ហាត់ប្រាណតាមបទចម្រៀង៖ កូនកំប្រុក**

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី២ ម៉ោងទី១)

ម៉ោងទី ២ (រយ:ពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការ បង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ លាងដៃមុននឹងក្រោយពេលញ៉ាំអាហារ៖(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៧ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយ:ពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

## ល្បែង៖ ពស់ព្រួយចិត្ត

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបរៀបរាងធរណីមាត្រ និងពណ៌តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមាររៀបរាងធរណីមាត្រ និងពណ៌តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារសហការជួយគ្នា យកចិត្តទុកដាក់ និងចេះរង់ចាំវេនក្នុងការរៀបរាងធរណីមាត្រ និងពណ៌។

**២. សម្ភារបង្រៀន៖**

- រូបពស់ទទេចំនួន ០១
- រូបពស់ដែលមានរៀបរាងធរណីមាត្រ និងរៀបពណ៌ចំនួន ០៣
- រាងធរណីមាត្រទាំង០៤ ដែលមាន០៤ពណ៌
- ស្កុតថ្លារៀបដាក់ក្រដាសរ៉ាមចំនួន០៤សន្លឹក។

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរ អ៊ុយ "ប" អង្គុយជារង្វង់ទៅតាមក្រុមតូចៗ (០៣ក្រុម)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហ៊ានទី៣)

- គ្រូប្រាប់ចំណងជើងមេរៀន រួចឱ្យកុមារថាតាម (ក្រុមរួចទាំងអស់គ្នា)
- គ្រូបង្ហាញរូបពស់ទទេ រាងធរណីមាត្រទាំង០៤ និងពណ៌ទាំង០៤ ឱ្យកុមារប្រាប់ឈ្មោះ
- គ្រូនិទានរឿង៖ ថ្ងៃមួយអ្នកគ្រូជិះកង់មកសាលារៀន ស្រាប់តែមកដល់ពាក់កណ្តាលផ្លូវឮសូរសំឡេងអ្វីយំ អ្នកគ្រូក៏ឈប់មើល ស្រាប់តែឃើញសត្វពស់ខ្លួនទទេហើយអង្គុយយំម្នាក់ឯង។ អ្នកគ្រូក៏សួរថា ហេតុអ្វីបានជាឯងយំ? ពស់ឆ្លើយថា "ខ្ញុំចង់ទៅរៀន ប៉ុន្តែខ្ញុំពុំមានសំលៀកបំពាក់ទេ ព្រោះឪពុកម្តាយខ្ញុំស្លាប់

អស់ហើយ៉ ពេលនោះអ្នកគ្រូក៏យករូបពស់ទទេមកបិទលើក្ដារខៀន
- សួរកុមារៈ (បើកូនណាអាចរកសំលៀកបំពាក់ឱ្យគេបានដោយយករាងធរណីមាត្រធ្វើជាសំលៀកបំពាក់ឱ្យគេ) ឱ្យកុមារស្ម័គ្រចិត្តឬណៅកុមារម្នាក់ឡើងមករៀបសំលៀកបំពាក់ឱ្យពស់
- បើករណីកុមាររៀបមិនទាន់បានតាមលំដាប់លំដោយទេនោះ អ្នកគ្រូប្រាប់ថាសំលៀកបំពាក់នេះមិនអាចទៅរៀនបានទេ ព្រោះសំលៀកបំពាក់នេះស្លៀកបានតែនៅផ្ទះទេ
- ឱ្យកុមារឡើងមកជួយកែតម្រូវ ឱ្យត្រូវតាមលំដាប់លំដោយ បើនៅតែរៀបមិនទាន់ត្រឹមត្រូវទេនោះ អ្នកគ្រូត្រូវជួយកែតម្រូវឱ្យត្រូវ (ឧទាហរណ៍៖ រៀបពណ៌ក្រហម ខៀវ ក្រហម ខៀវ...) រួចនាំកុមារអាន (ក្រុមរួចទាំងអស់គ្នា) ដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញរូបពស់មួយទៀតដែលមានរៀប (ត្រីកោណ ការេ រង្វង់...) ប្រាប់កុមារថា ពស់នេះចង់ទៅរៀនដែរ ប៉ុន្តែសំលៀកបំពាក់មិនពេញលេញទេ
- គ្រូបង្ហាញរូបពស់០២ទៀតដែលមានសំលៀកបំពាក់មិនពេញលេញ (ឧទាហរណ៍៖ បៃតង លឿង លឿង បៃតង លឿង លឿង.....) និង (រង្វង់ ត្រីកោណ ត្រីកោណ ចតុកោណកែង រង្វង់ ត្រីកោណ ត្រីកោណ ចតុកោណកែង..) ពួកគេចង់ទៅរៀនដែរ
- គ្រូប្រាប់ពីរបៀបអនុវត្តទៅតាមក្រុម៖
  - គ្រូឱ្យកូនអង្គុយជាក្រុមតូចៗ
  - ក្រុមនីមួយៗយករូបពស់នេះទៅរៀបសំលៀកបំពាក់ឱ្យគេបានពេញលេញដោយរៀបបន្តពីអ្នកគ្រូដែលបានរៀបចំរួចខ្លះហើយ និងត្រូវរង់ចាំវេនក្នុងការរៀប មិនត្រូវដណ្ដើមគ្នា
  - ពេលក្រុមណារៀបរួចហើយកូនត្រូវយកទៅបិទនៅលើក្ដារខៀនតាមកន្លែងដែលគ្រូបានប្រាប់។ ហើយក្រុមនីមួយៗរកអ្នកឡើងបង្ហាញមួយនាក់។
- ឱ្យកុមារនិយាយឡើងវិញ
- ឱ្យកុមារទៅអង្គុយតាមក្រុមនៅទីកន្លែងដែលគ្រូឱ្យអង្គុយ
- ឱ្យតំណាងក្រុមមកយកសម្ភារៈទៅចែកអនុវត្តតាមក្រុម
- ក្រុមនីមួយៗដំណើរការអនុវត្ត។ គ្រូដើរសម្របសម្រួល ជួយណែនាំបន្ថែមក្នុងករណីដែលពួកគេមិនទាន់យល់
- ឱ្យតំណាងក្រុមនីមួយៗឡើងបង្ហាញលទ្ធផលក្រុម។ បើមានក្រុមណាធ្វើមិនទាន់ត្រឹមត្រូវទេនោះគ្រូនាំកុមារជួយកែតម្រូវ
- គ្រូនាំកុមារអានរូបពស់ទាំង០៣ក្រុមតាមលំដាប់លំដោយ ដោយគ្រូប្រាប់ផងចង្អុលឱ្យចំរាង និងពណ៌ផង (ក្រុមរួចទាំងអស់គ្នា ៣ដង)
- នាំកុមារទះដៃតាមចង្វាក់លំដាប់លំដោយនៃការរៀបចំទៅតាមពស់ណាមួយ (ឧទាហរណ៍៖ លំដាប់ទី១ រាងត្រីកោណត្រូវទះដៃ ទី២ រាងការេត្រូវទះភ្លៅ និងទី៣រាងរង្វង់ត្រូវគោះជើង)។ នាំកុមារអនុវត្ត២ឬ៣ដង

***បញ្ជាក់៖*** - ចំពោះការរៀបចំរាង ឬពណ៌នៅលើរូបពស់ គ្រូត្រូវនាំកុមាររៀបផ្សេងពីនេះក៏បាន អាស្រ័យតាមការច្នៃប្រឌិតរបស់គ្រូ ប៉ុន្តែការរៀបត្រូវរៀបទៅតាមលំដាប់លំដោយ

- នៅពេលនាំកុមារនិយាយតាមលំដាប់បន្តបន្ទាប់នៅលើរូបពស់ បើចង់ឱ្យកុមារស្គាល់រាង គ្រូនាំកុមាររាប់ឈ្មោះរាង បើចង់ឱ្យកុមារស្គាល់ឈ្មោះពណ៌គ្រូនាំកុមាររាប់ឈ្មោះពណ៌ បើចង់ឱ្យកុមារស្គាល់ចំនួន គ្រូត្រូវនាំកុមាររាប់ចំនួន។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## រឿងនិទាន៖ គ្រួសារខ្ញុំ (និទាន)

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីចំណងជើងរឿង ខ្លឹមសាររឿង ប្រភេទរឿងបានត្រឹមត្រូវ ។
- កុមាររៀបរាប់ពីសកម្មភាពតួអង្គក្នុងរឿងបានត្រឹមត្រូវ ។
- កុមារយកចិត្តទុកដាក់និងចូលចិត្តស្តាប់មានបម្រុងប្រយ័ត្ន។

**២. សម្ភារបង្រៀន៖** អត្ថបទ រឿងនិទាន«គ្រួសារខ្ញុំ »

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរ អ៊ុយ "ប"

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំណួរ៖ តើថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី?ចំណងជើងរឿងអ្វី? គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀនជាក្រុមនិងទាំងអស់គ្នា
- គ្រូនិទានរឿងឱ្យកុមារស្តាប់ដោយលើកដាក់សម្លេង កាយវិការទឹកមុខទៅតាមសាច់រឿងមានពាក្យពិបាកដូចជា ពណ៌, អង្គុយ, ពិសា, រានហាល ...។ ក្រោយពីស្តាប់រឿងនេះចប់គ្រូសួរកុមារ តើក្នុងរឿងនេះមានតួអង្គនាក់ប៉ុន្មាន? តួអង្គណាខ្លះ?
  - កុមារឆ្លើយថាក្នុងរឿងនេះមានតួអង្គ៧នាក់ តា,យាយ,ពុក,ម៉ែ បងៗ និងផានិត
  - តើពុកម៉ែចៅនៅផ្ទះដែលឬទេ? គាត់ទៅណា ?តើចៅមានបងប្អូនប៉ុន្មាននាក់? តើចៅឈ្មោះអ្វីដែរអាយុប៉ុន្មាន?
  - កុមារឆ្លើយទៅតាមសំណួរដែលគ្រូសួរ...............
  - គ្រូសង្ខេបរឿងឱ្យកុមារស្តាប់ឡើងវិញ.................
- គ្រូឱ្យកុមារនិទានឡើងវិញឱ្យមិត្តភក្តិស្តាប់ រឿងនេះនិពន្ធដោយអ៊ុំៗ នៅក្រសួងអប់រំ។

រឿងនិទាន "គ្រួសារខ្ញុំ"

ព្រឹកថ្ងៃអាទិត្យនេះ ផានិតនៅចាំផ្ទះតែម្នាក់ឯង។ ផានីតកំពុងពិនិត្យមើលរូបភាពក្នុងសៀវភៅ និងដៃកាន់ខ្មៅដៃពណ៌ក្នុងគោលបំណងផាត់ពណ៌ក្នុងរូបភាពទាំងនោះនៅរានហាលខាងមុខផ្ទះ ស្រាប់តែមានលោកយាយមិនស្គាល់មុខម្នាក់បានស្រែកសួរ៖ ចៅតូច ចៅតូច ពុកម៉ែនៅផ្ទះដែរឬទេ?

ផានិត ៖ មិននៅទេ ! ពុកម៉ែគាត់ទៅស្រែតាំងពីព្រលឹមម្លេះ។

លោកយាយ ៖ តើអាចឱ្យយាយសុំចូលអង្គុយលេងបានដែរឬទេ?

ផានិត ៖ បានលោកយាយ | សូមអញ្ជើញពិសាទឹក។

លោកយាយ ៖ អរគុណណាស់ចៅ! តើចៅឈ្មោះអ្វី? អាយុ ប៉ុន្មានឆ្នាំ? មានបងប្អូនប៉ុន្មាននាក់?

ផានិត ៖ ខ្ញុំឈ្មោះផានិត អាយុ ៥ឆ្នាំ មានបងប្អូន ៣នាក់។ ម៉ែហៅខ្ញុំថាអាពៅ។

លោកយាយ ៖ បងៗ របស់ចៅទៅណាអស់ហើយ?

ផានិត ៖ គាត់ទៅផ្សារជាមួយមីងពូរបស់ខ្ញុំ។

លោកយាយ ៖ ចុះពុកម៉ែចៅឈ្មោះអ្វី?

ផានិត ៖ ពុកឈ្មោះផាន់ ម៉ែឈ្មោះលឹម។

លោកយាយ ៖ ចុះមាននរណាទៀតទេ ចៅផានិត?
ផានិត ៖ យាយតាគាត់ទៅវត្ត។
លោកយាយ ៖ ដូចនេះ គ្រួសាររបស់ចៅមានប៉ុន្មាននាក់? ផានិតរាប់ដៃស្ងាត់ៗ រួចឆ្លើយ៖ មានយាយតា ពុកម៉ែ បងៗ និងខ្ញុំ អូលោកយាយ ! គ្រួសារខ្ញុំមាន ៧នាក់ ។ លោកយាយ ៖ ចៅភ្លេច ២នាក់ ហើយ គឺមីងពូរបស់ចៅ។
ផានិត ៖ គាត់នៅផ្ទះផ្សេងទេ លោកយាយ ។ លោកយាយលាន់មាត់ថា ៖ អូ!
ផានិត ៖ នោះពុកម៉ែមកដល់ហើយ! ពុកម៉ែរបស់ផានិតគ្រាន់តែក្រឡេកឃើញភ្លាម ក៏ស្ទុះទៅឱបលោកយាយ ហើយប្រាប់ផានិតថា៖ ផានិត! កូនមកជម្រាបសួរលោកយាយភីម គាត់ជាប្អូនស្រីរបស់លោកតា និងជាមីងរបស់ពុកណា។ ផានិតឆ្លើយ៖ បាទ ហើយដើរទៅជម្រាបសួរលោកយាយ រួចកាន់សៀវភៅរត់ចូលទៅក្នុងផ្ទះដើម្បីទុកពេលឱ្យ ចាស់ៗ បានជជែកគ្នាលេងដោយសប្បាយរីករាយ។

- គ្រូបំផុសសំណួរ
- តើកូនៗស្គាល់ឈ្មោះអ្នកណាខ្លះក្នុងគ្រួសារនេះ? តើក្នុងរឿងនេះអប់រំកូនឱ្យចេះអ្វីខ្លះ.....?
- តើថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី ? ចំណងជើងមេរៀនអ្វី?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនមុខវិជ្ជាសិក្សាសង្គម ចំណងជើងរឿងនិទាន "គ្រួសារខ្ញុំ"
-

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ
## សន្ទនា៖ អ្វីៗដែលខ្ញុំចូលចិត្ត

**១. វត្ថុបំណង៖**
- កុមារប្រាប់ពីអ្វីៗដែលចូលចិត្ត បានច្បាស់លាស់
- កុមារសន្ទនាជាមួយមិត្តភក្តិពីអ្វីៗដែលគេចូលចិត្ត បានត្រឹមត្រូវ
- បណ្តុះស្មារតីកុមារឱ្យស្រឡាញ់ និងថែរក្សាសម្ភារដែលខ្លួនប្រើប្រាស់ប្រចាំថ្ងៃបានល្អប្រសើរ ប្រើប្រាស់បានយូរ

**២. សម្ភារបង្រៀន៖** គ្មាន
**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាអក្សរ U កុមារចាប់គ្នា៣ៗនាក់
**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហ៊ានទី៣)
- គ្រូប្រាប់ពីមុខវិជ្ជា និងចំណងជើងមេរៀនឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា
- គ្រូណែនាំពីរបៀបសន្ទនា៖
  - គ្រូឱ្យកូនបង្កើតក្រុម ៣នាក់ៗ ហើយឈរនៅដាច់ៗពីគ្នា
  - ក្នុងក្រុមនីមួយៗ កូនត្រូវនាំគ្នាប៉ាវរកអ្នកដែលត្រូវចាប់ផ្តើមនិយាយមុនគេ
  - កូនដែលត្រូវនិយាយមុនគេ ពេលដែលចាប់ផ្តើមដំបូង ត្រូវជម្រាបសួរមិត្តភក្តិសិន បន្ទាប់មកទើបនិយាយប្រាប់មិត្តភក្តិពីអ្វីដែលខ្លួនចូលចិត្ត និងបញ្ជាក់ពីមូលហេតុដែលចូលចិត្ត ។ បន្ទាប់មកកូនសួរទៅមិត្តភក្តិនៅស្តាំដៃបន្ត ដោយប្រើសំណួរចុះអ្នកវិញ
  - កូនដែលមិត្តភក្តិសួរ ត្រូវនិយាយដូចមិត្តភក្តិចាប់ផ្តើមដែរដំបូងដែរ រួចសួរទៅមិត្តភក្តិទៅចុងក្រោយបន្តទៀតដោយប្រើសំណួរដូចកូនមុនដែរ ។

- ដូច្នេះថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ មេរៀន សន្ទនា៖ "សម្ភារប្រើប្រាស់ប្រចាំថ្ងៃដែលស្រឡាញ់ពេញចិត្ត"

- គ្រូហៅកុមារពីរនាក់ឱ្យមកឈរជាមួយគ្រូនៅមុខមិត្តភក្តិទាំងអស់ ដើម្បីអនុវត្តជាគំរូឱ្យកុមារមើលសិន តាមរបៀបដែលបានណែនាំ ដោយគ្រូជាអ្នកចាប់ផ្តើមនិយាយមុនគេ
- គ្រូរៀបចំកុមារឱ្យឈរជាក្រុម ៣នាក់ៗនៅដាច់ពីគ្នា
- គ្រូឱ្យកុមារចាប់ផ្តើមអនុវត្ត គ្រប់ក្រុមក្នុងពេលតែមួយ
- គ្រូដើរសម្របសម្រួលតាមក្រុម ដោយធ្វើយ៉ាងណាត្រូវស្តាប់កុមារនិយាយ ឱ្យបានគ្រប់ក្រុមដើម្បីជួយកែលម្អនូវពាក្យណាដែលពួកគេនិយាយមិនបានត្រឹមត្រូវតាមអក្ខរាវិរុទ្ធ
- គ្រូឱ្យកុមារចាប់ក្រុម៣នាក់ៗសារថ្មីទៀត ហើយអនុវត្តការសន្ទនាដូចក្រុមមុនដែរ (បើក្នុងករណីនៅសល់ម៉ោង)
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមដំណាក់កាលនីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូសួរកុមារ៖
- កូនៗទាំងអស់គ្នាសប្បាយទេ ? តើមុននេះ កូនៗបានសន្ទនាពីអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ សន្ទនាអំពី " អ្វីៗដែលខ្ញុំចូលចិត្ត"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូច
- ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត)
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

**ម៉ោងទី៦ (រយៈពេល ៣០នាទី)**

## មុខវិជ្ជា៖ ចិត្តចលភាព

### វំលឹក ល្បែង៖ ក្រងកៅស៊ូកងជាខ្សែ

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី២ ម៉ោងទី៦)

# ថ្ងៃទី៨

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

រំលឹក **ហាត់ប្រាណតាមរឿងនិទានៈ មេមាន់នាំកូនទៅរកចំណី**

( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៣ ម៉ោងទី១ )

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" ( ដំណើរការ បង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី២ )
* ទម្លាប់ល្អៈ លាងដៃមុននឹងក្រោយពេលញ៉ាំអាហារៈ( ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២ )
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៨ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

### កំណាព្យៈ ពិធីបុណ្យអុំទូក

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីដើង និងអត្ថន័យនៃកំណាព្យ«ពិធីបុណ្យអុំទូក» បានត្រឹមត្រូវ។
- កុមារមានសមត្ថភាពសូត្រកំណាព្យត្រូវតាមវាក្យស័ព្ទនិងលំនាំបទ  បានត្រឹមត្រូវ។
- បណ្តុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន  មានចិត្តស្រឡាញ់  និងចូលចិត្តកំណាព្យ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** កុមារអង្គុយជារាងអក្សរ«ប»

**៤. ដំណើរការបង្រៀនៈ**( អនុវត្តនៅក្នុងជំហានទី៣ )

- ថ្ងៃនេះគ្រូនឹងយកមេរៀនកំណាព្យមួយមកបង្រៀនកូនៗទាំងអស់គ្នា
- គ្រូសូត្រកំណាព្យឱ្យកុមារស្តាប់មួយចប់សិនដើម្បីឱ្យកុមារយល់អត្ថន័យនៃកំណាព្យ
- គ្រូឱ្យកុមារអានអត្ថបទ និងរកពាក្យពិបាក គ្រូសួរកុមារ តើកំណាព្យដែលគ្រូបានសូត្រគេចង់ និយាយពីអ្វី?
  - គ្រូប្រាប់និងពន្យល់ពាក្យពិបាកមាន **ផៅញាតិ** មានន័យថាបងប្អូន  **ខ្មីឃ្មាត**  មានន័យថាការខិតខំប្រឹងប្រែង
  - អត្ថបទកំណាព្យនេះគឺចង់ឱ្យកុមារដឹងពីពេលវេលាប្រារព្ធពិធីបុណ្យប្រពៃណីខ្មែរ
- គ្រូនាំកុមារសូត្រកំណាព្យឃ្លាទី១ ឱ្យបានមួយចប់គ្រប់ៗគ្នា បន្ទាប់មកកុមារសូត្រឃ្លាទី២
- ពេលកុមារសូត្រកំណាព្យ ឃ្លាទី១ ឃ្លាទី២ រួចឱ្យកុមារសូត្រឃ្លាទាំងពីររួមបញ្ចូលគ្នា
- គ្រូនាំកុមារសូត្រឃ្លាបន្តបន្ទាប់តាមរបៀបខាងលើរហូតដល់ចប់នៃអត្ថបទកំណាព្យ

- គ្រូឱ្យកុមារសូត្រកំណាព្យសាឡើងវិញរួមគ្នា ១ឬ២ចប់
- គ្រូសួរកុមារ តើអម្បាញ់កូនរៀនមុខវិជ្ជាអ្វី ?មេរៀនអ្វី ?អ្នកនិពន្ធឈ្មោះអ្វី ?( កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ )អរគុណកូនៗដែលបានឆ្លើយ តើកូនចង់ដឹងទេថាថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី ?មេរៀនអ្វី ?
- គ្រូប្រាប់ថា ថ្ងៃនេះយើងរៀនមុខវិជ្ជាៈភាសាខ្មែរ មេរៀនៈកំណាព្យ«**ពិធីបុណ្យអុំទូក**»អ្នកនិពន្ធដោយលោកអ៊ំនៅក្រសួងអប់រំ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម ទាំងអស់គ្នា

**អត្ថបទកំណាំព្យ«ពិធីបុណ្យអុំទូក»(បទកាកគតិ)**

| | | |
|---|---|---|
| មិត្តអើយឃើញទេ | នៅក្នុងទន្លេ | មានទូកច្រើនក្រៃ |
| ខ្លះអុំខ្លះចែវ | បង្ហាញប្ញទ្ធិដៃ | គំរប់បីថ្ងៃ |
| | ប្រពៃណីជាតិ ។ | |
| ទំនៀមទំលាប់ | ខែដប់មួយជាប់ | អារម្មណ៍ផៅញាតិ |
| ធ្វើបុណ្យអុំទូក | ប្រជាព្រោងព្រាត | គ្រប់គ្នាខ្មីឃ្មាត |
| | ចូលរួមសប្បាយ ។ | |

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

### ចម្រៀងៈ បណ្តាំអ្នកគ្រូផ្តាំទៅ (ពេលទី១)

**១. វត្ថុបំណងៈ**

-កុមារប្រាប់បានពីរបៀបច្រៀង និងធ្វើកាយវិការតាមបទច្រៀង បានត្រឹមត្រូវ

-កុមារច្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀងបានត្រឹមត្រូវ

-កុមារស្រឡាញ់ចូលចិត្តច្រៀង និងសហការគ្នាដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** កុមារអង្គុយជាអក្សរ "ប" (ក្រោកឈរទាំងអស់គ្នា)

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣ )

- គ្រូបំផុសសំណួរៈ មុនពេលកូនចេញទៅផ្ទះគ្រូតែងនិយាយប្រាប់អ្វីខ្លះ ? ពេលកូនទៅដល់ផ្ទះកូនឃើញឪពុកម្តាយកូនត្រូវធ្វើដូចម្តេច ? កុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ គ្រូសរុបចំណងជើងដែលកុមារបានទាយ
- គ្រូប្រាប់កុមារៈ ថ្ងៃនេះគ្រូបង្រៀនកូនលើមុខវិជ្ជាសិក្សាសង្គម អំពីចម្រៀង**(បណ្តាំអ្នកគ្រូផ្តាំទៅ)**
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងអ្វីដែលគ្រូបានប្រាប់ ដោយនិយាយថា(អម្បាញ់មិញ មានកូនណាបានទាយត្រូវមុខវិជ្ជា និងចំណងជើងមេរៀន  កូនឆ្លាតមែន ពូកែទាយណាស់។ ប៉ុន្តែកូនដែលទាយមិនទាន់ត្រឹមត្រូវក៏ក្លាហានដែរ ហ៊ានឆ្លើយសំណួររបស់គ្រូ ដូច្នេះថ្ងៃក្រោយ កូនព្យាយាមឆ្លើយទៀតណា។
- គ្រូប្រាប់ពីមុខវិជ្ជា និងចំណងជើងមេរៀន រួចឱ្យកុមារថាតាម ជាក្រុម និងទាំងអស់គ្នា
- គ្រូច្រៀង និង ធ្វើកាយវិការឱ្យកុមារស្តាប់ និង មើលមួយចប់បទចម្រៀងសិន
- គ្រូនាំកុមារអានពាក្យពិបាក (បណ្តាំ,ផ្តាំ) ជាក្រុម និងទាំងអស់គ្នា

- គ្រូសួរកុមារៈ កូនដឹងទេថា តើចម្រៀង ដែលគ្រូច្រៀងឱ្យស្តាប់ អម្បាញ់មិញ គេចង់និយាយពីអ្វី? បើកុមារមិនអាចឆ្លើយបាន គ្រូត្រូវប្រាប់ពីអត្ថន័យ នៃបទចម្រៀងដោយប្រាប់កុមារថាៈ ចម្រៀងនេះមានន័យថា ឱ្យកូនៗទាំងអស់គ្នាចេះគោរពចាស់ទុំ (ជំរាបសួរ ជម្រាបលា អរគុណ)
- គ្រូអានអត្ថបទចម្រៀងជាពាក្យរាយឱ្យកុមារស្តាប់ម្តងមួយឃ្លាៗ រួចឱ្យកុមារអានតាមម្តងមួយក្រុមៗ រួចទាំងអស់គ្នា
- គ្រូធ្វើជាសំឡេង ណយៗ ណយៗ ណយៗ ទៅតាមលំនាំបទចម្រៀងឱ្យកុមារស្តាប់មួយចប់បទចម្រៀងសិន
- គ្រូនាំកុមារធ្វើជាសំឡេង ណយៗ ណយៗ ណយៗ ទៅតាមលំនាំបទចម្រៀងដែលគ្រូបានធ្វើឱ្យ ស្តាប់ (ម្តងមួយក្រុម ៗ រួចទាំងអស់គ្នា)ឱ្យបាន ២ចប់
- គ្រូនាំកុមារច្រៀង និង ធ្វើកាយវិការតាមបទចម្រៀង មួយឃ្លាម្តងៗ រហូតចប់បទចម្រៀង(ម្តងមួយក្រុមៗ រួចទាំងអស់គ្នា ឱ្យបាន ១ ឬ ២ ចប់
- គ្រូច្រៀងតិចៗ ម្តងមួយឃ្លាៗ កុមារច្រៀងឮៗម្តងមួយឃ្លាៗ តាមគ្រូរហូតចប់បទចម្រៀង(ម្តងមួយក្រុមៗ រួចទាំងអស់គ្នា ) ឱ្យបាន២ចប់
- គ្រូនាំកុមារច្រៀង និង ធ្វើកាយវិការតាមបទចម្រៀងសាឡើងវិញឱ្យបាន ២ចប់ ទៅ ៣ចប់ ទាំងអស់គ្នា
- របៀបធ្វើកាយវិការៈ
- ខ្លឹមសារចម្រៀងៈ

បណ្តាំដែលអ្នកគ្រូផ្តាំទៅ ថាឱ្យកូនពៅជម្រាបសួរចាស់ៗ
ម្តេចឡើយក៏ពៅមិនចាំច្បាស់ ភ្លេចអស់សំពះភ្លេចថាអរគុណ
ក្រោយៗសំពះចាស់ៗមុន « ២ដង » រួចថាអរគុណមុនទទួលអ្វីៗ

បន្ទរៈ ស្តាយណាស់អ្នកគ្រូខំចែកចំណី « ២ដង » ព្រោះតែថ្លាថ្លៃភ្លេចបណ្តាំអ្នកគ្រូ « ២ដង »

- **របៀបធ្វើកាយវិការៈ**
- បណ្តាំដែលអ្នកគ្រូផ្តាំទៅៈ ដៃឆ្វេងច្រត់ចង្កេះ ម្រាមដៃស្តាំចង្អុលរទៅរមក
- ថាឱ្យកូនពៅជម្រាបសួរចាស់ៗៈ ដៃទាំង២ផ្គុំសំពះ (សំពះត្រឹមចង្ការកើម) ហើយឱនឬក៏បន្ទន់បន្តិច
- ម្តេចឡើយក៏ពៅមិនចាំច្បាស់ៈ ម្រាមចង្អុលដៃទាំងពីរមកត្រចៀក ហើយរទៅឆ្វេងទៅស្តាំ
- ភ្លេចអស់សំពះភ្លេចថាអរគុណៈ ដៃទាំង២ផ្គុំសំពះ រួចលាបាតដៃទាំង២ជាកាយវិការទទួលអ្វីមួយ
- ក្រោយៗសំពះចាស់ៗមុន « ២ដង » ៖ ម្រាមចង្អុលដៃទាំងពីរមកត្រចៀក ហើយរទៅឆ្វេងទៅស្តាំ
- រួចថាអរគុណមុនទទួលអ្វីៗ ៖ ដៃទាំង២ផ្គុំសំពះ រួចលាបាតដៃទាំង២ជាកាយវិការទទួលអ្វីមួយ
- ស្តាយណាស់អ្នកគ្រូខំចែកចំណី ៖ រួចលាបាតដៃទាំង២ជាកាយវិការទទួលអ្វីមួយ(២ដង)
- ព្រោះតែថ្លាថ្លៃភ្លេចបណ្តាំអ្នកគ្រូ ៖ ដៃទាំង២ខ្វែងគ្នា ដោយយកមកឱបទ្រូង បន្ទាប់ម្រាមចង្អុលដៃទាំងពីរចង្អុលមកត្រចៀក

អត្ថបទចម្រៀង

បណ្តាំដែលអ្នកគ្រូផ្តាំទៅ ថាឱ្យកូនពៅជម្រាបសួរចាស់ៗ
ម្តេចឡើយក៏ពៅមិនចាំច្បាស់ ភ្លេចអស់សំពះភ្លេចថាអរគុណ
ក្រោយៗសំពះចាស់ៗមុន « ២ដង » រួចថាអរគុណមុនទទួលអ្វីៗ។

បន្ទរៈ ស្តាយណាស់អ្នកគ្រូខំចែកចំណី « ២ដង »ព្រោះតែថ្លាថ្លៃភ្លេចបណ្តាំអ្នកគ្រូ « ២ដង »

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

## សន្ទនា៖ មុខរបរសមាជិកគ្រួសារកុមារម្នាក់ៗ

**១. វត្ថុបំណង៖**

- កុមារនិយាយបានពីមុខរបរសមាជិកគ្រួសារម្នាក់ៗ បានត្រឹមត្រូវ។
- កុមារពិភាក្សាពីមុខរបរសមាជិកគ្រួសារម្នាក់ៗ បានត្រឹមត្រូវ។
- បណ្តុះទម្លាប់កុមារឱ្យយកចិត្តទុកដាក់ មានអំណត់ និងចូលរួមសហការយ៉ាងសកម្មជាមួយគ្រូ និងកុមារដទៃ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជាអក្សរ "U" កុមារអង្គុយជាដៃគូ៣នាក់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់ពីមុខវិជ្ជានិងចំណងជើងមេរៀនឱ្យកុមារថាតាមជាក្រុមនិងទាំងអស់គ្នា។
- គ្រូណែនាំពីរបៀបសន្ទនា
  - គ្រូឱ្យកុមារបង្កើតក្រុមដៃគូ៣នាក់ៗហើយឈរនៅដាច់ៗពីគ្នា។
  - ក្នុងក្រុមនីមួយៗកូនត្រូវនាំគ្នាប៉ាវរកអ្នកដែលត្រូវចាប់ផ្តើមនិយាយមុនគេ។
  - កូនដែលត្រូវនិយាយមុនគេពេលចាប់ផ្តើមដំបូងត្រូវជម្រាបសួរមិត្តភក្តិសិន។បន្ទាប់មកទើបនិយាយប្រាប់មិត្តភក្តិពីមុខរបរសមាជិកគ្រួសារម្នាក់ៗ(តើនៅក្នុងគ្រួសាររបស់កូនប្រកបមុខរបរអ្វី?ចុះប៉ារបស់កូនប្រកនមុខរបរអ្វី?ហើយម៉ាក់របស់កូនធ្វើការងារអ្វីដែរ?ចុះបងប្អូនរបស់កូនធ្វើអ្វីដែរ?) បន្ទាប់មកសួរទៅមិត្តភក្តិនៅស្តាំដៃបន្ត ដោយប្រើសំណួរបុះអ្នកវិញ?
  - កូនដែលមិត្តភក្តិសួរត្រូវនិយាយដូចមិត្តភក្តិចាប់ផ្តើមដំបូងដែរ។រួចក៏សួរទៅមិត្តភក្តិនៅចុងក្រោយបន្តទៀតដោយប្រើសំណួរដូចកូនមុនដែរ
- គ្រូហៅកុមារ២នាក់ឱ្យមកឈរជាមួយគ្រូនៅមុខមិត្តភក្តិទាំងអស់គ្នាដើម្បីអនុវត្តជាគំរូឱ្យកុមារមើលសិនតាមរបៀបដែលបានណែនាំដោយគ្រូជាអ្នកចាប់ផ្តើមនិយាយមុនគេ
- គ្រូរៀបចំកុមារឱ្យឈរជាក្រុមដៃគូ ៣ នាក់នៅដាច់ៗពីគ្នា
- គ្រូឱ្យកុមារចាប់ផ្តើមអនុវត្តគ្រប់ក្រុមក្នុងពេលតែមួយ
- គ្រូដើរសម្របសម្រួលតាមក្រុមដោយធ្វើយ៉ាងណាត្រូវស្តាប់កុមារនិយាយឱ្យបានគ្រប់ក្រុមដើម្បីជួយកែសម្រួលនៅពាក្យណាដែលពួកគេនិយាយមិនបានត្រឹមត្រូវតាមអក្ខរាវិរុទ្ធ
- គ្រូឱ្យកុមារចាប់ក្រុមដៃគូ៣នាក់ៗសារថ្មីទៀតហើយអនុវត្តការសន្ទនាដូចក្រុមមុនដែរ បើក្នុងករណីនៅសល់ម៉ោង

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

**∗ ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ៖**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

**ថ្ងៃទី៩**

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

រំលឹក **ចលនាមូលដ្ឋាន៖ លោត (លោតចូល កង ឬរង្វង់ លោតបត់បែនតាមខ្សែកាច់ លោតរំលងឧបសគ្គ)**

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៤ ម៉ោងទី១)

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការ បង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ លាងដៃមុននឹងក្រោយពេលញ៉ាំអាហារ៖(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៩ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

រំលឹក **សន្ទនា៖ មុខរបរសជីកគ្រួសារកុមារម្នាក់ៗ**

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៨ ម៉ោងទី៥)

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

**គំនូរ៖ គំនូសផ្កាមស្លឹកឈើ**

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបគូសផ្កាមស្លឹកឈើលើក្រដាសបានត្រឹមត្រូវ
- កុមារកាន់ខ្មៅដៃគូសផ្កាមស្លឹកឈើលើក្រដាសបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ មានបម្រុងប្រយ័ត្ន ក្នុងការគូសដោយសប្បាយរីករាយ

**២. សម្ភារបង្រៀន៖**

+ **សម្ភារសម្រាប់គ្រូ៖**
  - ផ្ទាំងក្រដាសដែលមានគូសផ្កាមស្លឹកឈើចំនួន១ផ្ទាំង(ផ្ទាំងធំ)
  - ក្រដាសសចំនួន ១សន្លឹក ដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំអនុវត្តមុខវិជ្ជា និងចំណងជើងមេរៀន
  - ផ្ទាំងក្រដាសដែលមានគូសផ្កាមស្លឹកឈើមិនទាន់គូសភ្ជាប់ចំនួន១សន្លឹក(ក្រដាសផ្ទាំងធំ)
  - ខ្មៅដៃចំនួន១ដើម,ស្លឹកឈើចំនួន១សន្លឹក,ស្កុតចំនួន១ដុំ។
+ **សម្ភារសម្រាប់កុមារ៖**

- ផ្ទាំងក្រដាស់សដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀននៅក្បាលសន្លឹកកិច្ចការ គ្រប់ចំនួនកុមារ
- ខ្មៅដៃគ្រប់ចំនួនកុមារ និងស្លឹកឈើគ្រប់ចំនួនកុមារ

**៣. ការរៀបចំកុមារ៖** អង្គុយរាងអក្សរ "ប" អង្គុយជាជួរតាមតុ ឬកៅអី

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូកាន់ស្លឹកឈើ១សន្លឹក ហើយសួរកុមារថា តើនៅដៃគ្រូមានកាន់អ្វី? ឆ្លើយតាមគំនិតរបស់កុមារម្នាក់ៗ
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារអានតាមជាក្រុមនិងទាំងអស់គ្នា
- គ្រូបង្ហាញផ្ទាំងគំនូសផ្ដាមស្លឹកឈើឱ្យកុមារសង្កេតនិងប្រាប់ឈ្មោះរួចបិទនៅលើក្ដាខៀនជាគំរូ
- គ្រូបង្ហាញផ្ទាំងក្រដាសស១សន្លឹកនិងស្លឹកឈើ១សន្លឹកឱ្យកុមារសង្កេត រួចប្រាប់ឈ្មោះ។ បន្ទាប់មកយកបិទលើក្ដាខៀនជិតផ្ទាំងគំនូសផ្ដាមស្លឹកឈើដែលជាគំរូ
- គ្រូសួរកុមារ៖ តើកូនដឹងទេថា គ្រូយកសម្ភារនេះមកធ្វើអ្វី?
- គ្រូប្រាប់កុមារ៖ គ្រូយកសម្ភារនេះមកគូសផ្ដាមស្លឹកឈើឱ្យកូនៗមើល ដូច្នេះកូនៗទាំងអស់គ្នាចាំនាំគ្នាមើល តើគ្រូគូសពីណាទៅណា?បន្តិចទៀតគ្រូឱ្យកូនគូសម្នាក់មួយៗ
- គ្រូយកផ្ទាំងក្រដាស់នោះទៅបិទនៅលើក្ដាខៀន ជិតផ្ទាំងក្រដាសជាគំរូដើម្បីណែនាំពីរបៀបគូសផ្ដាម
- គ្រូណែនាំពីរបៀបគូសផ្ដាមដោយគូរបណ្ដើរ និយាយប្រាប់កុមារបណ្ដើរយឺតៗ ហើយឈរមិនឱ្យបាំងកុមារណាម្នាក់ឡើយ ដើម្បីឱ្យកុមារសង្កេតពីទិសនៃការគូសផ្ដាម។
- ពេលណែនាំពីរបៀបគូសផ្ដាមស្លឹកឈើគ្រូនិយាយប្រាប់កុមារថា៖
  - កូនយកយកក្រដាសស១សន្លឹក ដាក់លើតុឬកៅអី រួចកូនយកស្លឹកឈើដាក់ពីលើក្រដាសនោះក្រោមអក្សរដែលគ្រូសរសេរ(គ្រូបង្ហាញកន្លែងដែលកុមារត្រូវដាក់ស្លឹកឈើ)
  - បន្ទាប់មកកូនយកដៃឆ្វេងទប់ស្លឹកឈើ រួចកូនយកខ្មៅដៃគូសតាមរាងស្លឹកឈើឱ្យបានពេញលេញ រួចកូនយកស្លឹកឈើនោះចេញពីក្រដាស ដូចដែលគ្រូធ្វើបង្ហាញកូន។
- គ្រូឱ្យកុមារស្ម័គ្រចិត្ត១នាក់និយាយប្រាប់ឡើងវិញ បើកុមារទាំងអស់មិនទាន់យល់ច្បាស់ទេនោះ គ្រូត្រូវនិយាយប្រាប់កុមារសាឡើងវិញម្តងទៀត។
- គ្រូរៀបចំកុមារឱ្យអង្គុយទៅតាមតុដែលគ្រូបានរៀបចំឬបង្វិលកៅអី អង្គុយគូសផ្ដាមស្លឹកឈើរៀងៗខ្លួន
- ឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារដែលគ្រូបានរៀបចំទុកទៅចែកគ្នាអនុវត្ត
- កុមារម្នាក់ៗនាំគ្នាអនុវត្ត គ្រូដើរសម្របសម្រួលគ្រប់ក្រុម ដើម្បីជួយកុមារណាដែលមិនទាន់ចេះកាន់ខ្មៅដៃគូរ និងមិនទាន់យល់ពីរបៀបគូសផ្ដាម និងដាក់ឈ្មោះកុមារម្នាក់ៗពីខាងក្រោមសន្លឹកកិច្ចការ
- គ្រូប្រាប់កុមារ៖ ពេលកូនគូសផ្ដាមរួចហើយកូនយកខ្មៅដៃទៅទុកឱ្យគ្រូវិញ ហើយសន្លឹកកិច្ចការរបស់កូនទុកនៅរៀងៗខ្លួន។
- ពេលកុមារគូសផ្ដាមហើយគ្រប់គ្នា គ្រូឱ្យកុមារទៅអង្គុយកន្លែងដើមជារាងអក្សរ(អ៊ុយ)វិញ
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារទៅឈរម្តងមួយក្រុមនៅខាងមុខ ហើយកាន់សន្លឹកកិច្ចការដាក់នៅត្រង់ដើមទ្រូងបង្ហាញមិត្តភក្តិ ដើម្បីឱ្យពួកគេជាអ្នកផ្ទៀងផ្ទាត់។
- គ្រូសួរកុមារដែលជាអ្នកផ្ទៀងផ្ទាត់៖ តើមិត្តភក្តិយើងគូសផ្ដាមបានត្រឹមត្រូវទេ? ស្អាតទេ? ដូចស្លឹកឈើឬទេ? បើមានកុមារណាបង្អាប់គូសផ្ដាមរបស់មិត្តភក្តិណាម្នាក់ គ្រូត្រូវចេះកែតម្រូវទៅជាពាក្យសម្ដីលើក

ទឹកចិត្តកុមារនោះវិញ

- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការរបស់មិត្តភក្តិគេឱ្យគ្រូសម្រាប់ទុកដាក់តាំងស្នាដៃកុមារ។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

## រំលឹក ល្បែង៖ ពស់ព្រួយចិត្ត

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៧ ម៉ោងទី៣)

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

**✱ ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

## ថ្ងៃទី១០

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

រំលឹក **ចលនាចរន្តៈ ដើរ រត់ លោត (ដើរខ្វែងជើងទៅមុខ រត់គ្រវីដៃទៅមុខ លោតជើងម្ខាង រត់តិចៗទៅមុខ)**

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៥ ម៉ោងទី១)

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការ បង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អៈ លាងដៃមុននឹងក្រោយពេលញុំាអាហារៈ(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១០ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ បុរេគណិត

### ល្បែងៈ ទៅផ្សារទិញសម្ភារផ្ទះបាយចំនួន ១ដល់៨

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីចំនួនសម្ភារផ្ទះបាយពី១ដល់៨ បានត្រឹមត្រូវ
- កុមាររាប់ចំនួនសម្ភារផ្ទះបាយពី១ដល៨ បានត្រឹមត្រូវ
- កុមារសហការជួយគ្នា យកចិត្តទុកដាក់ អំណត់ព្យាយាម លេងដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ** បណ្ណរូបភាពខ្ទះចំនួន១ ឆ្នាំងចំនួន២ វែកឆាចំនួន៣ កាំបិតចំនួន៤ ចានបាយចំនួន៥ ចានចង្កឹះចំនួន៦ ស្លាបព្រាចំនួន៧ សមចំនួន៨

**៣. ការរៀបចំកុមារៈ** កុមារអង្គុយជាអក្សរ "ប" កុមារឈរផ្គុំគ្នា

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហ៊ានទី៣)

- គ្រូសួរកុមារៈកូនៗធ្លាប់ទៅផ្សារជាមួយឪពុកម្តាយដែរទេ?បើកូនៗធ្លាប់បានទៅផ្សារជាមួយឪពុកម្តាយគាត់ទិញអ្វីខ្លះ?ហើយកូនៗប្រាប់គ្រូបានទេ?ដូច្នេះថ្ងៃនេះកូនទៅផ្សារជាមួយគ្រូដើម្បីទិញសម្ភារផ្ទះបាយទាំងនោះបានដែរឬទេ? ថាតើកូនៗចង់រៀនមុខវិជ្ជាអ្វី? អំពីអ្វី? ឱ្យកុមារឆ្លើយតាមការគិតរបស់គេម្នាក់ៗ
- គ្រូប្រាប់កុមារពេលនេះ គ្រូចង់បង្រៀនកូនពី មុខវិជ្ជាបុរេគណិត អំពីល្បែង ទៅផ្សារទិញសម្ភារក្នុងផ្ទះបាយពី១ដល់៨ តើកូនៗចង់រៀនជាមួយគ្រូឬទេ?
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនិងការនិយាយប្រាប់របស់គ្រូរួចសួរកុមារថា តើអម្បាញ់មិញមានកូនណាចង់រៀនជាមួយគ្រូទេ? កូនដែលមានគំនិតដូចគ្រូគឺកូនឆ្លាតនិងពូកែឈ្លាសវៃមែន។
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន(ជាក្រុមនិងទាំងអស់គ្នា)

- គ្រូដាក់បណ្ណសម្ភារក្នុងផ្ទះបាយលើតុពីមុខកុមារ ហើយហៅកុមារ១នាក់ឬ២នាក់ឱ្យមកលើកបង្ហាញបណ្ណសម្ភារក្នុងផ្ទះបាយដោយប្រាប់ពីឈ្មោះនិងចំនួនទៅតាមបណ្ណនីមួយៗ
- **គ្រូណែនាំពីរបៀបលេង**
  - គ្រូឱ្យកូនៗលេងទាំងអស់គ្នាជាមួយគ្រូ ហើយសម្ភារទាំងអស់នេះជារបស់គ្រូ ពេលគ្រូនិយាយថាថ្ងៃនេះគ្រូចង់ទៅផ្សារទិញសម្ភារផ្ទះបាយ តើកូនៗណាចង់ទៅខ្លះ? កូនៗនាំគ្នាឆ្លើយរួចមកឈរពីមុខគ្រូហើយចាំស្តាប់គ្រូប្រាប់
  - ពេលគ្រូថាមកយើងនាំគ្នាទៅផ្សារដូច្នេះកូនៗនាំគ្នាដើរជាមួយគ្រូទាំងអស់គ្នា។ ហើយកុំដើរចោលគ្រូខ្លាចវង្វេងព្រោះផ្សារមានមនុស្សច្រើនណាស់
  - ពេលគ្រូថាយើងមកដល់ផ្សារហើយគ្រូចង់ទិញសម្ភារក្នុងផ្ទះបាយ ពេលនោះកូនៗមើលមកដៃគ្រូ បើគ្រូលើបណ្ណរូបភាពអ្វីមួយ? ហើយមានចំនួនប៉ុន្មាន? កូនត្រូវនាំគ្នារត់បង្កើតក្រុមទៅតាមចំនួនរូបភាពក្នុងបណ្ណដែលគ្រូបានលើក រួចហើយកូននាំគ្នារាប់ចំនួន កូនក្នុង១ក្រុមៗ តើត្រូវតាមចំនួនរូបភាពដែលគ្រូបានលើកហើយឬនៅ?បើក្រុមណាមួយត្រឹមត្រូវ កូនទះដៃសរសើរ
  - ពេលកូនពិនិត្យចប់គ្រប់ក្រុម កូនត្រូវដើរតាមគ្រូទៅមុខបន្តទៀត ពេលគ្រូថាគ្រូចង់ទិញសម្ភារផ្សេងទៀត ពេលនោះកូនៗមើលមកដៃគ្រូ បើគ្រូលើកបណ្ណរូបភាពអ្វី? ហើយមានចំនួនប៉ុន្មាន?កូនត្រូវនាំគ្នារត់បង្កើតក្រុមទៅតាមចំនួនរូបភាពដែលគ្រូបានលើក រួចហើយកូននាំគ្នារាប់ចំនួន កូនក្នុង១ក្រុមៗ តើត្រូវតាមចំនួនរូបភាពដែលគ្រូបានលើកហើយឬនៅ?
  - គ្រូធ្វើរបៀបនេះបន្តបន្ទាប់ទាល់តែគ្រូប្រាប់ថា ទិញសម្ភារដល់គ្រប់ចំនួន យើងនាំគ្នាទៅផ្ទះវិញ ដូច្នេះកូនៗមកនៅជុំជាមួយគ្រូ រួចដើរតាមគ្រូត្រឡប់ទៅផ្ទះវិញ។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពកសាង៖ បត់រូបផ្ទះ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីការបត់រូបផ្ទះ  បានត្រឹមត្រូវ
- កុមារមានសមត្ថភាពក្នុងការបត់រូបផ្ទះ  បានត្រឹមត្រូវ។
- បណ្តុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន  មានចិត្តស្រឡាញ់  និងចូល ចិត្តកំណាព្យ។

**២. សម្ភារបង្រៀន៖**(អនុវត្តនៅក្នុងជំហ៊ានទី៣)

-គ្រូ៖បត់រូបផ្ទះ រួចចំនួន១សន្លឹក ក្រដាសរាងការេផ្ទាំងធំចំនួន១សន្លឹក

-កុមារ៖ក្រដាសរាងការេផ្ទាំងតូចគ្រប់ចំនួនកុមារ។

**៣.ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរ "U"

**៤.ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហ៊ានទី៣)

- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញបត់រូបផ្ទះឱ្យកុមារប្រាប់ពីរូបនោះ និងយកទៅបិទលើក្តារខៀនជាគំរូសម្រាប់កុមារសង្កេត

- គ្រូបង្ហាញ បត់រូបផ្ទះ រួចសួរកុមារ នេះជារូបអ្វី?តើមានស្នាមអ្វីនៅពីលើរូបនេះ?រួចយកមកបិទលើក្ដារខៀនទន្ទឹមនិងរូបគំរូដែលបានបង្ហាញមុន
- គ្រូណែនាំពីរបៀបបត់រូបផ្ទះយឺតៗ ណែនាំបណ្ដើរបត់បង្ហាញបណ្ដើរ ដើម្បីឱ្យកុមារសង្កេតឱ្យបានច្បាស់ ហើយគ្រូត្រូវឈរធ្វើយ៉ាងណាឱ្យកុមារមើលឃើញគ្រប់ៗគ្នា
  - កូនមានក្រដាសរាងការេមួយនាក់មួយសន្លឹក
  - ពេលចាប់ផ្ដើមកូនយកដៃទាំងពីរកាន់ក្រដាស ដោយមេដៃនឹងចង្អុលដៃស្ដាំដាក់ជិតគ្នារួចកាន់នៅជ្រុងក្រដាសខាងលើហើយមេដៃនិងចង្អុលដៃឆ្វេងដាក់ជិតគ្នារួចកាន់នៅជ្រុងក្រដាសខាងក្រោម។
  - បន្ទាប់មកយកជ្រុងក្រដាសខាងលើបត់មកដាក់លើជ្រុងក្រដាសខាងក្រោមរួចយកដៃឆូតកណ្ដាលឱ្យត្រង់បានជាផ្នត់។
- គ្រូរៀបចំកុមារអង្គុយជាជួរនៅតាមតុឬតាមកៅអីម្នាក់ៗតាមស្ថានភាពជាក់ស្ដែង
- គ្រូឱ្យកុមារពីរនាក់មកយកក្រដាសទៅចែកមិត្តភក្តិគេអនុវត្ត
- គ្រូឈរនៅមុខកុមារដោយនាំកុមារបត់ជាមួយម្ដងមួយវគ្គៗ។ពេលកុមារធ្វើទាំងអស់គ្នារួចមួយវគ្គតាមគ្រូ ហើយគ្រូក៏ចាប់ផ្ដើមធ្វើមួយវគ្គម្ដងទៀតនាំកុមារធ្វើរបៀបនេះទាល់តែដល់ចុងបញ្ចប់
- គ្រូដើរដាក់ឈ្មោះកុមារម្នាក់ៗនៅលើបត់រូបផ្ទះនៅផ្នែកខាងក្រោម។
- គ្រូនាំកុមារផ្ទៀងផ្ទាល់លទ្ធផលរបស់កុមារម្នាក់ៗដោយឱ្យកុមារចេញម្ដងមកពីជួរម្ដងមួយជួរមកឈរនិងមុខមិត្តភក្តិគេនឹងកាន់រូបលើកបង្ហាញដាក់ត្រឹមដើមទ្រូង។
- គ្រូសួរកុមារតើរូបមិត្តភក្តិយើងធ្វើបានត្រឹមត្រូវឬទេ?បត់បានស្អាតឬទេ?
- គ្រូនិយាយប្រាប់កុមារៈពេលកូននាំគ្នាបង្ហាញរួចហើយកូនត្រូវកាន់រូបនេះទៅអង្គុយនៅកន្លែងដើមវិញ
- ពេលនាំកុមារផ្ទៀងផ្ទាត់លទ្ធផលគ្រូមិនត្រូវបង្អាកប់ឬស្ដីបន្ទោសចំពោះកុមារណាដែលធ្វើមិនទាន់បានល្អនោះទេ គ្រូត្រូវចេះសរសើរលើកទឹកចិត្តពួកគេខិតខំប្រឹងប្រែងម្ដងទៀត
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតដល់គ្រប់កុមារទាំងអស់

  គ្រូឱ្យតំណាងជួរនីមួយៗប្រមូលសន្លឹកកិច្ចកុមារម្នាក់ៗជូនគ្រូទុកសម្រាប់ដាក់តាំងស្នាដៃកុមារនៅលើផ្ទាំងស្នាដៃកុមារនៅថ្ងៃបន្ទាប់

  គ្រូត្រូវដាក់ថ្ងៃ ខែ ឆ្នាំ អនុវត្ត មុខវិជ្ជានិងចំណងជើងមេរៀននៅក្បាលលើសន្លឹកកិច្ចការមុននឹងយកទៅដាក់តាំងស្នាដៃកុមារ។

ម៉ោងទី៨ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

## ល្បែង៖ ទះដៃតាមចំនួនព្យាង្គដែលរៀនរួច

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីពាក្យ ឃ្លា និងល្បះនៃពាក្យដែលបានរៀនរួច បានត្រឹមត្រូវ
- កុមារទះដៃត្រូវតាមចំនួនព្យាង្គនៃពាក្យដែលរៀនរួច បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ ព្យាយាម ទម្លាប់ប្រើពាក្យ ឃ្លាល្បះខ្លីៗ និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បណ្ណព្យាង្គនៃពាក្យដែលរៀនរួចមាន **"កុមារ ធីតា ចរិយា កុមារកាន់កែវ ចរិយាសើច..."**

៣. **ការរៀបចំកុមារ៖** -ឱ្យកុមារអង្គុយជារាងពាក់កណ្ដាលរង្វង់ អក្សរ "U"

៤. **ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនាំកុមារទះដៃតាមចំនួនកំណត់( ទះដៃមួយដង ទះដៃពីរដង ទះដៃបីដង ទះដៃបួនដង)
- គ្រូប្រាប់កុមារថា នៅថ្ងៃនេះ គ្រូនឹងនាំកូនលេង ទះដៃតាមចំនួនព្យាង្គ នៅក្នុងពាក្យដែលគ្រូហៅឱ្យកូនស្តាប់។
- បន្ទាប់មកទៀត គ្រូចាប់ផ្តើមណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេងដល់កុមារ ដោយនិយាយថា៖ **ដើម្បីលេងល្បែងនេះ កូនត្រូវស្តាប់ឱ្យបានច្បាស់នៅពាក្យដែលគ្រូអានឱ្យកូនស្តាប់ ហើយកូនត្រូវទះដៃទៅតាមចំនួនព្យាង្គនៃពាក្យនោះ។ ឧទាហរណ៍៖ គ្រូហៅពាក្យថា "កុមារ" ។ ពាក្យនេះមានចំនួន២ព្យាង្គ គឺ "កុ" និង "មារ" ដូចនេះកូនត្រូវទះដៃចំនួន២ដងដែរ ដោយព្យាង្គ "កុ" ទះដៃ១ដង និង "មារ" ទះដៃ១ដងទៀត ។ ហើយប្រសិនបើគ្រូហៅពាក្យដែលមានព្យាង្គចំនួន ៣ ឬ ៤ កូនៗត្រូវទះដៃតាមចំនួនព្យាង្គនៃពាក្យដែលគ្រូបានហៅប្រាប់នោះដែរ។**
- គ្រូនាំកុមារលេងសាកល្បងជាមួយនឹងពាក្យ ១ ទៅ ២ពាក្យ ទៅតាមរបៀបដែលដែលបានណែនាំខាងលើ ហើយសួរកុមារឡើងវិញ ពីរបៀបលេង
- គ្រូនាំកុមារលេងដោយហៅម្តងមួយពាក្យៗឱ្យកុមារស្តាប់ និងទះដៃតាមព្យាង្គនៃពាក្យទាំងនោះដោយការយកចិត្តទុកដាក់ ក្រោមការជួយសម្របសម្រួល និងពិនិត្យលើការអនុវត្តរបៀបលេងផងដែរ
- គ្រូត្រូវនាំកុមារផ្ទៀងផ្ទាត់ដោយទះដៃតាមចំនួនព្យាង្គរបស់ឈ្មោះកុមារឡើងវិញ នៅពេលដែលធ្វើសកម្មភាពតាមពាក្យនីមួយៗរួច។
- គ្រូលើកសសើរ និងលើកទឹកកុមារដែលបានចូលរួមក្នុងសកម្មភាពលេង
- គ្រូសួរបំផុសកុមារថា៖
  - **កូនៗទាំងអស់គ្នាសប្បាយទេ?**
  - **តើមុននេះ កូនលេងល្បែងអ្វីជាមួយគ្រូ?**
  - **តើចំនួនព្យាង្គដែលកូនទះដៃក្នុងពេលលេង មានចំនួនព្យាង្គប៉ុន្មានខ្លះ?**
  - **ដូចនេះ តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?** (ឱ្យកុមារឆ្លើយតាមការចងចាំរបស់ពួកគេ)
- គ្រូបញ្ជាក់កុមារបន្ថែមថា **ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែង "ទះដៃតាមចំនួនព្យាង្គដែលរៀនរួច**
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

∗ **ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ៖**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

## ថ្ងៃទី១១

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលនាព

## ល្បែងចលនាៈ លោតមឹកផ្ទះ

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីរបៀបលោតមឹកផ្ទះ បានត្រឹមត្រូវ
- កុមារលោតមឹកផ្ទះ បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន ប្រុងប្រយ័ត្នក្នុងការទប់លំនឹងខ្លួន និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** មេមឹកសម្រាប់កុមារម្នាក់ៗ

**៣. ការរៀបចំកុមារៈ** រៀបចំកុមារជា៣ក្រុម

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារតម្រង់ជួរជា៣ជួរដែលមានសមាជិកស្មើៗគ្នា (៣ក្រុម)
- បន្ទាប់មកគ្រូឱ្យកុមារធ្វើចលនាលោតជើងមួយទៅមុខទៅក្រោយចុះឡើង
- គ្រូឱ្យនាំកុមារសង្កេតមើលគំនូសមឹកយន្តហោះដែលគ្រូបានគូសរួច ហើយសួរកុមារថា តើកូនសង្កេតមើលគំនូសនេះទៅមើលថា មានរូបរាងដូចអ្វីអ្វី? ចូរកូនទស្សន៍ទាយទៅមើលថាតើគ្រូនិងនាំកូនលេងអ្វីជាមួយគំនូសនេះ?តើកូនធ្លាប់លេងវាពីមុនមកដែរឬទេ?
- គ្រូទទួលចម្លើយកុមារដោយលើកទឹកចិត្ត
- បន្ទាប់មកគ្រូប្រាប់កុមារថា គំនូសនេះ ជាគំនូសរូបផ្ទះ ហើយគ្រូនឹងនាំកូនលេងជានឹងគំនូសនេះ។
- គ្រូចាប់ផ្តើមណែនាំពីរបៀបលេង និងលក្ខខណ្ឌដល់កុមារ ថា ដើម្បីលេងលើគំនូសនេះបាន កូនៗត្រូវមានមេមឹកម្នាក់មួយៗ(លើកមេមឹកបង្ហាញ) បន្ទាប់មកកូនៗនៅក្នុងក្រុមទាំង២ត្រូវជ្រើសរើសតំណាងក្រុមចំនួន១នាក់ ហើយប៉ាវ កូនតំណាងក្រុមណាដែលប៉ាវឈ្នះមានសិទ្ធិលេងមុន។ ការលេងគឺកូនត្រូវបោះមេមឹកចូលទៅក្នុងក្រឡាចក្រត្រង្គទី១ ដោយលោតជើងមួយរំលងត្រង់កន្លែងដែលមានមេមឹក គឺលោតចូលក្នុងក្រឡាចក្រត្រង្គទី២ រហូតដល់ក្រឡាចក្រត្រង្គទី៧ និងលោតត្រឡប់មកវិញ ដើម្បីយកមេមឹករួចបោះបន្ត ក្នុងករណីកូនទី១ ធ្វើបានដល់លេខ៧ មានសិទ្ធិបូលយកផ្ទះមួយដោយគូសសញ្ញាសម្គាល់។ ករណីបោះរំលង ឬបោះមេជាប់ខ្សែ ឬចេញក្រៅខ្សែ ត្រូវផ្អាក រួចម្តង់សិទ្ធិដល់កូនដែលប៉ាវចាញ់លេងម្តង។
- បន្ទាប់មកគ្រូឱ្យកុមារ១ទៅ២នាក់ ប្រាប់ឡើងវិញពីរបៀបលេង និងលក្ខខណ្ឌ
- គ្រូឱ្យកុមារស្ម័គ្រចិត្តម្នាក់ឡើងមកលេងសាកល្បងតាមរបៀបដែលបានណែនាំ
- បន្ទាប់មកគ្រូចាប់ផ្តើមឱ្យតំណាងក្រុមទាំង៣ ប៉ាវដើម្បីរកអ្នកឈ្នះដើម្បីលេងមុខគេ
- គ្រូនាំកុមារលេង និងសម្របសម្រួលដំណើរការលេង ដោយផ្ទៀងផ្ទាត់ទៅនឹងលក្ខខណ្ឌដែលបានប្រាប់
- ប្រសិនបើមានពេលវេលា គ្រូអាចឱ្យសមាជិកក្នុងក្រុមនីមួយៗផ្លាស់ប្តូរគ្នាលេងបន្តឱ្យបានច្រើនគ្នា
- គ្រូលើកសរសើរចំពោះអ្នកដែលឈ្នះ ចំពោះអ្នកចាញ់គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ
- បន្ទាប់ពីលេងរួចហើយ គ្រូនាំកុមារធ្វើចលនាហិតក្លិនម្ហូបដែលឆ្ងុយឆ្ងាញ់ ដោយដកដង្ហើមចូល ចេញវែង ៗ ៣ ទៅ៤ដង (កូនៗស្រូបយកខ្យល់ដង្ហើមចូល ហើយស្រូបខ្យល់ដង្ហើមចេញមកក្រៅវែងៗដូចជាហិតក្លិន

ម្ហូបដែលមានក្លិនឆ្ងុយគួរឱ្យចង់ទទួលទាន) រួចគ្រូសួរកុមារថា **តើម្ហូបនេះមានក្លិនឆ្ងុយទេកូនៗ?**
- គ្រូទទួលចម្លើយកុមារ ដោយលើកសសើរ។
- បន្ទាប់គ្រូសួរម្តងមួយសំណួរឱ្យកុមារឆ្លើយ៖
  - **តើមុននេះ កូនៗបានលេងល្បែងអ្វី?**
  - **តើកូនបានធ្វើចលនាអ្វីខ្លះ?**
  - **តើមុខវិជ្ជាដែលកូនរៀនថ្ងៃនេះជាមុខវិជ្ជាអ្វី?មេរៀនអ្វីដែរ?**(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- បន្ទាប់មកទៀត គ្រូប្រាប់បញ្ជាក់កុមារ **ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព មេរៀនល្បែងចលនា "លោតមឹកផ្ទះ"**
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ទាំងអស់គ្នា
❖ បញ្ជាក់៖ គ្រូត្រូវគូសគំនូសមឹកយន្តហោះឱ្យបានរួចជាស្រេចមុនចាប់ផ្តើមដំណើរការបង្រៀន



ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការ បង្រៀនអនុវត្ត ដូចថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អៈ មករៀនឱ្យទៀងទាត់ពេលវេលារៀងរាល់ថ្ងៃ

- **គ្រូសួរកុមារៈ**
  - នៅពេលកូនទៅរៀន តើអ្នកណាជូនកូនទៅ? កូនទៅជិះអ្វីដែរ? កូនចូលរៀននៅម៉ោងប៉ុន្មាន? ហើយមានកូនណាខ្លះធ្លាប់មករៀនយឺតដែរឬទេ? ហេតុអ្វីបានជាកូនមករៀនយឺត?
  - ពេលកូនមករៀនយឺតតើកូនត្រូវធ្វើដូចម្តេច? តើកូនគួរតែមករៀនយឺតរាល់ពេលឬយ៉ាងណា?
- គ្រូណែនាំកុមារៈ ពេលមករៀនរាល់ថ្ងៃ កូនត្រូវមកឱ្យទាន់ម៉ោង គឺពេលព្រឹកចូលរៀនម៉ោង 7:10 នាទី ដូច្នេះកូនត្រូវមកដល់សាលាម៉ោង 6:30 នាទី ទើបកូនមករៀនទាន់ពេលវេលា ហើយរៀនមេរៀនទាន់មិត្តភក្តិយើងដែរ។ បើសិនជាកូនមកមិនទាន់ញឹកញាប់កូននឹងរៀនមិនទាន់មិត្តភក្តិយើងទេ ។

* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១១ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

### កំណាព្យៈ ថែសម្លៀកបំពាក់

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីដើង និងអត្ថន័យនៃកំណាព្យ«ថែសម្លៀកបំពាក់» បានត្រឹមត្រូវ។
- កុមារមានសមត្ថភាពសូត្រកំណាព្យត្រូវតាមវាក្យស័ព្ទនិងលំនាំបទ បានត្រឹមត្រូវ។
- បណ្តុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន មានចិត្តស្រឡាញ់ និងចូលចិត្តកំណាព្យ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** កុមារអង្គុយជារាងអក្សរ "U"

**៤. ដំណើរការបង្រៀនៈ**(អនុវត្តនៅក្នុងជំហានទី៣)

- ថ្ងៃនេះគ្រូនឹងយកមេរៀនកំណាព្យមួយមកបង្រៀនកូនៗទាំងអស់គ្នា
- គ្រូសូត្រកំណាព្យឱ្យកុមារស្តាប់មួយចប់សិនដើម្បីឱ្យកុមារយល់អត្ថន័យនៃកំណាព្យ
- គ្រូឱ្យកុមារអានអត្ថបទ និងរកពាក្យពិបាកគ្រូសួរកុមារ តើកំណាព្យដែលគ្រូបានសូត្រគេចង់និយាយពីអ្វី?
  - គ្រូប្រាប់និងពន្យល់ពាក្យពិបាកមាន **ថែទាំ** មានន័យថាថែដោយប្រុងប្រយ័ត្នមិនប្រហែសទុកចោល **ឥតសណ្តាប់**មានន័យថាទុកដាក់គ្មានរបៀប ។
  - អត្ថបទកំណាព្យនេះគឺចង់ឱ្យកុមារចេះសម្អាតនិងថែទាំសម្លៀកបំពាក់ឱ្យបានត្រឹមត្រូវ
- គ្រូនាំកុមារសូត្រកំណាព្យឃ្លាទី១ ឱ្យបានមួយចប់គ្រប់ៗគ្នា បន្ទាប់មកកុមារសូត្រឃ្លាទី២
- ពេលកុមារសូត្រកំណាព្យ ឃ្លាទី១ ឃ្លាទី២ រួចឱ្យកុមារសូត្រឃ្លាទាំងពីររួមបញ្ចូលគ្នា
- គ្រូនាំកុមារសូត្រឃ្លាបន្តបន្ទាប់តាមរបៀបខាងលើរហូតដល់ចប់នៃអត្ថបទកំណាព្យ

- គ្រូឱ្យកុមារសូត្រកំណាព្យសាឡើងវិញរួមគ្នា ១ឬ២ចប់
- គ្រូសួរកុមារ តើអម្បាញ់កូនរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?អ្នកនិពន្ធឈ្មោះអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់ គេម្នាក់ៗ)អរគុណកូនៗដែលបានឆ្លើយ តើកូនចង់ដឹងទេថាថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?
- គ្រូប្រាប់ថា ថ្ងៃនេះយើងរៀនមុខវិជ្ជាៈភាសាខ្មែរ មេរៀនៈកំណាព្យ«**ថៃសម្លៀកបំពាក់**»អ្នកនិពន្ធដោយលោកអ៊ំនៅក្រសួងអប់រំ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម ទាំងអស់គ្នា

**អត្ថបទកំណាព្យ "ថៃសម្លៀកបំពាក់" (បទកាកគតិ)**

**ខោអាវត្រូវថែទាំ　　　តាមលំនាំលំអោនស្រាប់**
**កុំរាយឥតសណ្ដាប់　　　មិនគួរគាប់នឹងក្មេកញាតិ ។**
**ជាកូនមានបទល្អ　　　មិនដែលក្រឥតមារយាទ**
**ទុកដាក់ហើយចេះឆ្លៀត　　　ជួយការទៀតជំនួសម្ដាយ ។**

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## ល្បែងៈ អ្នកវាយកណ្ដឹង

**១. វត្ថុបំណងៈ**
- កុមារប្រាប់បានពីឈ្មោះមិត្តភក្តិដោយសម្លេង បានត្រឹមត្រូវ
- កុមារបង្ហាញឈ្មោះមិត្តភក្តិដោយសម្លេង បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន និងមានភាពសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** ក្រម៉ា កណ្ដឹង កំប៉ុងដាក់គ្រាប់គ្រួស

**៣. ការរៀបចំកុមារៈ** អង្គុយជារាងពាក់កណ្ដាលរង្វង់ "U" អង្គុយរាងរង្វង់

**៤. ដំណើរការបង្រៀន**(អនុវត្តនៅក្នុងជំហានទី៣)
- គ្រូបំផុសសំណួរ តើកូនៗធ្លាប់លេងល្បែងអ្វីខ្លះ? ដូចច្នេះកូនៗទាយមើលថាថ្ងៃនេះគ្រូបង្រៀនកូនពីមុខវិជ្ជាអ្វី? អំពីអ្វី? ឱ្យកុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ ។ ពេលកុមារប្រាប់រួច គ្រូត្រូវសរុបនូវអ្វីដែលពួកគេបានប្រាប់
- គ្រូប្រាប់កុមារៈ ថ្ងៃនេះគ្រូបង្រៀនមុខវិជ្ជាសិក្សាសង្គម **អំពីល្បែង អ្នកវាយកណ្ដឹង**
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងការនិយាយប្រាប់របស់គ្រូ ដោយសួរកុមារថា តើអម្បាញ់មិញមានកូនណាទាយត្រូវឬទេ? បើមានមិត្តភក្តិយើងទាយត្រូវដូចនេះកូនៗនាំគ្នាទះដៃសរសើរមិត្តភក្តិយើងទាំងអស់គ្នា។ ឯកូនដែលទាយមិនទាន់ត្រូវ កូនក៏ឆ្លាតដែរ ព្រោះកូនបានឆ្លើយនឹងសំណួរ តែថ្ងៃក្រោយកូនត្រូវគិតបន្ថែម ហើយចាំឆ្លើយសំណួរគ្រូទៀតណា !
- គ្រូនាំកុមារអានពីមុខវិជ្ជា និងចំណងជើងមេរៀន (ជាក្រុម និងទាំងអស់គ្នា)
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**

- គ្រូឱ្យកូនលេងទាំងអស់គ្នា ហើយអង្គុយជារង្វង់។ បន្ទាប់មកឱ្យមិត្តភក្តិកូនណាម្នាក់ដែលស្ម័គ្រចិត្ត មកអង្គុយនៅកណ្ដាលវង់ ហើយយកក្រម៉ាចងមុខឱ្យជិតមិនឱ្យមើលឃើញ ហើយមានកាន់កំប៉ុង មួយមានដាក់គ្រាប់គ្រួសខាងក្នុង
- គ្រូឱ្យកំប៉ុងដាក់គ្រាប់គ្រួសទៅកូនណាម្នាក់ជាអ្នកអង្រួន បន្ទាប់មកគ្រូឱ្យកូនដែលចងមុខទាយ ឈ្មោះរួចហើយគ្រូស្រាយក្រម៉ាបើកមុខ ដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើកូនទាយត្រូវគ្រូនឹងឱ្យកូនដែល អង្រួនកំប៉ុងចងមុខវិញម្ដង ប៉ុន្តែបើកូនទាយខុសកូនត្រូវចងមុខលេងឡើងវិញម្ដងទៀត ។

- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្ដងទៀត)
- គ្រូរៀបចំកុមារលេងទាំងអស់គ្នា ដោយឱ្យកុមារទៅអង្គុយជារង្វង់នៅកន្លែងដែលគ្រូបានរៀបចំ
- គ្រូនាំកុមារលេងតាមអ្វីដែលគ្រូបានណែនាំ
- គ្រូ និងកុមារផ្ទៀងផ្ទាត់លទ្ធផល (បើកុមារធ្វើបានគ្រូលើកសរសើរ តែបើកុមារធ្វើមិនបានគ្រូត្រូវលើកទឹក ចិត្តឱ្យប្រឹងបន្ថែមទៀត )
- គ្រូនាំកុមារលេង និងផ្ទៀងផ្ទាត់របៀបនេះ រហូតចប់ម៉ោង។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

### សង្កេត៖ ការវិវត្តរបស់មនុស្ស

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីដំណើរវិវត្តន៍តាមដំណាក់កាលរបស់មនុស្សបានត្រឹមត្រូវ
- កុមារបង្ហាញពីដំណើរវិវត្តរបស់មនុស្សតាមដំណាក់កាលបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ ចូលរួម និងចេះថែរក្សាសុខភាពរាងកាយរបស់ខ្លួន ។

**២. សម្ភារបង្រៀន៖** ផ្ទាំងរូបភាពការវិវត្តន៍របស់មនុស្សចំនួន ៤ផ្ទាំង

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារាងពាក់កណ្ដាលរង្វង់ អក្សរ "ប" និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)
- គ្រូសួរកុមារ៖ កូនដឹងទេ តើថ្ងៃនេះគ្រូបានអ្វីធ្វើកូនៗទាំងអស់គ្នា?
- គ្រូឱ្យកុមារបិទភ្នែកទាំងអស់គ្នា ពេលកុមារបិទភ្នែក គ្រូយកស្រោមសំបុត្រដែលច្រកផ្ទាំងរូបភាពការវិវត្តន៍ របស់មនុស្សមកដាក់លើតុពីមុខកុមារ
- គ្រូឱ្យកុមារបើកភ្នែកវិញ រួចសួរកុមារ **តើមានអ្វីនៅពីមុខកូន? តើស្រោមសំបុត្រនេះមានអ្វីខ្លះ?**
- គ្រូឱ្យកុមារម្នាក់ឡើងមកយកទាំងរូបភាពចេញពីស្រោមសំបុត្ររួចផ្ទៀងផ្ទាត់ទៅនឹងលទ្ធផលដែលកុមារ បានទាយ បើមានកុមារណាទាយត្រូវគ្រូសរសើរកុមារដោយពាក្យសម្ដី (កូនដែលបានឆ្លើយត្រូវកូនឆ្លាត មែន ហើយពូកែទៀត ប៉ុន្តែកូនឆ្លើយមិនត្រូវក៏ឆ្លាតដែរ ដែលក្លាហានហ៊ានឆ្លើយសំណួរគ្រូ)។គ្រូបញ្ជាក់ ប្រាប់កុមារ៖ **រូបភាពទាំងអស់នេះហៅថាការវិវត្តន៍របស់មនុស្ស** រួចនាំកុមារអាន
- គ្រូសួរកុមារ៖ **កូនដឹងទេថា គ្រូនឹងឱ្យកូនៗធ្វើអ្វីជាមួយផ្ទាំងរូបភាពនេះ?**
- គ្រូណែនាំកុមារពីររបៀបអនុវត្តតាមក្រុមនីមួយៗ៖
    - **គ្រូឱ្យកូនៗអនុវត្តតាមក្រុមតូចៗ ហើយក្នុងក្រុមនីមួយៗត្រូវបានផ្ទាំងរូបភាពនេះមួយផ្ទាំង**

- **ពេលក្រុមនីមួយៗបានផ្ទាំងរូបភាពនេះហើយ កូនត្រូវដាក់កណ្ដាលវង់ ហើយនាំគ្នាសង្កេតមើលរូបទាំងអស់នោះ ហើយពិភាក្សាគ្នាលើរូបនីមួយៗថា តើឃើញអ្វីខ្លះក្នុងរូបភាព? តើការវិវត្តន៍របស់មនុស្សចាប់ផ្ដើមពីដំណាក់កាលណា ទៅដំណាក់កាលណា? ពេលកូននាំគ្នាសង្កេតកូនកុំដណ្ដើមគ្នា កុំដកផ្ទាំងរូបភាពនេះចុះឡើង បើកូនអង្គុយបញ្ច្រាសរូបត្រូវបង្វិលផ្ទាំងរូបភាពឱ្យត្រូវមិត្តភក្តិអាចមើលឃើញច្បាស់។ ហើយបើកូនណាស្គាល់ជួយប្រាប់ទៅមិត្តភក្តិដែលគេមិនស្គាល់ផង។ ហើយកូនត្រូវរកមិត្តណាម្នាក់សម្រាប់ឡើងនិយាយប្រាប់ពីអ្វីដែលកូនបានស្គាល់ និងដឹង**
- **ពេលកូនៗពិភាក្សាគ្នាចប់គ្រប់ក្រុមហើយ ត្រូវនាំគ្នាទៅអង្គុយនៅក្រុមជុំវិញដោយយកសម្ភារៈទៅរៀងៗខ្លួន។**

- ឱ្យកុមារម្នាក់ ឡើងនិយាយពីអ្វីដែលត្រូវបានប្រាប់ បើនិយាយមិនបានទេឱ្យមិត្តភក្តិជួយបំពេញបន្ថែម ប៉ុន្តែបើនៅតែនិយាយមិនបានពេញលេញទេនោះគ្រូត្រូវនិយាយប្រាប់កុមារសារឡើងវិញម្ដងទៀត
- រៀបចំកុមារជាក្រុមហើយអង្គុយជារង្វង់តាមទីកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូអោយតំណាងក្រុមនីមួយៗមកយកសម្ភារទៅ ហើយនាំគ្នាអនុវត្តតាមការណែនាំ
- គ្រូដើរសម្របសម្រួលកុមារគ្រប់ក្រុមទាំងអស់ ដើម្បីជួយក្រុមណាដែលមិនទាន់យល់ច្បាស់
- ពេលក្រុមនីមួយៗត្រូវបានបញ្ចប់ការងារ គ្រូឱ្យពួកគេទៅអង្គុយនៅក្រុមជុំវិញដោយយកផ្ទាំងរូបភាពទៅរៀងៗខ្លួន ទុកបង្ហាញពេលឡើងរាយការណ៍
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងមកនិយាយប្រាប់មិត្តភក្តិនិងគ្រូពីលទ្ធផលដែលពួកគេបានពិភាក្សាគ្នា (ម្ដងមួយក្រុមៗ) ដោយលើកផ្ទាំងរូបភាពចង្អុលបង្ហាញឈ្មោះរូបម្ដងមួយៗ
- គ្រូត្រូវកែតម្រូវពាក្យដែលពួកគេនិយាយមិនទាន់បានត្រឹមត្រូវតាមអក្ខរាវិរុទ្ធ រួចនាំកុមារអាននូវពាក្យទាំងនោះទាំងអស់គ្នា។
- គ្រូសរុបពីលទ្ធផលរបស់កុមារគ្រប់ក្រុម បន្ទាប់ពីបានស្ដាប់ពួកគេនិយាយចប់។ (ឧទាហរណ៍៖ គ្រូស្ដាប់បានកុមារប្រាប់បានពីដំណាក់កាលនៃការវិវត្តន៍របស់មនុស្ស បានខ្លះតែប៉ុណ្ណោះ។ នៅមានខ្លឹមសារផ្សេងទៀតដែលកុមារប្រាប់មិនបាន។ ដូច្នេះគ្រូត្រូវគិតគូរផ្ដល់ចំណេះដឹងថ្មីបន្ថែមឱ្យពួកគេអ្វីខ្លះទៀត?)
- គ្រូត្រូវផ្ដល់ចំណេះដឹងថ្មីៗបន្ថែមតាមរយៈ៖
    - គ្រូបង្ហាញផ្ទាំងរូបភាពឱ្យកុមារសង្កេតជារួម ឱ្យកុមារបានមើលឃើញទាំងអស់គ្នា។ បន្ទាប់មកគ្រូចង្អុលនឹងប្រាប់ពីរូបភាព និងដំណាក់កាលនៃវិវត្តន៍ម្ដងមួយៗ ឱ្យកុមារបានដឹង
    - គ្រូបំផុសសំណួរ៖ តើកូនស្ថិតក្នុងដំណាក់កាលនៃការវិវត្តន៍របស់មនុស្ស?តើកូនត្រូវធ្វើដូចម្ដេចដើម្បីថែទាំរូបរាងកាយរបស់យើងឱ្យបានល្អ? បើកុមារមិនអាចឆ្លើយបានគ្រូត្រូវប្រាប់ ហើយនាំកុមារថាតាមជាក្រុមនិងទាំងអស់គ្នា។
- គ្រូយកផ្ទាំងរូបភាពនោះបិទលើក្ដារខៀន រួចនាំកុមារអានឈ្មោះនៅរូបភាពនីមួយៗដោយគ្រូជាអ្នកចង្អុលផងប្រាប់ដំណើរវិវត្តន៍របស់មនុស្សដែលមានលើរូបភាព និងការថែទាំរូបរាងកាយឱ្យល្អ ផងដែរ។
- គ្រូសួរកុមារ៖ អម្បាញ់មិញកូនស្គាល់អ្វីខ្លះ? ដូច្នេះថ្ងៃនេះយើងរៀនពីមុខវិជ្ជាវិទ្យាសាស្ត្រអំពីសង្កេតការវិវត្តន៍របស់មនុស្ស
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន (ជាក្រុមនឹងទាំងអស់គ្នា)។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

**មុខវិជ្ជា៖ សិក្សាសង្គម**

*** ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី១២

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

## ហាត់ប្រាណតាមបទចម្រៀងៈ បូតសណ្ដែក

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីរបៀបធ្វើចលនារត់ លោត ជាចង្វាក់តាមបទចម្រៀងបានត្រឹមត្រូវ
- កុមារធ្វើចលនារត់ លោត ជាចង្វាក់តាមបទចម្រៀងបានត្រឹមត្រូវ
- កុមារមានបម្រុងប្រយ័ត្ន សហការ ស្វាហាប់ រហ័សរហួន និងសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** កុមារឈរជារង្វង់ កុមារឈរទល់មុខគ្នា២នាក់

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជារង្វង់ ហើយកុមារឈរទល់មុខគ្នា២នាក់
- គ្រូនាំកុមារធ្វើចលនាគ្រាប់តាមមនុស្សយន្ត កុមារលោតដៃទាំងពីរបោះទៅមុខ ហើយលោតទៅមុខ លោតទៅឆ្វេង លោតទៅស្ដាំ លោតថយក្រោយ (១ឬ២ដង)
- គ្រូច្រៀងឱ្យកុមារស្ដាប់ និងធ្វើចលនាឱ្យកុមារមើលតាមបទចម្រៀងរហូត១ចប់
- គ្រូនាំកុមារច្រៀងនិងធ្វើចលនាតាមបទចម្រៀងទាំងអស់គ្នាអាស្រ័យតាមពេលវេលា(២ឬ៣ចប់)
- គ្រូនាំកុមារទាំងអស់មកឈរជារង្វង់រួចសួរថាកូនៗ ហត់ទេ?ដើម្បីឱ្យមានកម្លាំងកូនត្រូវធ្វើដូចម្ដេច? ហើយផ្កាអ្វីដែលក្រអូមជាងគេ ផ្កាម្លិះ ដើមទាបឬខ្ពស់ អញ្ចឹងកូនយកដៃអោនបេះផ្កាទាំងអស់គ្នា បេះបានហើយឬនៅកូនៗ បើបានហើយកូនលើកផ្កាហិតទាំងអស់គ្នា ហើយស្រូបដង្ហើមចូលចេញវែងៗ (ក្រអូបណាស់២ទៅ៣ដង)
- ថ្ងៃនេះកូនរៀនមុខវិជ្ជាចិត្តចលភាពអំពី ហាត់ប្រាណតាមបទចម្រៀង ចំណងជើង «បូតសណ្ដែក» គ្រូឱ្យកុមារថាតាម១នាក់ ២នាក់តាមក្រុម

របៀបធ្វើចលនា

- ច្រៀងចាប់ពីបូតសណ្ដែក រហូតដល់មិត្តខ្លះកាប់ដី បន្តទុកដាំ= កុមារឈរទល់មុខគ្នា២នាក់ៗជារង្វង់យកបាតដៃទាំងពីរដាក់ផ្ដោបឆ្លាស់គ្នាទៅនឹងបាតដៃទាំងពីររបស់ដៃគូ រួចបូតដៃចុះក្រោមចេញហើយទះដៃរៀងៗខ្លួនមួយដង ទើបយកដៃស្ដាំទះលើបាតដៃស្ដាំ របស់ដៃគូខ្លួនដោយប្ដូរទះម្ដងទៅឆ្វេង ម្ដងទៅស្ដាំ និងយកដៃម្ខាងចង្អុលចុះ ចង្អុលឡើងជាចង្វាក់
- ដេញចចករត់លឿន រត់អើយរត់លឿន រត់លឿនហុយដី=កុមារនាំគ្នារត់លឿនទៅមុខជាចង្វាក់
- អឹងអើយបូតសណ្ដែក= កុមារងាកមកឈរទល់មុខគ្នា២នាក់ៗជារង្វង់វិញ រួចយកបានដៃទាំងពីរដាក់ផ្ដោបឆ្លាស់គ្នាទៅនឹងបាតដៃទាំងពីររបស់ដៃគូ រួចបូតដៃចុះក្រោមចេញ ហើយទះដៃរៀងៗខ្លួនមួយដង។

អត្ថបទចម្រៀង«បូតសណ្ដែក»

| | | | |
|---|---|---|---|
| | បូតសណ្ដែក | អឹងអើយបូតសណ្ដែក | យើងនាំគ្នារែក |
| | បូតដាក់ក្នុងល្អី | មិត្តខ្លះខំទូលខិតខំឃ្មាតខ្មី | មិត្តខ្លះកាប់ដីបន្តទុកដាំ |
| -បន្ទរៈ | មែនហើយមែនពិត | ដេញចង្រិតចូលរន្ធ | ដេញមាន់ស្រែខ្វក |
| | ដេញចចករត់លឿន | រត់អើយរត់លឿន | រត់លឿនហុយដី។ |
| | | អឹងអើយបូតសណ្ដែក។ | |

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការ បង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អៈ មករៀនឱ្យទៀងទាត់ពេលវេលារៀងរាល់ថ្ងៃ(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១២ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ បុរេគណិត

## ល្បែងៈ ដូមីណូ

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីរបៀបលេងល្បែងដូមីណូនិងចំនួនបានត្រឹមត្រូវ
- កុមាររាប់ចំនួនគ្រាប់ដូមីណូដាក់បានត្រឹមត្រូវ
- កុមារមានចិត្តអំណត់ក្នុងការចាំវេន ឈ្លាសវៃ សហការ សប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ** កូនកាសដូមីណូ២៨សន្លឹក(គ្រប់ចំនួនក្រុម)

**៣. ការរៀបចំកុមារៈ** កុមារអង្គុយជាអក្សរ "ប" កុមារអង្គុយជាក្រុមតូចៗ(មួយក្រុម៤នាក់)

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារក្រោកឈរទាំងអស់គ្នា ចាំរាប់ចង្កឹះជាមួយគ្រូ។ គ្រូនាំកុមាររាប់ចង្កឹះពី១ដល់៦ ដោយគ្រូជាអ្នកកាន់ចង្កឹះដកចេញម្តងមួយៗ ហើយកុមារនាំគ្នារាប់
- គ្រូនិយាយៈកូនៗទាំងអស់គ្នាឆ្លាតណាស់ រាប់ចំនួនបានត្រឹមត្រូវ ច្បាស់លាស់ដូច្នេះកូននាំគ្នាទាយមើលតើបន្តិចទៀតគ្រូបង្រៀនកូនពីមុខវិជ្ជាអ្វី? អំពីអ្វី? ឱ្យកុមារឆ្លើយតាមតាមគំនិតរបស់គេម្នាក់ៗ។
- គ្រូប្រាប់កុមារៈ«ថ្ងៃនេះយើងរៀនមុខវិជ្ជាបុរេគណិត អំពីដូមីណូ»បន្ទាប់មកសួរកុមារអម្បាញ់មិញមានកូនណាទាយត្រូវឬទេ?បើមានកូនណាទាយត្រូវ គ្រូឱ្យកុមារទះដៃសរសើរពួកគេ។ ឯកូនណាទាយមិនត្រូវកូនក៏ឆ្លាតដែរ ដែលហ៊ាន ក្លាហានឆ្លើយសំណួររបស់គ្រូ។
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារថាតាម(ជាក្រុម រួចទាំងអស់គ្នា)
- គ្រូបង្ហាញកូនកាសដូមីណូឱ្យកុមារសង្កេត និងប្រាប់ចំនួនដែលមាននៅក្នុងកូនកាស
- គ្រូណែនាំពីរបៀបលេងនិងលក្ខខណ្ឌនៃការលេង
  - គ្រូចែកកូនលេងជាក្រុម ក្នុងមួយក្រុមមានចំនួន៤នាក់ ហើយក្រុមនីមួយៗមានកូនកាសចំនួន២៨សន្លឹក
  - ពេលក្រុមកូននីមួយៗទទួលបានកូនកាសដូមីណូចំនួន២៨សន្លឹកហើយ ត្រូវដាក់ផ្កាប់ទាំងអស់នៅចំកណ្តាលរង្វង់ រួចម្នាក់ៗចាប់យកកូនកាសដូមីណូចំនួន៧សន្លឹករៀងៗខ្លួន។ពេលបានកូនកាសហើយត្រូវលាក់មិនឱ្យអ្នកនៅក្នុងក្រុមឃើញឡើយ។
  - កូនដែលមានកូនកាសចំនួន៦សងខាងជាអ្នកចាប់ផ្តើមដាក់កូនកាសមុនគេ បន្ទាប់មកកូនដែលនៅស្តាំដៃកូនទី១ ត្រូវមានកូនកាសរបស់ខ្លួនបើមានចំនួន៦ដែរ ត្រូវដាក់បន្តពីកូនកាសរបស់កូនទី១

ដែលមានចំនួន៦។ ប៉ុន្តែបើកូនទី២ មិនមានកូនកាសដូមីណូចំនួន៦ទេ គឺត្រូវរំលងទៅកូនទី៣។ កូនធ្វើរបៀបនេះបន្តបន្ទាប់គ្នាតាមវេនរហូតដល់កូនដែលអស់កូនកាសដូមីណូពីដៃមុនគេគឺជាឈ្នះលើទី១ រួចហើយកូនបន្ទាប់ត្រូវបន្តលេងរហូតដល់ដាក់កូនកាសអស់គ្រប់ៗគ្នា។

- គ្រូឱ្យកុមារ១នាក់ដែលស្ម័គ្រចិត្តនិយាយឡើងវិញពីអ្វីដែគ្រូបានណែនាំ បើនិយាយមិនបានទេនោះឱ្យមិត្តភក្តិប្រាប់បន្ថែម ប៉ុន្តែបើនិយាយមិនពេញលេញទេគ្រូត្រូវនិយាយប្រាប់សាឡើងវិញម្តងទៀត។
- គ្រូហៅកុមារ៣នាក់មកលេងជាមួយគ្រូសាកល្បងជាគំរូ ឱ្យកុមារមើលសិន ហើយកុមារដទៃទៀតមកឈរជុំវិញដើម្បីមើលពីរបៀបលេង
- គ្រូរៀបចំកុមារជាក្រុមតូចៗក្នុងមួយក្រុមមានចំនួន៤នាក់ ឱ្យទៅអង្គុយជារង្វង់នៅតាមទីកន្លែងដែលគ្រូបានរៀបចំឱ្យ
- គ្រូឱ្យកុមារមួយក្រុម ១នាក់មកយកសម្ភារទៅចែកមិត្តភក្តិអនុវត្ត តាមការណែនាំរបស់គ្រូ
- គ្រូដើរសម្របសម្រួលទៅតាមក្រុមនីមួយៗ ដើម្បីជួយកែតម្រូវ
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលដោយឱ្យក្រុមនីមួយៗបង្ហាញពីអ្នកឈ្នះទី១ ឈ្នះទី២ និងអ្នកឈ្នះបន្តបន្ទាប់
- គ្រូនាំកុមារលេងរបៀបនេះបន្តបន្ទាប់រហូតដល់បញ្ចប់ម៉ោង។ មុនលេងបន្តត្រូវសាប់កូនកាសដូមីណូឡើងវិញ ទើបចែកកូនកាសសាថ្មីទៀត
- ពេលលេងចប់គ្រូឱ្យក្រុមនីមួយៗពិនិត្យកូនកាសដូមីណូឱ្យគ្រប់ចំនួន២៨សន្លឹក ទើបនាំគ្នាយកទុកជូនគ្រូវិញ។

***បញ្ជាក់៖*** ករណីកុមារច្រើនគ្រូត្រូវចែកកុមារមួយក្រុមមានគ្នា៤នាក់ក្នុង១នាក់បាន៧សន្លឹក,បើមួយក្រុមមានគ្នា៧នាក់ក្នុង១នាក់បាន៤សន្លឹក។

**ម៉ោងទី៤ (រយៈពេល ៣០នាទី)**

## មុខវិជ្ជា៖ សិក្សាសង្គម

## រឿងនិទាន៖ ស្វាកាន់ខ្មៅដៃ (និទាន)

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបកាន់ខ្មៅដៃ និងទប់លំនឹងខ្មៅដៃពេលគូសបានត្រឹមត្រូវ។
- កុមារបង្ហាញពីរបឪបកាន់ និងទប់លំនឹងខ្មៅដៃគូរូប ដោយកំណត់ព្រំដែននៃគំនូសបានត្រឹមត្រូវ។
- កុមារខិតខំ ព្យាយាម អំណត់ កាន់ខ្មៅដៃគូឱ្យមានលំនឹង

**២. សម្ភារបង្រៀន៖** អត្ថបទរឿងនិទាន ស្វាកាន់ខ្មៅ( សម្រាប់គ្រូ )

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរ អ៊ុយ "ប"

**៤. ដំណើរការបង្រៀន៖**( អនុវត្តនៅក្នុងជំហានទី៣ )

- គ្រូបំផុសសំនួរ៖ នៅពេលគូសគំនូរ ឬសរសេរអក្សរលើក្រដាស តើកូនប្រើអ្វីមកគូរឬសរសេរ ? ចូរកូនគិតនិងទាយទៅមើលថា តើថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី ? មេរៀនអំពីអ្វី ? គ្រូសរុបចម្លើយរបស់កុមារ
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជា ភាសាខ្មែរ ចំណងជើងរឿងនិទាន «ស្វាកាន់ខ្មៅដៃ»
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដោយសួរកុមារថា៖ មុននេះមានកូនណាឆ្លើយដូចចម្លើយអ្នកគ្រូដែរឬទេ ? ដូច្នេះកូនទះដៃសរសើរមិត្តភក្តិយើងដែលដែលបានទាយត្រូវទាំងអស់គ្នា
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា

- ប្រាប់ឈ្មោះអ្នកនិពន្ធ៖ រឿងនិទាននេះនិពន្ធដោយអ៊ុំៗជាគ្រូនៅក្រសួងអប់រំ ឱ្យកុមារថាតាម
- គ្រូនិទានរឿងផ្ទាល់មាត់ឱ្យកុមារស្ដាប់ ដោយលើកដាក់សម្លេងតាមតួអង្គនៃសាច់រឿង
- គ្រូនាំកុមារអានពាក្យពិបាក ជាក្រុម និងទាំងអស់គ្នា ហើយប្រាប់ពីន័យរបស់ពាក្យ៖
  - ស្នូរ មានន័យថា សូរសំឡេង
  - អង្អែល មានន័យថា បោសថ្នមៗលើខ្លួន
  - សម្រូត មានន័យថា ទាញចុះក្រោម
  - ញញឹមញញែម មានន័យថា ទឹកមុខរីករាយសប្បាយចិត្ត។
- គ្រូសួរកុមារ៖ក្រោយពីស្ដាប់រឿងនេះចប់ តើក្នុងរឿងមានតួអង្គប៉ុន្មាន? តួអង្គណាខ្លះ? តើសា និងដាជាសត្វអ្វី? តើពួកគេកំពុងលេងនៅឯណា ?តើពួកគេបានឃើញអ្វី? តើដា បានប្រាប់ទៅសាពីរបៀបកាន់ខ្មៅដៃដូចម្ដេចខ្លះ? តើសាអាចរៀនគូស ឬសរសេរអ្វីខ្លះផ្សេងទៀតជាមួយខ្មៅដៃ? តើកូនគិតថាសា និង ដា ជាមិត្តភក្ដិដូចម្ដេច?ហេតុអ្វី? (កុមារឆ្លើយតបសំណួរគ្រូទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូសង្ខេបរឿងឱ្យកុមារស្ដាប់ឡើងវិញម្ដងទៀត
- បន្ទាប់មកគ្រូឱ្យកុមារនិយាយសង្ខេបរឿងឡើងវិញឱ្យមិត្តភក្ដិស្ដាប់ (កុមារនិយាយពីអ្វីដែលគេបានចងចាំ
- ប្រាប់ឈ្មោះអ្នកនិពន្ធ ៖ រឿងនេះ អ៊ំៗនៅក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកនិពន្ធ ។

រឿងនិទាន៖ ស្វាកាន់ខ្មៅដៃ

មានស្វាតូចៗពីរ មួយឈ្មោះ សា និងមួយទៀតឈ្មោះ ដា។ ស្វាទាំងពីរអង្គុយនៅលើដើមឈើមួយ ពួកវាមើល មកក្រោម បានឃើញក្មេងៗ កំពុងលេងនៅក្នុងទីធ្លាសាលារៀន។ ស្នូរជួងបានបន្លឺឡើង ម៉ឹង ម៉ឹង ម៉ឹង ក្មេងៗ បាននាំគ្នា ប្រញាប់ដើរចូលថ្នាក់រៀនវិញ។

សា ស្រែកថា ៖ អូ មើលពួកក្មេងៗ ទុកអ្វីនៅលើដី ប្រហែលជានំហើយ។ សា អង្អែលពោះដូចជាឃ្លានខ្លាំង ដា និយាយថា ៖ តោះយើងទៅមើល។ ពួកវាសម្រូតចុះយ៉ាងលឿន ពីលើដើមឈើមកខាងក្រោមមានខ្មៅដៃ មួយផ្ដេកនៅលើដី។

សានិយាយថា៖ អូ! មានស្អីគេហ្នឹងចង្អុលមករកខ្ញុំ ។ សា មិនដឹងថានោះជាខ្មៅដៃទេ វាក៏លើកខ្មៅដៃនោះឡើងដោយប្រើមេដៃ និងចង្អុលដៃរបស់វា។ តើនេះជាអ្វី?

ដា ឆ្លើយថា៖ វាជាខ្មៅដៃ ឯងកាន់ខ្មៅដៃដោយមេដៃ និងចង្អុលដៃរបស់ឯង ហើយប្រើដៃម្ខាងទៀត បង្វិលវា ឱ្យមកនៅលើប្រអប់ដៃរបស់ឯង។ ដា បានធ្វើបង្ហាញ។

សា និយាយថា ៖ អូ វាស្រួលកាន់ជាងមុន ប៉ុន្តែខ្ញុំចុកដៃ ។

ដា និយាយថា ៖ មិនអីទេដាក់ម្រាមដៃផ្សេងទៀតមកខាងក្រោមខ្មៅដៃរបស់ឯង ហើយដាក់ដៃឱ្យដល់ដីទៅ។ សា ដាក់ម្រាមដៃរបស់វានៅក្រោមខ្មៅដៃហើយនិយាយថា ៖ វាស្រួលជាងមុនហើយ មើលនែ ! បើខ្ញុំកម្រើក ត្រង់នៅលើដី ខ្ញុំអាចគូសគំនូសបាន ។

ដា សើចហើយនិយាយថា ៖ ឯងក៏អាចរៀនគូសនិងសរសេរអ្វីផ្សេងៗ ទៀតដូចជាគំនូសផ្ដេក គំនូសទេទៅ ឆ្វេង ទេរទៅស្ដាំ កោងផ្កាប់ កោងផ្ងារ រង្វង់ និងគំនូសអ្វីផ្សេងៗ ទៀតបាន មិនត្រឹមតែនៅលើដីទេ អាចសរសេរនៅលើ ក្រដាស ឬលើសៀវភៅបាន

សា សួរ ៖ ពិតមែនឬ ? ឯងអាចជួយខ្ញុំបានទេ?

ដាឆ្លើយ៖ ពិតជាបាន! ថាហើយ សា និង ដា បានញញឹមញញែមដាក់គ្នា ហើយក៏លាគ្នាទៅផ្ទះរៀងៗខ្លួន។

ម៉ោងទី៨ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ ភាសាខ្មែរ

## សម្គាល់តួអក្សរៈ "ឈ"

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីរូបរាង និងឈ្មោះអក្សរ "**ឈ**" បានត្រឹមត្រូវ
- កុមារកំណត់បានពីរូបរាងឈ្មោះអក្សរ"**ឈ**" និងរកពាក្យថ្មីផ្តើមចេញពីអក្សរ"**ឈ**" បានត្រឹមត្រូវ
- កុមារក្លាហាន និងយកចិត្តទុកដាក់ ព្យាយាមក្នុងការរកពាក្យថ្មីផ្តើមពីអក្សរ"ឈ"។

**២. សម្ភារបង្រៀនៈ**

- ផ្ទាំងរូបភាព ឈើ ឈូក ឈូសឈើ
- បណ្ណពាក្យ ឈើ ឈូក ឈូសឈើ ងាវ និងល្បះ ពូឈុំឈូសឈើ
- ប៊ិក ហ្វឺត ស្កុត (កាត់រៀបចំឱ្យហើយ)

**៣. ការរៀបចំកុមារៈ** អង្គុយជាអក្សរ អ៊ុយ "ប"

**៤. ដំណើរការបង្រៀនៈ**

**+ រកពាក្យ និងឃ្លា**

- គ្រូបង្ហាញផ្ទាំងរូបភាព "ឈើ" ដោយបិទបាំងបញ្ចេញខាងលើបន្តិច ខាងក្រោមបន្តិច ខាងឆ្វេងបន្តិច ខាងស្តាំបន្តិច រួចឱ្យកុមារទាយ
- បើករូបបង្ហាញ ដើម្បីផ្ទៀងផ្ទាត់ចម្លើយ (បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត ហើយយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចបង្ហាញបណ្ណពាក្យ "ឈើ" បិទពីក្រោមរូប រួចនាំកុមារអានទាំងរូប និងពាក្យដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញរូបភាព"**ឈូក**" ដោយលាស់មួយភ្លែតឱ្យកុមារឃើញ ហើយឱ្យកុមារទាយ បន្ទាប់មកគ្រូបង្ហាញរូបដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចបង្ហាញបណ្ណពាក្យ "**ឈូក**" ហើយបិទពីក្រោមរូប និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូឱ្យកុមារមួយនាក់ចេញទៅក្រៅថ្នាក់ ហើយមើលផ្ទាំងរូបភាព "**ឈូសឈើ**" រួចហើយឱ្យចូលថ្នាក់វិញ ហើយខ្សឹបពាក្យ "**ឈូសឈើ**" បន្តគ្នាឱ្យបាន ០៥នាក់។ ខ្សឹបដល់អ្នកទី០៥ ត្រូវឱ្យអ្នកទី០៥ និយាយប្រាប់មិត្តភក្តិឮពាក្យអ្វី? រួចសួរអ្នកទី១វិញ ត្រឹមត្រូវឬទេ? បន្ទាប់មក គ្រូបង្ហាញរូបភាព "**ឈូសឈើ**" ដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវ សរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន ហើយបង្ហាញបណ្ណពាក្យ"ឈូសឈើ" និងបិទពីក្រោមរូបភាព និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញឃ្លា "**ពូឈុំឈូសឈើ**" អានឱ្យកុមារស្តាប់រួចយកបិទពីក្រោមពាក្យ
- នាំកុមារអានរូប ពាក្យ និងឃ្លា (២ដង) គ្រូនាំកុមារអានផង និងចង្អុលផង។

**+ ស្តាប់សូរពាក្យ និងឃ្លាៈ**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារស្តាប់ (២ឬ៣ចប់) ដើម្បីឱ្យកុមារទាយសូរ និងញែកសូរនៃពាក្យ និងឃ្លា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- សួរកុមារ តើពាក្យ និងឃ្លាដែលគ្រូបានអានអម្បាញ់មិញឮសូរដូចម្តេច? (ពេលកុមារឆ្លើយ គ្រូមិនបាច់

វាយតម្លៃត្រូវឬខុសទេ)។

**+ ពិនិត្យរូបរាងអក្សរនៅក្នុងពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារសង្កេត (២ឬ៣ចប់) ដើម្បីឱ្យកុមារពិនិត្យរករូបរាងតួអក្សរដែលមានរាងដូចគ្នាច្រើន (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- គ្រូឱ្យកុមារដែលស្ម័គ្រចិត្តឡើងមកគូសវង់ជុំវិញតួអក្សរដែលមានរាងដូចគ្នាច្រើន (ពេលកុមារឡើងមកគូសជុំវង់វិញអក្សរមានរាងដូចគ្នាច្រើន បើកុមារចង់គូសប៉ុណ្ណាឱ្យគេគូសតាមចិត្តរបស់គេ គ្រូមិនត្រូវបញ្ឈប់ឬបង្ខំគេឡើយ)
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលទាំងអស់គ្នា បើមានកុមារគូសវង់ខុសត្រូវឱ្យកុមារដទៃជួយកែតម្រូវ។ នាំកុមាររាប់ចំនួនអក្សរដែលកុមារគូសវង់ដើម្បីផ្ទៀងផ្ទាត់ពីចំនួនច្រើន។

+ ប្រាប់ឈ្មោះតួអក្សរ៖

- សួរកុមារ តើតួអក្សរដែលកូនគូសវង់ជុំវិញនៅក្នុងពាក្យ និងឃ្លានោះឈ្មោះអក្សរអ្វី? បើកុមារឆ្លើយមិនត្រូវទេនោះ គ្រូត្រូវប្រាប់រួចនាំកុមារអាន (ក្រុមរួចទាំងអស់គ្នា)
- គ្រូបង្ហាញអក្សរចល័ត "ឈ" រួចសួរកុមារ អក្សរដែលគ្រូបង្ហាញនេះរាងដូចអក្សរដែលកូនបានគូសវង់នោះឬទេ? បើដូច ឈ្មោះអក្សរអ្វីដែរ?
- គ្រូសរសេរអក្សរ"ឈ" យ៉ាងធំនៅជ្រុងក្តារខៀន ដើម្បីឱ្យកុមារសង្កេតពីទិសនៃសំណេរ
- គ្រូសួរកុមារ អក្សរដែលគ្រូសរសេរនេះតើដូចអក្សរដែលគ្រូបង្ហាញនេះដូចអក្សរដែលកូនគូសវង់ឬទេ? ឈ្មោះអ្វី?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនអក្សរ"ឈ" នាំកុមារអានអក្សរ"ឈ" (ក្រុមរួចទាំងអស់គ្នា) ឱ្យបាន២ឬ៣ដង
- គ្រូសរសេរចំណងជើងមេរៀនលើក្តារខៀន រួចនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន (ក្រុមរួចទាំងអស់គ្នា)

**+ ប្រៀបធៀបអក្សរស្រដៀង៖**

- គ្រូសរសេរអក្សរ "ឈ ល ស " នៅលើក្តារខៀន
- គ្រូអានអក្សរ "ឈ ល ស" ឱ្យកុមារស្តាប់ និងសង្កេត
- សួរកុមារ តើអក្សរទាំងអស់នេះមានលក្ខណៈដូចគ្នានៅត្រង់ណាខ្លះ? ហើយខុសគ្នាត្រង់ណាខ្លះ?
- កុមារនិយាយប្រាប់ផងឡើងមកចង្អុលផង។

**+ រកពាក្យថ្មីផ្តើមពីអក្សរ"ឈ" ៖**

- គ្រូអានពាក្យ និងឃ្លាសារឡើងវិញឱ្យបានច្រើនដងដើម្បីឱ្យកុមារស្តាប់សូរ
- ឱ្យកុមាររកពាក្យថ្មីដែលផ្តើមពីអក្សរ"ឈ"
- គ្រូសរសេរពាក្យដែលកុមាររកបាននៅលើក្តារខៀនទាំងអស់ទាំងពាក្យត្រឹមត្រូវ និងពាក្យមិនត្រឹមត្រូវ
- នាំកុមារផ្ទៀងផ្ទាត់ដោយគ្រូអានម្តងមួយពាក្យៗ រួចសួរកុមារតើពាក្យនេះមានអក្សរ"ឈ" ឬទេ? បើត្រឹមត្រូវគ្រូគូសវង់ជុំវិញពាក្យនោះ។ បើពាក្យខុសគ្រូមិនត្រូវធ្វើអ្វីទាំងអស់។ គ្រូធ្វើរបៀបនេះទាល់តែអស់ពាក្យដែលកុមាររកបាន។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ ចិត្តចលភាព

## ល្បែង៖ ផ្ទាត់កៅស៊ូគងគ្នា

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបធ្វើចលនាម្រាមដៃផ្ទាត់កៅស៊ូគងគ្នាបានត្រឹមត្រូវ
- កុមារធ្វើចលនាម្រាមដៃផ្ទាត់កៅស៊ូគងគ្នាបានត្រឹមត្រូវ
- កុមារព្យាយាម អំណត់ ស្វាហាប់ ប្រុងប្រយ័ត្ន រហ័សរហួន ទន់ភ្លន់ និងសប្បាយរីករាយ

**២. សម្ភារបង្រៀន៖** មានកៅស៊ូចំនួន៥ ស្បោងខ្មៅតូចៗ( ស្បោងអាស្រ័យទៅតាមចំនួនក្រុម )

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរ អ៊ុយ "U" កុមារអង្គុយជារង្វង់តាមក្រុមតូចៗ

**៤. ដំណើរការបង្រៀន៖**( អនុវត្តនៅក្នុងជំហានទី៣ )

- គ្រូប្រាប់ពីមុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមជាក្រុមនិងទាំងអស់គ្នា
- គ្រូដាក់ស្បោងសម្ភារនៅលើតុពីមុខកុមារ រួចឱ្យកុមារស្ម័គ្រចិត្តចំនួន ៣ នាក់មកស្ទាបហើយទាយសម្ភារនៅក្នុងស្បោងខ្មៅរួចឱ្យទៅអង្គុយកន្លែងវិញ។
- គ្រូឱ្យកុមារ១នាក់ឡើងមកលូកយកសម្ភារៈនៅក្នុងស្បោងខ្មៅនោះចេញមួយចំនួន រួចសួរកុមារៈ តើមិត្តភក្តិយើង៣នាក់អម្បាញ់មិញមានអ្នកណាទាយត្រូវឬទេ ?គ្រូសរុបចម្លើយរបស់កុមារ
- គ្រូឱ្យកុមារទាំងអស់ទះដៃសរសើរមិត្តភក្តិដែលបានទាយត្រូវនឹងលើកទឹកចិត្តអ្នកដែលទាយ មិនទាន់ត្រូវ។
- គ្រូសួរកុមារៈ តើកូនដឹងទេថាគ្រូយកសម្ភារៈនេះមកឱ្យកូនធ្វើអ្វី ?កុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ
- **គ្រូណែនាំពីរបៀបលេង**
  - គ្រូឱ្យកូនៗលេងជាក្រុមតូចៗហើយអង្គុយជារង្វង់ក្នុងមួយក្រុមត្រូវបានសម្ភារនេះចំនួនមួយស្បោង ពេលក្រុមកូននីមួយៗបានសម្ភារៈ ហើយកូនត្រូវចាក់កៅស៊ូពីក្នុងស្បោងខ្មៅដាក់នៅកណ្ដាលរង់ ដោយរាយប៉ាយមិនឱ្យកៅស៊ូនោះគងលើគ្នា ពេលចាក់កៅស៊ូពីក្នុងស្បោងដាក់នៅកណ្តាលរង់ ហើយ កូនៗដណ្តើមគ្នា។
  - ដំបូងក្រុមកូននីមួយៗត្រូវប៉ាវរកអ្នកចាប់ផ្តើមមុនគេ

# ថ្ងៃទី១៣

ម៉ោងទី១ (រយៈពេលៈ ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលនាព

## ហាត់ប្រាណតាមរឿងនិទានៈ ទន្សាយនាំកូនទៅរកចំណី (និទាន)

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីរបៀបធ្វើចលនាដើរ លោត វារ រត់ឡើង ចុះតាមខ្លឹសារនៃរឿងនិទានបានត្រឹមត្រូវ
- កុមារធ្វើចលនាដើរ លោត វារ រត់ឡើង ចុះតាមខ្លឹសារនៃរឿងនិទានបានត្រឹមត្រូវ
- កុមារមានបម្រុងប្រយ័ត្ន ស្វាហាប់ រហ័សរហួន អំណត់ព្យាយាមនិងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ គ្មាន**

**៣. ការរៀបចំកុមារៈ** ឈរជាជួរ

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរទៅតាមទីកន្លែងដែលបានកំណត់
- តើកូនៗទាំងអស់គ្នាធ្លាប់ដើរទៅលេងបឹងជាមួយម៉ាក់ ប៉ាទេ?កូនធ្លាប់ឃើញគេហែលទឹកឬទេ?ដូច្នេះ កូនៗទាំងអស់គ្នាលាតដៃទាំងពីរធ្វើត្រាប់ចលនាហែលទឹកជាមួយគ្រូទាំងអស់គ្នា(នាំកុមារធ្វើចលនាហែលទឹកទៅដល់ទីកំណត់រួចហែលត្រឡប់មកទីកន្លែងដើមវិញ)
- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងៈ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព អំពីហាត់ប្រាណតាមរឿងនិទាន "ទន្សាយនាំកូនទៅរកចំណី" រួចឱ្យកុមារថាតាមជាក្រុមឬ ទាំងអស់គ្នា
- គ្រូនាំកុមារពិភាក្សាអំពីការធ្វើចលនាដើរ រត់ លោត វារឡើង ចុះ ទៅតាមខ្លឹមសាររឿងដោយប្រាប់កុមារ ពេលគ្រូនិទានដល់ពាក្យលោតផ្លោតៗទៅមុខ កូននាំគ្នាលោតទៅមុខ ពេលគ្រូនិទានដល់ពាក្យរត់យ៉ាងលឿន កូនត្រូវរត់យ៉ាងលឿន ពេលគ្រូនិទានដល់ពាក្យដើរកាន់ដៃគ្នាបួនៗនាក់ កូនត្រូវកាន់ដៃគ្នាបួនៗនាក់ និទានដល់ពាក្យដើរលបៗ កូនត្រូវដើរលបៗ ពេលគ្រូនិទានដល់ពាក្យវារឆ្លងកាត់រូង កូនត្រូវវារឆ្លងកាត់រូង និងដល់ពាក្យឡើង ចុះ កូនត្រូវឡើង ចុះ...។
- គ្រូចាប់ផ្ដើមនិទានរឿងបណ្ដើរនាំកុមារធ្វើសកម្មភាពបណ្ដើរតាមខ្លឹមសាររឿង បើកុមារធ្វើចលនាណាមួយមិនទាន់ត្រឹមត្រូវគ្រូជួយកែតម្រូវ **(ក្នុងករណីសល់ម៉ោងគ្រូអាចធ្វើឡើងវិញម្ដងទៀត)**
- គ្រូឱ្យកុមារទាំង អស់មកឈរជាជួររួចសួរថាកូនៗហាត់ទេ?តើកូនស្រេកទឹកឬទេ? បើកូនស្រេកទឹកក្នុងថ្នាក់រៀនយើងមាន តែទឹកក្ដៅ បើកូនចង់ញ៉ាំត្រូវធ្វើដូចម្ដេច?តើផ្លុំដូចម្ដេច? បើផ្លុំខ្លាំងៗវាដូចម្ដេចដែរ? ដូចនេះកូនត្រូវផ្លុំតិចៗ
- គ្រូនាំកុមារធ្វើសកម្មភាពផ្លុំទឹកក្ដៅផឹក កូនៗយកដៃស្ដាំធ្វើកាយវិការដូចកាន់កែវទឹកក្ដៅ រួចយកមកដងទឹកហើយដាក់ជិតមាត់រួចផ្លុំតិចៗ ទាក់ទងនឹងការដកដង្ហើមចូល ចេញ រួចសួរកុមារៈ កូនផ្លុំទឹកត្រជាក់ហើយឬនៅ? បើត្រជាក់ហើយកូននាំគ្នាផឹកទាំងអស់គ្នាដោយប្តូរម្ដងដៃស្ដាំ ម្ដងដៃឆ្វេង (ធ្វើ២ទៅ៣ដង)។

អត្ថបទរឿងនិទាន "ទន្សាយនាំកូនទៅរកចំណី"

ថ្ងៃមួយមេទន្សាយបាននាំកូនលោតផ្លោតៗ ទៅរកចំណីនៅឯព្រៃ។ ពេលវាលោតទៅដល់ព្រៃមេទន្សាយបាននាំកូនដើរស៊ីស្មៅនិងស្លឹកឈើក្នុងព្រៃយ៉ាងសប្បាយរីករាយ។ ពេលកំពុងតែស៊ីស្មៅស្រាប់តែលឺសំលេងឆ្កែចចកលូយ៉ាងខ្លាំង ពួកគេភ័យណាស់ក៏បាននាំគ្នារត់ទៅមុខយ៉ាងលឿន រួចចូលទៅពួនក្នុងគុម្ពោធ

ព្រៃ។ មួយសន្ទុះក្រោយមកមេទន្សាយក៏នាំកូនដើរលបៗ ងាក ឆ្វេង ងាកស្តាំដើរបន្តទៅមុខទៀតហើយជួប និងអូរមួយ មេទន្សាយឱ្យកូនកាន់ដៃគ្នា ប្អូនៗនាក់ដើម្បីលោតរំលងអូរនោះ។ ដើរទៅមុខបន្តិចក៏ជួបប្រទះរូង ថ្មដ៏ធំមួយ មេទន្សាយនាំកូនវារឆ្លងកាត់រូងនោះរួចហើយក៏នាំកូនដើរឡើងចុះៗ តាមដុំថ្ម រហូតដល់ដុំថ្មដ៏ធំ មួយអស្ចារ្យ ។ ពួកគេក៏នាំគ្នាឈរស្រូបយកខ្យល់អាកាសបរិសុទ្ធនៅទីនោះ ពួកគេសំរាកបន្តិចក៏នាំគ្នាវិលត្រ ឡប់មករកទីជំរករបស់គេវិញដោយក្តីរីករាយ ។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈសិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការ បង្រៀនអនុវត្ត ដូចថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ មករៀនឱ្យទៀងទាត់ពេលវេលារៀងរាល់ថ្ងៃ(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១៣ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

### ល្បែង៖ ភ្លើងឆេះលើភ្នំតួអក្សរ ឆ ជ ឈ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីឈ្មោះតួអក្សរចំនួន៣ ឆ ជ ឈ បានត្រឹមត្រូវ
- កុមារបង្ហាញតួអក្សរ៣តួ ឆ ជ ឈ បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បណ្ណតួ**អក្សរ ឆ** ចំនួន២សន្លឹក **អក្សរ ជ** ចំនួន២ **អក្សរ ឈ** ចំនួន២

**៣. ការរៀបចំកុមារ៖** ឱ្យកុមារឈរជុំគ្នាជាបណ្តុំជាមួយគ្រូ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញបណ្ណតួអក្សរ ឆ ជ ឈ ដែលគ្រូបានរៀបចំទុក រួចឱ្យកុមារប្រាប់ឈ្មោះតួអក្សរទាំងនោះ
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
    - គ្រូឱ្យកូនលេងទាំងអស់គ្នា ហើយកូនត្រូវឈរផ្តុំគ្នាជិតគ្រូ
    - គ្រូមានបណ្ណអក្សរ ឆ ចំនួន២សន្លឹក អក្សរ ជ ចំនួន២សន្លឹក និងបណ្ណអក្សរ ឈ ចំនួន២សន្លឹក ។ បណ្ណតួអក្សរនីមួយៗមាន២សន្លឹក គឺមួយសន្លឹកសម្រាប់កាន់លើកបង្ហាញកូន និងមួយសន្លឹកទៀតសម្រាប់បិទនៅតាមដើមឈើ សម្រាប់ឱ្យពួកកូនរត់ចូល
    - កូនៗត្រូវសង្កេតតួអក្សរដែលគ្រូបានបិទនៅតាមដើមឈើដើម្បីចំណាំទីកន្លែង ហើយចាំស្តាប់ពាក្យគ្រូនិយាយ
    - ពេលឮគ្រូនិយាយថា៖ « ភ្លើងឆេះលើភ្នំហើយ » កូនទាំងអស់គ្នាត្រូវរត់តិចៗដោយសេរី
    - ពេលឮគ្រូនិយាយថា៖ «ភ្លើងឆេះលើភ្នំកាន់តែខ្លាំងហើយ» កូនទាំងអស់គ្នាត្រូវរត់លឿនដោយសេរី

- ពេលឮគ្រូនិយាយថា៖ «ភ្លើងរលត់ហើយ» កូនទាំងអស់គ្នាត្រូវមើលមកគ្រូលើកតួអក្សរអ្វី កូនត្រូវនាំគ្នារត់ទៅរកតួអក្សរដែលគ្រូបានបិទនៅលើដើមឈើ ឱ្យដូចតួអក្សរដែលគ្រូបានលើក
- បើកូនណារត់ទៅរកតួអក្សរមិនត្រឹមត្រូវតាមតួអក្សរដែលគ្រូលើកបង្ហាញ គឺជាអ្នកចាញ់ ហើយមិត្តភក្តិជួយកែតម្រូវ

- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមដំណាក់កាលនីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូនាំកុមារលេងទាំងអស់គ្នា ពេលលេងម្តង គ្រូត្រូវនាំកុមារផ្ទៀងផ្ទាត់ម្តង ដោយឱ្យកុមារសង្កេតតួអក្សរដែលគ្រូលើក ទៅនឹងតួអក្សរដែលកុមាររត់ទៅរក និងឱ្យពួកគេប្រាប់ឈ្មោះតួអក្សរនោះ រួចនាំកុមារអានតួអក្សរនោះទាំងអស់គ្នា
- គ្រូនាំកុមារលេងរបៀបនេះឱ្យបានគ្រប់តួអក្សរ ប៉ុន្តែលេងដំបូងគ្រូត្រូវលើកតួអក្សរបង្ហាញតាមលំដាប់ បន្ទាប់មកទៀតលើតួអក្សរបង្ហាញមិនតាមលំដាប់
- គ្រូលើកសរសើរចំពោះកុមារដែលធ្វើបានល្អ ចំពោះកុមារដែលធ្វើមិនទាន់បានល្អគ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ )
- **គ្រូសួរកុមារ៖**
  - កូនៗទាំងអស់គ្នាសប្បាយទេ ? **តើមុននេះ កូនៗបានលេងល្បែងអ្វី?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - **តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ **ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែង មេរៀន** " ភ្លើងឆេះលើភ្នំតួអក្សរ ឆ ជ ឈ "
- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)
- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។**
-

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## ចម្រៀង៖ បណ្តាំអ្នកគ្រូផ្តាំទៅ (ពេលទី២)

**១. វត្ថុបំណង៖**

- កុមារប្រាប់បាន ពី របៀបច្រៀង និងធ្វើកាយវិការតាមបទច្រៀង បានត្រឹមត្រូវ
-កុមារច្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀងបានត្រឹមត្រូវ
-កុមារស្រឡាញ់ចូលចិត្តច្រៀង និងសហការគ្នាដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាអក្សរ "ប" (ក្រោកឈរទាំងអស់គ្នា)

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារប្រាប់ចំណងជើងចម្រៀង
- គ្រូឱ្យកុមារច្រៀង និង ធ្វើកាយវិការកម្រិតពេលទី១សាឡើងវិញ
- កុមារច្រៀង និងធ្វើកាយវិការកម្រិតពេលទី១សាឡើងវិញ

- គ្រូច្រៀងបំបាត់ពាក្យខ្លះៗឱ្យកុមារច្រៀងបំពេញពាក្យដែលបាត់៖ បណ្តាំ..អ្នកគ្រូ... ថាឱ្យ...ពៅជម្រាប ...ចាស់ៗ
- កុមារច្រៀង៖ បណ្តាំដែលអ្នកគ្រូផ្តាំទៅ ថាឱ្យកូនពៅជម្រាបសួរចាស់ៗ
- គ្រូធ្វើកាយវិការ ដូចខ្លឹមសារបទចម្រៀងក្នុងកម្រិតពេលទី១ រីឯកុមារច្រៀងទាំងអស់គ្នា
- គ្រូច្រៀង កុមារទាំងអស់គ្នាធ្វើកាយវិការ តាមបទចម្រៀង។
- គ្រូណែនាំប្រាប់ពីការប្រើសញ្ញាបាតដៃបញ្ជា៖
- បើកាលណាគ្រូផ្ងារបាតដៃឡើងទៅក្រុមណា ក្រុមនោះត្រូវច្រៀង និងធ្វើកាយវិការ
- បើកាលណាគ្រូផ្កាប់បាតដៃចុះទៅក្រុមណា ក្រុមនោះត្រូវឈប់ច្រៀង និងឈប់ធ្វើកាយវិការ
- បើកាលណាគ្រូផ្ងារបាតដៃទាំង២ឡើង ក្រុមនីមួយៗត្រូវច្រៀង និងធ្វើកាយវិការទាំងអស់គ្នា
- ហើយបើកាលណាគ្រូផ្កាប់បាតដៃទាំង២ចុះ ក្រុមនីមួយៗត្រូវឈប់ច្រៀង និងឈប់ធ្វើកាយវិការទាំងអស់គ្នា
- គ្រូនាំកុមារច្រៀង និង ធ្វើកាយវិការទាំងអស់គ្នាសាឡើងវិញជាក្រុម ឬ ទាំងអស់គ្នាឱ្យបាន ២ ឬ ៣ចប់
- គ្រូសួរ៖កូនៗទាំងអស់គ្នាសប្បាយទេ? តើអម្បាញ់មិញកូនៗរៀនមុខវិជ្ជាអ្វី? មានចំណងជើងដូចម្តេច? និងបានធ្វើអ្វីខ្លះ ?
- កុមារឆ្លើយ៖ រៀនមុខវិជ្ជាសិក្សាសង្គម ចម្រៀង បណ្តាំអ្នកគ្រូផ្តាំទៅ ពេលទី២ ឆ្លើយតាមការយល់ដឹងរបស់កុមារ
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះយើងរៀនមុខវិជ្ជាសិក្សាសង្គម ចំណងជើង ចម្រៀង បណ្តាំអ្នកគ្រូផ្តាំទៅ ពេលទី២ គ្រូនាំកុមារអានមុខវិជ្ជា ចំណងជើងមេរៀនជាក្រុម ឬ ទាំងអស់គ្នា ។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

## សង្កេត៖ សម្ភារផ្ទះបាយ

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីឈ្មោះសម្ភារផ្ទះបាយក្នុងគ្រួសារ និងការប្រើប្រាស់បានត្រឹមត្រូវ
- កុមារបង្ហាញសម្ភារៈផ្ទះបាយក្នុងគ្រួសារ និងការប្រើប្រាស់បានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ សប្បាយរីករាយ និងចេះស្រឡាញ់ថែរក្សាសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ ។

**២. សម្ភារបង្រៀន៖** ផ្ទាំងរូបភាពសម្ភារផ្ទះបាយ ( ឆ្នាំង ខ្ទះ ចាន ស្លាបព្រា សម វែក ជ្រុញ់ កាំបិត កញ្ច្រែង...)ចំនួន ៤ផ្ទាំង

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារាងពាក់កណ្តាលរង្វង់ អក្សរ "U" និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរបំផុសកុមារ៖ តើមុនពេលហូបបាយ កូនត្រូវយកសម្ភារៈអ្វីខ្លះ?
- គ្រូយកផ្ទាំងរូបភាពសម្ភារប្រើប្រាស់ក្នុងគ្រួសារដោយពញ្ញាក់អារម្មណ៍ឱ្យកុមារសង្កេត ហើយសួរកុមារថា តើកូនឃើញអ្វីខ្លះក្នុងរូបភាពនេះ?តើរូបភាពនេះប្រាប់កូនពីអ្វី? បើមានកុមារណាឆ្លើយត្រូវគ្រូសរសើរកុមារដោយពាក្យសម្តី (កូនដែលបានឆ្លើយត្រូវកូនឆ្លាតមែន ហើយពូកែទៀត ប៉ុន្តែកូនឆ្លើយមិនត្រូវក៏ឆ្លាតដែរ ដែលក្លាហានហ៊ានឆ្លើយសំណួរគ្រូ)។គ្រូបញ្ជាក់ប្រាប់កុមារ៖ **រូបភាពនេះ គឺជាសម្ភារៈនៅក្នុងផ្ទះបាយ** រួចនាំកុមារអាន

- គ្រូសួរកុមារ៖ **កូនដឹងទេថា គ្រូនឹងឱ្យកូនៗធ្វើអ្វីជាមួយផ្ទាំងរូបភាពនេះ?**
- គ្រូណែនាំកុមារពីរបៀបអនុវត្តតាមក្រុមនីមួយៗ៖
  - **គ្រូឱ្យកូនៗអនុវត្តតាមក្រុមតូចៗ ហើយក្នុងក្រុមនីមួយៗត្រូវបានផ្ទាំងរូបភាពនេះមួយផ្ទាំង**
  - **ពេលក្រុមនីមួយៗបានផ្ទាំងរូបភាពនេះហើយ កូនត្រូវដាក់កណ្តាលវង់ ហើយនាំគ្នាសង្កេតមើលរូបទាំងអស់នោះ ហើយពិភាក្សាគ្នាលើរូបនីមួយៗ ប្រាប់ពីឈ្មោះសម្ភារដែលមានក្នុងផ្ទាំងរូបភាព? តើសម្ភារនីមួយៗគេប្រើសម្រាប់ធ្វើអ្វី? ពេលកូននាំគ្នាសង្កេតកូនកុំដណ្តើមគ្នា កុំដកផ្ទាំងរូបភាពនេះចុះឡើង បើកូនអង្គុយបញ្ច្រាសរូបត្រូវបង្វិលផ្ទាំងរូបភាពឱ្យត្រូវមិត្តភក្តិអាចមើលឃើញច្បាស់។ ហើយបើកូនណាស្គាល់ជួយប្រាប់ទៅមិត្តភក្តិដែលគេមិនស្គាល់ផង។ ហើយកូនត្រូវរកមិត្តណាម្នាក់សម្រាប់ឡើងនិយាយប្រាប់ពីអ្វីដែលកូនបានស្គាល់ និងដឹង**
  - **ពេលកូនៗពិភាក្សាគ្នាចប់គ្រប់ក្រុមហើយ ត្រូវនាំគ្នាទៅអង្គុយនៅក្រុមដុំវិញដោយយកសម្ភារៈទៅរៀងៗខ្លួន។**
- ឱ្យកុមារមួយនាក់ ឡើងនិយាយពីអ្វីដែលត្រូវបានប្រាប់ បើនិយាយមិនបានទេឱ្យមិត្តភក្តិជួយបំពេញបន្ថែម ប៉ុន្តែបើនៅតែនិយាយមិនបានពេញលេញទេនោះគ្រូត្រូវនិយាយប្រាប់កុមារសារឡើងវិញម្តងទៀត
- រៀបចំកុមារជាក្រុមហើយអង្គុយជារង្វង់តាមទីកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូអោយតំណាងក្រុមនីមួយៗមកយកសម្ភារទៅ ហើយនាំគ្នាអនុវត្តតាមការណែនាំ
- គ្រូដើរសម្របសម្រួលកុមារគ្រប់ក្រុមទាំងអស់ ដើម្បីជួយក្រុមណាដែលមិនទាន់យល់ច្បាស់
- ពេលក្រុមនីមួយៗត្រូវបានបញ្ចប់ការងារ គ្រូឱ្យពួកគេទៅអង្គុយនៅក្រុមធំវិញដោយយកផ្ទាំងរូបភាពទៅរៀងៗខ្លួន ទុកបង្ហាញពេលឡើងរាយការណ៍
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងមកនិយាយប្រាប់មិត្តភក្តិនិងគ្រូពីលទ្ធផលដែលពួកគេបានពិភាក្សាគ្នា (ម្តងមួយក្រុមៗ) ដោយលើកផ្ទាំងរូបភាពចង្អុលបង្ហាញឈ្មោះរូបម្តងមួយៗ
-គ្រូត្រូវកែតម្រូវពាក្យដែលពួកគេនិយាយមិនទាន់បានត្រឹមត្រូវតាមអក្ខរាវិរុទ្ធ រួចនាំកុមារអាននូវពាក្យទាំងនោះទាំងអស់គ្នា។
- គ្រូសរុបពីលទ្ធផលរបស់កុមារគ្រប់ក្រុម បន្ទាប់ពីបានស្តាប់ពួកគេនិយាយចប់។ (ឧទាហរណ៍៖ គ្រូស្តាប់បានកុមារប្រាប់បានពីឈ្មោះសម្ភារ និងការបង្ហាញពីការប្រើប្រាស់ បានខ្លះតែប៉ុណ្ណោះ។ នៅមានឈ្មោះសម្ភារ និងការប្រើប្រាស់ផ្សេងទៀតដែលកុមារប្រាប់មិនបាន។ ដូច្នេះគ្រូត្រូវគិតគួរផ្តល់ចំណេះដឹងថ្មីបន្ថែមឱ្យពួកគេអ្វីខ្លះទៀត?)
- គ្រូត្រូវផ្តល់ចំណេះដឹងថ្មីៗបន្ថែមតាមរយៈ៖
  - គ្រូបង្ហាញផ្ទាំងរូបភាពឱ្យកុមារសង្កេតជារួម ឱ្យកុមារបានមើលឃើញទាំងអស់គ្នា។ បន្ទាប់មកគ្រូចង្អុលនឹងប្រាប់ពីឈ្មោះសម្ភារនីមួយៗ និងការប្រើប្រាស់សម្ភារ ឱ្យកុមារបានដឹង
  - គ្រូបំផុសសំណួរ៖ តើកូនត្រូវធ្វើដូចម្តេចដើម្បីថែរក្សាសម្ភារៈផ្ទះបាយឱ្យមានអនាម័យ និងបានគង់វង្ស? បើកុមារមិនអាចឆ្លើយបានគ្រូត្រូវប្រាប់ ហើយនាំកុមារថាតាមជាក្រុមនិងទាំងអស់គ្នា។
- គ្រូយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចនាំកុមារអានឈ្មោះនៅរូបភាពនីមួយៗដោយគ្រូជាអ្នកចង្អុលផងប្រាប់ឈ្មោះផង ប្រាប់ពីការប្រើប្រាស់សម្ភារ និងប្រាប់ពីការថែរក្សាសម្ភារទាំងអស់នោះ ផងដែរ។

- គ្រូសួរកុមារ៖ អម្បាញ់មិញកូនស្គាល់អ្វីខ្លះ ? ដូច្នេះថ្ងៃនេះយើងរៀនពីមុខវិជ្ជាវិទ្យាសាស្រ្តអំពីសង្កេតសម្ភារផ្ទះបាយ
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន (ជាក្រុមនឹងទាំងអស់គ្នា)។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

*** ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី១៤

ម៉ោងទី១ (រយៈពេល៖ ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

### ចលនាមូលដ្ឋាន៖ លោត (លោតជើងពីរទៅមុខ លោតជើងពីរទៅឆ្វេង ទៅស្តាំ លោតកាន់វត្ថុទៅដាក់ក្នុងកន្ត្រក)

**១. វត្ថុបំណង៖**

- កុមាររៀបរាប់ពីរបៀប លោតជើងទាំងពីរទៅមុខ លោតជើងទាំងពីរទៅឆ្វេងទៅស្តាំ លោតកាន់វត្ថុ ទៅដាក់ក្នុងកន្ត្រក តាមលំដាប់លំដោយបានច្បាស់លាស់
- កុមារ លោតជើងទាំងពីរទៅមុខ លោតជើងទាំងពីរទៅឆ្វេងទៅស្តាំ លោតកាន់វត្ថុទៅដាក់ក្នុងកន្ត្រក តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន បម្រុងប្រយ័ត្ន អំណត់ព្យាយាម សហការគ្នា និងសប្បាយ រីករាយ

**២. សម្ភារបង្រៀន៖** កូនបាល់តូចៗនិងកន្ត្រក

**៣. ការរៀបចំកុមារ៖** ចែកកុមារជាបីក្រុម ដោយឱ្យកុមារឈរជាជួរ (ករណីកុមារច្រើនអាចចែកជា៦ក្រុម ដោយ២ក្រុមធ្វើ១សកម្មភាព)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនាំកុមារធ្វើសកម្មភាពលោត ដោយឱ្យកុមារធ្វើចលនាលោតដូចសត្វកង្កែប ទៅតាមទីកន្លែងដែលគ្រូបាន កំណត់
- គ្រូបង្ហាញសម្ភារម្តងមួយៗឱ្យកុមារប្រាប់ឈ្មោះ
- គ្រូណែនាំកុមារពីរបៀបធ្វើចលនាមូលដ្ឋានលោត នីមួយៗ (លោតជើងទាំងពីរទៅមុខ លោតជើងទាំងពីរទៅឆ្វេង ទៅស្តាំ លោតកាន់វត្ថុទៅដាក់ក្នុងកន្ត្រក )
    - លោតបង្ហាញ៖ជើងទាំងពីរដាក់ទឹមគ្នាលោតទៅមុខ ជើងទាំងពីរដាក់ទឹមគ្នាលោតជើងទាំងពីរទៅឆ្វេងទៅ ស្តាំ ជើងទាំងពីរដាក់ទឹមគ្នាលោតកាន់កូនបាល់ទៅដាក់ក្នុងកន្ត្រកឆ្ពោះទៅដល់ទិសដៅដែលបានកំណត់។
- គ្រូឱ្យកុមារ១ឬ២នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ (បើកុមារនិយាយមិនបានគ្រូគ្រូប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាបីក្រុមនិងអនុវត្តតាមសកម្មភាពនីមួយៗ៖
    - ក្រុមទី១៖ លោតជើងពីរទៅមុខឆ្ពោះទៅដល់ទិសដៅដែលបានកំណត់
    - ក្រុមទី២៖លោតជើងពីរទៅមុខទៅឆ្វេងទៅស្តាំឆ្ពោះទៅដល់ទិសដៅដែលបានកំណត
    - ក្រុមទី៣៖លោតកាន់កូនបាល់ទៅដាក់ក្នុងកន្ត្រកឆ្ពោះទៅទិសដៅដែលបានកំណត់
- បន្ទាប់ពីកុមារបានលោតតាមរបៀបខាងលើរួចគ្រូឱ្យក្រុមនីមួយៗប្តូរសកម្មភាពលោតតាមសញ្ញារបស់គ្រូ។
- គ្រូដើរសម្របសម្រួលតាមក្រុមទាំង៣ ដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានលោតគ្រប់សកម្មភាព
- គ្រូសួរកុមារ៖
    - តើមុននេះ កូនៗបានធ្វើចលនាអ្វីខ្លះ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
    - គ្រូសួរទៅកុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)

- គ្រូប្រាប់កុមារថា ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព មានចំណងជើងមេរៀន៖ ចលនាមូលដ្ឋាន លោត "លោត ជើងទាំងពីរទៅមុខ លោតជើងទាំងពីរទៅឆ្វេងទៅស្ដាំ លោតកាន់វត្ថុទៅដាក់ក្នុងកន្ត្រក
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយរបស់គ្រូឬទេ? បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)
- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា**
- គ្រូនាំកុមារផ្លុំទឹកក្ដៅដោយដកដង្ហើមចូល ចេញវែងៗ (កូនៗយកដៃ ធ្វើកាយវិការដូចកាន់កែវទឹកក្ដៅ រួចយកមក ដាក់ជិតមាត់ ហើយផ្លុំ ដោយដកដង្ហើមចូល ចេញឱ្យវែងៗ រហូតដល់ទឹកត្រជាក់ រួចកូនញ៉ាំ គ្រូសួរកុមារថាតើកូនៗ ឆ្អែតហើយឬនៅ? កុមារឆ្លើយថាឆ្អែតហើយ) គ្រូអាចឱ្យកុមារធ្វើ ពីរ ឬបីដងក៏បាន តាមជាក់ស្ដែង ។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈសិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

✱ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការ បង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី២)

✱ ទម្លាប់ល្អ៖ មករៀនឱ្យទៀងទាត់ពេលវេលារៀងរាល់ថ្ងៃ(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២)

✱ គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១៤ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ វិទ្យាសាស្ត្រ

### ល្បែង៖ ថង់ទិព្វទាយឈ្មោះវត្ថុជាតុដើមនៃសម្ភារផ្ទះបាយ

**១. វត្ថុបំណង៖**

- កុមារប្រាប់ឈ្មោះវត្ថុជាតុដើមនៃសម្ភារផ្ទះបាយ បានត្រឹមត្រូវ
- កុមារទាយឈ្មោះវត្ថុជាតុដើមនៃសម្ភារផ្ទះបាយ បានត្រឹមត្រូវ
- កុមារខិតខំយកចិត្តទុកដាក់ ចងចាំឈ្មោះវត្ថុជាតុដើមនៃសម្ភារផ្ទះបាយ ព្យាយាមអំណត់ និងសប្បាយរីករាយ

**២. សម្ភារបង្រៀន៖** កូនកាសឈ្មោះរូបសម្ភារផ្ទះបាយ ថង់

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារាងអក្សរ អ៊ុយ U និងចែកកុមារជាក្រុមតូចៗឱ្យអង្គុយជារង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូលើកថង់ និងកូនកាសរូបសម្ភារផ្ទះបាយ បង្ហាញកុមារ រួចឱ្យកុមារប្រាប់ឈ្មោះ
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
    - កូនៗត្រូវឈរជារង្វង់ ហើយគ្រូកំណត់យកកូនណាម្នាក់ជាអ្នកចាប់ផ្ដើមកាន់ថង់មុនគេ
    - ពេលឮគ្រូឱ្យសញ្ញាទះដៃ កូនដែលកាន់ថង់ត្រូវហុចទៅអ្នកស្ដាំដៃបន្តៗគ្នា ដោយច្រៀងបណ្ដើរ ទះដៃបណ្ដើរ

- ពេលគ្រូឱ្យសញ្ញាបញ្ឈប់ ថង់នៅដៃកូនណា កូននោះត្រូវលូកដៃយករូបកូនកាស នោះមួយសន្លឹកមកមើល ហើយប្រាប់ឈ្មោះសម្ភារផ្ទះបាយរួចអោយកូនផ្សេងទៀតជាអ្នកទាយថាវត្ថុធាតុដើមដែលយកមកធ្វើសម្ភារនេះ គឺជាអ្វី
- បន្ទាប់មកកូនលើកកូនកាសនោះបង្ហាញមិត្តភក្តិ ដើម្បីផ្ទៀងផ្ទាត់ចម្លើយរួចកូនត្រូវយកកូនកាសនោះឱ្យគ្រូទុក ។ ពេលផ្ទៀងផ្ទាត់លទ្ធផលហើយ កូនត្រូវហុចថង់នោះទៅមិត្តភក្តិបន្តទៀតតាមសញ្ញាបញ្ជារបស់គ្រូ ។ កូនលេងរបៀបនេះរហូតដល់គ្រូបញ្ឈប់ ។
- ពេលកូនណាទាយខុស គឺជាអ្នកចាញ់ ហើយឱ្យមិត្តភក្តិដទៃទៀតជួយប្រាប់ និងកែតម្រូវ

- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមដំណាក់កាលនីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូនាំកុមារអនុវត្តការលេង ដោយគ្រូកែតម្រូវចំពោះកុមារណាដែលលេងមិនទាន់ត្រឹមត្រូវ
- **គ្រូសួរកុមារ៖**
    - កូនៗទាំងអស់គ្នាសប្បាយទេ?**តើមុននេះកូនៗបានលេងល្បែងអ្វី**?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
    - **តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ **ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ អំពីល្បែង មេរៀន** " ថង់ទិព្វ ទាយឈ្មោះវត្ថុធាតុដើមនៃសម្ភារផ្ទះបាយ "
- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)
- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា** ។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## គំនូរ៖ ផាត់ពណ៌រូបពែងទឹក

### ១. វត្ថុបំណង៖

- កុមារប្រាប់ពីរបៀបផាត់ពណ៌រូបពែងទឹកបានត្រឹមត្រូវ
- កុមារកាន់ខ្មៅដៃពណ៌ ផាត់ពណ៌រូបពែងទឹកដោយទប់លំនឹងបង្វិលតាមរូបបានត្រឹមត្រូវ
- កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់ សហការចូលរួមយ៉ាងសកម្មនិងសប្បាយរីករាយ។

### ២.សម្ភារបង្រៀន៖

\+ **សម្ភារសម្រាប់គ្រូ៖**

- ផ្ទាំងក្រដាសដែលមានរូបរូបពែងទឹកផាត់ពណ៌រួចចំនួន១សន្លឹក
- ផ្ទាំងក្រដាសរូបរូបពែងទឹកមិនទាន់ផាត់ពណ៌ដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀន(ក្រដាសផ្ទាំងធំ)
- ខ្មៅដៃពណ៌ចំនួន២ដើម(២ពណ៌),ស្កុតចំនួន១ដុំ។

\+ **សម្ភារសម្រាប់កុមារ៖**ផ្ទាំងក្រដាសរូបរូបពែងទឹកមិនទាន់ផាត់ពណ៌ដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្ត

មុខវិជ្ជា និងចំណងជើងមេរៀននៅក្បាលសន្លឹកកិច្ចការគ្រប់ចំនួនកុមារ និងខ្មៅដៃពណ៌សម្រាប់កុមារ

**៣. ការរៀបចំកុមារ៖**អង្គុយរាងអក្សរ "ប" ចែកកុមារជាក្រុម(អនុវត្តជាបុគ្គល)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរ៖ តើកូនយកអ្វីទៅដួសទឹកញ៉ាំជារៀងរាល់ថ្ងៃ? (ចម្លើយតាមគំនិតកុមារម្នាក់ៗ)
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារថាតាម(ជាក្រុមនិងទាំងអស់គ្នា)
- គ្រូបង្ហាញផ្ទាំងក្រដាសរូបដែលមានរូបរូបពែងទឹកផាត់ពណ៌រួចស្រេច ឱ្យកុមារសង្កេតនិងប្រាប់ឈ្មោះ រួចបិទនៅលើក្តារខៀនឱ្យកុមារមើលជាគំរូ
- គ្រូបង្ហាញផ្ទាំងក្រដាសរូបរូបពែងទឹក១សន្លឹកទៀត ដែលគ្រូមិនទាន់ផាត់ពណ៌ឱ្យកុមារសង្កេត
- គ្រូប្រាប់កុមារ៖ ផ្ទាំងក្រដាសរូបនេះគ្រូទុកសម្រាប់ផាត់ពណ៌ឱ្យកូនមើលពីរបៀបផាត់ពណ៌។ ដូច្នេះកូននាំគ្នាចាំមើលទាំងអស់គ្នាតើគ្រូចាប់ផ្តើមផាត់ពណ៌ពីណាទៅណា?
- គ្រូយកផ្ទាំងក្រដាសរូបនោះទៅបិទនៅលើក្តារខៀន ជិតផ្ទាំងក្រដាសជាគំរូដើម្បីណែនាំពីរបៀបផាត់ពណ៌
- គ្រូណែនាំពីរបៀបផាត់ពណ៌នៅលើផ្ទាំងក្រដាសរូបរូបពែងទឹកដែលបានបិទលើក្តារខៀន ដោយផាត់ពណ៌បណ្តើរ និយាយប្រាប់កុមារបណ្តើរយឺតៗ ដើម្បីឱ្យកុមារសង្កេតពីទិសនៃការផាត់ពណ៌។
- គ្រូប្រាប់កុមារ៖
  - កូនយកខ្មៅដៃពណ៌មកផាត់រូបរូបពែងទឹកដោយចាប់ដោយកូនចាប់ផ្តើមទាញពីលើចុះក្រោមដោយមិនឱ្យផាត់ចេញក្រៅរូបភាពរូបពែងទឹកទេ។ កូនៗត្រូវផាត់បន្ទើរៗរបៀបនេះឱ្យពេញរូបពែងទឹក។ (តាមរូបគំនូរផាត់ពណ៌របស់គ្រូជាក់ស្តែង)
  - បន្ទាប់មកកូនយកខ្មៅដៃពណ៌កូនផាត់ពណ៌រូបពែងទឹកឱ្យពេញលេញ
- គ្រូបង្ហាញផ្ទាំងក្រដាសជាសន្លឹកកិច្ចការកុមារម្នាក់ៗរួចប្រាប់កុមារ=កូនម្នាក់ៗត្រូវបានផ្ទាំងសន្លឹកកិច្ចការនេះមួយសន្លឹកនិងខ្មៅដៃពណ៌ សម្រាប់កូនផាត់ពណ៌ទៅតាមអ្វីដែលគ្រូបានបង្ហាញ
- គ្រូរៀបចំកុមារឱ្យអង្គុយទៅតាមតុដែលគ្រូបានរៀបចំឬបង្វិលកៅអី អង្គុយផាត់ពណ៌ (តាមស្ថានភាពជាក់ស្តែង)
- ឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅចែកគ្នាអនុវត្ត
- កុមារម្នាក់ៗនាំគ្នាអនុវត្ត គ្រូដើរសម្របសម្រួលគ្រប់ក្រុម ដើម្បីជួយកុមារណាដែលមិនទាន់ចេះកាន់ខ្មៅដៃពណ៌ផាត់ និងមិនទាន់យល់ពីរបៀបផាត់ និងដាក់ឈ្មោះកុមារម្នាក់ៗពីខាងក្រោមសន្លឹកកិច្ចការ
- គ្រូប្រាប់កុមារ៖ ពេលកូនផាត់រួចហើយកូនយកខ្មៅដៃពណ៌ទៅទុកឱ្យគ្រូវិញ ហើយសន្លឹកកិច្ចការរបស់កូនទុកនៅរៀងៗខ្លួន។
- ពេលកុមារផាត់ហើយគ្រប់គ្នា គ្រូឱ្យកុមារទៅអង្គុយកន្លែងដើមជារាងអក្សរ(អ៊ុយ)វិញ
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារទៅឈរម្តងមួយក្រុមនៅខាងមុខ ហើយកាន់សន្លឹកកិច្ចការដាក់នៅត្រង់ដើមទ្រូងបង្ហាញមិត្តភក្តិ ដើម្បីឱ្យពួកគេជាអ្នកផ្ទៀងផ្ទាត់។
- គ្រូសួរកុមារដែលជាអ្នកផ្ទៀងផ្ទាត់: តើមិត្តភក្តិយើងផាត់បានត្រឹមត្រូវទេ? ស្អាតទេ? បើមានកុមារណាបង្អាប់គំនូររបស់មិត្តភក្តិណាម្នាក់ គ្រូត្រូវចេះកែតម្រូវទៅជាពាក្យសម្តីលើកទឹកចិត្តកុមារនោះវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការរបស់មិត្តភក្តិគេឱ្យគ្រូសម្រាប់ទុកដាក់តាំងស្នាដៃកុមារ។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ បុរេគណិត

## សម្គាល់៖ ឆ្វេង-ស្តាំ មុខ-ក្រោយ

**១. វត្ថុបំណង៖«**

- កុមារប្រាប់ពីបញ្ញាត្តិទីតាំងក្នុងលំហ ឆ្វេងស្តាំមុខក្រោយ បានត្រឹមត្រូវ។
- កុមារកំណត់ទីតាំង ក្នុងលំហ ឆ្វេងស្តាំមុខក្រោយ បានត្រឹមត្រូវ។
- កុមារឈ្លាសវៃ រហ័សរហួនមានបម្រុងប្រយ័ត្ន ក្នុងការធ្វើសកម្មភាព ដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** កៅអី

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរ អ៊ុយ "U"

**៤.ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

**-គ្រូបំផុសសំណួរ៖**

- កូនៗសង្កេតមើល តើក្តាខៀនយើងនៅឯណា?តើសម្ភារលេងដែលកូនលេងរាល់ថ្ងៃនៅកន្លែងណាខ្លះ?
- តើ ថ្ងៃនេះយើង រៀនមុខវិជ្ជាអ្វី ? មេរៀនអ្វី?

- គ្រូប្រាប់ពីមុខវិជ្ជានិងចំណងជើង៖ ថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជាៈបុរេគណិត ចំណងជើង៖សម្គាល់ "ឆ្វេងស្តាំ មុខក្រោយ"
- គ្រូផ្ទៀងផ្ទាត់ចម្លើយកុមារដែលបានឆ្លើយទៅនឹងអ្វីដែលគ្រូបានប្រាប់( តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយរបស់គ្រូឬទេ? បើកូនណាឆ្លើយត្រូវគ្រូលើកសរសើរ បើកូនឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើង ២ទៅ ៣ដង តាមក្រុមនិងទាំងអស់គ្នា
- គ្រូឱ្យកុមារលើកដៃទាំងពីរឡើងទៅលើ រួចដាក់ចុះវិញបន្ទាប់មកគ្រូឱ្យកុមារលើកដៃស្តាំឡើងលើរួចដាក់ចុះវិញក្រោយមកទៀត គ្រូឱ្យកុមារលើកដៃឆ្វេងឡើងលើរួចដាក់ចុះវិញ ។
- គ្រូឱ្យកុមារម្នាក់ (ក)មកឈរជាគោល ហើយឱ្យកុមារ(ខ)មកឈរមួយចហៀងកុមារ(ក)និងកុមារ(គ) មកឈរមួយចំហៀងកុមារ(ក)រួចសួរកុមារទាំងអស់គ្នាថាតើកុមារ(ខ)ឈរនៅខាងណា?ហើយកុមារ (គ)ឈរនៅខាងណា?រួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូឱ្យកុមារ៣នាក់(ចឆជ)មកឈរជាជួរ រួចគ្រូសួរកុមារថាតើកុមារ(ច)ឈរនៅខាងណាកុមារ(ឆ)? ហើយកុមារ(ជ)ឈរនៅខាងណាកុមារ(ឆ) ?រួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូឱ្យកុមាររកអ្វីៗដែលស្ថិតនៅផ្នែកខាងឆ្វេង ផ្នែកខាងស្តាំ ផ្នែកខាងមុខ ផ្នែកខាងក្រោយ ដោយយកខ្លួនរបស់គាត់ជាគោល (នៅក្នុងថ្នាក់រៀន)
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផលដែលគេអនុវត្ត

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

**✱ ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ:**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី១៥

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

**ចលនាចរន្តៈ ដើរ រត់ លោត (ដើរជំហានវែងៗទៅមុខ រត់ទៅវាយវត្ថុចងព្យួរ លោតជើង២ទៅមុខ ដើរលឿនទៅមុខ**

**១. វត្ថុបំណងៈ**

- កុមាររៀបរាប់ពីរបៀបធ្វើចលនានីមួយៗ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារធ្វើចលនានីមួយៗ តាមលំដាប់លំដោយបាន ត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន បម្រុងប្រយ័ត្ន រង់ចាំវេន និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** ប៉េងប៉ោង

**៣. ការរៀបចំកុមារៈ** ចែកកុមារជាបីក្រុម ដោយឱ្យកុមារឈរជាជួរ

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនាំកុមារធ្វើសកម្មភាពដើរ ដោយឱ្យកុមារធ្វើចលនាដើរដូចពូកងទ័ព បោះជំហានវែងៗទៅមុខ
- គ្រូណែនាំកុមារពីរបៀបធ្វើចលនាចរន្តនីមួយៗ (ដើរបោះជំហានវែងៗទៅមុខ រត់ទៅវាយវត្ថុចងព្យួរ លោតជើងពីរទៅ មុខ ដើរលឿនទៅមុខ)
  - ដើរបោះជំហានវែងៗទៅមុខ ៖ ដើរបោះជំហានវែងៗដូចពូកងទ័ព
  - រត់ទៅវាយវត្ថុចងព្យួរ ៖ រត់ទៅវាយប៉េងប៉ោងដែលគ្រូបានចងព្យួរ
  - លោតជើងពីរទៅមុខៈ ដៃទាំងពីរស្របនឹងដងខ្លួនហើយជើងទាំងពីរលោតទៅមុខ
  - ដើរលឿនទៅមុខៈ ដើរទៅមុខដោយស្វាហាប់ ដៃទាំងពីរបង់បោយ
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាបីក្រុម និង អនុវត្តតាមសកម្មភាពនីមួយៗៈ
  - ក្រុមទី១ៈ ដើរបោះជំហានវែងៗទៅមុខ រត់ទៅវាយវត្ថុចងព្យួរ លោតជើងពីរទៅមុខ ដើរលឿនទៅមុខ(ធ្វើម្តងម្នាក់)
  - ក្រុមទី២ៈ ធ្វើបន្ទាប់ពីក្រុមទី១ធ្វើរួច
  - ក្រុមទី៣ៈ ធ្វើបន្ទាប់ពីក្រុមទី២ធ្វើរួច
- គ្រូដើរសម្របសម្រួលតាមក្រុមទាំង៣ ដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានដើរគ្រប់សកម្មភាព
- គ្រូសួរកុមារៈ
  - **តើមុននេះ កូនៗបានធ្វើចលនាអ្វីខ្លះ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - **គ្រូសួរទៅកុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារថា **ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព មានចំណងជើងមេរៀនៈ ចលនាចរន្ត ដើរ រត់ លោត" ដើរបោះជំហានវែងៗទៅមុខ រត់ទៅវាយវត្ថុចងព្យួរ លោតជើងពីរទៅ មុខ ដើរលឿនទៅមុខ"**
- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយរបស់គ្រូឬទេ? បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្ត)

- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា**
- គ្រូឱ្យកុមារទាំងអស់មកឈរជារង្វង់រួចសួរថាកូនៗហាត់ទេ? គ្រូនាំកុមារផ្លុំធូលីដីដែលនៅលើដៃ ដោយយកដៃមកដាក់ ជិតច្រមុះ ហើយផ្លុំទាំងអស់គ្នាទាក់ទងនឹងការដកដង្ហើមចេញដង្ហើមចូល(ធ្វើ២ទៅ៣ដង)។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

✱ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការ បង្រៀនអនុវត្ត ដូចថ្ងៃទី១ ម៉ោងទី២)

✱ ទម្លាប់ល្អ៖ មករៀនឱ្យទៀងទាត់ពេលវេលារៀងរាល់ថ្ងៃ(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២)

✱ គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១៥ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

### ល្បែង៖ ផ្គូផ្គងចំនួនរូបភាពទៅនឹងចំនួនចំណុចទៅនឹងលេខពី១ដល់៨

**១.វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបផ្គូផ្គងចំនួននឹងលេខពី១ ដល់៨ បានត្រឹមត្រូវ
- កុមារកំណត់បានចំនួនចំណុច ពី ១ ដល់៨ បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន សហការ ជួយគ្នាក្នុងការអនុវត្តការងារក្រុមបានត្រឹមត្រូវ ។

**២.សម្ភារបង្រៀន៖**

- បណ្ណចំនួនរូបភាពពី១ ដល់៨មានចំនួន១៥បណ្ណ
- បណ្ណចំនួនចំណុចពី១ ដល់៨ មានចំនួន១៥បណ្ណ
- បណ្ណចំនួនលេខពី១ ដល់៨ មានចំនួន១៥បណ្ណ

**៣.ការរៀបចំកុមារ៖** អង្គុយជារាងពាក់កណ្ដាលរង្វង់ អង្គុយតាមក្រុមតូចៗ (៣ក្រុម)

**៤.ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀន រួចនាំកុមារអានតាមជាក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញបណ្ណចំនួនរូបភាពពី១ ដល់៨ ឱ្យកុមារប្រាប់ពីចំនួនរូបភាពនៅក្នុងបណ្ណនីមួយៗ រួចយកបិទលើក្ដារខៀន និងនាំកុមាររាប់
- គ្រូបង្ហាញបណ្ណចំនួនចំណុចពី១ ដល់៨ ឱ្យកុមារប្រាប់ពីចំនួនចំណុចនៅក្នុងបណ្ណនីមួយៗ រួចយកបិទលើក្ដារខៀន ពីក្រោមរូបភាព និងនាំកុមាររាប់
- គ្រូបង្ហាញបណ្ណលេខពី១ ដល់៨ ឱ្យកុមារប្រាប់ពីលេខនោះ រួចយកមកបិទលើក្ដារខៀន ពីក្រោមចំនួនចំណុច និងលេខ រួចនាំកុមារអាន
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនទាំងអស់គ្នាលេងជាក្រុម ហើយក្នុងមួយក្រុមៗ កូនត្រូវបានសម្ភារទាំងអស់នេះមួយកំប្លេ

- ពេលក្រុមកូនបានសម្ភារទាំងនេះហើយ កូនត្រូវសង្កេតមើលចំនួន និងលេខទៅតាមបណ្ណនីមួយៗ រួចហើយកូននាំគ្នារៀបបណ្ណចំនួនរូបភាពពី១ ដល់៨ តាមលំដាប់។ បន្ទាប់មកកូនត្រូវយកបណ្ណចំនួនចំណុចពី១ ដល់៨ រៀបពីក្រោមបណ្ណរូបភាពពី១ ដល់៨ តាមលំដាប់ដែរ និងយកបណ្ណនេះមករៀបពីក្រោម បណ្ណ ចំនួនចំណុចពី១ ដល់៨ ទៀត
- ពេលកូននាំគ្នារៀប កូនត្រូវចេះចែកគ្នារៀបម្តងម្នាក់ៗទៅតាមវេន កុំដណ្តើមគ្នា ។ ពេលកូនរៀបហើយ កូនត្រូវនាំគ្នាពិនិត្យឡើងវិញ ក្រែងមានខុស ហើយកូនទៅអង្គុយនៅនឹងកន្លែងសិន រង់ចាំក្រុមមិត្តភក្តិយើងរៀបហើយទាំងអស់គ្នា

- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាក្រុម រួចឱ្យទៅអង្គុយជារង្វង់នៅតាមកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗ យកសម្ភារទៅអនុវត្ត
- គ្រូឱ្យកុមារចាប់ផ្តើមអនុវត្តទៅតាមក្រុមនីមួយៗ ហើយគ្រូដើរសម្របសម្រួលកែតម្រូវ
- ពេលកុមារធ្វើហើយគ្រប់ក្រុម គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារតាមក្រុមជាអ្នកផ្ទៀងផ្ទាត់ការងាររបស់ក្រុមនីមួយៗ ។ មុនផ្ទៀងផ្ទាត់ឱ្យម្ចាស់ក្រុមប្រាប់ពីអ្វីដែលពួកគេបានរៀប រួចរាប់ឱ្យមិត្តភក្តិស្តាប់ ។ គ្រូនាំកុមារផ្ទៀងផ្ទាត់រហូតគ្រប់ក្រុមទាំងអស់ ។ បើករណីមានខុស ឱ្យមិត្តភក្តិជួយកែតម្រូវ ។
- ពេលផ្ទៀងផ្ទាត់គ្រប់ក្រុមហើយ ត្រូវឱ្យតំណាងក្រុមនីមួយៗប្រមូលសម្ភារទៅទុកឱ្យគ្រូវិញ ហើយនាំគ្នាទៅអង្គុយជារួមក្រុមធំវិញ ។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពកសាង៖ រៀបវត្ថុតូចៗបិទលើរូបផ្ទាំង

### ១. វត្ថុបំណង៖

- កុមារប្រាប់ពីការរៀបវត្ថុតូចៗលើរូបផ្ទាំង  បានត្រឹមត្រូវ
- កុមារមានសមត្ថភាពក្នុងការរៀបវត្ថុតូចៗលើរូបផ្ទាំងបានត្រឹមត្រូវ។
- បណ្តុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន  មានចិត្តស្រឡាញ់  និងចូលចិត្ត ។

### ២. សម្ភារបង្រៀន៖

- គ្រូ៖ផ្ទាំងរូបភាពផ្ទាំងដែលបានរៀបគ្រាប់សណ្តែកបិទពីលើចំនួនមួយផ្ទាំង ,ផ្ទាំងរូបភាពផ្ទាំងដែលមិនមានរៀបគ្រាប់សណ្តែកបាយបិទលើរូបភាពចំនួនមួយផ្ទាំង ,គ្រាប់សណ្តែកបាយចំនួន ១ កញ្ចប់ស្កុតចំនួនមួយដុំការចំនួនមួយ ១ដប កន្សែងចំនួន 1 និងប្រាសដុសធ្មេញចំនួនមួយ។
- កុមារ៖ផ្ទាំងរូបភាពផ្ទាំងគ្រប់ចំនួនកុមារដែលមានដាក់ថ្ងៃខែឆ្នាំអនុវត្តមុខវិជ្ជាចំណងជើងមេរៀននៅលើសន្លឹកិច្ចការ ,គ្រាប់សណ្តែកបាយគ្រប់ចំនួនក្រុមកុមារ( ១ក្រុម១កញ្ចប់)
- ការគ្រប់ចំនួនក្រុមកុមារ( ១ក្រុម១ដប)។ប្រាសដុសធ្មេញគ្រប់ចំនួនក្រុមកុមារ( ១ក្រុម១ដើម),កន្សែងគ្រប់ចំនួនក្រុមកុមារ( ១ក្រុមកន្សែងចំនួន ១)

**៣.ការរៀបចំកុមារ៖**

-កុមារអង្គុយជារាងអក្សរ«ប»

**៤.ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញរូបផ្ទាំងដែលបានរៀបគ្រាប់សណ្តែកបាយបិទពីលើឱ្យកុមារប្រាប់ឈ្មោះនិងយករូបនោះបិទលើកក្តារខៀនជាគំរូសម្រាប់កុមារសង្កេត
- គ្រូណែនាំពីរបៀបរៀបគ្រាប់សណ្តែកបាយបិទលើរូបផ្ទាំងយឺតៗដើម្បីឱ្យកុមារងាយចាប់បាន
  - គ្រូឱ្យកូនលេងជាក្រុមតូចៗហើយក្រុមនីមួយៗ ត្រូវបានផ្ទាំងរូបភាពផ្ទាំងមួយសន្លឹកគ្រាប់សណ្តែកចំនួនមួយកញ្ចប់ ការចំនួនមួយដប កន្សែងចំនួនមួយ និងច្រាស់ដុសធ្មេញចំនួនមួយ
  - ដំបូងកូននាំគ្នាយកផ្ទាំងរូបភាពផ្ទាំងមួយផ្ទាំងដាក់នៅចំកណ្តាល ហើយគ្រាប់សណ្តែក ការ កន្សែង និងច្រាស់ដុសធ្មេញក៏ដាក់ចំកណ្តាលរង្វង់ក្បែរគ្នាដែរ
  - បន្ទាប់មកកូនណាម្នាក់ក្នុងក្រុមយកច្រាស់ដុះធ្មេញមកជ្រលក់ក្នុងការហើយយកទៅ។លាបលើរូបផ្ទាំងដោយពាសឱ្យសព្វពេញរូបផ្ទាំងប៉ុន្តែមិនឱ្យហៀរចេញក្រៅរូបផ្ទាំងទេ បើមានការប្រឡាក់ដៃកូនត្រូវយកកន្សែងមកជូត។បន្ទាប់មកយកគ្រាប់សណ្តែកបាយរៀបលើការក្នុងរូបផ្ទាំងឱ្យជិតៗគ្នាឱ្យពេញរូបផ្ទាំងគ្រូប្រាប់កុមារបណ្តើរធ្វើបង្ហាញបណ្តើរ ប៉ុន្តែការរៀបគ្រាប់សណ្តែកបាយក្នុងរូបផ្ទាំងមិនចាំបាច់រៀបពេញរូបផ្ទាំងនោះទេ រៀបតែបន្តិចជាគំរូបានហើយ
  - ពេលកូននាំគ្នារៀបគ្រាប់សណ្តែកបាយបិទលើរូបផ្ទាំងតាមក្រុមនីមួយៗត្រូវចេះរង់ចាំវេនធ្វើម្នាក់ម្តងៗកុំដណ្តើមគ្នា ហើយដាក់ដបការ ឱ្យបានត្រឹមត្រូវប្រយ័ត្នកំពប់ប្រឡាក់រូបហើយច្រាសដុសធ្មេញពេលលាបការរួចហើយត្រូវយកក្រដាសដាក់ពីក្រោម
- គ្រូរៀបចំកុមារជាក្រុមតូចៗរួចឱ្យទៅអង្គុយជារង្វង់នៅទីកន្លែងដែលកុមារបានរៀបចំ។
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារៈដែលគ្រូត្រៀមទុកអនុវត្ត
- គ្រូឱ្យកុមារក្នុងក្រុមនីមួយៗចាប់ផ្តើមអនុវត្តទាំងអស់គ្នាទៅតាមការណែនាំ
- គ្រូដើរសម្របសម្រួលកុមារគ្រប់ក្រុមហើយជួយកែតម្រូវក្រុមណាដែលធ្វើមិនទាន់បាន
- គ្រូប្រាប់កុមារ៖បើក្រុមកូនណាធ្វើរួចហើយកូនយកទៅបិទលើការខៀនតាមកន្លែងដែលគ្រូកំណត់ឱ្យទៅតាមក្រុមនីមួយៗហើយពួកកូនត្រូវយកសម្ភារៈទៅទុកជូនគ្រូវិញនិងនាំគ្នាទៅអង្គុយនៅតាមក្រុមជំវិញ
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលដោយឱ្យតំណាងក្រុមទៅឈរនៅជិតរូបដែលបានបិទនៅលើការខៀនបន្ទាប់មកឱ្យកុមារក្រុមធំសង្កេតមើលរូបនោះ។ដើម្បីវាយតម្លៃ(តើត្រឹមត្រូវឬទេ?រៀបពេញរូបផ្ទាំងទេ?មានរៀបចេញក្រៅរូបផ្ទាំងទេ?)
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតគ្រប់ក្រុមទាំងអស់នៅពេលផ្ទៀងផ្ទាត់មានក្រុមណាធ្វើមិនបានល្អគ្រូមិនត្រូវស្តីបន្ទោសឡើយ។ត្រូវចេះលើកទឹកចិត្តកុមារឱ្យខិតខំប្រឹងប្រែងបន្តទៀត
- គ្រូឱ្យតំណាងក្រុមនីមួយៗដករូបចេញពីក្តារខៀនជូនគ្រូរួចគ្រូដាក់ឈ្មោះក្រុមសម្រាប់ទុកដាក់តាំងស្នាដៃកុមារ
- គ្រូសួរកុមារ៖ថ្ងៃនេះយើងនាំគ្នារៀនមុខវិជ្ជាអ្វី?អំពីអ្វី?
- គ្រូប្រាប់កុមារ៖ថ្ងៃនេះយើងនាំគ្នារៀនមកវិជ្ជាសិក្សាសង្គម អំពីសកម្មភាពកសាង"រៀបវត្ថុតូចៗបិទលើរូបផ្ទាំង"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងអ្វីដែលគ្រូបានប្រាប់ បើមានកុមារទាយត្រូវលើកសរសើរដោយប្រើពាក្យសម្តី
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀនជាក្រុមរួចទាំងអស់គ្នា។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

## កំណាព្យៈ សាលានិងផ្ទះ

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីចំណងជើង និងអត្ថន័យនៃកំណាព្យ«សាលានិងផ្ទះ» បានត្រឹមត្រូវ។
- កុមារមានសមត្ថភាពសូត្រកំណាព្យត្រូវតាមវាក្យស័ព្ទនិងលំនាំបទ បានត្រឹមត្រូវ។
- បណ្តុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន មានចិត្តស្រឡាញ់ និងចូលចិត្តកំណាព្យ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** កុមារអង្គុយជារាងអក្សរ "ប"

**៤. ដំណើរការបង្រៀនៈ**(អនុវត្តនៅក្នុងជំហានទី៣)

- ថ្ងៃនេះគ្រូនឹងយកមេរៀនកំណាព្យមួយមកបង្រៀនកូនៗទាំងអស់គ្នា
- គ្រូសូត្រកំណាព្យឱ្យកុមារស្តាប់មួយចប់សិនដើម្បីឱ្យកុមារយល់អត្ថន័យនៃកំណាព្យ
- គ្រូឱ្យកុមារអានអត្ថបទនិងរកពាក្យពិបាកគ្រូសួរកុមារ តើកំណាព្យដែលគ្រូបានសូត្រគេចង់ និយាយពីអ្វី?
  - គ្រូប្រាប់និងពន្យល់ពាក្យពិបាកមាន **ថែទាំ** មានន័យថាថែដោយប្រុងប្រយ័ត្នមិនប្រហែសទុកចោល **មោះមុត**មានន័យថាដែលក្លាហាន អង់អាច ដែលមានចិត្តមោះមុតឥតញញើត **ល្ងង់ខ្លៅ** មានន័យថាដែលមិនចេះ មិនយល់។
  - អត្ថបទកំណាព្យនេះគឺចង់ឱ្យកុមារចេះស្រឡាញ់និងថែរក្សាសាលារៀននឹងផ្ទះដែលកូនរស់នៅ
- គ្រូនាំកុមារសូត្រកំណាព្យឃ្លាទី១ ឱ្យបានមួយចប់គ្រប់ៗគ្នា បន្ទាប់មកកុមារសូត្រឃ្លាទី២
- ពេលកុមារសូត្រកំណាព្យ ឃ្លាទី១ ឃ្លាទី២ រួចឱ្យកុមារសូត្រឃ្លាទាំងពីររួមបញ្ចូលគ្នា
- គ្រូនាំកុមារសូត្រឃ្លាបន្តបន្ទាប់តាមរបៀបខាងលើរហូតដល់ចប់នៃអត្ថបទកំណាព្យ
- គ្រូឱ្យកុមារសូត្រកំណាព្យសាឡើងវិញរួមគ្នា ១ឬ២ចប់
- គ្រូសួរកុមារ តើអម្បាញ់កូនរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?អ្នកនិពន្ធឈ្មោះអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)អរគុណកូនៗដែលបានឆ្លើយ តើកូនចង់ដឹងទេថាថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?
- គ្រូប្រាប់ថា ថ្ងៃនេះយើងរៀនមុខវិជ្ជាៈភាសាខ្មែរ មេរៀនៈកំណាព្យ«**សាលានិងផ្ទះ**»អ្នកនិពន្ធដោយលោក អ៊ុំនៅក្រសួងអប់រំ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម ទាំងអស់គ្នា

**អត្ថបទកំណាព្យ«សាលានិងផ្ទះ»(បទកាកគតិ)**

**នៅផ្ទះម៉ាក់ប៉ា ស្រឡាញ់រក្សា ថែទាំកក់ក្តៅ**
**ពេលមកសាលា អ្នកគ្រូប្រដៅ មិនឱ្យល្ងង់ខ្លៅ**
**មោះមុតក្លាហាន ។**

**យើងសើចក្អាកក្អាយ សាលាសប្បាយ ច្រៀងរាំកំសាន្ត**
**រៀនគួរស្តាប់រឿង ចងចាំគ្រប់ប្រាណ ស្រឡាញ់រាប់អាន**
**ប្រៀបបានបងប្អូន ។**

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

*** ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី១៦

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលនាព

## ល្បែងចលនាៈ លោតគាប់វត្ថុនឹងភ្លៅប្រណាំងគ្នា

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីរបៀបលោតគាប់វត្ថុនឹងភ្លៅទៅមុខ បានត្រឹមត្រូវ
- កុមារលោតគាប់វត្ថុនឹងភ្លៅទៅមុខ បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន ប្រុងប្រយ័ត្នក្នុងការទប់លំនឹងខ្លួន និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** បាល់តូចសម្រាប់កុមារគៀប(ចំនួន៦)

**៣. ការរៀបចំកុមារៈ** ឱ្យកុមារឈរជា៣ជួរ (ជួរមុខគេ គឺក្រុមទី១ ជួរទី២ គឺក្រុមទី២..........បន្តបន្ទាប់ )។

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារតម្រង់ជួរជា៣ជួរដែលមានសមាជិកស្មើៗគ្នា (៣ក្រុម)
- បន្ទាប់មកគ្រូឱ្យកុមារធ្វើចលនាលោតជើងបិរទៅមុខទៅក្រោយឆ្វេងស្តាំចុះឡើង
- គ្រូបង្ហាញបាល់តូចៗឱ្យកុមារសង្កេតរួចហើយសួរកុមារថា **តើនេះអ្វីកូនៗ? ចូរកូនទស្សន៍ទាយទៅមើលថាតើគ្រូនិងនាំកូនលេងអ្វីជាមួយនឹងបាល់នេះ?តើកូនធ្លាប់លេងល្បែងអ្វីខ្លះជាមួយនឹងបាល់?**
- គ្រូទទួលចម្លើយកុមារដោយលើកទឹកចិត្ត
- បន្ទាប់មកគ្រូប្រាប់កុមារថា **ថ្ងៃនេះគ្រូនឹងនាំកូនលេងល្បែងមួយជាមួយនឹងបាល់នេះ។**
- **គ្រូចាប់ផ្តើមណែនាំពីរបៀបលេង និងលក្ខខណ្ឌដល់កុមារៈ** ថា ដើម្បីលេងល្បែងនេះបាន កូនត្រូវឈរនៅទីដែលគ្រូបានកំណត់ចម្ងាយ ៣ម៉ែត្រនេះ បន្ទាប់មកកូនត្រូវគៀបបាល់នេះនៅនឹងភ្លៅរបស់កូន ហើយនៅពេលកូនឮសញ្ញាបញ្ជារបស់គ្រូ កូនត្រូវគៀបបាល់នៅនឹងភ្លៅលោតទៅមុខឱ្យលឿនដោយមិនឱ្យជ្រុះបាល់ចេញពីភ្លៅឱ្យទៅដល់គោលដៅ នោះកូននឹងក្លាយជាអ្នកឈ្នះ។ បើកូនណាជ្រុះបាល់ពីភ្លៅ គឺជាអ្នកចាញ់។
- បន្ទាប់មកគ្រូឱ្យកុមារ១ទៅ២នាក់ ប្រាប់ឡើងវិញពីរបៀបលេង និងលក្ខខណ្ឌ
- គ្រូឱ្យកុមារស្ម័គ្រចិត្តម្នាក់ឡើងមកលេងសាកល្បងតាមរបៀបដែលបានណែនាំ
- គ្រូនាំកុមារលេង និងសម្របសម្រួលដំណើរការលេង ដោយផ្ទៀងផ្ទាត់ទៅនឹងលក្ខខណ្ឌដែលបានប្រាប់ដោយចាប់ផ្តើមពីកុមារដែលឈរនៅមុខគេតាមជួរនៃក្រុមនីមួយៗ
- គ្រូបន្តឱ្យកុមារអនុវត្តរហូតអស់សមាជិកក្នុងក្រុមនីមួយៗ
- គ្រូលើកសរសើរចំពោះអ្នកដែលឈ្នះ ចំពោះអ្នកចាញ់គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទះបង្អាប់កុមារឡើយ
- បន្ទាប់ពីលេងរួចហើយ គ្រូនាំកុមារធ្វើចលនាស្រូបយកខ្យល់បរិសុទ្ធនៅវាលស្រែ ដោយដកដង្ហើមចូលចេញវែងៗ៣ ទៅ៤ដង (កូនៗស្រូបយកខ្យល់ដង្ហើមចូល ហើយស្រូបខ្យល់ដង្ហើមចេញមកក្រៅវែងៗដូចជាស្រូបយកខ្យល់បរិសុទ្ធនៅវាលស្រែ) រួចគ្រូសួរកុមារថា **តើកូនមានអារម្មណ៍ថាធូរស្រាលហើយឬនៅកូនៗ?**
- គ្រូទទួលចម្លើយកុមារ ដោយលើកសរសើរ។
- បន្ទាប់គ្រូសួរម្តងមួយសំណួរឱ្យកុមារឆ្លើយៈ

- **តើមុននេះ កូនៗបានលេងល្បែងអ្វី?**
- **តើកូនបានធ្វើចលនាអ្វីខ្លះជាមួយនឹងបាល់?**
- **តើមុខវិជ្ជាដែលកូនរៀនថ្ងៃនេះជាមុខវិជ្ជាអ្វី?មេរៀនអ្វីដែរ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)

- បន្ទាប់មកទៀត គ្រូប្រាប់បញ្ជាក់កុមារ **ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព មេរៀនល្បែងចលនា " លោតគាប់វត្ថុនឹងភ្លៅប្រណាំងគ្នា "**
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ទាំងអស់គ្នា

❖ **បញ្ជាក់៖** គ្រូត្រូវរៀបចំទីតាំង កំណត់ចម្ងាយទី មុននឹងចាប់ផ្ដើមមេរៀន

❖

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈសិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូចខែទី១ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ សម្អាតធ្មេញ មុននិងក្រោយពេលគេង និងក្រោយពេលញ៉ាំបាយ

- **គ្រូសួរកុមារ៖**
  - មានកូនណាធ្លាប់ឈឺធ្មេញឬទេ? ពេលឈឺធ្មេញតើពិបាកឬស្រួល? តើកូនចង់ឈឺធ្មេញឬទេ? បើកូនឈឺធ្មេញតើកូនបានមករៀនឬទេ?
  - បើកូនៗមិនចង់ឈឺធ្មេញ តើកូនៗនាំគ្នាធ្វើដូចម្ដេច?
  - តើកូនៗដុសធ្មេញមួយថ្ងៃប៉ុន្មានដង? ហើយដុសនៅពេលណាខ្លះ? បើកុមារប្រាប់មិនបានគ្រប់គ្រាន់ទេនោះគ្រូត្រូវប្រាប់កុមារបន្ថែម ។
  - តើពេលកូនដុសធ្មេញ កូនធ្វើរបៀបដូចម្ដេចដែរ?
- គ្រូឱ្យកុមារមួយឬពីរនាក់ឡើងមកបង្ហាញពីរបៀបដុសធ្មេញដែលត្រឹមត្រូវ បើកុមារធ្វើមិនបានត្រឹមត្រូវទេ គ្រូត្រូវប្រាប់កុមារបន្ថែម។
- គ្រូណែនាំកុមារបន្ថែម៖ ដើម្បីថែរក្សាធ្មេញឱ្យល្អកុំឱ្យដង្កូវស៊ីធ្មេញ កូនត្រូវនាំគ្នាដុសធ្មេញឱ្យស្អាត ក្នុងមួយថ្ងៃដុសធ្មេញបីដង ពេលក្រោកពីគេងដុះមួយដង ក្រោយញ៉ាំបាយថ្ងៃត្រង់ដុសមួយដង និងមុនពេលគេងដុសមួយដងទៀត។

* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១៦ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

### ល្បែង៖ គូសភ្ជាប់អក្សរដែលដូចគ្នា ច ឆ ជ ឈ

**១. វត្ថុបំណង៖**

- កុមារប្រាប់របៀបគូសភ្ជាប់តួអក្សរដែលដូចគ្នា ច ឆ ជ ឈ បានត្រឹមត្រូវ
- កុមារគូសភ្ជាប់តួអក្សរដែលដូចគ្នា ច ឆ ជ ឈ បានត្រឹមត្រូវ

- កុមារមានភាពឈ្លាសវៃ រហ័សរហួន បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** ផ្ទាំងរូបភាពតួអក្សរចំនួន ខ្មៅដៃ ជ័រលុប ហ្វឺត ស្កុត

**៣. ការរៀបចំកុមារ៖ ឱ្យ**កុមារអង្គុយជារាងពាក់កណ្ដាលរង្វង់ និងក្រុមតូចៗជារង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញផ្ទាំងតួអក្សរ ច ឆ ជ ឈ ដែលរៀនរួច(ដោយមានចំនួន៤តួឆ្លាស់គ្នាដោយលាយជាមួយតួអក្សរផ្សេងៗទៀត
- គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង
  - គ្រូឱ្យកូនលេងនៅតាមក្រុម ក្នុងមួយក្រុមមានផ្ទាំងតួអក្សរមួយសន្លឹកនិងខ្មៅដៃ
  - ពេលក្រុមនីមួយៗបានផ្ទាំងតួអក្សរនោះហើយកូមត្រូវនាំគ្នាសង្កេតអក្សរទាំងនោះ ពេលកូនសង្កេតកូនកុំដណ្ដើមគ្នាត្រូវសង្កេតម្ដងម្នាក់
  - ពេលកូនសង្កេតរួចហើយកូនត្រូវយកខ្មៅដៃទៅគូសភ្ជាប់តួអក្សរដែលដូចគ្នា ហើយពេលគូសកូនត្រូវចែកគ្នាគូសម្ដងម្នាក់ៗ កូនត្រូវចេះរង់ចាំវេន
  - ពេលក្រុមកូនណាធ្វើហើយកូនត្រូវយកទៅបិទលើក្ដារខៀនតាមកន្លែងដែលគ្រូកំណត់
  - ពេលចប់កិច្ចការកូនត្រូវយកខ្មៅដៃទៅទុកតាមកន្លែងដើមវិញ ហើយក្រុមកូនទៅអង្គុយកន្លែងដើមវិញ
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយពីអ្វីដែលគ្រូបានណែនាំឡើងវិញ(បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្ដងទៀត)
- គ្រូរៀបចំកុមារជាក្រុម រួចឱ្យពួកគេទៅអង្គុយតាមកន្លែងដែលគ្រូកំណត់
- ឱ្យតំណាងក្រុមមកយកសម្ភារចែកសមាជិកអនុវត្ត
- គ្រូឱ្យកុមារអនុវត្តតាមក្រុមនីមួយៗ គ្រូជាអ្នកសម្របសម្រួល
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗដោយឱ្យតំណាងក្រុមប្រាប់ពីអ្វីដែលពួកគេបានធ្វើ
- គ្រូលើកសរសើរចំពោះអ្នកដែលអនុវត្តបានត្រឹមត្រូវតាមការណែនាំ មិនត្រូវប្រៀបធៀប និងបន្ទះបង្អាប់កុមារឡើយ
- គ្រូសួរកុមារ៖
  - កូនៗទាំងអស់គ្នាសប្បាយទេ?តើមុននេះកូនៗបានធ្វើអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ
  - តើថ្ងៃនេះកូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែងមេរៀន " **គូសភ្ជាប់តួអក្សរដែលដូចគ្នា ច ឆ ជ ឈ** "
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។
-

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## រំលឹក ល្បែង៖ អ្នកវាយកណ្ដឹង

## (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១១ ម៉ោងទី៤)

ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ វិទ្យាសាស្ត្រ

## សង្កេតៈ សម្ភារដំណេក

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីឈ្មោះសម្ភារដំណេក និងការប្រើប្រាស់បានត្រឹមត្រូវ
- កុមារបង្ហាញសម្ភារៈដំណេក និងការប្រើប្រាស់សម្ភារបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ សប្បាយរីករាយ និងចេះស្រឡាញ់ថែរក្សា និងអនាម័យសម្ភារៈដំណេក ។

**២. សម្ភារបង្រៀនៈ** ផ្ទាំងរូបភាពសម្ភារដំណេក (ភួយ គ្រែ កន្ទេល មុង ខ្នើយ កើយ ខ្នើយអោប...)ចំនួន៤ផ្ទាំង

**៣. ការរៀបចំកុមារៈ** ឱ្យកុមារអង្គុយជារាងពាក់កណ្ដាលរង្វង់ (អក្សរ U) និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរបំផុសកុមារៈ កូនដឹងទេ មុនពេលគេង តើកូនត្រូវរៀបចំអ្វីខ្លះ?
- គ្រូយកផ្ទាំងរូបភាពសម្ភារប្រើប្រាស់ក្នុងគ្រួសារដោយពញ្ញាក់អារម្មណ៍ឱ្យកុមារសង្កេត ហើយសួរកុមារថា តើកូនឃើញអ្វីខ្លះក្នុងរូបភាពនេះ?តើរូបភាពនេះប្រាប់កូនពីអ្វី? បើមានកុមារណាឆ្លើយត្រូវគ្រូសរសើរកុមារដោយពាក្យសម្ដី (កូនដែលបានឆ្លើយត្រូវកូនឆ្លាតមែន ហើយពូកែទៀត ប៉ុន្តែកូនឆ្លើយមិនត្រូវក៏ឆ្លាតដែរ ដែលក្លាហានហ៊ានឆ្លើយសំណួរគ្រូ)។គ្រូបញ្ជាក់ប្រាប់កុមារៈ **រូបភាពនេះ គឺសម្ភារៈដំណេក** រួចនាំកុមារអាន
- គ្រូសួរកុមារៈ **កូនដឹងទេថា គ្រូនឹងឱ្យកូនៗធ្វើអ្វីជាមួយផ្ទាំងរូបភាពនេះ?**
- គ្រូណែនាំកុមារពីររបៀបអនុវត្តតាមក្រុមនីមួយៗៈ
    - គ្រូឱ្យកូនៗអនុវត្តតាមក្រុមតូចៗ ហើយក្នុងក្រុមនីមួយៗត្រូវបានផ្ទាំងរូបភាពនេះមួយផ្ទាំង
    - ពេលក្រុមនីមួយៗបានផ្ទាំងរូបភាពនេះហើយ កូនត្រូវដាក់កណ្ដាលវង់ ហើយនាំគ្នាសង្កេតមើលរូបទាំងអស់នោះ ហើយពិភាក្សាគ្នាលើរូបនីមួយៗថា តើឃើញអ្វីខ្លះក្នុងរូបភាព? តើសម្ភារនីមួយៗគេប្រើសម្រាប់ធ្វើអ្វី? ពេលកូននាំគ្នាសង្កេតកូនកុំដណ្ដើមគ្នា កុំដកផ្ទាំងរូបភាពនេះចុះឡើង បើកូនអង្គុយបញ្ច្រាសរូបត្រូវបង្វិលផ្ទាំងរូបភាពឱ្យត្រូវមិត្តភក្តិអាចមើលឃើញច្បាស់។ ហើយបើកូនណាស្គាល់ជួយប្រាប់ទៅមិត្តភក្តិដែលគេមិនស្គាល់ផង។ ហើយកូនត្រូវរកមិត្តណាម្នាក់សម្រាប់ឡើងនិយាយប្រាប់ពីអ្វីដែលកូនបានស្គាល់ និងដឹង
    - ពេលកូនៗពិភាក្សាគ្នាចប់គ្រប់ក្រុមហើយ ត្រូវនាំគ្នាទៅអង្គុយនៅក្រុមជុំវិញដោយយកសម្ភារៈទៅរៀងៗខ្លួន។
- ឱ្យកុមារម្នាក់ម្នាក់ ឡើងនិយាយពីអ្វីដែលត្រូវបានប្រាប់ បើនិយាយមិនបានទេឱ្យមិត្តភក្តិជួយបំពេញបន្ថែម ប៉ុន្តែបើនៅតែនិយាយមិនបានពេញលេញទេនោះគ្រូត្រូវនិយាយប្រាប់កុមារសារឡើងវិញម្ដងទៀត
- រៀបចំកុមារជាក្រុមហើយអង្គុយជារង្វង់តាមទីកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូអោយតំណាងក្រុមនីមួយៗមកយកសម្ភារទៅ ហើយនាំគ្នាអនុវត្តតាមការណែនាំ
- គ្រូដើរសម្របសម្រួលកុមារគ្រប់ក្រុមទាំងអស់ ដើម្បីជួយក្រុមណាដែលមិនទាន់យល់ច្បាស់
- ពេលក្រុមនីមួយៗត្រូវបានបញ្ចប់ការងារ គ្រូឱ្យពួកគេទៅអង្គុយនៅក្រុមជំវិញដោយយកផ្ទាំងរូបភាពទៅរៀងៗខ្លួន ទុកបង្ហាញពេលឡើងរាយការណ៍

- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងមកនិយាយប្រាប់មិត្តភក្តិនិងគ្រូពីលទ្ធផលដែលពួកគេបានពិភាក្សាគ្នា (ម្តងមួយក្រុមៗ) ដោយលើកផ្ទាំងរូបភាពចង្អុលបង្ហាញឈ្មោះរូបម្តងមួយៗ
- គ្រូត្រូវកែតម្រូវពាក្យដែលពួកគេនិយាយមិនទាន់បានត្រឹមត្រូវតាមអក្ខរាវិរុទ្ធ រួចនាំកុមារអាននូវពាក្យទាំងនោះទាំងអស់គ្នា។
- គ្រូសរុបពីលទ្ធផលរបស់កុមារគ្រប់ក្រុម បន្ទាប់ពីបានស្តាប់ពួកគេនិយាយចប់។ (ឧទាហរណ៍៖ គ្រូស្តាប់បានកុមារប្រាប់បានពីឈ្មោះសម្ភារៈ និងការបង្ហាញពីការប្រើប្រាស់ បានខ្លះតែប៉ុណ្ណោះ។ នៅមានឈ្មោះសម្ភារៈ និងការប្រើប្រាស់ផ្សេងទៀតដែលកុមារប្រាប់មិនបាន។ ដូច្នេះគ្រូត្រូវគិតគួរផ្តល់ចំណេះដឹងថ្មីបន្ថែមឱ្យពួកគេអ្វីខ្លះទៀត?)
- គ្រូត្រូវផ្តល់ចំណេះដឹងថ្មីៗបន្ថែមតាមរយៈ៖
  - គ្រូបង្ហាញផ្ទាំងរូបភាពឱ្យកុមារសង្កេតជារួម ឱ្យកុមារបានមើលឃើញទាំងអស់គ្នា។ បន្ទាប់មកគ្រូចង្អុលនឹងប្រាប់ពីឈ្មោះសម្ភារនីមួយៗ និងការប្រើប្រាស់សម្ភារ ឱ្យកុមារបានដឹង
  - គ្រូបំផុសសំណួរ៖ តើកូនត្រូវធ្វើដូចម្តេចដើម្បីឱ្យសម្ភារៈដំណេកមានអនាម័យ និងបានគង់វង្ស? បើកុមារមិនអាចឆ្លើយបានគ្រូត្រូវប្រាប់ ហើយនាំកុមារថាតាមជាក្រុមនិងទាំងអស់គ្នា។
- គ្រូយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចនាំកុមារអានឈ្មោះនៅរូបភាពនីមួយៗដោយគ្រូជាអ្នកចង្អុលផងប្រាប់ឈ្មោះផង ប្រាប់ពីការប្រើប្រាស់សម្ភារ និងប្រាប់ពីការថែទាំ និងអនាម័យសម្ភារទាំងអស់នោះ ផងដែរ។
- គ្រូសួរកុមារ៖ អម្បាញ់មិញកូនស្គាល់អ្វីខ្លះ? ដូច្នេះថ្ងៃនេះយើងរៀនពីមុខវិជ្ជាវិទ្យាសាស្ត្រអំពីសង្កេតសម្ភារដំណេក
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន (ជាក្រុមនឹងទាំងអស់គ្នា)។

**ម៉ោងទី៦ (រយៈពេល ៣០នាទី)**

## មុខវិជ្ជា៖ សិក្សាសង្គម

**✱ ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)**

# ថ្ងៃទី១៧

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

## រំលឹក ហាត់ប្រាណតាមបទចម្រៀង៖ បូតសណ្តែក

## (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១២ ម៉ោងទី១)

### ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការ បង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ សម្អាតធ្មេញ មុននិងក្រោយពេលគេង និងក្រោយពេលញ៉ាំបាយ(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១៧ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ បុរេគណិត

## ល្បែង៖ បំពេញលេខតាមចន្លោះពី១ដល់៨

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបបំពេញលេខតាមចន្លោះពី១ដល់៨ បានត្រឹមត្រូវ
- កុមារបំពេញលេខតាមចន្លោះពី១ដល់៨  បានត្រឹមត្រូវ
- កុមារក្លាហាន ចូលរួមសហការ ឈ្លាសវៃ រហ័សរហួន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បន្ទះលេខចំនួន៣ បណ្ណលេខពី១ដល់៨ ចំនួន៣ឈុត  ស្កុត (កាត់រៀបចំឱ្យហើយ)

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារាងពាក់កណ្តាលរង្វង់ និង ជាក្រុមតូចជារង្វង់

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនិយាយទៅកុមារថា៖ ថ្ងៃនេះគ្រូមានបណ្ណលេខជាច្រើន
- គ្រូបង្ហាញបន្ទះលេខដែលមានលេខមិនពេញលេញនិង បណ្ណលេខ តើមានបន្ទះ និង បណ្ណលេខអ្វីខ្លះ ?
- គ្រូបង្ហាញបន្ទះលេខ និងបណ្ណលេខ
- គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង
    - កូនត្រូវអង្គុយជារង្វង់ ទៅតាមក្រុមរបស់កូន ដែលគ្រូបានរៀបចំ
    - កូនត្រូវប្រាប់ឈ្មោះលេខនៅពេលគ្រូលើកបង្ហាញផ្ទាំងលេខនិងបណ្ណលេខទាំងអស់នោះហើយកូនត្រូវដាក់ផ្ទាំងលេខទាំងនោះនៅចំកណ្តាលរង្វង់ក្រុម បន្ទាប់មកកូនប៉ាវរកអ្នកចាប់ផ្តើម ដើម្បីជ្រើសរើសបណ្ណលេខដាក់បំពេញមុនគេត្រង់កន្លែងដែលមិនទាន់មានលេខ នៅពេលកូនបំពេញលេខចន្លោះបានហើយ កូនត្រូវឱ្យមិត្តភក្តិក្នុងក្រុមកូនជ្រើសរើសបណ្ណលេខមកដាក់បំពេញកន្លែងដែលបាត់រហូតដល់

ពេញចន្លោះនោះបន្តបន្ទាប់គ្នា

- គ្រូឱ្យកូន១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមអ្វីដែលគ្រូប្រាប់(បើកុមារនិយាយមិនបាន គ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូរៀបកុមារទាំងអស់លេងជាក្រុមតូចជារង្វង់ឱ្យក្រុមជួយផ្ទៀងផ្ទាត់ ដោយឱ្យតំណាងក្រុមយកបន្ទះបណ្ណលេខរបស់ក្រុមដែលបំពេញរួចមកបង្ហាញជារួមហើយអានទាំងអស់គ្នា
- គ្រូនាំកុមារអនុវត្តការលេង ដោយគ្រូកែតម្រូវចំពោះកុមារណាដែលលេងមិនទាន់ត្រឹមត្រូវ
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល (បើកុមារតាមក្រុមណាធ្វើបានល្អគ្រូលើកសរសើរ ឬ ចំពោះក្រុមកុមារណាធ្វើមិនបានល្អគ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ )
- **គ្រូសួរកុមារ៖**
  - កូនៗទាំងអស់គ្នាសប្បាយទេ? **តើមុននេះកូនៗបានលេងល្បែងអ្វី**?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - **តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាបុរេគណិតអំពីល្បែងមេរៀន "បំពេញលេខតាមចន្លោះពី១ដល់៨"
- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)
- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា** ។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## រឿងនិទាន៖ បូណាជាកូនល្អ (អំណាន)

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីសកម្មភាពតួអង្គតាមដំណើររឿង បានត្រឹមត្រូវ
- កុមារនិទានរឿងនិងវិភាគតួអង្គនៅក្នុងរឿងបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ យកគំរូតាមតួអង្គល្អ សហការជួយគ្នា និទានរឿងឱ្យមិត្តភក្តិស្តាប់ ។

**២. សម្ភារបង្រៀន៖**

- សៀវភៅរឿងនិទានបូណាជាកូនល្អ

**៣. ការរៀបចំកុមារ៖**

- ឱ្យកុមារអង្គុយជារាងអក្សរ អ៊ុយ "U"

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំនួរ៖ គ្រូបង្ហាញក្របសៀវភៅរួចសួរថា កូនៗសង្កេតឃើញរូបភាពអ្វីខ្លះ? តើរឿងនិទាននេះមានចំណងដូចម្តេច? កុមារទាយតាមគំនិតគេម្នាក់ៗ
- គ្រូសរុបចំណងជើងដែលកុមារបានទាយ
- គ្រូបើកសៀវភៅបង្ហាញរូបភាពម្តងមួយសន្លឹកៗរហូតដល់ចប់សាច់រឿងរួចសួរកុមារថា នៅពេលកូនមើលរូបភាពផ្នែកខាងក្នុងរួចហើយ ដូច្នេះកូនៗមានដូរចំណងជើងមេរៀនទៀតទេ?បើដូរតើមានចំណងជើង

ដូចម្ដេចដែរ?

- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ ចំណងជើងអំណានរឿង«បូណាជាកូនល្អ » រួចសួរថា មុននេះមានកូនណាឆ្លើយដូចចម្លើយរបស់អ្នកគ្រូដែរឬទេ?ដូច្នេះកូនទះដៃសរសើរមិត្តភក្តិយើងដែលបាន ទាយត្រូវទាំងអស់គ្នា ។
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងជា ក្រុមនិងទាំងអស់គ្នា
- ប្រាប់ឈ្មោះអ្នកនិពន្ធរឿងនេះអ៊ុំៗនៅក្រសួងអប់រំយុវជន និងកីឡាជាអ្នកនិពន្ធឱ្យកុមារថាតាម
- គ្រូអានរឿងនិទានដោយយកដៃចង្អុលតួអក្សរឱ្យកុមារស្ដាប់និងសង្កេតដោយមិនបាំងរូបភាពធ្វើរបៀប នេះរហូតដល់ចប់សាច់រឿង
- គ្រូប្រាប់ពាក្យពិបាកនិងពន្យល់ពាក្យពិបាកទាំងនោះរួចឱ្យកុមារអានតាម ជាក្រុមនិងទាំងអស់គ្នា
  - រង្វាន់៖ របស់ដែលថែម របស់លើកទឹកចិត្ត
  - ប្រុងប្រយ័ត្ន៖ ការខំប្រឹងថែទាំ ការប្រុងដោយមិនធ្វេសប្រហែស
  - ក្លាហាន៖ មោះមុត អង់អាច
  - សប្បុរសធម៌៖ ការធ្វើអំពើល្អ អ្នកប្រព្រឹត្តល្អ
- ក្រោយពីអានរឿងនេះចប់ គ្រូសួរកុមារថាៈ តើក្នុងរឿងមានតួអង្គប៉ុន្មាន? តួអង្គណាខ្លះ? តើនៅផ្ទះបូណា បានជួយធ្វើការងារអ្វីខ្លះ? ហេតុអ្វីបានជាម្ដាយបូណាទិញស្បែកជើងថ្មីឱ្យ?តើនៅសាលារៀនបូណាជា ក្មេងដូចម្ដេច? នៅតាមផ្លូវតើបូណាបានជួយមិត្តភក្តិអ្វីខ្លះ? (កុមារឆ្លើយតបសំណួរគ្រូទៅតាមគំនិត របស់គេម្នាក់ៗ)
- បន្ទាប់មកគ្រូឱ្យកុមារចង្អុរនិងអានពាក្យក្នុងរឿងតាមការចងចាំឡើងវិញ (កុមារនិយាយពីអ្វីដែលគេបាន ចងចាំ)

## អំណានរឿង «បូណាជាកុមារល្អ»

បូណាជាកុមារខិតខំរៀនសូត្រណាស់ អ្នកគ្រូតែងសរសើរបូណារាល់ថ្ងៃ នៅផ្ទះបូណាបានជួយធ្វើការ ឪពុកនិងម្ដាយសព្វគ្រប់ ដូចជាដងទឹក ជញ្ជូនអុស ស្រោចបន្លែ និងជួយបោសផ្ទះសំបែង។ ដោយឃើញកូន ឧស្សាហ៍ធ្វើការខិតខំរៀនសូត្រ ម្ដាយបូណាក៏ទិញស្បែកជើងមួយគូឱ្យជារង្វាន់ដល់បូណា។ ស្បែកជើងនោះ ស្អាតណាស់ បាតវាធ្វើអំពីកៅស៊ូ បូណាពាក់ស្បែកជើងថ្មីទៅរៀនរាល់ថ្ងៃដោយប្រុងប្រយ័ត្នខ្លាចដាច់ខ្សែ ឬ ប្រឡាក់ភក់។ថ្ងៃមួយមេឃភ្លៀងខ្លាំងនៅតាមផ្លូវមានទឹកដក់ជាថ្លុកធំៗ បូណាត្រូវលោតឆ្លងថ្លុកនោះតែភ្លាត់ ស្នៀត បូណាផុងជើងចូកក្នុងភក់នាំឱ្យប្រឡាក់ស្បែកជើងថ្មី និងខោ អាវ បូណាចង់យំ។ ពេលនោះមានមិត្ត ភក្តិរួមថ្នាក់ជាច្រើនដើរមកដល់ បូណាឃើញក៏រាដៃឃាត់មិនទាន់ឱ្យមិត្តឆ្លងថ្លុក ហើយក៏ស្ទុះទៅយកក្ដារមួយ បន្ទះវែងមកដាក់ធ្វើជាស្ពានឱ្យមិត្តទាំងអស់គ្នាឆ្លងដោយស្រួល គ្មានប្រឡាក់ជើងនិងខោអាវឡើយ មិត្តទាំងអស់ បានចាប់ដៃ ទះស្នា អរគុណ និងសរសើរដល់សេចក្ដីក្លាហាន និងទឹកចិត្តសប្បុរសធម៌ របស់បូណា។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

## កំណាព្យ៖ ត្រូវហូបទឹកឆ្អិន

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីជើង និងអត្ថន័យនៃកំណាព្យ«ត្រូវហូបទឹកឆ្អិន» បានត្រឹមត្រូវ។
- កុមារមានសមត្ថភាពសូត្រកំណាព្យត្រូវតាមវាក្យស័ព្ទនិងលំនាំបទ បានត្រឹមត្រូវ។
- បណ្ដុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន មានចិត្តស្រឡាញ់ និងចូលចិត្តកំណាព្យ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរ "ប"

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- ថ្ងៃនេះគ្រូនឹងយកមេរៀនកំណាព្យមួយមកបង្រៀនកូនៗទាំងអស់គ្នា
- គ្រូសូត្រកំណាព្យឱ្យកុមារស្ដាប់មួយចប់សិនដើម្បីឱ្យកុមារយល់អត្ថន័យនៃកំណាព្យ
- គ្រូឱ្យកុមារអានអត្ថបទនិងរកពាក្យពិបាកគ្រូសួរកុមារ តើកំណាព្យដែលគ្រូបានសូត្រគេចង់ និយាយពីអ្វី?
    - គ្រូប្រាប់និងពន្យល់ពាក្យពិបាកមាន **បង្អង់** មានន័យថាបញ្ឈប់ឬផ្អាក ។
    - អត្ថបទកំណាព្យនេះគឺចង់ឱ្យកុមារចេះហូបទឹកឆ្អិនឱ្យបានជាប្រចាំ
- គ្រូនាំកុមារសូត្រកំណាព្យឃ្លាទី១ ឱ្យបានមួយចប់គ្រប់ៗគ្នា បន្ទាប់មកកុមារសូត្រឃ្លាទី២
- ពេលកុមារសូត្រកំណាព្យ ឃ្លាទី១ ឃ្លាទី២ រួចឱ្យកុមារសូត្រឃ្លាទាំងពីររួមបញ្ចូលគ្នា
- គ្រូនាំកុមារសូត្រឃ្លាបន្តបន្ទាប់តាមរបៀបខាងលើរហូតដល់ចប់នៃអត្ថបទកំណាព្យ
- គ្រូឱ្យកុមារសូត្រកំណាព្យសាឡើងវិញរួមគ្នា ១ឬ២ចប់
- គ្រូសួរកុមារ តើអម្បាញ់កូនរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?អ្នកនិពន្ធឈ្មោះអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)អរគុណកូនៗដែលបានឆ្លើយ តើកូនចង់ដឹងទេថាថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?
- គ្រូប្រាប់ថា ថ្ងៃនេះយើងរៀនមុខវិជ្ជា៖ភាសាខ្មែរ មេរៀន៖កំណាព្យ«**ត្រូវហូបទឹកឆ្អិន**»អ្នកនិពន្ធដោយលោកអ៊ំនៅក្រសួងអប់រំ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម ទាំងអស់គ្នា

**អត្ថបទកំណាំព្យ«ត្រូវហូបទឹកឆ្អិន»(បទកាកគតិ)**

**យើងជាកុមារ ត្រូវតែចាំថា គួរហូបទឹកឆ្អិន**
**បើឃើញទឹកឆៅ ត្រូវបង្អង់សិន ចាំហូបទឹកឆ្អិន**
**ទើបគ្មានមេរោគ ។**

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

## រំលឹក ល្បែង៖ ផ្ទាត់កៅស៊ូគងគ្នា

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១២ ម៉ោងទី៦)**

# ថ្ងៃទី១៨

ម៉ោងទី១ (រយៈពេល៖ ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

### រំលឹក ហាត់ប្រាណតាមរឿងនិទាន៖ ទន្សាយនាំកូនទៅរកចំណី

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១៣ ម៉ោងទី១)

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការ បង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ សម្អាតធ្មេញ មុននិងក្រោយពេលគេង និងក្រោយពេលញ៉ាំបាយ(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១៨ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

### ល្បែង៖ រៀបតួអក្សរពី ក ដល់ ឈ តាមរូបផ្សេងៗ

**១. វត្ថុបំណង៖**

-កុមារប្រាប់ពីរបៀបរៀបតួអក្សរពី ក ដល់ ឈ តាមរូបភាពផ្សេងៗ បានត្រឹមត្រូវ

-កុមាររៀបតួអក្សរពី ក ដល់ ឈ តាមរូបភាពផ្សេងៗ បានត្រឹមត្រូវ

-កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បណ្ណរូបភាពអក្សរ ៣ឈុត (រូបភាពមានអក្សរខាងក្រោម)

**៣. ការរៀបចំកុមារ៖**

- ឱ្យកុមារអង្គុយជារាងពាក់កណ្ដាលរង្វង់ អក្សរ "U" និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញផ្ទាំងរូបភាពអក្សរ ដែលគ្រូបានរៀបចំទុកនៅតាមទីកន្លែងរួចជាស្រេច (ផ្ទាំងរូបភាពអក្សរចំនួន ៣ឈុត ដាក់លាយច្របល់ចូលគ្នាក្នុងមួយឈុត) ហើយសួរកុមារថា តើសម្ភារទាំងអស់នេះមានអ្វីខ្លះ?
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនៗលេងជាក្រុម ដោយក្នុងមួយក្រុមមានផ្ទាំងរូបភាពអក្សរមួយឈុត
  - ពេលក្រុមកូនបានផ្ទាំងរូបភាពអក្សរនេះហើយ កូននាំគ្នារៀបតួអក្សរតាមលំដាប់លំដោយពីអក្សរ ក ដល់ អក្សរ ឈ ។ ពេលកូនរៀប ត្រូវចែកគ្នារៀបកុំដណ្ដើមគ្នាណា ។
  - ពេលក្រុមកូនណាធ្វើរួចហើយ កូនត្រូវយកមកបិតលើក្ដារខៀនតាមកន្លែងដែលគ្រូបានរៀបចំឱ្យ

- ក្រុមណាដែលហើយមុនគេ ត្រូវទះដៃចំនួន៣ដង

- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបដែលក្រុមត្រូវធ្វើតាមការណែនាំ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- ឱ្យកុមារទៅអង្គុយនៅតាមក្រុម តាមកន្លែងដែលគ្រូបានរៀបចំ ដោយគ្រូរៀបចំកុមារជា៣ក្រុម
- ឱ្យតំណាងក្រុមឡើងមកយកសម្ភារទៅអនុវត្ត
- តាមក្រុមនីមួយៗអនុវត្ត ហើយគ្រូជាអ្នកដើរសម្របសម្រួល
- ពេលកុមារធ្វើចប់គ្រប់ក្រុមហើយ ឱ្យពួកគេទៅអង្គុយជារួមវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗ ដែលបានបិតលើក្តារខៀន ដោយឱ្យតំណាងក្រុមនីមួយៗឡើងបង្ហាញពីអ្វីដែលក្រុមបានធ្វើ ( ធ្វើម្តងមួយក្រុម)
- គ្រូលើកសរសើរចំពោះក្រុមដែលធ្វើរួចមុនគេ ចំពោះក្រុមធ្វើហើយក្រោយគេ គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្តុះបង្អាប់កុមារឡើយ )
- **គ្រូសួរកុមារៈ**
  - កូនៗទាំងអស់គ្នាសប្បាយទេ ? **តើមុននេះ កូនៗបានលេងល្បែងអ្វី**? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - **តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ **ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែង មេរៀន "រៀបតួអក្សរពី ក ដល់ ឈ តាមរូបផ្សេងៗ"**
- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)
- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា** ។
-

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

### ចម្រៀងៈ ស្អាតជានិច្ច ( ទះដៃតាមចង្វាក់ ៣, ៣, ៧)

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីចំណងជើង អត្ថន័យបទចម្រៀង និងរបៀបធ្វើកាយវិការបានត្រឹមត្រូវ
- កុមារច្រៀងចម្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀងបានត្រឹមត្រូវ
- កុមារស្រឡាញ់ ចូលចិត្តច្រៀងបទចម្រៀង សហការគ្នា និងចូលរួមយ៉ាងសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ**

- ផ្ទាំងក្រដាសធំ សរសេរខ្លឹមបទចម្រៀងស្អាតជានិច្ចសម្រាប់បិទលើក្តារខៀន
- ស្កុត ហែកត្រៀមទុកជាស្រេច

**៣. ការរៀបចំកុមារៈ** អង្គុយជាអក្សរ អ៊ុយ "ប"

**៤. ដំណើរការបង្រៀនៈ**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំណួរ៖ តើកូនធ្លាប់ច្រៀងបទចម្រៀងស្អាតជានិច្ចដែរឬទេ? រួចឱ្យកុមារច្រៀង និងធ្វើកាយវិការទាំងអស់គ្នាមួយចប់។ បន្ទាប់មក គ្រូសួរកុមារថា ដូច្នេះកូនទាយទៅមើលថា ថ្ងៃនេះ គ្រូនាំកូនរៀនមុខវិជ្ជាអ្វី? អំពីអ្វី? កុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ។ គ្រូសរុបចំណងជើងមេរៀនដែលកុមារទាយ
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះ គ្រូនឹងបង្រៀនកូននូវមុខវិជ្ជាសិក្សាសង្គម អំពីចម្រៀង "ស្អាតជានិច្ច" ម្តងទៀត ដោយធ្វើកាយវិការទះដៃចង្វាក់ ៣ ៤ ៧ វិញម្តង
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារ ទៅនឹងអ្វីដែលគ្រូបានប្រាប់ ដោយនិយាយថា៖ អម្បាញ់មិញ មានកូនៗបានទាយត្រូវ ពីមុខវិជ្ជា និងចំណងជើងមេរៀន។ កូនពិតជាឆ្លាតមែន ពូកែទាយណាស់។ ប៉ុន្តែកូនដែលទាយមិនត្រូវក៏ក្លាហានដែរ ហ៊ានឆ្លើយសំណួររបស់គ្រូ ដូច្នេះថ្ងៃក្រោយកូនព្យាយាមឆ្លើយទៀតណា!
- គ្រូប្រាប់ និងសរសេរមុខវិជ្ជា និងចំណងជើងដាក់លើក្តារខៀន រួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូយកផ្ទាំងក្រដាសខ្លឹមសារចម្រៀងបិទលើក្តារខៀន រួចច្រៀង និងធ្វើកាយវិការឱ្យកុមារស្តាប់ និងមើលមួយចប់
- គ្រូនាំកុមារអានពាក្យពិបាកនៅក្នុងអត្ថបទចម្រៀងដែលគ្រូគូសសម្គាល់លើខ្លឹមសារផ្ទាំងអត្ថបទចម្រៀង (ឃ្នាតខ្មី រូតរះ ម្ទីម្ទា )ជាក្រុម និងទាំងអស់គ្នា រួចប្រាប់ពីអត្ថន័យរបស់ពាក្យទៅកាន់កុមារ និងនាំកុមារអានតាមទាំងអស់គ្នាផងដែរ។(**ឃ្នាតខ្មី មានន័យថា ខំប្រឹង។ រូតរះ មានន័យថា ឱ្យលឿន។ ម្ទីម្ទា មានន័យថាប្រញាប់ប្រញាល់**)
- គ្រូសួរកុមារ៖ កូនដឹងទេថា តើចម្រៀង"ស្អាតជានិច្ច"នេះ ចង់និយាយពីអ្វី? បើកុមារមិនអាចឆ្លើយបាន គ្រូត្រូវប្រាប់កុមារពីអត្ថន័យបទចម្រៀង ដោយប្រាប់កុមារថា៖ ចម្រៀងនេះមានន័យថា ចម្រៀងនេះមានខ្លឹមសារចង់ឱ្យកូនៗកុំភ្លេចសម្អាតកាយ មិនថាពេលកូនៗទៅសាលា មុនឬក្រោយពេលហូបបាយត្រូវងូតទឹក និងលាងសម្អាតដៃ។ ហើយពេលដែលកូនលេងដី ឬវត្ថុផ្សេងៗរួចកូនត្រូវប្រញាប់លាងដៃឱ្យបានស្អាត ទើបមិនឆ្លងមេរោគ និងជាកូនល្អ។
- គ្រូអានអត្ថបទចម្រៀងជាពាក្យរាយឱ្យកុមារស្តាប់ម្តងមួយឃ្លាៗ រួចឱ្យកុមារអានតាមម្តងមួយក្រុម រួចទាំងអស់គ្នា
- គ្រូធ្វើសំឡេង ១ ២ ៣ ១ ២ ៣ ១ ២ ៣ ៤ ៥ ៦ ៧ ទៅតាមចង្វាក់នៃបទចម្រៀងឱ្យកុមារស្តាប់ មួយចប់នៃបទចម្រៀង។
- គ្រូនាំកុមារធ្វើសំឡេង ១ ២ ៣ ១ ២ ៣ ១ ២ ៣ ៤ ៥ ៦ ៧ ទៅតាមចង្វាក់នៃបទចម្រៀងដែលគ្រូបានធ្វើជាគំរូឱ្យស្តាប់(ម្តងមួយក្រុមៗរួចទាំងអស់គ្នា) ឱ្យបាន២ចប់
- គ្រូនាំកុមារច្រៀង និងធ្វើកាយវិការតាមបទចម្រៀង ម្តងមួយឃ្លាៗ រហូតដល់ចប់បទចម្រៀង(ម្តងមួយក្រុមរួចទាំងអស់គ្នាឱ្យបាន១ ឬ២ចប់)
- គ្រូច្រៀងតិចៗ ម្តងមួយឃ្លាៗ កុមារច្រៀងឮៗ ម្តងមួយឃ្លាៗតាមគ្រូ រហូតចប់បទចម្រៀង(ម្តងមួយក្រុម ឬទាំងអស់គ្នា) ឱ្យបាន២ចប់
- គ្រូនាំកុមារច្រៀង និងធ្វើកាយវិការតាមបទចម្រៀងសារឡើងវិញឱ្យបាន២ ទៅ៣ចប់ ទាំងអស់គ្នា

ខ្លឹមសារ និងកាយវិការចម្រៀង

\+ អត្ថបទចម្រៀង៖ **ស្អាតជានិច្ច**

ស្អាតជានិច្ចៗ យើងកុំភ្លេច ត្រូវសម្អាតកាយ

ទាំងពេលគេង ពេលញុំាបាយ សម្អាតកាយមុនទៅសាលា។
សូនរូបដីៗ ហើយឃ្នាតខ្មី រូតរះម្ទីម្នា
លាងដៃស្អាត គ្រប់វេលា ទើបឈ្មោះថាកុមារគំរូ។

+ កាយវិការ

- "ស្អាតជានិច្ចៗ" គ្រូធ្វើកាយវិការ ទះដៃ ១ ២ ៣ ចំនួន២ដង
- "យើងកុំភ្លេច" គ្រូធ្វើកាយវិការ ទះដៃ ១ ២ ៣
- "ត្រូវសម្អាតកាយ" គ្រូធ្វើកាយវិការ ទះដៃ ១ ២ ៣ ៤
- "ទាំងពេលគេង" គ្រូធ្វើកាយវិការ ទះដៃ ១ ២ ៣
- "ពេលញុំាបាយ" ធ្វើកាយវិការ ទះដៃ ១ ២ ៣
- "សម្អាតកាយមុនទៅសាលា" ធ្វើកាយវិការ ទះដៃ ១ ២ ៣ ៤ ៥ ៦ ៧។
- "សូនរូបដីៗ" ធ្វើកាយវិការ ទះដៃ ១ ២ ៣ ចំនួន២ដង
- "ហើយឃ្នាតខ្មី" ធ្វើកាយវិការ ទះដៃ ១ ២ ៣
- "រូតរះម្ទីម្នា" ធ្វើកាយវិការ ទះដៃ ១ ២ ៣ ៤
- "លាងដៃស្អាត" ធ្វើកាយវិការ ទះដៃ ១ ២ ៣
- "គ្រប់វេលា" ធ្វើកាយវិការ ទះដៃ ១ ២ ៣
- "ទើបឈ្មោះថាកុមារគំរូ" ធ្វើកាយវិការ ទះដៃ ១ ២ ៣ ៤ ៥ ៦ ៧។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

## ល្បែង៖ ធ្វើចំណាត់ថ្នាក់សម្ភារផ្ទះបាយនិងសម្ភារដំណេក

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបធ្វើចំណាត់ថ្នាក់សម្ភារផ្ទះបាយ និងសម្ភារដំណេក បានត្រឹមត្រូវ
- កុមារធ្វើចំណាត់ថ្នាក់សម្ភារផ្ទះបាយ និងសម្ភារដំណេក បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន សហការ ជួយគ្នាក្នុងការអនុវត្តការងារក្រុមបានត្រឹមត្រូវ ។

**២. សម្ភារបង្រៀន៖** - បន្ទះបណ្ណសម្ភារផ្ទះបាយ និងសម្ភារដំណេក ចំនួន៣ឈុត

**៣. ការរៀបចំកុមារ៖** - អង្គុយជារាងពាក់កណ្ដាលរង្វង់ អង្គុយតាមក្រុមតូចៗ (៣ក្រុម)

**៤.ដំណើរការបង្រៀន**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញបណ្ណសម្ភារផ្ទះបាយ និងសម្ភារដំណេក ដោយដាក់នៅលើតុពីមុខកុមារ រួចឱ្យកុមារម្នាក់ជាអ្នកលើកបង្ហាញ ហើយកុមារដទៃទៀតជាអ្នកប្រាប់ឈ្មោះ
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
    - គ្រូឱ្យកូនទាំងអស់គ្នាលេងជាក្រុម ហើយក្នុងមួយក្រុមៗ កូនត្រូវមានសម្ភារចម្រុះរាងដែលកូនបានបង្ហាញមួយកញ្ចប់

- ពេលក្រុមកូននីមួយៗបានសម្ភារទាំងនេះហើយ កូនត្រូវយកសម្ភារចេញពីថង់ដាក់នៅកណ្តាលរង្វង់ ។ បន្ទាប់មក ពួកកូនក្នុងក្រុមនីមួយៗ នាំគ្នាសង្កេតមើលបណ្តាសម្ភារទាំងអស់នោះ ដើម្បីចំណាំពីឈ្មោះ ប៉ុន្តែកូននាំគ្នាមើលឱ្យស្ងៀមស្ងាត់ មិនដណ្តើមគ្នាមើលទេ
- នៅពេលគ្រូឱ្យសញ្ញាចាប់ផ្តើម កូនៗគ្រប់ក្រុមត្រូវនាំគ្នារើសសម្ភារផ្ទះបាយដាក់មុំ និងសម្ភារដំណេកដាក់មុំ ។ បើក្រុមណារៀបបានរួចរាល់មុនគេ កូនត្រូវទះដៃជាសញ្ញា ។ បន្ទាប់មកអ្នករៀបរួចបន្តបន្ទាប់ ក៏ទះដៃបន្តបន្ទាប់ដែរ ។ ពេលកូនរៀបសម្ភារដាក់មុំៗ កូនត្រូវធ្វើម្នាក់ម្តងៗវង់ចាំវេន មិនដណ្តើមគ្នារញ៉េរញ៉ៃទេ ទើបជាកូនល្អ
- ពេលក្រុមកូនរៀបចំគ្រប់ក្រុមហើយនោះ កូនទុកមិត្តភក្តិយើងម្នាក់នៅកន្លែងរៀបសម្ភារ ឯកូនដទៃទៀត ទៅអង្គុយនៅក្រុមធំវិញ ហើយនាំគ្នាផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗជាមួយគ្រូ ។

- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាក្រុម រួចឱ្យទៅអង្គុយជារង្វង់នៅតាមកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗ យកសម្ភារទៅអនុវត្ត និងឱ្យក្រុមនីមួយៗចាប់ផ្តើមអនុវត្តតាមសញ្ញាបញ្ជារបស់គ្រូ
- គ្រូឱ្យក្រុមកុមារនីមួយៗដែលធ្វើរួចហើយទៅអង្គុយនៅក្រុមធំវិញ ក្នុងមួយក្រុមទុកតែកុមារម្នាក់ដើម្បីបង្ហាញលទ្ធផល
- គ្រូនាំកុមារផ្ទៀងផ្ទាត់ម្តងមួយក្រុមៗ ដោយឱ្យម្ចាស់ក្រុមនីមួយៗជាអ្នកបង្ហាញពីអ្វីដែលពួកគេបានធ្វើ ។ បន្ទាប់មកឱ្យកុមារដែលនៅអង្គុយក្នុងក្រុមធំជាអ្នកវាយតម្លៃ បើមានខុសជួយកែតម្រូវ ។ គ្រូត្រូវនាំផ្ទៀងផ្ទាត់គ្រប់ក្រុមទាំងអស់ ។ ពេលផ្ទៀងផ្ទាត់ចប់ គ្រូត្រូវឱ្យកុមារប្រមូលសម្ភារទុកជូនគ្រូវិញ ។
- **គ្រូសួរកុមារៈ** អម្បាញ់មិញកូនស្គាល់អ្វីខ្លះ? ដូចនេះកូនជួយប្រាប់គ្រូបានទេ តើយើងរៀនមុខវិជ្ជាអ្វី? អំពីអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
-គ្រូប្រាប់កុមារពី**មុខវិជ្ជា និងចំណងជើង រួចសួរកុមារ អម្បាញ់មិញមានកូនណាទាយត្រូវឬទេ ដូចនេះកូនៗដែលទាយត្រូវគឺជាកូនពូកែ កូនឆ្លាត។ រីឯកូនដែលទាយមិនត្រូវក៏ល្អដែរ ដែលក្លាហានក្នុងការនិយាយជាមួយគ្រូ។**
- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។**

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

**∗ ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ:**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី១៩

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

ចលនាមូលដ្ឋាន៖ លោត (លោតជើង១ទៅមុខ លោតជើង១បត់បែនតាមផ្លូវកាច់ លោតកាន់វត្ថុទៅដាក់ក្នុងកន្ត្រក

**១. វត្ថុបំណង៖**

- ប្រាប់បានពីររបៀបលោតជើងមួយទៅមុខ លោតជើងពីរបត់បែនតាមផ្លូវកាច់ លោតកាន់វត្ថុដាក់ក្នុងកន្ត្រកតាមលំដាប់លំដោយបានច្បាស់លាស់
- កុមារលោតជើងមួយទៅមុខ លោតជើងពីរបត់បែនតាមផ្លូវកាច់ លោតកាន់វត្ថុដាក់ក្នុងកន្ត្រកតាមលំដាប់លំដោយបានត្រឹមត្រូវ
- មានភាពរហ័សរហួនបម្រុងប្រយ័ត្នអំណត់ព្យាយាមនិងសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** ដបទឹកសុទ្ធ និងកន្ត្រក

**៣. ការរៀបចំកុមារ៖** ចែកកុមារជាបីក្រុមដោយឱ្យកុមារឈរជាបីជួរ (ករណីកុមារច្រើនអាចចែកជា៦ក្រុម ដោយ២ក្រុមធ្វើ១ សកម្មភាព)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី ៣)

- គ្រូនាំកុមារធ្វើសកម្មភាពលោតតិចៗដោយជ្រុំជើងនៅមួយកន្លែង។
- គ្រូបង្ហាញសម្ភារឱ្យកុមារប្រាប់ឈ្មោះ
- គ្រូណែនាំកុមារពីរបៀបធ្វើចលនាមូលដ្ឋាននីមួយៗ លោត″ (លោតជើងមួយទៅមុខ លោតជើងពីរបត់បែនតាមផ្លូវ កាច់ លោតកាន់វត្ថុដាក់ក្នុងកន្ត្រក)
- គ្រូឱ្យកុមារ១ឬ២នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ(បើកុមារនិយាយមិនបានត្រូវប្រាប់ម្តង ទៀត)
- គ្រូចែកកុមារជាបីក្រុមនិងអនុវត្តតាមសកម្មភាពនីមួយៗ៖
    - ក្រុមទី១៖ លោតជើងមួយទៅមុខឱ្យដល់ទិសដៅដែលបានកំណត់
    - ក្រុមទី២៖ លោតជើងពីរបត់បែនតាមផ្លូវកាច់ឱ្យដល់ទិសដៅដែលបានកំណត់
    - ក្រុមទី៣៖ លោតកាន់វត្ថុដាក់ក្នុងកន្ត្រកឱ្យដល់ទិសដៅដែលបានកំណត់។ បានលោតតាមរបៀបខាងលើរួចគ្រូឱ្យក្រុមនីមួយៗ
- បន្ទាប់ពីកុមារ ផ្លាស់ប្តូរសកម្មភាពលោតតាមសញ្ញារបស់គ្រូ។ -គ្រូដើរសម្របសម្រួលតាមក្រុមនីមួយៗ ដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានលោតគ្រប់សកម្មភាព។
- គ្រូសួរកុមារ តើអម្បាញ់មិញនេះកូនៗបានធ្វើចលនាអ្វី? (កុមារឆ្លើយ...)
- ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វីមានចំណងជើងអ្វី? (កុមារឆ្លើយ....)
- គ្រូប្រាប់កុមារថាថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាពមានចំណងជើងថាចលនាមូលដ្ឋាន **លោត″ លោតជើងមួយ ទៅមុខ លោតជើងពីរបត់បែនតាមផ្លូវកាច់ លោតកាន់វត្ថុទៅដាក់ក្នុងកន្ត្រក**
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយទៅនឹងអ្វីដែលគ្រូបានប្រាប់(តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយរបស់គ្រូទេ?បើមានកុមារឆ្លើយត្រូវគ្រូលើកសរសើរបើកុមារឆ្លើយមិនបានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត)
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀនជាក្រុមនិងទាំងអស់គ្នា។

-កូនៗហាត់ឬទេបើហាត់កូនចង់ធ្វើអ្វីបានដូច្នោះកូនទាំងអស់គ្នាលើកដៃឡើងយកប៉េងប៉ោងម្នាក់មួយម្នាក់មួយមកផ្លុំ (កូនយកមេដៃនិងចង្អុលដៃទាំងសងខាងមកចាប់មាត់ប៉េងប៉ោងយកមកដាក់ជិតមាត់ហើយផ្លុំ ខ្លាំងៗ រួចដៃទាំងពីរ ដែលកាន់មាត់ប៉េងប៉ោងលាតាមទំហំនៃប៉េងប៉ោងរីករហូតដល់ប៉េងប៉ោងបែក ទើបទះដៃជាសញ្ញាប៉េងប៉ោងផ្ទុះ)

- គ្រូ ឱ្យកុមារធ្វើរបៀបនេះពីឬបីដង។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ សម្អាតធ្មេញ មុននិងក្រោយពេលគេង និងក្រោយពេលញ៉ាំបាយ(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១៩ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

### ពិសោធន៍៖ វត្ថុរលាយ និងមិនរលាយក្នុងទឹក

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីឈ្មោះវត្ថុរលាយ និងមិនរលាយក្នុងទឹកបានត្រឹមត្រូវ
- កុមារកំណត់បានវត្ថុរលាយ និងមិនរលាយក្នុងទឹកបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់តាមដាននិងចូលរួមដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** កែវថ្លាចំនួន ១៥ កែវ គ្រាប់សណ្តែក អង្ករ អំបិល ស្ករស ទឹក

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរអ៊ុយ "U" និងក្រុមតូច

**៤. ដំណើរការបង្រៀន៖(អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូដាក់សម្ភារនៅលើតុមុខកុមារ(គ្រាប់សណ្តែក អង្ករ អំបិល ស្ករស...)
- គ្រូអោយកុមារមួយនាក់ដែលស្ម័គ្រចិត្តមករើសសម្ភារៈនៅលើតុម្តងមួយៗដើម្បីបង្ហាញរួចឱ្យមិត្តភក្តិជាអ្នកប្រាប់ ឈ្មោះ បើកុមារមិនស្គាល់សម្ភារៈណាមួយទេគ្រូត្រូវប្រាប់កុមាររួចឱ្យកុមារថាតាម។
- គ្រូសួរកុមារ
  - តើសម្ភារទាំងអស់នេះគ្រូយកមកឱ្យកូនដើម្បីធ្វើអ្វីដែរ?
  - ពេលកូនយកសម្ភារទាំងអស់នេះទៅលេងជាមួយទឹក តើកូនសង្កេតឃើញវាយ៉ាងដូចម្តេចដែរ?
- គ្រូត្រូវសរសេរចម្លើយរបស់កុមារនៅគៀនក្តារខៀន ណាមួយពេលកុមារឆ្លើយប៉ាន់ស្មានដើម្បីទុកទៀងផ្ទាត់។
- គ្រូណែនាំកុមារពីរបៀបអនុវត្តទៅតាមក្រុម
  - គ្រូអោយកូនលេងជាក្រុមតូចៗ ហើយក្នុងមួយក្រុមកូនត្រូវបានសម្ភារៈទាំងអស់នេះមួយឈុត

- គ្រូប្រាប់កុមារៈ កូនត្រូវយកសម្ភារៈទាំងអស់នេះទៅដាក់លើកណ្តាលវង់ បន្ទាប់មកកូនណាម្នាក់យកទឹកទៅចាក់ដាក់ក្នុងកែវ រួចហើយកូននាំគ្នាទម្លាក់សម្ភារៈទាំងនេះទៅក្នុងទឹកម្តងមួយៗ ដោយមិនដណ្តើមគ្នា ត្រូវចេះរង់ចាំវេន ធ្វើម្តងម្នាក់ៗ
- កូនត្រូវនាំគ្នាសង្កេតសម្ភារៈទាំងអស់នោះនៅក្នុងកែវ តើសម្ភារៈនោះយ៉ាងដូចម្តេចដែរ?
- ពេលកូននាំគ្នាអនុវត្តធ្វើយ៉ាងណាកុំឱ្យកំពប់ទឹកពេញថ្នាក់ត្រូវនាំគ្នាប្រយ័ត្នទាំងអស់គ្នា។

- គ្រូឱ្យកុមារណាម្នាក់ស្ម័គ្រចិត្តឡើងមកនិយាយប្រាប់ពីអ្វីដែលគ្រូបានប្រាប់ បើនិយាយមិនបានត្រឹមត្រូវទេឱ្យមិត្តភក្តិជួយបំពេញបន្ថែម បើនៅតែនិយាយមិនបានពេញលេញទេគ្រូត្រូវនិយាយប្រាប់កុមារសារឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមតូចៗរួចឱ្យទៅអង្គុយជារង្វង់នៅទីកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារៈទៅអនុវត្តការពិសោធន៍តាមក្រុម
- គ្រូឱ្យអនុវត្តការពិសោធន៍គ្រប់ក្រុមទាំងអស់នៅពេលតែមួយ
- គ្រូដើរសម្របសម្រួលទៅតាមក្រុមនីមួយៗនិងជួយបំផុសគំនិតបន្ថែមដើម្បីឱ្យធ្វើបានត្រឹមត្រូវ
- គ្រូឱ្យកុមារទៅអង្គុយនៅក្រុមធំវិញហើយនាំគ្នាយកសម្ភារៈទៅទុកឱ្យគ្រូវិញពេលគេធ្វើរួចគ្រប់ក្រុម
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ពីលទ្ធផលនៃការពិសោធន៍
- គ្រូសរុបលទ្ធផលរបស់កុមារគ្រប់ក្រុមតាមលទ្ធផលដែលពួកគេបានរាយការណ៍(គ្រាប់សណ្តែក អង្ករ មិនរលាយក្នុងទឹក និងស្ករស អំបិល ប៊ីចេង រលាយលិចក្នុងទឹក)
- គ្រូប្រាប់កុមារៈ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមកូនៗដែលបានរាយការណ៍ដូចនេះគ្រូយកសម្ភារទាំងនេះមកអនុវត្តជាមួយកូនម្តងទៀត
- គ្រូយកសម្ភារៈទាំងនោះមកដាក់នៅលើតុមុខកុមាររួចឱ្យកុមារស្ម័គ្រចិត្តមួយនាក់យកសម្ភារដាក់ក្នុងទឹកម្តងមួយៗរហូតដល់តែអស់សម្ភារ
- នាំកុមារសង្កេតទាំងអស់គ្នា ពេលទម្លាក់សម្ភារមួយនាំកុមារសង្កេតម្តង ហើយផ្ទៀងផ្ទាត់ទៅនឹងចម្លើយពេលពិសោធន៍ឃើញនឹងចម្លើយពេលប៉ាន់ស្មានទុកមុនពិសោធន៍ ដែលគ្រូបានសរសេរទុកលើក្តារខៀន
- គ្រូធ្វើរបៀបនេះទាល់តែអស់សម្ភារ
- គ្រូបូកសរុប និងសន្និដ្ឋានៈ
  - គ្រូប្រាប់កុមារៈ គ្រាប់សណ្តែក អង្ករ មិនរលាយក្នុងទឹក និងស្ករស អំបិល ប៊ីចេង រលាយក្នុងទឹក (នាំកុមារអានជាក្រុមទាំងអស់គ្នា)
  - គ្រូបញ្ជាក់ប្រាប់កុមារៈ គ្រាប់ធញ្ញជាតិមិនរលាយក្នុងទឹក ចំណែកគ្រឿងទេសរលាយក្នុងទឹក (រួចនាំកុមារថាតាមជាក្រុមនិងទាំងអស់គ្នា)
  - នាំកុមារអានពាក្យថ្មី និងពន្យល់អត្ថន័យនៃពាក្យរលាយមានន័យថាគ្មានសល់ សាបសូន្យ( រួចនាំកុមារអានជាក្រុមនិងទាំងអស់គ្នា)
  - ណែនាំកុមារពេលទៅផ្ទះវិញកូនកុំយកវត្ថុផ្សេងៗទៅទម្លាក់ក្នុងពាងទឹកដែលឪពុកម្តាយទុកប្រើប្រាស់ ហើយកុំទៅលេងទឹកបឹងស្ទឹងផ្តេសផ្តាសខ្លាចគ្រោះថ្នាក់ ម្យ៉ាងទៀតកូនត្រូវនាំគ្នាញុំាទឹកឆ្អិន។
- គ្រូសួរកុមារៈ អម្បាញ់មិញកូននាំគ្នាធ្វើអ្វីខ្លះ ? ដូច្នេះយើងនាំគ្នារៀនមុខវិជ្ជាអ្វី?អំពីអ្វី?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ អំពីពិសោធន៍ «**វត្ថុរលាយនិងមិនរលាយទឹក**»

- គ្រូផ្ទៀងផ្ទាត់ចម្លើយកុមារទៅនឹងការប្រាប់របស់គ្រូ។
- នាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន (ជាក្រុមនិងទាំងអស់គ្នា)។

**ម៉ោងទី៤ (រយៈពេល ៣០នាទី)**

## មុខវិជ្ជា៖ សិក្សាសង្គម

### គំនូរ៖ គូរសេរី

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបគូររូបផ្សេងៗដោយសេរីតាមការស្រមើលស្រម៉ៃបានត្រឹមត្រូវ
- កុមារកាន់ខ្មៅដៃគូររូបផ្សេងៗដោយសេរីតាមការស្រមើលស្រម៉ៃបានត្រឹមត្រូវ
- កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់ សហការចូលរួមយ៉ាងសកម្មនិងសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖**គ្មាន

**-កុមារ៖** ផ្ទាំងក្រដាសសដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀននៅក្បាលសន្លឹកកិច្ចការគ្រប់ចំនួនកុមារ និងខ្មៅដៃគ្រប់ចំនួនកុមារ

**៣. ការរៀបចំកុមារ៖** អង្គុយរាងអក្សរ "ប" ចែកកុមារជាក្រុម(អនុវត្តជាបុគ្គល)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

-គ្រូសួរ៖ តើកូនៗធ្លាប់ទៅដើរលេងជាមួយឪពុកម្ដាយនៅកន្លែងណាខ្លះ? ហើយនៅពេលកូនទៅដើរលេង កូនបានសង្កេតឃើញអ្វីខ្លះនៅទីនោះ? តើកូនៗពេញចិត្តនិងស្រឡាញ់អ្វីជាងគេ? (ចម្លើយតាមគំនិតកុមារម្នាក់ៗ)
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារថាតាម(ជាក្រុមនិងទាំងអស់គ្នា)
- គ្រូបង្ហាញផ្ទាំងក្រដាសស១សន្លឹក ដែលគ្រូមិនទាន់គូរឱ្យកុមារសង្កេត
- គ្រូប្រាប់កុមារ៖ ផ្ទាំងក្រដាសសនេះគ្រូទុកសម្រាប់ឱ្យកូនគូរគំនូរដោយសេរីតាមចំណង់ចំណូលចិត្តកូនដែលកូនបានឃើញ។ គ្រូឱ្យកូននាំគ្នាគូរដោយសេរី
- គ្រូបង្ហាញផ្ទាំងក្រដាសជាសន្លឹកកិច្ចការកុមារម្នាក់ៗរួចប្រាប់កុមារ=កូនម្នាក់ៗត្រូវបានផ្ទាំងសន្លឹកកិច្ចការនេះមួយសន្លឹកនិងខ្មៅដៃមួយដើម សម្រាប់កូនគូរដោយសេរីទៅតាមអ្វីដែលកូនចង់គូរម្នាក់ៗ
- គ្រូរៀបចំកុមារឱ្យអង្គុយទៅតាមតុដែលគ្រូបានរៀបចំឬបង្វិលកៅអី អង្គុយគូរ (តាមស្ថានភាពជាក់ស្ដែង)
- ឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅចែកគ្នាអនុវត្ត
- កុមារម្នាក់ៗនាំគ្នាអនុវត្ត គ្រូដើរសម្របសម្រួលគ្រប់ក្រុម សួរកុមារដាក់ចំណងជើងមេរៀនទៅតាមរូបភាពគំនូរជាក់ស្ដែងរបស់កុមារម្នាក់ៗ និងដាក់ឈ្មោះកុមារម្នាក់ៗពីខាងក្រោមសន្លឹកកិច្ចការរបស់កូនម្នាក់ៗ
- គ្រូប្រាប់កុមារ៖ ពេលកូនគូររួចហើយកូនយកខ្មៅដៃទៅទុកឱ្យគ្រូវិញ ហើយសន្លឹកកិច្ចការរបស់កូនទុកនៅរៀងៗខ្លួន។
- ពេលកុមារគូរហើយគ្រប់គ្នា គ្រូឱ្យកុមារទៅអង្គុយកន្លែងដើមជារាងអក្សរ(អ៊ុយ)វិញ
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារទៅឈរម្ដងមួយក្រុមនៅខាងមុខ ហើយកាន់សន្លឹកកិច្ចការដាក់នៅត្រង់ដើមទ្រូងបង្ហាញមិត្តភក្តិ ដើម្បីឱ្យពួកគេជាអ្នកផ្ទៀងផ្ទាត់។
- គ្រូសួរកុមារដែលជាអ្នកផ្ទៀងផ្ទាត់៖ តើមិត្តភក្តិយើងមួយណាគូរបានស្អាតជាងគេ? បើមានកុមារណា

បង្ហាប់គំនូររបស់មិត្តភក្តិណាម្នាក់ គ្រូត្រូវចេះកែតម្រូវទៅជាពាក្យសម្តីលើកទឹកចិត្តកុមារនោះវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការរបស់មិត្តភក្តិគេឱ្យគ្រូសម្រាប់ទុកដាក់តាំងស្នាដៃកុមារ។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

**មុខវិជ្ជា៖ បុរេគណិត**

**រំលឹក ល្បែង៖ បន្ថែមនិងបន្ថយចំនួនពី១ដល់៥**

**(ដំណើរការបង្រៀនអនុវត្តដូចខែទី២ ថ្ងៃទី១៧ ម៉ោងទី៣)**

ម៉ោងទី៦ (រយៈពេល ៣០នាទី)

**មុខវិជ្ជា៖ សិក្សាសង្គម**

*** ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ៖**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី២០

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

**រំលឹក ចលនាចរន្តៈ ដើរ រត់ លោត (ដើរជំហានវែងៗទៅមុខ រត់ទៅវាយវត្ថុចងព្យួរ លោតជើង២ទៅមុខ ដើរលឿនទៅមុខ)**

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៥ ម៉ោងទី១)**

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការ បង្រៀនអនុវត្ត ដូចថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អៈ សម្អាតធ្មេញ មុននិងក្រោយពេលគេង និងក្រោយពេលញ៉ាំបាយ (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី២០ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ បុរេគណិត

**គំនូរៈ គូសតាមស្នាមចុចលេខ៥និង៦**

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីរបៀបគូសលេខ៥ និងលេខ៦តាមស្នាមចុច បានត្រឹមត្រូវ
- កុមារគូសលេខ៥ និងលេខ៦តាមស្នាមចុច បានត្រឹមត្រូវ
- កុមារមានអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួនក្នុងការអនុវត្តជាបុគ្គល ។

**២. សម្ភារបង្រៀនៈ**

- បណ្ណលេខ ៥ និង ៦ មួយសន្លឹកជាគំរូ
- សន្លឹកក្រដាសមានសរសេរលេខ ៥ និង៦ ដែលមានស្នាមចុច ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ
- ខ្មៅដៃសម្រាប់គូសម្នាក់១
- ស្កុតកាត់រួចជាស្រេច

**៣. ការរៀបចំកុមារៈ** ជាក្រុមតូចៗ អង្គុយគូសជាបុគ្គល

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញបណ្ណលេខ ៥ និង៦ ឱ្យកុមារប្រាប់ ដោយសួរកុមារថាៈ **តើបណ្ណនេះមានលេខអ្វីខ្លះ?** រួចគ្រូ

បិទបណ្ណលេខនោះលើក្ដារខៀន
- គ្រូបង្ហាញសន្លឹកក្រដាសមានសរសេរលេខ ៥ និង៦ ដែលមានស្នាមចុច ហើយបិទលើក្ដារខៀន ដើម្បីបង្ហាញកុមារ រួចណែនាំពីរបៀបសរសេរម្ដងមួយតួអក្សរៗ យឺតៗលើផ្ទាំងក្រដាសតួអក្សរដែលមានស្នាមចុចនោះ តាមទិសដៅនៃការសរសេរ ឱ្យកុមារសង្កេតនិងនិយាយបណ្ដើរចាប់ពីកន្លែងចាប់ផ្ដើម រហូតដល់ចប់ (ពេលសរសេរ គ្រូឈរយ៉ាងណាឱ្យកុមារបានមើលឃើញទាំងអស់គ្នា)
- គ្រូប្រាប់កុមារថា បន្ដិចទៀតគ្រូនឹងក្រដាសមួយសន្លឹកដល់កូនៗទាំងអស់គ្នា(លើកបង្ហាញបណ្ដើរ)។ បន្ទាប់មកកូនចាប់យកខ្មៅដៃរបស់កូនមកគូសលេខ ៥ និង៦ តាមស្នាមចុច ដែលមាននៅលើក្រដាសកិច្ចការរបស់កូន។ កូនត្រូវសរសេរទៅតាមទិសដៅនៃការសរសេរឱ្យបានត្រឹមត្រូវ ដូចទៅនឹងការសរសេរបង្ហាញរបស់គ្រូអម្បាញ់មិញនេះ។
- គ្រូឱ្យកុមារទៅអង្គុយជាក្រុមតាមតុ ដែលបានរៀបចំរួច(បើករណីមិនមានតុ គ្រូឱ្យកុមារបង្វិលកៅអីដាក់ចំពីមុខ រួចអង្គុយគូសនៅលើកៅអីរៀងខ្លួន) រួចចែកសន្លឹកក្រដាសមានសរសេរលេខ៥ និង៦ ដែលមានស្នាមចុច ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ ដល់កុមារម្នាក់ៗ
- គ្រូឱ្យកុមារចាប់ផ្ដើមឱ្យកុមារគូសចម្លងតាមការណែនាំ រួចដើរពិនិត្យ និងជួយសម្របសម្រួលការសរសេររបស់កុមារម្នាក់ៗ
- គ្រូឱ្យកុមារយកសន្លឹកបណ្ណលេខដែលខ្លួនបានគូសចម្លង មកបិទលើក្ដារខៀន
- គ្រូនាំកុមារផ្ទៀងផ្ទាត់ការសរសេររបស់កុមារម្ដងម្នាក់ៗ ដោយឱ្យកុមារកាន់សន្លឹកកិច្ចការរបស់ខ្លួនមកឈរនៅមុខមិត្តភក្ដិ ម្ដងមួយក្រុមៗ រួចលើកបង្ហាញមិត្តភក្ដិ ហើយគ្រូនាំកុមារសង្កេតសន្លឹកកិច្ចការរបស់មិត្តភក្ដិដែលលើកបង្ហាញ។ ពេលផ្ទៀងផ្ទាត់លទ្ធផលកុមារម្នាក់ៗ គ្រូត្រូវនាំណែនាំមិត្តភក្ដិឱ្យចេះលើកសសើរ លើកទឹកចិត្តដល់កុមារដែលមិនទាន់ធ្វើបានល្អឱ្យប្រឹងប្រែងបន្ត មិនត្រូវប្រៀបធៀប ឬបន្ទុះបង្អាប់កុមារឡើយ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងជាក្រុម និងទាំងអស់គ្នាឡើងវិញ
- គ្រូប្រមូលសន្លឹកកិច្ចការរបស់កុមារទាំងអស់សម្រាប់ដាក់តាំងស្នាដៃកុមារក្នុងថ្នាក់

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពកសាង៖ ដោតបំពង់បឺតឆ្លាស់ពណ៌

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីរបៀបដោតបំពង់បឺតឆ្លាស់ពណ៌ បានត្រឹមត្រូវ
- កុមារមានសមត្ថភាពក្នុងការដោតបំពង់បឺតឆ្លាស់ពណ៌ បានត្រឹមត្រូវ។
- បណ្ដុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន អំណត់ក្នុងការធ្វើសកម្មភាព។

**២. សម្ភារបង្រៀន៖**
- គ្រូ៖បំពង់បឺតកាត់ខ្លីៗឆ្លាស់ពណ៌គ្នា ខ្សែ កញ្ជ្រែង
- បំពង់បឺតកាត់ខ្លីៗឆ្លាស់ពណ៌គ្នា ដែលដោតហើយទុកបង្ហាញជារួម
- កុមារ៖បំពង់បឺតកាត់ខ្លីៗឆ្លាស់ពណ៌គ្នា ខ្សែ កញ្ជ្រែង

**៣.ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរ "U"

**៤.ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញរូប បំពង់បឺតកាត់ខ្លីៗឆ្លាស់ពណ៌គ្នា ដែលដោតហើយឱ្យកុមារប្រាប់ពីរូបនោះ និងយកទៅបិទលើក្ដារខៀនជាគំរូសម្រាប់កុមារសង្កេត
- គ្រូបង្ហាញរូបសម្ភារដូចជាបំពង់បឺតកាត់ខ្លីៗឆ្លាស់ពណ៌គ្នា ខ្សែ កញ្ច្រែង រួចសួរកុមារ នេះជារូបអ្វី?តើអ្នកគ្រូយកសម្ភារទាំងអស់នោះមកធ្វើអ្វី?
- គ្រូណែនាំពីរបៀបដោតបំពង់បឺតឆ្លាស់ពណ៌ យឺតៗ ណែនាំបណ្ដើរដោតបំពង់បឺតឆ្លាស់ពណ៌បង្ហាញបណ្ដើរ ដើម្បីឱ្យកុមារសង្កេតឱ្យបានច្បាស់ ហើយគ្រូត្រូវឈរធ្វើយ៉ាងណាឱ្យកុមារមើលឃើញគ្រប់ៗគ្នា
  - •កូនយកដៃទាំងពីដៃស្ដាំកាន់ខ្សែ ដៃឆ្វេងរបស់កូនកាន់បំពង់បឺត
  - •បន្ទាប់មកកូនដោតបំពង់បឺតចូលទៅក្នុងខ្សែនៃដៃខាងស្ដាំដែលកូនកាន់
  - •ដោយកូនដោយឱ្យឆ្លាស់ពណ៌គ្នាមាន ក្រហម ខៀវ លឿង បៃតង ទឹកក្រូច
  - •កូនៗដោតម្ដងមួយពណ៌ៗកុំឱ្យជាន់ពណ៌គ្នារហូតកូនអាចដោតធ្វើខ្សែក ខ្សែដៃបាន។
- គ្រូរៀបចំកុមារឱ្យអង្គុយជាជួរ និងឱ្យកុមារពីរនាក់មកយកសម្ភារទៅចែកមិត្តភក្ដិគេអនុវត្ត
- គ្រូឱ្យកុមារចាប់ផ្ដើមអនុវត្តជាបុគ្គលម្នាក់ៗ
- គ្រូដើរសម្របសម្រួលទៅតាមជួរនីមួយៗដោយជួយកុមារណាដែលមិនទាន់ចេះដោតនិងដោតមិនទាន់បានត្រឹមត្រូវ។
- គ្រូនាំកុមារទៀងផ្ទាត់លទ្ធផលរបស់កុមារម្នាក់ៗរួចឱ្យកុមារចេញម្ដងមួយជួរម្ដងមួយជួរតាមឈរពីមុខមិត្តភក្ដិគេដោយកាន់រូបខ្សែដៃ ខ្សែក ដើម្បីបង្ហាញ
- គ្រូសួរកុមារ៖ តើរូបមិត្តភក្ដិយើងធ្វើបានត្រឹមត្រូវទេ?ខ្សែក ខ្សែដៃដោតបានឆ្លាស់ពណ៌ស្អាតទេ?
- គ្រូនិយាយប្រាប់កុមារ៖ ពេលក្រុមកូនបង្ហាញរួចហើយកូនកាន់រូបនេះទៅអង្គុយកន្លែងដើមវិញ។
- ពេលនាំកុមារផ្ទៀងផ្ទាត់លទ្ធផល គ្រូមិនត្រូវបង្អាប់កុមារដែលធ្វើមិនទាន់បានល្អនោះទេ។គ្រូត្រូវចេះសរសើរ លើកទឹកចិត្តកុមារឱ្យបានគ្រប់ៗគ្នាដើម្បីឱ្យពួកគេប្រឹងប្រែងបន្តទៀត។
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតទាល់តែគ្រប់កុមារទាំងអស់។
- គ្រូឱ្យតំណាងក្រុមនីមួយៗប្រមូលកិច្ចការកុមារម្នាក់ៗជូនគ្រូទុកសម្រាប់ដាក់តាំងស្នាដៃកុមារនៅលើផ្ទាំងស្នាដៃកុមារនៅថ្ងៃបន្ទាប់។
- គ្រូត្រូវដាក់ថ្ងៃខែឆ្នាំអនុវត្តមុខវិជ្ជានិងចំណងជើងមុននឹងយកទៅដាក់តាំងស្នាដៃកុមារ

ម៉ោងទី៥ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ ភាសាខ្មែរ

## គំនូរៈ គូសតាមស្នាមចុចតួអក្សរ ឃ ង ច

**១. វត្ថុបំណងៈ**

-កុមារប្រាប់បានពីរបៀបគូសតួអក្សរ ឃ ង ច តាមស្នាមចុច បានត្រឹមត្រូវ

-កុមារ គូសតួអក្សរ ឃ ង ច តាមស្នាមចុច បានត្រឹមត្រូវ

-កុមារមានអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួនក្នុងការអនុវត្តជាបុគ្គល ។

**២. សម្ភារបង្រៀនៈ**

- បណ្ណតួអក្សរ ឃ ង ច មួយសន្លឹកជាគំរូ
- សន្លឹកក្រដាសមានសរសេរតួអក្សរ ឃ ង ច ដែលមានស្នាមចុច ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ
- ខ្មៅដៃសម្រាប់គូសម្នាក់១
- ស៊ុតកាត់រួចជាស្រេច

**៣. ការរៀបចំកុមារៈ** អង្គុយគូសជាបុគ្គល

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញបណ្ណតួអក្សរ ឃ ង ច ឱ្យកុមារប្រាប់ ដោយសួរកុមារថាៈ **តើបណ្ណនេះមានតួអក្សរអ្វីខ្លះ?** រួចគ្រូបិទបណ្ណតួអក្សរនោះលើក្ដារខៀន
- គ្រូបង្ហាញសន្លឹកក្រដាសមានសរសេរតួអក្សរ ឃ ង ច ដែលមានស្នាមចុច ហើយបិទលើក្ដារខៀន ដើម្បីបង្ហាញកុមារ រួចណែនាំពីរបៀបសរសេរម្ដងមួយតួអក្សរៗ យឺតៗលើផ្ទាំងក្រដាសតួអក្សរដែលមានស្នាមចុចនោះ តាមទិសដៅនៃការសរសេរ ឱ្យកុមារសង្កេតនិងនិយាយបណ្ដើរចាប់ពីកន្លែងចាប់ផ្ដើម រហូតដល់ចប់ (ពេលសរសេរ គ្រូឈរយ៉ាងណាឱ្យកុមារបានមើលឃើញទាំងអស់គ្នា)
- គ្រូប្រាប់កុមារថា **បន្តិចទៀតគ្រូនឹងឱ្យក្រដាសមួយសន្លឹកដល់កូនៗទាំងអស់គ្នា(លើកបង្ហាញបណ្ដើរ)។ បន្ទាប់មកកូនចាប់យកខ្មៅដៃរបស់កូនមកគូសតួអក្សរ ឃ ង ច តាមស្នាមចុច ដែលមាននៅលើក្រដាសកិច្ចការរបស់កូន។ កូនត្រូវសរសេរទៅតាមទិសដៅនៃការសរសេរឱ្យបានត្រឹមត្រូវ ដូចទៅនឹងការសរសេរបង្ហាញរបស់គ្រូអម្បាញ់មិញនេះ។**
- គ្រូឱ្យកុមារទៅអង្គុយជាក្រុមតាមតុ ដែលបានរៀបចំរួច(បើករណីមិនមានតុ គ្រូឱ្យកុមារបង្វិលកៅអីដាក់ចំពីមុខ រួចអង្គុយគូសនៅលើកៅអីរៀងខ្លួន) រួចចែកសន្លឹកក្រដាសមានសរសេរតួអក្សរ ឃ ង ច ដែលមានសល់ចន្លោះពីក្រោមសម្រាប់សរសេរចម្លងតាម ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ ដល់កុមារម្នាក់ៗ
- គ្រូឱ្យកុមារចាប់ផ្ដើមឱ្យកុមារគូសចម្លងតាមការណែនាំ រួចដើរពិនិត្យ និងជួយសម្របសម្រួលការសរសេររបស់កុមារម្នាក់ៗ
- គ្រូឱ្យកុមារយកសន្លឹកបណ្ណលេខដែលខ្លួនបានគូសចម្លង មកបិទលើក្ដារខៀន បន្ទាប់ពីគូសរួច
- គ្រូនាំកុមារផ្ទៀងផ្ទាត់ការសរសេររបស់កុមារម្ដងម្នាក់ៗ ដោយឱ្យកុមារកាន់សន្លឹកកិច្ចការរបស់ខ្លួនមកឈរ

នៅមុខមិត្តភក្តិ ម្តងមួយក្រុមៗ រួចលើកបង្ហាញមិត្តភក្តិ ហើយគ្រូនាំកុមារសង្កេតសន្លឹកកិច្ចការរបស់មិត្តភក្តិដែលលើក

បង្ហាញ។ ពេលផ្ទៀងផ្ទាត់លទ្ធផលកុមារម្នាក់ៗ គ្រូត្រូវនាំណែនាំមិត្តភក្តិឱ្យចេះលើកសសើរ លើកទឹកចិត្តដល់កុមារដែលមិនទាន់ធ្វើបានល្អឱ្យប្រឹងប្រែងបន្ត មិនត្រូវប្រៀបធៀប ឬបន្ទុះបង្អាប់កុមារឡើយ

- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងជាក្រុម និងទាំងអស់គ្នា
- គ្រូប្រមូលសន្លឹកកិច្ចការរបស់កុមារទាំងអស់សម្រាប់ដាក់តាំងស្នាដៃកុមារក្នុងថ្នាក់

### ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

*** ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# កម្មវិធីសិក្សាខែទី៤

## កម្មវិធីសិក្សាប្រចាំខែទី៤ (២១ថ្ងៃ)

| ម៉ោង | ថ្ងៃទី១ សុក្រ | ថ្ងៃទី២ សៅរ៍ | ថ្ងៃទី៣ ចន្ទ | ថ្ងៃទី៤ អង្គារ | ថ្ងៃទី៥ ពុធ |
|---|---|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | | | |
| ៧៖១០-៧៖៤០ | ល្បែងចលនាៈ<br>"ក្រពើដេញចាប់" | ហាត់ប្រាណតាមបទចម្រៀងៈ<br>"ពេលសប្បាយ" | ហាត់ប្រាណតាមរឿងនិទានៈ<br>"មេសេះនាំកូនទៅរកចំណី" | ចលនាមូលដ្ឋានៈ "វារ"<br>-វារទៅមុខតាមទីកំណត់<br>-វារក្រោមតុ<br>-វារចូលកងឬរង្វង់ | ចលនាចន្លោះ "ដើរ រត់ លោត វារ"<br>-ដើរតាមផ្លូវ<br>-រត់រំលងឧបសគ្គ<br>-លោតចូលកងឬរង្វង់<br>-វារក្រោមតុ |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃៈ ពិនិត្យវត្តមាននិងអវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀង "ជម្រាបសួរ"<br>- ទម្លាប់ល្អៈ ត្រូវចេះចែករំលែកសម្ភារៈលេងនិងចំណីឱ្យមិត្តភក្តិ | | | | |
| ៨៖១០-៨៖៤០ | ភាសាខ្មែរ<br>សន្ទនាៈអំពីព្រឹត្តិការណ៍ផ្សេងៗដែលបានជួប ប្រាប់មិត្តភក្តិ | បុរេគណិត<br>សម្គាល់ៈ ចំនួននិងលេខពី១ដល់១០ | ភាសាខ្មែរ<br>ល្បែងៈទាយឈ្មោះសត្វដោយប្រើកាយវិកា | វិទ្យាសាស្ត្រ<br>ទស្សនាសង្កេតៈចំការបន្លែ | បុរេគណិត<br>សម្គាល់ៈធ្ងន់និងស្រាល |
| ៨៖៤០-៨៖៥០ | **ចេញលេង** | | | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>ល្បែងៈផ្គូផ្គងសំឡេង | សិក្សាសង្គម<br>រឿងនិទានៈទីណូ ស្រួច និងផ្លែត្រសក់ (និទាន) | សិក្សាសង្គម<br>ចម្រៀងៈយើងក្មេងៗនាំគ្នារាំ (ពេលទី១) | សិក្សាសង្គម<br>គំនូរៈផ្លែចេកណាំវាំមួយផ្លែ | សិក្សាសង្គម<br>សកម្មភាពកសាងៈ ហែកនិងបិទរូបផ្លែក្រូច |
| ៩៖២០-៩៖៥០ | វិទ្យាសាស្ត្រ<br>សង្កេតៈបន្លែ | ភាសាខ្មែរ<br>សម្គាល់តួអក្សរៈ "ញ" | វិទ្យាសាស្ត្រ<br>ល្បែងៈធ្វើចំណាត់ថ្នាក់បន្លែផ្លែ បន្លែស្លឹក បន្លែមើម | បុរេគណិត<br>ល្បែងៈទៅផ្សារទិញបន្លែនិងផ្លែឈើចំនួនពី១ដល់១០ | ភាសាខ្មែរ<br>កំណាព្យៈត្រូវញាំបន្លែពណ៌បៃតង |
| ៩៖៥០-១០៖០០ | **ចេញលេង** | | | | |
| ១០៖១០-១០៖៣០ | សិក្សាសង្គមៈ<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | ចិត្តចលភាព<br>ល្បែងៈ ផ្ទាត់គ្រាប់គ្រួសឬកៅស៊ូប្រណាំងគ្នា | សិក្សាសង្គមៈ<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គមៈ<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គមៈ<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ |

| ម៉ោង | ថ្ងៃទី៦ សៅរ៍ | ថ្ងៃទី៧ ចន្ទ | ថ្ងៃទី៨ អង្គារ | ថ្ងៃទី៩ ពុធ | ថ្ងៃទី១០ សុក្រ |
|---|---|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | | | |
| ៧៖១០-៧៖៤០ | ល្បែងចលនា៖<br>"ដណ្ដើមស្លឹកឈើ" | ហាត់ប្រាណតាមបទចម្រៀង៖<br>"ពេលសប្បាយ" (រំលឹក) | ហាត់ប្រាណតាមរឿងនិទាន៖<br>"មេសេះនាំកូនទៅរកចំណី"<br>(រំលឹក) | ចលនាមូលដ្ឋាន៖ "វារ"<br>-វារទៅមុខតាមទីកំណត់<br>-វារក្រោមតុ<br>-វារចូលកងឬរង្វង់ (រំលឹក) | ចលនាចរន្ត៖ "ដើរ រត់ លោត វារ"<br>-ដើរតាមផ្លូវ<br>-រត់រំលងឧបសគ្គ<br>-លោតចូលកងឬរង្វង់<br>-វារក្រោមតុ (រំលឹក) |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមាននិងអវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀង "ជម្រាបសួរ"<br>- ទម្លាប់ល្អ៖ ត្រូវចេះស្ដាប់ដំបូន្មានគ្រូនិងឪពុកម្ដាយ | | | | |
| ៨៖១០-៨៖៤០ | បុរេគណិត<br>ប្រៀបធៀប៖ ធ្ងន់ជាង និង ស្រាលជាង | ភាសាខ្មែរ<br>ល្បែង៖គូសភ្ជាប់អក្សរដែលដូចគ្នា ឆ ជ ឈ | វិទ្យាសាស្ត្រ<br>សង្កេត៖ផ្លែឈើ (ផ្លែក្រូចពោធិសាត់) | បុរេគណិត<br>ល្បែង៖បង្កើតសំណុំចំនួនតូចៗពី១ដល់១០ | ភាសាខ្មែរ<br>សន្ទនា៖សម្ភារប្រើប្រាស់ប្រចាំថ្ងៃដែលស្រលាញ់ពេញចិត្ត |
| ៨៖៤០-៨៖៥០ | **ចេញលេង** | | | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>រឿងនិទាន៖ ការអត់ឱន (និទាន) | សិក្សាសង្គម<br>ចម្រៀង៖យើងក្មេងៗនាំគ្នារាំ (ពេលទី២) | សិក្សាសង្គម<br>គំនូរ៖ផាត់ពណ៌ផ្លែកចេកណាំវ៉ា ទុំមួយផ្លែ | សិក្សាសង្គម<br>សកម្មភាពកសាង៖ រៀបវត្ថុតូចៗបិទលើរូបផ្លែត្រឡាច | សិក្សាសង្គម<br>ល្បែង៖បង្កើតក្រុមតាមសំឡេងដូចគ្នា |
| ៩៖២០-៩៖៥០ | ភាសាខ្មែរ<br>សម្គាល់តួអក្សរ៖ "ជ" | វិទ្យាសាស្ត្រ<br>ពិសោធន៍៖ភ្លក្សរសជាតិបន្លែ | បុរេគណិត<br>ល្បែង៖ចំណាត់ក្រុមផ្លែឈើតាមទំហំនិងពណ៌ | ភាសាខ្មែរ<br>អំណានរឿង៖បូណាជាកូនល្អ | វិទ្យាសាស្ត្រ<br>ពិសោធន៍៖ភ្លក្សរសជាតិផ្លែឈើ |
| ៩៖៥០-១០៖០០ | **ចេញលេង** | | | | |
| ១០៖១០-១០៖៣០ | ចិត្តចលភាព<br>ល្បែង៖ ផ្ទាត់កៅស៊ូប្រណាំងគ្នា | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ |

| ម៉ោង | ថ្ងៃទី១១ សៅរ៍ | ថ្ងៃទី១២ ចន្ទ | ថ្ងៃទី១៣ អង្គារ | ថ្ងៃទី១៤ ពុធ | ថ្ងៃទី១៥ សុក្រ |
|---|---|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | | | |
| ៧៖១០-៧៖៤០ | ល្បែងចលនា៖<br>"បង់សំណាញ់" | ហាត់ប្រាណតាមបទចម្រៀង៖<br>"យើងក្មេងៗនាំគ្នារាំ" | ហាត់ប្រាណតាមរឿងនិទាន៖<br>(យើងទៅឡេងចំការពោត) | ចលនាមូលដ្ឋាន៖ "វារ"<br>-វារទៅមុខដាក់វត្ថុលើខ្នង<br>-វាររុញបាល់បញ្ជូនទៅមុខ<br>-វារទៅឆ្វេង វារទៅស្ដាំ | ចលនាចរន្ត៖"ដើរ រត់ លោត វារ"<br>-ដើរវាងឧបសគ្គ<br>-រត់ទៅរកទី<br>-លោតរំលងខ្សែ<br>-វារទៅមុខដាក់វត្ថុលើខ្នង |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀង "ជម្រាបសួរ"<br>- ទម្លាប់ល្អ៖ អរគុណពេលទទួលបានអ្វីៗ ឬមានការជួយពីមិត្តភក្ដិនិងមនុស្សធំ | | | | |
| ៨៖១០-៨៖៤០ | បុរេគណិត<br>ប្រៀបធៀប៖ចំនួនស្មើគ្នា តិចជាង ច្រើនជាង ក្នុងចំនួនពី១ដល់១០ | ភាសាខ្មែរ<br>សម្គាល់តួអក្សរ៖ "ណ" | វិទ្យាសាស្ត្រ<br>សង្កេត៖ប្រៀបធៀបផ្លែឈើទុំនិងផ្លែឈើខ្ចី | បុរេគណិត<br>ល្បែង៖ផ្គុំចំនួនរូបភាពទៅនឹងចំនួនចំណុចពី១ដល់១០ | ភាសាខ្មែរ<br>កំណាព្យ៖ ថាអរគុណ |
| ៨៖៤០-៨៖៥០ | **ចេញលេង** | | | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>រឿងនិទាន៖ ទន្សាយចង់ស៊ីចេក (និទាន) | សិក្សាសង្គម<br>ចម្រៀង៖ឆ្វេង ស្ដាំ (ពេលទី១) | សិក្សាសង្គម<br>គំនូរ៖គូរមើមការ៉ុតតាមលំដាប់លេខ | សិក្សាសង្គម<br>សកម្មភាពកសាង៖បត់រូបមើមការ៉ុត | សិក្សាសង្គម<br>ល្បែង៖ប្រព័ន្ធគ្រួសារបន្លែ |
| ៩៖២០-៩៖៥០ | ភាសាខ្មែរ<br>ល្បែង៖គូសវង់រូបភាពមិនមែនបន្លែនិងផ្លែឈើ | វិទ្យាសាស្ត្រ<br>ល្បែង៖ធ្វើចំណាត់ថ្នាក់បន្លែនិងផ្លែឈើ | បុរេគណិត<br>ល្បែង៖ផ្គូផ្គងចំនួនរូបភាពទៅនឹងចំនួនចំណុចទៅនឹងលេខពី១ដល់១០ | ភាសាខ្មែរ<br>ល្បែង៖បំពេញតួអក្សរតាមចន្លោះពី ឃ ដល់ ណ | វិទ្យាសាស្ត្រ<br>សន្ទនា៖សារៈសំខាន់នៃការញ៉ាំបន្លែនិងផ្លែឈើ |
| ៩៖៥០-១០៖០០ | **ចេញលេង** | | | | |
| ១០៖១០-១០៖៣០ | ចិត្តចលភាព<br>ល្បែង៖ ក្ដាមវាររកចំណី | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ |

| ម៉ោង | ថ្ងៃទី១៦ សៅរ៍ | ថ្ងៃទី១៧ ចន្ទ | ថ្ងៃទី១៨ អង្គារ | ថ្ងៃទី១៩ ពុធ | ថ្ងៃទី២០ សុក្រ |
|---|---|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | | | |
| ៧៖១០-៧៖៤០ | ល្បែងចលនា៖<br>"រូបចម្លាក់មានចលនា" | ហាត់ប្រាណតាមបទចម្រៀង៖<br>"យើងក្មេងៗនាំគ្នារាំ" (រំលឹក) | ហាត់ប្រាណតាមរឿងនិទាន៖<br>"មេមាន់នាំកូនទៅរកចំណី"<br>(រំលឹក) | ចលនាមូលដ្ឋាន៖ "វារ"<br>-វារបត់បែនតាមខ្សែ<br>-វារដូចសត្វក្ដាម<br>-វារវាងឧបសគ្គ | ចលនាចន្លុះ"ដើរ រត់ លោត វារ"<br>-ដើរវាងឧបសគ្គ<br>-រត់ទៅរកទី<br>-លោតរំលងខ្សែ<br>-វារទៅមុខដាក់វត្ថុលើខ្នង<br>(រំលឹក) |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមាននិងអវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ) ចម្រៀង "ជម្រាបសួរ"<br>- ទម្លាប់ល្អ៖ ពេលរើសបានវត្ថុអ្វីមួយត្រូវសួររកម្ចាស់ឬប្រាប់គ្រូឬប្រាប់ឪពុកម្ដាយ | | | | |
| ៨៖១០-៨៖៤០ | បុរេគណិត<br>ល្បែង៖បំពេញលេខតាមចន្លោះ<br>ពី១ដល់១០ | ភាសាខ្មែរ<br>កំណាព្យ៖ដួយដាំចេកតា | វិទ្យាសាស្ត្រ<br>ល្បែង៖រកដៃគូ បន្លែស្លឹក<br>បន្លែផ្លែ | បុរេគណិត<br>ល្បែង៖បន្ថែម និងបន្ថយ<br>ចំនួនពី១ដល់១០ | ភាសាខ្មែរ<br>គំនូរ៖គូរចម្លងតាមគំរូតួអក្សរ<br>ធ ជ ឈ |
| ៨៖៤០-៨៖៥០ | **ចេញលេង** | | | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>រឿងនិទាន៖ ពពក និងផ្កា<br>(និទាន) | សិក្សាសង្គម<br>ចម្រៀង៖ធ្មេង ស្ដាំ (ពេលទី២) | សិក្សាសង្គម<br>គំនូរ៖គូរសេរី | សិក្សាសង្គម<br>សកម្មភាពកសាង៖ដេរតាម<br>ទម្រង់រូបផ្លែល្ពៅ | សិក្សាសង្គម<br>ល្បែង៖បិទមុខទាយសំឡេង |
| ៩៖២០-៩៖៥០ | ភាសាខ្មែរ<br>ល្បែង៖ធ្វើតាមការណែនាំ៣<br>ដំណាក់ | វិទ្យាសាស្ត្រ<br>ល្បែង៖ហុចកញ្ចប់បន្លែ ផ្លែឈើ | បុរេគណិត<br>ល្បែង៖រកដៃគូរលេខពី ១ដល់<br>១០ | ភាសាខ្មែរ<br>គំនូរ៖គូរតួអក្សរ ញ ដ ណ<br>តាមស្នាមចុច | វិទ្យាសាស្ត្រ<br>ល្បែង៖ប្រព័ន្ធគ្រួសារផ្លែឈើ |
| ៩៖៥០-១០៖០០ | **ចេញលេង** | | | | |
| ១០៖១០-១០៖៣០ | ចិត្តចលភាព<br>ល្បែង៖ ចាប់វត្ថុប្រណាំងគ្នា<br>ដោយប្រើម្រាមដៃ២ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ | សិក្សាសង្គម៖<br>-ល្បែងសេរី -រំលឹកមេរៀន<br>-អនាម័យទៅផ្ទះ |

| ម៉ោង | ថ្ងៃទី២១ សៅរ៍ | | |
|---|---|---|---|
| ៧៖០០-៧៖១០ | **ទទួលកុមារ និងគោរពទង់ជាតិ** | | |
| ៧៖១០-៧៖៤០ | ល្បែងចលនា៖<br>"បង់សំណាញ់"<br>(រំលឹក) | | |
| ៧៖៤០-៨៖១០ | - សកម្មភាពប្រចាំថ្ងៃ៖ ពិនិត្យវត្តមាននិងអវត្តមានកុមារ និងបង្ហាញកាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ)<br>- ទម្លាប់ល្អ៖ ត្រូវចូលគេងឱ្យទៀងទាត់ពេលវេលា | | |
| ៨៖១០-៨៖៤០ | បុរេគណិត<br>គំនូរ៖ គូរចម្លងតាមគំរូលេខ៧<br>និងលេខ៨ | | |
| ៨៖៤០-៨៖៥០ | ចេញលេង | | |
| ៨៖៥០-៩៖២០ | សិក្សាសង្គម<br>អំណាន៖ បូណាជាកូនល្អ | | |
| ៩៖២០-៩៖៥០ | ភាសាខ្មែរ<br>គំនូរ៖គូរចម្លងតាមគំរូតួអក្សរ<br>ឆ ជ ឈ (រំលឹក) | | |
| ៩៖៥០-១០៖០០ | **ចេញលេង** | | |
| ១០៖១០-១០៖៣០ | ចិត្តចលភាព<br>ល្បែង៖ ចាប់វត្ថុប្រណាំងគ្នា<br>ដោយប្រើម្រាមដៃទាំង២<br>(រំលឹក) | | |

# ដំណើរការបង្រៀនតាមកម្មវិធី

# សកម្មភាពបង្រៀន ប្រចាំខែទី ៤

## ថ្ងៃទី១

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

## ល្បែងចលនាៈ ក្រពើដេញចាប់

**១. វត្ថុបំណងៈ**

- ប្រាប់បានពីរបៀបធ្វើចលនារត់ដេញចាប់ រត់គេចពីក្រពើបានត្រឹមត្រូវតាមរយៈការណែនាំរបស់គ្រូ
- កុមាររត់ដេញចាប់ រត់គេច បានត្រឹមត្រូវតាមរយៈការអនុវត្តផ្ទាល់
- មានបម្រុងប្រយ័ត្ន ស្វាហាប់ រហ័សរហួនសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** រៀបកុមារជា២ក្រុម

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងដំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរតាមក្រុម តាមទីកន្លែងដែលបានកំណត់
- គ្រូសួរបំផុសកុមារថាៈ តើកូនស្គាល់សត្វអ្វីខ្លះនៅក្នុងទឹក? តើសត្វណាដែលកូនខ្លាចជាងគេ? ហើយបើសត្វនោះដេញកូន តើកូនត្រូវធ្វើដូចម្តេច?(គ្រូទទួលចម្លើយរបស់កុមារ)
- គ្រូនាំកុមារធ្វើចលនារត់តិចៗទៅមុខ រត់ទៅក្រោយចុះឡើង
- គ្រូប្រាប់កុមារថាៈ បន្តិចទៀត គ្រូនឹងនាំកូនលេងល្បែងមួយឈ្មោះថា "ក្រពើដេញចាប់"
- គ្រូរៀបចំទីតាំង កំណត់ចម្ងាយទី មុននឹងចាប់ផ្តើមមេរៀន។
- គ្រូបង្ហាញទីតាំង "គូសទីកំណត់ជាស្ទឹង" ពីគំនូសម្ខាងទៅគំនូសម្ខាងទៀតប្រហែល ៣ម៉ែត្រ
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេងដល់កុមារៈ** ដើម្បីលេងល្បែងក្រពើដេញចាប់នេះគឺត្រូវការកូនម្នាក់ ធ្វើជាសត្វក្រពើដែលឈរនៅចំកណ្តាលស្ទឹងចាំដេញចាប់អ្នកឆ្លងកាត់ស្ទឹង។ កូន១នាក់ត្រូវឈរនៅចំកណ្តាលស្ទឹង ធ្វើជាក្រពើចាំដេញចាប់អ្នករត់ឆ្លងស្ទឹង។ រីឯកូនៗផ្សេងទៀតត្រូវធ្វើជាអ្នកឆ្លងកាត់ស្ទឹង ឈរសងខាងមាត់ស្ទឹង។ អ្នកឆ្លងកាត់ស្ទឹងត្រូវរត់ ធ្វើយ៉ាងណាកុំឱ្យក្រពើដេញចាប់បាន។ បើកូនណាម្នាក់ឱ្យក្រពើចាប់បានកូនហ្នឹងក្លាយជាក្រពើ ហើយកាន់ដៃជាមួយក្រពើពេលដេញចាប់ក្រពើទាំងពីរមិនត្រូវរបូតដៃចេញពីគ្នាបានទេ។ បើក្រពើរបូតដៃចេញពីគ្នាពេលចាប់បានអ្នករត់គឺមិនយកធ្វើជាក្រពើឡើយ។ នៅពេលក្រពើមានគ្នា ៣នាក់ ត្រូវរត់ទៅចាប់កុមារម្នាក់ទៀត ប៉ុន្តែត្រូវប្រលែងដៃអ្នកទី១ឱ្យទៅធ្វើជាក្រពើថ្មីម្តងទៀត។ កូនលេងរបៀបនេះរហូតដល់បានក្រពើច្រើន។ កូនដែលរត់ឆ្លងស្ទឹងទៅមកក្រពើចាប់មិនបានជាអ្នកឈ្នះ។ ក្នុងពេលកូនលេងត្រូវមានបម្រុងប្រយ័ត្ន កុំឱ្យរត់ប៉ះគ្នាដែលនាំឱ្យដួល និងចេះយោគយល់គ្នាទៅវិញទៅមក។
- គ្រូឱ្យកុមារ១នាក់ ឬ២នាក់និយាយពីរបៀប និងលក្ខខណ្ឌនៃការលេងឡើងវិញតាមការចងចាំរបស់កុមារ (ប្រសិនបើកុមារនិយាយមិនត្រឹមត្រូវ គ្រូជួយបំពេញបន្ថែម)។
- គ្រូនាំកុមារលេងសាកល្បង តាមរបៀបដែលបានណែនាំខាងលើ
- គ្រូចាប់ផ្តើមនាំកុមារលេង និងជួយសម្របសម្រួលការលេង
- គ្រូលើកសរសើរ កុមារដែលធ្វើបានល្អ និងលើកទឹកចិត្តចំពោះកុមារដែលធ្វើមិនទាន់បានល្អ

- គ្រូនាំកុមារធ្វើកាយវិការផ្លុំទឹកក្តៅៈ
  - កូនៗស្រូបយកខ្យល់ដង្ហើមចូល ហើយផ្លុំខ្យល់ដង្ហើមចេញមកក្រៅវែងៗ ឱ្យបាន៣ ទៅ៤ដង បន្ទាប់មកកូនៗយកដៃកាន់កែវទឹកក្តៅរួចដាក់ជិតមាត់ ហើយផ្លុំតិចៗ ៣ ទៅ៤ដង ឱ្យត្រជាក់
  - កូនៗផ្លុំទឹកត្រជាក់ហើយឬនៅ?បើត្រជាក់ហើយកូននាំគ្នាផឹកទាំងអស់គ្នា។
- គ្រូសួរកុមារៈ
  - តើអម្បាញ់មិញ កូនៗបានលេងល្បែងអ្វី?
  - តើកូនបានធ្វើចលនាអ្វីខ្លះនៅក្នុងពេលលេងល្បែងនេះ?
  - តើថ្ងៃនេះកូនរៀនជាមុខវិជ្ជាអ្វី?មេរៀនអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារៈ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព មេរៀនល្បែងចលនា " ក្រពើដេញចាប់"
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ទាំងអស់គ្នា
-

**ម៉ោងទី ២ (រយៈពេល ៣០នាទី)**

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អៈ ត្រូវចេះចែករំលែកសម្ភារ និងនំចំណីឱ្យមិត្តភក្តិ
  - គ្រូសួរកុមារៈ
    - នៅក្នុងថ្នាក់រៀនយើងមានសម្ភារល្បែងច្រើនមុខខុសៗគ្នា។ កូននៅក្នុងថ្នាក់មានចំនួនច្រើនជាង សម្ភារល្បែងទាំងនោះ ដូច្នេះកូនត្រូវធ្វើដូចម្តេចដើម្បីឱ្យមិត្តភក្តិយើងបានលេងគ្រប់ៗគ្នា។
    - បើក្នុងថ្នាក់យើងមានបាល់តែពីរហើយមិត្តភក្តិចង់លេងដល់ទៅ៣នាក់ តើកូនត្រូវធ្វើដូចម្តេចដើម្បី បានលេងទាំងអស់គ្នា? ហើយមិនឈ្លោះគ្នា? មិនដណ្តើមគ្នា?
    - នៅពេលកូនចេញលេង កូនមាននំញ៉ាំហើយមិត្តភក្តិកូនមួយនាក់អង្គុយនៅជិតកូនហើយគ្មាននំញ៉ាំ តើកូនត្រូវធ្វើដូចម្តេច?
  - គ្រូណែនាំកុមារបន្ថែមទៀតៈ នៅពេលថ្នាក់រៀនយើងមានសម្ភារល្បែងតិចលេងមិនគ្រប់គ្នាកូនត្រូវចេះ ចែកគ្នាលេងម្តងម្នាក់ៗ បើសម្ភារមានតែមួយ ហើយកូនចង់លេងផង មិត្តភក្តិកូនចង់លេងផង ដូច្នេះកូន ត្រូវឱ្យមិត្តភក្តិកូនលេងសិន។ ហើយកូនទៅលេងសម្ភារផ្សេង ពេលមិត្តភក្តិកូនឈប់លេងកូនទៅលេង ម្តងវិញ។ចំពោះនំចំណីក៏ដូចគ្នាដែរ បើមិត្តភក្តិយើងណាម្នាក់គ្មាននំញ៉ាំកូនត្រូវចេះចែករំលែកឱ្យមិត្តភក្តិ បានញ៉ាំផង។
* គ្រូប្រាប់ពីសកម្មភាពដែលត្រូវរៀនក្នុងមួយព្រឹក រួចឱ្យកុមារថាតាម(ជាក្រុម រួចទាំងអស់គ្នា)។

ម៉ោងទី៣ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ ភាសាខ្មែរ

## សន្ទនា៖ អំពីព្រឹត្តិការណ៍ផ្សេងៗដែលបានជួបប្រាប់មិត្តភក្តិ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីព្រឹត្តិការណ៍ផ្សេងៗ ដែលខ្លួនបានជួប ប្រាប់មិត្តភក្តិបានបានត្រឹមត្រូវ
- កុមារកំណត់ពីសកម្មភាពសំខាន់ៗ នៅក្នុងព្រឹត្តិការណ៍នីមួយៗ ដែលបានជួប បានត្រឹមត្រូវ
- កុមារមានភាពក្លាហាន សហការ រីករាយ ។

**២. សម្ភារបង្រៀន៖** កន្ទេល

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាអក្សរ "ប" បែងចែកកុមារជា៣ក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសរសេរចំណងជើងលើក្តារខៀនរួចនាំកុមារអាន «**ព្រឹត្តិការណ៍ផ្សេងៗ ដែលបានជួបប្រាប់មិត្តភក្តិ**»
- គ្រូសួរសំណួរបំផុសថា៖តើប៉ុន្មានថ្ងៃនេះ កូនបានជួប រឿង អ្វីមួយដែឬទេ ?តើកូនអាចរៀបរាប់រឿងដែលបានជួបនោះប្រាប់មិត្តភក្តិយើងបានដែរឺទេ ? តើរឿងទាំងនោះគេហៅថាអ្វី ?
- គ្រូឱ្យកុមារ ២ទៅ៣នាក់រៀបរាប់ពីអ្វីដែលគេបានជួប
- គ្រូប្រាប់កុមារថា "បន្តិចទៀត គ្រូចង់ឱ្យកូនទាំងអស់និយាយគ្នាជាក្រុម ពីព្រឹត្តិការណ៍ដែលកូនបានជួបប្រាប់គ្នាទៅវិញទៅមក"
- គ្រូបែងចែកកុមារជា៣ក្រុម ដោយឱ្យកុមារអង្គុយបត់ជើងលើកន្ទេលជារាងរង្វង់ក្នុងក្រុមនីមួយៗ មានសមាជិក ៦នាក់ រហូតអស់កុមារ
- គ្រូឱ្យកុមារចាប់ផ្តើមនិយាយប្រាប់សមាជិកក្នុងក្រុមម្នាក់ម្តងៗពីព្រឹត្តិការណ៍ដែលបានជួបតាមការចងចាំដោយកំណត់ពេលវេលាសន្ទនាច្បាស់លាស់
- គ្រូដើរសម្របសម្រួលការអនុវត្តសកម្មភាពតាមក្រុម ដោយកែតម្រូវការសន្ទនា
- គ្រូហៅតំណាងក្រុម ១នាក់ក្នុងមួយក្រុម មកនិយាយប្រាប់ពីព្រឹត្តិការណ៍ដែលពួកគេបានជួបប្រាប់ដល់គ្រូនិងមិត្តរួមថ្នាក់
- គ្រូជួយសម្របសម្រួលការនិយាយរបស់តំណាងក្រុមនីមួយៗបន្ទាប់មកត្រូវនិយាយបន្ថែម "ដូច្នេះនៅពេលកូនជួបព្រឹត្តិការណ៍អ្វីមួយ ដែលបង្កគ្រោះថ្នាក់ដល់កូន ត្រូវតែរត់មករកមនុស្សចាស់ ណាដែលកូនស្គាល់ហើយនៅជិតកូនបំផុតដើម្បីស្វែងរកជំនួយទាន់ពេលវេលា"
- គ្រូលើកសរសើរ កុមារទាំងអស់ដែលបានចូលរួមសន្ទនា ដោយរីករាយសហការ
- **គ្រូសួរកុមារ៖** តើថ្ងៃនេះកូនរៀនជាមុខវិជ្ជាអ្វី ?មេរៀនអ្វី ?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ មេរៀនសន្ទនា៖ អំពីព្រឹត្តិការណ៍ផ្សេងៗដែលបានជួបប្រាប់មិត្តភក្តិ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ទាំងអស់គ្នា

ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ សិក្សាសង្គម

## ល្បែងៈ ផ្ទុផ្ទងសំឡេង

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីរបៀបផ្ទុផ្ទងសំឡេង បានត្រឹមត្រូវ
- កុមារផ្ទុផ្ទងសំឡេង បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន សហការ ជួយគ្នាក្នុងការអនុវត្តការងារក្រុមបានត្រឹមត្រូវ ។

**២. សម្ភារបង្រៀនៈ** កែវចំនួន២ ចង្កឹះ២ដើម ក្រដាស២សន្លឹក បន្ទះឬស្សី ចំនួន៤ និងដុំឈើចំនួន៤ (២កំប្លេរ)

**៣. ការរៀបចំកុមារៈ** អង្គុយជារាងពាក់កណ្ដាលរង្វង់ អង្គុយតាមក្រុមតូចៗ  អង្គុយបែរខ្នងដាក់គ្នា

**៤. ដំណើរការបង្រៀន**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញសម្ភារមានកែវ ក្រដាស  បន្ទះឫស្សី ដុំឈើ រួចឱ្យកុមារប្រាប់ពីឈ្មោះសម្ភារទាំងនោះ
- គ្រូចែកកុមារជាពីរក្រុមគឺក្រុម "ក" និងក្រុម "ខ" ហើយមានសម្ភារដូចៗគ្នា ទាំង២ក្រុម
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនទាំងអស់គ្នាលេងជាក្រុម ហើយក្នុងមួយក្រុមៗ កូនត្រូវបានសម្ភារទាំងអស់នេះចំនួនមួយកំប្លេ ដោយកូនត្រូវសង្កេតមើលសម្ភារទាំងនេះផង។ ពេលកូនលេង កូនត្រូវចេះចែកគ្នាលេង កុំដណ្ដើមគ្នា
  - កូនណាម្នាក់ក្នុងក្រុម "ក"ត្រូវយកចង្កឹះមកគោះកែវ ឱ្យចេញជាសំឡេង រីឯក្រុមម្ខាងទៀត ក្រុម "ខ" ត្រូវយកសម្ភារណាមកធ្វើឱ្យចេញជាសំឡេងដូចក្រុម "ក" ដែរ
  - បន្ទាប់មកកូនក្នុងក្រុម "ក" យកក្រដាសមកហែកឱ្យចេញជាសំឡេង ឯក្រុមម្ខាងទៀតក្រុម "ខ" ត្រូវយកសម្ភារណាមកធ្វើឱ្យចេញជាសំឡេងដូចក្រុម "ក" ដែរ
  - កូនក្នុងក្រុម "ខ" ត្រូវយកបន្ទះឫស្សីមកគោះគ្នាឱ្យចេញជាសំឡេង ឯក្រុមម្ខាងទៀតក្រុម "ក" ត្រូវយកសម្ភារណាមកធ្វើឱ្យចេញជាសំឡេងដូចក្រុម "ខ" ដែរ
  - ចុងក្រោយ កូនក្នុងក្រុម "ខ" ត្រូវយកដុំឈើមកគោះគ្នាឱ្យចេញជាសំឡេង ឯក្រុមម្ខាងទៀតក្រុម "ក" ត្រូវយកសម្ភារណាមកធ្វើឱ្យចេញជាសំឡេងដូចក្រុម "ខ" ដែរ
- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្ដងទៀត)
- គ្រូចែកកុមារជា២ក្រុម រួចឱ្យទៅអង្គុយទល់មុខគ្នានៅតាមកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗ យកសម្ភារទៅអនុវត្ត
- គ្រូឱ្យកុមារចាប់ផ្ដើមអនុវត្តទៅតាមក្រុមនីមួយៗ ហើយគ្រូដើរសម្របសម្រួលកែតម្រូវ
- ពេលកុមារធ្វើសកម្មភាពម្ដង គ្រូនាំកុមារផ្ទៀងផ្ទាត់ម្ដង ដោយឱ្យកុមារក្នុងក្រុមធ្វើមុនជួយផ្ទៀងផ្ទាត់
- ពេលផ្ទៀងផ្ទាត់គ្រប់ក្រុមហើយ ត្រូវឱ្យតំណាងក្រុមនីមួយៗប្រមូលសម្ភារទៅទុកឱ្យគ្រូវិញ ហើយនាំគ្នាទៅអង្គុយជារួមក្រុមធំវិញ
- **គ្រូសួរកុមារៈ**
  - កូនៗទាំងអស់គ្នាសប្បាយទេ? តើមុននេះកូនៗបានលេងល្បែងអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាសិក្សាសង្គម អំពីមេរៀនល្បែង " ផ្ទុផ្ទងសំឡេង "
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៨ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ វិទ្យាសាស្ត្រ

## សង្កេត៖ បន្លែ "ត្រសក់"

**១. វត្ថុបំណង**

- កុមារប្រាប់បានពីឈ្មោះរបស់បន្លែ ផ្លែត្រសក់ ពណ៌បៃតង រាងមូលទ្រវែងបានត្រឹមត្រូវ
- កុមារកំណត់បានពីរាង ពណ៌ ហើយនិងរស់ជាតិរបស់ផ្លែត្រសក់បានត្រឹមត្រូវ
- កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់ សហការ ចូលរួមបានយ៉ាងសកម្ម និងសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** បន្លែ ផ្លែត្រសក់

**៣. រៀបចំកុមារ៖** រៀបចំកុមារជារាងអក្សរ អ៊ុយ អង្គុយជាក្រុមតូចៗ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនិទានរឿង៖ ថ្ងៃនេះគ្រូបានធ្វើដំណើរមកសាលារៀនស្រាប់តែមានតាម្នាក់នៅតាមផ្លូវហៅអ្នកគ្រូឱ្យឈប់ ហើយគាត់បានផ្ញើថង់មួយមកឱ្យគ្រូ ដើម្បីយកមកផ្ញើកូនៗទាំងអស់គ្នាព្រោះគាត់ថាកូនៗទាំងអស់គ្នាជាកូនល្អ។ប៉ុន្តែអ្នកគ្រូមិនដឹងថាខាងក្នុងនោះមានអ្វីទេ? ដូច្នេះកូនៗទាំងអស់គ្នាចង់ដឹងទេ ថាតើខាងក្នុងថង់មានអ្វីខ្លះ?កុមារឆ្លើយតាមគំនិតគេម្នាក់ៗ។
- គ្រូបង្ហាញថង់នោះហើយប្រាប់កុមារថាគ្រូនឹងឱ្យកូនៗទាំងអស់គ្នាបានស្ទាបគ្រប់ៗគ្នាពេលកូនស្ទាបកូនត្រូវគិតវាតើក្នុងថង់នេះមានអ្វី?
- គ្រូឱ្យកុមារម្នាក់ឡើងមកយកសម្ភារចេញពីក្នុងថង់ហើយបង្ហាញមិត្តភក្តិ រួចសួរកុមារដើម្បីផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ(តើអម្បាញ់មិញមានមិត្តភក្តិណាទាយត្រូវទេកូន?) ពេលមានកុមារទាយត្រូវឱ្យកុមារទាំងអស់ទះដៃសរសើរ
- គ្រូបញ្ជាក់ថានេះជាផ្លែត្រសក់រួចសួរកុមារតើផ្លែត្រសក់នេះជាបន្លែឬផ្លែឈើ? ហើយគ្រូយកមកឱ្យកូនធ្វើអ្វី?
- **គ្រូណែនាំកុមារពីរបៀបអនុវត្តតាមក្រុមនីមួយៗ**
    - គ្រូឱ្យកូនធ្វើជាក្រុមតូចៗ ហើយក្នុងក្រុមនីមួយៗត្រូវទទួលបានផ្លែត្រសក់៣ផ្លែក្នុងមួយក្រុម
    - ពេលក្រុមកូននីមួយៗបានផ្លែត្រសក់នេះហើយកូនៗត្រូវនាំគ្នាពិនិត្យមើលនៅផ្នែកខាងក្រៅមានអ្វីខ្លះ? ពេលកូនសង្កេតហើយប្រាប់គ្រូដើម្បីគ្រូពុះផ្លែត្រសក់ជា២ ហើយពួកកូននាំគ្នាមើលផ្នែកខាងក្នុងទៀតមានអ្វីខ្លះ?ពេលកូនពិភាក្សាគ្នាត្រូវចេះចែកគ្នាមើលនិងនិយាយហើយកូនត្រូវរកមិត្តភក្តិណាម្នាក់ដើម្បីនិយាយប្រាប់មិត្តភក្តិបាននិងគ្រូពីអ្វីដែលកូនបានឃើញ។

  +ពេលកូនធ្វើចប់គ្រប់ក្រុមហើយកូនៗនាំគ្នាទៅអង្គុយក្រុមធំវិញរួចប្រមូលសម្ភារទុក
- គ្រូឱ្យកុមារម្នាក់ឡើងនិយាយពីអ្វីដែលគ្រូបានប្រាប់បើសិននិយាយមិនបានគ្រប់ទេត្រូវឱ្យមិត្តភក្តិជួយបំពេញបន្ថែមប៉ុន្តែបើនៅតែនិយាយមិនបានពេញលេញទេគ្រូត្រូវនិយាយប្រាប់កុមារសាឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមឱ្យអង្គុយជារង្វង់តាមទីកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូឱ្យកុមារម្នាក់ក្នុងក្រុមនីមួយៗមកយកសម្ភារទៅនាំគ្នាអនុវត្តតាមការណែនាំ
- គ្រូដើរសម្របសម្រួលតាមក្រុមដោយជួយបំផុសគំនិតបន្ថែមចំពោះក្រុមខ្លះមិនទាន់យល់
- នៅពេលក្រុមនីមួយៗសង្កេតផ្នែកខាងក្រៅរួចហើយគ្រូត្រូវដើរពុះផ្លែត្រសក់ជាពីរ( ពុះបញ្ឈរ )ដើម្បីឱ្យពួកគេសង្កេតផ្នែកខាងក្នុងបន្តទៀត

- ពេលក្រុមនីមួយៗសង្កេតចប់ គ្រូឱ្យពួកគេទៅអង្គុយក្រុមធំវិញរួចប្រមូលសម្ភារទុក
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងមកនិយាយប្រាប់ពីលទ្ធផលដែលពួកគេបានជជែកគ្នា(ម្តងមួយក្រុម) ពេលកុមារនិយាយពាក្យមិនត្រឹមត្រូវ គ្រូត្រូវកែតម្រូវហើយនាំកុមារអានទាំងអស់គ្នា

**ឧទាហរណ៍៖** កុមារគ្រប់ក្រុមបានប្រាប់ផ្លែត្រសក់នៅផ្នែកខាងក្រៅមាន ទង រាងមូលទ្រវែង ពណ៌បៃតង ឯផ្នែកខាងក្នុងមានសាច់ពណ៌ស គ្រាប់តូចៗពណ៌ស ហើយទន់ៗ...)

- គ្រូសរុបពីលទ្ធផលរបស់កុមារទាំងអស់ដែលបានឡើងបង្ហាញ។ ពេលគ្រូសរុបត្រូវគិតមើលតើក្រុមទាំងអស់នៅមិនទាន់ស្គាល់អ្វីខ្លះ?ដូច្នេះត្រូវផ្តល់ចំណេះដឹងថ្មីឱ្យកុមារទៀត។ (ឧទាហរណ៍ ៖ កុមារមិនទាន់ប្រាប់ពីសំបក ពេលពុះទៅមានជ័រ ផលប្រយោជន៍និងការជួយថែទាំពេលឪពុកម្តាយដាំជាដើម)
- គ្រូត្រូវបំផុសសំណួរដើម្បីផ្តល់ចំណេះដឹងបន្ថែម
  - នៅពេលម្តាយកូនយកផ្លែត្រសក់មកស្ល តើកូនសង្កេតឃើញគាត់ធ្វើដូចម្តេច?
  - ពេលគ្រូពុះផ្លែត្រសក់ជាពីរ តើកូនសង្កេតឃើញមានអ្វីសើមៗហើយស្អិតៗ
  - តើផ្លែត្រសក់មានប្រយោជន៍អ្វីខ្លះ?
  - ពេលឪពុកម្តាយកូនដាំត្រសក់ តើកូនអាចជួយអ្វីបានខ្លះ?
  - គ្រូត្រូវប្រាប់កុមារពេលឆ្លើយមិនបាននៅសំណួរណាមួយនោះ?
  - គ្រូនាំកុមារអានពាក្យខ្លះៗដែលពិបាក
  - គ្រូសួរកុមារ៖ អម្បាញ់មិញកូនស្គាល់ពីអ្វី?ដូច្នេះថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រអំពីសង្កេតផ្លែត្រសក់
  - គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន(ជាក្រុមនិងអានទាំងអស់គ្នា)។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

**✱ ល្បែងសេរី ៖**

- **រំលឹកមេរៀន (ដែលបានរៀនរយៈពេលមួយព្រឹក)**
- **អនាម័យទៅផ្ទះ**

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបលេងល្បែងទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេបានត្រឹមត្រូវ
- កុមារជ្រើសរើសល្បែងលេងទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេបានត្រឹមត្រូវ
- កុមារ សប្បាយរីករាយ សហការគ្នាក្នុងការលេងមានចិត្តអំណត់។

**២. ការរៀបចំសម្ភារ៖** សម្ភារមាននៅតាមជ្រុងថ្នាក់រៀននិងក្រៅថ្នាក់

**៣. ការរៀបចំកុមារ៖**

- កុមារអង្គុយជាអក្សរអ៊ុយ "U" និងក្រុមតូច
- កុមារអង្គុយទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេម្នាក់ៗក្នុងថ្នាក់និងក្រៅថ្នាក់

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរកុមារ៖ កូនទាំងអស់គ្នាចង់លេងល្បែងឬទេ? បើកូនចង់លេង តើកូននាំគ្នាលេងល្បែងអ្វីខ្លះ?

ដូច្នេះគ្រូនឹងឱ្យកូនទាំងអស់គ្នាលេងទៅតាមចំណង់ចំណូលចិត្តរបស់កូន។
- គ្រូប្រាប់កុមារៈ ថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជាសិក្សាសង្គម អំពីល្បែងសេរី
- គ្រូឱ្យកុមារអានមុខវិជ្ជានិងចំណងជើងមេរៀនជាក្រុមនិងទាំងអងស់គ្នា
- គ្រូបង្ហាញសម្ភារល្បែងដែលមាននៅតាមជ្រុងឱ្យកុមារដឹងពីទីកន្លែងដែលកុមារត្រូវនាំគ្នាយកមកលេង
- **គ្រូណែនាំកុមារមុនពេលលេងៈ**
  - គ្រូឱ្យកុមារទាំងអស់គ្នាយកសម្ភារដែលមាននៅក្នុងថ្នាក់រៀនលេងទៅតាមចំណង់ចំណូលចិត្តរបស់កូន៩ោធើ។ម្នាក់ៗ ឬកូនអាចទៅលេងល្បែងនៅក្រៅថ្នាក់ក៏បាន
  - ពេលកូនយកសម្ភារទាំងនោះមកលេង កូនត្រូវចេះថែរក្សាសម្ភារទាំងនោះ ហើយពេលឈប់លេង កូនត្រូវមើលសម្ភារនោះឱ្យបានគ្រប់ចំនួនមិនឱ្យបាត់បង់ ទើបយកទៅទុកឱ្យមានសណ្ដាប់ធ្នាប់នៅកន្លែងដើមវិញ
  - ពេលលេងកូនអាចលេងម្នាក់ឯងក៏បាន កូនអាចលេងជាមួយមិត្តភក្តិក៏បាន អាស្រ័យទៅតាមចិត្តរបស់កូន។ បើកូនលេងជាមួយមិត្តភក្តិ កូនត្រូវចេះចែកគ្នាលេងកុំដណ្តើមគ្នា កុំស្រែកឡូឡា ទើបជាកូនល្អ
  - ចំពោះទីកន្លែងដែលពួកកូនត្រូវលេងនោះអាចលេងនៅក្នុងថ្នាក់ក៏បាន លេងនៅក្រៅថ្នាក់ក៏បាន ស្រេចតែ ចិត្តពួកកូន។ បើកូនណាចង់លេងស្ពូរ ឬគោះកំប៉ុង កូនត្រូវលេងឱ្យឆ្ងាយពីមិត្តភក្តិ កុំឱ្យរំខានមិត្តភក្តិ
  - បើមានកូនណាមិនសូវចេះលេង ឬមិនចូលលេងនឹងគេនោះ កូនៗត្រូវជួយប្រាប់មិត្តភក្តិ និងនាំមិត្តភក្តិ លេងផង
  - ពេលកូនឈប់លេង កូនត្រូវនាំគ្នាយកសម្ភារទៅទុកកន្លែងដើម រួចនាំគ្នាមកអង្គុយនៅក្រុមធំវិញ
  - គ្រូឱ្យកុមារស្ម័គ្រចិត្តមួយនាក់ និយាយពីអ្វីដែលគ្រូបានប្រាប់។ គ្រូត្រូវបំពេញបន្ថែមនូវអ្វីដែលកុមារនិយាយមិនបានពេញលេញ
- គ្រូឱ្យកុមារលើកកៅអីទុកទៅខាង ម្តងមួយក្រុមៗរួចនាំគ្នាទៅយកសម្ភារមកលេង
- គ្រូឱ្យកុមារលេងតាមចំណង់ចំណូលចិត្តរបស់ពួកគេ
- គ្រូដើរសម្របសម្រួលកុមារលេង ដើម្បីកែតម្រូវកុមារលេងខុស និងជួយកុមារណាដែលមិនទាន់ចេះលេង
- ពេលកុមារលេងចប់គ្រូឱ្យកុមារយកសម្ភារទៅទុកដាក់ឱ្យមានសណ្ដាប់ធ្នាប់នៅតាមកន្លែងដើម រួចឱ្យពួកគេ យកកៅអីមករៀបអង្គុយវិញ
- ពេលកុមារអង្គុយជុំគ្នា គ្រូឱ្យកុមារនិយាយប្រាប់ពីអ្វីដែលគេបានលេង និងបានស្គាល់ ( ឱ្យកុមារនិយាយទៅតាមការយល់ដឹងរបស់គេ)។ ចំពោះចំនួនកុមារដែលត្រូវនិយាយអាស្រ័យទៅតាមពេលវេលា។

∗ **រំលឹកមេរៀនប្រចាំថ្ងៃៈ** គ្រូសួរកុមារពីមេរៀនដែលបានរៀនក្នុងមួយព្រឹក ក្នុងករណីកុមារមិនអាចប្រាប់បានគ្រប់ គ្រូត្រូវប្រាប់បន្ថែម រួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា។

∗ អនាម័យរៀបចំខ្លួនទៅផ្ទះៈ គ្រូឱ្យកុមារលាងដៃ លុបមុខ សិតសក់ឱ្យស្អាតរួចរៀបចំកៅអីទុក និងតម្រង់ជួរទៅតាមក្រុម គ្រូណែនាំសណ្ដាប់ធ្នាប់ពេលដើរតាមផ្លូវ ការគួសមជាមួយមនុស្សពេលទៅដល់ផ្ទះ ការទុកដាក់សម្ភារ សកម្មភាពមុន និងក្រោយពេលញ៉ាំបាយ ...។

# ថ្ងៃទី២

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

## ហាត់ប្រាណតាមបទចម្រៀងៈ ពេលសប្បាយ

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីចលនាដើរ លោតទៅមុខជាចង្វាក់តាមបទចម្រៀងបានត្រឹមត្រូវ
- កុមារច្រៀងនិងធ្វើចលនាដើរ លោតទៅមុខជាចង្វាក់តាមបទចម្រៀងបានត្រឹមត្រូវ
- កុមារស្រឡាញ់ចូលចិត្តច្រៀង មានភាពក្លាហាន ស្វាហាប់ ដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** កុមារឈរជាជួរ និងរង្វង់

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជារង្វង់ ហើយគ្រូឈរចំកណ្ដាល
- គ្រូនាំកុមារធ្វើចលនាត្រាប់តាមសត្វហើរ កុមារលាតដៃទាំងពីរទៅសងខាង ហើយធ្វើចលនាដូចសត្វហើរទៅមុខរេទៅឆ្វេង រេទៅស្ដាំ ហើយថយក្រោយ (១ឬ២ដង)
- គ្រូច្រៀងឱ្យកុមារស្ដាប់ និងធ្វើចលនាឱ្យកុមារមើលតាមបទចម្រៀងរហូត១ចប់
- គ្រូនាំកុមារច្រៀងនិងធ្វើចលនាតាមបទចម្រៀងទាំងអស់គ្នាអាស្រ័យតាមពេលវេលា(២ឬ៣ចប់)
- ថ្ងៃនេះកូនរៀនមុខវិជ្ជាចិត្តចលភាពអំពី ហាត់ប្រាណតាមបទចម្រៀង ចំណងជើង "ពេលសប្បាយ" គ្រូឱ្យកុមារថាតាម១នាក់ ២នាក់តាមក្រុម
- គ្រូនាំកុមារទាំងអស់មកឈរជារង្វង់រួចសួរថាកូនៗ ហត់ទេ?ដើម្បីឱ្យមានកម្លាំងកូនត្រូវធ្វើដូចម្ដេច? តើផ្កាអ្វីដែលក្រអូបជាងគេ? (ផ្កាម្លិះ) ដើមទាបឬខ្ពស់ អញ្ចឹងកូនយកដៃអោនបេះផ្កាទាំងអស់គ្នាបេះបាន ហើយឬនៅកូនៗ បើបានហើយកូនលើកផ្កាហិតទាំងអស់គ្នា ហើយស្រូបដង្ហើមចូលចេញវែងៗ (ក្រអូប ណាស់២ទៅ៣ដង)

**របៀបធ្វើចលនា**

- ច្រៀងមួយចប់បទចម្រៀងលើកទី១ៈ កុមារដើរ ជាចង្វាក់ដោយដៃបង់បោយដើរទៅមុខ ដល់យើងត្រូវទះដៃ ត្រូវឈប់ហើយលោតទះដៃ ២ដង
- ច្រៀងមួយចប់បទចម្រៀងលើកទី២ៈ កុមារបង់បោយដើរចំហៀងខ្លួនម្ដងទៅឆ្វេង ម្ដងទៅស្ដាំ (ពេលបង្រៀនម៉ោងបន្តបន្ទាប់អាចប្ដូរមកទះភ្លៅ ឬគោះជើង)

អត្ថបទចម្រៀង «**ពេលសប្បាយ**»

| | | |
|---|---|---|
| -ពេលសប្បាយ | ពេលយើងរីករាយ | យើងត្រូវទះដៃ(ទះដៃ២ដង) |
| -ពេលសប្បាយ | ពេលយើងរីករាយ | យើងត្រូវទះដៃ(ទះដៃ២ដង) |
| -ពេលសប្បាយ | ពេលយើងរីករាយ | យើងត្រូវទះដៃ |
| -យើងត្រូវទះដៃ | មិត្តរាល់គ្នា | បើមិនសប្បាយក៏ត្រូវទះដៃ(ទះដៃ២ដង) |

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈសិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អៈ ត្រូវចេះចែករំលែកសម្ភារនិងនំចំណីឱ្យមិត្តភក្តិ (ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី២ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ បុរេគណិត

## សម្គាល់ៈ ចំនួននិងលេខពី ១ ដល់ ១០

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីចំនួននិងលេខពី ១ ដល់១០ បានត្រឹមត្រូវ
- កុមាររាប់ចំនួននិងលេខពី ១ ដល់១០ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារឈ្លាសវៃ រហ័សរហួន ក្នុងការគិតបានហ្មត់ចត់ សហការគ្នាដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ**

- បណ្ណចំនួនរូបភាពពី១ ដល់១០ ចំនួន ១០ បន្ទះ
- បណ្ណចំនួនចំណុចពី១ ដល់១០ ចំនួន១០ បន្ទះ
- បណ្ណលេខ១ ដល់លេខ១០ ចំនួន ១០ បន្ទះ
- ស្កុតក្រដាស់ ១ដុំ

**៣. ការរៀបចំកុមារៈ** អង្គុយជាអក្សរអ៊ុយ "ប" និងក្រុមតូច

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំណួរៈ ពេលគ្រូធ្វើដំណើរមកតាមផ្លូវរើសបានសំបកងៀវមួយថង់ តើកូនណាម្នាក់ឡើងរាប់ឱ្យមិត្តភក្តិយើងមើល? ឱ្យកុមារឡើងរាប់សំបកងៀវបង្ហាញមិត្តក្នុងថ្នាក់
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងៈ ថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជា បុរេគណិត មេរៀន **សម្គាល់ចំនួន និងលេខពី ១ ដល់ ១០**
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើង ២ទៅ ៣ដង តាមក្រុមនិងទាំងអស់គ្នា
- ថ្ងៃនេះគ្រូមានសម្ភារជាច្រើន កូនចង់លេងទេ?
- គ្រូបង្ហាញបណ្ណចំនួនរូបភាពពី១ ដល់១០ ឱ្យកុមារប្រាប់ចំនួនរូបភាពនៅក្នុងបណ្ណនីមួយៗ រួចយកទៅបិទនៅលើក្តាខៀន រួចនាំកុមាររាប់
- គ្រូបង្ហាញបណ្ណចំនួនចំណុចពី១ ដល់១០ ឱ្យកុមារប្រាប់ពីចំនួនចំណុចនៅក្នុងបណ្ណនីមួយៗ រួចយកទៅបិទនៅលើក្តាខៀនពីក្រោមចំនួនរូបភាព រួចនាំកុមាររាប់
- គ្រូបង្ហាញបណ្ណលេខពី១ ដល់១០ ឱ្យកុមារប្រាប់ពីលេខនោះ រួចយកទៅបិទនៅលើក្តាខៀនពីក្រោមចំនួន ចំណុចពី ១ដល់១០ រួចនាំកុមាររាប់

- គ្រូនាំកុមាររាប់ចំនួនរូបភាព ចំនួនចំណុចនិងលេខពី១ ដល់១០ សាឡើងវិញម្តងមួយៗ។ គ្រូណែនាំកុមារជាមុនសិន រួចឱ្យក្រុមនីមួយៗទៅជ្រុងសិក្សា ដើម្បីរើសវត្ថុដែលមាននៅក្នុងជ្រុងនោះ (តាមវត្ថុជាក់ស្តែងដែលមានដូចជាបំពង់បឺត ចង្កឹះ ដុំឈើ...)
-គ្រូឱ្យកុមារក្រុមទី១ រើសវត្ថុចំនួន ៨
-គ្រូឱ្យកុមារក្រុមទី២ រើសវត្ថុចំនួន ៩
-គ្រូឱ្យកុមារក្រុមទី៣ រើសវត្ថុចំនួន១០
+គ្រូឱ្យកុមារបង្ហាញតាមក្រុមនីមួយៗ និងសម្របសម្រួលផ្ទៀងផ្ទាត់។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## រឿងនិទាន៖ ទីណូស្រួចនិងផ្លែត្រសក់ (និទាន)

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីសកម្មភាពតួអង្គតាមដំណើររឿង បានត្រឹមត្រូវ
- កុមារនិទានរឿងនិងវិភាគតួអង្គនៅក្នុងរឿងបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ យកគំរូតាមតួអង្គល្អ សហការជួយគ្នា និទានរឿងឱ្យមិត្តភក្តិស្តាប់ ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាបណ្តុំ ជាជួរ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំណួរ៖ តើប៉ាម៉ាក់កូនធ្លាប់ដាំដំណាំអ្វីខ្លះ ? តើកូនចូលចិត្តញ៉ាំបន្លែទាំងនេះទេ? តើថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអំពីអ្វី? គ្រូសរុបចម្លើយរបស់កុមារ
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជា សិក្សាសង្គម ចំណងជើងរឿងនិទាន «**ទីណូស្រួចនិងផ្លែត្រសក់** »
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដោយសួរកុមារថា៖ មុននេះមានកូនណាឆ្លើយដូចចម្លើយអ្នកគ្រូដែរឬទេ? ដូច្នេះកូនទះដៃសរសើរមិត្តភក្តិយើងដែលបានទាយត្រូវទាំងអស់គ្នា
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
- គ្រូប្រាប់ឈ្មោះអ្នកនិពន្ធ៖ រឿងនិទាននេះនិពន្ធដោយអ៊ុំៗអង្គការCYK ឱ្យកុមារថាតាម
- គ្រូនិទានរឿងផ្ទាល់មាត់ឱ្យកុមារស្តាប់ ដោយលើកដាក់សំឡេងតាមតួអង្គនៃសាច់រឿង
- គ្រូនាំកុមារអានពាក្យពិបាក ជាក្រុម និងទាំងអស់គ្នា៖
  - លួច៖ លបយកអ្វីមួយរបស់អ្នកដទៃ
  - វាវ ៖ លូនដោយប្រវា , បោះទង
- គ្រូសួរកុមារ៖ក្រោយពីស្តាប់រឿងនេះចប់ តើក្នុងរឿងមានតួអង្គប៉ុន្មាន? តួអង្គណាខ្លះ? តើស្រួចនិងទីណូនាំគ្នាទៅណា? ពួកគេបានធ្វើអ្វីខ្លះ? តើលោកតាបានណែនាំអ្នកទាំងពីរឱ្យធ្វើអ្វីខ្លះ? តើកូនគួរយកតម្រាប់តាមតួអង្គណា? (កុមារឆ្លើយតបសំណួរគ្រូទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូសង្ខេបរឿងឱ្យកុមារស្តាប់ឡើងវិញម្តងទៀត
- គ្រូឱ្យកុមារនិយាយសង្ខេបរឿងឡើងវិញឱ្យមិត្តភក្តិស្តាប់ (កុមារនិយាយពីអ្វីដែលគេបានចងចាំប្រសិនបើកុមារនិទានមិនទាន់បានពេញលេញ ឱ្យមិត្តភក្តិជួយបំពេញគ្រូសម្របសម្រួលបន្ថែម)

## អត្ថបទរឿង«ទីណូស្រួចនិងផ្លែត្រសក់»

ថ្ងៃនេះជាថ្ងៃអាទិត្យ ស្រួចកូនកណ្តុរនឹកចង់ដើរលេងកំសាន្តឯចំការ។ ស្រួចចេញពីផ្ទះពីព្រលឹមទៅបបួលទីណូ។ទីណូទាញយកមួកហាមធំមកពាក់ រួចដើរចេញទៅជាមួយស្រួច។ទីណូសួរថា៖"យើងនាំគ្នាទៅលេងឯណា?" ស្រួចឆ្លើយ៖"យើងនាំគ្នាទៅលេងឯចំការ"។ ខ្ញុំឮថាចំការ លោកតាអែម មានដាំល្ពៅ ឪឡឹក ត្រឡាច ត្រសក់ ច្រើនណាស់។ មកយើងទៅចំការលោកតាអែមរកត្រសក់ហូប។ ទីណូនិងស្រួចកាន់ដៃគ្នា ដើរបណ្តើរ ច្រៀងបណ្តើរ៖ "ចំការយើងស្រស់បំព្រង ត្រសក់ ដំឡូង ឪឡឹក ត្រឡាចចេញផ្កាមានផ្លែបាចសាច(ពីរដង) ល្ពៅ ត្រឡាចវារគងលើគ្នា។ យើងដាំ !យើងដាំ!យើងដាំ!យើងដាំ!យើងដាំ!យើងដាំ ច្រៀងចប់ស្រួចនិយាយ៖"ដល់ចំការតាអែមហើយតែមិនឃើញគាត់សោះ ទីណូឯងជួយស្រែកហៅគាត់មើល" ទីណូស្រែកហៅ៖ "លោកតា!លោកតា! លោកតានៅឯណា?" គ្មានសំឡេងអ្វីឆ្លើយសោះ។ ស្រួចក្រឡេកឃើញត្រសក់ធំៗខ្លួតៗគួរឱ្យស្រក់ទឹកមាត់។ ស្រួចចង់បេះត្រសក់ហូបក៏និយាយ៖"រកតាមិនឃើញអញ្ចឹងហើយបេះត្រសក់នេះហូបទៅ! មក!យើងបេះហូប"។ ទីណូចាប់ដៃស្រួចមិនឱ្យបេះរួចនិយាយថា៖ ឈប់!កុំអាលបេះ មិត្តឯងបេះមិនបានប្រាប់ម្ចាស់គេអញ្ចឹងគឺលួចគេហើយ។ យើងដើរទៅចុងចំការខាងនោះរកលោកតាម្តងទៀតសិន។ និយាយចប់ ទីណូអូសដៃមិត្តស្រួចដើរសំដៅចុងចំការ ហើយក៏បានជួបលោកតាអែមនៅទីនោះ។ តាអែមសួរថា៖ "អើចៅទាំងពីរមកចំការតាធ្វើអ្វីហ្នឹង ហ្អា? " ទីណូនិងស្រួចឆ្លើយ៖"ខ្ញុំមករកត្រសក់លោកតាហូប តែមិនឃើញលោកតា ខ្ញុំមិនហ៊ានបេះ"។ លោកតាអែមឆ្លើយ៖ " អើល្អហើយចៅ! កុំយករបស់គេមិនបានប្រាប់ម្ចាស់គេណា គេថាយើងចោរណាចៅ! ហ្ន! បេះទៅ ចង់ហូបអីបេះហូបទៅចៅ តែចៅទាំងពីរដើរឱ្យល្អណាប្រយ័ត្នដើរជាន់ដើមត្រសក់"។ ទីណូនិងស្រួចបេះត្រសក់ហូបបណ្តើរច្រៀងជូនលោកតាស្តាប់បណ្តើរនូវបទ "ចំការយើង"។

ចំការយើងស្រស់បំព្រង ត្រសក់ ដំឡូង ឪឡឹក ត្រឡាចចេញផ្កាបោះផ្លែបាចសាច(ពីរដង)។ ល្ពៅត្រឡាច វារគងលើគ្នា។ យើងដាំ យើងដាំ ! យើងដាំ យើងដាំ ៗៗ ។ ទីណូនិងស្រួចហូបត្រសក់ឆ្អែត អរគុណនិងលាលោកតា ហើយត្រឡប់ទៅផ្ទះវិញយ៉ាងសប្បាយចិត្ត។

ម៉ោងទី៩ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

## សម្គាល់តួអក្សរ៖ "ញ"

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរូបរាង និងឈ្មោះតួអក្សរ "ញ" បានត្រឹមត្រូវ
- កុមារកំណត់បានពីរូបរាងឈ្មោះតួអក្សរ "ញ" និងរកពាក្យថ្មីផ្តើមចេញពីតួអក្សរ "ញ" បានត្រឹមត្រូវ
- កុមារក្លាហាននិងយកចិត្តទុកដាក់ ព្យាយាមក្នុងការរកពាក្យថ្មីផ្តើមពីតួអក្សរ "ញ"ដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖**

- ផ្ទាំងរូបភាព ញញួរ ញាស់ ញាំ
- បណ្ណពាក្យ ញញួរ ញាស់ ញាំ និងល្បះ មីងញឹបញញឹមញញែម
- ប៊ិក ហ្វឺត ស្កុត (កាត់រៀបចំឱ្យហើយ)

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរ អ៊ុយ "U"

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

+ **រកពាក្យ និងឃ្លា**

- គ្រូបង្ហាញផ្ទាំងរូបភាព "ញញួរ" ដោយបិទបាំងបញ្ចេញខាងលើបន្តិច ខាងក្រោមបន្តិច ខាងឆ្វេងបន្តិច ខាងស្តាំបន្តិច រួចឱ្យកុមារទាយ
- បើករូបបង្ហាញ ដើម្បីផ្ទៀងផ្ទាត់ចម្លើយ (បើមានកុមារឆ្លើយត្រូវ សរសើរលើកទឹកចិត្ត ហើយយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចបង្ហាញបណ្ណពាក្យ "ញញួរ" បិទពីក្រោមរូប រួចនាំកុមារអានទាំងរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញរូបភាព"**ញាស់**" ដោយរលាស់មួយភ្លែតឱ្យកុមារឃើញ ហើយឱ្យកុមារទាយ បន្ទាប់មកគ្រូបង្ហាញរូបដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចបង្ហាញបណ្ណពាក្យ "**ញាស់**" ហើយបិទពីក្រោមរូប និងនាំកុមារអានរូប និងពាក្យដោយគ្រូអានផងចង្អុលផង
- គ្រូឱ្យកុមារ១នាក់ចេញទៅក្រៅថ្នាក់ ហើយមើលផ្ទាំងរូបភាព "**ញាំុ**" រួចហើយឱ្យចូលថ្នាក់វិញ ហើយខ្សឹបពាក្យ "**ញាំុ**" បន្តគ្នាឱ្យបាន ៥នាក់។ ខ្សឹបដល់អ្នកទី៥ ត្រូវឱ្យអ្នកទី៥ និយាយប្រាប់មិត្តភក្តិឮពាក្យអ្វី? រួចសួរអ្នកទី១វិញ ត្រឹមត្រូវឬទេ? បន្ទាប់មក គ្រូបង្ហាញរូបភាព "**ញាំុ**" ដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវ សរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន ហើយបង្ហាញបណ្ណពាក្យ "**ញាំុ**" និងបិទពីក្រោមរូបភាព និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញឃ្លា "**មីងញឹបញញឹមញញែម**" អានឱ្យកុមារស្តាប់រួចយកបិទពីក្រោមពាក្យ
- នាំកុមារអានរូប ពាក្យ និងឃ្លា (២ដង) គ្រូនាំកុមារអានផង និងចង្អុលផង។

+ **ស្តាប់សូរពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារស្តាប់ (២ឬ៣ចប់) ដើម្បីឱ្យកុមារទាយសូរ និងញែកសូរនៃពាក្យ និងឃ្លា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- គ្រូសួរកុមារ តើពាក្យ និងឃ្លាដែលគ្រូបានអានអម្បាញ់មិញឮសូរដូចម្តេច? (ពេលកុមារឆ្លើយ គ្រូមិនបាច់វាយតម្លៃត្រូវឬខុសទេ)។

+ **ពិនិត្យរូបរាងអក្សរនៅក្នុងពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារសង្កេត (២ឬ៣ចប់) ដើម្បីឱ្យកុមារពិនិត្យរករូបរាងតួអក្សរដែលមានរាងដូចគ្នាច្រើន (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- គ្រូឱ្យកុមារដែលស្ម័គ្រចិត្តឡើងមកគូសវង់ជុំវិញតួអក្សរដែលមានរាងដូចគ្នាច្រើន (ពេលកុមារឡើងមកគូសជុំវង់វិញអក្សរមានរាងដូចគ្នាច្រើន បើកុមារចង់គូសប៉ុណ្ណាឱ្យគេគូសតាមចិត្តរបស់គេ គ្រូមិនត្រូវបញ្ឈប់ឬបង្ខំគេឡើយ)
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលទាំងអស់គ្នា បើមានកុមារគូសវង់ខុសត្រូវឱ្យកុមារដទៃជួយកែតម្រូវ។ នាំកុមាររាប់ចំនួនអក្សរដែលកុមារគូសវង់ដើម្បីផ្ទៀងផ្ទាត់ពីចំនួនច្រើន។

+ **ប្រាប់ឈ្មោះតួអក្សរ៖**

- គ្រូសួរកុមារ តើតួអក្សរដែលកូនគូសវង់ជុំវិញនៅក្នុងពាក្យ និងឃ្លានោះឈ្មោះអក្សរអ្វី? បើកុមារឆ្លើយមិនត្រូវទេនោះ គ្រូត្រូវប្រាប់រួចនាំកុមារអាន (ក្រុម រួចទាំងអស់គ្នា)

- គ្រូបង្ហាញអក្សរចល័ត "ញ" រួចសួរកុមារ អក្សរដែលគ្រូបង្ហាញនេះរាងដូចអក្សរដែលកូនបានគូសវង់នោះឬទេ? បើដូច ឈ្មោះអក្សរអ្វី?
- គ្រូសរសេរអក្សរ "ញ" យ៉ាងធំនៅជ្រុងក្តារខៀន ដើម្បីឱ្យកុមារសង្កេតពីទិសនៃសំណេរ
-គ្រូសួរកុមារ អក្សរដែលគ្រូសរសេរនេះតើដូចអក្សរដែលគ្រូបង្ហាញនេះដូចអក្សរដែលកូនបានគូសវង់ឬទេ? ឈ្មោះអក្សរអ្វី?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនអក្សរ "ញ" នាំកុមារអានអក្សរ"ញ"(ក្រុម រួចទាំងអស់គ្នា) ឱ្យបាន២ឬ៣ដង
- គ្រូសរសេរចំណងជើងមេរៀនលើក្តារខៀន រួចនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន (ក្រុមរួចទាំងអស់គ្នា)

**+ ប្រៀបធៀបអក្សរស្រដៀងគ្នា៖**

- គ្រូសរសេរអក្សរ "ញ ព ធ" នៅលើក្តារខៀន
- គ្រូអានអក្សរ "ញ ព ធ" ឱ្យកុមារស្តាប់ និងសង្កេត
-គ្រូសួរកុមារ តើអក្សរទាំងអស់នេះមានលក្ខណៈដូចគ្នានៅត្រង់ណាខ្លះ? ហើយខុសគ្នាត្រង់ណាខ្លះ?
- កុមារនិយាយប្រាប់ផងឡើងមកចង្អុលផង។

**+ រកពាក្យថ្មីផ្តើមពីអក្សរ "ញ" ៖**

- គ្រូអានពាក្យ និងឃ្លាសាឡើងវិញឱ្យបានច្រើនដងដើម្បីឱ្យកុមារស្តាប់សូរ
- ឱ្យកុមាររកពាក្យថ្មីដែលផ្តើមពីអក្សរ "ញ"
- គ្រូសរសេរពាក្យដែលកុមាររកបាននៅលើក្តារខៀនទាំងអស់ទាំងពាក្យត្រឹមត្រូវ និងពាក្យមិនត្រឹមត្រូវ
- នាំកុមារផ្ទៀងផ្ទាត់ដោយគ្រូអានម្តងមួយពាក្យៗ រួចសួរកុមារតើពាក្យនេះមានអក្សរ"ញ" ឬទេ? បើត្រឹមត្រូវគ្រូគូសវង់ជុំវិញពាក្យនោះ។ បើពាក្យខុសគ្រូមិនត្រូវធ្វើអ្វីទាំងអស់។ គ្រូធ្វើរបៀបនេះទាល់តែអស់ពាក្យដែលកុមាររកបាន។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលនាព

## ល្បែង៖ ផ្ទាត់គ្រាប់គ្រួសប្រណាំងគ្នា

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបធ្វើចលនាម្រាមដៃផ្ទាត់គ្រាប់គ្រួសប្រណាំងគ្នាបានត្រឹមត្រូវ
- កុមារធ្វើចលនាម្រាមដៃផ្ទាត់គ្រាប់គ្រួសប្រណាំងគ្នា បានត្រឹមត្រូវ
- កុមារព្យាយាម អំណត់ សហការ ប្រុងប្រយ័ត្ន រហ័សរហួន ទន់ភ្លន់ និងសប្បាយរីករាយ

**២. សម្ភារបង្រៀន៖** មានគ្រាប់គ្រួសចំនួន៣០ គ្រាប់(ចំនួនអាស្រ័យទៅតាមកុមារ)

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរ អ៊ុយ "U" កុមារអង្គុយជារង្វង់តាមក្រុមតូចៗ

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់ពីមុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមជាក្រុមនិងទាំងអស់គ្នា
- គ្រូដាក់កញ្ចប់សម្ភារនៅលើតុពីមុខកុមាររួចឱ្យកុមារស្ម័គ្រចិត្តចំនួន ១ទៅ២នាក់ស្ទាបហើយទាយសម្ភារនៅក្នុងកញ្ចប់រួចឱ្យទៅអង្គុយកន្លែងវិញ
- គ្រូឱ្យកុមារ១នាក់ឡើងមកលូកយកសម្ភារនៅក្នុងថង់នោះចេញមួយចំនួន រួចសួរកុមារ តើមិត្តភក្តិយើង

៣នាក់អម្បាញ់មិញ មានអ្នកណាទាយត្រូវទេ? គ្រូសរុបចម្លើយរបស់កុមារ

- គ្រូឱ្យកុមារទាំងអស់ទះដៃសរសើរមិត្តភក្តិដែលបានទាយត្រូវ និងលើកទឹកចិត្ត អ្នកដែលទាយមិនត្រូវ
- គ្រូសួរកុមារ៖តើកូនដឹងទេថាគ្រូយកសម្ភារនេះមកឱ្យកូនធ្វើអ្វី?កុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ
- **គ្រូណែនាំពីរបៀបលេង៖**
  - កូនៗលេងដោយចាប់ដៃគូចំនួន២នាក់ ហើយក្នុងកូន១នាក់មានគ្រាប់ក្រួសចំនួន១គ្រាប់ដើម្បីយក មកផ្ទាត់តាមផ្លូវដែលអ្នកគ្រូបានគូរ នៅខាងមុខកូន។
  - ពេលកូនចាប់ផ្តើមផ្ទាត់គ្រាប់ក្រួស កូនត្រូវស្តាប់សញ្ញាគ្រូថា៖ ចាប់ផ្តើម! កូនត្រូវផ្ទាត់គ្រាប់ក្រួសទាំង អស់គ្នាដោយកូនត្រូវយកម្រាមដៃស្តាំមកផ្ទាត់គ្រាប់ក្រួសដែលកូនដាក់នៅចំណុចដំបូងនៃផ្លូវដែលគ្រូ គូរបត់បែនរហូតដល់ទីកំណត់ បើកូនណាផ្ទាត់ចេញក្រៅផ្លូវ កូនត្រូវយកគ្រាប់ក្រួសនោះមកដាក់ កន្លែងដើម រួចផ្ទាត់សាជាថ្មីម្តងទៀត។ បើកូនផ្ទាត់មិនចេញទៅក្រៅផ្លូវនោះ កូននៅតែបន្តផ្ទាត់រហូត ដល់ទីកំណត់ កូននោះគឺជាអ្នកឈ្នះ។

# ថ្ងៃទី៣

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

## ហាត់ប្រាណតាមរឿងនិទាន៖ មេសេះសនាំកូនទៅរកចំណី

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបធ្វើចលនាដើរ លោត រត់តាមខ្លឹមសារនៃរឿងនិទានបានត្រឹមត្រូវ
- កុមារដើរ លោត រត់តាមខ្លឹមសារនៃរឿងនិទានបានត្រឹមត្រូវ
- កុមារមានបម្រុងប្រយ័ត្ន ស្វាហាប់ រហ័សរហួន អំណត់ព្យាយាមនិងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** ឈរជាជួរ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរទៅតាមទីកន្លែងដែលបានកំណត់
- គ្រូសួរទៅកាន់កុមារ៖ កូនដែលឃើញសត្វសេះសលោតឬទេ ?នៅកន្លែងណា ? អញ្ចឹងកូននាំគ្នាធ្វើដំណើរសេះលោតទៅមុខទាំងអស់គ្នា គ្រូនាំកុមារលោតដល់ទីកំណត់រួចនាំកុមារត្រឡប់មកកន្លែងដើមវិញ
- គ្រូប្រាប់មុខវិជ្ជានិងចំណងជើង៖ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព អំពីហាត់ប្រាណតាមរឿងនិទាន **"មេសេះនាំកូនទៅរកចំណី"** រួចឱ្យកុមារថាតាមជាក្រុម ឬទាំងអស់គ្នា
- គ្រូនាំប្រាប់កុមារអំពីការធ្វើចលនា ទៅតាមខ្លឹមសាររឿង ដោយប្រាប់កុមារពេលគ្រូនិទាន ដល់ពាក្យលោត ផ្លោះ លោតទៅឆ្វេង លោតទៅស្តាំ លោតជាន់ដុំថ្ម រត់បោល រត់វិលងដុំថ្ម រត់ដល់ក្បាលគ្នា ឈរទល់គូទគ្នា រួចរុញចុះឡើងចំនួនពីរៗនាក់ កូនត្រូវធ្វើចលនាតាមពាក្យនោះ។
- គ្រូចាប់ផ្តើមនិទានរឿងបណ្តើរនាំកុមារធ្វើសកម្មភាពបណ្តើរតាមខ្លឹមសាររឿង បើកុមារធ្វើចលនាណាមួយមិនទាន់ត្រឹមត្រូវគ្រូជួយកែតម្រូវ (ក្នុងករណីសល់ម៉ោងគ្រូអាចធ្វើឡើងវិញម្តងទៀត)
- គ្រូឱ្យកុមារទាំងអស់មកឈរជាជួររួចសួរថាកូនៗហាត់ទេ ?ដើម្បីឱ្យមានកម្លាំងយើងនាំគ្នាទៅក្នុងសួនហិតផ្កា ?តើកូនចង់ហិតផ្កាអ្វី ?
- គ្រូនាំកុមារធ្វើសកម្មភាពហិតផ្កា កូនៗយកដៃធ្វើកាយវិការដូចកាន់ទងផ្កា រួចយកមកដាក់ជិតច្រមុះរួចហិត ដោយដកដង្ហើមចូល ចេញ រួចសួរកុមារ៖ តើផ្កានេះក្រអូបទេ ? (ធ្វើ២ទៅ៣ដង)។

### អត្ថបទរឿងនិទាន "មេសេះសនាំកូនទៅរកចំណី

មានមេសេះសមួយបាននាំកូនលោតផ្លោះរបងចេញពីក្រោល ដើម្បីទៅលេងនៅលើភ្នំមួយ។ គេនាំគ្នារត់បោលយ៉ាងលឿន ម្តងលោតទៅឆ្វេងម្តងលោតទៅស្តាំ ខ្លះរត់វិលងដុំថ្ម ខ្លះលោតជាន់លើដុំថ្មតូចៗ ខ្លះរត់ដល់ក្បាលគ្នា ខ្លះទៀតឈរទល់គូទគ្នា រុញទៅរុញមករហូតបានមកដល់ជ្រោះមួយដែលមានស្ពានបាក់បែកប៉ុន្តែមាំ។ មេសេះ និងកូន ក៏នាំគ្នាដើរតម្រង់ជួរឆ្លងស្ពានម្នាក់ម្តងៗដើម្បីកុំឱ្យផុងជើងធ្លាក់ ពួកគេលើកជើងខ្ពស់ៗ ហើយឈានជើងវែងៗ។ ពេលឆ្លងផុត ពួកគេក៏បានលោតបន្តទៀតដោយភ្នែកសំឡឹងមើលទៅលើភ្នំ ហើយក៏អង្គុយសម្រាកមួយសន្ទុះ ទើបក្រោកឡើងនាំគ្នាស៊ីស្មៅ។ មេសេះ និង កូននាំគ្នាស៊ីស្មៅឆ្អែតហើយក៏នាំគ្នាប្រលែងលេង យ៉ាងសប្បាយរីករាយរហូតដល់ពេលល្ងាចទើបគេនាំគ្នាត្រឡប់មកក្រោលវិញ ។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ ត្រូវចេះចែករំលែកសម្ភារនិងនំចំណីឱ្យមិត្តភក្តិ(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៣ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

### ល្បែង៖ ទាយឈ្មោះសត្វដោយប្រើកាយវិការ

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីឈ្មោះសត្វនិងរបៀបធ្វើកាយវិការបានត្រឹមត្រូវ
- កុមារកំណត់ឈ្មោះសត្វនិងធ្វើកាយវិការត្រាប់តាមសត្វក្នុងបណ្ណរូបភាពបានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** រូបភាពសត្វ ចំនួន២០ផ្ទាំង

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារាងពាក់កណ្ដាលរង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរសំណួរបំផុស ថ្ងៃនេះគ្រូមានបណ្ណរូបភាពជាច្រើន តើកូនចង់ដឹងថារូបទាំងនេះមានសត្វអ្វីខ្លះ? គ្រូឱ្យកុមារម្នាក់មករើសបណ្ណរូបភាពទាំងនោះបង្ហាញ និងប្រាប់ឈ្មោះសត្វ?
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនលេងទាំងអស់គ្នាហើយយើងមានបណ្ណរូបភាពជាច្រើនផ្កាប់នៅលើតុ (លើកម្រាល កន្ទេល ការ៉ូ ចំពីមុខកុមារ)
  - ពេលគ្រូឱ្យកូនណាម្នាក់មករើសបណ្ណរូបភាពមួយយកមកសង្កេតមើល រួចធ្វើកាយវិការត្រាប់តាមសត្វដែលនៅក្នុងរូបភាព ហើយកូនដទៃទៀតទាយពីឈ្មោះសត្វ បន្ទាប់មកកូនដែលកាន់បណ្ណរូបភាពត្រូវលើកបណ្ណនោះឡើងដើម្បីផ្ទៀងផ្ទាត់ចម្លើយទាំងអស់គ្នា រួចយកបណ្ណនោះមកដាក់លើតុគ្រូ ហើយ កូននាំគ្នាអានឈ្មោះសត្វនោះ (បើកុមារទាយឈ្មោះសត្វមិនត្រឹមត្រូវក៏គ្រូត្រូវនាំកុមារអានឈ្មោះសត្វដែលមានក្នុងបណ្ណនោះដែរ)

-គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយ ពីរបៀបលេងឡើងវិញ(បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្ដងទៀត)

-គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផលពេលដែលកុមារម្នាក់លេងចប់

-គ្រូឱ្យកុមារអនុវត្តបន្តបន្ទាប់គ្នារហូតដល់អស់បណ្ណរូបភាពនិងគ្រប់គ្នា គ្រូជាអ្នកសម្របសម្រួល

-គ្រូលើកសរសើរចំពោះអ្នកដែលអនុវត្តបានត្រឹមត្រូវតាមការណែនាំ មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ

**-គ្រូសួរកុមារ៖**

- កូនៗទាំងអស់គ្នាសប្បាយទេ?តើមុននេះកូនៗបានលេងល្បែងអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- តើថ្ងៃនេះកូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)

- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែងមេរៀន "**ទាយឈ្មោះសត្វដោយប្រើកាយវិការ**"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។
-

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## ចម្រៀង៖ យើងក្មេងៗនាំគ្នារាំ (ពេលទី១)

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបច្រៀង និងធ្វើកាយវិការតាមបទច្រៀង បានត្រឹមត្រូវ
- កុមារច្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀងបានត្រឹមត្រូវ
- កុមារស្រឡាញ់ចូលចិត្តច្រៀង និងសហការគ្នាដោយសប្បាយរីករាយ។

២. **សម្ភារបង្រៀន៖** គ្មាន

៣. **ការរៀបចំកុមារ៖** កុមារអង្គុយជាអក្សរ "U" កុមារឈរជាជួរ និងជារង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣ )

- គ្រូបំផុសសំណួរ៖ តើកូនធ្លាប់ចូលរួមកម្មវិធីអ្វីខ្លះ? ហើយកូនបានឃើញសកម្មភាពអ្វីខ្លះ? ដូច្នេះកូនទាយមើលថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជាអ្វី ? អំពីអ្វី? កុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ។ គ្រូសរុបចំណងជើងដែលកុមារបានទាយ
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះគ្រូបង្រៀនកូនលើមុខវិជ្ជាសិក្សាសង្គម អំពីចម្រៀង "**យើងក្មេងៗនាំគ្នារាំ**"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងអ្វីដែលគ្រូបានប្រាប់ ដោយនិយាយថា(អម្បាញ់មិញ មានកូនណាបានទាយត្រូវមុខវិជ្ជា និងចំណងជើងមេរៀន កូនឆ្លាតមែន ពូកែទាយណាស់។ ប៉ុន្តែកូនដែលទាយមិនទាន់ត្រឹមត្រូវក៏ក្លាហានដែរ ហ៊ានឆ្លើយសំណួររបស់គ្រូ ដូច្នេះថ្ងៃក្រោយ កូនព្យាយាមឆ្លើយទៀតណា។
- គ្រូប្រាប់ពីមុខវិជ្ជា និងចំណងជើងមេរៀន រួចឱ្យកុមារថាតាម ជាក្រុម និងទាំងអស់គ្នា
- គ្រូច្រៀង និង ធ្វើកាយវិការឱ្យកុមារស្តាប់ និង មើលមួយចប់បទចម្រៀងសិន
- គ្រូនាំកុមារអានពាក្យពិបាក (លម្ហែកាយា,សម្រាករៀន) ជាក្រុម និង ទាំងអស់គ្នា
- **គ្រូសួរកុមារ៖** កូនដឹងទេថា តើចម្រៀង ដែលគ្រូច្រៀងឱ្យស្តាប់ អម្បាញ់មិញ គេចង់និយាយពីអ្វី? បើកុមារមិនអាចឆ្លើយបាន គ្រូត្រូវប្រាប់ពីអត្ថន័យ នៃបទចម្រៀងដោយប្រាប់កុមារថា៖ ចម្រៀងនេះមានន័យថា ចង់ឱ្យកុមារចេះបង្កបរិយាកាសសប្បាយរីករាយ ។
- គ្រូអានអត្ថបទចម្រៀងជាពាក្យរាយឱ្យកុមារស្តាប់ម្តងមួយឃ្លាៗ រួចឱ្យកុមារអានតាមម្តងមួយក្រុមៗ រួចទាំងអស់គ្នា
- គ្រូធ្វើជាសំឡេង ឡាឡាឡាៗៗ ឡាឡាឡាៗៗៗ ទៅតាមលំនាំបទចម្រៀងឱ្យកុមារស្តាប់មួយចប់បទ

ចម្រៀងសិន

- គ្រូនាំកុមារធ្វើជាសំឡេង ឡាឡាឡាៗៗ ឡាឡាឡាៗៗៗ ទៅតាមលំនាំបទចម្រៀងដែលគ្រូបានធ្វើឱ្យស្តាប់(ម្តងមួយក្រុម ៗ រួចទាំងអស់គ្នា)ឱ្យបាន ២ចប់
- គ្រូនាំកុមារច្រៀង និង ធ្វើកាយវិការតាមបទចម្រៀង មួយឃ្លាម្តងៗ រហូតចប់បទចម្រៀង(ម្តងមួយក្រុមៗ រួចទាំងអស់គ្នា ឱ្យបាន ១ ឬ ២ ចប់
- គ្រូច្រៀងតិចៗ ម្តងមួយឃ្លាៗ កុមារច្រៀងឮៗម្តងមួយឃ្លាៗ តាមគ្រូរហូតចប់បទចម្រៀង( ម្តងមួយក្រុមៗ រួចទាំងអស់គ្នា ) ឱ្យបាន២ចប់
- គ្រូនាំកុមារច្រៀង និង ធ្វើកាយវិការតាមបទចម្រៀងសាឡើងវិញឱ្យបាន ២ចប់ ទៅ ៣ចប់ ទាំងអស់គ្នា

**+ របៀបធ្វើកាយវិការះ**

**- ខ្លឹមសារចម្រៀងះ**

| | |
|---|---|
| -យើងក្មេងៗនាំគ្នារាំ | រាំសប្បាយៗលម្ហែកាយា |
| មកមិត្តអើយយើងនាំគ្នារាំ រាំ រាំ | រាំលេងសប្បាយ។ |

- របៀបធ្វើកាយវិការះ ឱ្យកុមារលើកដៃទាំងពីរឡើងលើដាក់ត្រឹមទ្រូង រាំដើរទៅមុខជារង្វង់តាមខ្លឹមសារបទចម្រៀង។ (កុមារឈរជាជួរទទឹង )

**- ខ្លឹមសារចម្រៀងះ**

| | |
|---|---|
| -កាន់ដៃគ្នាៗជារង្វង់ | រាល់ថ្ងៃឈប់ៗឈប់សម្រាករៀន |
| មកមិត្តអើយយើងនាំគ្នារាំ រាំ រាំ | រាំលេងសប្បាយ។ |

-របៀបធ្វើកាយវិការះ ឱ្យកុមារកាន់ដៃគ្នាបង់បោយបោះជើងម្ខាងទៅមុខ ម្តងទៅឆ្វេង ម្តងទៅស្តាំ ជាចង្វាក់។ (កុមារឈរជាជួរបណ្តោយ )

-ខ្លឹមសារចម្រៀងះ

ឡាឡាឡាៗៗ ឡាឡាឡាៗៗៗ ។

ឡាៗៗ ឡាៗ ។ (ឡាៗ មួយអត្ថបទចម្រៀង)

- របៀបធ្វើកាយវិការះ ឡាឡាឡាៗៗ ឡាឡាឡាៗៗ ឡាឡាឡាៗៗ (បន្លឺមួយចប់បទចម្រៀង) កុមារលើកដៃទាំងពីរឡើងលើដាក់ត្រឹមចិញ្ចើមរាំដើរទៅមុខជារង្វង់តាមចង្វាក់ និងបោះជើងម្ខាងទៅមុខ ម្តងទៅឆ្វេង ម្តងទៅស្តាំ ជាចង្វាក់

អត្ថបទចម្រៀង "យើងក្មេងៗនាំគ្នារាំ"

| | |
|---|---|
| -យើងក្មេងៗនាំគ្នារាំ | រាំសប្បាយៗលម្ហែកាយា |
| មកមិត្តអើយយើងនាំគ្នារាំ រាំ រាំ | រាំលេងសប្បាយ។ |
| -កាន់ដៃគ្នាៗជារង្វង់ | រាល់ថ្ងៃឈប់ៗឈប់សម្រាករៀន |
| មកមិត្តអើយយើងនាំគ្នារាំ រាំ រាំ | រាំលេងសប្បាយ។ |

ឡាឡាឡាៗៗ ឡាឡាឡាៗៗៗ ។

ឡាៗៗ ឡាៗ ។(ឡាៗ មួយអត្ថបទចម្រៀង)

ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ វិទ្យាសាស្ត្រ

## ល្បែងៈ ធ្វើចំណាត់ថ្នាក់បន្លែ ផ្លែឈើ បន្លែស្លឹក បន្លែមើម

**១.វត្ថុបំណងៈ**

- កុមារប្រាប់ពីរបៀបធ្វើចំណាត់ថ្នាក់បន្លែ ផ្លែឈើ បន្លែស្លឹក បន្លែមើម បានត្រឹមត្រូវ
- កុមារធ្វើចំណាត់បន្លែ ផ្លែឈើ បន្លែស្លឹក បន្លែមើម បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន សហការ ជួយគ្នាក្នុងការអនុវត្តការងារក្រុមបានត្រឹមត្រូវ ។

**២. សម្ភារបង្រៀនៈ** បន្ទះបណ្ណបន្លែ ផ្លែឈើ បន្លែស្លឹក បន្លែមើម (មួយមុខមានចំនួន៥បណ្ណ)ចំនួន៤ឈុត

**៣. ការរៀបចំកុមារៈ** អង្គុយជារាងពាក់កណ្តាលរង្វង់ "ប", អង្គុយតាមក្រុមតូចៗ (៣ក្រុម)

**៤. ដំណើរការបង្រៀន**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញបន្ទះបណ្ណបន្លែ ផ្លែឈើ បន្លែស្លឹក បន្លែមើម ដោយដាក់នៅលើតុពីមុខកុមារ រួចឱ្យកុមារម្នាក់ជាអ្នកលើកបង្ហាញ ហើយកុមារ ដទៃទៀតជាអ្នកប្រាប់ឈ្មោះ (ឱ្យកុមារប្រាប់ឈ្មោះបន្លែ ផ្លែឈើ)
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេងៈ**
  - គ្រូឱ្យកូនទាំងអស់គ្នាលេងជាក្រុម ហើយក្នុងមួយក្រុមៗ កូនត្រូវមានបណ្ណបន្លែ ផ្លែឈើ បន្លែស្លឹក បន្លែមើម ដែលកូនបានបង្ហាញមួយកញ្ចប់ មុននេះ
  - ពេលក្រុមកូននីមួយៗបានសម្ភារទាំងនេះហើយ កូនត្រូវយកសម្ភារចេញពីថង់ដាក់នៅកណ្តាលរង់ ។ បន្ទាប់មក ពួកកូនក្នុងក្រុមនីមួយៗ នាំគ្នាសង្កេតមើលបណ្ណបន្លែ ផ្លែឈើ បន្លែស្លឹក បន្លែមើម ទាំងនោះ ដើម្បីចំណាំ ប៉ុន្តែកូននាំគ្នាមើលដោយស្ងៀមស្ងាត់ មិនដណ្តើមគ្នាមើលទេ
  - នៅពេលគ្រូឱ្យសញ្ញាចាប់ផ្តើម កូនៗគ្រប់ក្រុមត្រូវនាំគ្នារើសបណ្ណរូបភាពទាំងនោះដាក់តាមផ្នែក (បន្លែ ផ្លែឈើ បន្លែស្លឹក បន្លែមើម) ។ បើក្រុមណារៀបបានរួចរាល់មុនគេ កូនត្រូវទះដៃជាសញ្ញា ។ បន្ទាប់មកអ្នករៀបរួចបន្តបន្ទាប់ ក៏ទះដៃបន្តបន្ទាប់ដែរ ។ ពេលកូនរៀបបណ្ណរូបភាពទាំងនោះ កូនត្រូវធ្វើម្នាក់ម្តងៗរង់ចាំវេន មិនដណ្តើមគ្នារញ៉េរញ៉ៃទេ ទើបជាកូនល្អ
  - ពេលក្រុមកូនរៀបចំគ្រប់ក្រុមហើយនោះ កូនទុកមិត្តភក្តិយើងម្នាក់នៅកន្លែងរៀបសម្ភារ ឯកូនដទៃទៀត ទៅអង្គុយនៅក្រុមធំវិញ ហើយនាំគ្នាផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗជាមួយគ្រូ ។
- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាក្រុម រួចឱ្យទៅអង្គុយជារង្វង់នៅតាមកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗ យកសម្ភារ ហើយចាប់ផ្តើមអនុវត្តតាមសញ្ញាបញ្ជារបស់គ្រូ
- គ្រូឱ្យក្រុមកុមារនីមួយៗដែលធ្វើរួចហើយទៅអង្គុយនៅក្រុមធំវិញ ក្នុងមួយក្រុមទុកតែកុមារម្នាក់ដើម្បីបង្ហាញលទ្ធផល
- គ្រូនាំកុមារផ្ទៀងផ្ទាត់ម្តងមួយក្រុមៗ ដោយឱ្យម្ចាស់ក្រុមនីមួយៗជាអ្នកបង្ហាញពីអ្វីដែលពួកគេបានធ្វើ ។ បន្ទាប់មកឱ្យកុមារដែលនៅអង្គុយក្នុងក្រុមធំជាអ្នកវាយតម្លៃ បើមានខុសជួយកែតម្រូវ ។ ពេលផ្ទៀងផ្ទាត់ចប់ គ្រូត្រូវឱ្យកុមារប្រមូលសម្ភារទុកជូនគ្រូវិញ ។
- **គ្រូសួរកុមារៈ** អម្បាញ់មិញកូនស្គាល់អ្វីខ្លះ? ដូចនេះកូនជួយប្រាប់គ្រូបានទេ តើយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ អំពីល្បែង មេរៀន " **ចំណាត់ថ្នាក់បន្លែ ផ្លែឈើ បន្លែ**

ស្លឹក បន្លែមើម" រួចសួរកុមារ អំបាញ់មិញមានកូនណាទាយត្រូវឬទេ ដូចនេះកូនៗដែលទាយត្រូវគឺជាកូនពូកែ កូនឆ្លាត។ រីឯកូនដែលទាយមិន ត្រូវក៏ល្អដែរ ដែលក្លាហានក្នុងការនិយាយជាមួយគ្រូ។

- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

**ម៉ោងទី៦ (រយៈពេល ៣០នាទី)**

## មុខវិជ្ជាៈ សិក្សាសង្គម

* ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦ )

## ថ្ងៃទី៤

ម៉ោងទី១ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ ចិត្តចលភាព

## ចលនាមូលដ្ឋានៈ វារ (វារទៅមុខតាមទីកំណត់ វារក្រោមតុ វារចូលកង ឬវង្វង់)

**១. វត្ថុបំណងៈ**

- ប្រាប់បានពីរបៀបវារទៅមុខ វារក្រោមតុ វារចូលកងឬវង្វង់ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារវារទៅមុខ វារក្រោមតុ វារចូលកង ឬវង្វង់ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារមានភាព រហ័សរហួន បម្រុងប្រយ័ត្នអំណត់ព្យាយាមនិងសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ** កង និងតុ

**៣. ការរៀបចំកុមារៈ** ចែកកុមារជាបីក្រុមដោយឱ្យកុមារឈរជាបីជួរ( ករណីកុមារច្រើនអាចចែកជា៦ក្រុម ដោយ២ក្រុមធ្វើ១សកម្មភាព)

៤. **ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី ៣)

- គ្រូនាំកុមារធ្វើសកម្មភាពដើរ ដោយឱ្យកុមារធ្វើចលនាដើរដូចពួកងទ័ព ជ្រំជើងមួយកន្លែង
- គ្រូបង្ហាញសម្ភារឱ្យកុមារប្រាប់ឈ្មោះ
- គ្រូណែនាំកុមារពីរបៀបធ្វើចលនាមូលដ្ឋាននីមួយៗ "វារ" (វារទៅមុខ វារក្រោមតុ វារចូលកង ឬវង្វង់)
- គ្រូឱ្យកុមារ១ឬ២នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ(បើកុមារនិយាយមិនត្រឹមត្រូវគ្រូប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាបីក្រុមនិងអនុវត្តតាមសកម្មភាពៈ
  - ក្រុមទី១ៈ វារទៅមុខឱ្យដល់ទិសដៅដែលបានកំណត់
  - ក្រុមទី២ៈ វារក្រោមតុឱ្យដល់ទិសដៅដែលបានកំណត់
  - ក្រុមទី៣ៈ វារចូលកងឬវង្វង់ឱ្យដល់ទិសដៅដែលបានកំណត់
- បន្ទាប់ពីកុមារបានវារតាមរបៀបខាងលើរួចគ្រូឱ្យក្រុមនីមួយៗផ្លាស់ប្តូរសកម្មភាពវារតាមសញ្ញារបស់គ្រូ។
- គ្រូដើរសម្របសម្រួលតាមក្រុមនីមួយៗដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានវារគ្រប់សកម្មភាព។
- គ្រូសួរកុមារ តើអម្បាញ់មិញនេះកូនៗបានធ្វើចលនាអ្វី?
- ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វីមានចំណងជើងអ្វី?
- គ្រូប្រាប់កុមារថាថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាពមានចំណងជើងថាចលនាមូលដ្ឋាន "វារ" (**វារទៅមុខ វារ ក្រោមតុ វារចូលកងឬវង្វង់**)
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយទៅនឹងអ្វីដែលគ្រូបានប្រាប់( តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយរបស់គ្រូទេ?បើមានកុមារឆ្លើយត្រូវគ្រូលើកសរសើរបើកុមារឆ្លើយមិនបានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត) គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀនជាក្រុមនិងទាំងអស់គ្នា។
- កូនៗហត់ឬទេបើហត់កូនចង់ធ្វើអ្វី? ដូច្នេះកូនទាំងអស់គ្នាលើកដៃឡើងយកប៉េងប៉ោងម្នាក់ មួយមកផ្លុំ (កូនយកមេដៃនិងចង្អុលដៃទាំងសងខាងមកចាប់មាត់ប៉េងប៉ោងយកមកដាក់ជិតមាត់ហើយ ផ្លុំ ខ្លាំងៗ រួចដៃទាំងពីរ ដែលកាន់មាត់ប៉េងប៉ោងលាតាមទំហំនៃប៉េងប៉ោងរីកហូតដល់ប៉េងប៉ោងបែក ទើបទះដៃជាសញ្ញាប៉េងប៉ោងផ្ទុះ) គ្រូឱ្យកុមារធ្វើរបៀបនេះពីរឬបីដង។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ ត្រូវចេះចែករំលែកសម្ភារនិងនំចំណីឱ្យមិត្តភក្តិ(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៤ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

## ទស្សនាសង្កេត៖ ចំការបន្លែ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីឈ្មោះបន្លែ បានត្រឹមត្រូវ
- កុមារបង្ហាញពី ឈ្មោះ រូបរាងនិងផលប្រយោជន៍បន្លែ បានត្រឹមត្រូវ
- កុមារឈ្លាសវៃ រហ័សរហួន ច្នៃប្រឌិត សហការនិងចូលចិត្តញ៉ាំបន្លែ ។

**២. សម្ភារបង្រៀន៖** គ្រូអាចបត់បែនបានទៅតាមមូលដ្ឋាន

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរ អ៊ុយ "U"

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំណួរ៖
  + ថ្ងៃនេះមេឃស្រឡះល្អ តើកូនទាំងអស់គ្នាចង់ដើរលេងឬទេ? តើកូនចង់ទៅលេងនៅឯណា?
  + តើកូនធ្លាប់ឃើញម្តាយកូនទិញបន្លែអ្វីខ្លះមកស្លរាល់ថ្ងៃឱ្យកូនញ៉ាំ?
  + តើបន្លែទាំងនោះគេដាំនៅឯណា?
  + តើកូនចង់ទៅលេងចំការបន្លែជាមួយគ្រូឬទេ?បើកូនចង់ទៅលេងចំការបន្លែកូនត្រូវនាំគ្នាស្តាប់គ្រូ
- គ្រូណែនាំកុមារមុនពេលចេញដំណើរ៖
  - ពេលដើរនៅតាមផ្លូវកូនៗទាំងអស់គ្នាដើរខាងស្តាំដៃ ដើរជិតៗគ្រូកុំដើរលឿនទៅចោលគ្រូ កុំប្រឡែងគ្នាលេងនៅតាមផ្លូវ។ ហើយកូនមើលនៅតាមផ្លូវបើមានអ្វីៗកូនជួយប្រាប់គ្រូនិងប្រាប់មិត្តភក្តិយើងទៅវិញទៅមក។ បើកូនឃើញហើយមិនស្គាល់ទេនោះកូនត្រូវសួរគ្រូ
  - ពេលដើរទៅដល់ចំការបន្លែ កូនៗនាំគ្នាជម្រាបសួរម្ចាស់ចំការ ហើយមិនត្រូវរញ៉េរញ៉ៃពេញចំការគាត់ទេកូនត្រូវនាំគ្នាដើរមើលឱ្យមានសណ្តាប់ធ្នាប់ទើបជាកូនល្អ ។
- គ្រូឱ្យកុមារមកជុំគ្នារួចហើយក៏ធ្វើដំណើរចេញទៅលេងចំការបន្លែ
- ពេលដើរតាមផ្លូវគ្រូស្តាប់កុមារជជែកគ្នា ហើយបើគេនិយាយខុសគ្រូត្រូវកែលម្អភ្លាមប៉ុន្តែបើកុមារស្ងាត់ស្ងៀមមិននិយាយអ្វីសោះគ្រូត្រូវបំផុសសំណួរ(តើនៅតាមដងផ្លូវកូនឃើញអ្វីខ្លះ?)
- ពេលជិតទៅដល់ចំការបន្លែគ្រូឱ្យកុមារឈប់ទាំងអស់គ្នាបន្តិចរួចប្រាប់កុមារឱ្យមើលទៅខាងមុខ តើឃើញអ្វីខ្លះ? ឱ្យកុមារប៉ាន់ស្មានទាយ តាមគំនិតរបស់កុមារម្នាក់ៗ ដោយមិនគិតពីចម្លើយត្រូវឬខុស

- គ្រូឱ្យកុមារធ្វើដំណើរបន្តទៀតដើម្បីឱ្យឆាប់ទៅដល់ចំការបន្លែ
- ពេលទៅដល់ចំការបន្លែគ្រូនាំកុមារទាំងអស់ជម្រាបសួរម្ចាស់ចំការរួចឱ្យកុមារប្រាប់ម្ចាស់ចំការ ( ពួកខ្ញុំមកពីសាលាមត្តេយ្យសិក្សា........)  និងសួរម្ចាស់ចំការ( តើមីងឈ្មោះអ្វីដែរ ? ពួកខ្ញុំអាចសុំមើលចំការបន្លែមីងបានដែរឬទេ ? ) ឱ្យកុមារអរគុណម្ចាស់ចំការ។
- គ្រូនាំកុមារដើរចូលទៅក្នុងចំការនិងប្រាប់កុមារឱ្យនាំគ្នាដើរមើលជុំវិញចំការបន្លែមីងតើកូនឃើញមានអ្វីខ្លះ ?
- គ្រូប្រាប់កុមារពេលកូនដើរមើលដំណាំជុំវិញចំការមីង កូនមិនត្រូវបេះបោចឬដើរជាន់ដំណាំមីងទេ
- ពេលកុមារមើលជុំវិញចំការរួចហើយ ក៏ឱ្យកុមារមកជុំគ្នាហើយជួបជាមួយម្ចាស់ចំការដើម្បីឱ្យកុមារសួរគាត់ពីរបៀបដាំបន្លែទាំងអស់នោះ។
- ពេលកុមារមិនសូវចេះសួរគ្រូត្រូវបំផុសគំនិតឱ្យកុមារសួរទៅម្ចាស់ចំការ

**ឧទាហរណ៍៖** តើបន្លែទាំងអស់នេះឈ្មោះអ្វី ? តើដាំរបៀបដូចម្ដេច ? ដាំប៉ុន្មានខែទើបបានទទួលផល ? តើថែទាំដំណាំដូចម្ដេចទើបដំណាំលូតលាស់បានល្អ ? តើមីងយកទៅលក់នៅឯណា ? លក់ក្នុងមួយខែបានប៉ុន្មានរៀល ? ហេតុអ្វីបានចាំបាច់ធ្វើរបងព័ទ្ធជុំវិញ ?...

- ពេលកុមារសួរម្ចាស់ចំការរួចហើយគ្រូឱ្យកុមារចូលរួមធ្វើការងារផ្ទាល់ជាមួយម្ចាស់ចំការដូចជាដកស្មៅជ្រោយដីដាក់ជីជាដើម។ បន្ទាប់មកនាំកុមារលាងដៃឱ្យស្អាត
- គ្រូនាំកុមារជម្រាបលាម្ចាស់ចំការដើម្បីធ្វើដំណើរមកសាលារៀនវិញ
- ពេលមកដល់សាលាវិញគ្រូឱ្យកុមារអង្គុយសម្រាកឱ្យបាត់ហត់បន្តិចសិន
- **គ្រូបំផុសសំណួរ៖** តើអម្បាញ់មិញកូននាំគ្នាទៅដើរលេងនៅឯណា ? កូនឃើញអ្វីខ្លះ ? ដូច្នេះកូនជួយប្រាប់គ្រូថាតើអម្បាញ់មិញកូនរៀនមុខវិជ្ជាអ្វី ? អំពីអ្វី ?
- **គ្រូប្រាប់កុមារ៖** ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រអំពីទស្សនាសង្កេតចំការបន្លែ។  តើមានកូនណាទាយត្រូវឬទេ ? បើអញ្ចឹងកូននាំគ្នាទះដៃទាំងអស់គ្នាដើម្បីសរសើរមិត្តភក្តិយើងដែលបានទាយត្រូវ។
- ចំពោះកូនដែលទាយមិនត្រូវកុំអន់ចិត្តអី ព្រោះកូនក្លាហានហ៊ានឆ្លើយសំណួរគ្រូបាន
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន( ជាក្រុមនិងទាំងអស់គ្នា )។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## គំនូរ៖ ផ្លែចេកណាំវ៉ាមួយផ្លែ

### ១.វត្ថុបំណង៖

-កុមារប្រាប់ពីរបៀបគូរផ្លែចេកណាំវ៉ាមួយផ្លែបានត្រឹមត្រូវ

-កុមារកាន់ខ្មៅដៃគូរផ្លែចេកណាំវ៉ាមួយផ្លែដោយទប់លំនឹងបានត្រឹមត្រូវ

-កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់ សហការចូលរួមយ៉ាងសកម្មនិងសប្បាយរីករាយ។

### ២.សម្ភារបង្រៀន៖

+ **សម្ភារសម្រាប់គ្រូ៖**

- ផ្ទាំងក្រដាសដែលមានគូរផ្លែចេកណាំវ៉ាមួយផ្លែចំនួន១សន្លឹក
- ផ្ទាំងក្រដាសសដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀន( ក្រដាសផ្ទាំងធំ )

- ខ្មៅដៃចំនួន១ដើម ស្កុតចំនួន១ដុំ។

+ **សម្ភារសម្រាប់កុមារ៖**

- ផ្ទាំងក្រដាសសដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀននៅក្បាលសន្លឹកកិច្ចការគ្រប់ចំនួនកុមារ និងខ្មៅដៃគ្រប់ចំនួនកុមារ

៣. **ការរៀបចំកុមារ៖** អង្គុយរាងអក្សរ "ប" ចែកកុមារជាក្រុម(អនុវត្តជាបុគ្គល)

៤. **ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរ៖ តើនៅផ្ទះកូនៗមានដាំដំណាំអ្វីខ្លះ?(ចម្លើយតាមគំនិតកុមារម្នាក់ៗ)
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារថាតាម(ជាក្រុមនិងទាំងអស់គ្នា)
- គ្រូបង្ហាញផ្ទាំងក្រដាសដែលមានគូរផ្លែចេកណាំវ៉ាមួយផ្លែរួចស្រេច ឱ្យកុមារសង្កេតនិងប្រាប់ឈ្មោះ រួចបិទនៅលើក្ដារខៀន ឱ្យកុមារមើលជាគំរូ
- គ្រូបង្ហាញផ្ទាំងក្រដាសស១សន្លឹកទៀត ដែលគ្រូមិនទាន់គូរផ្លែចេកណាំវ៉ាមួយផ្លែឱ្យកុមារសង្កេត
- គ្រូប្រាប់កុមារ៖ ផ្ទាំងក្រដាសសនេះគ្រូទុកសម្រាប់គូរឱ្យកូនមើលពីរបៀបគូរ។ ដូច្នេះកូននាំគ្នាចាំមើលទាំងអស់គ្នា តើគ្រូចាប់ផ្ដើមគូរពីណាទៅណា?
- គ្រូយកផ្ទាំងក្រដាសនោះទៅបិទនៅលើក្ដារខៀន ជិតផ្ទាំងក្រដាសជាគំរូដើម្បីណែនាំពីរបៀបគូរ
- គ្រូណែនាំពីរបៀបគូរនៅលើផ្ទាំងក្រដាសសដែលបានបិទលើក្ដារខៀន ដោយគូរបណ្ដើរ និយាយប្រាប់កុមារបណ្ដើរយឺតៗ ដើម្បីឱ្យកុមារសង្កេតពីទិសនៃការគូរ។
- **គ្រូប្រាប់កុមារ៖**
    - កូនយកខ្មៅដៃគូរផ្លែចេកណាំវ៉ាមួយផ្លែដោយចាប់គូរទងពីលើចុះមកក្រោមបត់ពីស្ដាំមកឆ្វេងទាញចុះក្រោម បញ្ចប់បន្តិចរួចទាញឡើងលើ បត់មកឆ្វេងទាញឡើងលើគូរភ្ជាប់ទង (តាមរូបគំនូរគំរូរបស់គ្រូដាក់ស្ដែង)
    - បន្ទាប់មកកូនយកខ្មៅដៃកូនគូរផ្លែចេកណាំវ៉ាមួយផ្លែឱ្យពេញលេញ
- គ្រូបង្ហាញផ្ទាំងក្រដាសជាសន្លឹកកិច្ចការកុមារម្នាក់ៗរួចប្រាប់កុមារ៖ កូនម្នាក់ៗត្រូវបានផ្ទាំងសន្លឹកកិច្ចការនេះមួយសន្លឹកនិងខ្មៅដៃមួយដើម សម្រាប់កូនគូរទៅតាមអ្វីដែលគ្រូបានបង្ហាញ
- គ្រូរៀបចំកុមារឱ្យអង្គុយទៅតាមតុដែលគ្រូបានរៀបចំឬបង្វិលកៅអី អង្គុយគូរ (តាមស្ថានភាពជាក់ស្ដែង)
- ឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅចែកគ្នាអនុវត្ត
- កុមារម្នាក់ៗនាំគ្នាអនុវត្ត គ្រូដើរសម្របសម្រួលគ្រប់ក្រុម ដើម្បីជួយកុមារណាដែលមិនទាន់ចេះកាន់ខ្មៅដៃគូរ និងមិនទាន់យល់ពីរបៀបគូរ ហើយដាក់ឈ្មោះកុមារម្នាក់ៗពីខាងក្រោមសន្លឹកកិច្ចការ
- គ្រូប្រាប់កុមារ៖ ពេលកូនគូររួចហើយកូនយកខ្មៅដៃទៅទុកឱ្យគ្រូវិញ ហើយសន្លឹកកិច្ចការរបស់កូនទុកនៅរៀងៗខ្លួន។
- ពេលកុមារគូរហើយគ្រប់គ្នា គ្រូឱ្យកុមារទៅអង្គុយកន្លែងដើមជារាងអក្សរ(អ៊ុយ)វិញ
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផលដោយឱ្យកុមារទៅឈរម្ដងមួយក្រុមៗនៅខាងមុខ ហើយកាន់សន្លឹកកិច្ចការ ដាក់នៅត្រង់ដើមទ្រូងបង្ហាញមិត្តភក្តិ ដើម្បីឱ្យពួកគេជាអ្នកផ្ទៀងផ្ទាត់។
- គ្រូសួរកុមារដែលជាអ្នកផ្ទៀងផ្ទាត់៖ តើមិត្តភក្តិយើងគូរបានត្រឹមត្រូវទេ? ស្អាតទេ? បើមានកុមារណាបង្ហាប់គំនូររបស់មិត្តភក្តិណាម្នាក់ គ្រូត្រូវចេះកែតម្រូវទៅជាពាក្យសម្ដីលើកទឹកចិត្តកុមារនោះវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូឱ្យតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការរបស់មិត្តភក្តិគេឱ្យគ្រូ សម្រាប់ទុកដាក់តាំងស្នាដៃកុមារ។

ម៉ោងទី៨ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

## ល្បែង៖ ទៅផ្សារទិញបន្លែ ផ្លែឈើចំនួនពី១ដល់១០

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីចំនួនបន្លែ ផ្លែឈើពី១ដល់១០បានត្រឹមត្រូវ
- កុមាររាប់ចំនួនបន្លែ ផ្លែឈើពី១ដល់១០បានត្រឹមត្រូវ
- កុមារសហការជួយគ្នា យកចិត្តទុកដាក់ អំណាត់ព្យាយាម លេងដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖**

- បណ្ណរូបភាពត្រសក់ចំនួន១ផ្លែ ប៉េងប៉ោះចំនួន២ផ្លែ ការ៉ុតចំនួន៣មើម ឆៃថាវចំនួន៤មើម ត្រឡាចចំនួន៥ផ្លែ ម្រះចំនួន៦ផ្លែ ក្រូចឆ្មារ៧ផ្លែ ននោងចំនួន៨ផ្លែ ត្រាវចំនួន៩មើម ដំឡូងបារាំងចំនួន១០មើម
- បណ្ណរូបភាពផ្លែក្រូចចំនួន១ផ្លែ ដូងចំនួន២ផ្លែ ស្រកានាគចំនួន៣ផ្លែ មង្ឃុតចំនួន៤ផ្លែ ទន្លាប់ចំនួន៥ផ្លែ ទំពាំងបាយជូរចំនួន៧ផ្លែ ទុរេនចំនួន៨ផ្លែ ផ្លែទឹកដោះចំនួន៩ផ្លែ ផ្លែមៀនចំនួន១០ផ្លែ

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាអក្សរ "ប" ជាក្រុមតូចៗ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរកុមារ៖កូនៗធ្លាប់ញ៉ាំផ្លែឈើអ្វីខ្លះ?ហើយផ្លែឈើនោះបានមកពីណា?ដូច្នេះអាចប្រាប់គ្រូបានទេថា តើកូនៗចង់រៀនមុខវិជ្ជាអ្វី? អំពីអ្វី? ឱ្យកុមារឆ្លើយតាមការគិតរបស់គេម្នាក់ៗ
- គ្រូប្រាប់កុមារពេលនេះគ្រូចង់បង្រៀនកូនពីមុខវិជ្ជាបុរេគណិត អំពីល្បែង "ទៅផ្សារទិញបន្លែនិងផ្លែឈើពី ១ ដល់១០" តើកូនៗចង់រៀនជាមួយគ្រូឬទេ?
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារ តើអម្បាញ់មិញមានកូនណាឆ្លើយដូចចម្លើយគ្រូដែរឬទេ? កូនដែលមានគំនិតដូចគ្រូគឺកូនឆ្លាតនិងពូកែឈ្លាសវៃមែន!
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន(ជាក្រុមនិងទាំងអស់គ្នា)
- គ្រូដាក់បណ្ណបន្លែនិងផ្លែឈើលើតុពីមុខកុមារ ហើយហៅកុមារ១នាក់ឬ២នាក់ឱ្យមកលើកបង្ហាញបណ្ណបន្លែ និងផ្លែឈើ ដោយប្រាប់ពីឈ្មោះនិងចំនួនទៅតាមបណ្ណនីមួយៗ
- **គ្រូណែនាំពីរបៀបលេង៖**
    - គ្រូឱ្យកូនៗលេងទាំងអស់គ្នាជាមួយគ្រូ ហើយសម្ភារទាំងអស់នេះជារបស់គ្រូ ពេលគ្រូនិយាយថាថ្ងៃនេះគ្រូចង់ញ៉ាំផ្លែឈើ និងចង់ទិញបន្លែខ្លះមកស្ល តើទិញនៅឯណា? ដូច្នេះកូនៗទាំងអស់គ្នាចង់ទៅផ្សារជាមួយគ្រូដែរឬទេ? កូនៗនាំគ្នាឆ្លើយរួចមកឈរពីមុខគ្រូ ហើយចាំស្តាប់គ្រូប្រាប់
    - ពេលគ្រូនិយាយថា៖ មក យើងនាំគ្នាទៅផ្សារ ដូច្នេះកូនៗនាំគ្នាដើរជាមួយគ្រូទាំងអស់គ្នា។ ហើយកុំដើរចោលគ្រូខ្លាចវង្វេងព្រោះផ្សារមនុស្សច្រើនណាស់
    - ពេលគ្រូថាយើងមកដល់ផ្សារហើយ គ្រូចង់ទិញបន្លែ ពេលនោះកូនៗមើលមកដៃគ្រូ បើគ្រូលើបណ្ណរូបភាពអ្វី? ហើយមានចំនួនប៉ុន្មាន? កូនត្រូវនាំគ្នារត់បង្កើតក្រុមទៅតាមចំនួនរូបភាពដែលគ្រូបានលើករួចហើយកូននាំគ្នារាប់ចំនួន កូនក្នុង១ក្រុមៗ តើត្រូវតាមចំនួនរូបភាពដែលគ្រូបានលើកហើយឬនៅ?
    - ពេលកូនពិនិត្យចប់គ្រប់ក្រុម កូនត្រូវដើរតាមគ្រូទៅមុខបន្តទៀត ពេលគ្រូថាគ្រូចង់ទិញផ្លែឈើ ពេលនោះកូនៗមើលមកដៃគ្រូ បើគ្រូលើកបណ្ណរូបភាពអ្វី? ហើយមានចំនួនប៉ុន្មាន?កូនត្រូវនាំគ្នារត់បង្កើត

ក្រុមទៅតាមចំនួនរូបភាពដែលគ្រូបានលើក រួចហើយកូននាំគ្នារាប់ចំនួន កូនក្នុង១ក្រុមៗ តើត្រូវតាមចំនួនរូបភាពដែលគ្រូបានលើកហើយឬនៅ?

- គ្រូធ្វើរបៀបនេះបន្តបន្ទាប់ទាល់តែគ្រូប្រាប់ថា ទិញបន្លែផ្លែឈើគ្រប់ហើយ យើងនាំគ្នាទៅផ្ទះវិញ ដូច្នេះកូនៗមកនៅជុំជាមួយគ្រូ រួចដើរតាមគ្រូត្រឡប់ទៅផ្ទះវិញ។

- ឱ្យកុមារ១នាក់ឬ២នាក់និយាយឡើងវិញពីអ្វីដែលគ្រូបានប្រាប់ បើករណីកុមារមិនអាចប្រាប់បានទេនោះ គ្រូត្រូវនិយាយប្រាប់ឡើងវិញម្តងទៀត
- **គ្រូនាំកុមារអនុវត្តៈ** ពេលអនុវត្តមួយដងត្រូវនាំកុមារផ្ទៀងផ្ទាត់លទ្ធផលមួយដង ដោយឱ្យកុមារជួយពិនិត្យគ្នាទៅវិញទៅមក និងម្ចាស់ក្រុមរាប់ចំនួនបង្ហាញរួចនាំគ្នាផ្ទៀងផ្ទាត់ទៅនឹងចំនួនបណ្ណដែលគ្រូបានលើក។
- ឱ្យកុមារ១នាក់ឬ២នាក់និយាយឡើងវិញពីអ្វីដែលគ្រូបានប្រាប់ បើករណីកុមារមិនអាចប្រាប់បានទេនោះ គ្រូត្រូវនិយាយប្រាប់ឡើងវិញម្តងទៀត
- **គ្រូនាំកុមារអនុវត្តៈ** ពេលអនុវត្តមួយដងត្រូវនាំកុមារផ្ទៀងផ្ទាត់លទ្ធផលមួយដងដោយឱ្យកុមារជួយពិនិត្យគ្នាទៅវិញទៅមក និងម្ចាស់ក្រុមរាប់ចំនួនបង្ហាញរួចនាំគ្នាផ្ទៀងផ្ទាត់ទៅនឹងចំនួនប័ណ្ណដែលគ្រូបានលើក។

**ម៉ោងទី៦ (រយៈពេល ៣០នាទី)**

## មុខវិជ្ជាៈ សិក្សាសង្គម

* ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦ )

# ថ្ងៃទី៥

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

**ចលនាចរន្តៈ ដើរ រត់ លោត វារ (ដើរតាមផ្លូវ រត់រំលងឧបសគ្គ លោតចូលកង ឬវង្វង់ វារក្រោមតុ)**

**១. វត្ថុបំណងៈ**

- កុមាររៀបរាប់ពីរបៀបធ្វើចលនានីមួយៗ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារធ្វើចលនានីមួយៗ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន បម្រុងប្រយ័ត្ន រង់ចាំវេន និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** ដុំថ្ម កង តុខ្ពស់

**៣. ការរៀបចំកុមារៈ** ចែកកុមារជាបីក្រុម ដោយឱ្យកុមារឈរជាជួរ

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនាំកុមារធ្វើសកម្មភាពដើរ ដោយឱ្យកុមារធ្វើចលនាដើរដូចពួកកងទ័ព ជ្រំជើងនៅមួយកន្លែង
- គ្រូណែនាំកុមារពីរបៀបធ្វើចលនាចរន្តនីមួយៗ(ដើរតាមផ្លូវបត់បែន រត់រំលងឧបសគ្គ លោតចូលកងឬវង្វង់ វារក្រោមតុ)
  - ដើរតាមផ្លូវបត់បែន ៖ ដើរតាមគំនូសដែលគ្រូគូរបត់បែនតាមទីតាំងកំណត់
  - រត់រំលងឧបសគ្គ ៖ រត់រំលងដុំថ្មឬប្រឡាយទឹកដែលគ្រូបានគូរ និង រៀបចំ(រំលងឧបសគ្គ)
  - លោតចូលកងឬវង្វង់ៈ លោតចូលកងឬវង្វង់ដោយកុំឱ្យប៉ះ
  - វារក្រោមតុៈ ធ្វើចលនាវារដោយកុំឱ្យខ្នងប៉ះតុ
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាបីក្រុម និង អនុវត្តតាមសកម្មភាពនីមួយៗៈ
  - ក្រុមទី១ៈ ដើរតាមផ្លូវបត់បែន រត់រំលងឧបសគ្គ លោតចូលកងឬវង្វង់ វារក្រោមតុ
  - ក្រុមទី២ៈ ធ្វើសកម្មភាពបន្ទាប់ពីកុមារក្រុមទី១ធ្វើទាំងអស់គ្នា
  - ក្រុមទី៣ៈ ធ្វើសកម្មភាពបន្ទាប់ពីកុមារក្រុមទី២ធ្វើទាំងអស់គ្នា
- **គ្រូសួរកុមារៈ**
  - **តើមុននេះ កូនៗបានធ្វើចលនាអ្វីខ្លះ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - **គ្រូសួរទៅកុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារថា **ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព មានចំណងជើងមេរៀនៈ "ចលនាចរន្ត ដើរ រត់ លោត វារ" (ដើរតាមផ្លូវបត់បែន រត់រំលងឧបសគ្គ លោតចូលកងឬវង្វង់ វារក្រោមតុ)**
- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយរបស់គ្រូឬទេ? បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្ត)
- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា**
- គ្រូឱ្យកុមារទាំងអស់មកឈរជារង្វង់រួចនាំកុមារធ្វើសកម្មភាពតាមមាន់រងាវចំនួន៤ដង( យកដៃទាំង២មកដាក់ជិតមាត់រួចស្រែកថា កុកគីកែកឺត កុកគីកែកឺត)។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ ត្រូវចេះចែករំលែកសម្ភារនិងនំចំណីឱ្យមិត្តភក្តិ(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៥ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

សម្គាល់៖ ធ្ងន់ និងស្រាល

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីវត្ថុធ្ងន់ និងស្រាល បានត្រឹមត្រូវ
- កុមារបង្ហាញវត្ថុធ្ងន់ និងស្រាល បានត្រឹមត្រូវ
- កុមារឈ្លាសវៃ រហ័សរហួន មានបម្រុងប្រយ័ត្ន ក្នុងការធ្វើកិច្ចការ ដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** ដបទឹក២ សៀវភៅ២ក្បាល កៅអី២ ដុំថ្មនិងគ្រាប់ក្រួស

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរ អ៊ុយ "U"

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- **គ្រូបំផុសសំណួរ៖**
  - ថ្ងៃនេះគ្រូមានសម្ភារជាច្រើនកូនចង់ដឹងទេ?
  - គ្រូបង្ហាញសម្ភារមានដបមានទឹក ដបអត់ទឹក ដុំថ្ម គ្រាប់ក្រួស សៀវភៅមួយក្បាលក្រាស់ មួយក្បាលទៀតស្តើង រួចឱ្យកុមារប្រាប់ឈ្មោះសម្ភារ
- តើសម្ភារទាំងអស់នេះយើងយកមកធ្វើអ្វី?
- គ្រូចែកកុមារជាបីក្រុម
  - ក្រុមទី១៖ គ្រូឱ្យកុមារម្នាក់មកលើកដបទឹក២( ដបមួយដាក់ទឹក ដបមួយទៀតអត់ទឹក)រួចសួរកុមារ ថាពេលកូនលើកទៅយ៉ាងម៉េចដែរ?
  - ក្រុមទី២៖ គ្រូឱ្យកុមារម្នាក់ទៀតមកលើកដុំថ្មនិងគ្រាប់ក្រួស រួចសួរកុមារថាពេលកូនលើកទៅយ៉ាងម៉េចដែរ?
  - ក្រុមទី៣៖ គ្រូឱ្យកុមារម្នាក់មកលើកសៀវភៅ២ក្បាល(មួយក្បាលក្រាស់ មួយក្បាលទៀតស្តើង) រួចសួរកុមារថាពេលកូនលើកទៅយ៉ាងម៉េចដែរ?
- គ្រូឱ្យកុមារផ្លាស់ប្តូរសម្ភារលេងទៅតាមក្រុមដោយមិនជាន់គ្នាកុមារអនុវត្ត គ្រូឱ្យតំណាងក្រុមឡើងរាយការណ៍ពីលទ្ធផលតាមក្រុម
- អម្បាញ់មិញកូនៗបានលេងល្បែងអ្វី ? តើថ្ងៃនេះកូនរៀមុខវិជ្ជាអ្វី? មេរៀនអ្វី?
- គ្រូប្រាប់ពីមុខវិជ្ជានិងចំណងជើង៖ ថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជា៖បុរេគណិត ចំណងជើង៖សម្គាល់ "**ធ្ងន់ និងស្រាល**"

- គ្រូផ្ទៀងផ្ទាត់ចម្លើយកុមារដែលបានឆ្លើយទៅនឹងអ្វីដែលគ្រូបានប្រាប់( តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយរបស់គ្រូឬទេ? បើកូនណាឆ្លើយត្រូវគ្រូលើកសរសើរ បើកូនឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើង ២ទៅ ៣ដង តាមក្រុម និងទាំងអស់គ្នា

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពកសាង៖ ហែក និងបិទរូប "ផ្លែក្រូច"

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបការហែក និងបិទរូបផ្លែក្រូច បានត្រឹមត្រូវ
- កុមារមានសមត្ថភាពក្នុងការហែក និងបិទរូបផ្លែក្រូច បានត្រឹមត្រូវ។
- បណ្តុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន អំណត់ព្យាយាម។

**២. សម្ភារបង្រៀន៖**

- គ្រូ៖រូបផ្លែក្រូចដែលមានហែកហើយចំនួន១សន្លឹក(រូបមានទំហំធំសម្រាប់បង្ហាញជារួម)
- ផ្ទាំងរូបផ្លែក្រូចដែលមានស្នាមចុចចំនួន២សន្លឹក(រូបមានទំហំធំសម្រាប់បង្ហាញជារួម)
- កុមារ៖ផ្ទាំងរូបភាពផ្លែក្រូចដែលមានស្នាមចុចគ្រប់ចំនួនកុមារ

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរ "ប"

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញរូបផ្លែក្រូចដែលហែកតាមស្នាមចុចឱ្យកុមារប្រាប់ពីរូបនោះ និងយកទៅបិទលើក្តារខៀនជាគំរូសម្រាប់កុមារសង្កេត
- គ្រូបង្ហាញរូបផ្លែក្រូចមួយផ្ទាំងមានស្នាមចុច។ រួចសួរកុមារ នេះជារូបអ្វី?តើមានស្នាមអ្វីនៅពីលើរូបនេះ? រួចយកមកបិទលើក្តារខៀនទន្ទឹមនឹងរូបគំរូដែលបានបង្ហាញមុន
- គ្រូណែនាំពីរបៀបហែករូបផ្លែក្រូចយឺតៗ ណែនាំបណ្តើរហែកបង្ហាញបណ្តើរ ដើម្បីឱ្យកុមារសង្កេតឱ្យបានច្បាស់ ហើយគ្រូត្រូវឈរធ្វើយ៉ាងណាឱ្យកុមារមើលឃើញគ្រប់ៗគ្នា
    - កូនយកដៃទាំងពីរកាន់ក្រដាស ដោយមេដៃនិងចង្អុលដៃស្តាំដាក់ជិតគ្នាកាន់មួយចំហៀងនិងមេដៃនិងចង្អុលដៃឆ្វេងកាន់មួយចំហៀងនៅផ្នែកខាងលើដែលមានស្នាមចុចជាបន្ទាត់បញ្ឈរ
    - ពេលចាប់ផ្តើមហែកត្រូវទាញដៃស្តាំចូលក្នុង ដៃឆ្វេងចេញក្រៅរួចប្តូរដៃគ្នាចុះឡើងៗ រហូតដល់រាងរូបផ្លែក្រូច
    - បន្ទាប់មកក៏បង្វិលដៃទាំងពីរហែកទៅតាមទម្រង់រូបផ្លែក្រូចហូតដល់រូបផ្លែក្រូចមួយចេញពីផ្ទាំងក្រដាស
    - ពេលកូនហែកក្រដាសដែលហែកសល់ត្រូវយកទៅដាក់កន្ត្រកសម្រាមដែលគ្រូបានរៀបចំទុកកុំចោលផ្តេសផ្តាសនៅក្នុងថ្នាក់
    - បន្ទាប់ពីហែករួចហើយកូនៗយកការមកលាបផ្នែកខាងក្រោយនៃរូបផ្លែក្រូចឱ្យសព្វទើបបិទក្នុងសៀវភៅរបស់កូនៗ

- គ្រូរៀបចំកុមារឱ្យអង្គុយជាជួរ និងឱ្យកុមារពីរនាក់មកយកសម្ភារទៅចែកមិត្តភក្តិគេអនុវត្ត
- គ្រូឱ្យកុមារចាប់ផ្តើមអនុវត្តជាបុគ្គលម្នាក់ៗ
- គ្រូដើរសម្របសម្រួលទៅតាមជួរនីមួយៗដោយជួយកុមារណាដែលមិនទាន់ចេះធ្វើនិងដាក់ឈ្មោះនៅលើរូបផ្លែក្រូចដែលគេបានហែករួចនៅផ្នែកខាងក្រោម។
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់កុមារម្នាក់ៗរួចឱ្យកុមារចេញម្តងមួយជួរៗ ឱ្យឈរពីមុខមិត្តភក្តិគេដោយកាន់រូបដាក់ត្រឹមដើមទ្រូងដើម្បីបង្ហាញ
- **គ្រូសួរកុមារ៖** តើរូបមិត្តភក្តិយើងធ្វើបានត្រឹមត្រូវទេ? ហែកបិទបានស្អាតទេ?
- **គ្រូនិយាយប្រាប់កុមារ៖** ពេលក្រុមកូនបង្ហាញរួចហើយកូនកាន់រូបនេះទៅអង្គុយកន្លែងដើមវិញ។
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផល មិនត្រូវបង្អាប់កុមារដែលធ្វើមិនទាន់បានល្អនោះទេ។គ្រូត្រូវចេះសរសើរលើកទឹកចិត្តកុមារឱ្យបានគ្រប់ៗគ្នាដើម្បីឱ្យពួកគេប្រឹងប្រែងបន្តទៀត
-គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតទាល់តែគ្រប់កុមារទាំងអស់
-គ្រូឱ្យតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការកុមារម្នាក់ៗជូនគ្រូទុកសម្រាប់ដាក់តាំងស្នាដៃកុមារនៅលើផ្ទាំងស្នាដៃកុមារនៅថ្ងៃបន្ទាប់
-គ្រូត្រូវដាក់ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជានិងចំណងជើងនៅក្បាលលើសន្លឹកកិច្ចការ មុននឹងយកទៅដាក់តាំងស្នាដៃកុមារ

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

## កំណាព្យ៖ ត្រូវញ៉ាំបន្លែពណ៌បៃតង

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីចំណងជើង និងអត្ថន័យនៃកំណាព្យ "**ត្រូវញ៉ាំបន្លែបៃតង**" បានត្រឹមត្រូវ
- កុមារសូត្រកំណាព្យត្រូវតាមវាក្យស័ព្ទនិងទំនុកបទបានត្រឹមត្រូវ
- កុមារមានភាពក្លាហាន ស្រឡាញ់ និងចូលចិត្តកំណាព្យ។

**២. សម្ភារបង្រៀន៖** សៀវភៅអត្ថបទកំណាព្យ

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរ "U"

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- ថ្ងៃនេះគ្រូនឹងយកមេរៀនកំណាព្យមួយមកបង្រៀនកូនៗទាំងអស់គ្នា
- គ្រូសូត្រកំណាព្យឱ្យកុមារស្តាប់មួយចប់សិនដើម្បីឱ្យកុមារយល់អត្ថន័យនៃកំណាព្យ
- គ្រូអានអត្ថបទ និងរកពាក្យពិបាក
- គ្រូប្រាប់និងពន្យល់ពាក្យពិបាក
    - អាហារ៖ គ្រឿងសម្រាប់ញ៉ាំចម្អែត
    - ការពារ៖ ឃាត់ឃាំង រាំងរា
- **គ្រូសួរកុមារ៖** តើកំណាព្យដែលគ្រូបានសូត្រគេចង់និយាយពីអ្វី?
- គ្រូនាំកុមារសូត្រកំណាព្យឃ្លាទី១ ឱ្យបានមួយចប់គ្រប់ៗគ្នា បន្ទាប់មកកុមារសូត្រឃ្លាទី២
- ពេលកុមារសូត្រកំណាព្យ ឃ្លាទី១ ឃ្លាទី២ រួចឱ្យកុមារសូត្រឃ្លាទាំងពីររួមបញ្ចូលគ្នា

- គ្រូនាំកុមារសូត្រឃ្លាបន្តបន្ទាប់តាមរបៀបខាងលើរហូតដល់ចប់នៃអត្ថបទកំណាព្យ
- គ្រូឱ្យកុមារសូត្រកំណាព្យសាឡើងវិញរួមគ្នា ១ឬ២ចប់
- គ្រូសួរកុមារ តើអម្បាញ់មិញកូនរៀនមុខវិជ្ជាអ្វី ?មេរៀនអ្វី ?អ្នកនិពន្ធឈ្មោះអ្វី ?( កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ )
- គ្រូប្រាប់ថា ថ្ងៃនេះយើងរៀនមុខវិជ្ជាៈភាសាខ្មែរ មេរៀន កំណាព្យ "**ត្រូវញុំាបន្លែបៃតង**" អ្នកនិពន្ធដោយលោកអ៊ុំនៅក្រសួងអប់រំ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម និងទាំងអស់គ្នា

អត្ថបទកំណាព្យ "ត្រូវញុំាបន្លែពណ៌បៃតង" ( បទព្រហ្មគិតិ )

-មិត្តអើយចូរចងចាំ　　នៅពេលញុំាបាយម្តងៗ
ញុំាបន្លែបៃតង　　ម៉ាក់ផ្តាំផងកុំរេរា ។
-ស្លឹកបាស់ធ្មីខាត់ណា　　ជាអាហារជួយការពារ
សុខភាពមិត្តគ្រប់គ្នា　　ជានាបានរីកធំធាត់។

**ម៉ោងទី៦ (រយៈពេល ៣០នាទី)**

## មុខវិជ្ជាៈ សិក្សាសង្គម

✱ ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦ )

# ថ្ងៃទី៦

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

## ល្បែងចលនា៖ ដណ្តើមស្លឹកឈើ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបរត់ដណ្តើមស្លឹកឈើ បានត្រឹមត្រូវ
- កុមាររត់ដណ្តើមស្លឹកឈើ បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន ប្រុងប្រយ័ត្ន សហការ និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** មែកឈើមានស្លឹក មួយមែក

**៣. ការរៀបចំកុមារ៖** រៀបចំកុមារជា២ក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនាំកុមារឈរតម្រង់ជួរ ជា២ជួរ
- គ្រូនាំកុមារ រត់នៅមួយកន្លែង រត់ទៅមុខតិចៗ រត់ថយក្រោយតិចៗ
- គ្រូបង្ហាញមែកឈើដែលមានស្លឹកឱ្យកុមារសង្កេត រួចសួរកុមារថា ចូរកូនទាយទៅមើលថា តើគ្រូនឹងនាំកូនលេងល្បែងអ្វីជាមួយនឹងមែកស្លឹកឈើនេះ? (កុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ)
- **គ្រូណែនាំពីរបៀបលេងដល់កុមារ៖** ល្បែងនេះតម្រូវឱ្យកូនចែកគ្នាជា២ក្រុមស្មើៗគ្នា រួចឈរនៅលើម្ខាងនៃទីកំណត់ខ្សែគំនូសកំណត់ជាទីគោលដៅ ដោយក្រុមនីមួយៗត្រូវមានគម្លាតពីចំណុចដៅដាក់មែកឈើចម្ងាយ ៦ ម៉ែត្រ ដែលមានមែកស្លឹកឈើមួយនេះ នៅចំកណ្តាល ដោយមានគ្រូជាអាជ្ញាកណ្តាលជាអ្នកផ្តល់សញ្ញាដល់កូនៗក្រុមទាំង២។ តែមុននឹងលេង ក្រុមនីមួយៗត្រូវកំណត់លេខសម្គាល់សមាជិកក្រុមរបស់ខ្លួន ហើយឈរទៅតាមលំដាប់លេខរៀងឱ្យបានត្រឹមត្រូវគិតចាប់ពីលេខ១ ដល់លេខចុងក្រោយនៃចំនួនសមាជិកក្នុងក្រុមរបស់កូននីមួយៗ។ នៅពេលដែលអាជ្ញាកណ្តាលហៅលេខរៀងកូនណាមួយ កូនដែលឮលេខរៀងនោះត្រូវរត់ទៅដណ្តើមមែកស្លឹកឈើដែលនៅចំកណ្តាលឱ្យឆាប់រហ័ស។ ប្រសិនបើដៃគូម្ខាងយកមែកឈើលឿនជាង ពេលនោះកូននៅក្រុមម្ខាងទៀតត្រូវដេញចាប់ឬប៉ះឱ្យបានមុនពេល ដែលគេរត់មកដល់ទីរបស់គេ។ ក្រុមណាដែលដណ្តើមស្លឹកឈើបានច្រើនដងជាងគេ គឺជាអ្នកឈ្នះ។ កូនៗក្រុមដែលឈ្នះ មានសិទ្ធិឱ្យក្រុមដែលចាញ់ធ្វើសកម្មភាពអ្វីមួយក៏បាន។
- គ្រូឱ្យកុមារ១ទៅ២នាក់ និយាយពីរបៀប និងលក្ខខណ្ឌនៃលេងឡើងវិញ
- គ្រូបែងចែកកុមារជាក្រុមស្មើៗគ្នា និងកំណត់លេងរៀងឱ្យកុមារក្នុងក្រុមនីមួយៗ ហើយឱ្យឈរទៅតាមខ្សែគំនូសដែលបានកំណត់ជាគោលដៅសម្រាប់ក្រុមនីមួយៗ
- គ្រូចាប់ផ្តើមនាំកុមារលេងសាកល្បង ១ ទៅ២ គូសិន ដោយគ្រូជាអាជ្ញាកណ្តាល និងនាំកុមារអនុវត្តតាមរបៀប និងលក្ខខណ្ឌនៃការលេងដែលបានណែនាំរួច
- គ្រូនាំកុមារលេង និងសម្របសម្រួលដំណើរការលេង ដោយផ្ទៀងផ្ទាត់ទៅនឹងលក្ខខណ្ឌដែលបានប្រាប់ រហូតកំណត់បានក្រុមដែលឈ្នះ បន្ទាប់ពីរកក្រុមឈ្នះឃើញគ្រូសួរ តើកូនចង់ឱ្យកូនៗក្រុមដែលចាញ់ធ្វើអ្វី? គ្រូសម្របសម្រួលការធ្វើសកម្មភាពដែលក្រុមឈ្នះ ដាក់ឱ្យក្រុមចាញ់ធ្វើ។

- គ្រូលើកសរសើរចំពោះអ្នកដែលឈ្នះ ចំពោះអ្នកចាញ់គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទះបង្អាប់កុមារឡើយ
- គ្រូនាំកុមារធ្វើចលនាផ្លុំកម្ទេចតូចៗដែលនៅលើសៀវភៅ ដោយឱ្យកុមារលាបាតដៃទាំងពីរធ្វើជាសៀវភៅដាក់មកជិតមាត់ ស្រូបខ្យល់ចូល ហើយផ្លុំខ្យល់ចេញ៣ទៅ៤ដង (កូនៗផ្លុំខ្យល់ដង្ហើមចេញមកក្រៅវែងៗដូចជាការផ្លុំកម្ទេចដែលនៅលើសៀវភៅឱ្យជ្រុះ) រួចគ្រូសួរកុមារថា តើកម្ទេចនៅលើសៀវភៅរបស់កូនជ្រុះអស់ឬនៅ?
- គ្រូសួរកុមារ ៖
  - តើមុននេះ កូនៗបានលេងល្បែងអ្វី?
  - តើកូនធ្វើចលនាអ្វីខ្លះក្នុងការលេងល្បែងនេះ? ហើយល្បែងនេះគួរលេងនៅពេលណា?
  - តើថ្ងៃនេះកូនរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព មេរៀនល្បែងចលនា " **ដណ្ដើមស្លឹកឈើ** "
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ទាំងអស់គ្នា
-

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

∗ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូចខែទី៣ ថ្ងៃទី១ ម៉ោងទី២)

∗ ទម្លាប់ល្អ៖ ត្រូវចេះស្ដាប់ដំបូន្មានគ្រូ និងឪពុកម្ដាយ

- គ្រូនិទានរឿងខ្លី៖ មានកុមារីតូចម្នាក់រស់នៅជាមួយម្ដាយនៅក្បែរព្រៃមួយ ថ្ងៃមួយម្ដាយនាងចេញទៅក្រៅ ហើយហាមកូនមិនឱ្យដើរចេញពីផ្ទះទៅលេងឆ្ងាយនោះទេ ខ្លាចមានគ្រោះថ្នាក់។ ពេលម្ដាយនាងទៅបាត់ កុមារីតូចក៏បានចេញទៅដើរលេងដែរ ហើយក៏មានឆ្កែចចកមួយ បានដើរសំដៅមករកកុមារីតូចនោះ នាងភ័យណាស់ក៏រត់យ៉ាងលឿន រត់ផងយំផង ដល់កណ្ដាលផ្លូវក៏ជួបម្ដាយនាង។ ឆ្កែចចកក៏បានរត់ត្រឡប់ទៅក្រោយវិញ ពេលឃើញម្ដាយនាង ។ កុមារីតូចក៏បានទៅផ្ទះជាមួយម្ដាយនាងវិញ ហើយម្ដាយនាងក៏បានស្ដីបន្ទោសនាងជាច្រើន។
- គ្រូសួរកុមារ៖
  - តើកុមារីតូចនោះធ្វើរបៀបនេះត្រឹមត្រូវឬទេ? តើកុមារីតូចត្រូវធ្វើដូចម្ដេច? បើមិនត្រឹមត្រូវទេតើកូនគួរតែធ្វើដូចម្ដេចទើបជាកូនល្អ ដែលស្ដាប់ដំបូន្មានឪពុកម្ដាយ?
  - នៅពេលមកសាលារៀនគ្រូបានណែនាំកូនមិនឱ្យឈ្លោះគ្នា តើកូនឈ្លោះគ្នាឬទេ? បើគ្រូមិនឱ្យប្រលែងគ្នាលេងពេលបង្រៀន តើកូនធ្វើដូចម្ដេច?
- គ្រូណែនាំកុមារបន្ថែម៖ កូនៗត្រូវស្ដាប់អ្វីដែលឪពុកម្ដាយកូនបានប្រាប់ ហើយត្រូវធ្វើអ្វីតាមការប្រាប់របស់ពួកគាត់។ ពេលមកសាលារៀនកូនត្រូវស្ដាប់គ្រូរាល់ពេលដែលគ្រូបានណែនាំទើបជាកូនល្អ។

∗ គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៦ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ បុរេគណិត

## ប្រៀបធៀបៈ ធ្ងន់ជាង និងស្រាលជាង

### ១. វត្ថុបំណងៈ

- កុមារប្រាប់បានពីបញ្ញត្តិ ធ្ងន់ជាង ស្រាលជាង បានត្រឹមត្រូវ
- កុមារ ប្រៀបធៀបវត្ថុធ្ងន់ជាង និងស្រាលជាង បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ ព្យាយាម និងចូលរួមយ៉ាងសកម្ម ។

### ២. សម្ភារបង្រៀនៈ

- ថង់ចំនួន២ ប៉ុនគ្នា (ថង់ទី១ច្រកខ្សាច់ពេញដោយបិទស្លាកសម្គាល់លេខ១ ហើយថង់មួយទៀតច្រកខ្សាច់តិចជាងដោយបិទស្លាកសម្គាល់លេខ២)
- ផ្ទាំងក្រដាសធំដែលបែងចែកជា២ ផ្នែក (ផ្នែកទី១មានពណ៌ក្រហមតាងឱ្យធ្ងន់ជាង ផ្នែកទី២មានពណ៌បៃតងតាងឱ្យស្រាលជាង)
- បណ្ណលេខ ១ និងលេខ២ (អាស្រ័យចំនួនកុមារជាក់ស្តែង)
- ស្កុត...

**៣. ការរៀបចំកុមារៈ** ឱ្យកុមារអង្គុយជាអក្សរ "U" ឈរជារង្វង់

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរកុមារថាៈ តើកូនធ្លាប់លើកវត្ថុអ្វីដែរឬទេ? តើវត្ថុទាំងនោះជាវត្ថុអ្វីខ្លះ?
- គ្រូបង្ហាញសម្ភារដែលបានរៀបចំរួច ឱ្យកុមារសង្កេត ហើយឱ្យកុមារប្រាប់ឈ្មោះ
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេងៈ**
    - គ្រូឱ្យកូនលេងទាំងអស់គ្នា ដូច្នេះកូនត្រូវឈរជារង្វង់ ដោយកូនៗត្រូវចំណាំពីស្លាកលេខសម្គាល់នៃថង់ទាំង២ឱ្យច្បាស់
    - បន្ទាប់មកកូនហុចថង់ខ្សាច់នេះបន្តគ្នា ដោយចាប់ផ្តើមពីថង់ខ្សាច់ស្លាកលេខ១មុន បន្ទាប់មកថង់ខ្សាច់ស្លាកលេខ២ ហើយកូនៗត្រូវកំណត់សម្គាល់នូវទម្ងន់របស់ថង់ខ្សាច់នីមួយៗពេលហុចបន្តគ្នាផង។
    - បន្ទាប់ពីកូនបានកាន់ថង់ខ្សាច់ទាំងពីរគ្រប់គ្នាហើយ កូនត្រូវរើសបណ្ណលេខនៅលើតុរបស់គ្រូ ទៅបិទលើផ្ទាំងក្រដាសដែលបែងចែកធ្ងន់ជាង និងស្រាលជាង។ ពេលដែលកូនៗឡើងបិទត្រូវ ប្រុងប្រយ័ត្ន កុំដណ្តើមគ្នា ត្រូវឡើងម្តងម្នាក់ៗ។
- គ្រូឱ្យកុមារ១ ឬ ២នាក់និយាយឡើងវិញពីរបៀបលេងតាមដំណាក់កាលនីមួយៗ (បើកុមារនិយាយមិនបាន គ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូនាំកុមារលេងទាំងអស់គ្នា (បើសល់ពេលអាចលេង២ឬ៣ដង)
- គ្រូ និងកុមារផ្ទៀងផ្ទាត់ វាយតម្លៃលទ្ធផលនៃការឡើងបិទបង្ហាញរបស់កុមារ ដោយលើកសសើរ និងលើកទឹកចិត្តដល់កុមារដែលបានខិតខំប្រឹងប្រែង
- គ្រូប្រាប់កុមារថា"ដូចនេះ ថង់ខ្សាច់ទី១ ធ្ងន់ជាង ថង់ខ្សាច់ទី២ ឬថង់ខ្សាច់ទី២ ស្រាលជាងថង់ខ្សាច់ទី១"
- គ្រូសួរកុមារៈ តើមុខវិជ្ជាអ្វីដែលកូនរៀននៅម៉ោងនេះ? តើមានចំណងជើងមេរៀនអ្វី?(កុមារឆ្លើយតាមការចងចាំ)

- គ្រូប្រាប់កុមារៈ ថ្ងៃនេះកូនរៀនមុខវិជ្ជា បុរេគណិត មេរៀន **ល្បែងប្រៀបធៀប ធ្ងន់ជាង និងស្រាលជាង។**
- គ្រូនាំកុមារអានចំណងជើងជាក្រុម និងទាំងអស់គ្នា (២ឬ៣ដង)

(ម៉ោងទី៤ រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## រឿងនិទានៈ ការអត់ឱន (និទាន)

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីសកម្មភាពតួអង្គតាមដំណើររឿង បានត្រឹមត្រូវ
- កុមារនិទានរឿងនិងវិភាគតួអង្គនៅក្នុងរឿងបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ យកគំរូតាមតួអង្គល្អ សហការជួយគ្នា និទានរឿងឱ្យមិត្តភក្តិស្តាប់ ។

**២. សម្ភារបង្រៀនៈ** សៀវភៅរឿងនិទាន

**៣. ការរៀបចំកុមារៈ** ជាអក្សរអ៊ុយ "ប" អង្គុយលើកន្ទេល

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរកុមារៈ នៅពេលកូនៗ ធ្វើអ្វីខុសទៅលើនរណាម្នាក់ តើកូនៗត្រូវធ្វើដូចម្តេច?(កុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ)
- ថ្ងៃនេះគ្រូនិទានរឿងមួយឱ្យកូនស្តាប់គឺរឿង « ការអត់ឱន »
- គ្រូប្រាប់កុមារៈ ថ្ងៃនេះយើងរៀនមុខវិជ្ជាសិក្សាសង្គម ចំណងជើងមេរៀន រឿងនិទាន« ការអត់ឱន » រួចឱ្យកុមារអានតាម (ជាក្រុម និងទាំងអស់គ្នា )
- គ្រូប្រាប់ឈ្មោះអ្នកនិពន្ធៈ រឿងនិទាននេះនិពន្ធដោយអ៊ុំៗនៅក្រសួងអប់រំ យុវជននិងកីឡា
- គ្រូនិទានរឿងឱ្យកុមារស្តាប់ ដោយលើកដាក់សំឡេងតាមតួអង្គនៃសាច់រឿង
- គ្រូនាំកុមារអានពាក្យពិបាក និងពន្យល់ពាក្យៈ
    - អត់ឱនៈ អត់ទ្រាំ មិនប្រកាន់ទោស
    - រពឹសៈ នៅមិនស្ងៀម
    - ស្ទុះបម្រុងៈ រត់ តាំងចិត្តប្រុងវាយ
    - អភ័យទោសៈ លើកទោស មិនយកទោស
    - ប្រស្នាៈ បញ្ហា
    - ភ្ញិផ្កាៈ ផ្កាកម្រង
    - ម្ជុដៈ គ្រឿងធ្វើពីមាស
- គ្រូសួរកុមារៈ តើនៅក្នុងរឿងនេះមានតួអង្គប៉ុន្មាន?ឈ្មោះអ្វីខ្លះ? តើកូនស្រឡាញ់តួអង្គណាជាងគេ? ព្រោះអ្វី?
- គ្រូពន្យល់អត្ថន័យរឿង គឺអប់រំកូនឱ្យចេះឃោគយល់ អធ្យាស្រ័យអត់ឱនឱ្យគ្នា ពិសេសនៅពេលមានបញ្ហាអ្វីមួយកើតឡើង និងចេះចែករំលែកសម្ភារ ឬ នំចំណីគ្នាញុាំ
- គ្រូឱ្យកុមារនិទានឡើងវិញ បើកុមារនិតានមិនទាន់បានពេញលេញ មិត្តភក្តិនិងគ្រូជួយបំពេញបន្ថែម

រឿងនិទាន «**ការអត់ឱន** »

កាលពីព្រេងនាយមានកូនស្វាដ៏សែនពើសមួយឈ្មោះពីនពីន។ ពីនពីនមិនចេះនៅស្ងៀមតែងតែរត់លេងហក់លោតចុះឡើងពីដើមឈើមួយទៅដើមឈើមួយ។ ពីនពីនបានឃើញមិត្តភក្តិកំពុងចែកផ្លែចាន់គ្នាហូបយ៉ាងឆ្ងាញ់វាលេបទឹកមាត់ក្អឹកៗ ក៏ដាច់ចិត្តសុំមិត្តភក្តិភ្លក្សមួយម៉ាត់។ ពិតជាឆ្ងាញ់មែន !តើវាមាននៅឯណា ? ពីនពីនសួរ។ នៅក្នុងព្រៃខាងមុខឯនោះគ្រាន់តែស្ដាប់មិត្តភក្តិនិយាយចប់ពុំទាន់ពីនពីន រត់យ៉ាងលឿនចូលទៅក្នុងព្រៃ។ កំពុងតែធ្វើដំណើរ ស្រាប់តែកូនស្វាតូចមួយរត់មកបុកពីនពីនដួលទាំងពីរនាក់ ពីនពីនមិនប្រកាន់ឡើយស្ទុះងើបទៅជួយលើកកូនស្វាឱ្យងើបឈរ រួចបង្វិលខ្លួនមើលដើម្បីឱ្យប្រាកដក្នុងចិត្តថាពុំមានរបួស ហើយវាក៏រត់ទៅមុខទៀតយ៉ាងលឿន បានទៅដល់ដើមចាន់។ ពីនពីនឈោងដៃបេះផ្លែចាន់ ស្រាប់តែសំឡេងដើមចាន់ឃាត់ថាៈឯងត្រូវតែរកប្រស្នាឱ្យឃើញចំនួន៣ អំពីការអត់ឱនមកប្ដូរផ្លែចាន់នេះទើបបាន។

ពីនពីនសំឡឹងផ្លែចាន់ដោយលេបទឹកមាត់ហើយក៏អង្គុយសណ្ដូកជើងគិតបែបអស់សង្ឃឹម គិតចុះគិតឡើងនៅតែនឹកមិនឃើញ។ រំពេចនោះមានពស់មួយវារកាត់លើជើងពីនពីនខឹងមួម៉ៅ ក៏លូកដៃចាប់កពស់បម្រុងនឹងបោកតែបែរជាអាណិត ហើយក៏ព្រលែងពស់នោះវិញ។យី ! នរណាគប់មែកឈើត្រូវក្បាលខ្ញុំហ្នឹង? ពីនពីនអង្អែលក្បាលឈឺផង ខឹងផងស្ទុះបម្រុងទៅវាយកូនស្វាដែលឈរគប់ផ្លែចាន់ពីក្រោយខ្នង កូនស្វាសំពះសុំអភ័យទោសពីនពីន។ ពីនពីនរសាយកំហឹងហើយក៏ចាប់ដៃកូនស្វានោះឱ្យមកជួយគិតគ្នាផ្លែចាន់ពណ៌មាសមួយយ៉ាងធំបានធ្លាក់មកលើដៃពីនពីនឆ្ងល់ណាស់ក៏សួរទៅដើមចាន់ថាៈខ្ញុំពុំទាន់បានដោះស្រាយប្រស្នាឱ្យបង! តើហេតុអ្វីបានជាបងឱ្យចាន់ដ៏ក្រអូបឆ្ងាញ់នេះមកខ្ញុំ ? ដើមចាន់តបៈចូរឯងគិតទៅមើល ! ចាប់ពីពេលដែលឯងធ្វើដំណើររហូតដល់ពេលនេះតើពីនពីនបានធ្វើអ្វីខ្លះបានប៉ុន្មានដង ?ដែលទាក់ទងនឹងប្រស្នាអត់ឱននេះ? ពីនពីនគិតមួយសន្ទុះញញឹមនិងនិយាយថាៈ ខ្ញុំយល់ហើយៗ ! សូមអរគុណបងដើមចាន់ច្រើនណាស់ ! ជម្រាបលាបង ! ត្រឡប់ទៅវាំងវិញ នៅតាមផ្លូវពីនពីនចែកផ្លែចាន់ឱ្យកូនស្វាញ៉ាំជាមួយដែរ ចំណែកខ្លួនពីនពីន មានពណ៌មាសខុសពីធម្មតា។ មកដល់វាំងពីនពីនភ្ញាក់ផ្អើលយ៉ាងខ្លាំងឃើញមានការតុបតែងភ្លីផ្កា មានក្បួនឈរអមតាមផ្លូវ ខ្លះទះដៃ ខ្លះគ្រវីផ្កាអបអរសាទរ ពីនពីនបានពាក់មកុដអំពីមាសនិងបានឡើងសោយរាជ្យ។

ម៉ោងទី៨ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

## សម្គាល់តួអក្សរៈ "ដ"

### ១. វត្ថុបំណងៈ

- កុមារប្រាប់ពីរូបរាង និងឈ្មោះតួអក្សរ "**ដ**" បានត្រឹមត្រូវ
- កុមារកំណត់បានពីរូបរាងតួអក្សរ "**ដ**" និងរកពាក្យថ្មីផ្ដើមចេញពីតួអក្សរ "**ដ**" បានត្រឹមត្រូវ
- កុមារក្លាហាន និងយកចិត្តទុកដាក់ ព្យាយាមក្នុងការរកពាក្យថ្មីផ្ដើមពីអក្សរ"**ដ**"។

### ២. សម្ភារបង្រៀនៈ

- ផ្ទាំងរូបភាព ដំរី ដៃ ដូង
- បណ្ណពាក្យ ដំរី ដៃ ដូង និងល្បះ ដាដាំដើមដូង
- ប៊ិក ហ្វឺត ស្កុត (កាត់រៀបចំឱ្យហើយ)

### ៣. ការរៀបចំកុមារៈ អង្គុយជាអក្សរ អ៊ុយ "U"

៤. **ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

**+ រកពាក្យ និងឃ្លា**

- គ្រូបង្ហាញផ្ទាំងរូបភាព "ដំរី" ដោយបិទបាំងបញ្ចេញខាងលើបន្តិច ខាងក្រោមបន្តិច ខាងឆ្វេងបន្តិច ខាងស្តាំបន្តិច រួចឱ្យកុមារទាយ
- បើករូបបង្ហាញ ដើម្បីផ្ទៀងផ្ទាត់ចម្លើយ (បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត ហើយយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចបង្ហាញប័ណ្ណពាក្យ "ដំរី" បិទពីក្រោមរូប រួចនាំកុមារអានទាំងរូប និងពាក្យដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញរូបភាព"**ដៃ**" ដោយលាស់មួយភ្លែតឱ្យកុមារឃើញ ហើយឱ្យកុមារទាយ បន្ទាប់មកគ្រូបង្ហាញរូបដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន រួចបង្ហាញបណ្ណពាក្យ "**ដៃ**" ហើយបិទពីក្រោមរូប និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូឱ្យកុមារមួយនាក់ចេញទៅក្រៅថ្នាក់ ហើយមើលផ្ទាំងរូបភាព "**ដូង**" រួចហើយឱ្យចូលថ្នាក់វិញ ហើយខ្សឹបពាក្យ "**ដូង**" បន្តគ្នាឱ្យបាន ០៥នាក់។ ខ្សឹបដល់អ្នកទី០៥ ត្រូវឱ្យអ្នកទី០៥ និយាយប្រាប់មិត្តភក្តិៗពាក្យអ្វី? រួចសួរអ្នកទី១វិញ ត្រឹមត្រូវឬទេ? បន្ទាប់មក គ្រូបង្ហាញរូបភាព "**ដូង**" ដើម្បីផ្ទៀងផ្ទាត់ចម្លើយបើមានកុមារឆ្លើយត្រូវ សរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្តារខៀន ហើយបង្ហាញបណ្ណពាក្យ"**ដូង**" និងបិទពីក្រោមរូបភាព និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញឃ្លា "**ដាដាំដើមដូង**" អានឱ្យកុមារស្តាប់រួចយកបិទពីក្រោមពាក្យ
- នាំកុមារអានរូប ពាក្យ និងឃ្លា (២ដង) គ្រូនាំកុមារអានផង និងចង្អុលផង។

**+ ស្តាប់សូរពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារស្តាប់ (២ឬ៣ចប់) ដើម្បីឱ្យកុមារទាយសូរ និងញែកសូរនៃពាក្យ និងឃ្លា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- សួរកុមារ តើពាក្យ និងឃ្លាដែលគ្រូបានអានអំបាញ់មិញឮសូរដូចម្តេច? (ពេលកុមារឆ្លើយគ្រូមិនបាច់វាយតម្លៃត្រូវឬខុសទេ)។

**+ ពិនិត្យរូបរាងអក្សរនៅក្នុងពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារសង្កេត (២ឬ៣ចប់) ដើម្បីឱ្យកុមារពិនិត្យរករូបរាងតួអក្សរដែលមានរាងដូចគ្នាច្រើន (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- គ្រូឱ្យកុមារដែលស្ម័គ្រចិត្តឡើងមកគូសវង់ជុំវិញតួអក្សរដែលមានរាងដូចគ្នាច្រើន (ពេលកុមារឡើងមកគូសជុំវង់វិញអក្សរមានរាងដូចគ្នាច្រើន បើកុមារចង់គូស ឱ្យគេគូសតាមចិត្តរបស់គេ គ្រូមិនត្រូវបញ្ឈប់ឬបង្ខំគេឡើយ)
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលទាំងអស់គ្នា បើមានកុមារគូសវង់ខុសត្រូវឱ្យកុមារដទៃជួយកែតម្រូវ។ នាំកុមាររាប់ចំនួនអក្សរដែលកុមារគូសវង់ដើម្បីផ្ទៀងផ្ទាត់ពីចំនួនច្រើន។

**+ ប្រាប់ឈ្មោះតួអក្សរ៖**

- សួរកុមារ តើតួអក្សរដែលកូនគូសវង់ជុំវិញនៅក្នុងពាក្យ និងឃ្លានោះឈ្មោះអក្សរអ្វី? បើកុមារឆ្លើយមិនត្រូវទេនោះ គ្រូត្រូវប្រាប់រួចនាំកុមារអាន (ក្រុមរួចទាំងអស់គ្នា)

- គ្រូបង្ហាញអក្សរចល័ត "ដ" រួចសួរកុមារ អក្សរដែលគ្រូបង្ហាញនេះរាងដូចអក្សរដែលកូនបានគូសវង់នោះឬទេ? បើដូច ឈ្មោះអក្សរអ្វីដែរ?
- គ្រូសរសេរអក្សរ"ដ" យ៉ាងធំនៅជ្រុងក្ដារខៀន ដើម្បីឱ្យកុមារសង្កេតពីទិសនៃសំណេរ
- គ្រូសួរកុមារ អក្សរដែលគ្រូសរសេរនេះតើដូចអក្សរដែលគ្រូបង្ហាញនេះដូចអក្សរដែលកូនគូសវង់ឬទេ? ឈ្មោះអ្វី?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនអក្សរ"ដ" នាំកុមារអានអក្សរ"ដ" (ក្រុមរួចទាំងអស់គ្នា) ឱ្យបាន២ឬ៣ដង
- គ្រូសរសេរចំណងជើងមេរៀនលើក្ដារខៀន រួចនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន (ក្រុមរួចទាំងអស់គ្នា)

**+ ប្រៀបធៀបអក្សរស្រដៀង៖**

- គ្រូសរសេរអក្សរ "ដ ជ ផ " នៅលើក្ដារខៀន
- គ្រូអានអក្សរ "ដ ជ ផ " ឱ្យកុមារស្ដាប់ និងសង្កេត
- សួរកុមារ តើអក្សរទាំងអស់នេះមានលក្ខណៈដូចគ្នានៅត្រង់ណាខ្លះ? ហើយខុសគ្នាត្រង់ណាខ្លះ?
- កុមារនិយាយប្រាប់ផងឡើងមកចង្អុលផង។

**+ រកពាក្យថ្មីផ្ដើមពីអក្សរ"ដ" ៖**

- គ្រូអានពាក្យ និងឃ្លាសាឡើងវិញឱ្យបានច្រើនដងដើម្បីឱ្យកុមារស្ដាប់សូរ
- ឱ្យកុមាររកពាក្យថ្មីដែលផ្ដើមពីអក្សរ"ដ"
- គ្រូសរសេរពាក្យដែលកុមាររកបាននៅលើក្ដារខៀនទាំងអស់ទាំងពាក្យត្រឹមត្រូវ និងពាក្យមិនត្រឹមត្រូវ
- នាំកុមារផ្ទៀងផ្ទាត់ដោយគ្រូអានម្ដងមួយពាក្យៗ រួចសួរកុមារតើពាក្យនេះមានអក្សរ"ដ" ឬទេ? បើត្រឹមត្រូវគ្រូគូសវង់ជុំវិញពាក្យនោះ។ បើពាក្យខុសគ្រូមិនត្រូវធ្វើអ្វីទាំងអស់។ គ្រូធ្វើរបៀបនេះទាល់តែអស់ពាក្យដែលកុមាររកបាន។
-

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

## ល្បែង៖ ផ្ទាត់កៅស៊ូប្រណាំងគ្នា

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបធ្វើចលនាម្រាមដៃផ្ទាត់កៅស៊ូប្រណាំងគ្នាបានត្រឹមត្រូវ
- កុមារធ្វើចលនាម្រាមដៃផ្ទាត់កៅស៊ូប្រណាំងគ្នា បានត្រឹមត្រូវ
- កុមារព្យាយាម អំណត់ សហការ ប្រុងប្រយ័ត្ន រហ័សរហួន ទន់ភ្លន់ និងសប្បាយរីករាយ

**២. សម្ភារបង្រៀន៖** មានកៅស៊ូកង(ចំនួនអាស្រ័យទៅតាមកុមារ)

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរ "ប" កុមារអង្គុយជារង្វង់តាមក្រុមតូចៗ

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់ពីមុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមជាក្រុមនិងទាំងអស់គ្នា
- គ្រូដាក់កញ្ចប់សម្ភារនៅលើតុពីមុខកុមាររួចឱ្យកុមារស្ម័គ្រចិត្តចំនួន ១ទៅ២នាក់មកស្ទាបហើយទាយសម្ភារនៅក្នុងកញ្ចប់រួចឱ្យទៅអង្គុយកន្លែងដើមវិញ
- គ្រូឱ្យកុមារ១នាក់ឡើងមកលូកយកសម្ភារនៅក្នុងកញ្ចប់នោះចេញមួយចំនួន រួចសួរកុមារ តើមិត្តភក្ដិយើង៣នាក់អម្បាញ់មិញ មានអ្នកណាទាយត្រូវទេ?គ្រូសរុបចម្លើយរបស់កុមារ

- គ្រូឱ្យកុមារទាំងអស់ទះដៃសរសើរមិត្តភក្តិដែលបានទាយត្រូវនិងលើកទឹកចិត្ត អ្នកដែលទាយមិនត្រូវ
- គ្រូសួរកុមារៈតើកូនដឹងទេថាគ្រូយកសម្ភារនេះមកឱ្យកូនធ្វើអ្វី?កុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ
- **គ្រូណែនាំពីរបៀបលេងៈ**
  - គ្រូឱ្យកូនៗលេងដោយចាប់ដៃគូចំនួន២ៗនាក់ ហើយក្នុងកូនម្នាក់ៗមានកៅស៊ូចំនួន១ ដាក់នៅពីមុខរៀងៗខ្លួន ដើម្បីយកមកផ្ទាត់ឱ្យទៅដល់ទីកំណត់ដែលអ្នកគ្រូបានគូរទុកជាស្រេច ។
  - គ្រូឱ្យកូនផ្ទាត់ម្តង២គូៗ(កុមារចំនួន៤នាក់)
  - ពេលកូនចាប់ផ្តើមផ្ទាត់កៅស៊ូ កូនត្រូវយកចង្អុលដៃខាងស្តាំដាក់ចូលក្នុងរង្វង់កៅស៊ូហើយកូនចាំស្តាប់សញ្ញាគ្រូៈ កាលណាគ្រូស្រែកថា ចាប់ផ្តើមផ្ទាត់ កូនត្រូវផ្ទាត់កៅស៊ូនោះឱ្យដល់ទីដែលគ្រូបានកំណត់បើកូនណាផ្ទាត់ទៅដល់ទីមុនគេ កូននោះជាអ្នកឈ្នះ ហើយបើកូនណាផ្ទាត់កៅស៊ូមិនទៅដល់ទីកំណត់ កូននោះជាអ្នកចាញ់
  - គ្រូលើកសរសើរដល់កូនដែលផ្ទាត់ឈ្នះ ហើយកូនដែលផ្ទាត់ចាញ់ គ្រូលើកទឹកចិត្តឱ្យខំបន្តទៀត។

# ថ្ងៃទី៧

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

រំលឹក **ហាត់ប្រាណតាមបទចម្រៀងៈ ពេលសប្បាយ**

**(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី២ ម៉ោងទី១)**

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អៈ ត្រូវចេះស្តាប់ដំបូន្មានគ្រូ និងឪពុកម្តាយ(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៧ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

### ល្បែងៈ គូសភ្ជាប់តួអក្សរដែលដូចគ្នា ឆ ជ ឈ

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីរបៀបគូសភ្ជាប់តួអក្សរដែលដូចគ្នា ឆ ជ ឈ តាមការណែនាំ បានត្រឹមត្រូវ
- កុមារគូសភ្ជាប់តួអក្សរដែលដូចគ្នា ឆ ជ ឈ បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** ផ្ទាំងអក្សរអ៊ុតរួច ៣ផ្ទាំង ហ្វឺតសរសេរក្តារខៀន តាមជាក់ស្តែង

**៣. ការរៀបចំកុមារៈ** ឱ្យកុមារអង្គុយជារាងពាក់កណ្តាលរង្វង់ និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងដំហានទី៣)

- គ្រូបង្ហាញផ្ទាំងអក្សរ ដែលគ្រូបានរៀបចំទុកនៅតាមទីកន្លែងរួចជាស្រេច (ផ្ទាំងអក្សរចំនួន៣តួ ដាក់ឆ្លាស់លាយគ្នាជាមួយអក្សរផ្សេងៗទៀតនៅលើក្រដាសតែ១) ហើយសួរកុមារថា តើនៅលើផ្ទាំងនេះមានតួអក្សរអ្វីខ្លះ?
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេងៈ**
  - គ្រូឱ្យកូនៗលេងជាក្រុម ដោយក្នុងមួយក្រុមមានផ្ទាំងអក្សរមួយសន្លឹក និងហ្វឺត១ដើម
  - ពេលក្រុមកូនបានផ្ទាំងអក្សរនេះហើយ កូននាំគ្នាសង្កេតអក្សរដែលដូចគ្នា កូនត្រូវយកប៊ិកហ្វឺតមកគូសភ្ជាប់តួអក្សរដែលដូចគ្នា។ ពេលគូសកូនកុំដណ្តើមគ្នា ត្រូវចែកគ្នាគូស និងវេងចាំវេន
  - ពេលក្រុមកូនណាគូសរួចហើយមុនគេត្រូវទះដៃចំនួន៣ដង រួចកូនយកមកបិទលើក្តារខៀនតាមកន្លែងដែលគ្រូបានរៀបចំ ហើយយកប៊ិកហ្វឺតទៅទុកនៅតុគ្រូវិញ

- គ្រូឱ្យកុមារ១ ឬ២នាក់និយាយឡើងវិញពីរបៀបនិងលក្ខណ្ឌនៃការលេងតាមការណែនាំ(បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូឱ្យកុមារទៅអង្គុយនៅតាមក្រុម តាមកន្លែងដែលគ្រូបានរៀបចំ ដោយគ្រូរៀបចំកុមារជា៣ក្រុម
- គ្រូឱ្យតំណាងក្រុមឡើងមកយកសម្ភារទៅអនុវត្តតាមក្រុមនីមួយៗ ហើយគ្រូជាអ្នកដើរសម្របសម្រួល
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗ ដែលបានបិទលើក្តារខៀន ដោយឱ្យតំណាងក្រុមនីមួយៗឡើងបង្ហាញពីអ្វីដែលក្រុមបានធ្វើ ( ធ្វើម្តងមួយក្រុម)
- គ្រូលើកសរសើរចំពោះក្រុមដែលធ្វើរួចមុនគេ ចំពោះក្រុមធ្វើហើយក្រោយគេ គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ )
- **គ្រូសួរកុមារ៖**
  - កូនៗទាំងអស់គ្នាសប្បាយទេ?តើមុននេះកូនៗបានលេងល្បែងគូសភ្ជាប់អក្សរអ្វីខ្លះ?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ៖ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែង មេរៀន "គូសភ្ជាប់តួអក្សរដែលដូចគ្នា ឆ ជ ឈ"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយទៅនឹងអ្វីដែលគ្រូបានប្រាប់(តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយរបស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្ត)គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុមនិងទាំងអស់គ្នា ។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## ចម្រៀង៖ យើងក្មេងៗនាំគ្នារាំ (ពេលទី២)

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីចំណងជើង អត្ថន័យបទចម្រៀង និងរបៀបធ្វើកាយវិការបានត្រឹមត្រូវ
- កុមារច្រៀងចម្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀងបានត្រឹមត្រូវ
- កុមារស្រឡាញ់ ចូលចិត្តច្រៀងបទចម្រៀង សហការគ្នា និងចូលរួមយ៉ាងសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរអ៊ុយ "U" ឈរជារង្វង់

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)
- គ្រូសួរ៖ កូនគិតបន្តិចទៅមើលថា តើថ្ងៃមុនកូនបានរៀនច្រៀងចម្រៀងអ្វី?តើចម្រៀងនោះមានន័យដូចម្តេច?(បើកុមារឆ្លើយមិនត្រូវគ្រូប្រាប់កុមារតែម្តង)
- គ្រូសួរកុមារបន្តថា ដូច្នេះកូនទាយទៅមើលថា ថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជាអ្វី? អំពីអ្វី? កុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ។ គ្រូសរុបចំណងជើងមេរៀនដែលកុមារទាយ
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះ គ្រូនឹងបង្រៀនកូននូវមុខវិជ្ជាសិក្សាសង្គម អំពីចម្រៀង "**យើងក្មេងៗនាំគ្នារាំ**" នេះម្តងទៀត
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារ ទៅនឹងអ្វីដែលគ្រូបានប្រាប់ ដោយនិយាយថា៖ អម្បាញ់មិញ មានកូនៗ

ណាបានទាយត្រូវពីមុខវិជ្ជា និងចំណងជើងមេរៀន។ កូនពិតជាឆ្លាតមែន ពូកែទាយណាស់។ ប៉ុន្តែកូនដែលទាយមិនត្រូវក៏ក្លាហានដែរ ហ៊ានឆ្លើយសំណួររបស់គ្រូ ដូច្នេះថ្ងៃក្រោយកូនព្យាយាមឆ្លើយទៀតណា!

- គ្រូប្រាប់ និងសរសេរមុខវិជ្ជា ចំណងជើងដាក់លើក្តារខៀន រួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូឱ្យកុមារច្រៀង និងធ្វើកាយវិការដែលបានធ្វើនៅពេលទី១ឡើងវិញជាក្រុម និងទាំងអស់គ្នា( ឱ្យបាន២ចប់ )
- គ្រូប្រាប់កុមារថា ឥឡូវគ្រូនឹងច្រៀងចម្រៀងនេះម្តងទៀត តែគ្រូដូចជាភ្លេចពាក្យខ្លះៗ តើកូនអាចជួយថាបំពេញពាក្យនោះប្រាប់គ្រូបានទេ បន្ទាប់មកគ្រូចាប់ផ្តើមច្រៀងដោយធ្វើជាបំបាត់ពាក្យខ្លះក្នុងខ្លឹមសារអត្ថបទចម្រៀង ឱ្យកុមារជួយបំពេញ (គ្រូអនុវត្តបែបនេះឱ្យបាន២ចប់)
- គ្រូប្រាប់កុមារថាៈ ឥឡូវនេះគ្រូនឹងធ្វើកាយវិការតាមបទចម្រៀង ហើយកូនជាអ្នកច្រៀង តើកូនអាចច្រៀងចម្រៀងឱ្យគ្រូធ្វើកាយវិការបានដែរឬទេ ? បន្ទាប់មកគ្រូចាប់ផ្តើមធ្វើកាយវិការ ហើយកុមារទាំងអស់ច្រៀងចម្រៀង(គ្រូនាំអនុវត្តបែបនេះឱ្យបាន២ចប់)
- គ្រូប្រាប់កុមារថាៈ អម្បាញ់មិញកូនបានច្រៀងឱ្យគ្រូធ្វើកាយវិការ។ ឥឡូវកូនជាអ្នកធ្វើកាយវិការម្តង ហើយគ្រូនឹងច្រៀង តើកូនយល់ព្រមដែរឬទេ ? ។បន្ទាប់មកគ្រូចាប់ផ្តើមច្រៀង ហើយកុមារជាអ្នកធ្វើកាយវិការទាំងអស់គ្នា( គ្រូនាំអនុវត្តបែបនេះឱ្យបាន២ចប់ )
- គ្រូនាំកុមារច្រៀង និងធ្វើកាយវិការតាមបទចម្រៀងសារឡើងវិញឱ្យបាន២ ទៅ៣ចប់ ទាំងអស់គ្នា

**+ របៀបធ្វើកាយវិការៈ**

- ឱ្យកុមារឈរជារង្វង់
- "យើងក្មេងៗ" យកដៃទាំងពីរខ្វែងគ្នាដាក់លើទ្រូងហើយញាក់ស្មាចុះឡើង
- "នាំគ្នារាំ រាំសប្បាយៗ លំហែកាយា" លើកដៃឡើងរាំ ដូចជារាំវង់ ដើរទៅមុខតិចៗកុំឱ្យជាន់គ្នា
- "មកមិត្តអើយយើងនាំគ្នារាំ រាំ រាំរាំលេងសប្បាយ" បែរមុខរកគ្នាធ្វើកាយវិការបក់ដៃហៅគ្នាមករាំ ហើយរាំបន្ត
- "កាន់ដៃគ្នាៗជារង្វង់ រាល់ថ្ងៃឈប់ៗ ឈប់សម្រាករៀន" កាន់ដៃគ្នាហើយជើងបោះទៅមុខ បោះទៅក្រោយជារង្វង់ នៅមួយកន្លែង
- "មកមិត្តអើយយើងនាំគ្នារាំ រាំ រាំរាំលេងសប្បាយ" បែរមុខរកគ្នាធ្វើកាយវិការបក់ដៃហៅគ្នាមករាំ ហើយរាំបន្តទៅមុខជារង្វង់
- "ឡា ឡា ឡាៗៗ" លើកដៃស្តាំឡើងលើបង្វិលកដៃចុះឡើងដូចជារាំ ដៃឆ្វេងច្រត់ចង្កេះហើយបង្វិលខ្លួនទៅស្តាំ។ "ឡា ឡា ឡាៗៗ"លើកដៃឆ្វេងឡើងលើបង្វិលកដៃចុះឡើងដូចជារាំ ដៃស្តាំច្រត់ចង្កេះហើយបង្វិលខ្លួនទៅឆ្វេង

**អត្ថបទចម្រៀង«យើងក្មេងៗនាំគ្នារាំ »(ពេលទី២)**

យើងក្មេងៗ នាំគ្នារាំ　　　រាំសប្បាយៗ លំហែកាយា
មកមិត្តអើយយើងនាំគ្នារាំ　　　រាំ រាំរាំលេងសប្បាយ។
កាន់ដៃគ្នាៗ ជារង្វង់　　　រាល់ថ្ងៃឈប់ៗ ឈប់សម្រាករៀន
មកមិត្តអើយយើងនាំគ្នារាំ　　　រាំរាំ រាំលេងសប្បាយ។
ឡា ឡា ឡា ៗៗ　　　ឡា ឡា ឡា ៗៗ

ម៉ោងទី៨ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ វិទ្យាសាស្ត្រ

## ពិសោធន៍៖ ភ្លក្សរសជាតិបន្លែ

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរសជាតិបន្លែបានត្រឹមត្រូវ
- កុមារសន្និដ្ឋានពីរសជាតិបន្លែបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់តាមដាននិងចូលរួមដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** ផ្លែត្រសក់ ប៉េងប៉ោះ ផ្លែម្រះ មើមការ៉ុត ចាន៣ កូនកាំបិត

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរអ៊ុយ "ប" និងក្រុមតូច

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូដាក់សម្ភារក្នុងថង់នៅលើតុមុខកុមារ (ផ្លែត្រសក់ ប៉េងប៉ោះ ផ្លែម្រះ មើមការ៉ុត...)
- គ្រូអោយកុមារម្នាក់ដែលស្ម័គ្រចិត្តមករើសសម្ភារពីក្នុងថង់នៅលើតុម្តងមួយៗដើម្បីបង្ហាញរួចឱ្យមិត្តភក្តិជាអ្នកប្រាប់ឈ្មោះ បើកុមារមិនស្គាល់ឈ្មោះបន្លែណាមួយ គ្រូត្រូវប្រាប់កុមាររួចឱ្យកុមារថាតាម
- គ្រូរៀបចំបន្លែដែលបានចិតរួចបង្ហាញកុមារ
- គ្រូសួរកុមារ៖
  - តើបន្លែទាំងអស់នេះគ្រូយកមកឱ្យកូនដើម្បីធ្វើអ្វី?
  - ពេលកូនយកបន្លែទាំងអស់នេះទៅញ៉ាំ តើដឹងថារសជាតិវាយ៉ាងដូចម្តេចដែរ?
- គ្រូត្រូវសរសេរចម្លើយរបស់កុមារនៅកៀនក្តារខៀន ពេលកុមារឆ្លើយប៉ាន់ស្មានដើម្បីទុកទៀងផ្ទាត់។
- គ្រូណែនាំកុមារពីរបៀបអនុវត្តទៅតាមក្រុម
  - គ្រូអោយកូនញ៉ាំបន្លែទាំងនេះជាក្រុមតូចៗ ហើយក្នុងមួយក្រុមកូនត្រូវបានបន្លែទាំងបួនមុខ
  - គ្រូប្រាប់កុមារ៖ កូនត្រូវយកបន្លែទាំងអស់នេះទៅដាក់នៅកណ្តាលវង់ បន្ទាប់មកកូននាំគ្នាញ៉ាំបន្លែម្តងមួយមុខៗ ដោយមិនដណ្តើមគ្នា ត្រូវចេះរង់ចាំវេន ធ្វើម្តងម្នាក់ៗ
  - កូនត្រូវនាំគិតពីរសជាតិបន្លែទាំងនោះ តើរសជាតិយ៉ាងដូចម្តេចដែរ?
  - ពេលកូននាំគ្នាអនុវត្តធ្វើយ៉ាងណាកុំឱ្យកំពប់បន្លែចេញពីចាន ដែលនាំឱ្យកង្វះអនាម័យ
- គ្រូឱ្យកុមារណាម្នាក់ស្ម័គ្រចិត្តឡើងមកនិយាយប្រាប់ពីអ្វីដែលគ្រូបានប្រាប់ បើនិយាយមិនបានត្រឹមត្រូវទេ ឱ្យមិត្តភក្តិជួយបំពេញបន្ថែម បើនៅតែនិយាយមិនបានពេញលេញ គ្រូត្រូវនិយាយប្រាប់កុមារសាឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមតូចៗរួចឱ្យទៅអង្គុយជារង្វង់នៅទីកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅអនុវត្តការពិសោធន៍តាមក្រុម
- គ្រូឱ្យកុមារអនុវត្តការពិសោធន៍គ្រប់ក្រុមទាំងអស់នៅពេលតែមួយ
- គ្រូដើរសម្របសម្រួលទៅតាមក្រុមនីមួយៗនិងជួយបំផុសគំនិតបន្ថែមដើម្បីឱ្យធ្វើបានត្រឹមត្រូវ
- គ្រូឱ្យកុមារទៅអង្គុយនៅក្រុមធំវិញហើយនាំគ្នាយកសម្ភារទៅទុកឱ្យគ្រូវិញពេលគេធ្វើរួចគ្រប់ក្រុម
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ពីលទ្ធផលនៃការពិសោធន៍
- គ្រូសរុបលទ្ធផលរបស់កុមារគ្រប់ក្រុមដែលពួកគេបានរាយការណ៍(ត្រសក់មានរសជាតិសាប មើមការ៉ុត

មានរសជាតិផ្អែម ផ្លែប៉េងប៉ោះ មានរសជាតិជូរ ផ្លែម្រះមានរសជាតិល្វីង)

- គ្រូប្រាប់កុមារៈ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមកូនៗដែលបានរាយការណ៍ដូចនេះគ្រូយកបន្លែទាំងនេះមកអនុវត្តជាមួយកូនម្តងទៀត
- គ្រូយកបន្លែទាំងនោះមកដាក់នៅលើតុមុខកុមាររួចឱ្យកុមារស្ម័គ្រចិត្តមួយនាក់យកបន្លែញ៉ាំម្តងមួយៗ រហូតដល់គ្រប់មុខបន្លែ
- នាំកុមារសង្កេតទាំងអស់គ្នា ហើយផ្ទៀងផ្ទាត់ទៅនឹងចម្លើយពេលពិសោធន៍ឃើញនឹងចម្លើយពេលប៉ាន់ស្មានទុកមុនពិសោធន៍ ដែលគ្រូបានសរសេរទុកលើក្តារខៀន
- គ្រូធ្វើរបៀបនេះទាល់តែអស់សម្ភារ
- គ្រូបូកសរុប និងសន្និដ្ឋានៈ
  - គ្រូប្រាប់កុមារៈ ត្រសក់មានរសជាតិសាប មើមការ៉ុតមានរសជាតិផ្អែម ផ្លែប៉េងប៉ោះ មានរសជាតិជូរ ផ្លែម្រះមានរសជាតិល្វីង (នាំកុមារអានជាក្រុមទាំងអស់គ្នា)
  - នាំកុមារអានពាក្យថ្មី និងពន្យល់អត្ថន័យនៃពាក្យ « ភ្លក់ឬ ភ្លក្ស»មានន័យថាបរិភោគតែបន្តិចល្បងមើល (រួចនាំកុមារអានជាក្រុមនិងទាំងអស់គ្នា)

ណែនាំកុមារពីសារៈប្រយោជន៍នៃការញ៉ាំបន្លែដែលធ្វើឱ្យមានសុខភាពល្អ

- គ្រូសួរកុមារៈ អម្បាញ់មិញកូននាំគ្នាធ្វើអ្វីខ្លះ ? ដូច្នេះយើងនាំគ្នារៀនមុខវិជ្ជាអ្វី ?អំពីអ្វី ?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ អំពីពិសោធន៍ «ភ្លក់រសជាតិបន្លែ »
- គ្រូផ្ទៀងផ្ទាត់ចម្លើយកុមារទៅនឹងការប្រាប់របស់គ្រូ
- នាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន (ជាក្រុមនិងទាំងអស់គ្នា)។

**ម៉ោងទី៦ (រយៈពេល ៣០នាទី)**

## មុខវិជ្ជាៈ សិក្សាសង្គម

* ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

## ថ្ងៃទី៨

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

រំលឹក **ហាត់ប្រាណតាមរឿងនិទាន៖ មេសេះនាំកូនទៅរកចំណី**

( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៣ ម៉ោងទី១ )

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" ( ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២ )
* ទម្លាប់ល្អ៖ ត្រូវចេះស្តាប់ដំបូន្មានគ្រូ និងឪពុកម្តាយ( ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២ )
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៨ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

### សង្កេត៖ ផ្លែឈើ«ផ្លែក្រូចពោធិសាត់»

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីឈ្មោះរបស់ផ្លែក្រូច ពណ៌បៃតង រាងមូល បានត្រឹមត្រូវ
- កុមាររៀបរាប់បានពីរាង ពណ៌ និងរសជាតិរបស់ផ្លែក្រូចបានត្រឹមត្រូវ
- កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់ សហការ ចូលរួមបានយ៉ាងសកម្ម និងសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** ផ្លែឈើ( ផ្លែក្រូច )

**៣. រៀបចំកុមារ៖** រៀបចំកុមារជារាងអក្សរ "ប" អង្គុយជាក្រុមតូចៗ

**៤. ដំណើរការបង្រៀន៖ (អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូនិទានរឿង៖ ថ្ងៃនេះគ្រូបានធ្វើដំណើរមកសាលារៀនស្រាប់តែមានតាម្នាក់នៅតាមផ្លូវហៅអ្នកគ្រូឱ្យឈប់ហើយគាត់បានផ្ញើថង់មួយមកឱ្យគ្រូ ដើម្បីយកមកផ្ញើកូនៗទាំងអស់គ្នាព្រោះគាត់ថាកូនៗទាំងអស់គ្នាជាកូនល្អ។ប៉ុន្តែគ្រូមិនដឹងថាខាងក្នុងនោះមានអ្វីទេ ? ដូច្នេះកូនៗទាំងអស់គ្នាចង់ដឹងទេថាតើខាងក្នុងថង់មានអ្វីខ្លះ ?កុមារឆ្លើយតបគំនិតគេម្នាក់ៗ។
- គ្រូបង្ហាញថង់នោះហើយប្រាប់កុមារថាគ្រូនិងឱ្យកូនៗទាំងអស់គ្នាបានស្ទាប់ ហើយហិតក្លិន គ្រប់ៗគ្នា ពេលកូនស្ទាប់កូនត្រូវគិតវាតើក្នុងថង់នេះមានអ្វី ?ហើយប្រាប់គ្រូមានអ្វីនៅក្នុងថង់នេះ ?
- គ្រូឱ្យកុមារម្នាក់ឡើងមកយកសម្ភារចេញពីក្នុងថង់ហើយបង្ហាញមិត្តភក្តិ រួចសួរកុមារដើម្បីផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ( តើអម្បាញ់មិញមានមិត្តភក្តិណាទាយត្រូវទេកូន ? ) ពេលមានកុមារទាយត្រូវឱ្យកុមារទាំងអស់ទះដៃសរសើរ

- គ្រូបញ្ជាក់ថានេះជាផ្លែក្រូចរួចសួរកុមារតើផ្លែក្រូចនេះជាបន្លែឬផ្លែឈើ? ហើយគ្រូយកមកឱ្យកូនធ្វើអ្វី?
- គ្រូណែនាំកុមារពីរបៀបអនុវត្តតាមក្រុមនីមួយៗ
  - គ្រូឱ្យកូនធ្វើជាក្រុមតូចៗ ហើយក្នុងក្រុមនីមួយៗត្រូវទទួលបានផ្លែក្រូច១ផ្លែ
  - ពេលក្រុមកូននីមួយៗបានផ្លែក្រូចនេះហើយកូនៗត្រូវនាំគ្នាពិនិត្យមើលនៅផ្នែកខាងក្រៅមានអ្វីខ្លះ?ពេលកូនសង្កេតហើយប្រាប់គ្រូដើម្បីគ្រូបកផ្លែក្រូច ហើយកូនៗនាំគ្នាមើលផ្នែកខាងក្នុងទៀតមានអ្វីខ្លះ?ពេលកូនពិភាក្សាគ្នាត្រូវចេះចែកគ្នាមើល និងនិយាយហើយកូនត្រូវរកមិត្តភក្តិណាម្នាក់ដើម្បីនិយាយប្រាប់មិត្តភក្តិនិងគ្រូពីអ្វីដែលកូនបានស្គាល់
  - ពេលកូនធ្វើចប់គ្រប់ក្រុមហើយកូនៗនាំគ្នាទៅអង្គុយក្រុមធំវិញរួចប្រមូលសម្ភារទុក
- គ្រូឱ្យកុមារម្នាក់ឡើងនិយាយពីអ្វីដែលគ្រូបានប្រាប់ បើសិននិយាយមិនបានគ្រប់ទេត្រូវឱ្យមិត្តភក្តិជួយបំពេញបន្ថែម ប៉ុន្តែបើនៅតែនិយាយមិនបានពេញលេញទេគ្រូត្រូវនិយាយប្រាប់កុមារសាឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមឱ្យអង្គុយជារង្វង់តាមទីកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូឱ្យកុមារម្នាក់ក្នុងក្រុមនីមួយៗមកយកសម្ភារទៅនាំគ្នាអនុវត្តតាមការណែនាំ
- គ្រូដើរសម្របសម្រួលតាមក្រុមដោយជួយបំផុសគំនិតបន្ថែមចំពោះក្រុមខ្លះមិនទាន់យល់
- នៅពេលក្រុមនីមួយៗសង្កេតផ្នែកខាងក្រៅរួចហើយគ្រូត្រូវបកសំបកផ្លែក្រូចដើម្បីឱ្យកុមារសង្កេតផ្នែកខាងក្នុងបន្តទៀត
- ពេលក្រុមនីមួយៗសង្កេតចប់ហើយ គ្រូឱ្យពួកគេទៅអង្គុយក្រុមធំវិញរួចប្រមូលសម្ភារទុកវិញ
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងមករាយការណ៍ពីលទ្ធផលដែលពួកគេបានជជែកគ្នា(ម្តងមួយក្រុមៗ) ពេលកុមារនិយាយពាក្យមិនត្រឹមត្រូវតាមអក្ខរាវិរុទ្ធ គ្រូត្រូវកែតម្រូវហើយនាំកុមារអានទាំងអស់គ្នា

**ឧទាហរណ៍៖** កុមារគ្រប់ក្រុមបានប្រាប់ផ្លែក្រូចនៅផ្នែកខាងក្រៅមាន ទង ពណ៌លឿងទុំ រាងមូល ឯផ្នែកខាងក្នុងមានក្លែប ហើយសាច់វាដូចពងកំពឹស គ្រាប់មូល ហើយរឹង...)

- គ្រូសរុបពីលទ្ធផលរបស់កុមារទាំងអស់ដែលបានឡើងបង្ហាញ។ ពេលគ្រូសរុបត្រូវគិតមើលតើក្រុមទាំងអស់នៅមិនទាន់ស្គាល់អ្វីខ្លះ?ដូច្នេះត្រូវផ្តល់ចំណេះដឹងថ្មីឱ្យកុមារទៀត។ (ឧទាហរណ៍ ៖ កុមារមិនទាន់ប្រាប់ពីសំបក ពេលបកទៅមានក្លែប ផលប្រយោជន៍)
- គ្រូត្រូវបំផុសសំណួរដើម្បីផ្តល់ចំណេះដឹងបន្ថែម
  - នៅពេលម្តាយកូនយកផ្លែក្រូចមកសួរតើកូនសង្កេតឃើញគាត់ធ្វើដូចម្តេច?
  - ពេលគ្រូបកសំបកផ្លែក្រូចតើកូនសង្កេតឃើញមានអ្វី?
  - តើផ្លែក្រូចមានប្រយោជន៍អ្វីខ្លះ?
  - គ្រូត្រូវប្រាប់កុមារពេលឆ្លើយមិនបាននៅសំណួរណាមួយនោះ?
  - គ្រូនាំកុមារអានពាក្យខ្លះៗដែលពិបាក
  - គ្រូសួរកុមារៈអម្បាញ់មិញកូនស្គាល់ពីអ្វី?ដូច្នេះថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រអំពីសង្កេតផ្លែក្រូច
  - គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន(ជាក្រុមនិងអានទាំងអស់គ្នា)។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ សិក្សាសង្គម

## គំនូរៈ ផាត់ពណ៌ផ្លែចេកណាំវ៉ាទុំមួយផ្លែ

**១. វត្ថុបំណងៈ**

- កុមារប្រាប់ពីរបៀបផាត់ពណ៌ផ្លែចេកណាំវ៉ាមួយផ្លែបានត្រឹមត្រូវ
- កុមារកាន់ខ្មៅដៃពណ៌ ផាត់ពណ៌ផ្លែចេកណាំវ៉ាមួយផ្លែដោយទប់លំនឹងបង្វិលតាមរូបបានត្រឹមត្រូវ
- កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់ សហការចូលរួមយ៉ាងសកម្មនិងសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ**

+ **សម្ភារសម្រាប់គ្រូៈ**

- ផ្ទាំងក្រដាសដែលមានរូបផ្លែចេកណាំវ៉ាមួយផ្លែផាត់ពណ៌រួចចំនួន១សន្លឹក
- ផ្ទាំងក្រដាសរូបផ្លែចេកណាំវ៉ាមួយផ្លែដែលមិនទាន់ផាត់ពណ៌ដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀន(ក្រដាសផ្ទាំងធំ)
- ខ្មៅដៃពណ៌ចំនួន២ដើម(២ពណ៌),ស្កុតចំនួន១ដុំ។

+ **សម្ភារសម្រាប់កុមារៈ**

- ផ្ទាំងក្រដាសរូបផ្លែចេកណាំវ៉ាមួយផ្លែមិនទាន់ផាត់ពណ៌ដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀននៅក្បាលសន្លឹកកិច្ចការគ្រប់ចំនួនកុមារ និងខ្មៅដៃពណ៌សម្រាប់កុមារ

**៣. ការរៀបចំកុមារៈ** អង្គុយរាងអក្សរ "ប" ចែកកុមារជាក្រុម(អនុវត្តជាបុគ្គល)

**៤. ដំណើរការបង្រៀនៈ (អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូសួរៈ តើនៅផ្ទះកូនៗមានដាំដំណាំអ្វីខ្លះ? ហើយផ្លែចេកមានពណ៌អ្វីខ្លះ?(ចម្លើយតាមគំនិតកុមារម្នាក់ៗ)
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារថាតាម(ជាក្រុមនិងទាំងអស់គ្នា)
- គ្រូបង្ហាញផ្ទាំងក្រដាសរូបដែលមានរូបផ្លែចេកណាំវ៉ាមួយផ្លែផាត់ពណ៌រួចស្រេច ឱ្យកុមារសង្កេតនិងប្រាប់ឈ្មោះ រួចបិទនៅលើក្តារខៀនឱ្យកុមារមើលជាគំរូ
- គ្រូបង្ហាញផ្ទាំងក្រដាសរូបផ្លែចេកណាំវ៉ា១ផ្លែ ដែលគ្រូមិនទាន់ផាត់ពណ៌ឱ្យកុមារសង្កេត
- គ្រូប្រាប់កុមារៈផ្ទាំងក្រដាសរូបនេះគ្រូទុកសម្រាប់ផាត់ពណ៌ឱ្យកូនមើលពីរបៀបផាត់ពណ៌។ ដូច្នេះកូននាំគ្នាចាំមើលទាំងអស់គ្នាតើគ្រូចាប់ផ្តើមផាត់ពណ៌ពីណាទៅណា?
- គ្រូយកផ្ទាំងក្រដាសរូបនោះទៅបិទនៅលើក្តារខៀន ជិតផ្ទាំងក្រដាសជាគំរូដើម្បីណែនាំពីរបៀបផាត់ពណ៌
- គ្រូណែនាំពីរបៀបផាត់ពណ៌នៅលើផ្ទាំងក្រដាសរូបផ្លែចេកណាំវ៉ាមួយផ្លែដែលបានបិទលើក្តារខៀនដោយផាត់ពណ៌បណ្តើរ និយាយប្រាប់កុមារបណ្តើរយឺតៗ ដើម្បីឱ្យកុមារសង្កេតពីទិសនៃការផាត់ពណ៌។
  - គ្រូប្រាប់កុមារៈ
    - កូនយកខ្មៅដៃពណ៌មកផាត់រូបផ្លែចេកណាំវ៉ាមួយផ្លែដោយចាប់ផ្តើមទាញពីលើចុះក្រោម មិនឱ្យផាត់ចេញក្រៅរូបភាពផ្លែចេកណាំវ៉ាមួយផ្លែទេ។ កូនៗត្រូវផាត់បន្តើរៗរបៀបនេះឱ្យពេញរូបផ្លែចេកណាំវ៉ាមួយផ្លែ។ (តាមរូបគំនូរផាត់ពណ៌របស់គ្រូដាក់ស្តែង)
    - បន្ទាប់មកកូនយកខ្មៅដៃពណ៌ផាត់ពណ៌រូបផ្លែចេកណាំវ៉ាមួយផ្លែឱ្យពេញលេញ
- គ្រូបង្ហាញផ្ទាំងក្រដាសជាសន្លឹកកិច្ចការកុមារម្នាក់ៗរួចប្រាប់កុមារៈកូនម្នាក់ៗត្រូវបានផ្ទាំងសន្លឹកកិច្ចការ

នេះមួយសន្លឹកនិងខ្មៅដៃពណ៌ សម្រាប់កូនផាត់ពណ៌ទៅតាមអ្វីដែលគ្រូបានបង្ហាញ

- គ្រូរៀបចំកុមារឱ្យអង្គុយទៅតាមតុដែលគ្រូបានរៀបចំឬបង្វិលកៅអី អង្គុយផាត់ពណ៌(តាមស្ថានភាពជាក់ស្តែង)
- ឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅចែកគ្នាអនុវត្ត
- កុមារម្នាក់ៗនាំគ្នាអនុវត្ត គ្រូដើរសម្របសម្រួលគ្រប់ក្រុម ដើម្បីជួយកុមារណាដែលមិនទាន់ចេះកាន់ខ្មៅដៃពណ៌ផាត់ និងមិនទាន់យល់ពីរបៀបផាត់ និងដាក់ឈ្មោះកុមារម្នាក់ៗពីខាងក្រោមសន្លឹកកិច្ចការ
- គ្រូប្រាប់កុមារៈ ពេលកូនផាត់រួចហើយកូនយកខ្មៅដៃពណ៌ទៅទុកឱ្យគ្រូវិញ ហើយសន្លឹកកិច្ចការរបស់កូនទុកនៅរៀងៗខ្លួន។
- ពេលកុមារផាត់ហើយគ្រប់គ្នា គ្រូឱ្យកុមារទៅអង្គុយកន្លែងដើមជារាងអក្សរ(អ៊ុយ)វិញ
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារទៅឈរម្តងមួយក្រុមនៅខាងមុខ ហើយកាន់សន្លឹកកិច្ចការដាក់នៅត្រង់ដើមទ្រូងបង្ហាញមិត្តភក្តិ ដើម្បីឱ្យពួកគេជាអ្នកផ្ទៀងផ្ទាត់។
- គ្រូសួរកុមារដែលជាអ្នកផ្ទៀងផ្ទាត់ៈ តើមិត្តភក្តិយើងផាត់បានត្រឹមត្រូវឬទេ?ស្អាតឬទេ? បើមានកុមារណាបង្អាប់គំនូររបស់មិត្តភក្តិណាម្នាក់ គ្រូត្រូវចេះកែតម្រូវទៅជាពាក្យសម្តីលើកទឹកចិត្តកុមារនោះវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូឱ្យតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការរបស់មិត្តភក្តិគេឱ្យគ្រូ សម្រាប់ទុកដាក់តាំងស្នាដៃកុមារ។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ បុរេគណិត

## ល្បែងៈ ចំណាត់ក្រុមផ្លែឈើតាមទំហំ និងពណ៌

**១. វត្ថុបំណងៈ**

-កុមារប្រាប់បានពីរបៀបធ្វើចំណាត់ថ្នាក់តាមទំហំ និងពណ៌ បានត្រឹមត្រូវ

-កុមារធ្វើចំណាត់ថ្នាក់តាមទំហំ និងពណ៌ បានត្រឹមត្រូវ

-កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** កូនកាសផ្លែឈើចម្រុះពណ៌ ៤ឈុត

**៣. ការរៀបចំកុមារៈ** ឱ្យកុមារអង្គុយជាអក្សរអ៊ុយ " ប "និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់ពីមុខវិជ្ជា និងចំណងជើងមេរៀន រួចឱ្យកុមារថាតាម (ជាក្រុម និងទាំងអស់គ្នា)
- គ្រូបង្ហាញកូនកាសផ្លែឈើពីក្នុងថង់ម្តងមួយៗ រួចឱ្យកុមារប្រាប់ពីឈ្មោះ ពណ៌ និងទំហំផ្លែឈើទាំងនោះ បើកុមារមិនអាចប្រាប់ពីឈ្មោះ ពណ៌និងទំហំកូនកាសផ្លែឈើណាមួយនោះ គ្រូត្រូវប្រាប់ហើយឱ្យគេថាតាម
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនៗលេងជាក្រុម ដោយក្នុងមួយក្រុមមានកូនកាសផ្លែឈើដែលគ្រូបានបង្ហាញមុននេះមួយថង់
  - ពេលក្រុមកូននីមួយៗបានសម្ភារនេះគ្រប់ក្រុមហើយ កូនតាមក្រុមនីមួយៗ ត្រូវយកសម្ភារចេញពីថង់ ដាក់នៅកណ្តាលវង់ បន្ទាប់មកកូនៗក្នុងក្រុមនីមួយៗនាំគ្នាសង្កេតមើលកូនកាសរូបផ្លែឈើទាំងអស់នោះ ដើម្បីចំណាំឈ្មោះ ទំហំ និងពណ៌។ ប៉ុន្តែកូននាំគ្នាមើលឱ្យស្ងៀមស្ងាត់ តាមក្រុមនីមួយៗ

កុំឱ្យរំខានក្រុមដទៃ ។

- ពេលគ្រូឱ្យសញ្ញាចាប់ផ្តើមលើកទី១ កូនៗគ្រប់ក្រុមត្រូវនាំគ្នារៀបកូនកាសផ្លែឈើដែលមានទំហំដូចៗគ្នាដាក់មួយជុំៗ ។ ពេលកូនជ្រើសរើសកូនកាសផ្លែឈើដាក់មួយជុំៗ កូនត្រូវនាំគ្នាធ្វើម្នាក់ម្តងៗ ចេះរង់ចាំវេន មិនដណ្តើមគ្នារញ៉េរញ៉ៃនោះទេ ។
- ពេលគ្រូនាំកូនផ្ទៀងផ្ទាត់លើកទី១ហើយ កូនត្រូវប្រមូលកូនកាសផ្លែឈើទាំងនោះដាក់ប្រឬកប្រលប់នៅកណ្តាលវង់វិញដដែល រង់ចាំគ្រូឱ្យសញ្ញាលេងលើកទី២
- ពេលគ្រូឱ្យសញ្ញាចាប់ផ្តើមលើកទី២ កូនៗគ្រប់ក្រុម ត្រូវនាំគ្នារៀបកូនកាសផ្លែឈើដែលមានពណ៌ដូចៗគ្នាដាក់មួយជុំៗ ។ កូនត្រូវនាំគ្នាធ្វើម្នាក់ម្តងៗ ចេះរង់ចាំវេន មិនដណ្តើមគ្នារញ៉េរញ៉ៃ។

- ឱ្យកុមារម្នាក់ដែលស្ម័គ្រចិត្តនិយាយឡើងវិញ ពីអ្វីដែលគ្រូបានប្រាប់ (បើកុមារនិយាយមិនបានគ្រប់ទេ ឱ្យមិត្តភក្តិដទៃជួយនិយាយបន្ថែម បើនៅតែនិយាយមិនបានពេញលេញទេនោះ គ្រូត្រូវនិយាយប្រាប់សាឡើងវិញម្តងទៀត)
- គ្រូចែកកុមារជាក្រុម ហើយឱ្យកុមារនីមួយៗអង្គុយជារង្វង់ទៅតាមទីកន្លែងដែលគ្រូបានរៀបចំទុក
- គ្រូឱ្យកុមារម្នាក់ក្នុងមួយក្រុមទៅយកសម្ភារមកអនុវត្ត និងឱ្យក្រុមនីមួយៗចាប់ផ្តើមអនុវត្តតាមសញ្ញាបញ្ជារបស់គ្រូ ក្រុមនីមួយៗនាំគ្នាអនុវត្តលើកទី១
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗ ដោយឱ្យកុមារជួយគ្នាទៅវិញទៅមក(ឧទាហរណ៍៖ ក្រុមទី១ អ្នកបង្ហាញលទ្ធផល ដូចនេះក្រុមទី២ និងក្រុមទី៣មកសង្កេត ដើម្បីវាយតម្លៃ និងកែលម្អ ។ ក្រុមទី២ អ្នកបង្ហាញលទ្ធផល ដូចនេះក្រុមទី១ និងក្រុមទី៣ មកសង្កេត ដើម្បីវាយតម្លៃ និងកែលម្អ ។ ក្រុមទី៣ អ្នកបង្ហាញលទ្ធផល ដូចនេះ ក្រុមទី១ និងក្រុមទី២ មកសង្កេត ដើម្បីវាយតម្លៃ និងកែលម្អ
- ពេលផ្ទៀងផ្ទាត់លើកទី១ហើយ គ្រូឱ្យកុមារប្រមូលសម្ភារដាក់ប្រឬកប្រលប់ ដាក់នៅកណ្តាលរង្វង់វិញ។ រួចសួរកុមាររំលឹកឡើងវិញពីរបៀបលេងលើកទី២ បើកុមារភ្លេច គ្រូបញ្ជាក់បន្ថែម ។ បន្ទាប់មកគ្រូឱ្យសញ្ញាចាប់ផ្តើមលើកទី២បន្តទៀត
- ពេលធ្វើរួចគ្រប់ក្រុមហើយ គ្រូឱ្យកុមារទៅអង្គុយនៅក្រុមធំវិញ ហើយក្នុងមួយក្រុមទុកតែកុមារម្នាក់សម្រាប់បង្ហាញលទ្ធផលពេលផ្ទៀងផ្ទាត់
- គ្រូនាំកុមារផ្ទៀងផ្ទាត់ម្តងមួយក្រុមៗ ដោយឱ្យកុមារម្នាក់ប្រចាំក្រុមនីមួយៗជាអ្នកបង្ហាញពីអ្វីដែលពួកគេបានធ្វើ ។ បន្ទាប់មកកុមារដែលនៅអង្គុយក្រុមធំជាអ្នកវាយតម្លៃ និងជួយកែតម្រូវ នៅពេលគេធ្វើមិនទាន់បានត្រឹមត្រូវ គ្រូនាំកុមារផ្ទៀងផ្ទាត់ឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូឱ្យកុមារប្រមូលសម្ភារទៅជូនគ្រូវិញ បន្ទាប់ពីពួកគេត្រូវបានបញ្ចប់ការផ្ទៀងផ្ទាត់លទ្ធផល ។

### ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

✱ ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី៩

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

វំលឹក **ចលនាមូលដ្ឋានៈ វារ (វារទៅមុខតាមទីកំណត់ វារក្រោមតុ វារចូលកងឬវង្វង់)**

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៤ ម៉ោងទី១)

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អៈ ត្រូវចេះស្តាប់ដំបូន្មានគ្រូ និងឪពុកម្តាយ(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី៩ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ បុរេគណិត

### ល្បែងៈ បង្កើតសំណុំចំនួនតូចៗ ពី ១ ដល់១០

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីរបៀបបង្កើតសំណុំចំនួនតូចៗពី ១ ដល់១០ បានត្រឹមត្រូវ
- កុមារបង្ហាញចំនួនសំណុំតូចៗពី ១ ដល់១០ បានត្រឹមត្រូវ
- កុមារឈ្លាសវៃ អំណត់ សហការ ប្រុងប្រយ័ត្ន និងសប្បាយរីករាយ

**២. សម្ភារបង្រៀនៈ** បណ្ណចំនួនចំណុចពី១ ដល់១០ ចំនួន១០សន្លឹក , គ្រាប់ក្រួសចំនួន៣០ គ្រាប់

**៣. ការរៀបចំកុមារៈ** អង្គុយជារាងអក្សរអ៊ុយ "U" អង្គុយតាមក្រុមតូចៗជារង្វង់

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់ចំណងជើងៈ ថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជា គណិតវិទ្យា ចំណងជើង«បង្កើតសំណុំចំនួនតូចៗ ពី១ ដល់១០ (គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនទាំងអស់គ្នា)
- គ្រូបង្ហាញបណ្ណចំណុចដែលមានចំនួនពី១ដល់១០ ឱ្យកូនសង្កេតនិងរាប់ចំនួននៅក្នុងបណ្ណនោះម្តងមួយៗ

**+គ្រូណែនាំពីរបៀបលេង**

- គ្រូឱ្យកុមារលេងជាក្រុមតូចៗហើយក្នុងក្រុមនីមួយៗត្រូវបានគ្រាប់ក្រួសចំនួន១០គ្រាប់ហើយកូនដាក់នៅកណ្តាលវង់
    - ពេលគ្រូលើកបណ្ណចំនួនចំណុចចំនួនប៉ុន្មាន កូនក្នុងក្រុមត្រូវចាប់គ្រាប់ក្រួសនោះផ្តុំទៅតាមចំនួនដែលគ្រូបានលើក ដាក់ទៅជាសំណុំតូចៗ

- ពេលក្រុមនីមួយៗផ្គុំបានហើយ កូនប្រាប់គ្រូ តើកូនផ្គុំបានប៉ុន្មានសំណុំ?ហើយមាននៅសល់ឬមិនសល់? ពេលកូនធ្វើហើយកូនត្រូវពិនិត្យមើលឡើងវិញ ហើយពេលកូនៗរើសគ្រាប់ក្រួស កូនត្រូវចែគ្នា កុំដណ្តើមគ្នា កូនធ្វើម្នាក់ម្តងៗ។ពេលគ្រូលើកចំនួនផ្សេងៗទៀតកូនត្រូវធ្វើដូចគ្នាដែរ។

- ឱ្យកុមារ១ឬ២នាក់និយាយឡើងវិញពីអ្វីដែលគ្រូណែនាំ(បើកុមារនិយាយមិនបានទេត្រូវនិយាយប្រាប់ឡើងវិញម្តងទៀត)
- ចែកកុមារជាក្រុមរួចឱ្យទៅអង្គុយជារង្វង់តាមកន្លែងដែលគ្រូបានរៀបចំ
- ឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅអនុវត្ត
- កុមារអនុវត្តទៅតាមក្រុម គ្រូដើរសម្របសម្រួលពេលលើកបណ្ណចំនួនហើយគ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលម្តងមួយក្រុមៗ ហើយមុននិងផ្ទៀងផ្ទាត់ត្រូវឱ្យតំណាងក្រុមនិយាយប្រាប់ពីអ្វីដែលពួកគេធ្វើបានហើយឱ្យក្រុមដទៃជួយកែលម្អ បើករណីធ្វើខុសគ្រូចាប់ធ្វើបន្តបន្ទាប់តាមរបៀបនេះរហូតដល់ម៉ោងដែលលើកចំនួនបណ្ណផ្លាស់ប្តូរមិនតាមលំដាប់។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពកសាងៈ រៀបវត្ថុតូចៗបិទលើរូបផ្លែត្រឡាច

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីរបៀបរៀបវត្ថុតូចៗបិទលើរូបផ្លែត្រឡាចបានត្រឹមត្រូវ
- កុមាររៀបវត្ថុតូចៗបិទលើរូបផ្លែត្រឡាចបានត្រឹមត្រូវ។
- កុមារក្លាយហាន រហ័សរហួន មានគំនិតច្នៃប្រឌិត សហការ ដោយសប្បាយរីករាយ

**២. សម្ភារបង្រៀនៈ**

-សម្ភារគ្រូៈ ផ្ទាំងរូបភាពផ្លែត្រឡាចដែលបានរៀបគ្រាប់សណ្តែកបិទពីលើចំនួនមួយផ្ទាំង ,ផ្ទាំងរូបភាពផ្លែត្រឡាចដែលមិនមានរៀបគ្រាប់សណ្តែកបាយបិទលើរូបភាពចំនួនមួយផ្ទាំង ,គ្រាប់សណ្តែកបាយចំនួន ១ កញ្ចប់ ស្កុតចំនួន១ដុំ  កាវចំនួន១ដប កន្សែងចំនួន១ និងប្រាសដុសធ្មេញចំនួន១។

-សម្ភារកុមារៈ សន្លឹករូបភាពផ្លែត្រឡាចគ្រប់ចំនួនកុមារដែលមានដាក់មុខវិជ្ជា ចំណងជើងមេរៀន  ថ្ងៃ ខែ ឆ្នាំ អនុវត្ត,គ្រាប់សណ្តែកបាយគ្រប់ចំនួនក្រុមកុមារ(១ក្រុម១កញ្ចប់)

-កាវគ្រប់ចំនួនក្រុមកុមារ(១ក្រុម១ដប)។ប្រាសដុសធ្មេញគ្រប់ចំនួនក្រុមកុមារ(១ក្រុម១ដើម),កន្សែងគ្រប់ចំនួនក្រុមកុមារ(១ក្រុមកន្សែងចំនួន ១)

**៣. ការរៀបចំកុមារៈ** កុមារអង្គុយជារាងអក្សរអ៊ុយ "U" និងក្រុមតូច

**៤.ដំណើរការបង្រៀនៈ**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញផ្ទាំងរូបភាពផ្លែត្រឡាចដែលបានរៀបគ្រាប់សណ្តែកបាយបិទពីលើ ឱ្យកុមារប្រាប់ឈ្មោះនិងយករូបនោះបិទលើក្តារខៀនជាគំរូហើយកុមារសង្កេត
- គ្រូណែនាំពីរបៀបរៀបបិទគ្រាប់សណ្តែកបាយលើរូបផ្លែត្រឡាចយឺតៗដោយនិយាយបណ្តើរ បិទបណ្តើរពេលបិទត្រូវឱ្យកុមារបានសង្កេតទាំងអស់គ្នា
- គ្រូឱ្យកូនរៀបបិទគ្រាប់សណ្តែកលើរូបផ្លែត្រឡាចជាក្រុម ហើយក្រុមនីមួយៗត្រូវបានផ្ទាំងរូបភាពផ្លែ

ត្រឡាចមួយសន្លឹក គ្រាប់សណ្តែកចំនួនមួយកញ្ចប់ ការចំនួនមួយដប កន្សែងចំនួនមួយ និងច្រាស់ដុសធ្មេញចំនួនមួយ

- គ្រូប្រាប់កុមារៈ ដំបូងកូននាំគ្នាយកផ្ទាំងរូបភាពផ្លែត្រឡាចមួយផ្ទាំងដាក់នៅចំកណ្តាល ហើយគ្រាប់សណ្តែក ការ កន្សែង និងច្រាស់ដុសធ្មេញក៏ដាក់ចំកណ្តាលរង្វង់ក្បែរគ្នាដែរ
- គ្រូណែនាំកុមារៈពេលរៀបបិទរូបផ្លែត្រឡាចកូនត្រូវយកច្រាសដុះធ្មេញមកជ្រលក់ក្នុងការហើយយកទៅលាបលើរូបផ្លែត្រឡាចដោយពាសឱ្យសព្វពេញរូបផ្លែត្រឡាចប៉ុន្តែមិនឱ្យហៀរចេញក្រៅរូបផ្លែត្រឡាចទេ បើមានការប្រឡាក់ដៃកូនត្រូវយកកន្សែងមកជូត។បន្ទាប់មកយកគ្រាប់សណ្តែកបាយរៀបលើការក្នុងរូបផ្លែត្រឡាចឱ្យជិតៗគ្នាឱ្យពេញរូបផ្លែត្រឡាចគ្រូប្រាប់កុមារបណ្តើរធ្វើបង្ហាញបណ្តើរ ប៉ុន្តែការរៀបគ្រាប់សណ្តែកបាយក្នុងរូបផ្លែត្រឡាចមិនចាំបាច់រៀបពេញរូបផ្លែត្រឡាចនោះទេ រៀបតែបន្តិចជាគំរូបានហើយ ពេលកូននាំគ្នារៀបគ្រាប់សណ្តែកបាយបិទលើរូបផ្លែត្រឡាចតាមក្រុមនីមួយៗត្រូវចេះរង់ចាំវេន ធ្វើម្នាក់ម្តងៗកុំដណ្តើមគ្នា ហើយដាក់ដបការ ឱ្យបានត្រឹមត្រូវប្រយ័ត្នកំពប់ប្រឡាក់រូបហើយច្រាសដុសធ្មេញពេលលាបការរួចហើយត្រូវយកក្រដាសដាក់ពីក្រោម
- គ្រូរៀបចំកុមារជាក្រុមតូចៗ ឱ្យទៅអង្គុយជារង្វង់នៅទីកន្លែងដែលកុមារបានរៀបចំ។
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារដែលគ្រូត្រៀមទុកអនុវត្ត
- គ្រូឱ្យកុមារក្នុងក្រុមនីមួយៗចាប់ផ្តើមអនុវត្តទាំងអស់គ្នាទៅតាមការណែនាំ
- គ្រូដើរសម្របសម្រួលកុមារគ្រប់ក្រុមហើយជួយកែតម្រូវក្រុមណាដែលធ្វើមិនទាន់បាន
- គ្រូប្រាប់កុមារៈបើក្រុមកូនណាធ្វើរួចហើយកូនយកទៅបិទលើក្តារខៀនតាមកន្លែងដែលគ្រូកំណត់ឱ្យទៅតាមក្រុមនីមួយៗ ហើយពួកកូនត្រូវយកសម្ភារទៅទុកជូនគ្រូវិញនិងនាំគ្នាទៅអង្គុយនៅតាមក្រុមធំវិញ
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលដោយឱ្យតំណាងក្រុមទៅឈរនៅជិតរូបដែលបានបិទនៅលើក្តារខៀនបន្ទាប់មកឱ្យកុមារក្រុមធំសង្កេតមើលរូបនោះ។ដើម្បីវាយតម្លៃ(តើត្រឹមត្រូវឬទេ?រៀបពេញរូបផ្លែត្រឡាចទេ? មានរៀបចេញក្រៅរូបផ្លែត្រឡាចទេ?)
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតគ្រប់ក្រុមទាំងអស់ នៅពេលផ្ទៀងផ្ទាត់មានក្រុមណាធ្វើមិនបានល្អ គ្រូមិនត្រូវស្តីបន្ទោសឡើយ។ត្រូវចេះលើកទឹកចិត្តកុមារឱ្យខិតខំប្រឹងប្រែងបន្តទៀត
- គ្រូឱ្យតំណាងក្រុមនីមួយៗដករូបចេញពីក្តារខៀនជូនគ្រូ រួចគ្រូដាក់ឈ្មោះក្រុមសម្រាប់ទុកដាក់តាំងស្នាដៃកុមារ
- គ្រូសួរកុមារៈថ្ងៃនេះកូនរៀនមុខវិជ្ជាអ្វី?អំពីអ្វី?
- គ្រូប្រាប់កុមារៈថ្ងៃនេះយើងរៀនមុខវិជ្ជាសិក្សាសង្គម អំពីសកម្មភាពកសាង«រៀបវត្ថុតូចៗបិទលើរូបផ្លែត្រឡាច»
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងអ្វីដែលគ្រូបានប្រាប់ បើមានកុមារទាយត្រូវលើកសរសើរដោយប្រើពាក្យសម្តីលើកទឹកចិត្ត
- គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀនជាក្រុមរួចទាំងអស់គ្នា។

ម៉ោងទី៨ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

## អំណានរឿង៖ បូណាជាកូនល្អ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីរបៀបកាន់និងបើកសៀវភៅអានរឿនបានត្រឹមត្រូវ
- កុមារកាន់បើកនិងអានសៀវភៅរឿងនិទានពីទំព័រមុនរហូតដល់ទំព័រចុងក្រោយបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ ចូលចិត្តអានរឿង និងស្រឡាញ់ ថែទាំសៀវភៅ

**២. សម្ភារបង្រៀន៖** សៀវភៅរឿងនិទាន«បូណាជាកូនល្អ»

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារាងអក្សរអ៊ុយ "ប"

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញក្របសៀវភៅរួចសួរថាកូនៗសង្កេតឃើញរូបភាពអ្វីខ្លះ?តើរឿងនិទាននេះមានចំណងជើងដូចម្ដេច?
- គ្រូបើកសៀវភៅបង្ហាញរូបភាពម្ដងមួយសន្លឹកៗ រហូតដល់ចប់សាច់រឿងរួចសួរកុមារថា តើរឿងនិទាននេះមានចំណងដូចម្ដេច?
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជា ភាសាខ្មែរ ចំណងជើងអំណានរឿង «បូណាជាកូនល្អ» រួចសួរថាមុននេះមានកូនណាឆ្លើយដូចចម្លើយរបស់គ្រូដែរឬទេ?
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម និងទាំងអស់គ្នា
- គ្រូប្រាប់ឈ្មោះអ្នកនិពន្ធ ៖ រឿងនេះអំៗនៅក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកនិពន្ធ ។
- គ្រូអានរឿងនិទានដោយយកដៃចង្អុលតួអក្សរឱ្យកុមារស្ដាប់ និងសង្កេតដោយមិនឱ្យបាំងរូបភាព (ធ្វើរបៀបនេះរហូតដល់ចប់សាច់រឿង)
- គ្រូនាំកុមារអាននិងពន្យល់ពាក្យពិបាកៈ
  - រង្វាន់៖ របស់ដែលថែម របស់លើកទឹកចិត្ត
  - ប្រុងប្រយ័ត្នៈ៖ ការខំប្រឹងថែទាំ ការប្រុងដោយមិនធ្វេសប្រហែស
  - ក្លាហាន៖ មោះមុត អង់អាច
  - សប្បុរសធម៌៖ ការធ្វើអំពើល្អ អ្នកប្រព្រឹត្តល្អ
- ក្រោយពីអានរឿងនេះចប់គ្រូសួរកុមារថាៈ តើក្នុងរឿងមានតួអង្គប៉ុន្មាន? តួអង្គណាខ្លះ? តើនៅផ្ទះបូណាបានជួយធ្វើការងារអ្វីខ្លះ?ហេតុអ្វីបានជាម្ដាយបូណាទិញស្បែកជើងថ្មីឱ្យបូណា?តើនៅសាលារៀនបូណាជាក្មេងដូចម្ដេច?នៅតាមផ្លូវតើបូណាបានជួយមិត្តភក្ដិអ្វីខ្លះ?(កុមារឆ្លើយតបសំណួរគ្រូទៅតាមគំនិតរបស់គេម្នាក់ៗ)
- បន្ទាប់មកគ្រូឱ្យកុមារចង្អុរនិងអានពាក្យក្នុងរឿងតាមការចងចាំឡើងវិញ (កុមារនិយាយពីអ្វីដែលគេបានចងចាំ)

អំណានរឿង «បូណាជាកុមារល្អ»

បូណាជាកុមារខិតខំរៀនសូត្រណាស់ អ្នកគ្រូតែងសរសើរបូណារាល់ថ្ងៃ នៅផ្ទះបូណាបានជួយធ្វើការឪពុកនិងម្ដាយសព្វគ្រប់ ដូចជាដងទឹក ជញ្ជូនអុស ស្រោចបន្លែ និងជួយបោសផ្ទះសំបែង។ ដោយឃើញកូនឧស្សាហ៍ធ្វើការខិតខំរៀនសូត្រ ម្ដាយបូណាក៏ទិញស្បែកជើងមួយគូឱ្យជារង្វាន់ដល់បូណា។ ស្បែកជើងនោះស្អាតណាស់ បាតវាធ្វើអំពីកៅស៊ូ បូណាពាក់ស្បែកជើងថ្មីទៅរៀនរាល់ថ្ងៃដោយប្រុងប្រយ័ត្នខ្លាចដាច់ខ្សែ ឬ

ប្រឡាក់ភក់។ ថ្ងៃមួយមេឃភ្លៀងខ្លាំងនៅតាមផ្លូវមានទឹកដក់ជាថ្លុកធំៗ បូណាត្រូវលោតឆ្លងថ្លុកនោះតែភ្លាត់ស្នៀតបូណាផុងជើងចូលក្នុងភក់នាំឱ្យប្រឡាក់ស្បែកជើងថ្មី និងខោ អាវ បូណាចង់យំ។ ពេលនោះមានមិត្តភក្តិរួមថ្នាក់ជាច្រើនដើរមកដល់ បូណាឃើញក៏រាំងឃាត់មិនទាន់ឱ្យមិត្តឆ្លងថ្លុក ហើយក៏ស្ទុះទៅយកក្តារមួយបន្ទះវែងមកដាក់ធ្វើជាស្ពានឱ្យមិត្តទាំងអស់គ្នាឆ្លងដោយស្រួល គ្មានប្រឡាក់ជើងនិងខោអាវឡើយ មិត្តទាំងអស់បានចាប់ដៃ ទះស្នា អរគុណ និងសរសើរដល់សេចក្តីក្លាហាន និងទឹកចិត្តសប្បុរសធម៌ របស់បូណា។

**ម៉ោងទី៦ (រយៈពេល ៣០នាទី)**

## មុខវិជ្ជា៖ សិក្សាសង្គម

* ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

## ថ្ងៃទី១០

ម៉ោងទី១ (រយៈពេល៣០នាទី)

### មុខវិជ្ជា៖ ចិត្តចលភាព

រំលឹក **ចលនាចរន្ត៖ ដើរ រត់ លោត វារ (ដើរតាមផ្លូវ រត់វិលងឧបសគ្គ លោតចូលកងឬរង្វង់ វារក្រោមតុ)**

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី៥ ម៉ោងទី១)

ម៉ោងទី ២ (រយៈពេល ៣០នាទី)

### មុខវិជ្ជា៖ សិក្សាសង្គម

### សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ"(ដំណើរការបង្រៀនអនុវត្តដូច ខែទី១ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ ត្រូវចេះស្តាប់ដំបូន្មានគ្រូ និងឪពុកម្តាយ(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១០ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

### មុខវិជ្ជា៖ ភាសាខ្មែរ

### សន្ទនា៖ សម្ភារប្រើប្រាស់ប្រចាំថ្ងៃដែលស្រឡាញ់ពេញចិត្ត

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីសម្ភារប្រើប្រាស់ប្រចាំថ្ងៃ ដែលខ្លួនស្រឡាញ់ពេញចិត្ត ប្រាប់មិត្តភក្តិបានច្បាស់លាស់
- កុមារកំណត់ពីអត្ថប្រយោជន៍សម្ភារប្រើប្រាស់ ប្រចាំថ្ងៃដែលខ្លួនស្រឡាញ់ពេញចិត្តបានត្រឹមត្រូវ
- កុមារស្រឡាញ់ និង ថែរក្សាសម្ភារដែលខ្លួនប្រើប្រាស់ប្រចាំថ្ងៃបានល្អប្រសើរ (ប្រើប្រាស់បានយូរ)

**២. សម្ភារបង្រៀន៖** តុក្កតា២

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាអក្សរអ៊ើយ "U" កុមារចាប់ដៃគូគ្នា២នាក់ៗ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញតុក្កតា កុមារ២នាក់ ឈរសន្ទនាគ្នា ដើម្បីអោយកុមារទស្សន៍ទាយ បង្កើនការគិតមុនធ្វើកម្មភាព

**+ មេរៀនដោយសួរថា៖**

- កូនមើលនៅដៃគ្រូមានអ្វី? កូនណាអាចប្រាប់បាន? (កុមារឆ្លើយតាមការយល់ឃើញរបស់គេ)
- គ្រូធ្វើបង្ហាញពីការសន្ទនាគំរូ៖ ដោយកាន់តុក្កតា (តំណាងកុមារា នៅដៃស្តាំ និងតំណាងកុមារីនៅដៃឆ្វេង រួចសម្តែងការសន្ទនាគ្នា៖
- តុក្កតា (កុមារា) ដៃស្តាំ និយាយ៖ ជម្រាបសួរសំឡាញ់! តើសំឡាញ់ប្រាប់ពីឈ្មោះសម្ភារប្រើប្រាស់ប្រចាំថ្ងៃដែលសំឡាញ់ ស្រឡាញ់ពេញចិត្ត ដល់ខ្ញុំបានទេ?
- តុក្កតា (កុមារី) ដៃឆ្វេង និយាយតប៖ ជម្រាបសួរសំឡាញ់! សម្ភារប្រើប្រាស់ប្រចាំថ្ងៃដែលខ្ញុំស្រឡាញ់ គឺ កាតាបស្ពាយមកសាលារៀនរបស់ខ្ញុំ! ស្បែកជើងពណ៌ផ្កាឈូក! បំពង់ទឹកពណ៌ផ្កាឈូករបស់ខ្ញុំ!

- តុក្កតា(កុមារា) ដៃស្តាំនិយាយៈហេតុអ្វីបានជាសំឡាញ់ស្រឡាញ់ពេញចិត្តសម្ភារទាំងនេះជាងគេ?
- តុក្កតា (កុមារី) ដៃឆ្វេង ឆ្លើយៈ ពីព្រោះកាបូបស្ពាយ ស្បែកជើង និងបំពង់ទឹករបស់ខ្ញុំ មានពណ៌ផ្កាឈូក ហើយមានរូបតុក្កតាដែលខ្ញុំពេញចិត្ត!ចុះសំឡាញ់វិញ មានសម្ភារប្រើប្រាស់អ្វីខ្លះដែលស្រឡាញ់ពេញចិត្ត?

- តុក្កតា ដៃស្តាំ (កុមារា) ឆ្លើយៈ សម្ភារប្រើប្រាស់ប្រចាំថ្ងៃដែលខ្ញុំស្រឡាញ់ពេញចិត្ត គឺកាបូបស្ពាយ អាវសដៃខ្លី និងខោខ្លីពណ៌របស់ខ្ញុំ
- តុក្កតា (កុមារី) ដៃឆ្វេង សួរបន្តៈ ហេតុអ្វីបានជាសំឡាញ់ស្រឡាញ់ពេញចិត្តសម្ភារទាំងនោះ?
- តុក្កតា ដៃស្តាំ (កុមារា) ឆ្លើយៈ ព្រោះកាតាបស្ពាយខ្ញុំមានពណ៌ខៀវ និងមានរូបតុក្កតាដែលខ្ញុំស្រឡាញ់ ចំណែកឯខោ និងអាវនេះគឺម៉ាក់ទើបនឹងទិញឱ្យខ្ញុំ វាថ្មី ហើយស្អាត!
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញ ពីការនិយាយសន្ទនារបស់តុក្កតា ដូចគ្រូបានបង្ហាញ បើកុមាររៀបរាប់មិនទាន់បានត្រឹមត្រូវ គ្រូបំពេញបន្ថែមដោយនិយាយថាៈ •តើកូនណា និយាយឡើងវិញពីការសន្ទនាសម្ភារប្រើប្រាស់ប្រចាំថ្ងៃដែលស្រឡាញ់ពេញចិត្ត ដូចតុក្កតានិយាយគ្នាអម្បាញ់មិញបានទេ?
- គ្រូឱ្យកុមារចាប់ដៃគូគ្នា ២នាក់ៗ និយាយសន្ទនាប្រាប់ពីសម្ភារប្រើប្រាស់ប្រចាំថ្ងៃដែលស្រឡាញ់ពេញចិត្ត ដូចគំរូដែលគ្រូធ្វើបង្ហាញតាមតុក្កតា ខាងលើ
- គ្រូដើរសម្របសម្រួលការសន្ទនាដៃគូកុមារ នីមួយៗ ដើម្បីឱ្យការនិយាយសន្ទនាបានត្រឹមត្រូវ
- គ្រូនិយាយប្រាប់ ពីអត្ថប្រយោជន៍នៃសម្ភារប្រើប្រាស់ប្រចាំថ្ងៃ។ ដើម្បីឱ្យសម្ភារប្រើប្រាស់ប្រចាំថ្ងៃ ដែលកូនស្រឡាញ់ពេញចិត្ត នៅប្រើប្រាស់បានយូរ តើកូនត្រូវធ្វើដូចម្តេច?
- គ្រូលើកសរសើរចំពោះដៃគូសន្ទនានីមួយៗ
- គ្រូសួរកុមារ រកចំណងជើងមេរៀន បើកុមារឆ្លើយមិនទាន់ត្រឹមត្រូវ គ្រូប្រាប់ៈ
  - កូនៗទាំងអស់គ្នា! អំបាញ់មិញយើងនាំគ្នាសន្ទនាគ្នាអំពីអ្វី កូនណាអាចប្រាប់បាន? អញ្ចឹងថ្ងៃនេះយើងរៀនពីមេរៀនអ្វី?
  - គ្រូប្រាប់ ថ្ងៃនេះកូន រៀនមុខវិជ្ជាភាសាខ្មែរ ចំណងជើងមេរៀន សន្ទនាៈ "សម្ភារប្រើប្រាស់ប្រចាំថ្ងៃដែលស្រឡាញ់ពេញចិត្ត"
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ២ទៅ៣ដង

**ម៉ោងទី៤ (រយៈពេល ៣០នាទី)**

## មុខវិជ្ជាៈ សិក្សាសង្គម

## ល្បែងៈ បង្កើតក្រុមតាមសំឡេងដូចគ្នា

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីសំឡេងរបស់សត្វនីមួយៗ បានត្រឹមត្រូវ
- កុមារធ្វើត្រាប់តាមសំឡេងសត្វនីមួយៗ បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន និងមានភាពសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** បណ្ណសម្គាល់សត្វ

៣. **ការរៀបចំកុមារ៖** អង្គុយជារាងអក្សរអ៊ុយ "U" ឈរជារង្វង់

៤. **ដំណើរការបង្រៀន(អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូសួរ តើកូនៗធ្លាប់ស្គាល់សំឡេងសត្វអ្វីខ្លះ? កុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ ដូច្នេះកូនៗទាយមើលថាថ្ងៃនេះគ្រូបង្រៀនកូនពីមុខវិជ្ជាអ្វី? អំពីអ្វី? ឱ្យកុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ ។ ពេលកុមារប្រាប់រួច គ្រូត្រូវសរុបនូវអ្វីដែលពួកគេបានប្រាប់
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះគ្រូបង្រៀនមុខវិជ្ជាសិក្សាសង្គម **អំពីល្បែងបង្កើតក្រុមតាមសំឡេងដូចគ្នា**
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងការនិយាយប្រាប់របស់គ្រូ ដោយសួរកុមារថា តើអម្បាញ់មិញមានកូនណាទាយត្រូវឬទេ? បើមានមិត្តភក្តិយើងទាយត្រូវដូចនេះកូនៗនាំគ្នាទះដៃសរសើរមិត្តភក្តិយើងទាំងអស់គ្នា។ ឯកូនដែលទាយមិនទាន់ត្រូវ កូនក៏ឆ្លាតដែរ ព្រោះកូនបានឆ្លើយនឹងសំណួរ តែថ្ងៃក្រោយកូនត្រូវគិតបន្ថែម ហើយចាំឆ្លើយសំណួរគ្រូទៀតណា !
- គ្រូនាំកុមារអានពីមុខវិជ្ជា និងចំណងជើងមេរៀន (ជាក្រុម និងទាំងអស់គ្នា)
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនលេងទាំងអស់គ្នា ហើយឈរជារង្វង់
  - កូនម្នាក់ៗត្រូវបានបណ្ណសម្គាល់រូបសត្វម្នាក់មួយសន្លឹក ។ នៅពេលកូនបានបណ្ណសម្គាល់រូបសត្វគ្រប់ៗគ្នាហើយ កូនត្រូវនាំគ្នាធ្វើត្រាប់តាមសំឡេងសត្វទៅតាមបណ្ណសម្គាល់រូបសត្វនីមួយៗម្នាក់ម្តងៗ
  - ពេលគ្រូឱ្យសញ្ញាចាប់ផ្តើម ដោយរាប់ ១ ២ ៣ កូនៗត្រូវកាន់បណ្ណសម្គាល់រូបសត្វរួចដើរជារង្វង់។ ពេលកូនដើរបណ្តើរ ត្រូវធ្វើជាសំឡេងត្រាប់តាមសត្វដែលកូនបានកាន់
  - ពេលគ្រូឱ្យសញ្ញាទះដៃពីរដង កូនត្រូវរត់រកមិត្តភក្តិយើងដែលមានកាន់បណ្ណសម្គាល់រូបសត្វដូចៗ ដូចគ្នា ។
- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្តងទៀត)
- គ្រូនាំកុមារលេងដោយឱ្យកុមារឈរជារង្វង់ ហើយគ្រូជាអ្នកឱ្យសញ្ញាចាប់ផ្តើម
- គ្រូនាំកុមារលេងបន្តបន្ទាប់រហូតចប់ម៉ោង
- ពេលបញ្ចប់ការលេងរួច គ្រូឱ្យកុមារទៅអង្គុយក្រុមធំវិញ ។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

### ពិសោធន៍៖ ភ្លក្សរសជាតិផ្លែឈើ

១. **វត្ថុបំណង៖**

- កុមារប្រាប់ពីរសជាតិផ្លែឈើនីមួយៗ បានត្រឹមត្រូវ
- កុមារសន្និដ្ឋានពីរសជាតិផ្លែឈើនិមួយៗ បានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់តាមដាននិងចូលរួមដោយសប្បាយរីករាយ។

២. **សម្ភារបង្រៀន៖** ផ្លែប៉ោម ផ្លែចេកខ្ចី ផ្លែខ្នុរទុំ ផ្លែម្កាក់ ចាន កាំបិត

៣. **ការរៀបចំកុមារ៖** អង្គុយជាអក្សរអ៊ុយ "U" និងក្រុមតូច

៤. **ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូដាក់សម្ភារក្នុងថង់នៅលើតុមុខកុមារ (ផ្លែចេកខ្ចី ផ្លែខ្នុរទុំ ផ្លែម្កាក់ ផ្លែប៉ែរ...)
- គ្រូអោយកុមារមួយនាក់ដែលស្ម័គ្រចិត្តមកយកសម្ភារពីក្នុងថង់នៅលើតុម្តងមួយៗដើម្បីបង្ហាញរួចឱ្យមិត្តភក្តិជាអ្នកប្រាប់ឈ្មោះ បើកុមារមិនស្គាល់ផ្លែឈើណាមួយទេគ្រូត្រូវប្រាប់កុមាររួចឱ្យកុមារថាតាម។
- គ្រូរៀបចំផ្លែឈើដែលបានចិតរួចបង្ហាញកុមារ
- គ្រូសួរកុមារ
  - តើផ្លែឈើទាំងអស់នេះគ្រូយកមកឱ្យកូនដើម្បីធ្វើអ្វី?
  - ពេលកូនយកផ្លែឈើទាំងអស់នេះទៅញ៉ាំ តើកូនដឹងថារសជាតិវាយ៉ាងដូចម្តេចដែរ?
- គ្រូត្រូវសរសេរចម្លើយរបស់កុមារនៅកៀនក្តារខៀន ពេលកុមារឆ្លើយប៉ាន់ស្មានដើម្បីទុកផ្ទៀងផ្ទាត់។
- គ្រូណែនាំកុមារពីរបៀបអនុវត្តទៅតាមក្រុម
  - គ្រូអោយកូនលេងជាក្រុមតូចៗ ហើយក្នុងមួយក្រុមកូនត្រូវបានសម្ភារទាំងអស់នេះមួយឈុត
  - គ្រូប្រាប់កុមារៈ កូនត្រូវយកសម្ភារទាំងអស់នេះទៅដាក់កណ្តាលវង់ បន្ទាប់មកកូននាំគ្នាញ៉ាំផ្លែឈើម្តងមួយមុខៗ ដោយមិនដណ្តើមគ្នា ត្រូវចេះរង់ចាំវេន ធ្វើម្តងម្នាក់ៗ
  - កូនត្រូវនាំគិតពីរសជាតិផ្លែឈើទាំងនោះ តើមានរសជាតិយ៉ាងដូចម្តេចដែរ?
  - ពេលកូននាំគ្នាអនុវត្ត ធ្វើយ៉ាងណាកុំឱ្យកំពប់ផ្លែឈើចេញពីចាន ដែលនាំឱ្យកង្វះអនាម័យ
- គ្រូឱ្យកុមារ១ឬ ២ ម្នាក់ស្ម័គ្រចិត្តឡើងមកនិយាយប្រាប់ពីអ្វីដែលគ្រូបានប្រាប់ បើនិយាយមិនបានត្រឹមត្រូវទ ឱ្យមិត្តភក្តិជួយបំពេញបន្ថែម បើនៅតែនិយាយមិនបានពេញលេញគ្រូត្រូវនិយាយប្រាប់កុមារសាឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមតូចៗរួចឱ្យទៅអង្គុយជារង្វង់នៅទីកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅអនុវត្ត ពិសោធន៍តាមក្រុម
- គ្រូឱ្យក្រុមទាំងអស់អនុវត្តពិសោធន៍ ក្នុងពេលតែមួយ
- គ្រូដើរសម្របសម្រួលទៅតាមក្រុមនីមួយៗនិងជួយបំផុសគំនិតបន្ថែមដើម្បីឱ្យធ្វើបានត្រឹមត្រូវ
- គ្រូឱ្យកុមារទៅអង្គុយនៅក្រុមធំវិញហើយនាំគ្នាយកសម្ភារទៅទុកឱ្យគ្រូ ពេលគេធ្វើរួចគ្រប់ក្រុម
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍ពីលទ្ធផលនៃការពិសោធន៍
- គ្រូសរុបលទ្ធផលរបស់កុមារគ្រប់ក្រុមតាមលទ្ធផលដែលពួកគេបានរាយការណ៍(ផ្លែប៉ែរមានរសជាតិសាប ផ្លែខ្នុរទុំ មានរសជាតិផ្អែម ផ្លែម្កាក់មានរសជាតិជូរ ផ្លែចេកខ្ចីមានរសជាតិចត់)
- គ្រូប្រាប់កុមារៈ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមកូនៗដែលបានរាយការណ៍ដូចនេះគ្រូយកសម្ភារទាំងនេះមកអនុវត្តជាមួយកូនម្តងទៀត
- គ្រូយកសម្ភារទាំងនោះមកដាក់នៅលើតុមុខកុមាររួចឱ្យកុមារស្ម័គ្រចិត្តមួយនាក់យកផ្លែឈើញ៉ាំម្តងមួយៗរហូតដល់គ្រប់មុខផ្លែឈើ
- នាំកុមារភ្លក្សទាំងអស់គ្នា ហើយផ្ទៀងផ្ទាត់ទៅនឹងចម្លើយពេលពិសោធន៍ឃើញនឹងចម្លើយពេលប៉ាន់ស្មានទុកមុនពិសោធន៍ ដែលគ្រូបានសរសេរទុកលើក្តារខៀន
- គ្រូធ្វើរបៀបនេះទាល់តែអស់សម្ភារ
- គ្រូបូកសរុប និងសន្និដ្ឋានៈ
  - គ្រូប្រាប់កុមារៈ ផ្លែប៉ែរមានរសជាតិសាប ផ្លែខ្នុរទុំ មានរសជាតិផ្អែម ផ្លែម្កាក់មានរសជាតិជូរ ផ្លែ

ចេកខ្ទីមានរសជាតិចត់( នាំកុមារអានជាក្រុមទាំងអស់គ្នា )

- នាំកុមារអានពាក្យថ្មី និងពន្យល់អត្ថន័យនៃពាក្យ «ភ្លក្ស»មានន័យថាហូបសាកល្បង ( រួចនាំកុមារអានជាក្រុមនិងទាំងអស់គ្នា )
- ណែនាំកុមារពីសារៈប្រយោជន៍នៃការញ៉ាំផ្លែឈើ ដែលធ្វើឱ្យមានសុខភាពល្អ

- គ្រូសួរកុមារៈ អម្បាញ់មិញកូននាំគ្នាធ្វើអ្វីខ្លះ ? ដូច្នេះយើងនាំគ្នារៀនមុខវិជ្ជាអ្វី ?អំពីអ្វី ?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ អំពីពិសោធន៍ «ភ្លក់រសជាតិផ្លែឈើ »
- គ្រូផ្ទៀងផ្ទាត់ចម្លើយកុមារទៅនឹងការប្រាប់របស់គ្រូ។
- នាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន ( ជាក្រុមនិងទាំងអស់គ្នា )។

### ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

* ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦ )

## ថ្ងៃទី១១

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

## ល្បែងចលនា៖ បង់សំណាញ់

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបលេងល្បែងបង់សំណាញ់ បានត្រឹមត្រូវ
- កុមារលេងល្បែងបង់សំណាញ់ បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន ប្រុងប្រយ័ត្ន និងសប្បាយរីករាយ ។

**២. សម្ភារៈបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** ចែកកុមារជាពីរ២ក្រុមហើយឱ្យកុមារឈរជារង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកូនលេងទាំងអស់គ្នា ហើយលេងនៅក្រៅថ្នាក់រៀន
- គ្រូចែកកូនជា២ក្រុមដែលមានចំនួនស្មើគ្នា ហើយមួយក្រុមកូនធ្វើជាសំណាញ់ ហើយមួយក្រុមទៀតធ្វើជាត្រី
- កូនដែលធ្វើជាសំណាញ់ត្រូវកាន់ដៃគ្នាឈរធ្វើរង្វង់ ឯកូនដែលធ្វើជាត្រី ត្រូវនៅឈរជុំវិញសំណាញ់។ ហើយក្រុមសំណាញ់ត្រូវជជែកគ្នា ពីពេលវេលាដែលត្រូវទម្លាក់ដៃចុះ កូនអាចនាំគ្នារាប់លេខក៏បាន រាប់អក្សរក៏បានច្រៀងក៏បាន ប៉ុន្តែជជែកគ្នាបើរាប់លេខ តើរាប់ពីលេខណាដល់លេខប៉ុន្មាន ទើបបទម្លាក់ដៃចុះ ហើយមិនឱ្យក្រុមត្រីដឹងទេ
- ពេលគ្រូឱ្យសញ្ញាចាប់ផ្ដើមដោយទះដៃ២ដងក្រុមកូនដែលធ្វើសំណាញ់នាំគ្នារាប់ ពីលេខ១រហូតដល់ លេខដែលត្រូវឈប់ហើយដៃដែលកាន់គ្នាលើកឡើងទៅលើដើម្បីក្រុមត្រីរត់ចុះរត់ឡើង ចូលក្នុងរង្វង់ និងចេញកក្រៅរង្វង់។
- រីឯក្រុមកូនដែលជាត្រី ត្រូវរត់ចុះរត់ឡើងចូលក្នុងរង្វង់និងចេញក្រៅរង្វង់ មិនត្រូវរត់តែក្រៅៗ រង្វង់ នោះទេ
- ក្រុមកូនធ្វើសំណាញ់ពេលរាប់លេខដល់លេខដែលបានកំណត់គ្នាសម្រាប់ទម្លាក់ដៃចុះ។ ដែលនៅក្នុងវង់នោះត្រូវសំណាញ់ចាប់បានដូច្នេះត្រូវចេញទៅនៅមួយកន្លែង។ហើយកូនបន្តលេងទៀតរហូតដល់នៅសល់ត្រីតែមួយទើបឈប់ហើយកូនត្រូវចាប់ផ្ដើមសាថ្មីម្ដងទៀត ដោយក្រុមត្រីទៅធ្វើជាសំណាញ់ ហើយក្រុមសំណាញ់ទៅធ្វើជាត្រីវិញម្ដង

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូចខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ ត្រូវចេះអរគុណពេលទទួលបានអ្វីៗឬមានការជួយពីមិត្តភក្តិ និងមនុស្សធំ

- គ្រូប្រើតុក្កតាដើម្បីសំដែង៖ សួស្តី! មិត្តភក្តិទាំងអស់គ្នា ថ្ងៃនេះខ្ញុំសុំចូលរៀនជាមួយផងបានទេ?អរគុណ ហើយមិត្តភក្តិទាំងអស់គ្នាដែលបានឱ្យខ្ញុំចូលរៀន។
- តុក្កតាក៏និយាយទៅកាន់មិត្តភក្តិទាំងអស់គ្នាថា៖ មុនពេលខ្ញុំមករៀនម៉ាក់ខ្ញុំគាត់បានឱ្យនំមួយកញ្ចប់ ហើយខ្ញុំក៏ទទួលយកមក ហើយខ្ញុំក៏ជម្រាបលាគាត់ចេញមករៀន។ ពេលខ្ញុំដើរមកតាមផ្លូវស្រាប់តែខ្ញុំ ជំពប់ជើងដួល ពេលនោះមានពូម្នាក់មកជួយលើកខ្ញុំ និងសួរខ្ញុំថា តើក្មួយមានត្រូវអ្វីទេ ខ្ញុំក៏ឆ្លើយថាមិន ត្រូវអ្វីទេ។ រួចខ្ញុំក៏ជម្រាបលាពូដើរទៅមុខទៀត។
- តុក្កតាក៏សួរទៅមិត្តភក្តិគេថា៖ តើខ្ញុំធ្វើរបៀបនេះត្រូវឬទេ? បើមិនត្រូវតើខ្ញុំគួរធ្វើដូចម្តេចវិញ?
- គ្រូប្រាប់កុមារ៖ កូនៗជួយប្រាប់មិត្តភក្តិយើងផង តើគេត្រូវធ្វើដូចម្តេចជាមួយម្តាយពេលម្តាយឱ្យនំចំណី និងត្រូវធ្វើដូចម្តេចពេលពូមកជួយលើកពេលកូនដួល?
- តុក្កតាក៏និយាយបន្តទៀតថា៖ ខ្ញុំអរគុណមិត្តភក្តិទាំងអស់គ្នាហើយ ដែលបានជួយប្រាប់ខ្ញុំ ដូច្នេះខ្ញុំនឹងធ្វើ តាមអ្វី ដែលមិត្តភក្តិទាំងអស់គ្នាបានប្រាប់ទាំងនៅផ្ទះ ទាំងនៅសាលារៀន និងទាំងនៅក្នុងពិធីផ្សេងៗ។ ខ្ញុំលា មិត្តភក្តិទាំងអស់គ្នាហើយណាថ្ងៃក្រោយជួបគ្នាទៀត។
- ពេលតុក្កតាសម្តែងចប់ គ្រូត្រូវប្រាប់កុមារបន្ថែម បើមានអ្នកណាម្នាក់ឱ្យអ្វីមកកូន ដូចជានំ សម្ភារលេង កាដូ កូនត្រូវលើកដៃសំពះហើយថាអរគុណ និងទទួលយកដោយដៃទាំងពីរ។ ម្យ៉ាងទៀតពេលកូនជួប បញ្ហាអ្វីមួយ ដូចជាដួល វង្វេងផ្លូវ ឆ្កែដេញខាំ និងមានអ្នកមកជួយ កូនត្រូវលើកដៃសំពះហើយថាអរគុណ អ្នកនោះ។

* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១១ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

## ប្រៀបធៀប៖ ចំនួនស្មើគ្នា តិចជាង ច្រើនជាង ក្នុងចំនួនពី១ដល់១០

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីការប្រៀបធៀបចំនួនស្មើគ្នា តិចជាង ច្រើនជាងក្នុងចំនួនពី១ ដល់១០ បានត្រឹមត្រូវ
- កុមារប្រៀបធៀបចំនួនស្មើគ្នា តិចជាង ច្រើនជាងក្នុងចំនួនពី១ ដល់១០ បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ ព្យាយាម និងចូលរួមយ៉ាងសកម្ម ។

**២. សម្ភារបង្រៀន៖**

- ដបទឹកសុទ្ធមួយក្រុមចំនួន ៦ ដែលមានបិទលេខចន្លោះពី១ ដល់១០ក្នុង១ក្រុម(ដបខ្លះបិទលេខដូចគ្នា ដបខ្លះបិទលេខមិនដូចគ្នា)

-គ្រាប់ក្រួសចំនួន៥៥ គ្រាប់ក្នុងមួយក្រុម

**៣. ការរៀបចំកុមារ៖** ឱ្យកុមារឈរជា ២ជួរ រៀបចំកុមារជា៤ក្រុម

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនដល់កុមារ រួចសរសេរលើក្តារខៀន ហើយនាំកុមារអានជាក្រុម និងទាំងអសស់គ្នា
- គ្រូឱ្យកុមាររាប់ពី១ ដល់ ១០ជាក្រុម និងទាំងអស់គ្នា

- គ្រូយកសម្ភារមកឱ្យកុមារសង្កេត និងប្រាប់ពីឈ្មោះ
- គ្រូសួរកុមារថា **ចូរកូនគិតទៅមើលតើ យើងនឹងលេងអ្វីជាមួយនឹងដបទឹកសុទ្ធ និងគ្រាប់ក្រួសនេះ?**
- **គ្រូណែនាំពីរបៀបលេង និងលក្ខខណ្ឌនៃការលេង៖**
  - គ្រូចែកកូនជា៤ ក្រុមអង្គុយជារង្វង់ជុំវិញតុ ឬកន្ទេល ហើយកូនដែលជាតំណាងក្រុមនីមួយៗត្រូវឡើងមកយកសម្ភារលេងពីគ្រូ
  - ពេលដែលកូនៗក្រុមនីមួយៗទទួលបានសម្ភារហើយ កូនត្រូវយកគ្រាប់ក្រួស ដាក់ចូលក្នុងដបទៅតាមចំនួនលេខដែលបិទនៅលើដប។ បន្ទាប់មកកូនត្រូវតម្រៀប ដបដែលមានចំនួនគ្រាប់ក្រួសស្មើគ្នាទុកមួយឡែក ដបដែលមានគ្រាប់ក្រួសតិចទុកមួយឡែក ហើយដបដែលមានគ្រប់ក្រួសច្រើនជាង ទុកមួយឡែក ។ កូនៗក្រុមណាដែលធ្វើរួច ត្រូវទះដៃចំនួន៣ដង ដើម្បីបញ្ជាក់ថាក្រុមរបស់ខ្លួនបានធ្វើរួច ។
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមដំណាក់កាលនីមួយៗ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូឱ្យកុមារអនុវត្តលេងតាមក្រុមៗ ដោយគ្រូដើរជួយសម្របសម្រួលសកម្មភាពតាមក្រុម
- គ្រូផ្ទៀងផ្ទាត់ និងវាយតម្លៃលទ្ធផលប្រៀបធៀបនៃការអនុវត្តរបស់កុមារ ដោយចាប់យកលទ្ធផលរបស់ក្រុមណាមួយក្នុងចំណោមក្រុមទាំង៤ មកធ្វើការផ្ទៀងផ្ទាត់
- គ្រូលើកសសើរ និងលើកទឹកចិត្តដល់កុមារដែលបានខិតខំប្រឹងប្រែង មិនត្រូវបណ្តុះបង្អាប់ក្រុមដែលអនុវត្តមិនទាន់ត្រឹមត្រូវឡើយ
- គ្រូសួរកុមារឡើងវិញមេរៀនដែលបានរៀន ថា៖ **តើមុខវិជ្ជាអ្វីដែលកូនរៀននៅម៉ោងនេះ? តើមានចំណងជើងមេរៀនអ្វី?**(កុមារឆ្លើយតាមការចងចាំ)
- គ្រូនាំកុមារអានចំណងជើងលើក្តារខៀនឡើងវិញជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## រឿងនិទាន៖ ទន្សាយចង់ស៊ីចេក (និទាន)

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីសកម្មភាពតួអង្គតាមដំណើររឿង បានត្រឹមត្រូវ
- កុមារនិទានរឿងនិងវិភាគតួអង្គក្នុងរឿង បានត្រឹមត្រូវ
- កុមារឈ្លាសវៃ រហ័សរហួន ច្នៃប្រឌិត សហការនិងស្រឡាញ់ចូលចិត្តស្តាប់រឿងនិទាន។

**២. សម្ភារបង្រៀន៖** សៀវភៅរឿងនិទាន

**៣. ការរៀបចំកុមារ៖** អង្គុយជារាងអក្សរ អ៊ុយ "U"

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)
- តើកូនៗទាំងអស់គ្នាធ្លាប់ស្គាល់សត្វទន្សាយដែរឬទេ? តើទន្សាយមានជើងប៉ុន្មាន?តើទន្សាយជាសត្វដូចម្តេច ? ជាប្រភេទសត្វឆ្លាត ឬមិនឆ្លាត? (កុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ) បើកូនៗចង់ដឹងច្បាស់ កូនត្រូវយកចិត្តទុកដាក់ស្តាប់គ្រូនិទានរឿងណា !

- គ្រូនិទានរឿងឱ្យកុមារស្តាប់ ដោយលើកដាក់សំឡេង កាយវិការ ទឹកមុខ ទៅតាមតួអង្គក្នុងសាច់រឿង
មានទន្សាយមួយឃើញយាយទូលចេកដើរមក វាធ្វើពុតជាងាប់នៅក្បែរផ្លូវ ។ យាយឃើញទន្សាយ ត្រេកអរណាស់ក៏លើកទន្សាយដោយដៃទាំងពីរដាក់លើល្អីចេក រួចទូលដើរទៅ ។ ទន្សាយបកចេកស៊ីគ្មានសំចៃម្តងមួយៗទាល់តែអស់នៅសល់តែសំបក រួចលោតចូលព្រៃបាត់ ។ យាយមកដល់ផ្ទះដាក់ល្អីចុះ លើកដៃទះទ្រូង ហើយលាន់មាត់ថា៖ យី! ថ្ងៃនេះអញចាញ់បោកទន្សាយទេតើ ។
- ពន្យល់ន័យនៃពាក្យពិបាក៖
  - ធ្វើពុត៖ ល្បិច លាក់អំពើខូចរបស់ខ្លួន
  - ត្រេកអរ៖ រំភើប សប្បាយរីករាយ
  - គ្មានសំចៃ៖ គ្មានសន្សំទុក
- បំផុសសំណួរឱ្យកុមារយល់ដឹងពីអត្ថន័យនៃសាច់រឿង (ខ្លឹមសារ តួអង្គ និងការអប់រំ......)
- អត្ថន័យរឿងគឺអប់រំកូនឱ្យចេះប្រុងប្រយ័ត្នគ្រប់ជ្រុងជ្រោយ ក្រែងធ្វើអ្វីមួយចាញ់បោកគេ ដូចយាយអញ្ចឹង ។
- ក្រោយពីស្តាប់រឿងនេះចប់ តើក្នុងរឿងមានតួអង្គប៉ុន្មាន? តួអង្គណាខ្លះ? តើហេតុអ្វីបានជាទន្សាយ ធ្វើពុតជាងាប់? តើយាយនិយាយថាដូចម្តេច? (កុមារឆ្លើយតបសំណួរគ្រូទៅតាមគំនិតរបស់គេម្នាក់ៗ)
- សង្ខេបរឿងឱ្យកុមារស្តាប់ឡើងវិញ ៖
- កុមារនិយាយសង្ខេបរឿងឡើងវិញឱ្យមិត្តភក្តិស្តាប់ (កុមារនិយាយពីអ្វីដែលគេបានចងចាំ)
- បំផុសកុមាររកចំណងជើងរឿង៖ កូនៗអាចទាយបានទេ ថារឿងរបស់យើងចង់និយាយពីអ្វី? មានចំណងជើងអ្វី?(កុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ) ។
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះយើងរៀនមុខវិជ្ជារឿងនិទាន ដែលមានចំណងជើងថា " **ទន្សាយចង់ស៊ីចេក** "
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារ ដែលបានទាយទៅនឹងអ្វីដែលគ្រូបានប្រាប់
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ប្រាប់ឈ្មោះអ្នកនិពន្ធ ៖ រឿងនេះ អ៊ំៗនៅក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកនិពន្ធ ។

**ម៉ោងទី៨ (រយៈពេល ៣០នាទី)**

## មុខវិជ្ជា៖ ភាសាខ្មែរ

## ល្បែង៖ គូសវង់រូបភាពមិនមែនបន្លែនិងផ្លែឈើ

### ១. វត្ថុបំណង៖

- កុមារប្រាប់បានពីរបៀបគូសវង់រូបភាពមិនមែនជាបន្លែនិងផ្លែឈើ បានត្រឹមត្រូវ
- កុមារគូសវង់រូបភាពមិនមែនជាបន្លែនិងផ្លែឈើ បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** ផ្ទាំងរូបភាពចំនួន៤ផ្ទាំង ខ្មៅដៃ ជ័រលុប ហ្វឺត ស្កុត កន្ត្រៃ

### ៣. ការរៀបចំកុមារ៖

- ឱ្យកុមារអង្គុយជារាងអក្សរអ៊ុយ "U" និងក្រុមតូចៗជារង្វង់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញផ្ទាំងរូបភាពដែលមានបន្លែ ផ្លែឈើ សត្វ ឬវត្ថុផ្សេងៗ (នៅក្នុងផ្ទាំងតែមួយ)

- គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង
  - គ្រូឱ្យកូនលេងនៅតាមក្រុម ក្នុងមួយក្រុមមានផ្ទាំងរូបភាពមួយសន្លឹកនិងខ្មៅដៃ ឬហ្វឺត
  - ពេលក្រុមនីមួយៗបានផ្ទាំងរូបភាពនោះហើយកូនត្រូវនាំគ្នាសង្កេតរូបភាពទាំងនោះ ពេលកូនសង្កេតកូនកុំដណ្ដើមគ្នាត្រូវសង្កេតម្ដងម្នាក់
  - ពេលកូនសង្កេតរួចហើយកូនត្រូវយកខ្មៅដៃ ឬហ្វឺត ទៅគូសវង់ជុំវិញរូបភាពដែលមិនមែនជាបន្លែនិងផ្លែឈើ ហើយពេលគូសកូនត្រូវចែកគ្នាគូសម្ដងម្នាក់ៗ កូនត្រូវចេះរង់ចាំវេន
  - ពេលក្រុមកូនណាធ្វើហើយកូនត្រូវយកទៅបិទលើក្ដារខៀនតាមកន្លែងដែលគ្រូកំណត់
  - ពេលចប់កិច្ចការកូនត្រូវយកខ្មៅដៃឬហ្វឺតទៅទុកតាមកន្លែងដើម ហើយក្រុមកូនទៅអង្គុយកន្លែងដើមវិញ

-គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយពីអ្វីដែលគ្រូបានណែនាំឡើងវិញ(បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្ដងទៀត)

- គ្រូរៀបចំកុមារជាក្រុម រួចឱ្យពួកគេទៅអង្គុយតាមកន្លែងដែលគ្រូកំណត់
- ឱ្យតំណាងក្រុមមកយកសម្ភារចែកសមាជិកអនុវត្ត
- គ្រូឱ្យកុមារអនុវត្តតាមក្រុមនីមួយៗ គ្រូជាអ្នកសម្របសម្រួល
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗដោយឱ្យតំណាងក្រុមប្រាប់ពីអ្វីដែលពួកគេបានធ្វើ
- គ្រូលើកសរសើរចំពោះអ្នកដែលអនុវត្តបានត្រឹមត្រូវតាមកាណែនាំ មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ គ្រូសួរកុមារៈ
  - កូនៗទាំងអស់គ្នាសប្បាយទេ?តើមុននេះកូនៗបានធ្វើអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ
  - តើថ្ងៃនេះកូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែងមេរៀន "**គូសវង់រូបភាពមិនមែនជាបន្លែនិងផ្លែឈើ**"
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

**ម៉ោងទី៦ (រយៈពេល ៣០នាទី)**

## មុខវិជ្ជាៈ ចិត្តចលនភាព

## ល្បែងៈ ក្ដាមវារកចំណី

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីរបៀបប្រើម្រាមដៃ ក្នុងការចាប់យកចំណីបានត្រឹមត្រូវ
- កុមារប្រើម្រាមដៃក្នុងការចាប់យកចំណីបានត្រឹមត្រូវ។
- បណ្ដុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន មានចិត្តស្រឡាញ់ និងចូលចិត្ត ។

**២. សម្ភារបង្រៀនៈ** គ្រាប់គ្រួស (យកទៅតាមចំនួនតាមក្រុម)

**៣. ការរៀបចំកុមារៈ** កុមារអង្គុយជារាងអក្សរអ៊ុយ "U" ឬជាជួរ

**៤. ដំណើរការបង្រៀនៈ**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមក្រុម និងទាំងអស់គ្នា

- គ្រូដាក់កញ្ចប់សម្ភារនៅលើតុពីមុខកុមាររួចឱ្យកុមារស្ម័គ្រចិត្តចំនួន ៣នាក់ បន្ទាប់មកហើយទាយសម្ភារនៅក្នុងកញ្ចប់រួចឱ្យទៅអង្គុយកន្លែងវិញ
- គ្រូឱ្យកុមារ១នាក់ឡើងមកលូកយកសម្ភារនៅក្នុងថង់នោះ រួចសួរកុមារ តើមិត្តភក្តិយើង៣នាក់អម្បាញ់មិញ មាននរណាទាយត្រូវទេ?គ្រូសរុបចម្លើយរបស់កុមារ
- គ្រូឱ្យកុមារទាំងអស់ទះដៃសរសើរមិត្តភក្តិដែលបានទាយត្រូវនឹងលើកទឹកចិត្ត អ្នកដែលទាយមិនត្រូវ
- គ្រូសួរកុមារៈតើកូនដឹងទេថាគ្រូយកសម្ភារនេះមកឱ្យកូនធ្វើអ្វី?កុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ
- គ្រូណែនាំពីរបៀបលេង
  - គ្រូអោយកូនៗលេងជាក្រុមតូចៗហើយក្នុង១ក្រុមៗ ត្រូវមានសម្ភារនេះ១កញ្ចប់ហើយកុមារម្នាក់ៗទទួលបានគ្រាប់គ្រួស២គ្រាប់ និងក្រុមនីមួយៗត្រូវអង្គុយជាជួរ
  - ពេលក្រុមកូននីមួយៗបានគ្រាប់គ្រួសហើយ យកទៅតម្រៀបនៅទីកំណត់ចម្ងាយ៥០ ស.មពីជួរកុមារអង្គុយតាមក្រុមនីមួយៗ កូនៗកុំលេងកុំដណ្តើមគ្នា ដំបូងពេលកូនឮសញ្ញាបញ្ជារបស់គ្រូកូនត្រូវចាប់ផ្តើមវារទៅរកចំណីដោយម្រាមទាំង១០របស់កូនវារទៅមុខដល់ទីចំណី ហើយយកម្រាមដៃចង្អុលនិងម្រាមកណ្តាលកៀបយកចំណី រួចវារត្រឡប់មកទីវិញដោយប្រុងប្រយ័ត្នមិនឱ្យជ្រុះ ទើបកូនឈ្នះ
  - បើកូនណាធ្វើជ្រុះឬមកយឺតជាងគេគឺជាអ្នកចាញ់
- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញពីអ្វីដែលគ្រូបានប្រាប់បើនិយាយមិនទាន់ច្បាស់ទេគ្រូឱ្យមិត្តភក្តិជួយបំពេញបន្ថែម បើនៅតែមិនទាន់ពេញលេញទេនោះ គ្រូត្រូវនិយាយប្រាប់សារឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមតូចៗហើយឱ្យអង្គុយជាជួរទៅតាមកន្លែងដែលគ្រូបានរៀបចំទុក
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅចែកគ្នាអនុវត្ត
- គ្រូឱ្យសញ្ញាដើម្បីក្រុមនីមួយៗចាប់ផ្តើមអនុវត្តក្នុងពេលជាមួយគ្នា
- គ្រូដើរសម្របសម្រួលគ្រប់ក្រុមនិងជួយកែតម្រូវក្រុមណាដែលលេងមិនទាន់បានត្រឹមត្រូវ
- នៅពេលក្រុមនីមួយៗលេងដល់អ្នកចុងក្រោយ គ្រូនិងកុមារនាំគ្នាផ្ទៀងទាត់លទ្ធផលដើម្បីរកអ្នកឈ្នះនិងអ្នកចាញ់
- គ្រូនាំកុមារលេងនិងផ្ទៀងផ្ទាត់របៀបនេះរហូតដល់ចប់ (លេងម្តងផ្ទៀងផ្ទាត់ម្តង)។

# ថ្ងៃទី១២

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

## ហាត់ប្រាណតាមបទចម្រៀងៈ យើងក្មេងៗនាំគ្នារាំ

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីចលនាដើរទៅមុខ ដើរចំហៀងខ្លួនជាចង្វាក់តាមបទចម្រៀងបានត្រឹមត្រូវ
- កុមារច្រៀងនិងធ្វើចលនាដើរទៅមុខ ដើរចំហៀងខ្លួនជាចង្វាក់តាមបទចម្រៀងបានត្រឹមត្រូវ
- កុមារស្រឡាញ់ចូលចិត្តច្រៀង និងសហការគ្នាដោយសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** កុមារឈរជាជួរនិងជារង្វង់

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជារង្វង់ ហើយគ្រូឈរចំកណ្ដាល
- គ្រូនាំកុមារទាំងអស់ធ្វើចលនាគ្រាប់តាមខ្យល់បក់លើកដៃទាំងពីរឡើងលើរទៅឆ្វេង រទៅស្ដាំ បក់ទៅមុខ បក់ទៅក្រោយធ្វើ ២ ទៅ ៣ដង
- គ្រូច្រៀងឱ្យកុមារស្ដាប់ និងធ្វើចលនាឱ្យកុមារមើលតាមបទចម្រៀងរចប់១បទ
- គ្រូនាំកុមារច្រៀងនិងធ្វើចលនាតាមបទចម្រៀងទាំងអស់គ្នាអាស្រ័យតាមពេលវេលា(២ឬ៣ចប់)
- កូនៗធ្វើចលនាអម្បាញ់មិញហត់ឬទេ? បើហត់ ដើម្បីធ្វើឱ្យមានកម្លាំងកូនត្រូវញ៉ាំទឹកទាំងអស់គ្នា តែទឹកនោះគឺទឹកដាំពុះ វាក្ដៅដើម្បីញ៉ាំបានកូនត្រូវផ្លុំឱ្យត្រជាក់សិន កូនយកដៃកាន់កែវទឹកហើយផ្លុំ៣ដង រួចញ៉ាំទាំងអស់គ្នាៗ អឹកៗៗៗ
- ថ្ងៃនេះកូនរៀនមុខវិជ្ជាចិត្តចលភាព អំពីហាត់ប្រាណតាមបទចម្រៀង ចំណងជើង «**យើងក្មេងៗនាំគ្នារាំ**» គ្រូឱ្យកុមារថាតាម១ឬ២នាក់ តាមក្រុមនិងទាំងអស់គ្នា

របៀបធ្វើចលនា

- យើងក្មេងៗ នាំគ្នារាំ រាំសប្បាយៗ លម្ហែកាយៈ កុមារលើកដៃទាំងពីរឡើងលើដាក់ត្រឹមចិញ្ចើម រាំដើរទៅមុខជារង្វង់តាមចង្វាក់ (រាំវង់)
- មកមិត្តអើយយើងនាំគ្នារាំ រាំ រាំ រាំលេងសប្បាយៈ កុមារលើកដៃទាំងពីរឡើងលើដាក់ត្រឹមចិញ្ចើមរាំដើរទៅមុខជារង្វង់តាមចង្វាក់
- កាន់ដៃគ្នាជារង្វង់ រាល់ថ្ងៃឈប់ៗឈប់សម្រាករៀនៈ កុមារកាន់ដៃគ្នាបង់បោយដើរចំហៀងខ្លួនជារង្វង់
- មកមិត្តអើយយើងនាំគ្នារាំ រាំ រាំ រាំលេងសប្បាយៈ កុមារលើកដៃទាំងពីរឡើងលើដាក់ត្រឹមចិញ្ចើមរាំដើរទៅមុខជារង្វង់តាមចង្វាក់
- ឡាឡាឡាៗៗ ឡាឡាឡាៗៗ ឡាឡាឡាៗៗ (បន្ទឺមួយចប់បទចម្រៀង)ៈ កុមារលើកដៃទាំងពីរឡើងលើដាក់ត្រឹមចិញ្ចើមរាំដើរទៅមុខជារង្វង់តាមចង្វាក់ និងបោះជើងម្ខាងទៅមុខ ម្ដងទៅឆ្វេង ម្ដងទៅស្ដាំជាចង្វាក់

អត្ថបទចម្រៀង«យើងក្មេងៗនាំគ្នារាំ»

-យើងក្មេងៗនាំគ្នារាំ រាំសប្បាយៗលម្ហែកាយា
មកមិត្តអើយយើងនាំគ្នារាំ រាំ រាំ រាំលេងសប្បាយ។
-កាន់ដៃគ្នាៗជារង្វង់ រាល់ថ្ងៃឈប់ៗឈប់សម្រាករៀន
មកមិត្តអើយយើងនាំគ្នារាំ រាំ រាំ រាំលេងសប្បាយ។

ឡាឡាឡាៗៗ ឡាឡាឡាៗៗៗ ។
ឡាៗៗ ឡាៗ ។( ឡាៗ មួយអត្ថបទចម្រៀង )

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" ( ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២ )
* ទម្លាប់ល្អ៖ ត្រូវចេះអរគុណពេលទទួលបានអ្វីៗឬមានការជួយពីមិត្តភក្តិ និងមនុស្សធំ ( ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១១ ម៉ោងទី២ )
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១២ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

### សម្គាល់តួអក្សរ៖ "ណ"

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរូបរាង និងឈ្មោះអក្សរ "**ណ**" បានត្រឹមត្រូវ
- កុមារកំណត់ពីរូបរាងឈ្មោះអក្សរ"**ណ**" និងរកពាក្យថ្មីផ្តើមចេញពីអក្សរ"**ណ**" បានត្រឹមត្រូវ
- កុមារក្លាហាន និងយកចិត្តទុកដាក់ ព្យាយាមក្នុងការរកពាក្យថ្មីផ្តើមពីអក្សរ"**ណ**"។

**២. សម្ភារបង្រៀន៖**

- ផ្ទាំងរូបភាព ណូរី ណែម ណាំង
- បណ្ណពាក្យ ណូរី ណែម ណាំង និងល្បះ ណែមព្យួរណែងណោង
- ប៊ិក ហ្វឺត ស្កុត ( កាត់រៀបចំឱ្យហើយ )

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរអ៊ុយ "U"

**៤. ដំណើរការបង្រៀន៖**( អនុវត្តនៅក្នុងជំហានទី៣ )

**+ រកពាក្យ និងឃ្លា**

- គ្រូបង្ហាញផ្ទាំងរូបភាព "**ណូរី**" ដោយបិទបាំងបញ្ចេញខាងលើបន្តិច ខាងក្រោមបន្តិច ខាងឆ្វេងបន្តិច ខាងស្តាំបន្តិច រួចឱ្យកុមារទាយ
- បើករូបបង្ហាញ ដើម្បីផ្ទៀងផ្ទាត់ចម្លើយ ( បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត ហើយយកផ្ទាំងរូប

ភាពនោះបិទលើក្ដារខៀន រួចបង្ហាញបណ្ណពាក្យ "**ណូរី**" បិទពីក្រោមរូប រួចនាំកុមារអានទាំងរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង

- គ្រូបង្ហាញរូបភាព"**ណែម**" ដោយលាស់មួយភ្លែតឱ្យកុមារឃើញ ហើយឱ្យកុមារទាយ បន្ទាប់មកគ្រូបង្ហាញរូប ដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវសរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្ដារខៀន រួចបង្ហាញបណ្ណពាក្យ "**ណែម**" ហើយបិទពីក្រោមរូប និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូឱ្យកុមារ១នាក់ចេញទៅក្រៅថ្នាក់ ហើយមើលផ្ទាំងរូបភាព "**ណាំង**" រួចហើយឱ្យចូលថ្នាក់វិញ ហើយខ្សឹបពាក្យ "**ណាំង**" បន្តគ្នាឱ្យបាន៥នាក់។ ខ្សឹបដល់អ្នកទី៥ ត្រូវឱ្យអ្នកទី៥ និយាយប្រាប់មិត្តភក្តិៗពាក្យអ្វី? រួចសួរអ្នកទី១វិញ ត្រឹមត្រូវឬទេ? បន្ទាប់មក គ្រូបង្ហាញរូបភាព "**ណាំង**" ដើម្បីផ្ទៀងផ្ទាត់ចម្លើយ បើមានកុមារឆ្លើយត្រូវ សរសើរលើកទឹកចិត្ត រួចយកផ្ទាំងរូបភាពនោះបិទលើក្ដារខៀន ហើយបង្ហាញបណ្ណពាក្យ"**ណាំង**" និងបិទពីក្រោមរូបភាព និងនាំកុមារអានរូប និងពាក្យ ដោយគ្រូអានផងចង្អុលផង
- គ្រូបង្ហាញឃ្លា "**ណែមញូរណែងណោង**" អានឱ្យកុមារស្ដាប់រួចយកបិទពីក្រោមពាក្យ
- នាំកុមារអានរូប ពាក្យ និងឃ្លា (២ដង) គ្រូនាំកុមារអានផង និងចង្អុលផង។

**+ ស្ដាប់សូរពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារស្ដាប់ (២ឬ៣ចប់) ដើម្បីឱ្យកុមារទាយសូរ និងញែកសូរនៃពាក្យ និងឃ្លា (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- សួរកុមារ តើពាក្យ និងឃ្លាដែលគ្រូបានអានអម្បាញ់មិញឮសូរដូចម្ដេច? (ពេលកុមារឆ្លើយគ្រូមិនបាច់វាយតម្លៃត្រូវឬខុសទេ)។

**+ ពិនិត្យរូបរាងអក្សរនៅក្នុងពាក្យ និងឃ្លា៖**

- គ្រូអានពាក្យ និងឃ្លាឱ្យកុមារសង្កេត (២ឬ៣ចប់) ដើម្បីឱ្យកុមារពិនិត្យរករូបរាងតួអក្សរដែលមានរាងដូចគ្នាច្រើន (ពេលអានគ្រូត្រូវចង្អុលឱ្យចំពាក្យនីមួយៗ ហើយអានយឺតៗ)
- គ្រូឱ្យកុមារដែលស្ម័គ្រចិត្តឡើងមកគូសវង់ជុំវិញតួអក្សរដែលមានរាងដូចគ្នាច្រើន (ពេលកុមារឡើងមកគូសវង់ជុំវិញតួអក្សរមានរាងដូចគ្នាច្រើន បើកុមារចង់គូស ឱ្យគេគូសតាមចិត្តរបស់គេ គ្រូមិនត្រូវបញ្ឈប់ឬបង្ខំគេឡើយ)
- នាំកុមារផ្ទៀងផ្ទាត់លទ្ធផលទាំងអស់គ្នា បើមានកុមារគូសវង់ខុស ត្រូវឱ្យកុមារដទៃជួយកែតម្រូវ។ នាំកុមាររាប់ចំនួនអក្សរដែលកុមារគូសវង់ដើម្បីផ្ទៀងផ្ទាត់ពីចំនួនច្រើន។

+ ប្រាប់ឈ្មោះតួអក្សរ៖

- សួរកុមារ តើតួអក្សរដែលកូនគូសវង់ជុំវិញនៅក្នុងពាក្យ និងឃ្លានោះឈ្មោះអក្សរអ្វី? បើកុមារឆ្លើយមិនត្រូវទេនោះ គ្រូត្រូវប្រាប់រួចនាំកុមារអាន (ក្រុមរួចទាំងអស់គ្នា)
- គ្រូបង្ហាញអក្សរចល័ត "**ណ**" រួចសួរកុមារ អក្សរដែលគ្រូបង្ហាញនេះរាងដូចអក្សរដែលកូនបានគូសវង់នោះឬទេ? បើដូច ឈ្មោះអក្សរអ្វី?
- គ្រូសរសេរអក្សរ"**ណ**" យ៉ាងធំនៅជ្រុងក្ដារខៀន ដើម្បីឱ្យកុមារសង្កេតពីទិសនៃសំណេរ
- គ្រូសួរកុមារ អក្សរដែលគ្រូសរសេរនេះតើដូចអក្សរដែលគ្រូបង្ហាញ ហើយដូចអក្សរដែលកូនគូសវង់ឬទេ?ឈ្មោះអក្សរអ្វី?
- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនអក្សរ"**ណ**" នាំកុមារអានអក្សរ"**ណ**" (ក្រុមរួចទាំងអស់គ្នា) ឱ្យបាន២ឬ៣ដង

- គ្រូសរសេរចំណងជើងមេរៀនលើក្ដារខៀន រួចនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន (ក្រុមរួចទាំងអស់គ្នា)

+ ប្រៀបធៀបអក្សរស្រដៀង៖
- គ្រូសរសេរអក្សរ "ណ ឈ ល " នៅលើក្ដារខៀន
- គ្រូអានអក្សរ "ណ ឈ ល " ឱ្យកុមារស្ដាប់ និងសង្កេត
- សួរកុមារ តើអក្សរទាំងអស់នេះមានលក្ខណៈដូចគ្នាត្រង់ណាខ្លះ? ហើយខុសគ្នាត្រង់ណាខ្លះ?
- កុមារនិយាយប្រាប់ផងទ្បើងមកចង្អុលផង

+ រកពាក្យថ្មីផ្ដើមពីអក្សរ"**ណ**"
- គ្រូអានពាក្យ និងឃ្លាសារឡើងវិញឱ្យបានច្រើនដងដើម្បីឱ្យកុមារស្ដាប់សូរ
- ឱ្យកុមាររកពាក្យថ្មីដែលផ្ដើមពីអក្សរ"**ណ**"
- គ្រូសរសេរពាក្យដែលកុមាររកបាននៅលើក្ដារខៀនទាំងអស់ទាំងពាក្យត្រឹមត្រូវ និងពាក្យមិនត្រឹមត្រូវ
- នាំកុមារផ្ទៀងផ្ទាត់ដោយគ្រូអានម្ដងមួយពាក្យៗ រួចសួរកុមារតើពាក្យនេះមានអក្សរ"**ណ**" ឬទេ? បើត្រឹមត្រូវ គ្រូគូសវង់ជុំវិញពាក្យនោះ។ បើពាក្យខុសគ្រូមិនត្រូវធ្វើអ្វីទាំងអស់។ គ្រូធ្វើរបៀបនេះទាល់តែអស់ពាក្យដែលកុមាររកបាន។
-

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## ចម្រៀង៖ ឆ្វេង ស្ដាំ (ពេលទី១)

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីអត្ថន័យ និងរបៀបធ្វើកាយវិការតាមបទចម្រៀងឆ្វេង ស្ដាំបានត្រឹមត្រូវ
- កុមារច្រៀងចម្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀងឆ្វេង ស្ដាំបានត្រឹមត្រូវ
- កុមារស្រឡាញ់ ចូលចិត្តច្រៀងចម្រៀង សហការគ្នា និង សប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរ អ៊ុយ "ប"

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)
- គ្រូបំផុសសំណួរ និងឱ្យកុមារបង្ហាញ៖ តើឯណាដៃឆ្វេងកូន?ឯណាដៃស្ដាំកូន? ឯណាជើងឆ្វេងកូន? ឯណាជើងស្ដាំកូន? ដូច្នេះកូនទាយទៅមើលថា ថ្ងៃនេះ គ្រូនាំកូនរៀនមុខវិជ្ជាអ្វី? អំពីអ្វី? កុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ។ គ្រូសរុបចំណងជើងមេរៀនដែលកុមារទាយ
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះ គ្រូនឹងបង្រៀនកូននូវមុខវិជ្ជាសិក្សាសង្គម អំពីចម្រៀង "ឆ្វេង ស្ដាំ"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារ ទៅនឹងអ្វីដែលគ្រូបានប្រាប់ ដោយនិយាយថា៖ អម្បាញ់មិញ មានកូនៗបានទាយត្រូវ ពីមុខវិជ្ជា និងចំណងជើងមេរៀន។ កូនពិតជាឆ្លាតមែន ពូកែទាយណាស់។ ប៉ុន្តែកូនដែលទាយមិនត្រូវក៏ក្លាហានដែរ ហ៊ានឆ្លើយសំណួររបស់គ្រូ ដូច្នេះថ្ងៃក្រោយកូនព្យាយាមឆ្លើយទៀតណា!
- គ្រូប្រាប់ មុខវិជ្ជា និងចំណងជើង សរសេរដាក់លើក្ដារខៀន រួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូច្រៀង និងធ្វើកាយវិការឱ្យកុមារស្ដាប់ និងមើលមួយចប់
- គ្រូនាំកុមារអានពាក្យពិបាកនៅក្នុងអត្ថបទចម្រៀងដែលគ្រូគូសសម្គាល់លើខ្លឹមសារអត្ថបទចម្រៀង

(ស្ទាត់ ប្រយ័ត្ន ប្រឡំ )ជាក្រុម និងទាំងអស់គ្នា រួចប្រាប់ពីអត្ថន័យរបស់ពាក្យទៅកាន់កុមារ និងនាំកុមារអានតាមទាំងអស់គ្នាផងដែរ( ស្ទាត់ មានន័យថា ច្បាស់លាស់ មិនខុស ។ ប្រយ័ត្ន មានន័យថាការព្យាយាមធ្វើមិនឱ្យខុស ។ ប្រឡំ មានន័យថាដែលចំណាំមិនបាន។

- គ្រូសួរកុមារ៖ កូនដឹងទេថា តើចម្រៀង"ឆ្វេង ស្ដាំ"នេះ ចង់និយាយពីអ្វី? បើកុមារមិនអាចឆ្លើយបាន គ្រូត្រូវប្រាប់កុមារពីអត្ថន័យបទចម្រៀង ដោយប្រាប់កុមារថា៖ ចម្រៀងនេះមានន័យថា ពេលកូនដើរឆ្វេង ស្ដាំ ត្រូវចំណាំឱ្យច្បាស់ និងប្រុងប្រយ័ត្នកុំឱ្យប្រឡំដើរជើងស្ដាំមុនជើងឆ្វេង។
- គ្រូអានអត្ថបទចម្រៀងជាពាក្យរាយឱ្យកុមារស្ដាប់ម្ដងមួយឃ្លាៗ រួចឱ្យកុមារអានតាមម្ដងមួយក្រុម រួចទាំងអស់គ្នា
- គ្រូធ្វើសំឡេង ណយ ណយ ណយៗៗ ទៅតាមចង្វាក់នៃបទចម្រៀងឱ្យកុមារស្ដាប់ មួយចប់នៃបទចម្រៀង។
- គ្រូនាំកុមារធ្វើសំឡេង ណយ ណយ ណយៗៗ ទៅតាមចង្វាក់នៃបទចម្រៀងដែលគ្រូបានធ្វើជាគំរូឱ្យស្ដាប់( ម្ដងមួយក្រុមៗរួចទាំងអស់គ្នា ) ឱ្យបាន២ចប់
- គ្រូនាំកុមារច្រៀង និងធ្វើកាយវិការតាមបទចម្រៀង ម្ដងមួយឃ្លាៗ រហូតដល់ចប់បទចម្រៀង( ម្ដងមួយក្រុមរួចទាំងអស់គ្នាឱ្យបាន១ ឬ២ចប់ )
- គ្រូច្រៀងតិចៗ ម្ដងមួយឃ្លាៗ កុមារច្រៀងឮៗ ម្ដងមួយឃ្លាៗតាមគ្រូ រហូតចប់បទចម្រៀង( ម្ដងមួយក្រុម ឬទាំងអស់គ្នា ) ឱ្យបាន២ចប់
- គ្រូនាំកុមារច្រៀង និងធ្វើកាយវិការតាមបទចម្រៀងសារឡើងវិញឱ្យបាន២ ទៅ៣ចប់ ទាំងអស់គ្នា

ខ្លឹមសារ និងរបៀបធ្វើកាយវិការ

+ អត្ថបទចម្រៀង៖ ឆ្វេង ស្ដាំចាំឱ្យស្ទាត់ ១ ២ ពួកយើងប្រយ័ត្នដើរឱ្យត្រូវជើង ១ ២
ឆ្វេង ស្ដាំត្រូវចាំពួកយើង១ ២ ដើរឱ្យត្រូវជើងកុំឱ្យប្រឡំ ១ ២ ។
+ របៀបធ្វើកាយវិការ៖ ដើរដំណើរដូចពូកងទ័ព ដោយលើកជើងឆ្វេងឡើងរួចដាក់ចុះ ហើយលើកជើងស្ដាំម្ដង ដៃឆ្វេងបោះទៅមុខ ដៃស្ដាំបោះទៅក្រោយ ចុះឡើងតាមចង្វាក់ចម្រៀង។

ម៉ោងទី៨ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

## ល្បែង៖ ធ្វើចំណាត់ថ្នាក់បន្លែ និង ផ្លែឈើ

### ១. វត្ថុបំណង៖

- កុមារប្រាប់បានពីរបៀបធ្វើចំណាត់ថ្នាក់បន្លែ ផ្លែឈើ បានត្រឹមត្រូវ
- កុមារធ្វើចំណាត់ថ្នាក់បន្លែ ផ្លែឈើ បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន សហការ អនុវត្តការងារក្រុមបានត្រឹមត្រូវ ។

**២. សម្ភារបង្រៀន៖** បន្ទះបណ្ណបន្លែ ផ្លែឈើ (មួយមុខមានចំនួន៤បណ្ណ)ចំនួន៤ឈុត

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរអ៊ុយ"ប", អង្គុយជាក្រុមតូចៗ (៣ក្រុម)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញបន្ទះបណ្ណបន្លែ ផ្លែឈើ ដោយដាក់នៅលើតុពីមុខកុមារ រួចឱ្យកុមារម្នាក់ជាអ្នកលើកបង្ហាញ ហើយកុមារដទៃទៀតជាអ្នកប្រាប់ឈ្មោះ( ឱ្យកុមារប្រាប់ឈ្មោះបន្លែ ផ្លែឈើ )

- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនទាំងអស់គ្នាលេងជាក្រុម ហើយក្នុងមួយក្រុមៗ កូនត្រូវមានបណ្ណបន្លែ ផ្លែឈើដែលកូនបានបង្ហាញមួយកញ្ចប់ មុននេះ
  - ពេលក្រុមកូននីមួយៗបានសម្ភារទាំងនេះហើយ កូនត្រូវយកសម្ភារចេញពីថង់ដាក់នៅកណ្ដាលរង្វង់ បន្ទាប់មក កូនក្នុងក្រុមនីមួយៗ នាំគ្នាសង្កេតមើលបណ្ណបន្លែ ផ្លែឈើទាំងនោះ ដើម្បីចំណាំ ប៉ុន្តែកូននាំគ្នាមើលឱ្យស្ងៀមស្ងាត់ មិនដណ្ដើមគ្នាមើលទេ
  - នៅពេលគ្រូឱ្យសញ្ញាចាប់ផ្ដើម កូនៗគ្រប់ក្រុមត្រូវនាំគ្នារើសបណ្ណរូបភាពទាំងនោះដាក់ម៉ុំៗ ដោយបណ្ណបន្លែដាក់១ដុំ បណ្ណរូបភាពផ្លែឈើដាក់១ដុំ ។ បើក្រុមណារៀបបានរួចរាល់មុនគេ កូនត្រូវទះដៃជាសញ្ញា ។ បន្ទាប់មកអ្នករៀបរួចបន្តបន្ទាប់ ក៏ទះដៃបន្តបន្ទាប់ដែរ ។ ពេលកូនរៀបបណ្ណបន្លែ បណ្ណផ្លែឈើ ដាក់ម៉ុំៗ កូនត្រូវធ្វើម្នាក់ម្ដងៗរង់ចាំវេន មិនដណ្ដើមគ្នារញ៉េរញ៉ៃទេ ទើបជាកូនល្អ
  - ពេលក្រុមកូនរៀបចំរួចហើយនោះ កូនទុកមិត្តភក្តិយើងម្នាក់នៅកន្លែងរៀបសម្ភារ ឯកូនដទៃទៀតទៅអង្គុយនៅក្រុមធំវិញ ហើយនាំគ្នាផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗជាមួយគ្រូ ។
- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមអ្វីដែលគ្រូប្រាប់(បើកុមារនិយាយមិនបាន គ្រូត្រូវនិយាយប្រាប់ម្ដងទៀត)
- គ្រូចែកកុមារជាក្រុម រួចឱ្យទៅអង្គុយជារង្វង់នៅតាមកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗ យកសម្ភារទៅអនុវត្ត និងឱ្យក្រុមនីមួយៗចាប់ផ្ដើមអនុវត្តតាមសញ្ញាបញ្ជារបស់គ្រូក្នុងពេលតែមួយ
- គ្រូឱ្យក្រុមកុមារនីមួយៗដែលធ្វើរួចហើយ ទៅអង្គុយនៅក្រុមធំវិញ ក្នុងមួយក្រុមទុកតែកុមារម្នាក់ដើម្បីបង្ហាញលទ្ធផល
- គ្រូនាំកុមារផ្ទៀងផ្ទាត់ម្ដងមួយក្រុមៗ ដោយឱ្យម្ចាស់ក្រុមនីមួយៗជាអ្នកបង្ហាញពីអ្វីដែលពួកគេបានធ្វើ ។ បន្ទាប់មកឱ្យកុមារដែលនៅអង្គុយក្នុងក្រុមធំជាអ្នកវាយតម្លៃ បើមានខុសជួយកែតម្រូវ ។ គ្រូត្រូវនាំផ្ទៀងផ្ទាត់គ្រប់ក្រុមទាំងអស់ ។ ពេលផ្ទៀងផ្ទាត់ចប់ គ្រូត្រូវឱ្យកុមារប្រមូលសម្ភារទុកជូនគ្រូវិញ ។
- **គ្រូសួរកុមារ៖** អម្បាញ់មិញកូនស្គាល់បន្លែ ផ្លែឈើអ្វីខ្លះ? ដូចនេះកូនប្រាប់គ្រូបានទេ តើយើងរៀនមុខវិជ្ជាអ្វី? អំពីអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ អំពីល្បែង ចំណងជើង " ចំណាត់ថ្នាក់បន្លែ ផ្លែឈើ" រួចសួរកុមារ អម្បាញ់មិញមានកូនណាទាយត្រូវឬទេ?ដូចនេះកូនៗដែលទាយត្រូវគឺជាកូនពូកែ ឆ្លាត។ រីឯកូនដែលទាយមិនត្រូវក៏ល្អដែរ ដែលក្លាហានក្នុងការនិយាយជាមួយគ្រូ។
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

### ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

* ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី១៣

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

### ហាត់ប្រាណតាមរឿងនិទានៈ (យើងទៅលេងចំការពោត)

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីរបៀបដើរ លោត រត់ បោះ តាមខ្លឹមសារនៃរឿងនិទាន បានត្រឹមត្រូវ
- កុមារដើរ លោត រត់ បោះ តាមខ្លឹមសារនៃរឿងនិទាន បានត្រឹមត្រូវ
- កុមារមានបម្រុងប្រយ័ត្ន ស្វាហាប់ រហ័សរហួន អំណត់ព្យាយាមនិងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** គ្មាន

**៣. ការរៀបចំកុមារៈ** ឈរជាជួរ

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារឈរជាជួរទៅតាមទីកន្លែងដែលបានកំណត់
- គ្រូបំផុសសំនួរៈ តើកូនៗដែលឃើញពូកងទ័ពឬទេ?ពូកងទ័ពដើរដូចម្តេចដែរ?ដូចនេះកូនៗនាំគ្នាដើរទៅមុខជាជួរតាមដំណើរពូកងទ័ពជាមួយអ្នកគ្រូ(នាំកុមារដើរទៅមុខដល់ទីកំណត់រួចនាំកុមារត្រឡប់ក្រោយ ដើរមកកន្លែងដើមវិញ )
- គ្រូប្រាប់មុខវិជ្ជានិងចំណងជើងៈ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តចលភាព អំពីហាត់ប្រាណតាមរឿងនិទាន **"យើងទៅលេងចំការពោត"**
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
- គ្រូនាំកុមារធ្វើសកម្មភាពខ្លះៗទាក់ទងទៅនឹងខ្លឹមសាររឿងនិទាន ដោយនាំកុមារដើរទៅមុខ លោតផ្លោតៗ រើសបោះ
- គ្រូចាប់ផ្តើមនិទានរឿងបណ្តើរនាំកុមារធ្វើសកម្មភាពបណ្តើរតាមខ្លឹមសាររឿង បើកុមារធ្វើចលនាណាមួយមិនទាន់ត្រឹមត្រូវគ្រូជួយកែតម្រូវ (ក្នុងករណីសល់ម៉ោងគ្រូអាចធ្វើឡើងវិញម្តងទៀត)
- គ្រូឱ្យកុមារទាំងអស់មកឈរជាជួររួចសួរថាកូនៗហត់ទេ?តើកូនស្រេកទឹកឬទេ? បើទឹកក្តៅកូនញ៉ាំបានឬទេ? បើចង់ញ៉ាំត្រូវធ្វើដូចម្តេច? ដូច្នេះកូនៗទាំងអស់គ្នាយកដៃស្តាំធ្វើជាកែវទឹក ដៃឆ្វេងច្រត់ចង្កេះ រួចនាំគ្នាឱនធ្វើជាដួសទឹកយកមកដាក់ជិតមាត់ហើយនាំគ្នាផ្លុំតិចៗ រួចនាំគ្នាញ៉ាំទាំងអស់គ្នា(ធ្វើរបៀបនេះម្តងទៀត)។

### អត្ថបទរឿងៈ យើងទៅលេងចំការពោត

កាលពីថ្ងៃអាទិត្យគ្រូបាននាំកូនៗទៅលេងចំការពោត ពេលដើរទៅគ្រូបានជួបសត្វគីង្គក់មួយធំ លោតផ្លោតៗចេញពីគុម្ពចេក កូននិងអ្នកគ្រូ ឃើញក៏ស្ទុះទៅចាប់ តែចាប់មិនបាន ដោយវាលោតពីកន្លែងមួយទៅកន្លែងមួយទៀត រួចក៏លោតចូលក្នុងព្រៃបាត់ទៅ។ ពេលយើងដើរបានមួយសន្ទុះទៀតក៏បានមកដល់ចំការពោត គ្រូក៏បានដើរទៅកាច់ពោតពីដើមមួយទៅដើមមួយរួចបោះដាក់ជាគំនរ ចំណែកកូនៗនិងគ្រូក៏បានរើសបោះបន្តដាក់ក្នុងកញ្ជើរួចច្រកចូលការ៉ុង។ ពេលកូនៗបោះបានច្រើនល្មមហើយ ពួកយើងក៏នាំគ្នាយកពោតត្រឡប់មកផ្ទះវិញ។

ម៉ោងទី២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម
## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អៈ ត្រូវចេះអរគុណពេលទទួលបានអ្វីៗឬមានការជួយពីមិត្តភក្តិ និងមនុស្សធំ (ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១១ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១៣ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ វិទ្យាសាស្ត្រ
### សង្កេតៈ ប្រៀបធៀបផ្លែឈើទុំ និងផ្លែឈើខ្ចី

**១. វត្ថុបំណងៈ**
- កុមារប្រាប់បានពីផ្លែឈើខ្ចី និង ផ្លែឈើទុំ បានត្រឹមត្រូវ។
- កុមាររៀបរាប់ពីរាង ពណ៌ ហើយនិងរស់ជាតិរបស់ផ្លែឈើទុំ និងខ្ចី បានត្រឹមត្រូវ។
- កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់ សហការ ចូលរួមបានយ៉ាងសកម្ម និងសប្បាយរីករាយ។

**២. សម្ភារបង្រៀនៈ** ផ្លែចេកទុំនិងខ្ចី

**៣. រៀបចំកុមារៈ** រៀបចំកុមារជារាងអក្សរ " U" អង្គុយជាក្រុមតូចៗ

**៤. ដំណើរការបង្រៀនៈ**(អនុវត្តនៅក្នុងជំហានទី៣)
- គ្រូនិទានរឿងៈ ថ្ងៃនេះគ្រូបានធ្វើដំណើរមកសាលារៀនស្រាប់តែមានយាយម្នាក់នៅតាមផ្លូវហៅគ្រូឱ្យឈប់ ហើយគាត់បានផ្ញើថង់មួយមកឱ្យគ្រូ ដើម្បីយកមកផ្ញើកូនៗទាំងអស់គ្នាព្រោះគាត់ថាកូនៗទាំងអស់គ្នាជាកូនល្អ។ ប៉ុន្តែគ្រូមិនដឹងថាខាងក្នុងនោះមានអ្វីទេ? ដូច្នេះកូនៗទាំងអស់គ្នាចង់ដឹងទេថាតើខាងក្នុងថង់ខ្មៅមានអ្វីខ្លះ?កុមារឆ្លើយតាមគំនិតគេម្នាក់ៗ។
- គ្រូបង្ហាញថង់នោះហើយប្រាប់កុមារថាគ្រូនិងឱ្យកូនៗទាំងអស់គ្នាបានស្ទាប ហើយហិតក្លិន គ្រប់ៗគ្នា ពេលកូនស្ទាប កូនត្រូវគិតថាតើក្នុងថង់ខ្មៅនេះមានអ្វី?រួចប្រាប់មានអ្វីខ្លះនៅក្នុងថង់នេះ?
- គ្រូឱ្យកុមារម្នាក់ឡើងមកយកសម្ភារចេញពីក្នុងថង់ហើយបង្ហាញមិត្តភក្តិ រួចសួរកុមារដើម្បីផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ(តើអម្បាញ់មិញមានមិត្តភក្តិណាទាយត្រូវទេ?) ពេលមានកុមារទាយត្រូវ ឱ្យកុមារទាំងអស់ទះដៃសរសើរ
- គ្រូបញ្ជាក់ថា នេះជាផ្លែចេកខ្ចី និងទុំរួចសួរកុមារតើផ្លែចេកជាបន្លែឬផ្លែឈើ? ហើយគ្រូយកមកឱ្យកូនធ្វើអ្វី?
- គ្រូណែនាំកុមារពីរបៀបអនុវត្តតាមក្រុមនីមួយៗ
  - គ្រូឱ្យកូនសង្កេតជាក្រុមតូចៗ ហើយក្នុងក្រុមនីមួយៗត្រូវទទួលបានផ្លែចេកទុំមួយ ចេកខ្ចីមួយផ្លែ
  - ពេលក្រុមកូននីមួយៗបានផ្លែចេកនេះហើយកូនៗត្រូវនាំគ្នាពិនិត្យមើលនៅផ្នែកខាងក្រៅមានអ្វីខ្លះ?ពេលកូនសង្កេតហើយប្រាប់គ្រូដើម្បីគ្រូបកផ្លែចេកទុំ និងខ្ចី ហើយកូននាំគ្នាមើលផ្នែកខាងក្នុងទៀតមានអ្វីខ្លះ?ពេលកូនពិភាក្សាគ្នាត្រូវចេះចែកគ្នាមើលនិងនិយាយ ហើយកូនត្រូវរកមិត្តភក្តិណា

ម្នាក់ដើម្បីនិយាយប្រាប់មិត្តភក្តិនិងគ្រូ ពីអ្វីដែលកូនបានស្គាល់។

- ពេលកូនសង្កេតចប់គ្រប់ក្រុមហើយកូនៗនាំគ្នាទៅអង្គុយក្រុមធំវិញរួចប្រមូលសម្ភារទុកវិញ

- គ្រូឱ្យកុមារម្នាក់ឡើងនិយាយពីអ្វីដែលគ្រូបានប្រាប់ បើសិននិយាយមិនបានពេញលេញ ត្រូវឱ្យមិត្តភក្តិជួយបំពេញបន្ថែម បើនៅតែនិយាយមិនបានពេញលេញទេគ្រូត្រូវនិយាយប្រាប់កុមារសាឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមឱ្យអង្គុយជារង្វង់តាមទីកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូឱ្យកុមារម្នាក់ក្នុងក្រុមនីមួយៗមកយកសម្ភារទៅនាំគ្នាអនុវត្តតាមការណែនាំ
- គ្រូដើរសម្របសម្រួលតាមក្រុមដោយជួយបំផុសគំនិតបន្ថែមចំពោះក្រុមខ្លះមិនទាន់យល់
- នៅពេលក្រុមនីមួយៗសង្កេតផ្នែកខាងក្រៅរួចហើយគ្រូត្រូវបកសំបកផ្លែចេកខ្ចី និងទុំដើម្បីឱ្យកុមារសង្កេតផ្នែកខាងក្នុងបន្តទៀត
- ពេលក្រុមនីមួយៗសង្កេតចប់សព្វគ្រប់ហើយគ្រូឱ្យពួកគេទៅអង្គុយក្រុមធំវិញរួចប្រមូលសម្ភារទុក
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងមករាយការណ៍ពីលទ្ធផលដែលពួកគេបានសង្កេតនិងពិភាក្សាគ្នា(ម្តងមួយក្រុម)ពេលកុមារនិយាយពាក្យមិនត្រឹមត្រូវតាមអក្ខរាវិរុទ្ធ គ្រូត្រូវកែតម្រូវហើយនាំកុមារអានទាំងអស់គ្នា ឧទាហរណ៍៖ កុមារគ្រប់ក្រុមបានប្រាប់ផ្លែចេកខ្ចីនៅផ្នែកខាងក្រៅមាន ទង ពណ៌បៃតង រាងមូលទ្រវែងកោង ឯផ្នែកខាងក្នុងមាន សាច់ពណ៌ស ហើយមានរស់ជាតិចត់...។ចំណែកឯចេកទុំ មាន ទង ពណ៌លឿង រាងមូលទ្រវែងកោង ឯផ្នែកខាងក្នុងមាន សាច់ពណ៌ស ហើយមានរសជាតិផ្អែម...)
- គ្រូសរុបពីលទ្ធផលរបស់កុមារទាំងអស់ដែលបានឡើងបង្ហាញ។ ពេលគ្រូសរុបត្រូវគិតមើលតើក្រុមទាំងអស់នៅមិនទាន់ស្គាល់អ្វីខ្លះ?ដូច្នេះត្រូវផ្តល់ចំណេះដឹងថ្មីឱ្យកុមារទៀត។ (ឧទាហរណ៍ ៖ កុមារមិនទាន់ប្រាប់បានពីសំបកចេកខ្ចី និងចេកទុំ ពេលបកមានសាច់សដូចគ្នា ប៉ុន្តែចេកខ្ចីមានរស់ជាតិចត់ ហើយចេកទុំមានរសជាតិផ្អែម ផលប្រយោជន៍)
- គ្រូត្រូវបំផុសសំណួរដើម្បីផ្តល់ចំណេះដឹងបន្ថែម
  - នៅពេលម្តាយកូនយកផ្លែចេកខ្ចី និងចេកទុំមកសួរតើកូនសង្កេតឃើញគាត់ធ្វើដូចម្តេច?
  - ពេលគ្រូបកសំបកផ្លែចេកទុំ និង ចេកខ្ចី តើកូនសង្កេតឃើញមានអ្វី?
  - តើផ្លែចេកខ្ចី និងទុំមានប្រយោជន៍អ្វីខ្លះ?
  - គ្រូត្រូវប្រាប់កុមារ ប្រសិនបើកុមារឆ្លើយមិនបាននូវសំណួរណាមួយ
  - គ្រូនាំកុមារអានពាក្យខ្លះៗដែលពិបាក
  - គ្រូសួរកុមារ៖ អម្បាញ់មិញកូនស្គាល់ពីអ្វី?ដូច្នេះថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្រ្ត សង្កេត ផ្លែឈើខ្ចី និងផ្លែឈើទុំ
  - គ្រូនាំកុមារអានមុខវិជ្ជានិងចំណងជើងមេរៀន(ជាក្រុមនិងអានទាំងអស់គ្នា)។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ សិក្សាសង្គម

## គំនូរៈ គូរមើមការ៉ុតតាមលំដាប់លេខ

### ១. វត្ថុបំណងៈ

- កុមារប្រាប់បានពីរបៀបគូរមើមការ៉ុតតាមលំដាប់លេខពី១ ដល់ ៩ បានត្រឹមត្រូវ
- កុមារគូរមើមការ៉ុតតាមលំដាប់លេខពី១ ដល់ ៩ បានត្រឹមត្រូវ
- កុមារមានភាពសប្បាយរីករាយ អំណត់ ព្យាយាម ផ្ចិតផ្ចង់ យកចិត្តទុកដាក់ក្នុងការគូររូប

### ២. សម្ភារបង្រៀនៈ

+ សម្ភារសម្រាប់គ្រូៈ
- ផ្ទាំងក្រដាសដែលមានគូរមើមការ៉ុតតាមលំដាប់លេខពី១ ដល់ ៩ ចំនួន១សន្លឹក
- ផ្ទាំងក្រដាសដែលមិនទាន់គូរមើមការ៉ុត ដោយមានតែលេខ លំដាប់លេខពី១ ដល់ ៩ ចំនួន១សន្លឹក
- ប៊ិចហ្វឺតចំនួន១ដើម,ស្កុតចំនួន១ដុំ។

+ សម្ភារសម្រាប់កុមារៈ
- ផ្ទាំងក្រដាស់ដែលមានលេខតាមលំដាប់លេខពី១ ដល់ ៩ ជារាងមើមការ៉ុត មានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀននៅក្បាលសន្លឹកកិច្ចការ គ្រប់ចំនួនកុមារ
- ខ្មៅដៃគ្រប់ចំនួនកុមារ។

**៣. ការរៀបចំកុមារៈ** អង្គុយរាងអក្សរអ៊ុយ "U" ចែកកុមារអង្គុយជាក្រុមប៉ន្តែអនុវត្តជាបុគ្គល

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារថាតាម(ជាក្រុមនិងទាំងអស់គ្នា)
- គ្រូបង្ហាញផ្ទាំងក្រដាសដែលមានគូរមើមការ៉ុតតាមលំដាប់លេខពី១ ដល់ ៩ ដែលគ្រូបានគូសភ្ជាប់បំពេញតាមលំដាប់រួចស្រេច ឱ្យកុមារសង្កេតនិងប្រាប់លេខ រួចបិទនៅលើក្តារខៀនឱ្យកុមារមើលជាគំរូ
- គ្រូបង្ហាញផ្ទាំងក្រដាស់១សន្លឹកទៀតដែលមិនទាន់មានគូរមើមការ៉ុតតាមលំដាប់លេខពី១ ដល់ ៩ ឱ្យកុមារសង្កេតនិងប្រាប់លេខសម្រាប់គ្រូទុកណែនាំគូរ រួចបិទលើក្តារខៀនទន្ទឹមនឹងផ្ទាំងរូបគំរូ
- គ្រូប្រាប់កុមារៈ ផ្ទាំងក្រដាសនេះគ្រូទុកសម្រាប់គូរ ឱ្យកូនមើលពីរបៀបគូរ។ ដូច្នេះកូននាំគ្នាចាំមើលទាំងអស់គ្នា តើគ្រូចាប់ផ្តើមគូរពីណាទៅណា?
- គ្រូណែនាំពីរបៀបគូរនៅលើផ្ទាំងក្រដាសរូបមើមការ៉ុតដែលមានលេខតាមលំដាប់ពី១ ដល់ ៩ ដែលបានបិទលើក្តារខៀន ដោយគូរបណ្តើរ និយាយប្រាប់កុមារបណ្តើរយឺតៗ ដើម្បីឱ្យកុមារសង្កេតពីទិសនៃការគូរ។
  - កូនយកខ្មៅដៃគូរមើមការ៉ុតតាមលំដាប់លេខពី១ ដល់ ៩ ដោយចាប់ទាញពីលេខ១រហូតដល់លេខ៩ តាមលំដាប់
  - ពេលកូនគូរ កូនយកដៃឆ្វេងទប់ក្រដាសមួយចំហៀងខាងឆ្វេង និងដៃស្តាំកាន់ខ្មៅដៃគូរ
  - ពេលកូនកំពុងគូរ កូនត្រូវយកចិត្តទុកដាក់ កុំប្រលែងគ្នាលេង បើមានមិត្តភក្តិដែលនៅជិតមិនទាន់ចេះគូរ កូនត្រូវជួយមិត្តភក្តិផង
- គ្រូបង្ហាញផ្ទាំងក្រដាសជាសន្លឹកកិច្ចការកុមារម្នាក់ៗរួចប្រាប់កុមារៈ កូនម្នាក់ៗត្រូវបានផ្ទាំងសន្លឹកកិច្ចការនេះ១សន្លឹកនិងខ្មៅដៃមួយដើម សម្រាប់កូនគូរទៅតាមអ្វីដែលគ្រូបានបង្ហាញ

- គ្រូរៀបចំកុមារឱ្យអង្គុយទៅតាមតុដែលគ្រូបានរៀបចំឬបង្វិលកៅអីអង្គុយគូរក្នុងករណីគ្រូមិនមានតុ (តាមស្ថានភាពជាក់ស្តែង)
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅចែកគ្នាអនុវត្ត
- គ្រូកុមារម្នាក់ៗនាំគ្នាអនុវត្ត គ្រូដើរសម្របសម្រួលគ្រប់ក្រុម ដើម្បីជួយកុមារណាដែលមិនទាន់ចេះកាន់ខ្មៅដៃគូរ និងមិនទាន់យល់ពីរបៀបគូរ និងដាក់ឈ្មោះកុមារម្នាក់ៗពីខាងក្រោមសន្លឹកកិច្ចការនៅពេលដែលកុមារធ្វើរួច
- គ្រូប្រាប់កុមារ ពេលកូនគូរគ្រប់គ្នារួចហើយកូនយកខ្មៅដៃទៅទុកឱ្យគ្រូវិញ និងនាំគ្នាទៅអង្គុយកន្លែងដើមវិញ កាន់សន្លឹកកិច្ចការយកទៅជាមួយរៀងៗខ្លួន
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារទៅឈរម្តងមួយក្រុមនៅខាងមុខ ហើយកាន់សន្លឹកកិច្ចការដាក់នៅត្រង់ដើមទ្រូងបង្ហាញមិត្តភក្តិ ដើម្បីឱ្យពួកគេជាអ្នកផ្ទៀងផ្ទាត់។
- គ្រូសួរកុមារដែលជាអ្នកផ្ទៀងផ្ទាត់: តើមិត្តភក្តិយើងគូរបានត្រឹមត្រូវឬទេ? ស្អាតឬទេ? ត្រឹមត្រូវតាមលំដាប់លេខឬទេ? បើមានកុមារណាបង្អាប់គំនូររបស់មិត្តភក្តិណាម្នាក់ គ្រូត្រូវចេះកែតម្រូវទៅជាពាក្យសម្តីលើកទឹកចិត្តកុមារនោះវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូឱ្យតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការរបស់មិត្តភក្តិ ដើម្បីគ្រូទុកដាក់តាំងជាស្នាដៃកុមារ។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

## ល្បែង៖ ផ្គូផ្គងចំនួនរូបភាពទៅនឹងចំនួនចំណុចទៅនឹងលេខពី១ដល់១០

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីរបៀបផ្គូផ្គងចំនួនរូបភាពទៅនឹងចំនួនចំណុច ទៅនឹងលេខពី១ ដល់១០ បានត្រឹមត្រូវ
- កុមារបង្ហាញចំនួនរូបភាពទៅនឹងចំនួនចំណុច ទៅនឹងលេខពី១ ដល់១០ បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន សហការ ជួយគ្នាក្នុងការអនុវត្តការងារក្រុមបានត្រឹមត្រូវ ។

**២. សម្ភារបង្រៀន៖**
- បណ្ណចំនួនរូបភាពពី១ដល់១០ គ្រប់ចំនួនក្រុម
- បណ្ណចំនួនចំណុចពី១ដល់១០ គ្រប់ចំនួនក្រុម
- បណ្ណចំនួនលេខពី១ដល់១០ គ្រប់ចំនួនក្រុម

**៣. ការរៀបចំកុមារ៖** អង្គុយជារាងអក្សរអ៊ុយ "U" អង្គុយតាមក្រុមតូចៗ

**៤. ដំណើរការបង្រៀន**(អនុវត្តនៅក្នុងជំហានទី៣)
- គ្រូបង្ហាញបណ្ណចំនួនរូបភាពពី១ដល់១០ ឱ្យកុមារប្រាប់ពីចំនួនរូបភាពនៅក្នុងបណ្ណនីមួយៗ រួចយកបិទលើក្តារខៀន និងនាំកុមាររាប់
- គ្រូបង្ហាញបណ្ណចំនួនចំណុចពី១ដល់១០ ឱ្យកុមារប្រាប់ពីចំនួនចំណុចនៅក្នុងបណ្ណនីមួយៗ រួចយកបិទលើក្តារ ខៀន ពីក្រោមរូបភាព និងនាំកុមាររាប់
- គ្រូបង្ហាញបណ្ណលេខពី១ដល់១០ ឱ្យកុមារប្រាប់ពីលេខនោះ រួចយកមកបិទលើក្តារខៀន ពីក្រោមចំនួន

ចំណុច និងលេខ រួចនាំកុមាររាប់

- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនទាំងអស់គ្នាលេងជាក្រុម ហើយក្នុងមួយក្រុមៗ កូនត្រូវបានសម្ភារទាំងអស់នេះមួយកំប្លេ
  - ពេលក្រុមកូនបានសម្ភារទាំងនេះហើយ កូនត្រូវសង្កេតមើលចំនួន និងលេខទៅតាមបណ្ណនីមួយៗ រួចហើយកូននាំគ្នារៀបបណ្ណចំនួនរូបភាពពី១ដល់១០តាមលំដាប់។ បន្ទាប់មកកូនត្រូវយកបណ្ណចំនួនចំណុចពី១ដល់១០ រៀបពីក្រោមបណ្ណរូបភាពពី១ដល់១០ តាមលំដាប់ដែរ និងយកបណ្ណលេខមករៀបពីក្រោម បណ្ណចំនួនចំណុចពី១ដល់១០ ទៀត
  - ពេលកូននាំគ្នារៀប កូនត្រូវចេះចែកគ្នារៀបម្តងម្នាក់ៗទៅតាមវេន កុំដណ្តើមគ្នា ។ ពេលកូនរៀបហើយ កូនត្រូវនាំគ្នាពិនិត្យឡើងវិញ ក្រែងមានខុស ហើយកូនទៅអង្គុយនៅនឹងកន្លែងសិន រង់ចាំក្រុមមិត្តភក្តិយើងរៀបហើយទាំងអស់គ្នា ។
- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមអ្វីដែលគ្រូបានប្រាប់(បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ឡើងវិញម្តងទៀត)
- គ្រូរៀបកុមារជាក្រុម រួចឱ្យទៅអង្គុយជារង្វង់នៅតាមកន្លែងដែលគ្រូបានរៀបចំ
- គ្រូឱ្យតំណាងក្រុមនីមួយៗ មកយកសម្ភារទៅអនុវត្ត
- គ្រូឱ្យកុមារចាប់ផ្តើមអនុវត្តទៅតាមក្រុមនីមួយៗ ហើយគ្រូដើរសម្របសម្រួលកែតម្រូវ
- ពេលកុមារធ្វើហើយគ្រប់ក្រុម គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារតាមក្រុមជាអ្នកផ្ទៀងផ្ទាត់ការងាររបស់ក្រុមនីមួយៗ ។ មុនផ្ទៀងផ្ទាត់ឱ្យម្ចាស់ក្រុមប្រាប់ពីអ្វីដែលពួកគេបានរៀប រួចរាប់ឱ្យមិត្តភក្តិស្តាប់ ។ គ្រូនាំកុមារផ្ទៀងផ្ទាត់រហូតគ្រប់ក្រុមទាំងអស់ ។ បើករណីមានខុស ឱ្យមិត្តភក្តិជួយកែតម្រូវ ។
- ពេលផ្ទៀងផ្ទាត់គ្រប់ក្រុមហើយ គ្រូត្រូវកុមារពិនិត្យមើលសម្ភារតាមក្រុមនីមួយៗឱ្យបានគ្រប់ចំនួន ទើបឱ្យតំណាងក្រុមនីមួយៗប្រមូលសម្ភារទាំងនោះ យកទៅជូនគ្រូ ហើយនាំគ្នាទៅអង្គុយកន្លែងដើមវិញ
- **គ្រូសួរកុមារៈ**
  - កូនៗទាំងអស់គ្នាសប្បាយទេ? តើមុននេះកូនៗបានលេងល្បែងអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាបុរេគណិត អំពីល្បែង " **ផ្គូផ្គងចំនួនរូបភាពទៅនឹងចំនួនចំណុចទៅនឹងលេខពី១ដល់១០** "
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយរបស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូប្រើពាក្យសំដីដើម្បីលើកសរសើរកុមារទាំងនោះ បើមានកុមារណាឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យពួកគេចូលរួមបន្តទៀត)
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

**ម៉ោងទី៦ (រយៈពេល ៣០នាទី)**

## មុខវិជ្ជាៈ សិក្សាសង្គម

* ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី១៤

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលនាភាព

ចលនាមូលដ្ឋាន៖ វារ (-វារទៅមុខដាក់វត្ថុលើខ្នង -វាររុញបាល់បញ្ជូនទៅមុខ -វារទៅឆ្វេង វារទៅស្តាំ)

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបវារទៅមុខដាក់វត្ថុលើខ្នង វាររុញបាល់បញ្ជូនទៅមុខ វារទៅឆ្វេង វារទៅស្តាំ បានត្រឹមត្រូវ
- កុមារវារទៅមុខដាក់វត្ថុលើខ្នង វាររុញបាល់បញ្ជូនទៅមុខ វារទៅឆ្វេងវារទៅស្តាំ បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន បម្រុងប្រយ័ត្ន អំណត់ ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** សៀវភៅនិងបាល់

**៣. ការរៀបចំកុមារ៖** ចែកកុមារជាបីក្រុម ឱ្យកុមារឈរជាជួរ (ករណីកុមារច្រើនអាចចែកជា៦ក្រុម ដោយ២ក្រុមធ្វើ១សកម្មភាព)

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

-គ្រូនាំកុមារធ្វើសកម្មភាពដើរ ដោយឱ្យកុមារធ្វើចលនាដើរដូចពួកងទ័ព ដើរទៅមុខដល់ទីកំណត់រួចដើរត្រឡប់មកដល់កន្លែងដើមវិញ

-គ្រូបង្ហាញសៀវភៅ រួចបង្ហាញបាល់ (បង្ហាញម្តងមួយ)

-គ្រូណែនាំកុមារពីរបៀបធ្វើចលនានីមួយៗ

- គ្រូឱ្យកូនអនុវត្តជាក្រុមហើយឈរជាជួរទៅតាមទីកន្លែងរបស់ក្រុមនីមួយៗ
- ក្រុមកូននីមួយៗត្រូវធ្វើចលនាផ្សេងៗគ្នា គឺកូនក្រុមទី១៖ វារទៅមុខដាក់វត្ថុលើខ្នង ឱ្យដល់ទិសដៅដែលបានកំណត់ កូនក្រុមទី២៖វាររុញបាល់បញ្ជូនទៅមុខឱ្យដល់ទិសដៅដែលបានកំណត់ និងកូនក្រុមទី៣៖ វារទៅឆ្វេង វារទៅស្តាំឱ្យដល់ទិសដៅដែលបានកំណត់
- ពេលក្រុមកូននីមួយៗកំពុងធ្វើសកម្មភាព បើគ្រូប្រើសញ្ញាដោយទះដៃ កូនត្រូវប្តូរគ្នាធ្វើសកម្មភាពផ្សេងទៀតតាមការណែនាំរបស់គ្រូ។ ហើយក្រុមកូននីមួយៗត្រូវបានធ្វើសកម្មភាពទាំងបី ដូចដែលគ្រូបានណែនាំ។

-គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ (បើកុមារនិយាយមិនបានគ្រូប្រាប់ម្តងទៀត)

-គ្រូធ្វើជាគំរូពីចលនានីមួយៗបង្ហាញកុមារ

-គ្រូរៀបចំកុមារជាបីក្រុម និង អនុវត្តតាមសកម្មភាពនីមួយៗ ទៅតាមការណែនាំខាងលើនិងតាមទីកន្លែងកំណត់ដោយឱ្យកុមារផ្លាស់ប្តូរសកម្មភាពទៅតាមសញ្ញាបញ្ជារបស់គ្រូ

- គ្រូនាំកុមារផ្លុំទឹកក្តៅដោយដកដង្ហើមចូល ចេញវែងៗ (កូនៗយកដៃ ធ្វើកាយវិការដូចកាន់កែវទឹកក្តៅ រួចយកមក ដាក់ជិតមាត់ ហើយផ្លុំ ដោយដកដង្ហើមចូល ចេញឱ្យវែងៗ រហូតដល់ទឹកត្រជាក់ រួចកូនញ៉ាំ គ្រូសួរកុមារថាតើកូនៗ ឆ្អែតហើយឬនៅ? កុមារឆ្លើយថាឆ្អែតហើយ) គ្រូអាចឱ្យកុមារធ្វើ ពីរ ឬបីដងក៏បានតាមជាក់ស្តែង ។
- គ្រូសួរកុមារ៖

- តើមុននេះ កូនៗបានធ្វើចលនាអ្វីខ្លះ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូសួរទៅកុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)

- គ្រូប្រាប់កុមារថា ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព មានចំណងជើងមេរៀន៖ ចលនាមូលដ្ឋាន **"វារទៅមុខ ដាក់វត្ថុលើខ្នង វារុញបាល់បញ្ជូនទៅមុខ វារទៅឆ្វេង វារទៅស្តាំ"**
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយរបស់គ្រូឬទេ? បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាសិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

∗ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)

(ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១១ ម៉ោងទី២)

∗ គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១៥ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

## ល្បែង៖ ផ្គុំចំនួនរូបភាពទៅនឹងចំនួនចំណុចពី១ដល់១០

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបផ្គុំចំនួនរូបភាពទៅនឹងចំនួនចំណុចពី១ដល់១០ បានត្រឹមត្រូវ
- កុមារផ្គុំចំនួនរូបភាពទៅនឹងចំនួនចំណុចពី១ដល់១០ បានត្រឹមត្រូវ
- កុមារក្លាហាន ចូលរួមសហការ ឈ្លាសវៃ រហ័សរហួន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បណ្ណរូបភាពលេខពី១ដល់១០ និងបណ្ណចំនួនចំណុចពី១ដល់១០ ចំនួន៣ឈុត

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារាងអក្សរអ៊ុយ "U" ក្រុមតូចជារង្វង់

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារក្រោកឈរទាំងអស់គ្នា ហើយរាប់ម្រាមដៃពី១ដល់១០
- គ្រូបំផុសសំណួរ៖ កូនដឹងទេថ្ងៃនេះយើងនិងរៀនពីមុខវិជ្ជាអ្វី? មេរៀនអ្វីដែរ? ឱ្យកុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ
- គ្រូប្រាប់កុមារថ្ងៃនេះរៀនមុខវិជ្ជាៈបុរេគណិត មេរៀន **ផ្គុំចំនួនរូបភាពទៅនឹងចំនួនចំណុចពី១ដល់១០**
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងការនិយាយប្រាប់របស់គ្រូ រួចសួរកុមារថាតើមុននេះមានកូនណាទាយត្រូវឬទេ? បើមានកូនណាទាយត្រូវ ឱ្យកូនដទៃទៀតទះដៃសរសើរ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ( ជាក្រុម និងទាំងអស់គ្នា)

- គ្រូបង្ហាញសម្ភារដែលត្រូវយកឱ្យកុមារលេង
  - បង្ហាញបណ្ណចំនួនរូបភាពពី១ដល់១០ រួចនាំកុមាររាប់បណ្ណរូបភាពនោះម្តង១ៗ រួចដាក់លើតុពីមុខកុមារ ធ្វើយ៉ាងណាឱ្យកុមារមើលឃើញ
  - បង្ហាញបណ្ណចំនួនចំណុចពី១ដល់១០ រួចនាំកុមាររាប់បណ្ណចំណុចនោះម្តង១ៗ រួចដាក់លើតុពីមុខកុមារ ធ្វើយ៉ាងណាឱ្យកុមារមើលឃើញ ។
  - គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង
  - គ្រូឱ្យកូនៗលេងទៅតាមក្រុម ហើយក្នុងក្រុមនីមួយៗត្រូវបានសម្ភារទាំងនេះមួយកញ្ចប់ ហើយសម្ភារទាំងនេះគ្រូដាក់ច្របូកច្របល់គ្នា
  - នៅពេលក្រុមកូននីមួយៗបានកញ្ចប់សម្ភារនេះហើយ កូនត្រូវចាក់សម្ភារពីកញ្ចប់នៅកណ្តាលវង់ រួចនាំគ្នាផ្គុំដើម្បីរកបណ្ណចំនួនរូបភាព និងបណ្ណចំនួនចំណុចដែលមានចំនួនស្មើគ្នាពី១ដល់១០ រួចយកមកផ្គុំបញ្ចូលគ្នាម្តងមួយៗ កូនៗត្រូវចេះចែកគ្នារៀប មិនត្រូវដណ្តើមគ្នា ត្រូវចេះរង់ចាំវេន
  - ពេលក្រុមកូននីមួយៗនាំគ្នាផ្គុំបណ្ណបញ្ចូលគ្នារួចហើយនោះ កូនៗត្រូវនាំគ្នាពិនិត្យមើលឡើងវិញ ក្រែងមានរៀបខុស ។
- គ្រូឱ្យកូន១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមអ្វីដែលគ្រូប្រាប់ (បើកុមារនិយាយមិនបាន គ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូចែកកុមារទាំងអស់ជាក្រុម រួចទៅអង្គុយជារង្វង់នៅកន្លែងដែលគ្រូបានត្រៀមទុក
- គ្រូឱ្យតំណាងក្រុមនីមួយៗយកសម្ភារទៅអនុវត្ត
- គ្រូដើរសម្របសម្រួលគ្រប់ក្រុម ហើយជួយណែនាំបន្ថែមចំពោះក្រុមណាដែលមិនទាន់យល់ច្បាស់
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗ នៅពេលផ្ទៀងផ្ទាត់ក្រុមណាមួយ ត្រូវឱ្យម្ចាស់ក្រុមជាអ្នកនិយាយបង្ហាញពីអ្វីដែលក្រុមបានធ្វើ បើរៀបមិនទាន់បានត្រឹមត្រូវ ឱ្យកុមារក្រុមដទៃទៀតជួយកែលម្អ និងនាំកុមាររាប់ចំនួនទាំងនោះ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតគ្រប់ក្រុមទាំងអស់ ។ ពេលផ្ទៀងផ្ទាត់រួចគ្រប់ក្រុមហើយ គ្រូត្រូវឱ្យតំណាងក្រុមប្រមូលសម្ភារទៅទុកជូនគ្រូ ហើយនាំគ្នាទៅអង្គុយក្រុមដំរិញ ។
-

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

### សកម្មភាពកសាង៖ បត់រូបមើមការ៉ុត

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីការបត់រូបមើមការ៉ុត បានត្រឹមត្រូវ
- កុមារមានសមត្ថភាពក្នុងការបត់រូបមើមការ៉ុត បានត្រឹមត្រូវ។
- បណ្តុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន មានចិត្តស្រឡាញ់។

**២. សម្ភារបង្រៀន៖**

- គ្រូ៖រូបមើមការ៉ុតបត់រួចចំនួន១សន្លឹក-ក្រដាសរាងការេផ្ទាំងធំចំនួន១សន្លឹក
- កុមារ៖ក្រដាសរាងការេផ្ទាំងតូចគ្រប់ចំនួនកុមារ។

៣. **ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរអ៊ុយ "ប"តាមក្រុមតូចៗ

៤. **ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

-គ្រូប្រាប់មុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមក្រុម និងទាំងអស់គ្នា

-គ្រូបង្ហាញរូបបត់មើមការ៉ុត ឱ្យកុមារប្រាប់ពីរូបនោះ និងយកទៅបិទលើក្ដារខៀនជាគំរូសម្រាប់កុមារសង្កេត

-គ្រូបង្ហាញរូបបត់មើមការ៉ុត រួចសួរកុមារ នេះជារូបអ្វី?តើមានស្នាមអ្វីនៅពីលើរូបនេះ?រួចយកមកបិទលើក្ដារខៀនទន្ទឹមនិងរូបគំរូដែលបានបង្ហាញមុន

-គ្រូណែនាំពីរបៀបបត់មើមការ៉ុតយឺតៗ ណែនាំបណ្ដើរបត់បង្ហាញបណ្ដើរ ដើម្បីឱ្យកុមារសង្កេតឱ្យបានច្បាស់ ហើយគ្រូត្រូវឈរធ្វើយ៉ាងណាឱ្យកុមារមើលឃើញគ្រប់ៗគ្នា

- កូនមានក្រដាសរាងការេ១នាក់១សន្លឹក
- ពេលចាប់ផ្ដើមកូនយកដៃទាំងពីរកាន់ក្រដាស ដោយមេដៃនឹងចង្អុលដៃស្ដាំដាក់ជិតគ្នារួចកាន់នៅជ្រុងក្រដាសខាងលើហើយមេដៃនិងចង្អុលដៃឆ្វេងដាក់ជិតគ្នារួចកាន់នៅជ្រុងក្រដាសខាងក្រោម។
- បន្ទាប់មកយកជ្រុងក្រដាសខាងលើបត់មកដាក់លើជ្រុងក្រដាសខាងក្រោមរួចយកដៃធូតកណ្ដាលឱ្យត្រង់បានជាផ្នាត់។

- គ្រូរៀបចំកុមារអង្គុយជាជួរនៅតាមតុឬតាមកៅអីម្នាក់ៗតាមស្ថានភាពជាក់ស្ដែង

- គ្រូឱ្យតំណាងនិមួយៗមកយកក្រដាសទៅចែកមិត្តភក្ដិអនុវត្ត

- គ្រូឈរនៅមុខកុមារដោយនាំកុមារបត់ ម្ដងមួយវគ្គៗ ពេលកុមារធ្វើទាំងអស់គ្នារួចមួយវគ្គតាមគ្រូ ហើយគ្រូក៏ចាប់ផ្ដើមធ្វើមួយវគ្គម្ដងទៀតនាំកុមារធ្វើរបៀបនេះទាល់តែដល់ចុងបញ្ចប់

- គ្រូដើរដាក់ឈ្មោះកុមារម្នាក់ៗនៅលើរូបបត់មើមការ៉ុតនៅផ្នែកខាងក្រោម។

- គ្រូនាំកុមារផ្ទៀងផ្ទាល់លទ្ធផលរបស់កុមារម្នាក់ៗដោយឱ្យកុមារចេញមកម្ដងមួយក្រុមមកឈរនៅពីមុខមិត្តភក្ដិគេហើយកាន់រូបមើមការ៉ុតលើកបង្ហាញដាក់ត្រឹមដើមទ្រូង។

- គ្រូសួរកុមារតើរូបមិត្តភក្ដិយើងធ្វើបានត្រឹមត្រូវឬទេ?បត់បានស្អាតឬទេ?

- គ្រូនិយាយប្រាប់កុមារ៖ពេលកូននាំគ្នាបង្ហាញរួចហើយកូនត្រូវកាន់រូបនេះទៅអង្គុយនៅកន្លែងដើមវិញ

- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលគ្រូមិនត្រូវបន្ទុះបង្អាប់ឬស្ដីបន្ទោសចំពោះកុមារណាដែលធ្វើមិនទាន់បានល្អនោះទេ គ្រូត្រូវចេះសរសើរលើកទឹកចិត្តពួកគេខិតខំប្រឹងប្រែងម្ដងទៀត

- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតដល់គ្រប់ក្រុមកុមារទាំងអស់

-គ្រូឱ្យតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចកុមារម្នាក់ៗជូនគ្រូទុកសម្រាប់ដាក់តាំងស្នាដៃកុមារនៅលើផ្ទាំងស្នាដៃកុមារនៅថ្ងៃបន្ទាប់គ្រូត្រូវដាក់ថ្ងៃ ខែ ឆ្នាំ អនុវត្ត មុខវិជ្ជានិងចំណងជើងមេរៀននៅលើសន្លឹកកិច្ចការមុននឹងយកទៅដាក់តាំងស្នាដៃកុមារ។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

## ល្បែង៖ បំពេញតួអក្សរតាមចន្លោះពី យ ដល់ ណ

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបបំពេញតួអក្សរតាមចន្លោះពី យ ដល់ ណ តាមលំដាប់ បានត្រឹមត្រូវ
- កុមាររៀបបំពេញតួអក្សរតាមចន្លោះពី យ ដល់ ណ តាមលំដាប់ បានត្រឹមត្រូវ
- កុមារមានភាព សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បន្ទះតួអក្សរពី យ ដល់ ណ ចំនួន៣បន្ទះ និង បណ្ណអក្សរចំនួន១៨បណ្ណ (អក្សរចល័ត)

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារាងអក្សរអ៊ុយ "U" និងក្រុមតូច

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

-គ្រូនិយាយទៅកុមារថា៖ ថ្ងៃនេះគ្រូមានបន្ទះតួអក្សរមួយផ្ទាំងដែលមានតួអក្សរមិនពេញលេញ មិនតាមលំដាប់ និងបណ្ណអក្សរចល័តជាច្រើន។ តើកូនចង់ដឹងថាបន្ទះនេះ មានតួអក្សរអ្វីខ្លះ?

-គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង

- កូនត្រូវអង្គុយជារង្វង់ ទៅតាមក្រុមរបស់កូន ដែលគ្រូបានរៀបចំ
- កូនត្រូវប្រាប់ឈ្មោះតួអក្សរនៅពេលគ្រូលើកបង្ហាញបន្ទះតួអក្សរនិងបណ្ណតួអក្សរទាំងអស់នោះ ហើយ កូនត្រូវដាក់បន្ទះតួអក្សរទាំងនោះនៅចំកណ្ដាលរង្វង់នៃក្រុម បន្ទាប់មកកូនប៉ាវរកអ្នកចាប់ផ្ដើមដើម្បី ជ្រើសរើសបណ្ណតួអក្សរដាក់បំពេញមុនគេនៅក្នុងប្រអប់ដែលមិនទាន់មានតួអក្សរ ពេលកូនបំពេញតួ អក្សរក្នុងប្រអប់ហើយ កូនឱ្យមិត្តភក្តិដែលនៅខាងស្ដាំដៃក្នុងក្រុមកូនរើសយកបណ្ណតួអក្សរមកដាក់ បំពេញក្នុងប្រអប់ដែលមិនមានតួអក្សរម្តងម្នាក់ៗរហូតដល់អស់បណ្ណតួអក្សរ

-គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយពីអ្វីដែលគ្រូបានណែនាំឡើងវិញ(បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)

- គ្រូរៀបចំកុមារជាក្រុម រួចឱ្យពួកគេទៅអង្គុយតាមកន្លែងដែលគ្រូកំណត់
- ឱ្យតំណាងក្រុមមកយកសម្ភារចែកសមាជិកអនុវត្ត
- គ្រូឱ្យកុមារអនុវត្តតាមក្រុមនីមួយៗ គ្រូជាអ្នកសម្របសម្រួល
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗដោយឱ្យតំណាងក្រុមប្រាប់ពីអ្វីដែលពួកគេបានធ្វើ
- គ្រូលើកសរសើរចំពោះអ្នកដែលអនុវត្តបានត្រឹមត្រូវតាមកាណែនាំ មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ

-គ្រូសួរកុមារ៖

- កូនៗទាំងអស់គ្នាសប្បាយទេ?តើមុននេះកូនៗបានធ្វើអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ
- តើថ្ងៃនេះកូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)

- គ្រូប្រាប់កុមារថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ មេរៀនល្បែង "**បំពេញតួអក្សរតាមចន្លោះពីតួអក្សរ "យ ដល់ ណ"**
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

✱ ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

## ថ្ងៃទី១៥

## ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

**ចលនាចរន្ត៖ ដើរ រត់ លោត វារ (ដើរវាងឧបសគ្គ រត់ទៅរកទី លោតរំលងខ្សែ វារទៅមុខដាក់វត្ថុលើខ្នង)**

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបធ្វើចលនានីមួយៗ តាមលំដាប់លំដោយបានត្រឹមត្រូវ
- កុមារធ្វើចលនានីមួយៗ តាមលំដាប់លំដោយបាន ត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន បម្រុងប្រយ័ត្ន រង់ចាំវេន និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** មែកឈើមានបន្លា បង្គោលសម្រាប់ចងខ្សែ សៀវភៅសម្រាប់កុមារដាក់លើខ្នង ខ្សែ កន្ទេល ឬតង់។

**៣. ការរៀបចំកុមារ៖** ចែកកុមារជាបីក្រុម ដោយឱ្យកុមារឈរជាជួរ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូចែកកុមារជាបីក្រុម ដោយឈរជាបីជួរ
- គ្រូនាំកុមារធ្វើសកម្មភាពដើរ ដោយឱ្យកុមារដើរបង់បោយវែងៗទៅមុខ រួចដើរត្រឡប់មកក្រោយវិញ
- គ្រូណែនាំកុមារពីរបៀបធ្វើចលនាចរន្តនីមួយៗ (ដើរវាងឧបសគ្គ រត់ទៅរកទីកំណត់ លោតរំលងខ្សែ វារទៅមុខដាក់វត្ថុលើខ្នង)
  - ដើរវាងឧបសគ្គ ៖ដើរទៅដល់កន្លែងមានឧបសគ្គ(មែកឈើមានបន្លា)កូនត្រូវដើរវាង
  - រត់ទៅរកទីកំណត់ ៖ បន្ទាប់មកកូនត្រូវរត់ទៅរកទីដែលគ្រូបានគូសកំណត់
  - លោតរំលងខ្សែ ៖ ពេលកូនរត់ដល់ទីដែលមានខ្សែចង កូនត្រូវលោតរំលងខ្សែនោះ
  - វារទៅមុខដាក់វត្ថុលើខ្នង ៖ បន្ទាប់ពីលោតរួចកូនត្រូវវារលើកន្ទេលគ្រូបានក្រាលរួចដោយដាក់វត្ថុលើខ្នង
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបធ្វើចលនានីមួយៗ (បើកុមារនិយាយមិនបាន គ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូដើរសម្របសម្រួលតាមក្រុមទាំង៣ ដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានអនុវត្តគ្រប់សកម្មភាព
- គ្រូសួរកុមារ៖
  - **តើមុននេះ កូនៗបានធ្វើចលនាអ្វីខ្លះ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - **គ្រូសួរទៅកុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារថា **ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព មានចំណងជើងមេរៀន៖ ចលនាចរន្ត ដើរ រត់ លោត វារ " ដើរវាងឧបសគ្គ រត់ទៅរកទីកំណត់ លោតរំលងខ្សែ វារទៅមុខដាក់វត្ថុលើខ្នង"**
- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយរបស់គ្រូឬទេ? បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្ត)
- **គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា**
- គ្រូនាំកុមារផ្លុំទឹកក្តៅដោយដកដង្ហើមចូល ចេញវែងៗ (កូនៗយកដៃ ធ្វើកាយវិការដូចកាន់កែវទឹកក្តៅ រួច

យកមកដាក់ជិតមាត់ ហើយផ្លុំ ដោយដកដង្ហើមចូល ចេញឱ្យវែងៗ រហូតដល់ទឹកត្រជាក់ រួចកូនញ៉ាំ គ្រូសួរកុមារថាតើកូនៗឆ្អែតហើយឬនៅ? កុមារឆ្លើយថាឆ្អែតហើយ) គ្រូអាចឱ្យកុមារធ្វើ ២ឬ៣ដងក៏បាន តាមជាក់ស្តែង ។

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈសិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អៈ ត្រូវចេះអរគុណពេលទទួលបានអ្វីៗឬមានការជួយពីមិត្តភក្តិ និងមនុស្សធំ (ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១៥ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ

## កំណាព្យៈ ថាអរគុណ

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីចំណងជើងនិងអត្ថន័យនៃកំណាព្យ«ថាអរគុណ» បានត្រឹមត្រូវ។
- កុមារសូត្រកំណាព្យត្រូវតាមវាក្យស័ព្ទនិងទំនុកបទ បានត្រឹមត្រូវ។
- កុមារមានភាពក្លាហាន ស្រឡាញ់ ចូលចិត្តសូត្រកំណាព្យ។

**២. សម្ភារបង្រៀនៈ** សៀវភៅអត្ថបទកំណាព្យ

**៣. ការរៀបចំកុមារៈ** កុមារអង្គុយជារាងអក្សរអ៊ុយ«U»

**៤. ដំណើរការបង្រៀនៈ**

- ថ្ងៃនេះគ្រូនឹងយកមេរៀនកំណាព្យមួយមកបង្រៀនកូនៗទាំងអស់គ្នា
- គ្រូសូត្រកំណាព្យឱ្យកុមារស្តាប់មួយចប់សិនដើម្បីឱ្យកុមារយល់អត្ថន័យនៃកំណាព្យ
- គ្រូឱ្យកុមារអាន និងរកពាក្យពិបាក
- គ្រូប្រាប់និងពន្យល់ពាក្យពិបាកៈ
  - ញញឹមៈ សើច បិទមាត់មិនចេញសំឡេង
  - បញ្ជាក់ៈ ធ្វើឱ្យច្បាស់ ឱ្យជាក់
  - ផ្តេសផ្តាសៈ មិនត្រឹមត្រូវ
- គ្រូសួរកុមារតើកំណាព្យដែលកូនបានសូត្រគេចង់និយាយអំពីអ្វី?
- គ្រូនាំកុមារសូត្រកំណាព្យឃ្លាទី១ ឱ្យបានមួយចប់ បន្ទាប់មកកុមារសូត្រឃ្លាទី២
- ពេលកុមារសូត្រកំណាព្យ ឃ្លាទី១ ឃ្លាទី២ រួចឱ្យកុមារសូត្រឃ្លាទាំងពីររួមបញ្ចូលគ្នា
- គ្រូនាំកុមារសូត្រឃ្លាបន្តបន្ទាប់តាមរបៀបខាងលើរហូតដល់ចប់នៃអត្ថបទកំណាព្យ

- គ្រូឱ្យកុមារសូត្រកំណាព្យសាឡើងវិញរួមគ្នា ១ឬ២ចប់
- គ្រូសួរកុមារ តើអម្បាញ់មិញកូនរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វី ? អ្នកនិពន្ធឈ្មោះអ្វី ? ( កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ )
- គ្រូប្រាប់ថា ថ្ងៃនេះយើងរៀនមុខវិជ្ជាៈភាសាខ្មែរ មេរៀនៈកំណាព្យ«ថាអរគុណ»អ្នកនិពន្ធដោយអ៊ំៗនៅក្រសួងអប់រំ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម ទាំងអស់គ្នា

**អត្ថបទកំណាព្យ«ថាអរគុណ»(បទកាកគតិ)**

ពេលម៉ាក់ហុចនំ មុនយកនោះខ្ញុំ
ថាអរគុណម៉ាក់ លើកដៃសំពះ
លោកញញឹមដាក់ រួចលោកបញ្ជាក់
ថាខ្ញុំចេះណាស់។
ខ្ញុំសប្បាយចិត្ត ចាំពាក្យនេះពិត
មិនភ្លេចផ្តេសផ្តាស មុនទទួលអ្វី
ថាយ៉ាងរហ័ស អរគុណយ៉ាងច្បាស់
ទើបចាស់ពេញចិត្ត។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## ល្បែងៈ ប្រព័ន្ធគ្រួសារបន្លែ

**១. វត្ថុបំណងៈ**

- កុមាររៀបរាប់ពីប្រភេទបន្លែនីមួយៗ បានត្រឹមត្រូវ
- កុមារបង្ហាញឈ្មោះប្រភេទបន្លែនីមួយៗ បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម រហ័សរហួន សហការ ជួយគ្នាក្នុងការអនុវត្តការងារក្រុមដោយសប្បាយរីករាយ

**២. សម្ភារបង្រៀនៈ** ត្រកួន ផ្ទី ត្រសក់...

**៣. ការរៀបចំកុមារៈ** អង្គុយជារាងអក្សរអ៊ីយ "U" អង្គុយតាមក្រុមតូចៗ

**៤. ដំណើរការបង្រៀន**( អនុវត្តនៅក្នុងជំហានទី៣ )

- គ្រូសួរៈ តើកូនៗធ្លាប់ស្គាល់បន្លែអ្វីខ្លះ ? ដូច្នេះកូនៗទាយមើលថាថ្ងៃនេះគ្រូបង្រៀនកូនពីមុខវិជ្ជាអ្វី ? អំពីមេរៀនអ្វី ? ឱ្យកុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ ។ ពេលកុមារប្រាប់រួច គ្រូត្រូវសរុបនូវអ្វីដែលពួកគេបានប្រាប់
- គ្រូប្រាប់កុមារៈ ថ្ងៃនេះគ្រូបង្រៀនមុខវិជ្ជាសិក្សាសង្គម អំពីល្បែង«**ប្រព័ន្ធគ្រួសារបន្លែ**»
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងការនិយាយប្រាប់របស់គ្រូ ដោយសួរកុមារថា តើអម្បាញ់មិញមានកូនណាទាយត្រូវឬទេ ? បើមានមិត្តភក្តិយើងទាយត្រូវដូចនេះកូនៗនាំគ្នាទះដៃសរសើរមិត្តភក្តិយើងទាំងអស់គ្នា។ ឯកូនដែលទាយមិនទាន់ត្រូវ កូនក៏ឆ្លាតដែរ ព្រោះកូនបានឆ្លើយនឹងសំណួរ តែថ្ងៃក្រោយកូនត្រូវគិតបន្ថែម ហើយចាំឆ្លើយសំណួរគ្រូទៀតណា !

- គ្រូនាំកុមារអានពីមុខវិជ្ជា និងចំណងជើងមេរៀន (ជាក្រុម និងទាំងអស់គ្នា)
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនលេងជាមួយគ្រូម្តងមួយក្រុម ឯកូនដែលគ្រូមិនទាន់ឱ្យលេង កូនត្រូវជួយស្តាប់មិត្តភក្តិយើងនិយាយ
  - ក្រុមដែលគ្រូនាំលេងមុនគេ ត្រូវមកឈរជារង្វង់នៅកណ្តាលថ្នាក់ ឯកូនដែលគ្រូមិនទាន់ឱ្យលេង ត្រូវអង្គុយនៅកៅអីជុំវិញក្រុមលេង ប្រហែលកន្លះម៉ែត្រ ដើម្បីសង្កេតអ្នកធ្វើខុស
  - ដំបូងកូនត្រូវរកអ្នកចាប់ផ្តើមនិយាយមុនគេ (កូនៗត្រូវឯកភាពយល់ព្រមកំណត់ឱ្យមិត្តភក្តិណាម្នាក់ជាអ្នកចាប់ផ្តើមមុនគេ )
  - ពេលគ្រូឱ្យសញ្ញាចាប់ផ្តើម កូនដែលត្រូវចាប់ផ្តើមមុនគេ ត្រូវនិយាយឈ្មោះបន្លែមួយមុខ រួចហើយអ្នកនៅឈរស្តាំដៃត្រូវប្រាប់ឈ្មោះបន្លែមួយមុខទៀតផ្សេងពីគ្នា រួចបន្តទៅអ្នកបន្ទាប់ទៀត បើកូនណាប្រាប់ឈ្មោះបន្លែដូចអ្នកមុនដែរនោះ កូនជាអ្នកចាញ់ ហើយកូនត្រូវដកចេញពីក្រុមទៅឈរនៅមួយកន្លែង ហើយកូនដែលនៅក្នុងក្រុម ត្រូវធ្វើរបៀបនេះបន្តរហូតដល់អ្នកចុងក្រោយ ។
  - ពេលក្រុមកូនបានបញ្ចប់ការលេងហើយ ត្រូវប្តូរឱ្យក្រុមកូនផ្សេងទៀតមកលេងម្តង ហើយក្រុមកូនទៅអង្គុយវិញ ដើម្បីជួយសង្កេតអ្នកធ្វើខុស
- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្តងទៀត)
- គ្រូត្រូវរៀបចំកុមារមួយក្រុម ឱ្យឈរជារង្វង់នៅកណ្តាលថ្នាក់ ឯកុមារក្រុមផ្សេងទៀតឱ្យអង្គុយជុំវិញក្រុមដែលត្រូវលេង ចាំជួយសង្កេត និងស្តាប់អ្នកធ្វើខុស
- មុននឹងនាំកុមារលេង គ្រូត្រូវប្រាប់កុមារក្នុងក្រុមឱ្យរកឈ្មោះបន្លែម្នាក់ៗ ឱ្យបានមួយមុខ
- គ្រូនាំកុមារលេងម្តងមួយក្រុមៗ ហើយគ្រូជាអ្នកឱ្យសញ្ញាចាប់ផ្តើម។ ចំពោះការជ្រើសរើសកុមារចាប់ផ្តើមនិយាយមុនគេនោះ គ្រូអាចជាអ្នកកំណត់ ឬឱ្យកុមារក្នុងក្រុមជាអ្នកសម្រេច ឬឱ្យកុមារប៉ាវរកអ្នកឈ្នះ (បើកុមារមានចំនួនតិច) ក៏បាន
- គ្រូនាំកុមារលេងដោយប្តូរក្រុមលេង គឺក្រុមលេងរួចឱ្យទៅអង្គុយវិញ ឯក្រុមអង្គុយឱ្យមកលេងម្តងវិញ ។ ក្នុងមួយក្រុមគ្រូនាំកុមារលេងតែមួយសារ
- គ្រូនាំកុមារលេងបន្តបន្ទាប់ឱ្យបានគ្រប់ក្រុម រហូតចប់ម៉ោង
- ពេលបញ្ចប់ការលេងគ្រប់ក្រុម គ្រូឱ្យកុមារទៅអង្គុយក្រុមធំវិញ ហើយអ្នកដែលចាញ់ទាំងអស់ត្រូវមកឈរពីមុខ រង់ចាំមិត្តភក្តិទាំងអស់ឱ្យធ្វើសកម្មភាពផ្សេងៗ ដូចជា ច្រៀង រាំ ដើរទា ដើរបង្ហាញម៉ូត ឬសកម្មភាពផ្សេងៗទៀត ។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ វិទ្យាសាស្ត្រ

## សន្ទនា៖ សារៈសំខាន់នៃការញ៉ាំបន្លែនិងផ្លែឈើ

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីសារសំខាន់នៃការញ៉ាំបន្លែនិងផ្លែឈើ បានត្រឹមត្រូវ
- កុមារកំណត់បានពីសារសំខាន់នៃការញ៉ាំបន្លែនិងផ្លែឈើ បានត្រឹមត្រូវ
- បណ្ដុះទម្លាប់កុមារឱ្យយកចិត្តទុកដាក់ មានអំណត់ និងចូលរួមសហការយ៉ាងសកម្មជាមួយគ្រូ និងកុមារដទៃ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជាអក្សរអ៊ុយ "ሀ" កុមារអង្គុយជាដៃគូ២នាក់ៗ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់ពីមុខវិជ្ជានិងចំណងជើងមេរៀនឱ្យកុមារថាតាមជាក្រុមនិងទាំងអស់គ្នា។
- គ្រូណែនាំពីរបៀបសន្ទនា៖
  - គ្រូឱ្យកុមារបង្កើតក្រុមដៃគូ២នាក់ៗហើយឈរនៅដាច់ៗពីគ្នា។
  - ក្នុងក្រុមនីមួយៗកូនត្រូវនាំគ្នាប៉ាវរកអ្នកដែលត្រូវចាប់ផ្ដើមនិយាយមុនគេ។
  - កូនដែលត្រូវនិយាយមុនគេពេលចាប់ផ្ដើមដំបូងត្រូវជម្រាបសួរមិត្តភក្តិសិន។បន្ទាប់មកទើបនិយាយប្រាប់មិត្តភក្តិពីសារសំខាន់នៃការញ៉ាំបន្លែនិងផ្លែឈើ(ដើម្បីឱ្យកូនមានសុខភាពល្អតើកូនត្រូវញ៉ាំអ្វីខ្លះ?ចុះប៉ារបស់កូនប្រកបមុខរបរអ្វី?ហើយម៉ាក់របស់កូនធ្វើការងារអ្វីដែរ?ចុះបងប្អូនរបស់កូនធ្វើអ្វីដែរ?)បន្ទាប់មកសួរទៅមិត្តភក្តិនៅស្ដាំដៃបន្ត ដោយប្រើសំណួរចុះអ្នកវិញ?
  - កូនដែលមិត្តភក្តិសួរត្រូវនិយាយដូចមិត្តភក្តិចាប់ផ្ដើមដំបូងដែរ។រួចក៏សួរទៅមិត្តភក្តិនៅចុងក្រោយបន្តទៀតដោយប្រើសំណួរដូចកូនមុនដែរ
- គ្រូហៅកុមារ២នាក់ឱ្យមកឈរជាមួយគ្រូនៅមុខមិត្តភក្តិទាំងអស់គ្នាដើម្បីអនុវត្តជាគំរូឱ្យកុមារមើលសិនតាមរបៀបដែលបានណែនាំដោយគ្រូជាអ្នកចាប់ផ្ដើមនិយាយមុន
- គ្រូរៀបចំកុមារឱ្យឈរជាក្រុមដៃគូ ២ នាក់នៅដាច់ៗពីគ្នា
- គ្រូឱ្យកុមារចាប់ផ្ដើមអនុវត្តគ្រប់ក្រុមក្នុងពេលតែមួយ
- គ្រូដើរសម្របសម្រួលតាមក្រុមដោយធ្វើយ៉ាងណាត្រូវស្ដាប់កុមារនិយាយឱ្យបានគ្រប់ក្រុមដើម្បីជួយកែសម្រួលនូវពាក្យណាដែលពួកគេនិយាយមិនបានត្រឹមត្រូវតាមអក្ខរាវិរុទ្ធ
- គ្រូឱ្យកុមារចាប់ក្រុមដៃគូ២នាក់ៗសាថ្មីទៀតហើយអនុវត្តការសន្ទនាដូចក្រុមមុនដែរ (បើក្នុងករណីនៅសល់ម៉ោង)

ម៉ោងទី៦ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ សិក្សាសង្គម

✱ ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី១៦

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

## ល្បែងចលនា៖ រូបចម្លាក់មានចលនា

**១. វត្ថុបំណង៖**

កុមារប្រាប់បានពីរបៀបលេងល្បែងរូបចម្លាក់មានចលនា បានត្រឹមត្រូវ

កុមារលេងល្បែងរូបចម្លាក់មានចលនា បានត្រឹមត្រូវ

កុមារមានភាពស្វាហាប់ រហ័សរហួន ប្រុងប្រយ័ត្ន និងសប្បាយរីករាយ ។

**២. សម្ភារៈបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** ចែកកុមារជាក្រុមតូចៗដោយមួយក្រុមមានគ្នា៨នាក់

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមារលេងជាក្រុមតូចៗ ហើយមួយក្រុមមានចំនួន៨នាក់។
- គ្រូឱ្យកូនលេងម្តងមួយក្រុម ហើយក្រុម ដទៃនាំគ្នាអង្គុយជួយមើលមិត្តភក្តិយើងធ្វើ។ កូននាំគ្នាលេងនៅក្នុងថ្នាក់ជាមួយគ្រូ។ពេលលេងក្រុមកូនដែលត្រូវលេងមុនចំនួន៨នាក់ទៅឈរជាជួរនៅទីដែលគ្រូបានគូសបន្ទាត់ឱ្យឈរ។ ចំណែកឈរបែរមុខទៅជញ្ជាំងជាអ្នកបញ្ជាដោយឱ្យសញ្ញាចាប់ផ្តើមនិងសញ្ញាបញ្ឈប់ ពេលគ្រូឱ្យសញ្ញាចាប់ផ្តើមដោយទះជញ្ជាំងរួចនិយាយថា"១-២-៣រូបចម្លាក់"កូនដែលឈរនៅទីត្រូវនាំគ្នាដើរប្រណាំងគ្នាសំដៅទៅរកជញ្ជាំងដោយធ្វើដំណើរផ្សេងៗតាមចិត្តរបស់កូនម្នាក់ៗ ដូចជាដើរបង់បោយ ដើរទូលដៃ ដើរលើកជើងខ្ពស់ៗ ពេលគ្រូឱ្យសញ្ញាឈប់ដោយទះជញ្ជាំងរួចនិយាយ ថាឈប់ កូនត្រូវនាំគ្នាឈប់ ទៅទោះ បីកូនកំពុងឈានជើងឬកំពុងបង់បោយក៏ដោយត្រូវឈប់ភ្លាម បើសិនជាគ្រូធ្វើសញ្ញាឱ្យឈប់ហើយមានកូនណាម្នាក់បន្តធ្វើដំណើរនោះត្រូវត្រឡប់ទៅទីចេញដំណើរវិញ ហើយចាប់ដើរមកមុខបន្តទៀតពេលកូនណាដើរដល់ទីហើយប៉ះជញ្ជាំងនិងស្រែកឡើងថា"ខ្ញុំមិនមែនជារូបចម្លាក់ទេ"គឺកូននោះជាអ្នកឈ្នះ ។ហើយឱ្យទៅឈរមួយកន្លែង
- បន្ទាប់មកកូនដែលនៅសល់ត្រូវដើរបន្តដើម្បីរកអ្នកឈ្នះបន្តបន្ទាប់រហូតដល់ម៉ោងកំណត់ ពេលក្រុម កូនលេងចប់គ្រូឱ្យកូនក្រុមផ្សេងលេងបន្តបន្ទាប់រហូតដល់អស់ក្រុម
- គ្រូឱ្យកុមារស្ម័គ្រចិត្តម្នាក់និយាយឡើងវិញពីអ្វីដែលគ្រូបានប្រាប់ បើកុមារនិយាយមិនបានត្រឹមត្រូវឱ្យ កុមារដទៃជួយប្រាប់បន្ថែម បើនៅតែមិនអាចប្រាប់បានពេញលេញទេនោះគ្រូត្រូវប្រាប់ ឡើងវិញម្តងទៀត
- គ្រូរៀបចំកុមារជាក្រុមហើយឱ្យមួយក្រុមមកលេងជាមួយគ្រូ និងក្រុមផ្សេងជាអ្នកមើលមិត្តភក្តិលេងដើម្បីតាមដានអ្នកដែលធ្វើខុស
- គ្រូនាំកុមារលេង និងសម្របសម្រួលការលេងទៅតាមម៉ោងកំណត់ពេលដល់ម៉ោងកំណត់គ្រូត្រូវផ្ទៀងផ្ទាត់រកអ្នកដែលឈ្នះនៅក្នុងក្រុម
- គ្រូប្តូរឱ្យក្រុមផ្សេងលេងម្តងដោយអនុវត្តការលេងនិងផ្ទៀងផ្ទាត់ដូចក្រុមមុនដែរនិងនាំលេងបន្តបន្ទាប់រហូតគ្រប់ក្រុមពេលលេងគ្រប់ក្រុមហើយគ្រូនាំកុមារផ្ទៀងផ្ទាត់ពីចំនួនអ្នកឈ្នះនៅក្រុមក្នុងនីមួយៗបើក្រុមណាមានអ្នកឈ្នះច្រើនជាងគេក្រុមនោះគឺជាក្រុមឈ្នះ

គ្រូសួរកុមារ៖

- អម្បាញ់មិញកូនលេងល្បែងអ្វី?ដូច្នេះកូនជួយប្រាប់គ្រូមើលតើយើងរៀនពីមុខវិជ្ជាអ្វី?កុមារឆ្លើយតាមគំនិតគេម្នាក់ៗរួចបូកសរុបចម្លើយរបស់កុមារ
- គ្រូប្រាប់កុមារថា៖ ថ្ងៃនេះយើងរៀនមុខវិជ្ជាចិត្តលភាព អំពីល្បែង"រូបចម្លាក់មានចលនា"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងអ្វីដែលគ្រូប្រាប់និងឱ្យកុមារទះដៃសរសើរបើមានកុមារទាយត្រូវគ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម និងទាំងអស់គ្នា

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

✱ ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូចខែទី៣ ថ្ងៃទី១ ម៉ោងទី២)

✱ ទម្លាប់ល្អ៖ពេលរើសបានវត្ថុអ្វីមួយត្រូវសួររកម្ចាស់ឬប្រាប់គ្រូ ឬប្រាប់ឪពុកម្ដាយ

- គ្រូបំផុសសំណួរ៖ ពេលមកសាលារៀន កូនចេញលេងនៅក្រៅថ្នាក់ បើកូនរើសបានអ្វីមួយ(ខ្មៅដៃជ័រលុប លុយ...) កូនត្រូវធ្វើដូចម្ដេច? បើរកម្ចាស់មិនឃើញតើកូនត្រូវធ្វើដូចម្ដេច? បើនៅផ្ទះកូន ពេលលេងជាមួយមិត្តភក្តិផ្ទះជិតៗស្រាប់តែកូនរើសបានលុយ 500 រៀល ឬសម្ភារលេង តើកូនយកទុកខ្លួនឯងឬត្រូវធ្វើដូចម្ដេច? បើករណីរកម្ចាស់មិនឃើញទេកូនត្រូវប្រាប់ឪពុកម្ដាយ។
- គ្រូប្រាប់កុមារបន្ថែម ពេលកូនរើសបានអ្វីមួយទាំងនៅសាលារៀន ទាំងនៅផ្ទះ កូនត្រូវសួររកម្ចាស់ បើរកមិនឃើញទេនោះ កូនត្រូវប្រាប់គ្រូពេលនៅសាលារៀន ឬឪពុកម្ដាយពេលនៅផ្ទះ កូនមិនត្រូវយករបស់មិត្តភក្តិទេ។
- គ្រូឱ្យកុមារសម្ដែង៖ ដោយឱ្យកុមារណាម្នាក់រើសបានអ្វីមួយ រួចគេក៏សួរមិត្តភក្តិគេដើម្បីរកម្ចាស់ប៉ុន្តែគ្មានមិត្តភក្តិណាឆ្លើយទេ។ គេក៏យករបស់នោះជូនគ្រូ ប្រាប់គ្រូថាពេលចេញលេងខ្ញុំរើសបាននៅទីធ្លា ប៉ុន្តែរកម្ចាស់មិនឃើញទេ។

✱ គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១៦ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

## ល្បែង៖ បំពេញលេខតាមចន្លោះពី១ដល់១០

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបបំពេញលេខតាមចន្លោះពី១ដល់១០ បានត្រឹមត្រូវ
- កុមារបំពេញលេខតាមចន្លោះពី១ដល់១០ បានត្រឹមត្រូវ
- កុមារក្លាហាន ចូលរួមសហការ ឈ្លាសវៃ រហ័សរហួន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បន្ទះលេខចំនួន៣ បណ្ណលេខពី១ដល់១០ចំនួន៣ឈុត ស្កុត (កាត់រៀបចំឱ្យហើយ)

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារាងអក្សរអ៊ុយ"U" និង ជាក្រុមតូច

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងដំហានទី៣)

- គ្រូនិយាយទៅកុមារថា៖ ថ្ងៃនេះគ្រូមានបណ្ណលេខជាច្រើន
- គ្រូបង្ហាញបន្ទះលេខដែលមានលេខមិនពេញលេញនិង បណ្ណលេខ តើមានបន្ទះ និង បណ្ណលេខអ្វីខ្លះ?
- គ្រូបង្ហាញបន្ទះលេខ និងបណ្ណលេខ
- ថ្ងៃនេះគ្រូយកមុខវិជ្ជា:បុរេគណិតមានចំណងជើងថា៖**ល្បែង បំពេញលេខតាមចន្លោះពី១ដល់១០** មកបង្រៀនកូន
- គ្រូឱ្យកុមារអានចំណងជើង ២ទៅ៣ដង
- គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង
    - កូនត្រូវអង្គុយជារង្វង់ ទៅតាមក្រុមរបស់កូន ដែលគ្រូបានរៀបចំ
    - កូនត្រូវប្រាប់ឈ្មោះលេខនៅពេលគ្រូលើកបង្ហាញផ្ទាំងលេខនិងបណ្ណលេខទាំងអស់នោះហើយកូនត្រូវដាក់ផ្ទាំងលេខទាំងនោះនៅចំកណ្តាលរង្វង់ បន្ទាប់មកកូនប៉ាវរកអ្នកចាប់ផ្តើមដើម្បីជ្រើសរើសបណ្ណលេខដាក់បំពេញមុនគេត្រង់កន្លែងដែលមិនទាន់មានលេខ នៅពេលកូនបំពេញលេខ ចន្លោះបានហើយ កូនត្រូវឱ្យមិត្តភក្តិក្នុងក្រុមកូនជ្រើសរើសបណ្ណលេខមកដាក់បំពេញកន្លែងដែលបាត់រហូតដល់ពេញចន្លោះនោះបន្តបន្ទាប់គ្នា
- គ្រូឱ្យកូន១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមអ្វីដែលគ្រូប្រាប់(បើកុមារនិយាយមិនបាន គ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូរៀបកុមារទាំងអស់លេងជាក្រុមតូចអង្គុយជារង្វង់ ឱ្យក្រុមជួយផ្ទៀងផ្ទាត់ដោយឱ្យតំណាងក្រុមយកបន្ទះបណ្ណលេខរបស់ក្រុមដែលបំពេញរួចមកបង្ហាញជារួមហើយអានទាំងអស់គ្នា
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល (បើកុមារតាមក្រុមណាធ្វើបានល្អគ្រូលើកសរសើរ ឬ ចំពោះក្រុមកុមារណាធ្វើមិនបានល្អគ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ )។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## រឿងនិទាន៖ ពពក និងផ្កា (និទាន)

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីសកម្មភាពតួអង្គតាមដំណើររឿង បានត្រឹមត្រូវ
- កុមារនិទានរឿងនិងវិភាគតួអង្គនៅក្នុងរឿងបានត្រឹមត្រូវ
- កុមារយកចិត្តទុកដាក់ យកគំរូតាមតួអង្គល្អ សហការជួយគ្នា និទានរឿងឱ្យមិត្តភក្តិស្តាប់ ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាបណ្តុំ ជាជួរ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងដំហានទី៣)

- គ្រូបំផុសសំណួរ៖ តើកូនធ្លាប់ជួយឪពុកម្តាយធ្វើការងារផ្ទះដែរឬទេ? ការងារអ្វីខ្លះ? តើថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអំពីអ្វី? គ្រូសរុបចម្លើយរបស់កុមារ

-គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជា សិក្សាសង្គម ចំណងជើងរឿងនិទាន «**ពពកនិងកូនផ្កា** »

-គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដោយសួរកុមារថា៖មុននេះមានកូនណាឆ្លើយដូចចម្លើយអ្នកគ្រូដែរឬទេ? ដូច្នេះកូនទះដៃសរសើរមិត្តភក្តិយើងដែលបានទាយត្រូវទាំងអស់គ្នា

-គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា

-ប្រាប់ឈ្មោះអ្នកនិពន្ធ៖ រឿងនិទាននេះនិពន្ធដោយអ៊ំៗជាគ្រូនៅក្រសួងអប់រំ ឱ្យកុមារថាតាម

-គ្រូនិទានរឿងផ្ទាល់មាត់ឱ្យកុមារស្តាប់ ដោយលើកដាក់សំឡេងតាមតួអង្គនៃសាច់រឿង

-គ្រូនាំកុមារអានពាក្យពិបាក ជាក្រុម និងទាំងអស់គ្នា៖

- ខ្សោះ៖ ដែលស្ងួតសោះ
- អង្វរ៖ ពោលពាក្យលំអុក ទទូច បន្ទន់ចិត្តឱ្យអាណិត
- បង្អុរ៖ ធ្លាក់ភ្លៀង

- គ្រូសួរកុមារ៖ក្រោយពីស្តាប់រឿងនេះចប់ តើក្នុងរឿងមានតួអង្គប៉ុន្មាន? តួអង្គអ្វីខ្លះ? ហេតុអ្វីបានជាកូនផ្កាងាប់?តើកូនយកគំរូតាមពពកដែរឬទេ?ហេតុអ្វី? (កុមារឆ្លើយតបសំណួរគ្រូទៅតាមគំនិតរបស់គេម្នាក់ៗ)

- គ្រូសង្ខេបរឿងឱ្យកុមារស្តាប់ឡើងវិញម្តងទៀត

- បន្ទាប់មកគ្រូឱ្យកុមារនិយាយសង្ខេបរឿងឡើងវិញឱ្យមិត្តភក្តិស្តាប់ (កុមារនិយាយពីអ្វីដែលគេបានចងចាំ)

- ប្រាប់ឈ្មោះអ្នកនិពន្ធ ៖ រឿងនេះ អ៊ំៗនៅក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកនិពន្ធ ។

## អត្ថបទរឿង "ពពក និងកូនផ្កា"

នៅមុខផ្ទះមួយមានដើមផ្កាក្លាំងងារមួយដើមធំកំពុងបញ្ចេញផ្កាយ៉ាងច្រើនក្រអូបឈ្ងុយឈ្ងប់។ លោកតាម្ចាស់ ផ្ទះបានកាត់មែកផ្កាក្លាំងងារបំបែកផ្សាំដាក់ក្នុងកូនជាលជាច្រើន ដើម្បីទុកចែកចាយញាតិមិត្ត។ លោកតាថែទាំដោយដាក់ជី និងស្រោចទឹកជារៀងរាល់ថ្ងៃ។ ថ្ងៃមួយលោកតាបានដួលជំពប់ជើងនឹងដុំថ្ម។ អ្នកជិតខាងក៏ស្ទុះមកគ្រាហ៍លោកតាយកទៅព្យាបាលនៅឯមន្ទីរពេទ្យ។ កូនផ្កាក្នុងជាលគ្មានអ្នកស្រោចទឹក។ វាមិនអាចទប់ទល់នឹងភាពខ្សោះទឹក បានបានស្រែកហៅពពកនៅលើមេឃឱ្យបង្អុរភ្លៀងស្រោចលើខ្លួនវាផង។ ពពកឆ្លើយថា "ពួកយើងរវល់ណាស់ព្រោះថ្ងៃនេះយើងត្រូវទៅស្រោច រុក្ខជាតិផ្ទះលោកម្ចាស់ " ។

ដើមផ្កាក្លាំងងារធំ ក៏បានជួយអង្វរដែរថា " រុក្ខជាតិធំៗ ដូចពួកខ្ញុំមាន ឫសជ្រៅអាចទ្រាំបានយូរថ្ងៃ។ សូមពពកជួយកូនផ្កាតូចៗនេះសិនទៅ។ ពពកឆ្លើយថា "មិនបានទេ! ខ្ញុំត្រូវតែទៅ ចាំថ្ងៃខានស្អែក ខ្ញុំនឹងត្រឡប់មក បង្អុរភ្លៀងស្រោចឱ្យពួកអ្នក " ។ ក្រោយមកពពកក៏ត្រឡប់មកតាមពាក្យសន្យាមែន តែអ្វីៗហួសអស់ហើយ កូនផ្កាដែលត្រូវសង្គ្រោះជាបន្ទាន់នោះបានស្វិតងាប់អស់រលីង។ ពពកនឹកស្តាយក្រោយ ព្រោះតែចង់ផ្គាប់ផ្គន់លោកម្ចាស់ពេកមិនបានគិតឱ្យបានច្បាស់ពីជីវិតកូនផ្កាតូចៗ ឃើញដូច្នេះដើមផ្កាក្លាំងងារមិននិយាយវែងឆ្ងាយទេ គ្រាន់តែពោលយ៉ាងខ្លីថា "ហ៊ឺ! ពពកអើយប្រសិនបើអ្នកគិតឱ្យច្បាស់លាស់នោះ ម្លេះសមកូនផ្កាមិនងាប់ទេ "។

ម៉ោងទី៨ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ភាសាខ្មែរ
## ល្បែងៈ ធ្វើតាមការណែនាំ៣ដំណាក់

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីសកម្មភាពតាមដំណាក់ ដោយអនុវត្ត តាមការណែនាំ បានត្រឹមត្រូវ
- កុមារបង្ហាញពីសកម្មភាពតាមការណែនាំ៣ដំណាក់ បានត្រឹមត្រូវ
- កុមារមានភាពឈ្លាសវៃ រហ័សរហួន សហការ បម្រុងប្រយ័ត្ន ព្យាយាម និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀនៈ** កៅអី កែវទឹក

**៣. ការរៀបចំកុមារៈ** ឱ្យកុមារអង្គុយជារាងអក្សរអ៊ុយ "ប" និងចែកកុមារជាក្រុម

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូរៀបចំសម្ភារទាំងអស់ដាក់លើតុ លើកកែវទឹក ហើយសួរកុមារថា នេះជាអ្វី? បន្ទាប់មកគ្រូលើក ឬចង្អុលទៅកៅអី ហើយសួរកុមារថា នេះជាអ្វី? កុមារឆ្លើយតបទៅតាមសំណួររបស់គ្រូ
- **ណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
- គ្រូដាក់កែវទឹកនៅលើតុក្រោយខ្នងកុមារចម្ងាយ៣ម៉ែត្រ ឬ(តាមដាក់ស្តែងបើថ្នាក់តូច)
- គ្រូហៅកុមារម្នាក់មកឈរជិត រួចនិយាយព្ញៗឱ្យកុមារស្តាប់ និងធ្វើតាមការណែនាំរបស់គ្រូ ដោយនិយាយថា ចូរ**កូនទៅយកកែវទឹកនៅលើតុនោះមកជូនគ្រូ រួចទៅអង្គុយនៅលើកៅអី ឬកន្លែងរបស់កូនវិញ បន្ទាប់មកកូនទះដៃពីរដង (កុមារចេញទៅយកសម្ភារលេងម្នាក់ម្តងៗ នៅក្នុងក្រុម)**។ ក្នុងក្រុមនីមួយៗ បើមានកូនៗណាមិនបានធ្វើតាមការណែនាំរបស់គ្រូច្រើនជាងគេ គឺជាអ្នកចាញ់។
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីរបៀបលេងតាមដំណាក់នីមួយៗ (បើកុមារនិយាយមិនបាន គ្រូត្រូវប្រាប់ម្តងទៀត)
- រៀបចំកុមារជា៣ក្រុម បើកុមារច្រើនរៀបតាមកុមារជាក់ស្តែង
- ចែកសម្ភារ និងឱ្យកុមារអនុវត្តការលេង(ឱ្យតំណាងក្រុមឡើងមកយកសម្ភារលេងដោយខ្លួនឯង)
- គ្រូលើកសរសើរចំពោះ(ក្រុម)ឬអ្នកដែលឈ្នះ ចំពោះអ្នកចាញ់គ្រូលើកទឹកចិត្តឱ្យប្រឹងបន្ថែមទៀត មិនត្រូវប្រៀបធៀប និងបន្ទុះបង្អាប់កុមារឡើយ )
- **គ្រូសួរកុមារៈ**
  - កូនៗទាំងអស់គ្នាសប្បាយទេ ? **តើមុននេះ កូនៗបានលេងល្បែងអ្វី**? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - **តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ **ថ្ងៃនេះយើងរៀនមុខវិជ្ជាភាសាខ្មែរ អំពីល្បែង មេរៀន " ធ្វើតាមការណែនាំមាន៣ដំណាក់"**
- **គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់** (តើមុននេះមានកូនៗណាឆ្លើយដូចចម្លើយរបស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)

-**គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា** ។

ម៉ោងទី៦ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ ចិត្តចលភាព

## ល្បែង៖ ចាប់វត្ថុប្រណាំងគ្នាដោយប្រើម្រាមដៃ២

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបធ្វើចលនាម្រាមដៃចាប់វត្ថុប្រណាំងគ្នាបានត្រឹមត្រូវ
- កុមារធ្វើចលនាម្រាមដៃចាប់វត្ថុប្រណាំងគ្នា បានត្រឹមត្រូវ
- កុមារព្យាយាម អំណត់ សហការ ប្រុងប្រយ័ត្ន រហ័សរហួន ទន់ភ្លន់ និងសប្បាយរីករាយ

**២. សម្ភារបង្រៀន៖** គ្រាប់អំពិលចំនួន១កញ្ចប់ធំ

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរ អ៊ុយ "U" កុមារអង្គុយជារង្វង់តាមក្រុមតូចៗ

**៤. ដំណើរការបង្រៀន៖(អនុវត្តនៅក្នុងជំហានទី៣)**

- គ្រូប្រាប់ពីមុខវិជ្ជានិងចំណងជើងមេរៀនរួចឱ្យកុមារថាតាមជាក្រុមនិងទាំងអស់គ្នា
- គ្រូដាក់កញ្ចប់សម្ភារនៅលើតុពីមុខកុមាររួចឱ្យកុមារស្ម័គ្រចិត្តចំនួន ១ទៅ២ នាក់មកស្ទាបហើយទាយសម្ភារនៅក្នុងកញ្ចប់នោះរួចឱ្យកុមារទៅអង្គុយកន្លែងវិញ
- គ្រូឱ្យកុមារ១នាក់ឡើងមកលូកយកសម្ភារនៅក្នុងកញ្ចប់នោះចេញ រួចសួរកុមារ តើមិត្តភក្តិយើង២នាក់អម្បាញ់មិញ មានអ្នកណាទាយត្រូវទេ?គ្រូសរុបចម្លើយរបស់កុមារ
- គ្រូឱ្យកុមារទាំងអស់ទះដៃសរសើរមិត្តភក្តិដែលបានទាយត្រូវនិងលើកទឹកចិត្ត អ្នកដែលទាយមិនទាន់ត្រូវ
- គ្រូសួរកុមារ៖តើកូនដឹងទេថាគ្រូយកសម្ភារនេះមកឱ្យកូនធ្វើអ្វី?កុមារឆ្លើយតាមគំនិតរបស់គេម្នាក់ៗ
- **គ្រូណែនាំពីរបៀបលេង**
    - គ្រូឱ្យកូនៗលេងជាក្រុមតូចៗហើយក្នុង១ក្រុមត្រូវបានសម្ភារ១កញ្ចប់និងក្រុមនីមួយៗត្រូវអង្គុយជារង្វង់
    - ពេលក្រុមកូននីមួយៗបានសម្ភារហើយ កូនត្រូវចាក់គ្រាប់អំពិលចេញពីក្នុងកញ្ចប់តូចដាក់នៅកណ្តាលវង់ហើយកូនកុំដណ្តើមគ្នា
    - ពេលកូនចាប់ផ្តើមលេង កូនត្រូវចាំស្តាប់សញ្ញារបស់គ្រូ កាលណាគ្រូស្រែកថា ចាប់ផ្តើមលេង កូនទាំងអស់គ្នាត្រូវនាំគ្នាចាប់យកគ្រាប់អំពិលដោយប្រើមេដៃស្តាំជាមួយចង្អុលដៃស្តាំពីចំណុចម្ខាងទៅដាក់ចំណុចម្ខាងទៀត បន្ទាប់មកកូនត្រូវចាប់យកគ្រាប់អំពិលរបៀបនេះដោយប្តូរម្រាមដៃជាបន្តបន្ទាប់គ្នារហូតដល់កូនដៃ(កូនចាប់របៀបនេះរហូតដល់អស់គ្រាប់អំពិល)។
    - គ្រូនាំកុមារលេងដៃខាងឆ្វេងម្តងដោយចាប់ផ្តើមលេងពីមេដៃឆ្វេងជាមួយចង្អុលដៃឆ្វេងហើយចាប់យកគ្រាប់អំពិលពីចំណុចម្ខាងទៅដាក់ចំណុចម្ខាងទៀត លេងរបៀបនេះបន្តបន្ទាប់គ្នារហូតដល់កូនដៃ (គ្រូឱ្យកុមារលេងរបៀបនេះពី១ដងទៅ២ដងអាស្រ័យលើពេលវេលា)។
    - គ្រូនិងកុមារផ្ទៀងផ្ទាត់ដោយរាប់ចំនួនគ្រាប់អំពិលរបស់កូនម្នាក់ៗកូនណាដែលបានគ្រាប់អំពិលច្រើនជាងគេគឺជាអ្នកឈ្នះ ហើយកូនណាដែលបានគ្រាប់អំពិលតិចជាងគេគឺជាអ្នកចាញ់ ។
    - គ្រូលើកសរសើរដល់កូនដែលឈ្នះគេ ចំពោះកូនដែលចាញ់គេ គ្រូលើកទឹកចិត្តឱ្យខំបន្តទៀត។

## ថ្ងៃទី១៧

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

រំលឹក **ហាត់ប្រាណតាមបទចម្រៀង៖ យើងក្មេងៗនាំគ្នារាំ**

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១២ ម៉ោងទី១)

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖សិក្សាសង្គម

### សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូចខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ ពេលរើសបានវត្ថុអ្វីមួយត្រូវសួររកម្ចាស់ឬប្រាប់គ្រូ ឬប្រាប់ឳពុកម្តាយ (ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១៧ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

### កំណាព្យ៖ ជួយដាំចេកតា

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីចំណងជើង និងអត្ថន័យនៃកំណាព្យ«**ជួយដាំចេកតា** » បានត្រឹមត្រូវ។
- កុមារសូត្រកំណាព្យត្រូវតាមវាក្យស័ព្ទនិងទំនុកបទបានត្រឹមត្រូវ។
- កុមារមានភាពក្លាហាន ស្រឡាញ់ និងចូលចិត្តកំណាព្យ។

**២. សម្ភារបង្រៀន៖** សៀវភៅអត្ថបទកំណាព្យ

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជារាងអក្សរអ៊ុយ"ᑌ"

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- ថ្ងៃនេះគ្រូនឹងយកមេរៀនកំណាព្យមួយមកបង្រៀនកូនៗទាំងអស់គ្នា
- គ្រូសូត្រកំណាព្យឱ្យកុមារស្តាប់មួយចប់សិនដើម្បីឱ្យកុមារយល់អត្ថន័យនៃកំណាព្យ
- គ្រូឱ្យកុមារអានអត្ថបទ និងរកពាក្យពិបាក
- គ្រូប្រាប់និងពន្យល់ពាក្យពិបាក
    - អនេក៖ ច្រើនរាប់ពុំបាន
    - សប្បាយ៖ មិនមានទុក្ខព្រួយ
- គ្រូសួរកុមារ តើកំណាព្យដែលគ្រូបានសូត្រគេចង់និយាយពីអ្វី?
- គ្រូនាំកុមារសូត្រកំណាព្យឃ្លាទី១ ឱ្យបានមួយចប់គ្រប់ៗគ្នា បន្ទាប់មកកុមារសូត្រឃ្លាទី២
- ពេលកុមារសូត្រកំណាព្យ ឃ្លាទី១ ឃ្លាទី២ រួចឱ្យកុមារសូត្រឃ្លាទាំងពីររួមបញ្ចូលគ្នា

- គ្រូនាំកុមារសូត្រឃ្លាបន្តបន្ទាប់តាមរបៀបខាងលើរហូតដល់ចប់នៃអត្ថបទកំណាព្យ
- គ្រូឱ្យកុមារសូត្រកំណាព្យសាឡើងវិញរួមគ្នា ១ឬ២ចប់
- គ្រូសួរកុមារ តើអម្បាញ់មិញកូនរៀនមុខវិជ្ជាអ្វី?មេរៀនអ្វី?អ្នកនិពន្ធឈ្មោះអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់ថា ថ្ងៃនេះយើងរៀនមុខវិជ្ជា៖ភាសាខ្មែរ មេរៀន កំណាព្យ«ជួយដាំចេកតា»អ្នកនិពន្ធដោយលោក អ៊ំនៅក្រសួងអប់រំ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុម និងទាំងអស់គ្នា

អត្ថបទកំណាព្យ «ជួយដាំចេកតា» (បទកាកគតិ)

| | | |
|---|---|---|
| ថ្ងៃមួយនោះណា | ខ្ញុំទៅចំការ | ឃើញតាដាំចេក |
| តាដាំជាជួរ | ត្រង់ល្អអនេក | ខ្ញុំសប្បាយពេក |
| | ជួយដាំចេកតា។ | |

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## ចម្រៀង៖ ឆ្វេង ស្តាំ (ពេលទី២)

**១. វត្ថុបំណង៖**
- កុមារប្រាប់បានពីអត្ថន័យ និងរបៀបធ្វើកាយវិការបទចម្រៀងឆ្វេង ស្តាំបានត្រឹមត្រូវ
- កុមារច្រៀងចម្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀងឆ្វេង ស្តាំបានត្រឹមត្រូវ
- កុមារស្រឡាញ់ ចូលចិត្តច្រៀងចម្រៀង សហការគ្នា និងចូលរួមយ៉ាងសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** អង្គុយជារាងអក្សរអ៊ុយ "U"

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)
- គ្រូបំផុសសំណួរ៖ កូនគិតបន្តិចទៅមើលថា តើថ្ងៃមុនកូនបានរៀនច្រៀងចម្រៀងអ្វី?តើចម្រៀងនោះមានន័យដូចម្តេច?(បើកុមារឆ្លើយមិនត្រូវគ្រូប្រាប់កុមារតែម្តង)
- គ្រូសួរកុមារបន្តថា កូនទាយទៅមើលថា ថ្ងៃនេះ គ្រូនាំកូនរៀនមុខវិជ្ជាអ្វី? អំពីអ្វី? កុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ។ គ្រូសរុបចំណងជើងមេរៀនដែលកុមារទាយ
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះ គ្រូនឹងបង្រៀនកូន មុខវិជ្ជាសិក្សាសង្គម អំពីចម្រៀង "ឆ្វេង ស្តាំ" នេះម្តងទៀត
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារ ទៅនឹងអ្វីដែលគ្រូបានប្រាប់ ដោយនិយាយថា៖ អម្បាញ់មិញ មានកូនៗបានទាយត្រូវ ពីមុខវិជ្ជា និងចំណងជើងមេរៀន។ កូនពិតជាឆ្លាតមែន ពូកែទាយណាស់។ ប៉ុន្តែកូនដែលទាយមិនត្រូវក៏ក្លាហានដែរ ហ៊ានឆ្លើយសំណួររបស់គ្រូ ដូច្នេះថ្ងៃក្រោយកូនព្យាយាមឆ្លើយទៀតណា!
- គ្រូប្រាប់ និងសរសេរមុខវិជ្ជា និងចំណងជើងដាក់លើក្តារខៀន រួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូឱ្យកុមារច្រៀង និងធ្វើកាយវិការដែលបានធ្វើនៅពេលទី១ឡើងវិញជាក្រុម និងទាំងអស់គ្នា ឱ្យបាន២ចប់
- គ្រូប្រាប់កុមារថា ឥឡូវគ្រូនឹងច្រៀងចម្រៀងនេះម្តង តែគ្រូដូចជាភ្លេចពាក្យខ្លះៗ តើកូនអាចជួយថាពាក្យនោះប្រាប់លោកគ្រូបានទេ បើគ្រូភ្លេចពាក្យទាំងនោះ។ បន្ទាប់មកគ្រូចាប់ផ្តើមច្រៀងដោយធ្វើជាបំបាត់

ពាក្យខ្លះក្នុងខ្លឹមសារអត្ថបទចម្រៀង ឱ្យកុមារជួយបំពេញ។ គ្រូអនុវត្តបែបនេះឱ្យបាន២ចប់។

- គ្រូប្រាប់កុមារថា៖ ឥឡូវនេះគ្រូនឹងធ្វើកាយវិការតាមបទចម្រៀងនេះហើយកូនជាអ្នកច្រៀងឱ្យគ្រូធ្វើកាយវិការ បន្ទាប់មកគ្រូចាប់ផ្តើមធ្វើកាយវិការ ហើយកុមារទាំងអស់ច្រៀងចម្រៀង។គ្រូនាំអនុវត្តបែបនេះឱ្យបាន២ចប់។
- គ្រូប្រាប់កុមារថា៖ អម្បាញ់មិញកូនបានច្រៀងឱ្យគ្រូធ្វើកាយវិការ។ ឥឡូវកូនជាអ្នកធ្វើកាយវិការម្តង ហើយគ្រូនឹងច្រៀងឱ្យកូនធ្វើកាយវិការវិញម្តង តើកូនយល់ព្រមដែរឬទេ? បន្ទាប់មកគ្រូចាប់ផ្តើមច្រៀង ហើយកុមារជាអ្នកធ្វើកាយវិការទាំងអស់គ្នា។ គ្រូនាំអនុវត្តបែបនេះឱ្យបាន២ចប់។
- គ្រូនាំកុមារច្រៀង និងធ្វើកាយវិការតាមបទចម្រៀងសាឡើងវិញឱ្យបាន២ ទៅ៣ចប់ ទាំងអស់គ្នា

ខ្លឹមសារ និងរបៀបធ្វើកាយវិការ

+ អត្ថបទចម្រៀង៖ ឆ្វេង ស្តាំយើងក្មេងៗ ឆ្វេង ស្តាំ ចាំឱ្យស្ទាត់ ១ ២ ពួកយើងប្រយ័ត្នដើរឱ្យត្រូវជើង ១ ២

ឆ្វេង ស្តាំត្រូវចាំពួកយើង ដើរឱ្យត្រូវជើងកុំច្រឡំ ១ ២ ។

+ របៀបធ្វើកាយវិការ៖ ដើរដំណើរដូចពួកងទ័ព ដោយលើកជើងឆ្វេងឡើងរួចដាក់ចុះ ហើយលើកជើងស្តាំម្តង ដៃឆ្វេងបោះទៅមុខ ដៃស្តាំបោះទៅក្រោយ ចុះឡើងតាមចង្វាក់ចម្រៀង

### ម៉ោងទី៨ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

## ល្បែង៖ ហុចកញ្ចប់បន្លែ និងផ្លែឈើ

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបលេងល្បែងហុចកញ្ចប់បន្លែ និងផ្លែឈើ បានត្រឹមត្រូវ
- កុមារលេងល្បែងហុចកញ្ចប់បន្លែ និងផ្លែឈើ បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន សហការ ជួយគ្នាក្នុងការអនុវត្តការងារក្រុមបានត្រឹមត្រូវ ។

**២. សម្ភារបង្រៀន៖** បណ្ណបន្លែ និងផ្លែឈើមួយឈុត កន្សែង

**៣. ការរៀបចំកុមារ៖** អង្គុយជារាងអក្សរអ៊ុយ "U"

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងដំហានទី៣)

- គ្រូឱ្យកុមារប្រាប់ឈ្មោះបន្លែដែលគេធ្លាប់ស្គាល់ បន្ទាប់មកឱ្យកុមារប្រាប់ឈ្មោះផ្លែឈើបន្តទៀត
- គ្រូដាក់បណ្ណបន្លែ និងផ្លែឈើនៅលើតុ រួចឱ្យកុមារម្នាក់ឡើងមករើសបណ្ណបន្លែបង្ហាញ រួចឱ្យមិត្តភក្តិប្រាប់ឈ្មោះ និងឱ្យកុមារម្នាក់ទៀតឡើងមករើសបណ្ណផ្លែឈើបង្ហាញ រួចឱ្យមិត្តភក្តិប្រាប់ឈ្មោះ
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
    - គ្រូឱ្យកូនទាំងអស់គ្នាលេងជាមួយគ្រូ ហើយកូននាំគ្នាអង្គុយជារង្វង់ ។ គ្រូមានបណ្ណបន្លែនិងផ្លែឈើដែលបានបង្ហាញកូនអម្បាញ់មិញ ដាក់ផ្កាប់នៅកណ្តាលរង្វង់ ហើយដាក់ច្របូកច្របល់គ្នា
    - កូនត្រូវរកមិត្តភក្តិណាម្នាក់សម្រាប់ចាប់ផ្តើម ។ ពេលរកបានអ្នកចាប់ផ្តើមហើយ គ្រូឱ្យកញ្ចប់ទៅកូនដែលត្រូវចាប់ផ្តើមកាន់សម្រាប់ហុចបន្តគ្នា
    - ពេលគ្រូឱ្យសញ្ញាចាប់ផ្តើមដោយទះដៃម្តង កូនដែលជាអ្នកចាប់ផ្តើមត្រូវហុចកញ្ចប់ទៅអ្នកស្តាំដៃបន្តបន្ទាប់ ហុចបណ្តើរច្រៀងបណ្តើរ ។ ពេលគ្រូឱ្យសញ្ញាបញ្ឈប់ដោយទះដៃពីរដង កូនៗត្រូវឈប់

ច្រៀង ហើយកញ្ចប់នៅលើដៃកូនណា កូននោះយកបណ្ណមួយសន្លឹកដែលផ្កាប់នៅកណ្ដាលវង់ មកសង្កេតមើលរួចប្រាប់ឈ្មោះរូបនៅក្នុងបណ្ណនោះឱ្យមិត្តភក្ដិស្ដាប់ បន្ទាប់មកលើកបណ្ណនោះបង្ហាញមិត្តភក្ដិដើម្បីផ្ទៀងផ្ទាត់ បើប្រាប់មិនត្រឹមត្រូវគឺមិត្តភក្ដិជួយកែលម្អ រួចយកបណ្ណនោះទុកនៅកន្លែងដែលគ្រូឱ្យទុក

- កូនត្រូវហុចបន្តបន្ទាប់តាមសញ្ញាបញ្ជាចាប់ផ្ដើម និងបញ្ឈប់របស់គ្រូ

- គ្រូឱ្យកុមារ១ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្ដងទៀត)
- គ្រូរៀបចំកុមារឱ្យអង្គុយជារង្វង់ ហើយឱ្យកុមារយកបណ្ណបន្លែផ្លែឈើមករៀបផ្កាប់រាយប៉ាយកណ្ដាលវង់ពីមុខកុមារទាំងអស់គ្នា
- គ្រូនាំកុមារលេងទាំងអស់គ្នា ដោយគ្រូជាអ្នកឱ្យសញ្ញាចាប់ផ្ដើម ដោយទះដៃម្ដង និងសញ្ញាបញ្ឈប់ទះដៃពីរដង
- ពេលលេងម្ដង គ្រូនាំកុមាផ្ទៀងផ្ទាត់លទ្ធផលម្ដង ហើយពេលទះដៃជាសញ្ញាបញ្ឈប់ គ្រូត្រូវមើលកុមារចៀសវាងចំ កុមារដេដែលៗ ធ្វើយ៉ាងណាឱ្យកុមារបានលេងទាំងអស់គ្នា បើករណីបណ្ណបន្លែ និងផ្លែឈើមានតិច ពេលលេងអស់ បណ្ណមួយសា ត្រូវរៀបបណ្ណឡើងវិញមួយសាទៀត ហើយនាំកុមារលេងបន្តទៀតរហូតដល់ម៉ោង
- **គ្រូសួរកុមារ៖** អម្បាញ់មិញកូនស្គាល់អ្វីខ្លះ? ដូចនេះកូនជួយប្រាប់គ្រូបានទេ? តើយើងរៀនមុខវិជ្ជាអ្វី? មេរៀនអំពីអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ **ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ អំពីល្បែង " ហុចកញ្ចប់បន្លែ និងផ្លែឈើ "** រួចសួរកុមារអម្បាញ់មិញមានកូនណាទាយត្រូវឬទេ?ដូចនេះកូនៗដែលទាយត្រូវគឺជាកូនពូកែកូនឆ្លាត។រីឯកូនដែលទាយមិនត្រូវក៏ល្អដែរ ដែលក្លាហានក្នុងការនិយាយជាមួយគ្រូ។
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

### ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

∗ ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី១៨

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

រំលឹក **ហាត់ប្រាណតាមរឿងនិទាន៖ មេមាន់នាំកូនទៅរកចំណី**

( ដំណើរការបង្រៀនអនុវត្តដូចខែទី៣ ថ្ងៃទី៣ ម៉ោងទី១ )

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖សិក្សាសង្គម

### សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" ( ដំណើរការបង្រៀនអនុវត្តដូចខែទី៣ ថ្ងៃទី១ ម៉ោងទី២ )
* ទម្លាប់ល្អ៖ ពេលរើសបានវត្ថុអ្វីមួយត្រូវសួររកម្ចាស់ឬប្រាប់គ្រូ ឬប្រាប់ឪពុកម្តាយ ( ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១៦ ម៉ោងទី២ )
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១៨ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ វិទ្យាសាស្ត្រ

### ល្បែង៖ រកដៃគូបន្លែស្លឹក និងបន្លែផ្លែ

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីឈ្មោះបន្លែស្លឹក និងបន្លែផ្លែបានត្រឹមត្រូវ
- កុមាររាប់ឈ្មោះបន្លែស្លឹក និងបន្លែផ្លែបានត្រឹមត្រូវ
- កុមារខិតខំ យកចិត្តទុកដាក់ ចងចាំ សហការ និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បណ្ណឈ្មោះបន្លែស្លឹក និងបន្លែផ្លែ មួយបន្ទះមាន២សន្លឹក

**៣. ការរៀបចំកុមារ៖** ឱ្យកុមារអង្គុយជារាងអក្សរអ៊ុយ "ប" និងឱ្យកុមារឈរជារង្វង់

**៤. ដំណើរការបង្រៀន៖** ( អនុវត្តនៅក្នុងជំហានទី៣ )

- គ្រូឱ្យកុមាររាប់ឈ្មោះបន្លែស្លឹក និងបន្លែផ្លែទាំងអស់គ្នា
- គ្រូដាក់បណ្ណឈ្មោះបន្លែស្លឹក និងបន្លែផ្លែនៅលើតុមុខកុមារទាំងអស់ រួចហៅកុមារម្នាក់ ឱ្យមកលើកបណ្ណនោះម្តងមួយៗបង្ហាញមិត្តភក្តិនិងប្រាប់ឈ្មោះ
- គ្រូប្រាប់កុមារបន្ថែមក្នុងបណ្ណឈ្មោះបន្លែស្លឹក និងបន្លែផ្លែ ក្នុងមួយបណ្ណមាន២សន្លឹក (គ្រូលើកបង្ហាញទាល់តែគ្រប់បណ្ណបន្លែស្លឹក និងបន្លែផ្លែទាំងអស់)
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
    - គ្រូឱ្យកុមារលេងទាំងអស់គ្នា ហើយកូននាំគ្នាឈរជារង្វង់ គ្រូនឹងឱ្យបណ្ណកូនម្នាក់មួយសន្លឹកកាន់នៅដៃ
    - ពេលកូនបានបណ្ណនៅដៃទាំងអស់គ្នាហើយ កូនលើកបង្ហាញប្រាប់មិត្តភក្តិម្នាក់ម្តងៗពីឈ្មោះបន្លែ

ស្លឹក និងបន្លែផ្លែក្នុងបណ្ណនោះ ដើម្បីឱ្យមិត្តភក្តិយើងចំណាំ

- ពេលគ្រូឱ្យសញ្ញាចាប់ផ្តើម កូនៗនាំគ្នាដើរជារង្វង់ ដើរផង ច្រៀងផង ពេលគ្រូឱ្យសញ្ញាបញ្ឈប់កូនទាំងអស់គ្នា រត់រកដៃគូដែលមានឈ្មោះបន្លែស្លឹក និងបន្លែផ្លែដូចគ្នា ហើយឈរពីរនាក់ៗ ឃ្លាតឆ្ងាយពីគ្នា
- ពេលកូនចាប់ដៃគូបានហើយ កូនត្រូវសង្កេតមើលបណ្ណរបស់ខ្លួនដូចគ្នាឬទេ ? ដើម្បីចាំគ្រូនាំផ្ទៀងផ្ទាត់

- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីអ្វីដែលគ្រូបានប្រាប់ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូរៀបកុមារឱ្យឈរជារង្វង់ ហើយគ្រូឱ្យកុមារពីរនាក់យកបណ្ណចែកមិត្តភក្តិទាំងអស់គ្នា
- គ្រូនាំកុមារលេងទាំងអស់គ្នា គ្រូជាអ្នកឱ្យសញ្ញាចាប់ផ្តើម និងសញ្ញាបញ្ឈប់
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផល គឺឱ្យកុមារដែលចាប់ដៃគូគ្នានោះប្រាប់ពីបណ្ណទាំងពីរ អក្សរដូចគ្នាឬទេ? ហើយឈ្មោះបន្លែអ្វី? បន្ទាប់មកឱ្យគូដទៃទៀតជាអ្នកវាយតម្លៃ (បើប្រាប់ឈ្មោះបន្លែខុសត្រូវជួយកែតម្រូវ) ។ គ្រូធ្វើរបៀបនេះទាល់តែគ្រប់កូនទាំងអស់ ។
- គ្រូនាំកុមារលេងរបៀបនេះបន្តបន្ទាប់ ប៉ុន្តែប្តូរបណ្ណគ្នាទៅវិញទៅមក រហូតដល់ម៉ោង
- គ្រូឱ្យកុមារប្រមូលសម្ភារទុកជូនគ្រូវិញ និងឱ្យកុមារទៅអង្គុយនៅក្នុងក្រុមធំវិញទាំងអស់គ្នា
- **គ្រូសួរកុមារ៖**
  - កូនៗទាំងអស់គ្នាសប្បាយទេ ? **តើមុននេះ កូនៗបានលេងល្បែងអ្វី**? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - **តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ?** (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ **ថ្ងៃនេះយើងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ មេរៀនល្បែង "រកដៃគូបន្លែស្លឹក បន្លែផ្លែ"**
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយ របស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

### គំនូរ៖ គូរសេរី

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបគូររូបផ្សេងៗដោយសេរីតាមការស្រមើស្រមៃបានត្រឹមត្រូវ
- កុមារកាន់ខ្មៅដៃគូររូបផ្សេងៗដោយសេរីតាមការស្រមើស្រមៃបានត្រឹមត្រូវ
- កុមារមានភាពអំណត់ ព្យាយាម ផ្ចិតផ្ចង់ សហការយ៉ាងសកម្មនិងសប្បាយរីករាយ។

**២. សម្ភារបង្រៀន៖**

☞**សម្ភារសម្រាប់គ្រូ៖** គ្មាន

☞**សម្ភារសម្រាប់កុមារ៖**

-ផ្ទាំងក្រដាសសដែលមានដាក់ឈ្មោះ ថ្ងៃ ខែ ឆ្នាំ អនុវត្តមុខវិជ្ជា និងចំណងជើងមេរៀននៅក្បាលសន្លឹកកិច្ច

ការគ្រប់ចំនួនកុមារ និងខ្មៅដៃគ្រប់ចំនួនកុមារ

៣. **ការរៀបចំកុមារ៖** អង្គុយរាងអក្សរ "ប" ចែកកុមារជាក្រុម(អនុវត្តជាបុគ្គល)

៤. **ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូសួរ៖ តើកូនៗធ្លាប់ទៅដើរលេងជាមួយឪពុកម្តាយនៅកន្លែងណាខ្លះ? ហើយនៅពេលកូនទៅដើរលេង កូនបានសង្កេតឃើញអ្វីខ្លះនៅទីនោះ? តើកូនៗពេញចិត្តនិងស្រឡាញ់អ្វីជាងគេ? (ចម្លើយតាមគំនិតកុមារម្នាក់ៗ)
- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចឱ្យកុមារថាតាម(ជាក្រុមនិងទាំងអស់គ្នា)
- គ្រូបង្ហាញផ្ទាំងក្រដាសស១សន្លឹក ដែលគ្រូមិនទាន់គូរឱ្យកុមារសង្កេត
- គ្រូប្រាប់កុមារ៖ ផ្ទាំងក្រដាសសនេះគ្រូទុកសម្រាប់ឱ្យកូនគូរគំនូរដោយសេរីតាមចំណង់ចំណូលចិត្តកូនដែលកូនបានឃើញ។ គ្រូឱ្យកូននាំគ្នាគូរដោយសេរី
- គ្រូបង្ហាញផ្ទាំងក្រដាសជាសន្លឹកកិច្ចការកុមារម្នាក់ៗរួចប្រាប់កុមារ៖កូនម្នាក់ៗត្រូវបានផ្ទាំងសន្លឹកកិច្ចការនេះមួយសន្លឹកនិងខ្មៅដៃមួយដើម សម្រាប់កូនគូរដោយសេរីទៅតាមអ្វីដែលកូនចង់គូរម្នាក់ៗ
- គ្រូរៀបចំកុមារឱ្យអង្គុយទៅតាមតុដែលគ្រូបានរៀបចំឬបង្វិលកៅអី អង្គុយគូរ (តាមស្ថានភាពជាក់ស្តែង)
- ឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារទៅចែកគ្នាអនុវត្ត
- កុមារម្នាក់ៗនាំគ្នាអនុវត្ត គ្រូដើរសម្របសម្រួលគ្រប់ក្រុម សួរកុមារដាក់ចំណងជើងមេរៀនទៅតាមរូបភាពគំនូរជាក់ស្តែងរបស់កុមារម្នាក់ៗ និងដាក់ឈ្មោះកុមារ ពីខាងក្រោមសន្លឹកកិច្ចការរបស់កូនម្នាក់ៗ
- គ្រូប្រាប់កុមារ៖ ពេលកូនគូររួចហើយកូនយកខ្មៅដៃទៅទុកឱ្យគ្រូវិញ ហើយសន្លឹកកិច្ចការរបស់កូនទុកនៅរៀងៗខ្លួន។
- ពេលកុមារគូរហើយគ្រប់គ្នា គ្រូឱ្យកុមារទៅអង្គុយកន្លែងដើមជារាងអក្សរ(អ៊ុយ)វិញ
- គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផល ដោយឱ្យកុមារទៅឈរម្តងមួយក្រុមនៅខាងមុខ ហើយកាន់សន្លឹកកិច្ចការដាក់នៅត្រង់ដើមទ្រូងបង្ហាញមិត្តភក្តិ ដើម្បីឱ្យពួកគេជាអ្នកផ្ទៀងផ្ទាត់។
- គ្រូសួរកុមារដែលជាអ្នកផ្ទៀងផ្ទាត់: តើមិត្តភក្តិយើងមួយណាគូរបានស្អាតជាងគេ? បើមានកុមារណាបង្អាប់គំនូររបស់មិត្តភក្តិណាម្នាក់ គ្រូត្រូវចេះកែតម្រូវទៅជាពាក្យសម្តីលើកទឹកចិត្តកុមារនោះវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះឱ្យបានគ្រប់ក្រុមទាំងអស់
- គ្រូឱ្យតំណាងក្រុមនីមួយៗប្រមូលសន្លឹកកិច្ចការរបស់មិត្តភក្តិគេឱ្យគ្រូសម្រាប់ទុកដាក់តាំងស្នាដៃកុមារ។

**ម៉ោងទី៨ (រយៈពេល ៣០នាទី)**

## មុខវិជ្ជា៖ បុរេគណិត

## ល្បែង៖ រកដៃគូលេខពី១ដល់១០

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបរកដៃគូលេខពី១ ដល់១០ បានត្រឹមត្រូវ
- កុមាររកដៃគូលេខពី១ដល់១០ បានត្រឹមត្រូវ
- កុមារខិតខំ យកចិត្តទុកដាក់ សហការ និងសប្បាយរីករាយ ។

**២. សម្ភារបង្រៀន៖** បណ្ណលេខពី១ដល់១០ មួយបន្ទះមាន៤សន្លឹក

**៣. ការរៀបចំកុមារៈ** ឱ្យកុមារអង្គុយជារាងអក្សរ "U" និងឱ្យកុមារឈរជារង្វង់

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូឱ្យកុមាររាប់លេខតាមបណ្ណពី១ដល់១០ ទាំងអស់គ្នា
- គ្រូដាក់បណ្ណលេខពី១ដល់១០នៅលើតុមុខកុមារទាំងអស់ រួចហៅកុមារម្នាក់ ឱ្យមកលើកបណ្ណលេខនោះម្តងមួយៗបង្ហាញមិត្តភក្តិនិងប្រាប់លេខនោះ
- គ្រូប្រាប់កុមារបន្ថែមក្នុងបណ្ណលេខនីមួយៗ ក្នុងមួយបណ្ណមាន៤សន្លឹក (គ្រូលើកបង្ហាញទាល់តែគ្រប់លេខទាំងអស់)
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកុមារលេងទាំងអស់គ្នា ហើយកូននាំគ្នាឈរជារង្វង់ គ្រូនឹងឱ្យបណ្ណលេខកូនម្នាក់មួយសន្លឹកកាន់នៅដៃ
  - ពេលកូនបានបណ្ណលេខនៅដៃទាំងអស់គ្នាហើយ កូនលើកបង្ហាញមិត្តភក្តិម្នាក់ម្តងៗពីលេខក្នុងបណ្ណ នោះ ដើម្បីឱ្យមិត្តភក្តិយើងចំណាំ
  - ពេលគ្រូឱ្យសញ្ញាចាប់ផ្តើម កូនៗនាំគ្នាដើរជារង្វង់ ដើរផង ច្រៀងផង ពេលគ្រូឱ្យសញ្ញាបញ្ឈប់កូនទាំងអស់គ្នា រត់រកដៃគូដែលមានបណ្ណលេខដូចគ្នា ហើយឈរពីនាក់ៗ ឃ្លាតឆ្ងាយពីគ្នា
  - ពេលកូនចាប់ដៃគូបានហើយ កូនត្រូវសង្កេតមើលបណ្ណលេខរបស់ខ្លួនដូចគ្នាឬទេ ? ដើម្បីចាំគ្រូនាំផ្ទៀងផ្ទាត់
- គ្រូឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញពីអ្វីដែលគ្រូបានប្រាប់ (បើកុមារនិយាយមិនបានគ្រូត្រូវប្រាប់ម្តងទៀត)
- គ្រូរៀបកុមារឱ្យឈរជារង្វង់ ហើយគ្រូឱ្យកុមារពីរនាក់យកបណ្ណលេខចែកមិត្តភក្តិទាំងអស់គ្នា
- គ្រូនាំកុមារលេងទាំងអស់គ្នា គ្រូជាអ្នកឱ្យសញ្ញាចាប់ផ្តើម និងសញ្ញាបញ្ឈប់
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផល គឺឱ្យកុមារដែលចាប់ដៃគូគ្នានោះប្រាប់ពីបណ្ណលេខដូចគ្នាឬទេ? ហើយលេខអ្វី? បន្ទាប់មកឱ្យគូដទៃទៀតជាអ្នកវាយតម្លៃ (បើប្រាប់លេខខុសត្រូវជួយកែតម្រូវ) ។ គ្រូធ្វើរបៀបនេះទាល់តែគ្រប់កូនទាំងអស់ ។
- គ្រូនាំកុមារលេងរបៀបនេះបន្តបន្ទាប់ បន្តែប្តូរបណ្ណគ្នាទៅវិញទៅមក រហូតដល់ម៉ោង
- គ្រូឱ្យកុមារប្រមូលសម្ភារទុកជូនគ្រូវិញ និងឱ្យកុមារទៅអង្គុយនៅក្នុងក្រុមជំវិញទាំងអស់គ្នា
- **គ្រូសួរកុមារៈ**
  - កូនៗទាំងអស់គ្នាសប្បាយទេ?តើមុននេះកូនៗបានលេងល្បែងអ្វី?(កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - តើថ្ងៃនេះ កូនៗរៀនមុខវិជ្ជាអ្វី ? មេរៀនអ្វីដែរ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាបុរេគណិត មេរៀនល្បែង "រកដៃលេខពី១ដល់១០"
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយរបស់គ្រូឬទេ?បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹកចិត្តឱ្យចូលរួមបន្តទៀត)
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា ។

**ម៉ោងទី៦ (រយៈពេល ៣០នាទី)**

## មុខវិជ្ជាៈ សិក្សាសង្គម

✱ ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី១៩

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ ចិត្តចលភាព

### ចលនាមូលដ្ឋានៈ វារ (វារបត់បែនតាមខ្សែ វារដូចសត្វក្ដាម វាររាំងឧបសគ្គ)

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីរបៀបវារ វារបត់បែនតាមខ្សែ វារដូចសត្វក្ដាម វាររាំងឧបសគ្គ បានត្រឹមត្រូវ
- កុមារវារ វារបត់បែនតាមខ្សែរ វារដូចសត្វក្ដាម វាររាំងឧបសគ្គ បានត្រឹមត្រូវ
- កុមារមានភាពស្វាហាប់ រហ័សរហួន បម្រុងប្រយ័ត្ន អំណត់ ព្យាយាម និងសប្បាយរីករាយ

**២. សម្ភារបង្រៀនៈ** ខ្សែ

**៣. ការរៀបចំកុមារៈ** ចែកកុមារជាបីក្រុម ឱ្យកុមារឈរជាជួរ ករណីកុមារច្រើនអាចចែកជា៦ក្រុម ដោយ២ក្រុមធ្វើ១សកម្មភាព

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនាំកុមារធ្វើសកម្មភាពដើរ ដោយឱ្យកុមារធ្វើចលនាដើរដូចពួកងទ័ព ជុំំជើងមួយកន្លែង
- គ្រូបង្ហាញសម្ភារម្តងមួយៗឱ្យកុមារប្រាប់ឈ្មោះ
- គ្រូណែនាំកុមារពីរបៀបធ្វើចលនានីមួយៗ និងឱ្យកុមារ១ ឬ ២ នាក់និយាយឡើងវិញ (បើកុមារនិយាយមិនបានគ្រូប្រាប់ម្តងទៀត)
- គ្រូចែកកុមារជាបីក្រុម និង អនុវត្តតាមសកម្មភាពនីមួយៗៈ
  - ក្រុមទី១ៈ វារបត់បែនតាមខ្សែឱ្យដល់ទិសដៅដែលបានកំណត់
  - ក្រុមទី២ៈ វារដូចសត្វក្ដាមឱ្យដល់ទិសដៅដែលបានកំណត់
  - ក្រុមទី៣ៈ វាររាំងឧបសគ្គឱ្យដល់ទិសដៅដែលបានកំណត់
- បន្ទាប់ពីកុមារបានវារតាមរបៀបខាងលើរួច គ្រូឱ្យក្រុមនីមួយៗប្តូរសកម្មភាពវារតាមសញ្ញារបស់គ្រូ
- គ្រូដើរសម្របសម្រួលតាមក្រុមទាំង៣ ដោយធ្វើយ៉ាងណាឱ្យកុមារទាំងអស់បានវារគ្រប់សកម្មភាព
- កូនៗហត់ទេ? ដើម្បីឱ្យមានកម្លាំងកូនធ្វើដូចម្តេច? (កុមារឆ្លើយហិតផ្កា) ហើយផ្កាអីក្រអូបជាងគេ? គេ ដាំនៅឯណា? ដើមវាទាប ឬខ្ពស់ ? ដូននេះគ្រូនាំកូនទៅបេះផ្កាហិតដោយដកដង្ហើមវែងៗ (កូនៗយកដៃធ្វើសកម្មភាព បេះផ្កា យកមកដាក់ជិតច្រមុះរួចហិត ហើយដកដង្ហើមចូល ចេញឱ្យវែងៗ? កុមារឆ្លើយថាក្រអូប) គ្រូឱ្យកុមារហិតផ្កាឱ្យបានពីរ ឬបីដងដោយដកដង្ហើមវែងៗ ។
- គ្រូសួរកុមារៈ
  - តើមុននេះ កូនៗបានធ្វើចលនាអ្វីខ្លះ? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
  - គ្រូសួរទៅកុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអ្វី? (កុមារឆ្លើយទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូប្រាប់កុមារថា ថ្ងៃនេះយើងរៀនអំពីមុខវិជ្ជាចិត្តចលភាព មានចំណងជើងមេរៀនៈ ចលនាមូលដ្ឋាន វារ "**វារបត់ បែនតាមខ្សែ វារដូចសត្វក្ដាម វាររាំងឧបសគ្គ**
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដែលបានឆ្លើយ ទៅនឹងអ្វីដែលគ្រូបានប្រាប់ (តើមុននេះមានកូនៗណាឆ្លើយដូច ចម្លើយរបស់គ្រូឬទេ? បើមានកុមារណាឆ្លើយត្រូវ គ្រូលើកសរសើរ បើកុមារឆ្លើយមិនទាន់បានត្រឹមត្រូវគ្រូលើកទឹក ចិត្តឱ្យចូលរួមបន្តទៀត)
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូច ខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ ពេលរើសបានវត្ថុអ្វីមួយត្រូវសួររកម្ចាស់ឬប្រាប់គ្រូ ឬប្រាប់ឪពុកម្តាយ (ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី១៩ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

### ល្បែង៖ បន្ថែម និងបន្ថយចំនួនពី១ដល់១០

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីការបន្ថែមនិងបន្ថយចំនួនពី១ ដល់១០ បានត្រឹមត្រូវ
- កុមារកំណត់បានការបន្ថែមនិងបន្ថយចំនួនពី ១ ដល់១០ បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន សហការ ក្នុងការអនុវត្តការងារក្រុមបានត្រឹមត្រូវ ។

**២. សម្ភារបង្រៀន៖** មានគ្រាប់ក្រួស /គម្របដបទឹកសុទ្ធ

**៣. ការរៀបចំកុមារ៖** អង្គុយជារាងពាក់កណ្តាលរង្វង់ "ប"

**៤. ដំណើរការបង្រៀន៖**(អនុវត្តនៅក្នុងជំហានទី៣)

- គ្រូនាំកុមាររាប់ចំនួនពី១ ដល់១០ ដូចជា ម្រាមដៃ និងសម្ភារ ផ្សេងៗដែលមានក្នុងថ្នាក់
- ថ្ងៃនេះគ្រូនាំកូនរៀនមុខវិជ្ជាបុរេគណិត ចំណងជើងមេរៀន ល្បែង (បន្ថែមនិងបន្ថយចំនួនពី១ ដល់១០)
- គ្រូនាំកុមារអានចំណងជើងមេរៀន២ទៅ៣ដង ជាបុគ្គលជាក្រុមនិងទាំងអស់គ្នា
- ឱ្យកុមាររាប់គ្រាប់ក្រួសបន្ថែមម្តង១គ្រាប់ៗរហូតគ្រប់ចំនួន១០គ្រាប់
- គ្រូចាប់យកគ្រាប់ក្រួសចំនួន១ដាក់លើតុឱ្យកុមារសង្កេតហើយសួរកុមារថាតើគ្រាប់ក្រួសនៅទីនេះមាន ចំនួនប៉ុន្មាន? បន្ទាប់មកចាប់យកគ្រាប់ក្រួសចំនួន១ដាក់លើតុបន្ថែមទៀតរួចសួរកុមារថា៖តើគ្រាប់ក្រួស ទាំងអស់មានចំនួនប៉ុន្មានគ្រាប់?នាំកុមាររាប់គ្រាប់ក្រួស
- គ្រូចាប់យកគ្រាប់ក្រួសចំនួន២ដាក់លើតុឱ្យកុមារសង្កេតហើយសួរកុមារថាតើគ្រាប់ក្រួសនៅទីនេះមាន ចំនួនប៉ុន្មាន? បន្ទាប់មកចាប់យកគ្រាប់ក្រួសចំនួន១ដាក់លើតុបន្ថែមទៀតរួចសួរកុមារថា៖តើគ្រាប់ក្រួស ទាំងអស់មានចំនួនប៉ុន្មានគ្រាប់?នាំកុមាររាប់គ្រាប់ក្រួស
- គ្រូចាប់យកគ្រាប់ក្រួសចំនួន៣ដាក់លើតុឱ្យកុមារសង្កេតហើយសួរកុមារថាតើគ្រាប់ក្រួសនៅទីនេះមាន ចំនួនប៉ុន្មាន? បន្ទាប់មកចាប់យកគ្រាប់ក្រួសចំនួន១ដាក់លើតុបន្ថែមទៀតរួចសួរកុមារថា៖តើគ្រាប់ក្រួស ទាំងអស់មានចំនួនប៉ុន្មានគ្រាប់?នាំកុមាររាប់គ្រាប់ក្រួស
- គ្រូចាប់យកគ្រាប់ក្រួសចំនួន៤ដាក់លើតុឱ្យកុមារសង្កេតហើយសួរកុមារថាតើគ្រាប់ក្រួសនៅទីនេះមាន ចំនួនប៉ុន្មាន? បន្ទាប់មកចាប់យកគ្រាប់ក្រួសចំនួន១ដាក់លើតុបន្ថែមទៀតរួចសួរកុមារថា៖តើគ្រាប់ក្រួស ទាំងអស់មានចំនួនប៉ុន្មានគ្រាប់?នាំកុមាររាប់គ្រាប់ក្រួស

- គ្រូចាប់យកគ្រាប់ក្រួសចំនួន១០ដាក់លើតុឱ្យកុមារសង្កេតហើយសួរកុមារថាតើគ្រាប់ក្រួសនៅទីនេះមានចំនួនប៉ុន្មាន? បន្ទាប់មកចាប់យកគ្រាប់ក្រួសចំនួន១ដាក់លើតុបន្ថែមទៀតរួចសួរកុមារថាៈតើគ្រាប់ក្រួសទាំងអស់មានចំនួនប៉ុន្មានគ្រាប់?នាំកុមាររាប់គ្រាប់ក្រួស
- គ្រូចាប់យកគ្រាប់ក្រួសចំនួន១០ដាក់លើតុឱ្យកុមារសង្កេតហើយសួរកុមារថាតើគ្រាប់ក្រួសនៅទីនេះមានចំនួនប៉ុន្មាន? បន្ទាប់មកចាប់យកគ្រាប់ក្រួសចំនួន១ចេញដាក់លើតុរួចសួរកុមារថាៈតើគ្រាប់ក្រួសនៅសល់មានចំនួនប៉ុន្មានគ្រាប់?នាំកុមាររាប់គ្រាប់ក្រួស
- គ្រូចាប់យកគ្រាប់ក្រួសចំនួន៤ដាក់លើតុឱ្យកុមារសង្កេតហើយសួរកុមារថាតើគ្រាប់ក្រួសនៅទីនេះមានចំនួនប៉ុន្មាន? បន្ទាប់មកចាប់យកគ្រាប់ក្រួសចំនួន១ចេញដាក់លើតុរួចសួរកុមារថាៈតើគ្រាប់ក្រួសនៅសល់មានចំនួនប៉ុន្មានគ្រាប់?នាំកុមាររាប់គ្រាប់ក្រួស
- គ្រូចាប់យកគ្រាប់ក្រួសចំនួន៣ដាក់លើតុឱ្យកុមារសង្កេតហើយសួរកុមារថាតើគ្រាប់ក្រួសនៅទីនេះមានចំនួនប៉ុន្មាន? បន្ទាប់មកចាប់យកគ្រាប់ក្រួសចំនួន១ចេញដាក់លើតុរួចសួរកុមារថាៈតើគ្រាប់ក្រួសនៅសល់មានចំនួនប៉ុន្មានគ្រាប់?នាំកុមាររាប់គ្រាប់ក្រួស
- គ្រូចាប់យកគ្រាប់ក្រួសចំនួន២ដាក់លើតុឱ្យកុមារសង្កេតហើយសួរកុមារថាតើគ្រាប់ក្រួសនៅទីនេះមានចំនួនប៉ុន្មាន? បន្ទាប់មកចាប់យកគ្រាប់ក្រួសចំនួន១ចេញដាក់លើតុរួចសួរកុមារថាៈតើគ្រាប់ក្រួសនៅសល់មានចំនួនប៉ុន្មានគ្រាប់?នាំកុមាររាប់គ្រាប់ក្រួស
- គ្រូចាប់យកគ្រាប់ក្រួសចំនួន១ដាក់លើតុឱ្យកុមារសង្កេតហើយសួរកុមារថាតើគ្រាប់ក្រួសនៅទីនេះមានចំនួនប៉ុន្មាន? បន្ទាប់មកចាប់យកគ្រាប់ក្រួសចំនួន១ចេញដាក់លើតុរួចសួរកុមារថាៈតើគ្រាប់ក្រួសនៅសល់មានចំនួនប៉ុន្មានគ្រាប់?នាំកុមាររាប់គ្រាប់ក្រួស
- លេងរបៀបនេះសាចុះសាឡើងឱ្យបានច្រើនដង ។

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

## សកម្មភាពកសាងៈ ដេរតាមទម្រង់រូបផ្លែល្ពៅ

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីរបៀបដេរតាមទម្រង់រូបផ្លែល្ពៅ បានត្រឹមត្រូវ
- កុមារមានសមត្ថភាពក្នុងការដេរតាមទម្រង់រូបផ្លែល្ពៅ បានត្រឹមត្រូវ។
- បណ្តុះទម្លាប់កុមារឱ្យមានភាពក្លាយហាន រហ័សរហួន មានចិត្តស្រឡាញ់ និងចូលចិត្ត ។

**២. សម្ភារបង្រៀនៈ**

-គ្រូៈផ្ទាំងរូបភាពផ្លែល្ពៅដែលបានដេររួចចំនួនមួយផ្ទាំង ,ផ្ទាំងរូបភាពផ្លែល្ពៅដែលមិនទាន់ដេរចំនួនមួយផ្ទាំង ,អំបោះមួយដុំ ១

-កុមារៈផ្ទាំងរូបភាពផ្លែល្ពៅគ្រប់ចំនួនកុមារដែលមានដាក់ថ្ងៃខែឆ្នាំអនុវត្ត មុខវិជ្ជាចំណងជើងមេរៀននៅលើសន្លឹកិច្ចការ ,អំបោះមួយដុំ ១ គ្រប់ចំនួនក្រុមកុមារ( ១ក្រុម១ដុំ)

**៣. ការរៀបចំកុមារៈ** កុមារអង្គុយជារាងអក្សរអ៊ុយ "U" រង្វង់ជា៣ក្រុម

**៤. ដំណើរការបង្រៀនៈ**( អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបង្ហាញរូបផ្លែល្ពៅដែលបានដើររួចឱ្យកុមារប្រាប់ឈ្មោះនិងយករូបនោះបិទលើក្តារខៀនជាគំរូសម្រាប់កុមារសង្កេត
- គ្រូណែនាំពីរបៀបដើរតាមទម្រង់រូបផ្លែល្ពៅយឺតៗដើម្បីឱ្យកុមារងាយចាប់បាន
  - គ្រូឱ្យកូនដើរជាក្រុមតូចៗហើយក្រុមនីមួយៗ ត្រូវបានផ្ទាំងរូបភាពផ្លែល្ពៅមួយសន្លឹក«អំបោះមួយដុំ
  - ដំបូងកូននាំគ្នាយកផ្ទាំងរូបភាពផ្លែល្ពៅមួយផ្ទាំងដាក់នៅចំកណ្តាល និងអំបោះមួយដុំក៏ដាក់ចំកណ្តាលរង្វង់ក្បែរគ្នាដែរ
  - បន្ទាប់មកកូនណាម្នាក់ក្នុងក្រុមយកអំបោះមួយដុំនិងផ្ទាំងរូបផ្លែល្ពៅហើយយកទៅដើរតាមទម្រង់រូបផ្លែល្ពៅប៉ុន្តែមិនឱ្យដើរខុសថ្មេររូបផ្លែល្ពៅទេ គ្រូប្រាប់កុមារបណ្តើរធ្វើបង្ហាញបណ្តើរ ប៉ុន្តែការដើរតាមទម្រង់រូបផ្លែល្ពៅ មិនចាំបាច់ដើរពេញសាច់របស់វាទេគ្រាន់តែដើរតាមទម្រង់រូបផ្លែល្ពៅ
  - ពេលកូននាំគ្នាដើរលើទម្រង់រូបផ្លែល្ពៅតាមក្រុមនីមួយៗត្រូវចេះរង់ចាំវេនធ្វើម្នាក់ម្តងៗកុំដណ្តើមគ្នាប្រយ័ត្នដើរខុស
- គ្រូរៀបចំកុមារជាក្រុមតូចៗរួចឱ្យទៅអង្គុយជារង្វង់នៅទីកន្លែងដែលបានរៀបចំ។
- គ្រូឱ្យតំណាងក្រុមនីមួយៗមកយកសម្ភារដែលគ្រូត្រៀមទុកអនុវត្ត
- គ្រូឱ្យកុមារក្នុងក្រុមនីមួយៗចាប់ផ្តើមអនុវត្តទាំងអស់គ្នាទៅតាមការណែនាំ
- គ្រូដើរសម្របសម្រួលកុមារគ្រប់ក្រុមហើយជួយកែតម្រូវក្រុមណាដែលធ្វើមិនទាន់បាន
- គ្រូប្រាប់កុមារៈបើក្រុមកូនណាធ្វើរួចហើយកូនយកទៅបិទលើក្តារខៀនតាមកន្លែងដែលគ្រូកំណត់ឱ្យទៅតាមក្រុមនីមួយៗហើយពួកកូនត្រូវយកសម្ភារទៅទុកជូនគ្រូវិញនិងនាំគ្នាទៅអង្គុយនៅតាមក្រុមធំវិញ
- គ្រូនាំកុមារផ្ទៀងផ្ទាត់លទ្ធផលដោយឱ្យតំណាងក្រុមទៅឈរនៅជិតរូបដែលបានបិទនៅលើក្តារខៀន បន្ទាប់មកឱ្យកុមារក្រុមធំសង្កេតមើលរូបនោះ ដើម្បីវាយតម្លៃ( តើដើរតាមទម្រង់រូបផ្លែល្ពៅបានត្រឹមត្រូវឬទេ ?
- គ្រូនាំកុមារផ្ទៀងផ្ទាត់របៀបនេះរហូតគ្រប់ក្រុមទាំងអស់នៅពេលផ្ទៀងផ្ទាត់មានក្រុមណាធ្វើមិនបានល្អគ្រូមិនត្រូវស្តីបន្ទោសឡើយ ត្រូវចេះលើកទឹកចិត្តកុមារឱ្យខិតខំប្រឹងប្រែងបន្តទៀត
- គ្រូឱ្យតំណាងក្រុមនីមួយៗដករូបចេញពីក្តារខៀនជូនគ្រូរួចគ្រូដាក់ឈ្មោះក្រុមសម្រាប់ទុកដាក់តាំងស្នាដៃកុមារ
- គ្រូសួរកុមារៈថ្ងៃនេះយើងនាំគ្នារៀនមុខវិជ្ជាអ្វី ?អំពីអ្វី ?
- គ្រូប្រាប់កុមារៈថ្ងៃនេះយើងនាំគ្នារៀនមុខវិជ្ជា សិក្សាសង្គម អំពីសកម្មភាពកសាង«**ដើរតាមទម្រង់រូបផ្លែល្ពៅ**»
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងអ្វីដែលគ្រូបានប្រាប់ បើមានកុមារទាយត្រូវលើកសរសើរដោយប្រើពាក្យសម្តី
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀនជាក្រុមរួចទាំងអស់គ្នា។

ម៉ោងទី៨ (រយៈពេល ៣០នាទី)

# មុខវិជ្ជាៈ ភាសាខ្មែរ

## គំនូរៈ គូសតួអក្សរ ញ ដ ណ តាមស្នាមចុច

**១. វត្ថុបំណងៈ**

- កុមារប្រាប់បានពីរបៀបគូសតួអក្សរ ញ ដ ណ តាមស្នាមចុច បានត្រឹមត្រូវ
- កុមារ គូសតួអក្សរ ញ ដ ណ តាមស្នាមចុច បានត្រឹមត្រូវ
- កុមារមានអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួនក្នុងការអនុវត្តជាបុគ្គល ។

**២. សម្ភារបង្រៀនៈ**

- បណ្ណតួអក្សរ ញ ដ ណ មួយសន្លឹកជាគំរូ
- សន្លឹកក្រដាសមានសរសេរតួអក្សរ ញ ដ ណ ដែលមានស្នាមចុច ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ
- ខ្មៅដៃសម្រាប់គូសម្នាក់១
- ស៊ុតកាត់រួចជាស្រេច

**៣. ការរៀបចំកុមារៈ** អង្គុយគូសជាបុគ្គល

**៤. ដំណើរការបង្រៀនៈ** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញបណ្ណតួអក្សរ ញ ដ ណ  ឱ្យកុមារប្រាប់ ដោយសួរកុមារថាៈ តើបណ្ណនេះមានតួអក្សរអ្វីខ្លះ? រួចគ្រូបិទ បណ្ណតួអក្សរនោះលើក្ដារខៀន
- គ្រូបង្ហាញសន្លឹកក្រដាសមានសរសេរតួអក្សរ ញ ដ ណ ដែលមានស្នាមចុច ហើយបិទលើក្ដារខៀន ដើម្បីបង្ហាញកុមារ រួចណែនាំពីរបៀបសរសេរម្ដងមួយតួអក្សរៗ យឺតៗលើផ្ទាំងក្រដាសតួអក្សរដែលមានស្នាមចុចនោះ តាមទិសដៅនៃការសរសេរ ឱ្យកុមារសង្កេតនិងនិយាយបណ្ដើរចាប់ពីកន្លែងចាប់ផ្ដើម រហូតដល់ចប់ (ពេលសរសេរ គ្រូឈរយ៉ាងណាឱ្យកុមារបានមើលឃើញទាំងអស់គ្នា)
- គ្រូប្រាប់កុមារថា បន្តិចទៀតគ្រូនឹងក្រដាសមួយសន្លឹកដល់កូនៗទាំងអស់គ្នា(លើកបង្ហាញបណ្ដើរ)។ បន្ទាប់មកកូនចាប់យកខ្មៅដៃរបស់កូនមកគូសតួអក្សរ ញ ដ ណ តាមស្នាមចុច ដែលមាននៅលើក្រដាសកិច្ចការរបស់កូន។ កូនត្រូវសរសេរទៅតាមទិសដៅនៃការសរសេរឱ្យបានត្រឹមត្រូវ ដូចទៅនឹងការសរសេរបង្ហាញរបស់គ្រូអម្បាញ់មិញនេះ។
- គ្រូឱ្យកុមារទៅអង្គុយជាក្រុមតាមតុ ដែលបានរៀបចំរួច(បើករណីមិនមានតុ គ្រូឱ្យកុមារបង្វិលកៅអីដាក់ចំពីមុខ រួចអង្គុយគូសនៅលើកៅអីរៀងខ្លួន) រួចចែកសន្លឹកក្រដាសមានសរសេរតួអក្សរ ញ ដ ណ ដែលមានសល់ចន្លោះពីក្រោមសម្រាប់សរសេរចម្លងតាម ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ ដល់កុមារម្នាក់ៗ
- គ្រូឱ្យកុមារចាប់ផ្ដើមឱ្យកុមារគូសចម្លងតាមការណែនាំ រួចដើរពិនិត្យ និងជួយសម្របសម្រួលការសរសេររបស់កុមារម្នាក់ៗ
- គ្រូឱ្យកុមារយកសន្លឹកបណ្ណលេខដែលខ្លួនបានគូសចម្លង មកបិទលើក្ដារខៀន បន្ទាប់ពីគូសរួច
- គ្រូនាំកុមារផ្ទៀងផ្ទាត់ការសរសេររបស់កុមារម្ដងម្នាក់ៗ ដោយឱ្យកុមារកាន់សន្លឹកកិច្ចការរបស់ខ្លួនមកឈរ

នៅមុខមិត្តភក្តិ ម្តងមួយក្រុមៗ រួចលើកបង្ហាញមិត្តភក្តិ ហើយគ្រូនាំកុមារសង្កេតសន្លឹកកិច្ចការរបស់មិត្តភក្តិដែលលើកបង្ហាញៗ។ ពេលផ្ទៀងផ្ទាត់លទ្ធផលកុមារម្នាក់ៗ គ្រូត្រូវនាំណែនាំមិត្តភក្តិឱ្យចេះលើកសសើរ លើកទឹកចិត្តដល់កុមារដែលមិនទាន់ធ្វើបានល្អឱ្យប្រឹងប្រែងបន្ត មិនត្រូវប្រៀបធៀប ឬបន្ទុះបង្អាប់កុមារឡើយ

- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងជាក្រុម និងទាំងអស់គ្នាឡើងវិញ
- គ្រូប្រមូលសន្លឹកកិច្ចការរបស់កុមារទាំងអស់សម្រាប់ដាក់តាំងស្នាដៃកុមារក្នុងថ្នាក់

**ម៉ោងទី៦ (រយៈពេល ៣០នាទី)**

## មុខវិជ្ជាៈ សិក្សាសង្គម

* ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី២០

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

រំលឹក **ចលនាចរន្ត៖ ដើរ រត់ លោត វារ (ដើរវាងឧបសគ្គ រត់ទៅរកទី លោត រំលងខ្សែ វារទៅមុខដាក់វត្ថុលើខ្នង)**

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១៥ ម៉ោងទី១)

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូចខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ ពេលរើសបានវត្ថុអ្វីមួយត្រូវសួររកម្ចាស់ឬប្រាប់គ្រូ ឬប្រាប់ឪពុកម្ដាយ (ដំណើរការបង្រៀនអនុវត្តដូច ថ្ងៃទី១៦ ម៉ោងទី២)
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី២០ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ភាសាខ្មែរ

### គំនូរ៖ គូសចម្លងតាមគំរូតួអក្សរ ឆ ជ ឈ

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបគូសចម្លងតាមគំរូតួអក្សរ ឆ ជ ឈ បានត្រឹមត្រូវ
- កុមារ គូសចម្លងតាមគំរូតួអក្សរ ឆ ជ ឈ បានត្រឹមត្រូវ
- កុមារមានអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួនក្នុងការអនុវត្តជាបុគ្គល ។

**២. សម្ភារបង្រៀន៖**

- បណ្ណតួអក្សរ ឆ ជ ឈ មួយសន្លឹក ជាគំរូ
- សន្លឹកក្រដាសមានសរសេរតួអក្សរ ឆ ជ ឈ ដែលមានសល់ចន្លោះពីក្រោមសម្រាប់សរសេរចម្លងតាម ហើយមាន ថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ
- ខ្មៅដៃសម្រាប់គូសម្នាក់១
- ស្កុតកាត់រួចជាស្រេច

**៣. ការរៀបចំកុមារ៖** អង្គុយគូសជាបុគ្គល

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញបណ្ណតួអក្សរ ឆ ជ ឈ ឱ្យកុមារប្រាប់ ដោយសួរកុមារថា៖ តើបណ្ណនេះមានតួអក្សរអ្វីខ្លះ? រួច

គ្រូបិទបណ្ណតួអក្សរនោះលើក្តារខៀន

- គ្រូបង្ហាញសន្លឹកក្រដាសមានសរសេរតួអក្សរ ធ ជ ឈ ដែលមានសល់ចន្លោះពីក្រោមសម្រាប់សរសេរចម្លងតាម ហើយបិទលើក្តារខៀន ដើម្បីបង្ហាញកុមារ រួចណែនាំពីរបៀបសរសេរម្តងមួយតួអក្សរៗ យឺតៗលើផ្ទាំងក្រដាសតួអក្សរដែលមានស្នាមចុចនោះ តាមទិសដៅនៃការសរសេរ ឱ្យកុមារសង្កេតនិងនិយាយបណ្តើរចាប់ពីកន្លែងចាប់ផ្តើម រហូតដល់ចប់ (ពេលសរសេរ គ្រូឈរយ៉ាងណាឱ្យកុមារបានមើលឃើញទាំងអស់គ្នា)
- គ្រូប្រាប់កុមារថា បន្តិចទៀតគ្រូនឹងក្រដាសមួយសន្លឹកដល់កូនៗទាំងអស់គ្នា(លើកបង្ហាញបណ្តើរ)។ បន្ទាប់មកកូនចាប់យកខ្មៅដៃរបស់កូនមកគូសចម្លងតួអក្សរ ធ ជ ឈ នៅចន្លោះខាងក្រោម ដែលមាននៅលើក្រដាសកិច្ចការរបស់កូន។ កូនត្រូវសរសេរទៅតាមទិសដៅនៃការសរសេរឱ្យបានត្រឹមត្រូវ ដូចទៅនឹងការសរសេរបង្ហាញរបស់គ្រូអម្បាញ់មិញនេះ។
- គ្រូឱ្យកុមារទៅអង្គុយជាក្រុមតាមតុ ដែលបានរៀបចំរួច(បើករណីមិនមានតុ គ្រូឱ្យកុមារបង្វិលកៅអីដាក់ចំពីមុខ រួចអង្គុយគូសនៅលើកៅអីរៀងខ្លួន) រួចចែកសន្លឹកក្រដាសមានសរសេរតួអក្សរ ធ ជ ឈ ដែលមានសល់ចន្លោះពីក្រោមសម្រាប់សរសេរចម្លងតាម ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន និងឈ្មោះកុមារម្នាក់ៗរួចស្រេច នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ ដល់កុមារម្នាក់ៗ
- គ្រូឱ្យកុមារចាប់ផ្តើមឱ្យកុមារគូសចម្លងតាមការណែនាំ រួចដើរពិនិត្យ និងជួយសម្របសម្រួលការសរសេររបស់កុមារម្នាក់ៗ
- គ្រូឱ្យកុមារយកសន្លឹកបណ្ណលេខដែលខ្លួនបានគូសចម្លង មកបិទលើក្តារខៀន បន្ទាប់ពីគូសរួច
- គ្រូនាំកុមារផ្ទៀងផ្ទាត់ការសរសេររបស់កុមារម្តងម្នាក់ៗ ដោយឱ្យកុមារកាន់សន្លឹកកិច្ចការរបស់ខ្លួនមកឈរនៅមុខមិត្តភក្តិ ម្តងមួយក្រុមៗ រួចលើកបង្ហាញមិត្តភក្តិ ហើយគ្រូនាំកុមារសង្កេតសន្លឹកកិច្ចការរបស់មិត្តភក្តិដែលលើកបង្ហាញ។ ពេលផ្ទៀងផ្ទាត់លទ្ធផលកុមារម្នាក់ៗ គ្រូត្រូវនាំណែនាំមិត្តភក្តិឱ្យចេះលើកសរសើរលើកទឹកចិត្តដល់កុមារដែលមិនទាន់ធ្វើបានល្អឱ្យប្រឹងប្រែងបន្ត មិនត្រូវប្រៀបធៀប ឬបន្ទុះបង្អាប់កុមារឡើយ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងជាក្រុម និងទាំងអស់គ្នា
- គ្រូប្រមូលសន្លឹកកិច្ចការរបស់កុមារទាំងអស់សម្រាប់ដាក់តាំងស្នាដៃកុមារក្នុងថ្នាក់

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## ល្បែង៖ បិទមុខទាយសំឡេង

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបលេងល្បែងបិទមុខទាយសំឡេង បានត្រឹមត្រូវ
- កុមារលេងល្បែងបិទមុខទាយសំឡេង បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន និងមានភាពសប្បាយរីករាយ ។

**២.សម្ភារបង្រៀន៖** ក្រម៉ា ពែងដាក់ទឹក

**៣.ការរៀបចំកុមារ៖** - អង្គុយជារាងអក្សរអ៊ុយ"U" អង្គុយជាក្រុមតូច

**៤.ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំណួរ តើកូនៗធ្លាប់លេងល្បែងអ្វីខ្លះ? ដូចច្នេះកូនៗទាយមើលថាថ្ងៃនេះគ្រូបង្រៀនកូនពីមុខវិជ្ជាអ្វី? មេរៀនអ្វី? ឱ្យកុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ ។ ពេលកុមារប្រាប់រួច គ្រូត្រូវសរុបនូវអ្វីដែលពួកគេបានប្រាប់
- គ្រូប្រាប់កុមារៈ ថ្ងៃនេះគ្រូបង្រៀនមុខវិជ្ជាសិក្សាសង្គម អំពីល្បែងបិទមុខទាយសំឡេង
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងការនិយាយប្រាប់របស់គ្រូ ដោយសួរកុមារថា តើអម្បាញ់មិញមានកូនណាទាយត្រូវឬទេ? បើមានមិត្តភក្តិយើងទាយត្រូវដូចនេះកូនៗនាំគ្នាទះដៃសរសើរមិត្តភក្តិយើងទាំងអស់គ្នា។ ឯកូនដែលទាយមិនទាន់ត្រូវ កូនក៏ឆ្លាតដែរ ព្រោះកូនបានឆ្លើយនឹងសំណួរ តែថ្ងៃក្រោយកូនត្រូវគិតបន្ថែម ហើយចាំឆ្លើយសំណួរគ្រូទៀតណា !
- គ្រូនាំកុមារអានពីមុខវិជ្ជា និងចំណងជើងមេរៀន (ជាក្រុម និងទាំងអស់គ្នា)
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
  - គ្រូឱ្យកូនលេងទាំងអស់គ្នាជាមួយគ្រូ ហើយកូននាំគ្នាអង្គុយជារង្វង់
  - គ្រូឱ្យកូនណាម្នាក់ស្ម័គ្រចិត្ត ហើយមកអង្គុយកណ្តាលវង់រួចយកក្រម៉ាចងមុខឱ្យជិតមិនឱ្យមើលឃើញឡើយ
  - គ្រូយកពែងទឹកដាក់ពីមុខកូនដែលចងមុខអង្គុយកណ្តាលវង់ បន្ទាប់មកគ្រូឱ្យកូនណាម្នាក់ចេញពីកន្លែងអង្គុយដើរលបៗមិនឱ្យឮសម្រិបជើងទៅយកពែងទឹក ដែលនៅពីមុខកូនដែលចងមុខអង្គុយកណ្តាលវង់។ បើកូនណាទៅយកពែងទឹកនោះបានដោយមិនឱ្យកូនដែលចងមុខដឹងគឺជាអ្នកឈ្នះ ។ បើកូនណាទៅយកពែងទឹកបាន ប៉ុន្តែឱ្យកូនដែលចងមុខដឹងគឺជាអ្នកចាញ់ ត្រូវដកចេញក្រៅវង់ឱ្យទៅអង្គុយមួយកន្លែង ។ ពេលលេងចប់ អ្នកចាញ់ទាំងអស់ត្រូវធ្វើសកម្មភាពទៅតាមអ្វីដែលអ្នកឈ្នះឱ្យធ្វើ ។
  - ពេលលេងកូនត្រូវលេងម្តងម្នាក់កុំដណ្តើមគ្នា ត្រូវចេះអង្គុយរង់ចាំវេនដោយស្ងៀមស្ងាត់
- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្តងទៀត)
- មុននឹងនាំកុមារលេង គ្រូត្រូវប្រាប់កុមារឱ្យចងចាំពីរបៀបលេងឱ្យបានច្បាស់លាស់
- គ្រូនាំកុមារលេងទាំងអស់គ្នាដោយឱ្យកុមារទៅអង្គុយជារង្វង់នៅកន្លែង និងតាមអ្វីដែលគ្រូបានរៀបចំ
- គ្រូនាំកុមារលេងបន្តបន្ទាប់រហូតចប់ម៉ោង

- ពេលបញ្ចប់ការលេងរួចហើយគ្រូឱ្យកុមារទៅអង្គុយក្រុមធំវិញ ហើយអ្នកដែលចាញ់ទាំងអស់ត្រូវមកឈរពីមុខ រង់ចាំមិត្តភក្តិទាំងអស់ឱ្យធ្វើសកម្មភាពផ្សេងៗ ដូចជា ច្រៀង រាំ ដើរទា ដើរបង្ហាញម៉ូត ឬសកម្មភាពផ្សេងៗទៀត ធ្វើដំណើរគ្រាប់តាមពូកងទ័ព។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

# មុខវិជ្ជា៖ វិទ្យាសាស្ត្រ

## ល្បែង៖ប្រព័ន្ធគ្រួសារផ្លែឈើ

**១. វត្ថុបំណង៖**

- កុមាររៀបរាប់ពីប្រភេទផ្លែឈើ បានត្រឹមត្រូវ
- កុមារបង្ហាញឈ្មោះប្រភេទផ្លែឈើ បានត្រឹមត្រូវ
- កុមារអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួន សហការ ជួយគ្នាក្នុងការអនុវត្តការងារក្រុមបានត្រឹមត្រូវ ។

**២.សម្ភារបង្រៀន៖** គ្មាន

**៣.ការរៀបចំកុមារ៖** អង្គុយជារាងអក្សរអ៊ុយ"ប" អង្គុយជារង្វង់

**៤.ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំណួរ តើកូនៗធ្លាប់ស្គាល់ផ្លែឈើអ្វីខ្លះ? ដូចច្នេះកូនៗទាយមើលថាថ្ងៃនេះគ្រូបង្រៀនកូនពីមុខវិជ្ជាអ្វី? មេរៀនអ្វី? ឱ្យកុមារឆ្លើយតាមគំនិតរបស់ពួកគេម្នាក់ៗ ។ ពេលកុមារប្រាប់រួច គ្រូត្រូវសរុបនូវអ្វីដែលពួកគេបានប្រាប់
- គ្រូប្រាប់កុមារ៖ ថ្ងៃនេះគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ អំពីល្បែង«**ប្រព័ន្ធគ្រួសារផ្លែឈើ**»
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារទៅនឹងការនិយាយប្រាប់របស់គ្រូ ដោយសួរកុមារថា តើអម្បាញ់មិញមានកូនណាទាយត្រូវឬទេ? បើមានមិត្តភក្តិយើងទាយត្រូវដូចនេះកូនៗនាំគ្នាទះដៃសរសើរមិត្តភក្តិយើងទាំងអស់គ្នា។ ឯកូនដែលទាយមិនទាន់ត្រូវ កូនក៏ឆ្លាតដែរ ព្រោះកូនបានឆ្លើយនឹងសំណួរ តែថ្ងៃក្រោយកូនត្រូវគិតបន្ថែម ហើយចាំឆ្លើសំណួរគ្រូទៀតណា !
- គ្រូនាំកុមារអានពីមុខវិជ្ជា និងចំណងជើងមេរៀន (ជាក្រុម និងទាំងអស់គ្នា)
- **គ្រូណែនាំពីរបៀប និងលក្ខខណ្ឌនៃការលេង**
    - គ្រូឱ្យកូនលេងជាមួយគ្រូម្តងមួយក្រុម ឯកូនដែលគ្រូមិនទាន់ឱ្យលេង កូនត្រូវជួយស្តាប់មិត្តភក្តិយើងនិយាយ
    - ក្រុមដែលគ្រូនាំលេងមុនគេ ត្រូវមកឈរជារង្វង់នៅកណ្តាលថ្នាក់ ឯកូនដែលគ្រូមិនទាន់ឱ្យលេង ត្រូវអង្គុយនៅកៅអីជុំវិញក្រុមលេង ប្រហែលកន្លះម៉ែត្រ ដើម្បីសង្កេតអ្នកធ្វើខុស
    - ដំបូងកូនត្រូវរកអ្នកចាប់ផ្តើមនិយាយមុនគេ (កូនៗត្រូវឯកភាពយល់ព្រមកំណត់ឱ្យមិត្តភក្តិណាម្នាក់ជាអ្នកចាប់ផ្តើមមុនគេ )
    - ពេលគ្រូឱ្យសញ្ញាចាប់ផ្តើម កូនដែលត្រូវចាប់ផ្តើមមុនគេ ត្រូវនិយាយឈ្មោះផ្លែឈើមួយមុខ រួចហើយអ្នកនៅឈរស្តាំដៃត្រូវប្រាប់ឈ្មោះផ្លែឈើមួយមុខទៀតផ្សេងពីគ្នា រួចបន្តទៅអ្នកបន្ទាប់ទៀត បើកូនណាប្រាប់ឈ្មោះផ្លែឈើដូចអ្នកមុនដែរនោះ កូនជាអ្នកចាញ់ ហើយកូនត្រូវដកចេញពីក្រុមទៅឈរនៅមួយកន្លែង ហើយកូនដែលនៅក្នុងក្រុម ត្រូវធ្វើរបៀបនេះបន្តរហូតដល់អ្នកចុងក្រោយ ។
    - ពេលក្រុមកូនបានបញ្ចប់ការលេងហើយ ត្រូវប្តូរឱ្យក្រុមកូនផ្សេងទៀតមកលេងម្តង ហើយក្រុមកូនទៅអង្គុយវិញ ដើម្បីជួយសង្កេតអ្នកធ្វើខុស
- គ្រូឱ្យកុមារ១ ឬ២នាក់ និយាយឡើងវិញតាមគ្រូប្រាប់ (បើកុមារនិយាយមិនបានទេ គ្រូត្រូវនិយាយប្រាប់ម្តងទៀត)

- គ្រូត្រូវរៀបចំកុមារមួយក្រុម ឱ្យឈរជារង្វង់នៅកណ្ដាលថ្នាក់ ឯកុមារក្រុមផ្សេងទៀតឱ្យអង្គុយជុំវិញក្រុមដែលត្រូវលេង ចាំជួយសង្កេត និងស្ដាប់អ្នកធ្វើខុស
- មុននឹងនាំកុមារលេង គ្រូត្រូវប្រាប់កុមារក្នុងក្រុមឱ្យរកឈ្មោះផ្លែឈើម្នាក់ៗ ឱ្យបានមួយមុខ
- គ្រូនាំកុមារលេងម្ដងមួយក្រុមៗ ហើយគ្រូជាអ្នកឱ្យសញ្ញាចាប់ផ្ដើម។ ចំពោះការជ្រើសរើសកុមារចាប់ផ្ដើមនិយាយមុនគេនោះ គ្រូអាចជាអ្នកកំណត់ ឬឱ្យកុមារក្នុងក្រុមជាអ្នកសម្រេច ឬឱ្យកុមារប៉ាវរកអ្នកឈ្នះ (បើកុមារមានចំនួនតិច) ក៏បាន
- គ្រូនាំកុមារលេងដោយប្ដូរក្រុមលេង គឺក្រុមលេងរួចឱ្យទៅអង្គុយវិញ ឯក្រុមអង្គុយឱ្យមកលេងម្ដងវិញ ។ ក្នុងមួយក្រុមគ្រូនាំកុមារលេងតែមួយសារ
- គ្រូនាំកុមារលេងបន្តបន្ទាប់រហូតអស់ក្រុម រហូតចប់ម៉ោង
- ពេលបញ្ចប់ការលេងគ្រប់ក្រុម គ្រូឱ្យកុមារទៅអង្គុយក្រុមធំវិញ ហើយអ្នកដែលចាញ់ទាំងអស់ត្រូវមកឈរពីមុខ រង់ចាំមិត្តភក្ដិទាំងអស់ឱ្យធ្វើសកម្មភាពផ្សេងៗ ដូចជាច្រៀង រាំ ដើរទា ដើរបង្ហាញម៉ូត ឬសកម្មភាពផ្សេងៗទៀត ។

### ម៉ោងទី៦ (រយៈពេល ៣០នាទី)

## មុខវិជ្ជាៈ សិក្សាសង្គម

∗ ល្បែងសេរី រំលឹកមេរៀនប្រចាំថ្ងៃ និងអនាម័យរៀបចំខ្លួនទៅផ្ទះ (ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១ ម៉ោងទី៦)

# ថ្ងៃទី២១

ម៉ោងទី១ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ ចិត្តចលភាព

## រំលឹក ល្បែងចលនា៖ បង់សំណាញ់

(ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១១ ម៉ោងទី១)

ម៉ោងទី ២ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖សិក្សាសង្គម

## សកម្មភាពប្រចាំថ្ងៃ

* ពិនិត្យវត្តមាន និងអវត្តមាន បង្ហាញកាលបរិច្ឆេទ និងចម្រៀង "ជម្រាបសួរ" (ដំណើរការបង្រៀនអនុវត្តដូចខែទី៣ ថ្ងៃទី១ ម៉ោងទី២)
* ទម្លាប់ល្អ៖ ត្រូវចូលគេងឱ្យបានទៀងទាត់ពេលវេលា
  - គ្រូសួរកុមារ៖
    - ដើម្បីឱ្យកូនមានសុខភាពល្អ កូនត្រូវធ្វើដូចម្តេចខ្លះ?
    - ក្រៅពីញ៉ាំផ្លែឈើ បន្លែ សាច់ តើកូនត្រូវធ្វើអ្វីទៀត?
    - ក្រៅពីកូនហាត់ប្រាណតើកូនត្រូវធ្វើអ្វីទៀត?
  - ក្នុងមួយថ្ងៃកូនគេងប៉ុន្មានដង? គេងនៅពេលណាខ្លះ?
  - គ្រូប្រាប់កុមារបន្ថែម ៖ ពេលកូនគេងគ្រប់គ្រាន់ និងទៀងទាត់ពេលវេលា គឺជួយមួយផ្នែកឱ្យកូនមានសុខភាពល្អ កូនត្រូវគេងមួយថ្ងៃពីរដង គឺនៅពេលកូនញ៉ាំបាយថ្ងៃត្រង់ហើយ កូនត្រូវនាំគ្នាគេងមួយដង នៅពេលយប់ គេងមួយដងទៀត។ ពេលញ៉ាំបាយថ្ងៃត្រង់ហើយកូនត្រូវនាំគ្នាគេង រួចទើបងើបឡើងងូតទឹកអោយស្អាតទើបកូនលេង ពេលយប់កូនត្រូវគេងពីម៉ោង 9:00 ទៅបើគេងយប់ជ្រៅពេកក៏មិនល្អដែរ។
* គ្រូប្រាប់មេរៀនដែលត្រូវរៀនមួយព្រឹក ដែលទាក់ទងនឹងថ្ងៃទី២១ រួចឱ្យកុមារថាតាមជាក្រុម និងទាំងអស់គ្នា

ម៉ោងទី៣ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ បុរេគណិត

### គំនូរ៖ គូរចម្លងតាមគំរូលេខ៧ និងលេខ៨

**១. វត្ថុបំណង៖**

- កុមារប្រាប់បានពីរបៀបគូរចម្លងតាមគំរូលេខ៧ និងលេខ៨ បានត្រឹមត្រូវ
- កុមារគូរចម្លងតាមគំរូគូសលេខ៧ និងលេខ៨ បានត្រឹមត្រូវ
- កុមារមានអំណត់ ព្យាយាម ឈ្លាសវៃ រហ័សរហួនក្នុងការអនុវត្តជាបុគ្គល ។

**២. សម្ភារបង្រៀន៖**

- បណ្ណលេខ ៧ និង ៨ មួយសន្លឹកជាគំរូ
- សន្លឹកក្រដាសមានសរសេរលេខ ៧ និង៨ ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន (គ្រប់ចំនួនកុមារ)

- ខ្មៅដៃសម្រាប់គូស(គ្រប់ចំនួនកុមារ)
- ស្កុតកាត់រួចជាស្រេច

**៣. ការរៀបចំកុមារ៖** អង្គុយជាអក្សរអ៊ុយ"U" និងជាបុគ្គល

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូប្រាប់មុខវិជ្ជា និងចំណងជើងមេរៀនរួចនាំកុមារអានជាក្រុម និងទាំងអស់គ្នា
- គ្រូបង្ហាញបណ្ណលេខ ៧ និង៨ ឱ្យកុមារប្រាប់ ដោយសួរកុមារថា៖ តើបណ្ណនេះមានលេខអ្វីខ្លះ? រួចគ្រូបិទបណ្ណលេខនោះលើក្តារខៀន
- គ្រូបង្ហាញសន្លឹកក្រដាសមានសរសេរលេខ ៧ និង៨ ហើយបិទលើក្តារខៀន ដើម្បីបង្ហាញកុមារ រួចណែនាំពីរបៀបគូសសម្លង យឺតៗលើផ្ទាំងក្រដាសលេខ តាមទិសដៅនៃការសរសេរ ឱ្យកុមារសង្កេតនិងនិយាយបណ្តើរចាប់ពីកន្លែងចាប់ផ្តើម រហូតដល់ចប់ (ពេលគូសចម្លងគ្រូឈរយ៉ាងណាឱ្យកុមារបានមើលឃើញទាំងអស់គ្នា)
- គ្រូប្រាប់កុមារថា បន្តិចទៀតគ្រូនឹងចែកក្រដាសមួយសន្លឹកដល់កូនៗទាំងអស់គ្នា(និយាយបណ្តើរ លើកបង្ហាញបណ្តើរ)។ បន្ទាប់មកកូនចាប់យកខ្មៅដៃរបស់កូនមកគូសលេខ ៧ និង៨ ដែលមាននៅលើក្រដាសកិច្ចការរបស់កូន។ កូនត្រូវគូសទៅតាមទិសដៅឱ្យបានត្រឹមត្រូវ ដូចទៅនឹងការគូសបង្ហាញរបស់គ្រូអម្បាញ់មិញនេះ។
- គ្រូឱ្យកុមារទៅអង្គុយជាក្រុមតាមតុ ដែលបានរៀបចំរួច(បើករណីមិនមានតុ គ្រូឱ្យកុមារបង្វិលកៅអីដាក់ចំពីមុខ រួចអង្គុយគូសនៅលើកៅអីរៀងខ្លួន) រួចចែកសន្លឹកក្រដាសមានសរសេរលេខ៧ និង៨ ហើយមានថ្ងៃខែឆ្នាំ មុខវិជ្ជា ចំណងជើងមេរៀន
- គ្រូឱ្យកុមារចាប់ផ្តើមឱ្យកុមារគូសចម្លងតាមការណែនាំ រួចដើរពិនិត្យ និងជួយសម្របសម្រួលការសរសេររបស់កុមារម្នាក់ៗ និងសរសេរឈ្មោះកុមារម្នាក់ៗ នៅលើក្បាលសន្លឹកកិច្ចការនីមួយៗ ដល់កុមារម្នាក់ៗ
- គ្រូឱ្យកុមារយកសន្លឹកបណ្ណលេខដែលខ្លួនបានគូសចម្លង មកបិទលើក្តារខៀន
- គ្រូនាំកុមារផ្ទៀងផ្ទាត់ការសរសេររបស់កុមារម្តងម្នាក់ៗ ដោយឱ្យកុមារកាន់សន្លឹកកិច្ចការរបស់ខ្លួនមកឈរនៅមុខមិត្តភក្តិ ម្តងមួយក្រុមៗ រួចលើកបង្ហាញមិត្តភក្តិ ហើយគ្រូនាំកុមារសង្កេតសន្លឹកកិច្ចការរបស់មិត្តភក្តិដែលលើកបង្ហាញ។ ពេលផ្ទៀងផ្ទាត់លទ្ធផលកុមារម្នាក់ៗ គ្រូត្រូវណែនាំមិត្តភក្តិឱ្យចេះលើកសសើរ លើកទឹកចិត្តដល់កុមារដែលមិនទាន់ធ្វើបានល្អឱ្យប្រឹងប្រែងបន្ត មិនត្រូវប្រៀបធៀប ឬបន្ទុះបង្អាប់កុមារឡើយ
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងជាក្រុម និងទាំងអស់គ្នាឡើងវិញ
- គ្រូប្រមូលសន្លឹកកិច្ចការរបស់កុមារទាំងអស់សម្រាប់ដាក់តាំងស្នាដៃកុមារក្នុងថ្នាក់

ម៉ោងទី៤ (រយៈពេល ៣០នាទី)

## មុខវិជ្ជា៖ សិក្សាសង្គម

## អំណាន៖ បូណាជាកូនល្អ

**១. វត្ថុបំណង៖**

- កុមារប្រាប់ពីសកម្មភាពតួអង្គតាមដំណើររឿង បានត្រឹមត្រូវ
- កុមារនិទានរឿងនិងវិភាគតួអង្គនៅក្នុងរឿងបានត្រឹមត្រូវ

- កុមារយកចិត្តទុកដាក់ យកគំរូតាមតួអង្គល្អ សហការជួយគ្នា និទានរឿងឱ្យមិត្តភក្តិស្តាប់ ។

**២. សម្ភារបង្រៀន៖** គ្មាន

**៣. ការរៀបចំកុមារ៖** កុមារអង្គុយជាបណ្តុំ ជាជួរ

**៤. ដំណើរការបង្រៀន៖** (អនុវត្តនៅក្នុងជំហានទី៣)

- គ្រូបំផុសសំនួរ៖ តើកូនធ្លាប់ជួយឪពុកម្តាយធ្វើការងារផ្ទះដែរឬទេ? ការងារអ្វីខ្លះ? តើថ្ងៃនេះយើងរៀនមុខវិជ្ជាអ្វី? មេរៀនអំពីអ្វី? គ្រូសរុបចម្លើយរបស់កុមារ
- គ្រូប្រាប់កុមារ ថ្ងៃនេះយើងរៀនមុខវិជ្ជា សិក្សាសង្គម ចំណងជើងរឿងនិទាន «បូណាជាកូនល្អ»
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់កុមារដោយសួរកុមារថា៖មុននេះមានកូនណាឆ្លើយដូចចម្លើយអ្នកគ្រូដែរឬទេ?ដូចច្នេះកូនទះដៃសរសើរមិត្តភក្តិយើងដែលដែលបានទាយត្រូវទាំងអស់គ្នា
- គ្រូនាំកុមារអានមុខវិជ្ជា និងចំណងជើងមេរៀន ជាក្រុម និងទាំងអស់គ្នា
- ប្រាប់ឈ្មោះអ្នកនិពន្ធ៖ រឿងនិទាននេះនិពន្ធដោយអ៊ំៗជាគ្រូនៅក្រសួងអប់រំ ឱ្យកុមារថាតាម
- គ្រូនិទានរឿងផ្ទាល់មាត់ឱ្យកុមារស្តាប់ ដោយលើកដាក់សំឡេងតាមតួអង្គនៃសាច់រឿង
- គ្រូនាំកុមារអានពាក្យពិបាក ជាក្រុម និងទាំងអស់គ្នា៖
  - រង្វាន់៖ របស់ដែលថែម របស់លើកទឹកចិត្ត
  - ប្រុងប្រយ័ត្ន៖ ការខំប្រឹងថែទាំ ការប្រុងដោយមិនធ្វេសប្រហែស
  - ក្លាហាន៖ មោះមុត អង់អាច
  - សប្បុរសធម៌៖ ការធ្វើអំពើល្អ អ្នកប្រព្រឹត្តល្អ
- គ្រូសួរកុមារ៖ក្រោយពីស្តាប់រឿងនេះចប់ តើក្នុងរឿងមានតួអង្គប៉ុន្មាន? តួអង្គណាខ្លះ? តើនៅផ្ទះបូណាបានជួយ ធ្វើការងារអ្វីខ្លះ? ហេតុអ្វីបានជាម្តាយបូណាទិញស្បែកជើងថ្មីឱ្យ?តើនៅសាលារៀនបូណាជាក្មេងដូចម្តេច?នៅតាមផ្លូវតើបូណាបានជួយមិត្តភក្តិណាខ្លះ? (កុមារឆ្លើយតបសំណួរគ្រូទៅតាមគំនិតរបស់គេម្នាក់ៗ)
- គ្រូសង្ខេបរឿងឱ្យកុមារស្តាប់ឡើងវិញម្តងទៀត
- បន្ទាប់មកគ្រូឱ្យកុមារនិយាយសង្ខេបរឿងឡើងវិញឱ្យមិត្តភក្តិស្តាប់ (កុមារនិយាយពីអ្វីដែលគេបានចងចាំ
- គ្រូឱ្យកុមារប្រាប់ឈ្មោះអ្នកនិពន្ធ ៖ រឿងនេះ អ៊ំៗនៅក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកនិពន្ធ ។

អត្ថបទរឿង «បូណាជាកុមារល្អ»

បូណាជាកុមារខិតខំរៀនសូត្រណាស់ អ្នកគ្រូតែងសរសើរបូណារាល់ថ្ងៃ នៅផ្ទះបូណាបានជួយធ្វើការឪពុកនិងម្តាយសព្វគ្រប់ ដូចជាដងទឹក ជញ្ជូនអុស ស្រោចបន្លែ និងជួយបោសផ្ទះសំបែង។ ដោយឃើញកូនឧស្សាហ៍ធ្វើការខិតខំរៀនសូត្រ ម្តាយបូណាក៏ទិញស្បែកជើងមួយគូឱ្យជារង្វាន់ដល់បូណា។ ស្បែកជើងនោះស្អាតណាស់ បាតវាធ្វើអំពីកៅស៊ូ បូណាពាក់ស្បែកជើងថ្មីទៅរៀនរាល់ថ្ងៃដោយប្រុងប្រយ័ត្នខ្លាចដាច់ខ្សែ ឬប្រឡាក់ភក់។ថ្ងៃមួយមេឃភ្លៀងខ្លាំងនៅតាមផ្លូវមានទឹកដក់ជាថ្លុកធំៗ បូណាត្រូវលោតឆ្លងថ្លុកនោះតែភ្លាត់ស្នៀត បូណាផុងជើងចូកក្នុងភក់នាំឱ្យប្រឡាក់ស្បែកជើងថ្មី និងខោ អាវ បូណាចង់យំ។ ពេលនោះមានមិត្តភក្តិរួមថ្នាក់ជាច្រើនដើរមកដល់ បូណាឃើញក៏រាដៃឃាត់មិនទាន់ឱ្យមិត្តឆ្លងថ្លុក ហើយក៏ស្ទុះទៅយកក្តារមួយបន្ទះវែងមកដាក់ធ្វើជាស្ពានឱ្យមិត្តទាំងអស់គ្នាឆ្លងដោយស្រួល គ្មានប្រឡាក់ជើងនិងខោអាវឡើយ មិត្តទាំងអស់បានចាប់ដៃ ទះស្មា អរគុណ និងសរសើរដល់សេចក្តីក្លាហាន និងទឹកចិត្តសប្បុរសធម៌ របស់បូណា។

ម៉ោងទី៥ (រយៈពេល ៣០នាទី)

**មុខវិជ្ជា៖ ភាសាខ្មែរ**

រំលឹក **គំនូរ ៖ គូរចម្លងតាមគំរូតួអក្សរ ឆ ជ ឈ**

( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី២០ ម៉ោងទី៣ )

ម៉ោងទី៦ (រយៈពេល ៣០នាទី)

**មុខវិជ្ជា៖ ចិត្តចលភាព**

រំលឹក **ល្បែង៖ ចាប់វត្ថុប្រណាំងគ្នាដោយប្រើម្រាមដៃ២**

( ដំណើរការបង្រៀនអនុវត្តដូចថ្ងៃទី១៦ ម៉ោងទី៦ )

# ការគាំទ្រនិងដំណើរការនៃការបង្កើត និងការគ្រប់គ្រងថ្នាក់មត្តេយ្យសិក្សាសហគមន៍ របស់អង្គការគាំពារកុមារខ្មែរ (CYK) នៅប្រទេសកម្ពុជា

# មត្តេយ្យសិក្សាសហគមន៍របស់អង្គការគាំពារកុមារខ្មែរ(CYK)

I. **សាវតារគម្រោងៈ**

អង្គការគាំពារកុមារភៀសខ្លួន(CYR) ជាអង្គការមិនមែនស្ម័គ្រចិត្តសម្រាប់សាសនា និងមិនមែនរដ្ឋាភិបាល ហើយត្រូវបង្កើតឡើងនៅទីក្រុងតូក្យូក្នុងឆ្នាំ១៩៨០ ដើម្បីឆ្លើយតបនឹងកង្វះខាតដ៏ធ្ងន់ធ្ងររបស់កុមារភៀសខ្លួនកម្ពុជា ដែលរស់នៅប្រទេសថៃ។ អង្គការគាំពារកុមារភៀសខ្លួនបានធ្វើការគាំទ្រមណ្ឌលសម្រាប់សាលាមត្តេយ្យជាច្រើន"ភូមិដ្ឋាននៃក្តីសង្ឃឹម" នៅក្នុងជំរុំភៀសខ្លួនរហូតដល់ពេលដែលជនភៀសខ្លួនទាំងនោះធ្វើមាតុភូមិនិវត្តន៍មកកាន់មាតុប្រទេសវិញ បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។

អង្គការគាំពារកុមារខ្មែរ(CYK)ដែលជាផ្នែកមួយរបស់អង្គការកុមារភៀសខ្លួនក៏បានចាប់ផ្តើមដំណើរការរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៩១។ អង្គការគាំពារកុមារខ្មែរ(CYK)បានគាំទ្រដល់កម្មវិធីថែទាំនិងអប់រំកុមារតូចនៅតាមសហគមន៍ ដើម្បីជាការលើកស្ទួយសុខមាលភាពរបស់កុមារនិង ភាពម្ចាស់ការដោយខ្លួនឯងរបស់មាតាបិតាកុមារទាំងនោះ តាមរយៈសកម្មភាពបង្កើតប្រាក់ចំណូល។ ជាងនេះទៅទៀត អង្គការគាំពារកុមារខ្មែរបានប្រមើលមើលពិភពលោកដ៏ល្អ ដែលមនុស្សរស់នៅ ជាពិសេសគឺសម្រាប់កុមារតូចៗនិងស្ត្រីអាច រីកចំរើនលូតលាស់ ធំធាត់ និងអភិវឌ្ឍខ្លួនឯងបាន ដោយគ្មាន ភាពអត់ឃ្លាន គ្មានភាពក្រីក្រ នេះហើយជាទីដែលមនុស្សរស់នៅ ក្នុងភាពសុខដុមរមនា ដែលអាចកសាងសង្គមកម្ពុជា ជាសង្គមពុទ្ធិនិងវិបុលភាព។

II. **ទស្សនវិស័យៈ**

អង្គការគាំពារកុមារខ្មែរបានប្រមើលពិភពលោកដ៏ល្អ ដែលមនុស្សរស់នៅ ជាពិសេសគឺសម្រាប់កុមារតូចៗនិងស្ត្រី អាចរីកចំរើនលូតលាស់ ធំធាត់ និងអភិវឌ្ឍខ្លួនឯងបានដោយគ្មានភាពអត់ឃ្លាន គ្មានភាពក្រីក្រនេះហើយជាទីដែល មនុស្សរស់នៅក្នុង ភាពសុខដុមរមនា ដើម្បីអាចកសាងសង្គមកម្ពុជាជាសង្គមពុទ្ធិនិងវិបុលភាព។

III. **បេសកកម្មៈ**

អង្គការគាំពារកុមារមានគោលបំណងលើកកម្ពស់ការអភិវឌ្ឍន៍ រាងកាយនិងផ្លូវចិត្តរបស់កុមារដើម្បីក្លាយជាធនធានមនុស្សប្រកបដោយសក្តានុពលនិងផលិតភាពសម្រាប់ប្រទេសជាតិនាពេលអនាគត។

IV. **គុណតម្លៃៈ**

"កុមារ ជាអនាគតរបស់យើង" ភាពរីករាយរបស់កុមារនៅថ្ងៃនេះអាចនាំមកនូវសន្តិភាពនៅថ្ងៃស្អែក។

V. **គម្រោងមត្តេយ្យសិក្សាសហគមន៍ៈ**

ចាប់ពីឆ្នាំ២០១១ អង្គការគាំពារកុមារខ្មែរ(CYK) បានពង្រីកគម្រោងអប់រំកុមារតូចរបស់ខ្លួន ដោយបើកឱ្យដំណើរការមត្តេយ្យសិក្សាសហគមន៍ ក្រោមកិច្ចសហប្រតិបត្តិការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល ខេត្តតាកែវ និងខេត្តកំពង់ឆ្នាំង និងមន្ត្រីជំនាញនៃការិយាល័យអប់រំស្រុក អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងសហគមន៍ក្នុងខេត្តទាំងនោះ។

**១. គោលបំណងៈ**

ដើម្បីចូលរួមក្នុងការលើកកម្ពស់អនុវិស័យអប់រំកុមារតូចនៅប្រទេសកម្ពុជា អង្គការគាំពារកុមារខ្មែរបានៈ

ក. បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូច ប្រកបដោយគុណភាព និងទាន់ពេលវេលាសម្រាប់កុមារដែលគ្រប់អាយុចូលរៀននៅមត្តេយ្យសិក្សា ជាពិសេសកុមារអាយុ៥ឆ្នាំ(នៅតំបន់ដែលជួបការលំបាក) ដោយផ្តល់ឱកាសឱ្យគាត់មានការអភិវឌ្ឍសមត្ថភាពពេញលេញនិងគ្រប់ផ្នែកគឺគាត់ចេះរួម

រស់នៅជាមួយគ្នា ដោយសុខដុមរម្យនា។ មានទំនាក់ទំនងល្អជាមួយមិត្តភក្តិ ជាមួយមនុស្សធំនៅជុំវិញខ្លួនដោយមានទំនុកចិត្ត។ ការប្រើពាក្យសម្តី និងអត្តចរឹតបានសមរម្យ មានភាពក្លាហាន ម្ចាស់ការទទួលខុសត្រូវរាល់ការងារដែលពួកគេបានធ្វើ ចេះរង់ចាំវេន សហការគ្នាក្នុងការធ្វើអ្វីមួយ។ មានភាពស្មោះត្រង់ ចេះចែករំលែកសម្ភារៈលេង នំចំណីឲ្យគ្នាទៅវិញទៅមក។ មានគំនិតច្នៃប្រឌិតក្នុងការលេងក្នុងការធ្វើអ្វីមួយឲ្យបានសម្រេច។ ចេះរាប់លេខ អានអក្សរ ស្គាល់រាង ពណ៌ ប្រើម្រាមដៃក្នុងការគូររូបផ្សេងៗ បត់រូប សូនរូបជាដើម។ កុមារមានសុខភាពល្អតាមរយៈការធ្វើចលនាពេលហាត់ប្រាណរាល់ព្រឹកនិងការញ៉ាំអាហារសម្រន់ដែលមានគុណភាព

ខ. ចូលរួមចំណែកបង្កើន អត្រាចូលរៀនរបស់កុមារអាយុ៦ឆ្នាំនៅសាលាបឋមសិក្សា និងបន្តគ្រប់ភូមិសិក្សា ប្រកបដោយគុណភាព មិនត្រួតថ្នាក់និងមិនបោះបង់ការសិក្សា។

គ. លើកកម្ពស់ការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន សហគមន៍ សប្បុរសជននានាដើម្បីធានាថាមត្តេយ្យសិក្សសហគមន៍ដែលគាំទ្រដោយអង្គការគាំពារកុមារខ្មែរ បំពេញបានយ៉ាងពេញលេញនូវស្តង់ដារ និងនិរន្តរភាពនៃមត្តេយ្យសិក្សាសហគមន៍របស់ក្រសួងអប់រំ យុវជន និងកីឡា។

ឃ. កសាងសមត្ថភាពសម្រាប់សមាជិកគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ស្តីពីការងារមត្តេយ្យសិក្សាសហគមន៍រួមទាំងការកៀរគរធនធាន ដើម្បីឱ្យពួកគាត់អាចកៀរគរធនធានក្នុងមូលដ្ឋានសម្រាប់គាំទ្រដល់មត្តេយ្យសិក្សាសហគមន៍។

ង. លើកកម្ពស់ការចិញ្ចឹមបីបាច់កូនដោយវិជ្ជមាន (កម្មវិធីអប់រំមាតាបិតា) ក្នុងចំណោមឪពុកម្តាយ និងអាណាព្យាបាលកុមារ។ តាមរយៈកម្មវិធីនេះឪពុកម្តាយនិងអាណាព្យាបាលកុមារទទួលស្គាល់ការអប់រំនិងការថែទាំកូន គឺជាកាតព្វកិច្ចរបស់ពួកគាត់ និងយល់ពីសារៈសំខាន់នៃការសិក្សារបស់កូននៅមត្តេយ្យសិក្សាសហគមន៍។ កែប្រែអត្តចរឹតពីមិនសូវយកចិត្តទុកដាក់ជាមួយកូន មកជាការយកចិត្តទុកដាក់ជាមួយកូនរាល់ពេល ដោយផ្តល់អ្វីៗជាតម្រូវការត្រឹមត្រូវរបស់កូន។ យល់ពីវិធីសាស្ត្រនៃការថែទាំនិងចិញ្ចឹមកូនឱ្យបានល្អ។ បង្កើនទំនាក់ទំនងល្អជាមួយគ្រូ ជាមួយសហគមន៍ ក្នុងការជួយបំពេញចំណេះដឹងឱ្យកូន។

ច. ជួយគាំទ្រឪពុកម្តាយ និងអាណាព្យាបាលកុមារ ដើម្បីរកចំណូលបន្ថែម សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ និងរួមចំណែកបង់វិភាគទានដល់មត្តេយ្យសិក្សាសហគមន៍ សម្រាប់ការអប់រំកូនពួកគាត់។

**២. លក្ខខណ្ឌតម្រូវៈ**

- មានតម្រូវការថ្នាក់មត្តេយ្យសិក្សាសហគមន៍ខ្លាំង ដោយសារមិនទាន់មានសេវាមត្តេយ្យនៅក្បែរ ហើយមានកុមារដែលគ្រប់អាយុចូលមត្តេយ្យសិក្សាមានចំនួនច្រើន។
- មានទីតាំងសម្រាប់ប្រើប្រាស់ជាថ្នាក់មត្តេយ្យ ដូចជាថ្នាក់ទំនេរក្នុងសាលាបឋមសិក្សា បន្ទប់ប្រជុំក្នុងភូមិសាលាបុណ្យ ឬដីទំនេរនៅក្នុងសហគមន៍សម្រាប់សាងសង់។
- មានគ្រូស្ម័គ្រចិត្តក្នុងសហគមន៍សម្រាប់មត្តេយ្យសិក្សាសហគមន៍។
- ក្រុមប្រឹក្សាឃុំដឹកនាំរចនាសម្ព័ន្ធប្រតិបត្តិការ ដោយបង្កើតគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សា សហគមន៍ ជួបប្រជុំជាមួយអ្នកភូមិ និងអាជ្ញាធរមូលដ្ឋាន ផ្សព្វផ្សាយពីគោលបំណងនៃការបង្កើត និងគ្រប់គ្រងដោយខ្លួនឯងនូវថ្នាក់មត្តេយ្យសិក្សាសហគមន៍ ដោយមានការគាំទ្រពីឪពុកម្តាយ។
- ក្រុមប្រឹក្សាឃុំត្រូវគ្រោងថវិកាសម្រាប់ប្រាក់ឧត្ថម្ភគ្រូក្នុងអំឡុងពេលដែលអង្គការគាំទ្រ និងគាំទ្រផ្នែក

ហិរញ្ញវត្ថុ ដូចជាប្រាក់ឧត្តម្ភគ្រូ លើការងារបង្រៀន/រៀន ការផលិតសម្ភារៈ ការបំប៉នសមត្ថភាពគ្រូ និងការអភិវឌ្ឍន៍ថ្នាក់រៀន ក្រោយពេលវេលាកំណត់នៃជំនួយដែលមានរយៈពេល៣ឆ្នាំ។ លើសពីនេះ ការចំណាយលើការគ្រប់គ្រងផ្សេងទៀតនិងអាហារសម្រន់(ប្រសិនបើចាំបាច់)សម្រាប់កុមារនឹងត្រូវត្រៀមដោយគណៈកម្មការគ្រប់គ្រងនិងឪពុកម្តាយ។

- ថ្នាក់មត្តេយ្យសហគមន៍ត្រូវក្លាយជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ ហើយគ្រប់គ្រងដោយគណៈកម្មការគ្រប់គ្រងនិងក្រុមប្រឹក្សាឃុំ។ ឪពុកម្តាយនឹងចូលរួមចំណែកតូចមួយដោយចូលរួមបង់វិភាគទានប្រចាំខែក្នុងអំឡុងពេលដែលអង្គការគាំទ្ររយៈពេល៣ឆ្នាំ និងបន្តបង់វិភាគទានដើម្បីបំពេញតម្រូវការសម្ភារៈនៅមត្តេយ្យសិក្សាសហគមន៍ ចាប់ពីឆ្នាំទី៤តទៅ។

## ៣. ការរៀបចំបង្កើតនិងដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍៖

- ជួសជុលបន្ទប់ចាស់ៗនិងបង្គន់អនាម័យ ដោយមានលាបថ្នាំថ្មី ក្រាលការ៉ូ និងសាងសង់បង្គន់អនាម័យប្រសិនបើមិនទាន់មាន និងសាងសង់កន្លែងលាងដៃដែលជាការចូលរួមបដិភាគរបស់គណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍លើថ្លៃដាង។
- ករណីសាងសង់ថ្នាក់រៀនថ្មីនិងបង្គន់អនាម័យ ( ត្រូវអនុវត្តតាមស្តង់ដារអប្បបរមារបស់ក្រសួងអប់រំ យុវជន និងកីឡាដែលថ្នាក់មានទំហំ៦ម×៦ម) ប៉ុន្តែសហគមន៍អាចពង្រីកទំហំបន្ថែមបាន ហើយការសាងសង់កន្លែងលាងដៃដែលជាការចូលរួមបដិភាគរបស់គណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍លើថ្លៃដាង។ ថ្នាក់រៀនសង់ដោយដាក់សរសរលេចចេញក្រៅដើម្បីងាយស្រួលតុបតែង និងត្រូវមានបង្អួច៧ហើយបង្អួចនីមួយៗត្រូវមានចម្រឹងនិងទ្វារបិទ-បើក មានក្រាលការ៉ូខាងក្នុង និងមានសាបជុំវិញប្រវែងយ៉ាងតិច១ម៉ែត្រ។ បង្គន់អនាម័យត្រូវមានអាងស្តុកទឹក ចានបង្គន់ មានក្រាលការ៉ូខាងក្នុងយ៉ាងហោចណាស់ត្រឹមមាត់អាងស្តុកទឹក និងមានតទឹកចូលក្នុងអាង។
- ផ្តល់ជាកញ្ចប់សម្ភារៈបរិក្ខាដូចជាតុនិងកៅអីសម្រាប់កុមារនិងគ្រូ ទូដាក់ឯកសារគ្រូ ទូរដាក់សម្ភារៈល្បែង ទូរដាក់ស្បែកជើង សម្ភារៈបម្រើឱ្យការងារបង្រៀននិងរៀន សម្ភារៈអនាម័យ សៀវភៅរឿង សៀវភៅវិទ្យាសាស្ត្ររូបភាព សៀវភៅកំណាព្យ សៀវភៅចម្រៀង និងសម្ភារៈល្បែងសិក្សាមួយចំនួន
- ផ្តល់ល្បែងក្រៅថ្នាក់ចំនួន១កំប្លេ (ក្តាររំអីលនិងប៉ាក់បើកធ្វើពីឈើ)។
- ផ្តល់អាហារសម្រន់ដល់កុមារ(នំប្រចាំថ្ងៃ ពងទាឬពងមាន់ស្ងោរ និងទឹកសណ្តែក ចំនួន២ដងក្នុង១ខែ)
- បណ្តុះបណ្តាល និងបំប៉នសមត្ថភាពគ្រូមត្តេយ្យសិក្សាសហគមន៍តាមស្តង់ដា។
- កសាងសមត្ថភាពដោយបើកវគ្គបំប៉នគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ និងប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តការងារប្រចាំឆ្នាំរបស់គណៈកម្មការ និងលើកផែនការអនុវត្តបន្ត។
- រៀបចំកម្មវិធីទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍សម្រាប់គ្រូមត្តេយ្យសិក្សាសហគមន៍និងគណៈ កម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍។
- រៀបចំកម្មវិធីពិសេសសម្រាប់កុមារ(ទិវាកុមារអន្តរជាតិ១មិថុនា និងកម្មវិធីបញ្ជូនកុមារគ្រប់អាយុ៦ឆ្នាំទៅរៀននៅសាលាបឋមសិក្សា)។
- ចុះពិនិត្យតាមដានការងារគ្រូមត្តេយ្យសិក្សាសហគមន៍ប្រចាំខែ ដោយទីប្រឹក្សាគម្រោងអប់រំកុមារតូចរបស់អង្គការ មន្ត្រីជំនាញថ្នាក់មន្ទីរនិងថ្នាក់ស្រុក និងគ.ក.ន.កឃុំ។
- ចុះពិនិត្យតាមដាននិងវាយតម្លៃរៀងរាល់៣ខែម្តងនៅឆ្នាំបន្ទាប់ ក្រោយពីបានផ្ទេរការទទួលខុសត្រូវលើ

ដំណើរការនិងការគ្រប់គ្រងមត្តេយ្យជូនក្រុមប្រឹក្សាឃុំ និងគណៈកម្មការគ្រប់គ្រង។

- លើកកម្ពស់ការចិញ្ចឹមបីបាច់កូនដោយវិជ្ជមានតាមយៈកម្មវិធីអប់រំមាតាបិតា និងប្រជុំជាមួយមាតាបិតា/គណៈកម្មការគ្រប់គ្រង ដើម្បីឆ្លុះបញ្ចាំងពីវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយ ឬសំណូមពរទាក់ទងនឹងមត្តេយ្យសិក្សាសហគមន៍។

## VI. ដំណើរការនៃការបង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍៖

### ១. មុនពេលដំណើរការថ្នាក់៖

នៅពេលអង្គការគាំពារកុមារខ្មែរ(CYK)បានកំណត់យកខេត្តដែលត្រូវសហការក្នុងការគាំទ្រ មត្តេយ្យសិក្សាសហគមន៍ហើយនោះ នាយិកាអង្គការ បានទៅជួបជាមួយថ្នាក់ដឹកនាំមន្ទីរអប់រំយុវជន និងកីឡាខេត្ត និងអ្នកទទួលបន្ទុកការងារអប់រំកុមារតូចថ្នាក់មន្ទីរ ដើម្បីបង្ហាញពីគោលបំណងនៃគម្រោងរបស់អង្គការដែលត្រូវអនុវត្តនៅប្រទេសកម្ពុជា និងសិក្សាថាតើអាចទទួលយកបាននិងសហការធ្វើការងារជាមួយគ្នាបានដែរឬទេ? បើសិនជាថ្នាក់មន្ទីរអេ.យ.កខេត្តព្រមព្រៀងហើយនោះក៏ត្រូវកំណត់ជ្រើសរើសស្រុកគោលដៅសម្រាប់អនុវត្ត រួចផ្តល់ព័ត៌មានទៅឱ្យមន្ត្រីជំនាញអប់រំកុមារតូចថ្នាក់ស្រុកគោលដៅទាំងអស់ ដើម្បីផ្តល់ព័ត៌មានបន្តទៅដល់សហគមន៍។ ពេលឯកភាពគ្នាហើយក៏បានធ្វើកិច្ចព្រមព្រៀងរវាងមន្ទីរអេ.យ.កខេត្ត ជាមួយអង្គការគាំពារកុមារខ្មែរ(CYK)។

បន្ទាប់មកសហគមន៍នៅតាមស្រុកគោលដៅនីមួយៗ ធ្វើសំណើរមិនទាន់ជាផ្លូវការមកអង្គការគាំពារកុមារខ្មែរ(CYK)តាមរយៈ ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងថ្នាក់ដឹកនាំមន្ទីរអេ.យ.កខេត្ត ដោយភ្ជាប់ជាមួយនូវស្ថិតិកុមារអាយុពី៣ឆ្នាំដល់ក្រោម៦ឆ្នាំក្នុងភូមិគោលដៅដែលចង់បង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍។ ថ្នាក់ដឹកនាំមន្ទីរអេ.យ.កខេត្ត ពេលបានសំណើតាមស្រុកគោលដៅហើយនោះ ក៏សរុបផ្ញើមកនាយិកាអង្គការគាំពារកុមារខ្មែរ(CYK) ដើម្បីស្នើសុំទៅជួយសិក្សាទីតាំងទាំងនោះ ដែលត្រូវផ្តល់អគារថ្មី ឬជួសជុលអគារចាស់។

នាយិកាអង្គការគាំពារកុមារខ្មែរ(CYK) ពេលបានទទួលសំណើរបស់សហគមន៍គ្រប់អស់ហើយក៏បានពិនិត្យមើលសំណើទាំងនោះ ដើម្បីវិភាគរកទីកន្លែងជាអាទិភាពដែលត្រូវចុះទៅសិក្សាទីតាំង។ ពេលចុះសិក្សាទីតាំងមានការចូលរួមពីមន្ត្រីជំនាញអប់រំកុមារតូចថ្នាក់មន្ទីរនិងថ្នាក់ស្រុក ដោយជួបជាមួយគណៈកម្មការដែលសហគមន៍បានរៀបចំទុកមុន និងមេឃុំជាដើម ដើម្បីសួរព័ត៌មានមួយចំនួនដែលទាក់ទងនិងស្ថិតិកុមារ ស្ថានភាពប្រជាជន ការចូលរួមរបស់សហគមន៍និងមាតាបិតាកុមារ ការជ្រើសរើសគ្រូ ពិនិត្យមើលទីកន្លែងដែលត្រូវសាងសង់អគារថ្មីឬជួសជុលអគារចាស់ និងពន្យល់លម្អិតអំពីគម្រោងរបស់អង្គការ ជាពិសេសប្លង់អគារដែលត្រូវសាងសង់ថ្នាក់មត្តេយ្យសិក្សាសហគមន៍។ បន្ទាប់មកគណៈកម្មការត្រូវធ្វើសំណើផ្លូវការដោយមានភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចជា លិខិតស្នើសុំ តារាងប៉ាន់ស្មានតម្លៃ លិខិតបង្គាប់ការ លិខិតផ្ទេរទីតាំងសម្រាប់ប្រើប្រាស់ជាថ្នាក់មត្តេយ្យ ស្ថិតិកុមារពី០ដល់៥ឆ្នាំក្នុងភូមិចំណុះជាដើម។ល។ ពេលសិក្សាទីតាំងចប់សព្វគ្រប់និងមានសំណើផ្លូវការពីគណៈកម្មការតាមរយៈការិយាល័យអ.យ.កស្រុកនិងមន្ទីរអេ.យ.កខេត្ត ហើយ នាយិកាអង្គការនិងក្រុមការងារគម្រោងអប់រំកុមារតូចពិភាក្សាគ្នានិងវិភាគម្តងទៀត ដើម្បីកំណត់កន្លែងជាអាទិភាពចុងក្រោយ។ រួចដាក់ស្នើសុំទៅទីស្នាក់ការកណ្តាលប្រចាំនៅទីក្រុងតូក្យូប្រទេសជប៉ុន (អង្គការគាំពារកុមារកៀសខ្លួន(CYR)) ដោយភ្ជាប់ជាមួយនូវរបាយការណ៍សិក្សាទីតាំង រូបភាព និងសំណើ។

ក្រោយពីបានឯកភាពគ្នារវាងអង្គការគាំពារកុមារខ្មែរ និងទីស្នាក់ការកណ្តាលលើការជ្រើសរើសទីតាំងសម្រាប់អនុវត្តគម្រោងមត្តេយ្យសិក្សាសហគមន៍ ក្រុមការងារគម្រោងអប់រំកុមារតូចរបស់អង្គការចុះជួបជា

មួយគណៈកម្មការនិងជាងសំណង់ម្ដងទៀត ដោយមានការចូលរួមរបស់មន្ត្រីជំនាញថ្នាក់មន្ទីរនិងថ្នាក់ស្រុក ដើម្បី ពិភាក្សានិងបញ្ជាក់អំពីទំហំបន្ទប់ អ្នកទទួលខុសត្រូវតាមដានការសាងសង់ឬជួសជុល ការងារជ្រើសរើសគ្រូបង្រៀន ការចូលរួមវិភាគទានរបស់មាតាបិតាកុមារ ការបង្កើតគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ជាដើម។ល។ ករណីឯកភាពគ្នា ត្រូវធ្វើកិច្ចសន្យាស្ដីពីការងារគ្រប់គ្រងនិងដំណើរការមត្តេយ្យសិក្សាសហគមន៍ និងចុះហត្ថលេខារវាងគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ជាមួយអង្គការគាំពារកុមារខ្មែរ(CYK)។ បន្ទាប់មកក៏បានជួបជាមួយជាងសំណង់ ដើម្បីពិភាក្សានិងបញ្ជាក់អំពីប្លង់នៃការសាងសង់ឬជួសជុល ចរចារតម្លៃនៃការងារសំណង់ និងដំណាក់កាលនៃការបង់ប្រាក់ដោយឱ្យជាងមានជម្រើសគឺៈ

**ជម្រើសទី១ៈ** បង់ប្រាក់លើកទី១ចំនួន៥០%ពេលចុះហត្ថលេខាលើកិច្ចសន្យា លើកទី២ចំនួន៣០%ពេលការងារបាន៥០%និងលើកចុងក្រោយចំនួន២០% ពេលការងារចប់សព្វគ្រប់ដោយមានការយល់ព្រមទទួលស្គាល់ ដោយគណៈកម្មការ។

**ជម្រើសទី២ៈ** បង់ប្រាក់លើកទី១ចំនួន៧០%ពេលចុះហត្ថលេខាលើកិច្ចសន្យា និងលើកចុងក្រោយចំនួន៣០%ពេលការងារចប់សព្វគ្រប់ដោយមានការយល់ព្រមទទួលស្គាល់ដោយគណៈកម្មការ។

បន្ទាប់ពីសម្រេចឯកភាពគ្នា កិច្ចសន្យារវាងអង្គការគាំពារកុមារខ្មែរ(CYK)និងជាងម៉ៅការសំណង់ត្រូវបានចុះហត្ថលេខា ហើយថវិកាលើកទី១ ត្រូវបានបង់ជូនជាងម៉ៅការសំណង់។ ហើយគណៈកម្មការជាអ្នកចុះអង្កេត ពិនិត្យតាមដានការសាងសង់ឬជួសជុលនិងថតរូប និងរាយការណ៍សកម្មភាពជាងផ្ញើមកអង្គការគាំពារកុមារខ្មែរ(CYK)ជាព័ត៌មាន។

ក្នុងអំឡុងពេលសាងសង់ឬជួសជុល ទីប្រឹក្សារបស់អង្គការក៏ចាប់ផ្ដើមបណ្ដុះបណ្ដាលគ្រូដំបូងមានរយៈពេល២០ថ្ងៃនៅការិយាល័យរបស់អង្គការនៅទីក្រុងភ្នំពេញ។ ក្នុងអំឡុងពេលបណ្ដុះបណ្ដាលដំបូងនេះ នាយិកាអង្គការតែងតែផ្ដល់ឱកាសដល់គ្រូមត្តេយ្យសិក្សាសហគមន៍ក្រៅគម្រោងដែលស្ម័គ្រចិត្ត ហើយឃុំសង្កាត់បានជ្រើសរើសឱ្យបង្រៀន ប៉ុន្តែមិនមានលទ្ធភាពក្នុងការបណ្ដុះបណ្ដាល បានចូលរួមទៅតាមសំណើរបស់មន្ត្រីជំនាញអប់រំកុមារតូចថ្នាក់ស្រុក។ ចំពោះគ្រូមត្តេយ្យសិក្សាសហគមន៍ក្រៅគម្រោងដែលបានចូលរួមវគ្គបណ្ដុះបណ្ដាលនោះ នាយិកាអង្គការនិងប្រធានរដ្ឋបាលបានជួយឧត្ថម្ភលើឯកសារ ការផលិតសម្ភារៈសម្រាប់បង្រៀន/រៀន និងតុបតែងថ្នាក់ និងកន្លែងស្នាក់នៅដោយប្រើប្រាស់ថវិកាផ្ទាល់ខ្លួន និងផ្ដល់កញ្ចប់សម្ភារៈល្បែងសិក្សាសម្រាប់ថ្នាក់ផងដែរ។ ឯខ្លឹមសារដែលបានបណ្ដុះបណ្ដាល គឺផ្ដោតលើមេរៀនមួយចំនួនដែលជាចំណេះទូទៅទាក់ទងនឹងគ្រូនិងកុមារ និង មេរៀនមួយចំនួនទាក់ទងនឹងជំនាញមត្តេយ្យសិក្សារួមមានៈ តួនាទី និងភារកិច្ចរបស់គ្រូមត្តេយ្យសិក្សាសហគមន៍ របៀបធ្វើផែនការអភិវឌ្ឍន៍ថ្នាក់មត្តេយ្យសិក្សាសហគមន៍ប្រចាំឆ្នាំ-ខែ ការរៀបចំតុបតែងថ្នាក់រៀនតាមស្តង់ដា ការរៀបចំសៀវភៅ បញ្ជីផ្សេងៗ ការរៀបចំក្រូណូនិងសឺមីទុកដាក់ឯកសារតាមប្រភេទ ការផលិតនិងប្រើប្រាស់សម្ភារឧបទេសតាមកម្មវិធីសិក្សាប្រចាំខែ ការប្រើប្រាស់កម្មវិធីសិក្សាប្រចាំថ្ងៃ-ខែ វិធីសាស្ត្រនៃការបង្រៀនគ្រប់មុខវិជ្ជា របៀបបំពេញខ្លឹមសារក្នុងទម្រង់តារាងផ្សេងៗ និងរបៀបធ្វើតេស្តសម្រាប់កុមារអាយុ៥ឆ្នាំ។ ហើយគ្រូៗក៏បាន
ផលិតសម្ភារៈបង្រៀន/រៀនសម្រាប់រយៈពេល១០ខែ និងសម្ភារៈសម្រាប់ តុបតែងថ្នាក់ផងដែរ។

ក្រោយការងារសាងសង់ឬជួសជុលថ្នាក់ បង្គន់អនាម័យ និងកន្លែងលាងដៃ ត្រូវបានបញ្ចប់ជាស្ថាពរ ហើយវគ្គបំបណ្ដុះបណ្ដាលគ្រូក៏ត្រូវបានបញ្ចប់ ក្រុមការងារគម្រោងអប់រំកុមារតូចរបស់អង្គការគាំពារកុមារខ្មែរបាន

សហការជាមួយសមាជិកគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ និងមន្ត្រីការិយាល័យអប់រំស្រុក និងគ្រូប្រចាំថ្នាក់ អញ្ជើញគ្រូមត្តេយ្យសិក្សារដ្ឋនិងមត្តេយ្យសហគមន៍ដែលនៅក្បែរៗ មកជួយរៀបចំតុបតែងថ្នាក់បំពាក់សម្ភារបង្រៀន/រៀន និងសម្ភារៈបរិក្ខា រួចចាប់ផ្តើមចុះឈ្មោះកុមារ និងការបើកដំណើរការមត្តេយ្យសិក្សាសហគមន៍ទាំងនោះជាផ្លូវការ។

**២. ពេលកំពុងដំណើរការថ្នាក់៖**

ដោយមានការឯកភាពពីថ្នាក់ដឹកនាំមន្ទីរអេ.យ.កខេត្ត មន្ត្រីជំនាញថ្នាក់ស្រុក គណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍និងមាតាបិតាផង និងដើម្បីឱ្យមាតាបិតាកុមារយល់ថា មត្តេយ្យសិក្សាសហគមន៍គឺជារបស់សហគមន៍ផង អង្គការគាំពារកុមារខ្មែរ(CYK)លើកទឹកចិត្តពួកគាត់ឱ្យចូលរួមបង់វិភាគទានចំនួន ២០០០រៀលពេលចុះឈ្មោះ(តែម្តងគត់) និងបង់ប្រចាំខែ១នាក់៤០០០រៀល ដើម្បីសន្សំទុករយៈពេល៣ឆ្នាំ។ បន្ទាប់ពីអង្គការបញ្ចប់គម្រោងគណៈកម្មការអាចយកប្រាក់សន្សំនេះទៅដំណើរការអភិវឌ្ឍន៍ថ្នាក់មត្តេយ្យសិក្សាសហគមន៍បន្ត។ បន្ទាប់មកគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ បានផ្សព្វផ្សាយដល់មាតាបិតាកុមារពីការយកប្រាក់វិភាគទាន ដោយបញ្ជាក់ច្បាស់ពីមូលហេតុ និងការប្រើប្រាស់ប្រាក់វិភាគទាន។ ការយកប្រាក់វិភាគទាន គឺមានចែងនៅក្នុងពាក្យសុំចុះឈ្មោះចូលរៀន ដូច្នេះពេលមាតាបិតាកុមារមកចុះឈ្មោះឱ្យកូន ពួកគាត់ត្រូវអានពាក្យនេះសិន ហើយគ្រូក៏ពន្យល់បន្ថែមពីការប្រាក់វិភាគទាន។ បើករណីមានមាតាបិតាកុមារមួយចំនួនមិនចេះអក្សរទេនោះ គ្រូត្រូវអានឲ្យពួកគាត់ស្តាប់ បើពួកគាត់ព្រមព្រៀងហើយ គឺត្រូវចុះហត្ថលេខាជាភស្តុតាងនៃការយល់ព្រម។ សម្រាប់មាតាបិតាដែលមិនមានលទ្ធភាពបង់ប្រាក់វិភាគទាននេះ អង្គការមានការងារដេរ បាល់និងតុក្កតាក្រណាត់ជូនប្រចាំខែ ដើម្បីរកប្រាក់ចំណូលបន្ថែមផង និងដើម្បីអាចចូលរួមវិភាគទានសម្រាប់ កូនគាត់ជារៀងរាល់ខែផង។

**២.១. ការចុះពិនិត្យតាមដាន៖**

បន្ទាប់ពីថ្នាក់មត្តេយ្យសិក្សាសហគមន៍ចាប់ផ្តើមដំណើរបង្រៀននិងរៀនបានមួយខែ ក្រុមការងារគម្រោងអប់រំកុមារតូចរបស់អង្គការគាំពារកុមារខ្មែរ(CYK) មន្ត្រីជំនាញអប់រំកុមារតូចថ្នាក់មន្ទីរនិងថ្នាក់ស្រុក សមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារ (គ.ក.នក) ដែលជាតំណាងគណៈកម្មការគ្រប់គ្រង មត្តេយ្យសិក្សាសហគមន៍ បានចុះពិនិត្យតាមដានការអនុវត្តការងាររបស់គ្រូរៀងរាល់ខែ នៅគ្រប់មត្តេយ្យសិក្សាសហគមន៍ក្នុងគម្រោង។ ការចុះពិនិត្យតាមដានគឺផ្តោតលើសូចនាករចំនួន៣៣ដែលជាសូចនាករវាយតម្លៃគ្រូមត្តេយ្យសិក្សាសហគមន៍ចូលស្តង់ដា។ ការចុះពិនិត្យតាមដានខែដំបូងគឺផ្តោតលើការរៀបចំថ្នាក់រៀនតាមស្តង់ដា ការរៀបចំសៀវភៅ និងបញ្ជីផ្សេងការរៀបចំក្រូណូនិងសីមីទុកដាក់ឯកសារតាមប្រភេទ និងការគ្រប់គ្រងកុមារ។ ខែបន្តបន្ទាប់ ចុះពិនិត្យតាមដានលើការអនុវត្តសូចនាករដែលគ្រូត្រូវអនុវត្តឱ្យបានពេញលេញគ្រប់ចំនួន ដើម្បីបំពេញស្តង់ដារហូតដល់អង្គការគាំពារកុមារខ្មែរ(CYK)ត្រូវបានបញ្ចប់គម្រោង។ ចំពោះមន្ត្រីជំនាញអប់រំកុមារតូចថ្នាក់ស្រុក គណៈកម្មការគ្រប់គ្រងមត្តេយ្យក៏បានអនុវត្តសូចនាករមួយចំនួនដែលជាការងាររបស់ពួកគាត់ ដើម្បីបំពេញពិន្ទុឱ្យគ្រូផងដែរ។ រាល់ការចុះពិនិត្យតាមដានម្តងៗពេលបញ្ចប់ការសង្កេតក្រុមការងារតែងតែបានប្រជុំជាមួយគ្រូដើម្បីបង្ហាញពីលទ្ធផលនៃការអនុវត្តការងារថ្ងៃកំពុងសង្កេត ការអនុវត្តអនុសាសន៍ពីខែមុនដោយបញ្ជាក់ពីចំណុចដែលធ្វើបានល្អ ចំណុចដែលធ្វើមិនទាន់បានល្អ ការជួយបំពេញបន្ថែមនូវអ្វីៗដែលគ្រូធ្វើមិនទាន់បាន ដោះស្រាយនូវរាល់សំណូមពររបស់គ្រូ ផ្តល់អនុសាសន៍សម្រាប់គ្រូអនុវត្តខែបន្ទាប់ដោយសរសេរអនុសាសន៍ក្នុងសៀវភៅអនុសាសន៍របស់គ្រូ និងមានសរសេរកំណត់ហេតុប្រជុំដាក់

លាក់ ដើម្បីទុកជាឯកសារភស្តុតាង។

**២.២. ការបំប៉នសមត្ថភាពគ្រូបន្ថែម៖**

ក្រោយពីក្រុមការងារបានចុះពិនិត្យតាមដានការអនុវត្តការងាររបស់គ្រូគ្រប់កន្លែងជារៀងរាល់ខែ ឃើញថាគ្រូនៅមិនទាន់យល់ច្បាស់ ឬខ្សោយលើមុខវិជ្ជាណាមួយ ឬមានសំណូមពរពីតម្រូវការចាំបាច់របស់គ្រូ និងមានវិធីសាស្ត្រថ្មីៗ អង្គការគាំពារកុមារខ្មែរ(CYK) យកចំណុចទាំងនោះមកបើកជាវគ្គបំប៉នសមត្ថភាពគ្រូបន្ថែមរយៈពេល១០ថ្ងៃ រៀងរាល់ឆ្នាំ។ មុននឹងបើកវគ្គបំប៉នក្រុមការងារជំនាញកុមារតូចថ្នាក់មន្ទីរ និងថ្នាក់ស្រុក និងទីប្រឹក្សាគម្រោងអប់រំកុមារតូចរបស់អង្គការគាំពារកុមារខ្មែរ (CYK) បានប្រជុំដើម្បីសម្រេចកំណត់មេរៀនដែលត្រូវយកមកបំប៉នសមត្ថភាពគ្រូបន្ថែម។ ការបំប៉នសមត្ថភាពគ្រូនេះ តែងតែផ្តល់ឱកាសឱ្យគ្រូមត្តេយ្យសិក្សាសហគមន៍ក្រៅគម្រោងបានចូលរួមតាមសំណើរបស់មន្ត្រីជំនាញអប់រំកុមារតូចថ្នាក់ស្រុក។ ម៉្យាងទៀតអង្គការគាំពារកុមារខ្មែរ(CYK)ក៏បានជួយជាសម្ភារៈនិងឯកសារមួយចំនួនដល់គ្រូមត្តេយ្យសិក្សាសហគមន៍ក្នុងគម្រោងដែរ គ្រាន់តែមិនបានជួយឧបត្ថម្ភអាហារប្រចាំថ្ងៃ។ ក្រោយពីបញ្ចប់វគ្គបំប៉នក្រុមការងារតែងតែបានតាមដានការប្រែប្រួលរបស់គ្រូនៅពេលចុះពិនិត្យតាមដានប្រចាំខែម្តងៗ។

**២.៣. កម្មវិធីចុះទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍៖**

ការជួយអភិវឌ្ឍន៍សមត្ថភាពគ្រូមត្តេយ្យសិក្សាសហគមន៍ បន្ថែមមិនមែនធ្វើតែតាមវគ្គបំប៉នសមត្ថភាព តាមការចុះពិនិត្យតាមដាន និងតាមការប្រជុំបច្ចេកទេសនោះទេ អង្គការគាំពារកុមារខ្មែរ(CYK)ក៏បានបង្កើតកម្មវិធីទស្សនៈកិច្ចសិក្សារៀងរាល់ឆ្នាំ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមករវាងគ្រូមត្តេយ្យសិក្សាសហគមន៍ក្នុងគម្រោងជាមួយគ្រូមត្តេយ្យសិក្សាសហគមន៍ក្រៅគម្រោងដែលអនុវត្តការងារបានល្អ ហើយជាប់ស្តង់ដា។ ការចុះទស្សនៈកិច្ចសិក្សាគឺផ្តោតទៅលើអ្វីដែលជាតម្រូវការចាំបាច់របស់គ្រូមត្តេយ្យសិក្សាសហគមន៍ដែលពួកគាត់មិនអាចធ្វើបាន ឬធ្វើមិនបានល្អ ដូចជាការគ្រប់គ្រងកុមារ ការរៀបចំបរិស្ថានក្នុងនិងក្រៅថ្នាក់រៀន ការងារបង្រៀននិងរៀន ការផលិតសម្ភារឧបទេសសម្បូរបែប របៀបទំនាក់ទំនងជាមួយសហគមន៍ មាតាបិតាកុមារ និងអ្នកពាក់ព័ន្ធមួយចំនួនទៀត ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ថ្នាក់មត្តេយ្យសិក្សាសហគមន៍ពីមួយឆ្នាំទៅមួយឆ្នាំ។ រាល់ដំណើរការទស្សនៈកិច្ចសិក្សារៀងរាល់ឆ្នាំ ពីក្រុមការងារតែងតែរៀបចំសរសេរជាឯកសារបទពិសោធន៍ ដោយសរសេរលម្អិតពីដំណើរការអនុវត្តបន្តបន្ទាប់ ទៅតាមសកម្មភាព នីមួយៗ ដើម្បីចែកជូនគ្រូយកទៅអនុវត្ត។ ក្រោយពីបានបញ្ចប់ដំណើរចុះទស្សនៈកិច្ចសិក្សា ក្រុមការងារតែងតែបានតាមដានការប្រែប្រួលរបស់គ្រូនៅពេលចុះពិនិត្យតាមដានប្រចាំខែម្តងៗ និងឱ្យពួកគាត់រាយការណ៍នៅពេលពួកគាត់ទៅចូលរួមវគ្គបំប៉ន។

**២.៤. ការងាររបស់គណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍៖**

នៅពេលដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍ គណៈកម្មការគ្រប់គ្រងគ្រប់កន្លែងកន្លងមកពួកគាត់មិនទាន់យល់ពីការងារមត្តេយ្យសិក្សាសហគមន៍ជាការទទួលខុសត្រូវរបស់ពួកគាត់នោះទេ ពួកគាត់គិតថាជាភារកិច្ចរបស់អ្នកទទួលបន្ទុកការងារអប់រំកុមារតូចថ្នាក់ស្រុកទៅវិញ។ ម៉្យាងទៀតពួកគាត់មិនដែលបានធ្វើផែនការសកម្មភាពសម្រាប់អភិវឌ្ឍថ្នាក់មត្តេយ្យសិក្សាសហគមន៍ប្រចាំឆ្នាំនៅឡើយដែរ គឺធ្វើការងារទៅតាមថវិកាដែលមាន ឬតាមនឹកឃើញ។ ដោយមើលឃើញបញ្ហាទាំងអស់នេះហើយទើបអង្គការគាំពារកុមារខ្មែរ(CYK)បានសហការជាមួយមន្ត្រីជំនាញថ្នាក់មន្ទីរនិងថ្នាក់ស្រុក រៀបចំឱ្យមាន៣សកម្មភាព សម្រាប់ជួយគណៈកម្មការគ្រប់គ្រងមត្តយ្យសិក្សាសហគមន៍ ឱ្យមានសមត្ថភាពពេញលេញ សម្រាប់ជួយថ្នាក់មត្តេយ្យសិក្សា

សហគមន៍ឱ្យមានដំណើរ ការល្អពីមួយឆ្នាំទៅមួយឆ្នាំ។ សកម្មភាពទាំង៣ រួមមាន៖

**២.៤.១. វគ្គបណ្តុះបណ្តាល៖** រៀងរាល់ឆ្នាំ បានបើកវគ្គបណ្តុះបណ្តាលគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ មានរយៈពេល៥ថ្ងៃ ដោយផ្តោតលើតួនាទី និងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ការអនុវត្តការងាររបស់គ្រូមត្តេយ្យសិក្សាសហគមន៍ របៀបវាយតម្លៃគ្រូ មត្តេយ្យសិក្សាសហគមន៍ផ្អែកលើសូចនាករទាំង៣៣ និងធ្វើផែនការសកម្មភាពរបស់ គណៈកម្មការគ្រប់គ្រង មត្តេយ្យសិក្សាសហគមន៍ប្រចាំឆ្នាំ-ខែ សម្រាប់យកទៅអនុវត្តជាក់ស្តែងទៅតាមមូលដ្ឋាន រៀងៗខ្លួន និងសាកល្បងធ្វើផែនការថវិកា មួយឬពីរ សកម្មភាពជាគំរូ។

**២.៤.២. ដំណើរការទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍៖** ផ្តល់ឱកាសឱ្យសមាសភាពគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍មួយកន្លែងចំនួន ៣នាក់ចូលរួមកម្មវិធីទស្សនៈកិច្ចសិក្សា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក ជាមួយគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ក្រៅគម្រោង ដែលមានដំណើរការបានល្អ ដែលមិនមានអង្គការដៃគូណាជួយ។ ការចុះទស្សនៈកិច្ចសិក្សានេះផ្តោតសំខាន់លើវិធីសាស្រ្តនៃការកៀរគរកថវិកា ដើម្បីអភិវឌ្ឍថ្នាក់មត្តេយ្យសិក្សាសហគមន៍ វិធីសាស្រ្តក្នុងការជំរុញឱ្យមាតាបិតាកុមារនិងសហគមន៍ ចូលរួមគាំទ្រថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងការងារមួយចំនួនទៀត ដែលធ្វើឱ្យមត្តេយ្យសិក្សាសហគមន៍រីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ។

២.៤.៣. ការប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ៖ បានរៀបចំឱ្យមានការប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តការងាររយៈពេលមួយឆ្នាំ ដោយផ្តល់ឱកាសឱ្យសមាសភាពគណៈកម្មការមួយកន្លែងចំនួន ៣នាក់បានចូលរួមប្រជុំរយៈពេល៣ថ្ងៃ។ ការប្រជុំនេះផ្តោតលើការអនុវត្តការងាររយៈពេលមួយឆ្នាំ ដោយផ្អែកលើផែនការ សកម្មភាពដែលបានគ្រោងទុកប្រចាំឆ្នាំ និងលើកឡើងពីសកម្មភាពដែលបានធ្វើ សកម្មភាពដែលមិនទាន់បានធ្វើ រួចបញ្ជាក់ពីមូលហេតុដែលមិនបានធ្វើ រួមគ្នាដោះស្រាយការលំបាកណាដែលកន្លែងនីមួយៗមិនអាចដោះស្រាយបាន និងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំថ្មីបន្តទៀត ដោយផ្អែកលើសកម្មភាពការងារដែលនៅសេសសល់ពីឆ្នាំចាស់ ផ្អែកលើបទពិសោធន៍ទទួលបានពីទស្សនៈកិច្ចសិក្សា និងបន្ថែមសកម្មភាពថ្មីៗមួយចំនួនទៀត។

**២.៥. កម្មវិធីពិសេសសម្រាប់កុមារ និងសកម្មភាពផ្សេងៗក្រៅពីការងារដែលបានរៀបរាប់ខាងលើអង្គការគាំពារកុមារខ្មែរ(CYK)បានអនុវត្តសកម្មភាពផ្សេងៗមួយចំនួនរួមមាន៖**

២.៥.១. ទិវាកុមារអន្តរជាតិ១មិថុនា៖ រៀងរាល់ឆ្នាំអង្គការគាំពារកុមារខ្មែរ(CYK)បានផ្តល់កញ្ចប់ថវិកាដល់ថ្នាក់មត្តេយ្យសិក្សាសហគមន៍ទាំងអស់ក្នុងគម្រោងដើម្បីរៀបចំពិធីអបអរសាទរទិវាកុមារអន្តរជាតិ១មិថុនា ដើម្បី បង្កើនការយកចិត្តទុកដាក់អនុវត្តសិទ្ធកុមារជាមូលដ្ឋានដោយបង្កលក្ខណៈឱ្យកុមារបានសប្បាយរីករាយអបអរទទួលស្គាល់សិទ្ធពួកគេជាសកល និងចូលរួមគោរពនិងគាំពារសិទ្ធជាអនុសញ្ញាជាតិនិងអន្តរជាតិជាសកលស្តីពីសិទ្ធកុមារ ដោយលប់បំបាត់ចោលនិងមិនរើសអើងចំពោះកុមារពិការ ក្រីក្រ ជនជាតិដើមភាគតិចព្រមទាំងបញ្ឈប់និងប្រឆាំងដាច់ខាតលើការរំលោភបំពាន ការជួញដូរ ការគេងប្រវ័ញ្ច និងការប្រើអំពើហិង្សាលើកុមារគ្រប់រូបភាព។ ដោយមានការសម្របសម្រួលពីក្រុមការងារអប់រំកុមារតូចរបស់អង្គការគាំពារកុមារខ្មែរ(CYK) មន្រ្តីជំនាញអប់រំកុមារតូចថ្នាក់មន្ទីរនិងថ្នាក់ស្រុក មាតាបិតានិងអាណាព្យាបាលកុមារ សមាជិកគណៈកម្មការគ្រប់គ្រង

មត្តេយ្យ គ្រូ និងកុមារ បានចូលរួម ស្តាប់យ៉ាងយកចិត្តទុកដាក់ពីប្រវត្តិនៃទិវាកុមារអន្តរជាតិ និងចូល

រួមលេងល្បែងកំសាន្តនានា ដូចជា ទាញព្រ័ត លោតបាវ ហុចបាល់បន្តគ្នា ជិះសេះប្រណាំងគ្នា មនុស្ស២នាក់ជើង៣ បំបែកប៉េងប៉ោង ដើរលើត្រឡោក ជាដើមនិងហូបអាហារសាមគ្គីយ៉ាងសប្បាយរីករាយ។

២.៥.២.ពីធីបញ្ជូនកុមារគ្រប់អាយុ៦ឆ្នាំទៅបឋមសិក្សា៖ពេលកុមារដែលរៀននៅមត្តេយ្យសិក្សាសហគមន៍ គ្រប់អាយុ៦ឆ្នាំ ពួកគាត់ត្រូវបានបញ្ជូនទៅរៀននៅថ្នាក់ទី១នៃសាលាបឋមសិក្សា អង្គការគាំពារកុមារខ្មែរ(CYK)បានចេញវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាឱ្យពួកគាត់រៀងរាល់ឆ្នាំ ហើយបានរៀបចំធ្វើពិធីដើម្បីប្រគល់វិញ្ញាបនប័ត្រ ជាការលើកទឹកចិត្តដល់ពួកគាត់ និងមាតាបិតាកុមារ។ ពិធីនេះមានការចូលរួមពីក្រុមការងារគម្រោងអប់រំកុមារតូចរបស់អង្គការ ថ្នាក់ដឹកនាំមន្ទីរអ.យ.កខេត្ត មន្ត្រីជំនាញអប់រំកុមារតូចថ្នាក់ស្រុក គណៈកម្មការគ្រប់គ្រង មាតាបិតាកុមារ គ្រូ និងកុមារ។

២.៥.៣. ការចែកជូនសម្ភារៈល្បែង៖ អង្គការគាំពារកុមារខ្មែរក៏បានផ្តល់បាល់និងតុក្កតាក្រណាត់ និងសម្ភារឧបទេស/ល្បែងសិក្សា ដូចជា ក្តារផ្គុំរូបឡាន ក្តាររៀបអក្សរក-ខ ផ្ទាំងអក្សរក-ខភ្ជាប់រូបភាព កាតក-ខភ្ជាប់រូបភាព ល្បែងចាប់គូបន្លែ ផ្លែឈើ និងសត្វ ផ្ទាំងព្យញ្ជនៈទាំង៣៣តួ ផ្ទាំងជើងព្យញ្ជនៈទាំង៣៣តួ សៀវភៅមិត្តវិទ្យាសាស្ត្ររូបភាព សៀវភៅរឿង សៀវភៅចម្រៀង និងសៀវភៅកំណាព្យ ជាដើម ជូនកុមារមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍របស់អង្គការមួយចំនួនដែលធ្វើការងារទាក់ទងការថែទាំ អប់រំ និងអភិវឌ្ឍន៍កុមារតូច នៅទូទាំងប្រទេសកម្ពុជា។

## ៣. ក្រោយពេលដំណើរការថ្នាក់៖

ក្រោយពីការគាំទ្ររយៈពេល៣ឆ្នាំ អង្គការគាំពារកុមារខ្មែរ (CYK) បានធ្វើពិធីផ្ទេរការទទួលខុសត្រូវលើដំណើរការនិងការគ្រប់គ្រងថ្នាក់មត្តេយ្យសិក្សាសហគមន៍ជូនទៅគណៈកម្មការគ្រប់គ្រង និងក្រុមប្រឹក្សាឃុំ និងបានប្រគល់ប្រាក់វិភាគទានដែលបានសន្សំទុករយៈពេល៣ឆ្នាំ ជូនតំណាងគណៈកម្មការគ្រប់គ្រងសម្រាប់ប្រើប្រាស់ ដើម្បីបន្តនិរន្តរភាពនិងអភិវឌ្ឍន៍ថ្នាក់មត្តេយ្យនោះ ដោយមានឯកសារបញ្ជាក់ត្រឹមត្រូវ។ ពិធីនេះមានការចូលរួមពីក្រុមការងារគម្រោងអប់រំកុមារតូចរបស់អង្គការ ថ្នាក់ដឹកនាំមន្ទីរអ.យ.កខេត្ត មន្ត្រីជំនាញអប់រំកុមារតូចថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ គណៈកម្មការគ្រប់គ្រង មាតាបិតាកុមារ និងកុមារ មត្តេយ្យសិក្សាសហគមន៍។

ក្រោយពីបានផ្ទេរការទទួលខុសត្រូវលើដំណើរការនិងការគ្រប់គ្រងថ្នាក់មត្តេយ្យសិក្សាសហគមន៍ ជូនគណៈកម្មការគ្រប់គ្រងនិងក្រុមប្រឹក្សាឃុំ ក្រុមការងារគម្រោងអប់រំកុមារតូចរបស់អង្គការគាំពារកុមារខ្មែរ(CYK) បានចុះពិនិត្យតាមដានចំនួន៤លើកនៅឆ្នាំបន្ទាប់នៅតាមទីតាំងនីមួយៗ ដើម្បីវាយតម្លៃលើដំណើរការនិងការគ្រប់គ្រងបន្តរបស់ថ្នាក់មត្តេយ្យសិក្សាសហគមន៍ទាំងនោះ ជួយគ្រូបន្ថែមលើការងារបច្ចេកទេសនិងការងាររដ្ឋបាល និងផ្តល់ជា សម្ភារៈបម្រើឱ្យការងារបង្រៀននិងរៀនទៅតាមលទ្ធភាព។

### បញ្ហាប្រឈម

១. គ្រូមានសមត្ថភាពមិនស្មើគ្នា ដូច្នេះការទទួលយកចំណេះដឹងបន្ថែមតាមរយៈ ការផ្តល់អនុសាសន៍ នៅពេលចុះពិនិត្យតាមដាន ក៏ពួកគាត់អភិវឌ្ឍសមត្ថភាពជំនាញ (ការបង្រៀន ការគ្រប់គ្រងកុមារការរៀបចំបរិស្ថានក្នុងនិងក្រៅថ្នាក់ និងការងារទំនាក់ទំនងជាមួយគ្រប់អ្នកពាក់ព័ន្ធ)មិនបានដូចគ្នាដែរ។

២. មេរៀនមួយចំនួនមិនមានសរសេរខ្លឹមសារនៅក្នុងសៀវភៅគ្រូ ជាពិសេសមេរៀនក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ ដូច្នេះការបង្រៀនមិនទាន់បានសម្រេចលទ្ធផល ទៅតាមស្តង់ដានៃកំរិតអាយុរបស់កុមារ។

៣.ល្បែងលេងក្រៅថ្នាក់នៅមានចំនួនតិច មិនទាន់សមស្របតាមចំនួនកុមារ ហើយគណៈកម្មការគ្រប់គ្រងខ្វះការច្នៃប្រឌិតសម្ភារៈល្បែងក្រៅថ្នាក់បន្ថែមដែលអាចរកបាននៅមូលដ្ឋានសម្រាប់កុមារលេង ដោយពឹងផ្អែកតែលើ សម្ភារល្បែងក្រៅថ្នាក់ដែលអង្គការផ្តល់ជូនប៉ុណ្ណោះ។

៤. គណៈកម្មការគ្រប់គ្រងថ្នាក់មត្តេយ្យសិក្សាសហគមន៍មួយចំនួន អនុវត្តការងារមិនបានសម្រេចតាមលទ្ធផលដែលបានគ្រោងទុកក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ដោយសារទេពកោសល្យ ក្នុងការកៀរគរថវិកាសម្រាប់អភិវឌ្ឍថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងជីវភាពរបស់សហគមន៍នៅមានកំរិត។

៥. មាតាបិតាមួយចំនួនមិនយល់អំពីច្បាស់អំពីសារៈសំខាន់នៃការអប់រំកុមារតូច និងមិនសូវយកចិត្តទុកដាក់ក្នុងការចូលរួមប្រជុំនិងគាំទ្រដល់មត្តេយ្យសិក្សាសហគមន៍។

VI. **បូកសរុប**

ចាប់ពីឆ្នាំ២០១១ រហូតដល់ឆ្នាំ២០២៣ អង្គការគាំពារកុមារខ្មែរ(CYK)បានគាំទ្រលើការបើកដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍សរុបចំនួន៣២កន្លែង(៣៤ថ្នាក់) ក្នុងខេត្តកណ្តាល ខេត្តតាកែវ និងខេត្តកំពង់ឆ្នាំង។ ហើយមត្តេយ្យសិក្សាសហគមន៍ទាំងនោះនៅតែដំណើរការបានល្អប្រសើរ ដោយមានការគាំទ្រពីក្រុមប្រឹក្សាឃុំ គណៈកម្មការគ្រប់គ្រង និងមាតាបិតា ក្រោយពីអង្គការបានផ្ទេរការទទួលខុសត្រូវលើដំណើរការ និងការគ្រប់គ្រង ជូនក្រុមប្រឹក្សាឃុំ និងគណៈកម្មការគ្រប់គ្រងទាំងអស់ ត្រឹមចុងខែមីនា ឆ្នាំ២០២៤។ លើកលែងតែមត្តេយ្យ១កន្លែងក្នុងភូមិឈើទាល ស្រុកអង្គស្នួល ខេត្តកណ្តាលដែលត្រូវបានបិទដោយសារអ្នកគ្រូទទួលមរណៈភាពដោយជម្ងឺ ហើយមិនអាចរកគ្រូថ្មីមកជំនួសបាន។ ក្នុងចំណោមមត្តេយ្យសិក្សាសហគមន៍ទាំង៣២កន្លែង(៣៤ថ្នាក់) មានមត្តេយ្យសិក្សាសហគមន៍សរុបចំនួន២៣កន្លែង(២៥ថ្នាក់)ត្រូវបានវាយម្លៃក្លាយជាមត្តេយ្យសិក្សាសហគមន៍ស្តង់ដាត្រឹមឆ្នាំ២០២៤។

ដំណើរការសកម្មភាពដែលបានសរសេរខាងលើនេះបានបង្ហាញអំពីការគាំទ្រ និងដំណើរការនៃការបើកដំណើរការនិងការគ្រប់គ្រងថ្នាក់មត្តេយ្យសិក្សាសហគមន៍របស់អង្គការគាំពារកុមារខ្មែរ (CYK) នៅប្រទេសកម្ពុជា ចាប់តាំង ពីពេលចាប់ផ្តើមគម្រោងរហូតដល់បញ្ចប់គម្រោង។ ឯកសារនេះអាចជាឯកសារយោងសម្រាប់អ្នកដែលមា លទ្ធភាពចង់បង្កើតមត្តេយ្យសិក្សាសហគមន៍ ហើយចង់ដំណើរការឱ្យបានល្អប្រសើរ និងជោគជ័យ។

ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៤



អ៊ុម សុផានី

ទីប្រឹក្សាគម្រោងអប់រំកុមារតូច

របស់អង្គការគាំពារកុមារខ្មែរ(CYK)